សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

ស្ថាប័ន
នយោបាយ
នៃ
ព្រះរាជាណាចក្រ
កម្ពុជា

Political Institutions of Kingdom of Cambodia

ដុំ អ៊ុម

បោះពុម្ពលើកទី១ ឆ្នាំ២០២១

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

ប្រវត្តិសង្ខេប

- **ដុំ អ៊ីម** (Dom Im) កើតនៅថ្ងៃទី០៧ ខែមីនា ឆ្នាំ១៩៧០ នៅភូមិបឹងក្រចាប់ ឃុំព្រែកតាមាក់ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល
- ឪពុកឈ្មោះ **ឈឹម ដុំ** (ស្លាប់)
- ម្តាយឈ្មោះ **សួន ផាង** សព្វថ្ងៃ នៅភូមិបឹងក្រចាប់ ឃុំព្រែកតាមាក់ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល។

ទូរស័ព្ទ: ០១១ ៦៦៨ ៦៧៨ / ០៦៩ ៦៦៨ ៦៧៨ / ០៨៨៨ ៦៧៧ ៦៨៨

E-mail: dom_im@yahoo.com

ស្ថាប័នរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

Political Institutions of Kingdom of Cambodia

ដុំ អ៊ីម

២០២១

បុព្វកថា

ដំណើរអភិវឌ្ឍនៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងយុគសម័យទំនើបនេះ ជាមេរៀនដ៏ជោគជ័យបំផុតមួយដែលចាប់ឫសគល់ចេញពីការបញ្ចប់របបប្រល័យពូជសាសន៍ ការបញ្ចប់សង្គ្រាម ការផ្សះផ្សារជាតិ ការកសាងមូលដ្ឋានរឹងមាំនៃសន្តិភាពនិងស្ថេរភាព និងការអភិវឌ្ឍសេដ្ឋកិច្ច។ នៅក្រោយពេលដែលសន្តិភាពត្រូវបានកើតឡើងដោយបរិបូរណ៍នៅឆ្នាំ១៩៩៨ កម្ពុជាទទួលកំណើនសេដ្ឋកិច្ចខ្ពស់ គឺប្រមាណ ៨% ក្នុងមួយឆ្នាំ។ លើសពីនេះទៀត អត្រានៃភាពក្រីក្រត្រូវបានកាត់បន្ថយពីប្រមាណ៥៣% នៅឆ្នាំ ២០០៤មកនៅទាបជាង១០%នៅឆ្នាំ២០១៩។ ដំណើរនៃការអភិវឌ្ឍជាតិជាសកម្មភាពដែលបន្តទៅមុខជាប់ជានិច្ច ហើយគោលនយោបាយថ្មីៗ ដែលមានលក្ខណៈអន្តរវិស័យគ្របដណ្តប់ ក៏កំពុងលេចរូបរាងឡើង ដើម្បីតម្រង់ទិសកម្ពុជាឆ្ពោះទៅកាន់ប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងឈានឡើងជាប្រទេសមានប្រាក់ចំណូលខ្ពស់ នៅឆ្នាំ២០៥០។ ការប្រែប្រួលឆាប់រហ័សនៃនិម្មាបនកម្មពិភពលោក និងតំបន់ រួមទាំងទំនាក់ទំនងភូមិសាស្ត្រនយោបាយ បានផ្តល់កាលានុវត្តភាពសម្រាប់ការអភិវឌ្ឍឧស្សាហកម្មនៅកម្ពុជា ដែលត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាមូលដ្ឋានគ្រឹះនៃកំណើនសេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងបន្តពង្រឹង និងអភិវឌ្ឍវិស័យអប់រំឆ្ពោះទៅរកការស្រាវជ្រាវ និងនវានុវត្តន៍ ដើម្បីពង្រឹងសមត្ថភាពនិងជំនាញរបស់ធនធានមនុស្សនៅកម្ពុជា ឱ្យស្របទៅនឹងបរិបទថ្មីនៃការអភិវឌ្ឍ ជាពិសេសការពង្រឹងសហគ្រិនភាពក្នុងការរៀបចំម៉ូដែលធុរកិច្ចថ្មីៗ។ ដើម្បីចាប់យកកាលានុវត្តភាពពីបដិវត្តន៍ឧស្សាហកម្មទី៤ និងសេដ្ឋកិច្ចឌីជីថល ដែលកំពុងផុសផុលឡើង ប្រព័ន្ធអេកូឡូហ្ស៊ីដែលបង្កលក្ខណៈអំណោយផលដល់ការបង្កើតថ្មី នវានុវត្តន៍ ការស្រាវជ្រាវ និងអភិវឌ្ឍន៍ត្រូវតែមានការកែលម្អ។

បណ្តាប្រទេសនៅទ្វីបអាស៊ី កំពុងនាំមុខក្នុងការវិនិយោគលើការស្រាវជ្រាវ និងអភិវឌ្ឍ ដោយមានភាគហ៊ុនប្រមាណ៤៤% នៃការវិនិយោគទាំងមូលរបស់ពិភពលោក។ ប្រទេសចិនកំពុងបន្តកសាងហេដ្ឋារចនាសម្ព័ន្ធនៃការវិនិយោគលើការស្រាវជ្រាវ និងអភិវឌ្ឍ ក៏ដូចជាសមត្ថភាពមនុស្ស។ ផ្ទុយទៅវិញ ប្រទេសនៅទ្វីបអាមេរិកខាងត្បូង និងអាហ្វ្រិក កំពុងស្ថិតនៅឆ្ងាយពីការវិនិយោគនេះ ហើយជាលទ្ធផលប្រទេសទាំងនោះក៏ពុំមានកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ដែរ។ ទុនវិនិយោគសរុបលើការស្រាវ ជ្រាវ និងអភិវឌ្ឍរបស់ប្រទេសនៅទ្វីបអាមេរិកខាងត្បូងនិងអាហ្វ្រិក មានប្រមាណ៥%នៃការវិនិយោគទាំងមូលរបស់ពិភពលោក ក្នុងពេលដែលតំបន់ទាំង២នេះ មានប្រជាជនប្រមាណ២០%នៃប្រជាជនពិភពលោក។ ប្រទេសចំនួន៦ដែលមានលំដាប់ខ្ពស់ជាងគេ នៅក្នុងការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ រួមមានសហរដ្ឋអាមេរិក ចិន ជប៉ុន អាល្លឺម៉ង់ ឥណ្ឌា និងកូរ៉េខាងត្បូង ដែលស្មើនឹងប្រមាណ ៧០%នៃទុនវិនិយោគសរុបរបស់ពិភពលោក។

តើចំណេះដឹង ផលិតផល និងសេវាកម្មថ្មីទាំងនេះកើតឡើងមកពីអ្វី? ហើយកើតឡើងដោយរបៀបណា? ព្រះរាជាណាចក្រកម្ពុជាកំពុងតែកសាងមូលដ្ឋានសម្រាប់ការត្រៀមខ្លួនទទួល និងប្រកួត

ប្រជែងក្នុងយុគសម័យបដិវត្តឧស្សាហកម្មទី៤ នៅក្នុងសេដ្ឋកិច្ចដែលផ្អែកលើពុទ្ធិ ហើយដែលប្រការនេះ ចាំបាច់តម្រូវឱ្យពលរដ្ឋកម្ពុជា ត្រូវក្លាយខ្លួនជាពលរដ្ឋឌីជីថល ពលរដ្ឋសកល និងពលរដ្ឋដែលប្រកបដោយការទទួលខុសត្រូវ ដែលមានសមត្ថភាពក្នុងការផលិត ចែកចាយ និងប្រើប្រាស់ពុទ្ធិដើម្បីទទួលមនុញ្ញផល និងរួមចំណែកក្នុងកំណើន។ ធនាគារពិភពលោកបានធ្វើការកត់សម្គាល់តាំងពីឆ្នាំ២០០២ នូវបម្លាស់ប្តូរនៃមូលដ្ឋានសេដ្ឋកិច្ច ពីសេដ្ឋកិច្ចដែលពឹងផ្អែកលើកម្លាំងពលកម្ម និងធនធានអតិកម្ម (Labor and Resource Based Economy) ទៅកាន់សេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិ (Knowledge Based-Economy) ដែលក្នុងន័យនេះ ពុទ្ធិគឺជាគន្លឹះនៃការអភិវឌ្ឍ។ អាស្រ័យហេតុនេះ នៅលើគន្លងដែលកម្ពុជាកំពុងធ្វើដំណើរឆ្ពោះទៅកាន់សេដ្ឋកិច្ចឌីជីថល សង្គមកម្ពុជាត្រូវតែមានសមត្ថភាពក្នុងការផលិត ជ្រើសរើស បន្សាំ បង្កើតមុខរបរ និងប្រើប្រាស់ពុទ្ធិ ដើម្បីរក្សានិរន្តរភាពនៃកំណើន និងកែលម្អជីវភាពរស់នៅ។ សមត្ថភាពទាំងនេះ អាចកើតឡើងនៅពេលពលរដ្ឋកម្ពុជាមានឱកាសក្នុងការទទួលបានបទពិសោធន៍ពីការស្រាវជ្រាវ ការបណ្តុះគំនិតច្នៃប្រឌិត និងការស្វែងរកនវានុវត្តន៍។

កំណែទម្រង់វិស័យអប់រំ គឺជាការត្រួសត្រាយមាគ៌ាសម្រាប់ដំណើរឆ្ពោះទៅកាន់សង្គមប្រកបដោយពុទ្ធិ និងប្រជាពលរដ្ឋប្រកបដោយភាពរស់រវើក។ តាមរយៈមូលដ្ឋានអប់រំ សង្គមប្រកបដោយពុទ្ធិនឹងប្រមូលផ្តុំ បង្កើត និងចែករំលែក ទៅកាន់សមាជិកក្នុងសង្គមនូវសម្បទាអប់រំ ពិសេសគឺពុទ្ធិសម្បទាក្នុងបុព្វហេតុនៃមនុស្សជាតិ និងឧត្តមប្រយោជន៍នៃប្រទេស។ សង្គមប្រកបដោយពុទ្ធិ គឺពុំគ្រាន់តែជាសង្គមដែលសម្បូរព័ត៌មានប៉ុណ្ណោះទេ តែជាសង្គមដែលប្រជាពលរដ្ឋអាចធ្វើបរិវត្តកម្មពីព័ត៌មានទៅជាមូលធនប្រកបដោយប្រសិទ្ធភាព។ ការរីកចម្រើនទៅមុខជាលំដាប់នៃបច្ចេកវិទ្យា និងតំណភ្ជាប់ បានពង្រីកព្រំដែននៃការចូលទៅកាន់ និងការទទួលបានព័ត៌មានជាសកល ហើយដែលក្នុងន័យនេះ ការអប់រំនឹងបន្តវិវត្តទៅមុខ និងមានការផ្លាស់ប្តូរ។ សង្គមមួយដែលមានអំណាន និងរបាប់ជាបុរេលក្ខខណ្ឌនៃជីវភាពប្រចាំថ្ងៃនៃប្រជាពលរដ្ឋ ពេលនោះបំណិននៃអំណាន និពន្ធ និងការគណនាលេខនព្វន្ត គឺជាចលករនៃការរៀនរបស់សិស្ស។ ធាតុដ៏ចម្បងមួយដែលស្ថិតនៅក្នុងការកសាងសង្គមដែលប្រកបដោយពុទ្ធិ គឺសៀវភៅសិក្សា ហើយការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សាជាប្រចាំ គឺជានវានុវត្តន៍នៃវិស័យអប់រំដែលនាំទៅរកការសិក្សាពេញមួយជីវិត ការអភិវឌ្ឍសម្បទាអប់រំ និងការចែករំលែកចំណេះដឹង។ មូលដ្ឋានអប់រំ ជាពិសេសគឺគ្រឹះស្ថានឧត្តមសិក្សាត្រូវមានតួនាទីដែលប្រកបដោយការឆ្លើយតបចំពោះតម្រូវការខាងលើនេះ។ សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំត្រូវបន្តសិក្សាជាប់ជានិច្ចតាមរយៈការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ហើយដែលសៀវភៅសិក្សាទាំងនេះនឹងក្លាយជាស្ពាននៃទំនាក់ទំនងរវាងនវានុវត្តន៍នៃបច្ចេកវិទ្យា និងការរៀននិងបង្រៀននៅក្នុងថ្នាក់រៀន។

សង្គមដែលប្រកបពុទ្ធិ ក៏ជាសង្គមដែលបណ្តុះឱ្យមានរចនាសម្ព័ន្ធទន់នៃសេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិដែរ។ ឧទាហរណ៍ជាក់ស្តែងនៃបែបផែននេះរួមមាន Silicon Valley នៃសហរដ្ឋអាមេរិក សួនឧស្សាហកម្មវិស្វកម្មអាកាសយានយន្ត និងយានយន្តនៅទីក្រុង Munich ប្រទេសអាល្លឺម៉ង់ តំបន់ជីវបច្ចេកវិទ្យានៅក្រុង Hyderabad ប្រទេសឥណ្ឌា តំបន់ផលិតគ្រឿងអេឡិចត្រូនិកនិងសារគមនាគមន៍

ឌីជីថលនៅទីក្រុង Seoul ប្រទេសកូរេខាងត្បូង ក៏ដូចជាសួនឧស្សាហកម្មថាមពល និងឥន្ធនគីមីសាស្ត្រ នៃប្រទេសប្រេស៊ីល ហើយក៏នៅមានទីក្រុងនៃប្រទេសជាច្រើនទៀតនៅលើពិភពលោក។ លក្ខណៈសម្បត្តិនៃទីក្រុងទាំងនេះគឺការប្រើប្រាស់និន្នាការនៃការអភិវឌ្ឍដែលជំរុញ និងតម្រង់ទិសដោយចំណេះដឹង ហើយដែលចំណេះដឹងទាំងនោះ កើតចេញជាដំបូងពីការវិនិយោគទៅលើគ្រឹះស្ថានឧត្តមសិក្សា ស្ថាប័នស្រាវជ្រាវ មជ្ឈមណ្ឌលឧត្តមភាពនៃជំនាញជាន់ខ្ពស់ ការប្រកួតប្រជែងដោយគុណាធិបតេយ្យ និង ជាពិសេសគឺការបណ្តុះវប្បធម៌អំណាន និងនិពន្ធសៀវភៅ។ ល្បឿននៃការរីកចម្រើនផ្នែកពុទ្ធិ និងបច្ចេកវិទ្យាកំពុងមានសន្ទុះលឿនជាងអ្វីដែលសិស្ស និងនិស្សិតអាចទទួលបានពីគ្រូនៅគ្រឹះស្ថានសិក្សា ដែលធ្វើឱ្យគោលដៅនៃការអប់រំនៅពេលបច្ចុប្បន្ននេះ មានការប្រឈមខ្លាំងជាងពេលណាទាំងអស់។ ឧទាហរណ៍ ក្នុងមួយឆ្នាំ មានសៀវភៅជាង២,២លានចំណងជើង ត្រូវបានសរសេរនិងបោះពុម្ពដែលក្នុងនោះប្រទេសចិនមាន៤៤០ពាន់ ចំណែកឯសហរដ្ឋអាមេរិកមាន ៣០៥ពាន់ និងប្រទេសរុស្ស៊ីមាន ១២០ពាន់ចំណងជើង។

ខណៈពេលដែលបច្ចេកវិទ្យាកំពុងរីកចម្រើនជារៀងរាល់ថ្ងៃ មធ្យោបាយសម្រាប់អំណានក៏មានច្រើន ជម្រើសសម្រាប់សិស្ស-និស្សិត និងសាធារណៈជន រួមមានការអានសៀវភៅ ការអានលើឧបករណ៍អេឡិចត្រូនិក ការអានដោយប្រើទូរសព្ទវៃឆ្លាត និងការអានលើកុំព្យូទ័រ ដែលសុទ្ធសឹងជាមធ្យោបាយសំខាន់ៗដែលនាំអ្នកអានទាំងឡាយឱ្យសម្រេចគោលបំណងអានរបស់ខ្លួន។ ម្យ៉ាងវិញទៀត អំណានដោយប្រើមធ្យោបាយបច្ចេកវិទ្យាទំនើប ចំណាយពេលតិច ងាយស្រួលអាន និងជួយដល់បរិស្ថានមួយកម្រិតទៀត។ នាពេលបច្ចុប្បន្ន សិស្ស-និស្សិត និងសាធារណៈជនកម្ពុជាដែលស្រឡាញ់អំណានកំពុងតែប្រើប្រាស់មធ្យោបាយអំណានទាំងនេះ។ បើយើងក្រឡេកមើលទៅប្រទេសជឿនលឿន ទោះបីជាបច្ចេកវិទ្យារីកចម្រើនខ្លាំងយ៉ាងណា អំណានតាមរយៈសៀវភៅនៅតែមានសន្ទុះដដែល។ ម្យ៉ាងវិញទៀត បច្ចេកវិទ្យាអានបែបទំនើបតាមរយៈឧបករណ៍ទំនើប អាស្រ័យលើលទ្ធភាពនៃធនធានអប់រំឌីជីថល និងមាតិកាឌីជីថលគ្រប់គ្រាន់ដែលបានផលិត និងបង្ហោះចែកចាយសម្រាប់អំណាន។

ក្នុងបរិបទកម្ពុជា ជាពិសេសក្នុងបរិការណ៍នៃការផ្ទុះរីករាលដាលនៃជំងឺកូវីដ-១៩ ក្រសួងអប់រំ យុវជន និងកីឡា បានជំរុញឱ្យមានបរិវត្តកម្មឌីជីថលនៅក្នុងអេកូស៊ីស្តែមនៃការអប់រំ ជាពិសេសការអប់រំតាមប្រព័ន្ធអេឡិចត្រូនិក និងការអប់រំពីចម្ងាយដើម្បីលើកកម្ពស់អំណាន តាមរយៈការផលិតមាតិកាឌីជីថលដែលមានភាពចំរុះ ការកសាងសមត្ថភាពផ្នែកតំណភ្ជាប់និងវេទិកាឌីជីថល ការពង្រីកវិសាលភាពនៃមជ្ឈមណ្ឌលទិន្នន័យ និងការលើកកម្ពស់គុណភាពនៃការផលិតធនធានអប់រំឌីជីថល គួបផ្សំជាមួយការចែកសន្លឹកកិច្ចការឱ្យសិស្សយកទៅរៀននៅផ្ទះ និងការចុះទៅជួបជាមួយសិស្សជាបណ្តុំនៅតាមសហគមន៍។ ក្នុងន័យលើកកម្ពស់អំណាន និងភាពសម្បូរបែបនៃធនធានសៀវភៅសិក្សា ឱ្យកាន់តែមានប្រសិទ្ធភាពនិងភាពសក្តិសិទ្ធិ និងផ្តល់ឱកាសអំណានកាន់តែច្រើនថែមទៀតដល់សិស្សានុសិស្ស និស្សិត និងសាធារណៈជន ក្រសួងអប់រំ យុវជន និងកីឡាលើកទឹកចិត្តនូវចំណុចមួយចំនួនដូចខាងក្រោម៖

1. សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំ សូមបន្តនិងបង្កើនការបោះពុម្ពស្នាដៃបន្ថែមទៀត ដើម្បីធ្វើឱ្យធនធានសម្រាប់អំណានកាន់តែសម្បូរបែប ជាពិសេសធនធានអំណានជាខេមរភាសា
2. គ្រឹះស្ថានឧត្តមសិក្សា សូមផ្តល់លទ្ធភាពគ្រប់បែបយ៉ាង ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ និង និស្សិតគ្រប់កម្រិតសិក្សាអាចចូលរួមអាន និងសិក្សាស្រាវជ្រាវតាមគ្រប់លទ្ធភាពជាមួយធនធានអំណាន ជាពិសេសការរៀបចំឱ្យមានពេលវេលាសម្រាប់សហសិក្សា និងអំណានក្នុងបណ្ណាល័យ
3. សាស្ត្រាចារ្យតាមមុខវិជ្ជា និងអ្នកស្រាវជ្រាវតាមជំនាញឬវិស័យ ត្រូវរៀបចំដំណើរការរៀនបង្រៀន និងស្រាវជ្រាវដែលមានដាក់បញ្ចូលកិច្ចការស្វ័យសិក្សា សហសិក្សា ឬការស្រាវជ្រាវបណ្ណាល័យដែលតម្រូវឱ្យនិស្សិត ត្រូវអាននិងស្រាវជ្រាវជាមួយធនធានអំណាន
4. គ្រឹះស្ថានឧត្តមសិក្សា និងមជ្ឈមណ្ឌលស្រាវជ្រាវ ត្រូវខិតខំឱ្យអស់លទ្ធភាពក្នុងការបង្កើតបណ្ណាល័យ មជ្ឈមណ្ឌលរក្សាឯកសារ ឬមជ្ឈមណ្ឌលអប់រំឌីជីថលជាដើម ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ និងនិស្សិតគ្រប់កម្រិតសិក្សា អាចទទួលបាន និងស្វែងរកប្រភពសម្រាប់អំណាន កាន់តែសម្បូរបែប និងមានភាពបត់បែន ឆ្លើយតបតាមតម្រូវការអ្នកអាន
5. និស្សិតគ្រប់កម្រិតសិក្សា ត្រូវខិតខំនិងចំណាយពេលអាន និងចាត់ទុកវប្បធម៌ និងអកប្បកិរិយាអំណានជាផ្នែកមួយ នៃពេលវេលានិងភាពស៊ីវិល័យនៃជីវិតប្រចាំថ្ងៃ
6. បងប្អូនជនរួមជាតិ ដែលជាមាតាបិតា ឬអ្នកអាណាព្យាបាល សូមជួយជំរុញនិងបង្កលក្ខណៈកាន់តែ ច្រើនថែមទៀត ជាពិសេសការលែលកចំណាយនៅក្នុងគ្រួសារសម្រាប់ការទិញសម្ភារៈសិក្សា សៀវភៅអាន និងឧបករណ៍សម្រាប់អំណានដល់កូនៗ ដែលចាត់ទុកជាការវិនិយោគមួយដ៏សំខាន់ សម្រាប់ បង្កើនចំណេះដឹង និងអនាគតរបស់ពួកគេ។

ដោយមានការគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅឆ្នាំ២០២០ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ដែលហៅកាត់ថា “មូលនិធិ ស.គ.ន” និងហៅជាភាសាអង់គ្លេសថា The Research Creativity and Innovation Fund ដែលហៅកាត់ជាភាសាអង់គ្លេសថា “RCI Fund”។ គោលដៅចម្បងនៃមូលនិធិនេះ គឺរួមចំណែកលើកកម្ពស់វប្បធម៌នៃការស្រាវជ្រាវ បំផុសគំនិតច្នៃប្រឌិត និងជំរុញការធ្វើនវានុវត្ត ដើម្បីជាប្រយោជន៍ដល់វិស័យអប់រំ យុវជន និងកីឡា ដែលឆ្លើយតបទៅនឹងទីផ្សារពលកម្ម និងសាកលភាវូបនីយកម្ម។ មូលនិធិ ស.គ.ន បានសម្រេចកំណត់ប្រធានបទ ជាអាទិភាពសម្រាប់ការគាំទ្រដោយមូលនិធិចំនួន៣ រួមមាន ឌីជីថលនីយកម្មសម្រាប់បដិវត្តឧស្សាហកម្ម៤.0 (Digitalization for IR.4.0) ការស្រាវជ្រាវអនុវត្តលើវិស័យ កសិកម្ម (Applied Agricultural Research) និងការស្រាវជ្រាវគរុកោសល្យសតវត្សទី២១ (21st Century Pedagogy Research)។

ដោយមានការធ្វើអាទិភាពរូបនីយកម្មទៅលើទិសដៅនៃការប្រើប្រាស់ថវិកាមូលនិធិ សម្រាប់ឆ្នាំ២០២០ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា បានផ្តល់ការគាំទ្រដល់ **ការរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សា (Text book) ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា**។ គោលបំណងនៃការរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា គឺដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រីកសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូនដល់និស្សិតដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ លើសពីនេះទៀតការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា មានគោលដៅដូចខាងក្រោម ៖

- ឆ្លើយតបជាបន្ទាន់ចំពោះការខ្វះខាតធនធានសិក្សា ដែលជាតម្រូវការសិក្សារបស់និស្សិតនៅកម្រិតឧត្តមសិក្សា
- លើកកម្ពស់ទំនើបភាវូបនីយកម្ម និងឧត្តមានុវត្តន៍នៃការរៀននិងបង្រៀន និងការស្រាវជ្រាវនៅលើមុខវិជ្ជា កម្មវិធីសិក្សា ឬមុខជំនាញជាក់លាក់
- បង្កើនភាពស៊ីជម្រៅក្នុងការកសាងវិជ្ជាជីវៈនិងបទពិសោធន៍សម្រាប់ហានៈសាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវ
- រួមចំណែកដល់ការកសាងភាពជាសហគមន៍វិជ្ជាជីវៈ ការចែករំលែកបទពិសោធន៍ និងវប្បធម៌នៃការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា។

ក្រសួងអប់រំ យុវជន និងកីឡា បានវាយតម្លៃខ្ពស់ចំពោះការបោះជំហានប្រកបដោយមនសិការវិជ្ជាជីវៈនៃគ្រឹះស្ថានឧត្តមសិក្សា និងបុគ្គលិកអប់រំទាំងអស់ ក្នុងការរៀបចំ រៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រឹងសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូននិស្សិតដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ សៀវភៅសិក្សាជាផ្នែកមួយនៃការទទួលស្គាល់គុណភាពអប់រំនៃគ្រឹះស្ថានឧត្តមសិក្សា និងជាធនធានសិក្សាដែលជាមូលដ្ឋានមួយដ៏សំខាន់ ក្នុងការគាំទ្រដល់ការបង្រៀន និងរៀន ហើយត្រូវមានបរិមាណគ្រប់គ្រាន់ ឆ្លើយតបទៅនឹងកម្មវិធីអប់រំ និងតម្រូវការសិក្សាស្រាវជ្រាវ។ ជាគោលការណ៍ គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ ត្រូវមានសៀវភៅសិក្សាដែលប្រើជាគោលសម្រាប់មុខវិជ្ជានីមួយៗ។ ចំនួនសៀវភៅសិក្សាដែលគ្រប់គ្រាន់សម្រាប់ការស្រាវជ្រាវ និងការសិក្សារបស់និស្សិត ត្រូវមានយ៉ាងតិចមួយចំណងជើងក្នុងមួយមុខវិជ្ជា ហើយត្រូវតម្កល់យ៉ាងតិច២ច្បាប់ នៅក្នុងបណ្ណាល័យ ឬអាចរកបានតាមប្រព័ន្ធអេឡិចត្រូនិក។ ក្រសួងអប់រំ យុវជន និងកីឡា លើកទឹកចិត្តបន្ថែមទៀតជូនដល់គ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជនដែលបានស្នើសុំថវិកាមូលនិធិរួច សូមចូលរួមបន្ថែមទៀត ដើម្បីបង្កើនចំនួនចំណងជើងសៀវភៅ។ ចំណែកគ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជនដែលពុំទាន់បានដាក់ពាក្យស្នើសុំ សូមចូលរួមដើម្បីជាគុណប្រយោជន៍ដល់តម្រូវការដ៏ទូទៅ និងផ្លែផ្កានៃនិស្សិតកម្ពុជាក្នុងការសិក្សា និងស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។

សេចក្តីបញ្ជាក់
នៃមូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍

សៀវភៅសិក្សានេះ ជាលទ្ធផលនៃការស្នើសុំអនុវត្តថវិកាមូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ក្នុងគម្រោង**រៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា។** សៀវភៅសិក្សានេះ ត្រូវបានរៀបរៀង និពន្ធ ឬកែលម្អដោយមានការធានាអះអាងថាជាស្នាដៃរបស់អ្នកនិពន្ធផ្ទាល់ និងបានឆ្លងកាត់ត្រួតពិនិត្យ ផ្តល់យោបល់ និងវាយតម្លៃដោយក្រុមប្រឹក្សាអប់រំ ក្រុមប្រឹក្សាស្រាវជ្រាវ ឬក្រុមប្រឹក្សាដែលមានតម្លៃស្មើនៃគ្រឹះស្ថានឧត្តមសិក្សា និងតាមរយៈកិច្ចសន្យាដែលបានធ្វើឡើង និងដែលបានតម្កល់ទុកនៅមូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍។ រាល់ខ្លឹមសារ ការបកស្រាយ និងរូបភាព គឺជាជំហរនិងទស្សនៈផ្ទាល់របស់អ្នកនិពន្ធ ហើយ ពុំឆ្លុះបញ្ចាំង ឬជាតំណាងដល់មូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ នៃក្រសួងអប់រំ យុវជន និងកីឡាឡើយ។

ចំណាប់អារម្មណ៍រួម

នេះជាកិត្តិយស និងមោទនភាពសម្រាប់រូបខ្ញុំ ដែលមានឱកាសផ្តល់ចំណាប់អារម្មណ៍រួម ចំពោះស្នាដៃដំបូងនៃការ**រៀបរៀង និពន្ធ និងកែលម្អសៀវភៅ** នៅកម្រិតឧត្តមសិក្សារបស់អស់លោក លោកស្រី ជាមន្ត្រីរាជការ សាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

ជាច្រើនឆ្នាំកន្លងមកនេះ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ចបានដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍធនធានមនុស្សផ្នែកនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបច្ចុប្បន្នធនធានមនុស្សទាំងនោះបាន និងកំពុងចូលរួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍប្រទេសជាតិ។ លទ្ធផលសម្រេចបានដ៏ប្រសើរនេះកើតចេញតាមរយៈការផ្តល់សេវាអប់រំបណ្តុះបណ្តាលប្រកបដោយគុណភាពនៅថ្នាក់ឧត្តមសិក្សា និងក្រោយឧត្តមសិក្សា ការបង្កើនសមត្ថភាពមុខជំនាញបច្ចេកទេសដល់សាស្ត្រាចារ្យបង្រៀន ការធ្វើសហប្រតិបត្តិការជាមួយគ្រឹះស្ថានសិក្សាក្នុង និងក្រៅប្រទេស អង្គការជាតិ-អន្តរជាតិ ព្រមទាំងនិងស្ថាប័នពាក់ព័ន្ធនានា ក្នុងគោលបំណងតែមួយគត់គឺធ្វើឲ្យកាន់តែល្អប្រសើរនូវការសិក្សា ការបង្រៀន និងការស្រាវជ្រាវ ការបោះពុម្ពផ្សាយ និងការជំរុញឲ្យមាននវានុវត្តន៍។

ក្នុងឆ្នាំសិក្សា២០២០-២០២១ ទោះបីជាស្ថិតក្នុងបរិបទនៃការរីករាលដាលនៃជម្ងឺកូវីដ-១៩ សាកលវិទ្យាល័យនៅតែបន្តកិច្ចខិតខំប្រឹងប្រែងក្នុងការចូលរួមលើកកម្ពស់សកម្មភាពស្រាវជ្រាវ ក្នុងនោះតាមសេចក្តីប្រកាសព័ត៌មាន**ស្តីពីការផ្តល់ថវិកាមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ សម្រាប់ការរៀបរៀង និពន្ធ និងកែលម្អសៀវភៅនៅកម្រិតឧត្តមសិក្សា** របស់ក្រសួងអប់រំ យុវជន និងកីឡា កាលពីថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចបានធ្វើការផ្សព្វផ្សាយជូនដំណឹង និងលើកទឹកចិត្តដល់មន្ត្រីរាជការ សាស្ត្រាចារ្យ នៃសាកលវិទ្យាល័យឲ្យចូលរួមដាក់ពាក្យសុំ រៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សាដើម្បីចូលរួមលើកកម្ពស់វប្បធម៌នៃការស្រាវជ្រាវ បំផុសគំនិតច្នៃប្រឌិត និងជំរុញការធ្វើនវានុវត្តន៍ ដើម្បីជាប្រយោជន៍ដល់វិស័យអប់រំស្របតាមការវិវត្តនៃបរិបទសង្គម សេដ្ឋកិច្ច បច្ចេកវិទ្យា និងឆ្លើយតបទៅនឹងបច្ចុប្បន្នភាពនៃតម្រូវការទីផ្សារការងារ។ ជាលទ្ធផល នៅដំហានចាប់ផ្តើមដំបូងនេះ សាកលវិទ្យាល័យទទួលបានស្នាដៃរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សាចំនួន១២ចំណងជើង។

សៀវភៅសិក្សាទាំង១២ចំណងជើងដែលជាស្នាដៃរបស់អ្នកនិពន្ធទាំងអស់ ត្រូវបានចាត់ទុកជាធនធានសិក្សាដ៏សំខាន់របស់សាកលវិទ្យាល័យ ខ្ញុំសូមធ្វើការកោតសរសើរដោយស្មោះ និងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងយ៉ាងសកម្មប្រកបដោយមនសិការវិជ្ជាជីវៈរបស់អស់លោក លោកស្រី មន្ត្រីរាជការ សាស្ត្រាចារ្យទាំងអស់របស់សាកលវិទ្យាល័យក្នុងការចូលរួម រៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងបង្កើនធនធានសិក្សាជាខេមរភាសាសម្រាប់និស្សិត និងការត្រៀមខ្លួនដើម្បីធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ សៀវភៅសិក្សា គឺជាធនធានសិក្សាដ៏ចាំបាច់មិនអាចខ្វះបានដែលគាំទ្រដល់ការបង្រៀននិងរៀន របស់សាស្ត្រាចារ្យ និងនិស្សិត ហើយត្រូវមានបរិមាណគ្រប់គ្រាន់ឆ្លើយតបទៅនឹងកម្មវិធីបណ្តុះបណ្តាលនិងតម្រូវការនៃការសិក្សាស្រាវជ្រាវ។សៀវភៅដែលជាស្នាដៃនិពន្ធរបស់អស់លោក លោកស្រី មន្ត្រីរាជការ សាស្ត្រាចារ្យទាំងអស់ ពិតជាមានសារសំខាន់ និងជាវិភាគទានដ៏មានសារៈប្រយោជន៍សម្រាប់និស្សិតកំពុងសិក្សា អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយ ក៏ដូចជាសម្រាប់តម្កល់ទុកនៅបណ្ណាល័យរបស់សាកលវិទ្យាល័យសម្រាប់និស្សិតអាន និងស្វែងយល់ផងដែរ។

ខ្ញុំមានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា អស់លោក លោកស្រី មន្ត្រីរាជការ សាស្ត្រាចារ្យទាំងអស់នឹងបន្តចូលរួមរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានេះនៅដំណាក់កាលជាបន្តបន្ទាប់ទៀតនាពេលខាងមុខ។

ជាចុងក្រោយ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ **ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា** និងថ្នាក់ដឹកនាំពាក់ព័ន្ធគ្រប់កម្រិតដែលបានផ្តួចផ្តើមបង្កើតមូលនិធិ ស.គ.ន នេះឡើង ដែលជាការផ្តល់ឱកាសឲ្យសាកលវិទ្យាល័យ បានចូលរួមចំណែកក្នុងការលើកកម្ពស់វប្បធម៌នៃការស្រាវជ្រាវនៅកម្ពុជា។

ថ្ងៃពុធ ៨រោច ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១

សាកលវិទ្យាធិការ

បណ្ឌិត លុយ ចណ្ណា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
សាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និង
វិទ្យាសាស្ត្រសេដ្ឋកិច្ច

លិខិតបញ្ជាក់

ខ្ញុំបាទឈ្មោះ: **លុយ ចណ្ណា** ជាសាកលវិទ្យាធិការ នៃសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

សូមគោរពបញ្ជាក់ជូន
ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី នៃក្រសួងអប់រំ យុវជន និងកីឡា

សៀវភៅដែលមានចំណងជើង ស្ថាប័ននយោបាយនៃព្រះរាជាណាចក្រកម្ពុជា ដែលនិពន្ធតាក់តែងឡើងដោយ លោក ង៉ុំ អ៊ីម សម្រាប់ដំណើរការរៀន និងបង្រៀន និងតម្កល់ទុកនៅក្នុងបណ្ណាល័យនៃសាកលវិទ្យាល័យ។

តាងនាមឲ្យគណៈត្រួតពិនិត្យ យើងខ្ញុំសង្កេតឃើញថា៖ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគ ដែលមាននៅក្នុងសៀវភៅនេះ ជាពាក្យពេចន៍ ឃ្លាប្រយោគរបស់អ្នកនិពន្ធ ដោយឡែកគំនិត និងខ្លឹមសារ មិនមានការខុសអំពីខ្លឹមសារលំនាំដើម នៃឯកសារនោះទេ។

សៀវភៅនេះ បានសរសេរជាភាសាខ្មែរ ដែលធ្វើឲ្យមានលក្ខណៈងាយយល់ អាចយកទៅអនុវត្តបាន។

អាស្រ័យហេតុនេះ សូមផ្ញើកពាក់ព័ន្ធ មេត្តាជ្រាបជាព័ត៌មានតាមការគួរ ។

ថ្ងៃសៅរ៍ ៦កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២១
សាកលវិទ្យាធិការ

បណ្ឌិត លុយ ចណ្ណា

សេចក្តីថ្លែងអំណរគុណ

សូមថ្លែងអំណរគុណចំពោះ

-ក្រសួងអប់រំ យុវជន និងកីឡា ដែលបានលើកកម្ពស់វប្បធម៌នៃការស្រាវជ្រាវ បំផុសគំនិតច្នៃប្រឌិត និងជំរុញការធ្វើនវានុវត្តន៍ ដើម្បីជាប្រយោជន៍ដល់វិស័យអប់រំ ដើម្បីឆ្លើយតបនឹងតម្រូវការនៃការវិវត្តន៍ស្របតាមបរិបទសង្គម សេដ្ឋកិច្ច និងបច្ចេកវិទ្យា តាមរយៈការបង្កើនបរិមាណនៃធនធានសិក្សាជាខេមរៈភាសា ជូនដល់និស្សិតដែលកំពុងសិក្សា និងការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា ក្នុងចក្ខុវិស័យ «មុខវិជ្ជាសិក្សាមួយសៀវភៅមួយ»។

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានគាំទ្រសកម្មភាពរបស់មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ជាពិសេស គឺលើកទឹកចិត្ត និងជំរុញឲ្យមានការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា។

-មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ (ស.គ.ន.) នៃក្រសួងអប់រំ យុវជន និងកីឡា ដែលបានផ្តួចផ្តើម និងលើកកម្ពស់ការរៀបរៀង និពន្ធ និងកែលម្អធនធានសិក្សាជាខេមរៈភាសានៅកម្រិតឧត្តមសិក្សា។

-សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានចូលរួមអនុវត្តស្របតាមទិសដៅ និងចក្ខុវិស័យរបស់ក្រសួងអប់រំ យុវជន និងកីឡា ជាពិសេស គឺការគាំទ្រសកម្មភាពមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍(មូលនិធិស.គ.ន.) ដោយអំពាវនាវ ផ្តល់ឱកាសលើកទឹកចិត្ត និងជំរុញការចូលរួមពីបុគ្គលិកអប់រំ និងសាស្ត្រាចារ្យវេលាកា រក្នុងសាកលវិទ្យាល័យ ឲ្យបានចូលរួមចំណែក កសាងធនធានសិក្សាជាខេមរៈភាសា ដើម្បីឆ្លើយតបនឹងបច្ចុប្បន្នភាព កម្មវិធីបណ្តុះបណ្តាលក្នុងសាកលវិទ្យាល័យ។

-ក្រុមប្រឹក្សាវិទ្យាសាស្ត្រនៃសាកលវិទ្យាល័យ ដែលជាផ្នែកមួយដ៏សំខាន់ និងមិនអាចខ្វះបាន ក្នុងការត្រួតពិនិត្យវាយតម្លៃ និងផ្តល់យោបល់ស្ថាបនាលើស្នាដៃសៀវភៅ ដែលធ្វើឲ្យស្នាដៃមួយនេះកាន់តែមានភាពល្អប្រសើរឡើង និងមានខ្លឹមសារពេញលេញ។

-ភាគីពាក់ព័ន្ធទាំងអស់ ដែលបានផ្តល់ឯកសារនានាគាំទ្រដល់ការរៀបរៀង និងនិពន្ធសៀវភៅនេះ។

-ក្រុមគ្រួសារទាំងមូល ដែលបានផ្តល់ឱកាសដល់ខ្ញុំបាទក្នុងការរៀបរៀង និងនិពន្ធសៀវភៅនេះ។

កិច្ចសម្តែងកតញ្ញូតវេទិតាធម៌

ខ្ញុំសូមលំឱនកាយក្រាបប្រណិប័តន៍សម្តែងនូវ
កតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ចំពោះលោកឪពុកអ្នកម្តាយ

ដែលបានការបង្កើតរូបរាងកាយ និងបីបាច់ថែរក្សា អប់រំទូន្មានកូនតាំងពីតូចដល់ធំឲ្យរៀនសូត្រទទួលបានចំណេះដឹងមកដល់បច្ចុប្បន្ន។

នេះគឺជាគុណូបការគុណយ៉ាងអនេកប្បការ និងវិសេសថ្លៃថ្លាបំផុត ដែលមិនអាចកាត់ថ្លៃបានរបស់លោកអ្នកមានគុណទាំងទ្វេ។

សូមប្រណិប័តន៍ជូនស្នាដៃនេះចំពោះអ្នកម្តាយដ៏មានគុណ
សួន ផាង

និង

សូមបួងសួងឧទ្ទិសស្នាដៃនេះជូនទៅដល់វិញ្ញាណក្ខន្ធ

លោកឪពុក លឹម ដុំ និងបុព្វការីជន

ដោយក្តីគោរពដឹងគុណយ៉ាងជ្រាលជ្រៅជាទីបំផុត

សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ **ជុំ អ៊ឹម** សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ

- **សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានដឹកនាំរាជរដ្ឋាភិបាល ក្រោមនយោបាយឈ្នះៗ និងចក្ខុវិស័យគតិបណ្ឌិត បានធ្វើឲ្យព្រះរាជាណាចក្រកម្ពុជាទទួលបាននូវសុខសន្តិភាពពិតប្រាកដ ហើយបានអភិវឌ្ឍន៍ប្រទេសជាតិឲ្យរីកចម្រើនជាបន្តបន្ទាប់រហូតមកដល់បច្ចុប្បន្ន។

- **ឯកឧត្តម រដ្ឋមន្ត្រី** ក្រសួងអប់រំយុវជន និងកីឡា

- **ឯកឧត្តម រដ្ឋមន្ត្រី**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- **ឯកឧត្តមរដ្ឋលេខាធិការ** និង **ឯកឧត្តមអនុរដ្ឋលេខាធិការ**នៃក្រសួងអប់រំយុវជន និងកីឡាទាំងអស់ ដែលបានបង្កើត **មូនិធិ ស.ភ.ន** សម្រាប់ការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា។

- **ឯកឧត្តម បណ្ឌិត លុយ ចណ្ណា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

- លោក **ពៅ សារឿន** សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

- លោក **បណ្ឌិត សឿន សោភ័ណ** សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

-លោកស្រី **ប៉ូលី បញ្ញា** អនុប្រធានការិយាល័យស្រាវជ្រាវនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

- **សាស្ត្រាចារ្យ**នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលលើកទឹកចិត្ត ព្រមទាំងជំរុញការសិក្សាស្រាវជ្រាវរៀបចំតាក់តែងចងក្រងជាសៀវភៅឡើង។

-ជាពិសេស **ប្រពន្ធសម្លាញ់ អ៊ុក សុគន្ធបុប្ផា និងកូន ជុំ សុភណ្ណរដ្ឋ** ដែលបានយកចិត្តទុកដាក់ជួយជ្រោមជ្រែង លើកទឹកចិត្ត និងផ្តល់ភាពកក់ក្តៅដល់ស្វាមី។

អារម្ភកថា

ស្ថាប័ននយោបាយនៃព្រះរាជាណាចក្រកម្ពុជា គឺជាសមិទ្ធផលនៃការខិតខំប្រឹងប្រែងសិក្សាស្រាវជ្រាវ និងរៀបចំចងក្រងដោយបានផ្អែកលើមូលដ្ឋានលិខិតបទដ្ឋានគតិយុត្តនានា និងរដ្ឋធម្មនុញ្ញ ដើម្បីឆ្លើយតបតាមតម្រូវការក្នុងការសិក្សាស្រាវជ្រាវ ព្រមទាំងរួមចំណែកក្នុងការអភិវឌ្ឍន៍ធនធានមនុស្សនៅកម្ពុជា។

បើពិនិត្យទៅលើកាលានុវត្តភាព និងតម្រូវការចាំបាច់ ក្នុងការអភិវឌ្ឍន៍សង្គម ខ្ញុំបាទចាំបាច់ត្រូវរៀបចំចងក្រងបោះពុម្ពសៀវភៅ **ស្ថាប័ននយោបាយ** ដែលទាក់ទងនឹងទ្រឹស្តីទូទៅអំពីស្ថាប័ន ការបង្កើតស្ថាប័ននៅសម័យបុរាណ ស្ថាប័នសម័យទំនើប ស្ថាប័នជាតិ ស្ថាប័នអន្តរជាតិ និងការវិវត្តន៍របស់ស្ថាប័ននៅក្នុងសម័យកាលនីមួយៗ ព្រមទាំងដំណើរការប្រព្រឹត្តទៅរបស់អង្គការរដ្ឋ ស្ថាប័នសំខាន់ៗរបស់រដ្ឋ ជាពិសេសស្ថាប័ននយោបាយនៃព្រះរាជាណាចក្រកម្ពុជា ដែលបានបង្កើតឡើងនៅក្នុងប្រទេសកម្ពុជាយើង ចាប់តាំងពីអតីតកាលរហូតមកដល់បច្ចុប្បន្នកាល។

ស្នាដៃនេះ ពិតជាបានចូលរួមចំណែកក្នុងការកសាងពុទ្ធិ និងជាឯកសារជំនួយស្មារតីយ៉ាងសំខាន់សម្រាប់សិស្ស និស្សិត និងអ្នកសិក្សា អ្នកស្រាវជ្រាវផ្សេងៗទៀត នៅក្នុងការបណ្តុះបណ្តាល និងសិក្សាស្រាវជ្រាវ ដើម្បីកសាងធនធានមនុស្ស ឈានទៅការអភិវឌ្ឍន៍ និងវឌ្ឍនភាពសង្គមជាតិខ្មែរ។

ខ្ញុំបាទសូមស្វាគមន៍នូវការចូលរួមចំណែកអំពីសំណាក់សម្តេច ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា អស់លោក លោកស្រី អ្នកនាងកញ្ញា សិស្ស និស្សិត និងប្រិយមិត្តអ្នកអានទាំងអស់ ដើម្បីញ៉ាំងឲ្យស្នាដៃនេះកាន់តែមានអត្ថន័យ និងខ្លឹមសារល្អប្រសើរឡើងថែមទៀត។

ខ្ញុំបាទមានមោទកភាព សប្បាយរីករាយដែលធ្វើឲ្យសៀវភៅ ″ **ស្ថាប័ននយោបាយនៃព្រះរាជាណាចក្រកម្ពុជា** ″ បានបោះពុម្ពផ្សាយប្រកបដោយជោគជ័យ។

សូមសម្តេច ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា អស់លោក លោកស្រី អ្នកនាងកញ្ញា សិស្ស និស្សិត ព្រមទាំងប្រជាពលរដ្ឋខ្មែរទូទាំងប្រទេសកម្ពុជាទទួលបាននូវសុខសន្តិភាព សេចក្តីសុខចម្រើន និងសុភមង្គលជានិច្ចនិរន្តរ៍។

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១

អ្នកនិពន្ធ ដុំ អ៊ីម

មាតិកា

សេចក្តីផ្តើម ១

ជំពូកទី១ ..... ៣

ទ្រឹស្តីទូទៅអំពីស្ថាប័ន ៣

ផ្នែកទី១ ..... ៣

អំពីស្ថាប័ន ៣

ក.សញ្ញាណទូទៅ ៣

ខ.និយមន័យស្ថាប័ន ៤

គ.លក្ខខណ្ឌស្ថាប័ន ៦

ផ្នែកទី២ ..... ៧

ប្រវត្តិនៃការកកើតស្ថាប័ន ៧

ក សញ្ញាណទូទៅ ៧

ខ-ស្ថាប័នសម័យដើម ៨

គ-ស្ថាប័នសម័យទំនើប ៨

ផ្នែកទី៣ ..... ៩

អំពីប្រភេទស្ថាប័ន ៩

ក-ស្ថាប័នអន្តរជាតិ ៩

១.ស្ថាប័នអន្តរជាតិសាធារណៈ ៩

២.ស្ថាប័នអន្តរជាតិឯកជន ១០

ខ-ស្ថាប័នជាតិ ១០

១.ស្ថាប័នជាតិឯកជន ១១

២.ស្ថាប័នជាតិសាធារណៈ ១១

ជំពូកទី២ ..... ១២
ស្ថាប័ននយោបាយ ១២
ជំពូកទី៣ ..... ១៣
ស្ថាប័នខ្មែរសម័យដើម ១៣
ផ្នែកទី១ ..... ១៣
ស្ថាប័ននយោបាយមុនសម័យអង្គរ ១៣
ក.ព្រះមហាក្សត្រ ១៣
ខ.ការគ្រងរាជសម្បត្តិ ១៤
ផ្នែកទី២ ..... ១៥
ស្ថាប័ននយោបាយសម័យអង្គរ ១៥
ក.ព្រះមហាក្សត្រ ១៥
ខ.ការគ្រងរាជសម្បត្តិ ១៥
គ.អំណាចព្រះមហាក្សត្រ ១៥
ឃ.ព្រះរាជទង្វាន់ទង្ស ១៦
ង.ព្រាហ្មណ៍ និងបព្វជិត ១៧
ផ្នែកទី៣ ..... ១៨
ស្ថាប័ននយោបាយក្រោយសម័យអង្គរ ១៨
ក.ព្រះមហាក្សត្រ ១៨
ខ.ការគ្រងរាជសម្បត្តិ ១៨
គ.អំណាចព្រះមហាក្សត្រ ១៩
ឃ.ព្រះរាជទង្វាន់ទង្ស និងមន្ត្រី ១៩
១-ឧត្តយោរាជ ១៩

២-ឧបរាជ ឬមហាឧបរាជ ២០

៣-មន្ត្រី ២០

ផ្នែកទី៤ ..... ២១

ស្ថាប័ននយោបាយសម័យអាណានិគមនិយមបារាំង ២១

ក.ទំនាក់ទំនងខ្មែរជាមួយបារាំង ២១

ខ.ទំនាក់ទំនងសៀមជាមួយបារាំង ២២

គ.ព្រះមហាក្សត្រខ្មែរ ២២

១-ការរៀបចំរាជរដ្ឋាភិបាល ២៣

២-ព្រះរាជវង្សានុវង្ស ២៣

៣-ក្រុមប្រឹក្សារាជសម្បត្តិ ២៤

៤-មន្ត្រីជាន់ខ្ពស់ ២៤

ជំពូកទី៤ ..... ២៧

ស្ថាប័នខ្មែរសម័យទំនើប ២៧

ផ្នែកទី១ ..... ២៧

ស្ថាប័ននយោបាយសម័យសង្គមរាស្ត្រនិយម ២៧

ក.ព្រះមហាក្សត្រ ២៧

១ ការគ្រងរាជសម្បត្តិ ២៧

២-អំណាចព្រះមហាក្សត្រ ២៨

ខ.ស្ថាប័នរីតិប្បញ្ញត្តិ ៣១

I-រដ្ឋសភា ៣១

១.ទិដ្ឋភាពទូទៅ ៣១

២.ប្រវត្តិរដ្ឋសភាខ្មែរ ៣១

៣.រដ្ឋសភានៅឆ្នាំ១៩៤៧ ..... **៣២**

៤ .នីតិវិធីនៃការចូលកាន់តំណែងរបស់សមាជិករដ្ឋសភា **៣៣**

៥. សមាជិករដ្ឋសភា **៣៣**

៦.ការបោះឆ្នោតជ្រើសតាំង **៣៣**

៦.១.អ្នកដែលមានសិទ្ធិជ្រើសតាំង **៣៤**

៦.២.អ្នកដែលមិនមានសិទ្ធិជ្រើសតាំង **៣៤**

៦.៣.លក្ខខណ្ឌនៃការឈរឈ្មោះ **៣៤**

៦.៤.លក្ខខណ្ឌមិនអាចឈរឈ្មោះ **៣៤**

៧.ការប្រជុំរដ្ឋសភា **៣៥**

៧.១ ការប្រជុំជាសាមញ្ញ **៣៥**

៧.២ ការប្រជុំជាវិសាមញ្ញ **៣៦**

៨.ការអនុម័ត **៣៦**

៩.អាណត្តិរដ្ឋសភា **៣៦**

១០.អំពីអត័យឯកសិទ្ធិសភា **៣៧**

II-**ព្រឹទ្ធសភា** **៣៧**

១.ទិដ្ឋភាពទូទៅ **៣៧**

២.ក្រុមប្រឹក្សាព្រះរាជាណាចក្រ **៣៨**

គ.ស្ថាប័ននីតិប្រតិបត្តិ(រាជរដ្ឋាភិបាល) **៤0**

១-ការបង្កើតរាជរដ្ឋាភិបាល **៤0**

២.ការទទួលខុសត្រូវរបស់សមាជិករាជរដ្ឋាភិបាល **៤0**

៣-កិច្ចប្រជុំគណៈរដ្ឋមន្ត្រី **៤១**

៤.ទិសមិតភាពនៃសមាជិករាជរដ្ឋាភិបាល **៤២**

ឃ.សមាជជាតិ ៤៥
ផ្នែកទី២ ..... ៤៧
ស្ថាប័នឧបាយសម័យសាធារណរដ្ឋខ្មែរ ៤៧
ក.ប្រធានាធិបតី ៤៧
១-លក្ខខណ្ឌឈរឈ្មោះ ៤៧
២-តួនាទីរបស់ប្រធានាធិបតី ៤៨
ខ.អង្គការនីតិប្បញ្ញត្តិ ៤៩
១-រដ្ឋសភា ៤៩
២-ព្រឹទ្ធសភា ៥0
គ.អង្គការនីតិប្រតិបត្តិ ៥១
ឃ.តុលាការធម្មនុញ្ញ ៥២
ផ្នែកទី៣ ..... ៥៤
ស្ថាប័នឧបាយសម័យកម្ពុជាប្រជាធិបតេយ្យ ៥៤
ក.ស្ថានភាពទូទៅ ៥៤
ខ.គណៈប្រធានរដ្ឋ ៥៤
គ.រដ្ឋសភា ៥៥
ឃ.រដ្ឋាភិបាល ៥៥
ផ្នែកទី៤ ..... ៥៧
ស្ថាប័នឧបាយសាធារណរដ្ឋប្រជាមានិតកម្ពុជា ៥៧
ក.ស្ថានភាពទូទៅ ៥៧
ខ.ក្រុមប្រឹក្សារដ្ឋ ៥៧
១-សមាសភាពក្រុមប្រឹក្សារដ្ឋ ៥៧

២-តួនាទីក្រុមប្រឹក្សារដ្ឋ **៥៨**

៣-នីតិកាលរបស់ក្រុមប្រឹក្សារដ្ឋ **៥៩**

គ.ក្រុមប្រឹក្សារដ្ឋមន្ត្រី **៦០**

១-សមាសភាពក្រុមប្រឹក្សារដ្ឋមន្ត្រី **៦០**

២-តួនាទី និងភារកិច្ចក្រុមប្រឹក្សារដ្ឋមន្ត្រី **៦១**

៣-ការប្រជុំក្រុមប្រឹក្សារដ្ឋមន្ត្រី **៦៥**

៣.១.ការប្រជុំអចិន្ត្រៃយ៍ **៦៥**

៣.២.ការប្រជុំពេញអង្គ(សម្ងហាភាព) **៦៦**

៤-នីតិកាលក្រុមប្រឹក្សារដ្ឋមន្ត្រី **៦៧**

ឃ.រដ្ឋសភា **៦៨**

១-ការចូលកាន់តំណែង **៧០**

២-អាណត្តិសភា **៧០**

៣-ការកោះប្រជុំរដ្ឋសភា **៧០**

៤-សមាជិករដ្ឋសភា **៧១**

៥-ប្រធានរដ្ឋសភា **៧៣**

៦-ការអនុម័ត **៧៥**

៧-សិទ្ធិអំណាចរដ្ឋសភា **៧៥**

៨-អភ័យឯកសិទ្ធិសភា **៧៧**

ជំពូកទី៥ ..... **៧៩**

ស្ថាប័នឧបាយព្រះរាជាណាចក្រកម្ពុជា **៧៩**

សម័យពីឆ្នាំ១៩៩៣មកដល់បច្ចុប្បន្ន **៧៩**

ស្ថានភាពទូទៅ **៧៩**

ផ្នែកទី១ ..... ៨១
ព្រះមហាក្សត្រ ៨១
ក.ការជ្រើសរើសព្រះមហាក្សត្រ ៨១
ខ.ក្រុមប្រឹក្សារាជសម្បត្តិ ៨២
១-សមាសភាពក្រុមប្រឹក្សារាជសម្បត្តិ ៨២
២-ការរៀបចំ និងការប្រព្រឹត្តទៅក្រុមប្រឹក្សារាជសម្បត្តិ ៨៤
គ.ព្រះរាជឆ្នាទីព្រះមហាក្សត្រ ៨៥
១-ព្រះមហាក្សត្រជាប្រមុខរដ្ឋ ៨៥
២-ជាមេបញ្ជាការកំពូលនៃកងយោធពលខេមរភូមិន្ទ ៨៦
៣-ព្រះមហាក្សត្រជាប្រមុខស្ថាប័នតុលាការ ៨៨
ឃ-អំណាចព្រះមហាក្សត្រ ៩០
១-អំណាចតែងតាំង និងការដកហូត ៩០
១-១ ការតែងតាំង ៩១
១-២ តែងតាំងដកហូតមន្ត្រីរាជការជាន់ខ្ពស់ស៊ីវិល និងយោធា ៩១
១-៣ ប្រទានគ្រឿងឥស្សរិយយស ៩៣
២-អំណាចប្រកាសឲ្យប្រើច្បាស់ច្បាប់ ៩៩
៣-អំណាចប្រកាសសង្គ្រាម និងតាពអាសន្ន ១០០
៤-អំណាចលើកលែងទោស ១០១
ង.ការិយាល័យប្រតិបត្តិរបស់ព្រះមហាក្សត្រ ១០៣
១-ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ ១០៣
១.១.ក្រុមអ្នកឧកញ៉ាចៅហ្វាខាំង ១០៣
១.២.ក្រុមជំនិតព្រះមហាក្សត្រ ១០៤

១.៣.មន្ត្រីអចិន្ត្រៃយ៍ ១០៤

១.៤.មន្ត្រីកិត្តិយស ១០៥

២-ក្រុមប្រឹក្សាយោធាព្រះមហាក្សត្រ ១០៥

៣-ឧត្តមក្រុមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ ១០៥

៤-ក្រុមសម្តេចឪ ១០៦

ផ្នែកទី២ ..... ១០៨

នីតិប្រតិបត្តិ(រាជរដ្ឋាភិបាល) ១០៨

ក.បែបបទនៃការរៀបចំរាជរដ្ឋាភិបាល ១០៨

១-ការបង្កើតរាជរដ្ឋាភិបាល ១០៨

១.១.ការបង្កើតរាជរដ្ឋាភិបាលតាមមាត្រា១១៨ថ្មី ១០៨

១.២.ការបង្កើតរាជរដ្ឋាភិបាលផ្នែកតាមច្បាប់ធម្មនុញ្ញបន្ថែម ១០៩

២-លក្ខខណ្ឌបេក្ខភាពនាយករដ្ឋមន្ត្រី ១១១

ខ.សមាសភាពរាជរដ្ឋាភិបាល ១១២

គ.គណៈរដ្ឋមន្ត្រី និងសមត្ថកិច្ចនាយករដ្ឋមន្ត្រី ១១៣

១-គណៈរដ្ឋមន្ត្រី ១១៣

២-កិច្ចប្រជុំគណៈរដ្ឋមន្ត្រី ១១៤

២.១.កិច្ចប្រជុំលើកទី១ ..... ១១៤

២.២.កិច្ចប្រជុំអន្តរក្រសួង ១១៤

២.៣.កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ១១៥

៣-តួនាទី និងសមត្ថកិច្ចនាយករដ្ឋមន្ត្រី ១១៦

៤-តួនាទី និងសមត្ថកិច្ចឧបនាយករដ្ឋមន្ត្រី ១១៩

៥-តួនាទី និងសមត្ថកិច្ចទេសរដ្ឋមន្ត្រី ១២០

៦-តួនាទី និងសមត្ថកិច្ចរដ្ឋមន្ត្រី ១២១

៧-តួនាទី និងសមត្ថកិច្ចរដ្ឋលេខាធិការ ១២២

៧.១.រដ្ឋលេខាធិការស្ងួយ័ត ១២២

៧.២.រដ្ឋលេខាធិការជាអនុប្រធានស្ថាប័ន ១២៣

៧.៣.រដ្ឋលេខាធិការអមទីស្តីការគណៈរដ្ឋមន្ត្រី

ឬរដ្ឋលេខាធិការអមនាយករដ្ឋមន្ត្រី ១២៣

៨-តួនាទី និងសមត្ថកិច្ចអនុរដ្ឋលេខាធិការ ១២៤

៩-មុខងារ និងសមត្ថកិច្ចក្រសួង ១២៤

១០-ក្រសួង និងស្ថាប័នរដ្ឋ ១២៥

១១.រដ្ឋលេខាធិការដ្ឋានចំណុះទីស្តីការគណៈរដ្ឋមន្ត្រី ១២៩

ឃ.ការទទួលខុសត្រូវរបស់សមាជិករាជរដ្ឋាភិបាល ១២៩

ង.វិសមិតភាពនៃសមាជិករាជរដ្ឋាភិបាល ១៣០

ផ្នែកទី៣ ..... ១៣១

នីតិប្បញ្ញត្តិ(រដ្ឋសភា) ១៣១

ក.អំពីរដ្ឋសភា ១៣១

១.ការប្រជុំរដ្ឋសភា ១៣២

២.ការប្រជុំជាសាមញ្ញ ១៣២

៣.ការប្រជុំជាវិសាមញ្ញ ១៣២

៤.ការប្រជុំរាល់ថ្ងៃ ១៣៣

៥.ការអនុម័ត ១៣៤

៥.១.ការប្រើចំនួននៃការអនុម័តដោយរដ្ឋសភា ១៣៤

៥.១.១.ការអនុម័តដោយសម្លេងភាគច្រើនបីភាគបួន(៣/៤) ១៣៥

៥.១.២.ការអនុម័តដោយសម្លេងភាគច្រើនពីរភាគបី(២/៣) ១៣៥

៥.១.៣.ការអនុម័តសម្លេងភាគច្រើនដោយប្រៀប ១៣៦

៥.១.៤.ការអនុម័តដោយសម្លេងភាគច្រើនជាច់ខាត(៥0%+១) ១៣៧

៥.២.នីតិវិធីនៃការអនុម័តចោះឆ្នោត ១៣៨

៥.២.១ ការអនុម័តដោយវិធីលើកដៃ ១៣៨

៥.២.២ ការអនុម័តចោះឆ្នោតជាចំហ ១៣៨

៥.២.៣ ការអនុម័តចោះឆ្នោតដោយសម្ងាត់.....១៣៩

ខ.សមាជិករដ្ឋសភា ១៤0

១-ការចោះឆ្នោតជាសាកល ១៤១

២-ការចោះឆ្នោតដោយសេរី ១៤១

៣-ការចោះឆ្នោតដោយស្មើភាព.....១៤១

៤-ការចោះឆ្នោតដោយចំពោះ.....១៤១

៥-ការចោះឆ្នោតដោយសម្ងាត់.....១៤១

គ.លក្ខខណ្ឌនៃការឈរឈ្មោះ និងមិនអាចឈរឈ្មោះ.....១៤២

១-លក្ខខណ្ឌនៃការឈរឈ្មោះ.....១៤២

២-លក្ខខណ្ឌមិនអាចឈរឈ្មោះ.....១៤២

ឃ.នីតិវិធីនៃការចូលកាន់តំណែងរបស់រដ្ឋសភា ១៤៣

១-ការចូលកាន់តំណែងក្នុងករណីធម្មតា.....១៤៣

២-ការចូលកាន់តំណែងក្នុងករណីពិសេស.....១៤៤

៣-សុពលភាពអ្នកតំណាងរាស្ត្រ.....១៤៥

ង.អាណត្តិរដ្ឋសភា.....១៤៥

ច.តួនាទីប្រធានរដ្ឋសភា.....១៤៥

ឆ.ឆ្នាំងទីអនុប្រធានរដ្ឋសភា ១៤៩
ជ.ឆ្នាំងទីរបស់តំណាងរាស្ត្រ ១៤៩
ឈ.គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ១៥១
១-សមាសភាព ១៥១
២-ឆ្នាំងទី ១៥១
ញ.គណៈកម្មការជំនាញនានារដ្ឋសភា ១៥៣
១-ការជ្រើសរើសគណៈកម្មការជំនាញ ១៥៤
២-គណៈកម្មការជំនាញនានា ១៥៥
៣-ឆ្នាំងទីគណៈកម្មការនានារបស់រដ្ឋសភា ១៥៥
ដ.អំពីវិសមិតភាពសភា ១៥៦
ឋ.អំពីអភ័យឯកសិទ្ធិសភា ១៥៧
ឌ.អំពីឋាន: និងបុព្វសិទ្ធិសភា ១៦១
ឍ.ការគ្រប់គ្រងអគ្គលេខាធិការដ្ឋានរដ្ឋសភា ១៦៣
១-សញ្ញាណទូទៅ ១៦៣
២-អគ្គលេខាធិការដ្ឋានរដ្ឋសភា ១៦៤
៣-ការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា ១៦៤
៤-ឆ្នាំងទី និងភារកិច្ចអគ្គលេខាធិការ ១៦៤
ផ្នែកទី៤ ..... ១៦៨
នីតិប្បញ្ញត្តិ ព្រឹទ្ធសភា ១៦៨
ក.ព្រឹទ្ធសភាជាអ្វី? ១៦៨
ខ.ការរៀបចំ និងការប្រព្រឹត្តទៅរបស់ព្រឹទ្ធសភា ១៦៩
១-ការបង្កើតស្ថាប័នព្រឹទ្ធសភា ១៦៩

២-នីតិវិធីចូលកាន់តំណែងរបស់ព្រឹទ្ធសភា.....១៧០

២.១.ប្រធានបណ្តោះអាសន្ន.....១៧០

២.២.សុពលភាពសមាជិកព្រឹទ្ធសភា.....១៧១

គ.សមាជិកព្រឹទ្ធសភា.....១៧១

១-ការជ្រើសរើសសមាជិកព្រឹទ្ធសភា.....១៧១

២-ការបាត់បង់សមាជិកភាព.....១៧៣

ឃ.លក្ខខណ្ឌនៃការឈរឈ្មោះ និងមិនអាចឈរឈ្មោះ.....១៧៤

១-លក្ខខណ្ឌនៃការឈរឈ្មោះ.....១៧៤

២-លក្ខខណ្ឌមិនអាចឈរឈ្មោះ.....១៧៤

៣-លក្ខខណ្ឌឈរឈ្មោះចំពោះអ្នកដែលច្បាប់ហាម.....១៧៥

ង.តួនាទីរបស់ព្រឹទ្ធសភា.....១៧៥

១-ការអនុភត្តអំណាចរបស់ព្រឹទ្ធសភា.....១៧៦

១.១.ការផ្តួចផ្តើមធ្វើច្បាប់.....១៧៦

១.២.ការត្រួតពិនិត្យច្បាប់.....១៧៧

១.៣.ការអនុម័តរបស់ព្រឹទ្ធសភា.....១៧៨

២.តួនាទីជាអ្នកសម្របសម្រួល.....១៧៩

៣-តួនាទីផ្សេងទៀតរបស់ព្រឹទ្ធសភា.....១៨០

ច.ការប្រជុំព្រឹទ្ធសភា.....១៨១

១-ការប្រជុំជាសាមញ្ញ.....១៨២

២-ការប្រជុំជាវិសាមញ្ញ.....១៨២

៣-ការប្រជុំរាល់ថ្ងៃ.....១៨៣

៤-នីតិវិធីនៃការអនុម័ត.....១៨៤

៤.១.ការអនុម័តដោយវិធីលើកដៃ ១៨៤

៤.២.ការអនុម័តចោះឆ្នោតជាចំហ..... ១៨៤

៤.៣. ការអនុម័តចោះឆ្នោតជាចំហនៅលើវេទិកា..... ១៨៥

៤.៤.ការអនុម័តចោះឆ្នោតដោយសម្ងាត់ ១៨៥

៤.៥.ការប្រើចំនួនៃការអនុម័តដោយព្រឹទ្ធសភា ១៨៦

៤.៥.១.ការអនុម័តដោយសម្លេងភាគច្រើនបីភាគបួន(៣/៤) ១៨៦

៤.៥.២.ការអនុម័តដោយសម្លេងភាគច្រើនពីរភាគបី(២/៣) ១៨៦

៤.៥.៣.ការអនុម័តដោយសម្លេងភាគច្រើនជាច់ខាត(៥0%+១) ១៨៧

ឆ.អាណត្តិព្រឹទ្ធសភា..... ១៨៨

ជ.តួនាទីប្រធានព្រឹទ្ធសភា ១៨៨

ឈ.តួនាទីអនុប្រធានព្រឹទ្ធសភា.....១៩២

ញ.គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ១៩២

១-ការបង្កើតគណៈកម្មាធិការអចិន្ត្រៃយ៍ ១៩២

២-សមាសភាព ១៩៣

៣-តួនាទី និងភារកិច្ច ១៩៤

ដ.គណៈកម្មការនានាព្រឹទ្ធសភា..... ១៩៦

១-ការបង្កើតគណៈកម្មការ..... ១៩៦

២-គណៈកម្មការជំនាញនានា ១៩៨

៣-តួនាទីគណៈកម្មការ ១៩៩

ថ.ទិសមិតភាពព្រឹទ្ធសភា ២00

ឋ.អំពីអត័យឯកសិទ្ធិព្រឹទ្ធសភា.....២0១

ឆ.អំពីឋាន: និងបុព្វសិទ្ធិសមាជិកព្រឹទ្ធសភា.....២0៤

ឆ.ការគ្រប់គ្រងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា..... ២០៦
១-សញ្ញាណទូទៅ(Notions) ២០៦
២-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា..... ២០៦
៣-ការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា..... ២០៧
៤-តួនាទី និងភារកិច្ចអគ្គលេខាធិការ ២០៧
ផ្នែកទី៥..... ២១០
ក្រុមប្រឹក្សាធម្មនុញ្ញ ២១០
ក.ប្រវត្តិក្រុមប្រឹក្សាធម្មនុញ្ញ ២១០
ខ.ការរៀបចំក្រុមប្រឹក្សាធម្មនុញ្ញ..... ២១១
១-ការបង្កើតស្ថាប័ន..... ២១១
២-ការចូលកាន់តំណែង ២១២
គ.សមាសភាព និងអាណត្តិក្រុមប្រឹក្សាធម្មនុញ្ញ ២១៣
ឃ.ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ២១៤
១-ការជ្រើសរើសប្រធាន..... ២១៤
២-តួនាទី និងភារកិច្ចប្រធាន..... ២១៥
ង.លក្ខណៈសម្បត្តិសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ..... ២១៨
ច.សមត្ថកិច្ចក្រុមប្រឹក្សាធម្មនុញ្ញ..... ២១៩
១-ការពិនិត្យធម្មនុញ្ញភាពនៃច្បាប់ ២២០
១.១.ការពិនិត្យធម្មនុញ្ញភាពនៃច្បាប់ជាអាទិភាព..... ២២១
១.១.១.ការត្រួតពិនិត្យជាចាំបាច..... ២២១
១.១.២.ការត្រួតពិនិត្យមិនជាចាំបាច..... ២២២
១.២-ការពិនិត្យធម្មនុញ្ញភាពនៃច្បាប់ជាបច្ចាកាល ២២៣

២-ការបកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ **២២៥**

៣-ការដោះស្រាយវិវាទនៃការចោះឆ្គោត **២២៧**

៤-សមត្ថកិច្ចផ្សេងៗ **២៣១**

ជ.អំពីការប្រជុំ **២៣២**

១-ការប្រជុំជាបឋម **២៣៣**

២-ការប្រជុំពេញអង្គ **២៣៣**

៣-អំពីការបញ្ចោញ្ចមតិ **២៣៤**

៤-អំពីការខានមកប្រជុំ **២៣៥**

៥-អំពីការជាក់ឥន័យ **២៣៥**

ឈ.ឥសមិតភាពនៃក្រុមប្រឹក្សាធម្មនុញ្ញ **២៣៧**

ញ.អត័យឯកសិទ្ធិ (Immunity) **២៣៨**

ដ.ឋានៈ និងបុព្វសិទ្ធិ **២៣៩**

ឋ.អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ **២៣៩**

១-សញ្ញាណទូទៅ **២៣៩**

២-អគ្គលេខាធិការដ្ឋាន **២៣៩**

៣-ការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាន **២៤0**

៤-ឆ្នាំធី និងតារកិច្ចអគ្គលេខាធិការ **២៤១**

ផ្នែកទី៦ ..... **២៤៣**

សមាជជាតិ **២៤៣**

សេចក្តីផ្តើម

(Introduction)

ស្ថិតក្នុងបរិបទសាកលភាវូបនីយកម្ម បានធ្វើឲ្យព្រះរាជាណាចក្រកម្ពុជាមានការប្រែប្រួល និងមានភាពរីកចម្រើនយ៉ាងខ្លាំងក្លាទាំងផ្នែកនយោបាយទាំងផ្នែកសេដ្ឋកិច្ច។ សាកលភាវូបនីយកម្មបានរួមចំណែកយ៉ាងសំខាន់ក្នុងការផ្លាស់ប្តូរផ្នត់គំនិតប្រជាពលរដ្ឋខ្មែរ ក៏ដូចជាផ្នត់គំនិតអ្នកដឹកនាំខ្មែរគ្រប់លំដាប់ថ្នាក់ឲ្យមានការរៀបចំរបៀបរបបនៃការគ្រប់គ្រងរដ្ឋ តាមបែបផែនផ្សេងៗពីការប្រមូលផ្តុំ “មជ្ឈការ” មកជាការគ្រប់គ្រងរដ្ឋតាមបែបប្រជាធិបតេយ្យ “វិមជ្ឈការ” ដែលប្រកបដោយការទទួលខុសត្រូវខ្ពស់ និងការយកចិត្តទុកដាក់ខ្ពស់សមស្របនឹងបរិបទថ្មីនៃការរីកចម្រើនរបស់សង្គមខ្មែរនៅលើឆាកអន្តរជាតិ។

ព្រះរាជាណាចក្រកម្ពុជាយើង ពីដំណាក់កាលមួយ ទៅដំណាក់កាលមួយអ្នកដឹកនាំខ្មែរតែងតែខិតខំប្រឹងប្រែងឲ្យអស់លទ្ធភាពក្នុងការកសាងប្រទេសជាតិ ជាពិសេសការធ្វើកំណែទម្រង់ទៅលើស្ថាប័នសំខាន់ៗទាំងបីរបស់រដ្ឋ ដែលមានដូចជា ស្ថាប័ននយោបាយ ស្ថាប័នរដ្ឋបាល និងស្ថាប័នតុលាការ ដោយផ្អែកលើគោលដៅដ៏ចម្បងៗនៃកម្មវិធីកំណែទម្រង់លើ វិស័យច្បាប់ ប្រព័ន្ធយុត្តិធម៌ រដ្ឋបាល និងបណ្តាវិស័យផ្សេងៗទៀត រួមទាំងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជាផងដែរ ដែលរួមចំណែកការការពារសិទ្ធិមនុស្ស និងសេរីភាពបុគ្គល ការធ្វើទំនើបកម្មនៅក្នុងក្របខ័ណ្ឌច្បាប់ ដែលផ្តល់លទ្ធភាពឲ្យទទួលបាននូវព័ត៌មានអំពីច្បាប់ និងភាពយុត្តិធម៌ឲ្យកាន់តែប្រសើរឡើង ដើម្បីបង្កើននូវគុណភាពនៃដំណើរការប្រព្រឹត្តទៅនៃអង្គការរដ្ឋដែលពាក់ព័ន្ធទៅនឹងការពង្រឹងសេវាកម្មផ្នែកយុត្តិធម៌គឺអំណាចរបស់តុលាការ និងសេវាកម្មផ្នែកអយ្យការ ដែលបានរួមបញ្ចូលទៅជាយន្តការតែមួយ ដើម្បីធ្វើការដោះស្រាយវិវាទនានានៅក្នុងសង្គមតាមប្រព័ន្ធតុលាការ និងពង្រឹងវិស័យយុត្តិធម៌ឲ្យប្រសើរឡើង។

ការធ្វើកំណែទម្រង់ទាំងនេះ គឺក្នុងគោលដៅដើម្បីឲ្យក្លាយទៅជារដ្ឋមួយមានឯកភាពជាតិ មានសុខសន្តិភាព និងវឌ្ឍនភាពសង្គមជាតិសមស្របតាមលទ្ធិប្រជាធិបតេយ្យដូចបណ្តាប្រទេសជឿនលឿនក្នុងពិភពលោក។

យើងបានដឹងហើយថា **ស្ថាប័ននយោបាយ** គឺជាស្ថាប័នសំខាន់បំផុតដែលបានបង្កើតឡើងដើម្បីដឹកនាំ និងគ្រប់គ្រងប្រទេសជាតិទាំងមូល ហើយស្ថាប័នទាំងនេះ ជាអ្នករៀបចំសង្គមជាតិឲ្យមានសណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយល្អមានយុត្តិធម៌ក្នុងសង្គមជាតិ និងបង្កលក្ខណៈងាយស្រួលក្នុងការគ្រប់គ្រង សំដៅធ្វើយ៉ាងណាឲ្យការរស់នៅរបស់ប្រជាពលរដ្ឋមានសុខសន្តិភាពទាំងផ្លូវកាយ ទាំងផ្លូវចិត្ត និងប្រទេសជាតិរីកចម្រើនខ្លាំងក្លាដូចប្រទេសដទៃនៅក្នុងពិភពលោក។

ស្របតាមការរីកចម្រើន និងការវិវឌ្ឍរបស់សង្គមជាតិយើងបច្ចុប្បន្ន យើងជាអ្នកសិក្សាត្រូវតែយល់ដឹងអំពីស្ថាប័ននីមួយៗរបស់រដ្ឋឲ្យបានច្បាស់លាស់ ថាតើស្ថាប័នជាអ្វី?តើមានស្ថាប័នអ្វីខ្លះ? តើអង្គការណាជាអ្នកបង្កើត? ហើយស្ថាប័នបង្កើតឡើងយ៉ាងដូចម្តេចដែរ? តើស្ថាប័នបានបង្កើតឡើងចាប់តាំងពីពេលណាមក? ហើយវាមានការវិវឌ្ឍន៍ និងមានសារប្រយោជន៍អ្វីខ្លះ?

ចំពោះគោលបំណង នៃការបង្កើតស្ថាប័ននេះ គឺដើម្បីរៀបចំសង្គម ឲ្យមានសណ្តាប់ធ្នាប់ និងរបៀបរៀបរយល្អមានយុត្តិធម៌នៅក្នុងសង្គមជាតិ និងបង្កលក្ខណៈងាយស្រួលក្នុងការគ្រប់គ្រងរដ្ឋសំដៅធ្វើយ៉ាងណា ឲ្យការរស់នៅរបស់ប្រជាពលរដ្ឋមានសុខសន្តិភាពទាំងផ្លូវកាយទាំងផ្លូវចិត្ត។

ដើម្បីផ្តល់ឲ្យអ្នកសិក្សា និងអ្នកស្រាវជ្រាវបានយល់ដឹងអំពីទ្រឹស្តីទូទៅនៃស្ថាប័ន និងស្ថាប័ននយោបាយនៅព្រះរាជាណាចក្រកម្ពុជាចាប់តាំងពីមុនសម័យអង្គរ សម័យអង្គរ និងសម័យក្រោយៗរហូតមកដល់សម័យបច្ចុប្បន្ន។ ដើម្បីឲ្យអ្នកសិក្សា និងអ្នកស្រាវជ្រាវយល់ដឹងអំពីការបង្កើតស្ថាប័ននយោបាយពីដើមរហូតមកដល់បច្ចុប្បន្ន ធ្វើឲ្យយល់ដឹងសម័យកាលនីមួយៗថាតើគេបង្កើតស្ថាប័ននយោបាយសំខាន់ៗអ្វីខ្លះ? ហើយគេបង្កើតឡើងដើម្បីអ្វី? តើប្រទេសកម្ពុជាយើងដឹកនាំប្រទេសដោយផ្អែកលើស្ថាប័នទាំងនេះដែរឬទេ? ហើយដំណើរការប្រព្រឹត្តទៅនៃការដឹកនាំរដ្ឋពីសម័យមួយទៅសម័យមួយទៀតដោយផ្អែកលើចំណេះដឹងផ្នែកវិធានគតិយុត្ត ឬក៏ផ្អែកលើបទពិសោធន៍ដែលដូនតាយើងបន្សល់ទុកយើង? ហើយប្រទេសកម្ពុជានៅពេលមានវិបត្តិនយោបាយសង្គមម្តងៗ ថាតើគេត្រូវផ្អែកទៅលើមូលដ្ឋានអ្វីខ្លះ? ដើម្បីដោះស្រាយវិបត្តិនយោបាយទាំងអស់នោះ ហេតុផលនេះហើយ ដែលតម្រូវឲ្យខ្ញុំបាទចាំបាច់ត្រូវសរសេរសៀវភៅអំពីស្ថាប័ននយោបាយនៃព្រះរាជាណាចក្រកម្ពុជានេះឡើង។

ជាងនេះទៅទៀត គឺផ្តល់ផលប្រយោជន៍ដល់យើងជាអ្នកសិក្សា ដើម្បីធ្វើការប្រៀបធៀបពីការកកើតឡើងនៃប្រវត្តិស្ថាប័នខ្មែរ ពីសង្គមមួយទៅសង្គមមួយទៀត ព្រមទាំងភាពជោគជ័យ និងភាពអន់ថយ ថាតើបានកើតមានឡើងយ៉ាងដូចម្តេចខ្លះ? ដើម្បីធ្វើជាបទពិសោធន៍ក្នុងការដឹកនាំ និងការរៀបចំព្រមទាំងគ្រប់គ្រងប្រទេសជាតិឲ្យមានវឌ្ឍនភាព រីកចម្រើន ជឿនលឿនទៅថ្ងៃអនាគត។

ជំពូកទី១

ទ្រឹស្តីទូទៅអំពីស្ថាប័ន

(General Theory of Institutions)

ផ្នែកទី១

អំពីស្ថាប័ន

(Institutions)

ក.សញ្ញាណទូទៅ

(General notion)

សង្គមជាតិមួយ ឬរដ្ឋណាមួយអាចដំណើរការប្រព្រឹត្តទៅប្រកបដោយស្ថិរភាព សុខសន្តិភាព សណ្តាប់ធ្នាប់សាធារណៈ និងការអភិវឌ្ឍន៍ឲ្យបានល្អប្រសើរ គឺទាមទារឲ្យរដ្ឋទាំងនោះ ចូលរួមសកម្មភាពក្នុងការបង្កើតឲ្យមានស្ថាប័នធំៗសំខាន់ៗជាច្រើនគ្រប់បែបយ៉ាង ដើម្បីរៀបចំរបៀបរបបគ្រប់គ្រង និងដំណើរការប្រព្រឹត្តទៅនៃស្ថាប័នរដ្ឋទាំងនោះប្រកបដោយប្រសិទ្ធភាពខ្ពស់។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក៏បានចែងអំពីស្ថាប័នសំខាន់ៗជាច្រើន ដើម្បីឲ្យប្រជាពលរដ្ឋខ្មែរ អង្គការស្ថាប័នរដ្ឋ អាចអនុវត្តន៍ការងារឲ្យមានប្រសិទ្ធភាពខ្ពស់កសាងប្រទេសជាតិឲ្យមានសុខសន្តិភាព និងរីកចម្រើនរុងរឿងឡើងវិញ ដោយផ្អែកលើប្រព័ន្ធគ្រប់គ្រងតាមបែប “មជ្ឈការ” ហើយខិតខំពង្រឹងសមត្ថភាពរបស់ខ្លួន ព្រមទាំងការធ្វើកំណែទម្រង់ របបនយោបាយគ្រប់គ្រងរដ្ឋជាបន្តបន្ទាប់ រហូតដល់បានអនុវត្តនូវរបបនយោបាយថ្មីមួយតាមបែបប្រជាធិបតេយ្យ “**ទិមជ្ឈការ**”ប្រកបទៅដោយការយកចិត្តទុកដាក់ខ្ពស់ សមស្របបរិបទថ្មីនៃការរីកចម្រើនរបស់សង្គមជាតិនៅលើឆាកអន្តរជាតិ។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានប្តេជ្ញារក្សាការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី និងការអនុវត្តនយោបាយបង្រួបបង្រួមជាតិ ដើម្បីការពារឯកភាពជាតិ រក្សាបាននូវទំនៀមទម្លាប់ និងប្រពៃណីល្អរបស់ជាតិ។ រាជរដ្ឋាភិបាលកម្ពុជា ក៏ត្រូវការពារនីត្យានុកូលភាពជានាបានសណ្តាប់ធ្នាប់ល្អ និងសន្តិសុខសាធារណៈព្រមទាំងយកចិត្តទុកដាក់ជាអាទិភាពចំពោះសុខុមាលភាពជីវភាពរស់នៅរបស់ប្រជាពលរដ្ឋផងដែរ។

លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ បានធានានូវការគោរពសិទ្ធិមនុស្ស ការគោរពច្បាប់ និងការទទួលខុសត្រូវខ្ពស់ចំពោះដោគវាសនាអនាគតប្រទេសជាតិយើង ឲ្យបានឈានឡើងជាលំដាប់ ក្នុងការកសាង និងការអភិវឌ្ឍន៍ប្រទេសជាតិឲ្យរីកចម្រើនលូតលាស់សម្បូរុងរឿងជានិច្ចនិរន្តរ៍។

ខ.និយមន័យស្ថាប័ន

(Definition of Institutions)

ស្ថាប័ន គឺជារចនាសម្ព័ន្ធ ឬយន្តការនៃការរៀបចំ សណ្តាប់ធ្នាប់សាធារណៈ និងកិច្ចសហប្រតិបត្តិការក្នុងការគ្រប់គ្រងឥរិយាបទ ទៅលើនីតិបុគ្គលនីមួយៗនៅក្នុងសហគមន៍ទាំងនោះ។

ស្ថាប័ន គឺត្រូវបានបញ្ជាក់អំពីអត្ថន័យច្បាស់លាស់ ចំពោះតម្រូវការរបស់សង្គមដែលមានភាពជាអចិន្ត្រៃយ៍ ដែលកំណត់អំពីជីវភាពរស់នៅរបស់បុគ្គលម្នាក់ៗ និងគោលដៅច្បាស់លាស់ក្នុងការអនុវត្តនូវវិធានគតិយុត្តនានា ដើម្បីធានាដល់កិច្ចសហប្រតិបត្តិការក្នុងការគ្រប់គ្រងទៅលើឥរិយាបថនីមួយៗរបស់មនុស្សនៅក្នុងសង្គមជាតិ។[1]

ស្ថាប័ន គឺជាអង្គការដែលបានចូលរួមរៀបចំសណ្តាប់ធ្នាប់ឲ្យបានល្អប្រសើរឡើង ដើម្បីឲ្យសង្គមមួយមានអត្ថិភាព ក្នុងដំណើរការប្រព្រឹត្តទៅរបស់ខ្លួនឲ្យបានរលូន។[2]

ពាក្យថា"**ស្ថាប័ន**" ជាទូទៅសំដៅដល់ការអនុវត្តន៍ទៅលើទំនៀមទម្លាប់ឥរិយាបថសំខាន់ដែលមានលក្ខណៈដូចគ្នាទៅនឹងអង្គការរដ្ឋនានារបស់រដ្ឋាភិបាល និងការអនុវត្តន៍ទៅលើសេវាសាធារណៈនៅក្នុងសង្គម។

ស្ថាប័ន គឺជារចនាសម្ព័ន្ធនិងយន្តការនៃការរៀបចំសណ្តាប់ធ្នាប់សាធារណៈ និងរបៀបរបបនៃការគ្រប់គ្រងទៅលើមនុស្សទាំងឡាយនៅក្នុងសង្គមផងដែរ។[3]

ស្ថាប័ន គឺជាសារព័ន្ធនៃទម្រង់ ឬអង្គការសង្គមដែលបានបង្កើតឡើងដោយវិធានច្បាប់ ឬបង្កើតឡើងដោយទម្លាប់។[4]

---

[1] Durkheim,Emile {1895} "the Rules of sociological Method" 8th editions, pp.45.

"An **institution** is any structure or mechanism of social order and cooperation governing the behavior of a set of individuals within a given human community. Institutions are identified with a social purpose and permanence, transcending individual human lives and intention by enforcing rules that governs cooperative human behavior".

[2] Paul Foulquié, Vocabulaire des sciences sociales, PUF, 1ère édition, 1978. " Institution : Organisme ou organisation ordonnés à la bonne marche de l'existence sociale. Les institutions politiques, culturelles, charitables ...".

[3] The term "institution" is commonly applied to customs and behavior patterns important to a society, as well as to particular formal organizations of government and public service. As structures and mechanisms of social order among humans.

[4] Dictionnaire Le Robert d'aujourd'hui, ADAGP, Paris, 1997. " Les institutions : ensemble des formes ou organisations sociales établies par la loi ou la coutume. "

ស្ថាប័ន គឺជាគ្រឹះស្ថាន ឬជាអង្គភាពការងារមួយ ដែលបានបង្កើតឡើងដើម្បីដំណើរការប្រព្រឹត្តទៅឲ្យបានល្អប្រសើរ ដែលមានដូចជា សាលារៀន មន្ទីរពេទ្យ អង្គភាពកងទ័ព ឬវិហារសាសនាកាតូលិក។ល។

ស្ថាប័ន គឺជារចនាសម្ព័ន្ធមូលដ្ឋាននៃប្រទេសនីមួយៗ ដែលអនុញ្ញាតឲ្យមានការកំណត់នូវរបបនយោបាយមួយ គឺចំណុះក្រោមនីតិសាធារណៈពោលគឺស្ថាប័នសាធារណៈ។[5]

ស្ថាប័ន គឺជាអ្វីៗទាំងអស់ ដែលបានបង្កើតឡើង ដោយនីតិបុគ្គល ដោយក្រុមមនុស្ស ឬដោយរបបនយោបាយ ដោយអង្គការរដ្ឋណាមួយ ដែលរួមមាន បណ្តាស្ថាប័នជាតិ ស្ថាប័នអន្តរជាតិ ស្ថាប័នហិរញ្ញវត្ថុ ព្រមទាំងស្ថាប័ននយោបាយ ដែលមានរដ្ឋសភា និងព្រឹទ្ធសភា និងមានស្ថាប័នផ្សេងៗជាច្រើនទៀតរួមទាំងសាសនាផងដែរ។ល។[6]

ស្ថាប័ន គឺជាសារព័ននៃវិធានគតិយុត្តនានា ដែលបានបង្កើតឡើង ដើម្បីបំពេញតម្រូវការប្រយោជន៍សមូហភាព។ ជាអង្គការ ដែលសំដៅបំពេញតម្រូវការផលប្រយោជន៍ជាសមូហភាព ដែលមានដូចជា រដ្ឋាភិបាល រដ្ឋសភា ព្រឹទ្ធសភា អង្គការមូលនិធិ អាណាព្យាបាល គឺសុទ្ធសឹងជាស្ថាប័នទាំងអស់។

ស្ថាប័ន គឺជាសារព័ន្ធនៃទម្រង់ ឬរចនាសម្ព័ន្ធអង្គការនយោបាយ ដែលបានបង្កើតឡើងដោយច្បាប់ ឬដោយទម្លាប់ហើយត្រូវស្ថិតក្រោមនីតិសាធារណៈ។ ដូចជាស្ថាប័នប្រជាធិបតេយ្យ ស្ថាប័ននីតិប្បញ្ញត្តិ(ស្ថាប័នរដ្ឋសភា និងព្រឹទ្ធសភា)និងស្ថាប័ននីតិប្រតិបត្តិមានរដ្ឋាភិបាលជាដើម។

រួមសេចក្តីមកពាក្យថា "**ស្ថាប័ន**" គឺសំដៅដល់អង្គភាពការងារមួយ ដែលបានដំណើរការប្រព្រឹត្តទៅក្រោមវិធានគតិយុត្តមួយ ដែលបានបង្កើតឡើងដោយក្រុមមនុស្ស ដោយអង្គការរដ្ឋ ដើម្បីធ្វើការសម្របសម្រួលដល់ការគ្រប់គ្រងនៅក្នុងសង្គមនោះ ឬរដ្ឋនោះឲ្យមានការអភិវឌ្ឍន៍រីកចម្រើន និងជឿនលឿន ជាពិសេសការរៀបចំសណ្តាប់ធ្នាប់សាធារណៈ ឲ្យបានល្អប្រសើរ ហើយស្ថាប័នគឺ មិនសំដៅទៅលើអ្វីៗទាំងឡាយណា ដែលមានដូចជា ទីកន្លែង ទីតាំង អគារ ឬបុគ្គលម្នាក់ៗនៃអង្គភាពនោះទេ។

ពោលគឺ ស្ថាប័នសំដៅដល់ដំណើរការប្រព្រឹត្តទៅរបស់អង្គភាពការងារទាំងនោះដែលមានលក្ខណៈជាអរូបិយ ការដំណើរការប្រព្រឹត្តទៅរបស់អង្គភាពការងារណាមួយគឺហៅថា ស្ថាប័ន។

---

[5] Lexique des sciences sociales, dalloz, 6è édition, 1994. "**Institution**: Etablissement, corps constitué : école, armée, église … Structures fondamentales d'un pays permettant de définir un régime politique et relevant du droit public : institutions publiques. "

[6] Dictionnaire Les Petit Robert, nouvelle édition, 1993." Institution : La chose instituée (personne morale, groupement, régime) : Institutions nationales, internationales, financières, . Institutions politiques, religieuses, …"

ស្ថាប័នមួយ គឺជាអង្គភាពចាត់តាំងមួយដែលត្រូវបានបង្កើតឡើង សម្រាប់គោលដៅជាក់លាក់មួយ ជាទូទៅអង្គភាពស្រាវជ្រាវមួយ ឬស្ថាប័នស្រាវជ្រាវមួយ ត្រូវបានបង្កើតឡើងសម្រាប់ធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទជាក់លាក់ណាមួយ ហើយដែលស្ថាប័នមួយក៏អាចជាអង្គភាពប្រកបវិជ្ជាជីវៈមួយផងដែរ។[7]

គ.លក្ខខណ្ឌស្ថាប័ន

(Conditions of Institutions)

លក្ខខណ្ឌ ដែលអាចចាត់ទុកថាជាស្ថាប័នបានលុះត្រាតែអង្គភាពការងារដែលបង្កើតឡើងនោះគឺត្រូវតែមានរយៈពេលយូរអង្វែង ហើយមានលក្ខណៈជាអចិន្ត្រៃយ៍ និងស្ថិតស្ថេរព្រមទាំងមានរចនាសម្ព័ន្ធមួយសម្រាប់រៀបចំគ្រប់គ្រងច្បាស់លាស់។

អង្គភាពការងារទាំងឡាយណា ដែលបានបង្កើតឡើងក្នុងរយៈពេលខ្លី ហើយត្រូវរលាយបាត់ទៅវិញគេមិនអាចចាត់ទុកថាជាស្ថាប័ននោះទេ។

ឧទាហរណ៍ ដូចជា សភាធម្មនុញ្ញ ឬគណៈកម្មការជាតិរៀបចំការបោះឆ្នោតជាដើម គឺមិនចាត់ទុកថាជាស្ថាប័នទេ។

សភាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលបានបង្កើតឡើង ដោយប្រជាពលរដ្ឋខ្មែរតាមរយៈការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រទូទាំងប្រទេស នៅថ្ងៃទី២៣ ដល់ថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៣។ ក្រោយពីប្រកាសលទ្ធផល យើងទទួលបានតំណាងរាស្ត្រចំនួន១២០រូប ហើយតំណាងរាស្ត្រទាំង១២០រូប បានប្រែក្លាយទៅជាសភាធម្មនុញ្ញមួយនៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៩៣ សភាធម្មនុញ្ញក៏បានបង្កើតគណៈកម្មការអចិន្ត្រៃយ៍មួយ ដើម្បីរៀបរៀងរដ្ឋធម្មនុញ្ញ រដ្ឋធម្មនុញ្ញមួយត្រូវបានអនុម័តដោយសភាធម្មនុញ្ញនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣។ ហើយសភាធម្មនុញ្ញត្រូវរលាយបាត់ទៅវិញ នៅពេលដែលរដ្ឋធម្មនុញ្ញថ្មីមួយបានចូលជាធរមាន នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) ត្រូវបានបង្កើតជាគណៈកម្មការជាច្រើនឡើងជារៀងរាល់៥ឆ្នាំម្តងដើម្បីរៀបចំការបោះឆ្នោតជាសាកល។ ក្រោយពី(គ.ជ.ប)បានបង្កើតគណៈកម្មការរួចហើយ ត្រូវបានរៀបចំធ្វើការបោះឆ្នោត ដើម្បីឲ្យមានដំណើរការល្អ រហូតដល់ការប្រកាសលទ្ធផលនៃការបោះឆ្នោតជាផ្លូវការហើយ ទើបគណៈកម្មការជាតិរៀបចំការបោះឆ្នោតនេះត្រូវរលាយបាត់ទៅវិញ ដូចនេះគណៈកម្មការទាំងនេះមិនចាត់ទុកថាជាស្ថាប័នទេ។

[7] An **institute** is an organisational body created for a certain purpose. Often they are research organisations (research institutions) created to do research on specific topics. An institute can also be a professional body.

ផ្នែកទី២

ប្រវត្តិនៃការកកើតស្ថាប័ន

(History of Institutions)

ក សញ្ញាណទូទៅ

(General notion)

ស្ថាប័ន គឺជាកម្មវត្ថុដ៏ចម្បងមួយនៃការសិក្សាអំពីវិទ្យាសាស្ត្រសង្គម ដែលរួមមានដូចជា: វិទ្យាសាស្ត្រនយោបាយ សេដ្ឋកិច្ច ច្បាប់ នរវិទ្យា សង្គមវិទ្យា ហើយត្រូវបានលោក Durkheim [8] ពិពណ៌នាថា ការសិក្សាអំពីស្ថាប័ន គឺជាវិទ្យាសាស្ត្រមួយ ដែលជាការសិក្សាទៅលើដំណើរការប្រព្រឹត្តទៅនៃការកកើតឡើងរបស់អង្គភាពការងារមួយ ឬគឺជាដំណើរការប្រព្រឹត្តទៅទាំងមូលរបស់អង្គការស្ថាប័នទាំងនោះ។

ស្ថាប័ន គឺជាក្តីកង្វល់ដ៏សំខាន់មួយ ដែលទាក់ទងទៅនឹងវិស័យគតិយុត្ត របបនយោបាយ គ្រប់គ្រងរដ្ឋ និងទាក់ទងទៅនឹងយន្តការជាផ្លូវការនានា ដែលបានបង្កើតឡើង សម្រាប់រៀបចំនូវគោលនយោបាយរបស់រដ្ឋ នៅក្នុងដំណើរការរៀបចំតាក់តែងច្បាប់ និងការអនុវត្តច្បាប់ទាំងឡាយឲ្យមានប្រសិទ្ធភាពខ្ពស់។

ពាក្យ“**ស្ថាប័ន**”(Institution) គឺមានប្រភពដើមចេញមកពីពាក្យឡាតាំង“Institutum” ដែលមានន័យថា “មធ្យោបាយ” ឬ“ទម្លាប់” និងពាក្យថា “Instituere” គឺមានន័យថា “កសាង” “បង្កើត” “លើកឡើង” ឬ“អប់រំ”។[9]

បើពិនិត្យមើលទៅលើប្រវត្តិសាស្ត្រនៃពិភពលោកយើងនេះ គេសង្កេតឃើញថាស្ថាប័នបានកើតមានឡើង ជាយូរមកហើយនៅក្នុងសង្គមមនុស្ស ក៏ប៉ុន្តែវាមានលក្ខណៈខុសគ្នាក្នុងការរៀបចំ និងដំណើរការប្រព្រឹត្តទៅរបស់ស្ថាប័ននីមួយៗដែលបានបង្កើតឡើង គឺអាស្រ័យទៅលើស្ថានភាពសង្គម និងរបបនយោបាយសង្គម។

ហេតុនេះ យើងអាចបែងចែកស្ថាប័នជាពីរសម័យកាលគឺ:

-ស្ថាប័នសម័យដើម

-ស្ថាប័នសម័យទំនើប

---

[8] Durkheim birth in Epinal,Franc.April 15, 1858, Death 15 November1917.He was Sociologist.

[9] The word "institution" comes from the Latin word ***institutum*** meaning "facility" or "habit"; from ***instituere*** meaning "build", "create", "raise" or "educate".

ខ-ស្ថាប័នសម័យដើម

(Pre-era of Institutions)

ស្ថាប័នសម័យដើម គឺជាស្ថាប័នទាំងឡាយណាដែលបានបង្កើតឡើង ដោយពឹងផ្អែកតែទៅលើទំនៀមទំលាប់ប្រពៃណីបុព្វបុរសរបស់ពួកគេដែលបានបន្សល់ទុក ឬតាមរយៈការអនុវត្តន៍ជាក់ស្តែងដែលឪពុកបានបន្សល់ទុកឲ្យកូនចៅតៗគ្នារៀងមក ហើយស្ថាប័នទាំងនេះ បានបង្កើតឡើងគឺមិនអាស្រ័យទៅលើលិខិតបទដ្ឋានគតិយុត្ត ឬមិនអាស្រ័យលើនីតិវិធីច្បាប់ ឬមិនអាស្រ័យលើរដ្ឋធម្មនុញ្ញ ឬមិនអាស្រ័យលើអង្គការរដ្ឋណាមួយជាអ្នកបង្កើតឡើងឡើយ។

ស្ថាប័នសម័យដើម គឺគេសង្កេតឃើញថា អ្នកដឹកនាំតែងបានផ្តោតជាសំខាន់ទៅលើការគ្រប់គ្រងប្រទេសឲ្យបានរឹងមាំដោយពឹងផ្អែកទៅលើស្ថាប័នធំៗពីរគឺ:

-ស្ថាប័ននយោបាយ (Political Institutions)

-ស្ថាប័នរដ្ឋបាល (Administrative Institutions)

ដូចនេះ គេអាចនិយាយបានថា សង្គមមនុស្សបានរៀបចំឲ្យមានស្ថាប័ននេះឡើង គឺដើម្បីជានាបាននូវស្ថិរភាពក្នុងការគ្រប់គ្រងឲ្យមានរបៀបរៀបរយសង្គម និងដំណើរការប្រព្រឹត្តទៅរបស់សង្គមជាតិតាំងពីយូរលង់ណាស់មកហើយ។

គ-ស្ថាប័នសម័យទំនើប

(Modern era of Institutions)

ស្ថាប័នសម័យទំនើប គឺជាស្ថាប័នទាំងឡាយណាដែលបានបង្កើតឡើង ដោយនីតិបុគ្គលអាស្រ័យដោយអង្គការរដ្ឋមានសមត្ថកិច្ចបង្កើតឡើង ដោយផ្អែកលើបែបបទ និងតាមនីតិវិធីច្បាប់ច្បាស់លាស់ ជាពិសេសការបង្កើតឡើងតាមរយៈរដ្ឋធម្មនុញ្ញ (គឺមិនបង្កើតឡើងតាមរយៈទំនៀមទម្លាប់ ឬប្បវេណីនោះទេ)។

តាមរយៈនៃការវិវឌ្ឍន៍របស់សង្គមជាតិ បច្ចេកទេសដែលជាវិទ្យាសាស្ត្រទំនើបៗ ត្រូវបានគេកំណត់យ៉ាងច្បាស់លាស់អំពីលក្ខខណ្ឌ និងសមត្ថកិច្ចរបស់ស្ថាប័នដោយមានការបកស្រាយពីអង្គការអន្តរជាតិនានា ហើយបានការរៀបចំជាច្បាប់ និងធាតុផ្សំផ្សេងៗ ក្នុងការបង្កើតស្ថាប័ននានា ដើម្បីបញ្ជាក់ឲ្យកាន់តែច្បាស់ថែមទៀត។

ជាទូទៅនៅក្នុងរដ្ឋធម្មនុញ្ញសុទ្ធសឹងបានចែងយ៉ាងច្បាស់លាស់អំពីស្ថាប័ន ដែលក្នុងនោះគេបានបង្កើតឲ្យមានស្ថាប័នតិច ឬច្រើន គឺអាស្រ័យទៅដោយរបបនយោបាយសង្គម ការគ្រប់គ្រងរដ្ឋ និងអ្នកដឹកនាំរដ្ឋ។

ផ្នែកទី៣

អំពីប្រភេទស្ថាប័ន

(Types of Institutions)

នៅក្នុងពិភពលោកយើងនេះ បណ្តារដ្ឋនីមួយៗបានបង្កើតស្ថាប័នជាច្រើនគ្រប់បែបយ៉ាង ដើម្បីយកមកគ្រប់គ្រងដឹកនាំរដ្ឋទាំងនោះឲ្យមានការអភិវឌ្ឍន៍ និងរីកចម្រើនរុងរឿង។ការណ៍នេះ ដើម្បីគ្រប់គ្រងក្នុងជាតិ និងអន្តរជាតិប្រកបទៅដោយរបៀបរៀបរយសណ្តាប់ធ្នាប់ល្អគឺចាំបាច់ត្រូវបង្កើតឲ្យមានស្ថាប័ន ហេតុនេះគេអាចចែកស្ថាប័នធំៗជា២ប្រភេទគឺ:

-ស្ថាប័នអន្តរជាតិ (International Institutions)

-ស្ថាប័នជាតិ (National Institutions)

ក-ស្ថាប័នអន្តរជាតិ

(International Institutions)

ស្ថាប័នអន្តរជាតិ គឺជាកន្សោមមួយនៃរចនាសម្ព័ន្ធ និងយន្តការនានា ដែលមានលក្ខណៈផ្លូវច្បាប់ ហើយបានភ្ជាប់ទៅបណ្តាទំនាក់ទំនងអន្តរជាតិទាំងឡាយ រវាងរដ្ឋនឹងរដ្ឋ ទៅនឹងសហគមន៍អន្តរជាតិ។[10]

ស្ថាប័នអន្តរជាតិ គឺជាស្ថាប័នដែលបានបង្កើតឡើង ដោយបណ្តាប្រទេសជាច្រើន ដែលបានផ្តួចផ្តើមគំនិតរួមគ្នាដោយឈរលើគោលការណ៍រួមទិសដៅ និងមាគ៌ាគតិយុត្តជាមូលដ្ឋាន។ ស្ថាប័នអន្តរជាតិត្រូវបានបែងចែកជា២ទៀតគឺ:

-ស្ថាប័នអន្តរជាតិសាធារណៈ(International Public Institutions)

-ស្ថាប័នអន្តរជាតិឯកជន (International Private Institutions)

១.ស្ថាប័នអន្តរជាតិសាធារណៈ

(International Public Institutions)

ស្ថាប័នអន្តរជាតិសាធារណៈ គឺសំដៅដល់ដំណើរការប្រព្រឹត្តទៅនៃអង្គការអន្តរជាតិមួយជាស្ថាប័នអន្តរជាតិមួយ ដែលបង្កើតឡើង ដោយបណ្តាប្រទេសជាច្រើនរួមគ្នា ហើយបានបង្កើតទៅជាអង្គការអន្តរជាតិនានាជាច្រើន ដែលស្ថាប័នអន្តរជាតិទាំងនេះបានរៀបចំ និងដំណើរការប្រព្រឹត្តទៅដោយពឹងផ្អែកទៅលើឆន្ទៈរួមគ្នា តាមរយៈកិច្ចសហប្រតិបត្តិការនានា រវាងបណ្តារដ្ឋទាំងឡាយដែលជាសមាជិក។

---

[10] ខៀវ ថវិកា ស្ថាប័នអន្តរជាតិ បោះពុម្ពឆ្នាំ១៩៩៧ ទំព័រ២។

ស្ថាប័នទាំងនេះអាចដំណើរប្រព្រឹត្តទៅបានល្អប្រសើរ ដោយពឹងផ្អែកទៅលើការបង់មូលនិធិពីបណ្តាសមាជិកទាំងអស់នៃអង្គការ ដែលបណ្តារដ្ឋនានាត្រូវបង់វិភាគទានជារៀងរាល់ឆ្នាំ។

ឧទាហរណ៍: អង្គការសហប្រជាជាតិUN បានបង្កើតស្ថាប័នសំខាន់ៗ រហូតដល់៦ ស្ថាប័ន ដែលធ្វើឲ្យអង្គការនេះរឹងមាំ និងស្ថិតស្ថេររហូតមកដល់សព្វថ្ងៃ។

២.ស្ថាប័នអន្តរជាតិឯកជន

(International Private Institutions)

ស្ថាប័នអន្តរជាតិឯកជន គឺជាស្ថាប័នអន្តរជាតិមួយ ដែលត្រូវបានបង្កើតឡើងដោយបុគ្គលឯកជនដែលមានការចូលរួមពីបុគ្គលឯកជននានា ឬពីបណ្តាអ្នកស្ម័គ្រចិត្តនានា ឬពីក្រុមមនុស្សដែលមកពីបណ្តាប្រទេសជាច្រើនរួមគ្នាបង្កើតឡើង គឺដើម្បីបម្រើផលប្រយោជន៍មនុស្សទូទៅ ឬដើម្បីបម្រើមនុស្សជាតិទាំងមូល។

ស្ថាប័នទាំងនេះ អាចដំណើរការប្រព្រឹត្តទៅបានល្អប្រសើរ អាស្រ័យដោយមានការចូលរួមពីអ្នកស្ម័គ្រចិត្ត សប្បុរសធម៌ ពីអង្គការអន្តរជាតិធំៗ បានផ្តល់មូលនិធិយ៉ាងច្រើនដើម្បីដំណើរការបុគ្គលិកនៃអង្គការនេះត្រូវទទួលបានប្រាក់បៀវត្សរ៍ពីអង្គការ ឬស្ថាប័នអន្តរជាតិឯកជន ដែលមូលនិធិទាំងនេះបានមកពីសមាជិកនៃអង្គការនេះ ឬពីសប្បុរសជននានានៃបណ្តាប្រទេសជាច្រើននៅលើពិភពលោក។

ឧទាហរណ៍ គ្រូពេទ្យគ្មានព្រំដែន ឬអង្គការកាកបាទក្រហមអន្តរជាតិ ឬអង្គការសាសនាកាតូលិកជាដើម។

ខ-ស្ថាប័នជាតិ

(National Institutions)

ស្ថាប័នជាតិ គឺជាស្ថាប័ន ដែលបានបង្កើតឡើងនៅក្នុងរដ្ឋមួយ ជាទូទៅរដ្ឋនីមួយៗ ឬជាតិនីមួយៗ តែងតែមានស្ថាប័នរៀងៗខ្លួន ក៏ប៉ុន្តែស្ថាប័នពុំមានដូចគ្នាទាំងអស់នោះទេ។

កាលណាសង្គមជាតិកាន់តែរីកចម្រើនលូតលាស់ និងជឿនលឿននោះស្ថាប័នកាន់តែរីកចម្រើន នឹងកាន់តែស្មុគស្មាញផងដែរ ប៉ុន្តែស្ថាប័នមានច្រើនប្រភេទខុសៗគ្នា អាស្រ័យទៅតាមតម្រូវការរបស់អ្នកដឹកនាំរដ្ឋ និងរបស់សង្គមនីមួយៗផងដែរ ក៏ប៉ុន្តែ យើងអាចបែងចែកស្ថាប័នជាតិទាំងនោះជាពីរផ្នែកធំៗគឺ:

-ស្ថាប័នជាតិឯកជន(National Private Institutions)

-ស្ថាប័នជាតិសាធារណៈ(National Public Institutions)

១.ស្ថាប័នជាតិឯកជន

(National Private Institutions)

ស្ថាប័នជាតិឯកជន គឺជាស្ថាប័នមួយ ដែលបានបង្កើតឡើង ដោយបុគ្គលឯកជន បុគ្គលស្ម័គ្រចិត្តឯកជនដទៃទៀតចូលរួមគ្នាបង្កើតឡើងនៅក្នុងរដ្ឋមួយ ឬជាតិណាមួយដើម្បីទទួលបាននូវអង្គការមួយ ឬអង្គភាពមួយ នៅពេលអង្គការ ឬអង្គភាពនោះចាប់ផ្តើមដំណើរការ ទើបគេអាចហៅអង្គការ ឬអង្គភាពនោះថា ជាស្ថាប័ន ដោយអង្គការ ឬអង្គភាពនោះបានបង្កើតឡើងដោយបុគ្គលឯកជន ទើបគេហៅស្ថាប័ននោះថា ជាស្ថាប័នឯកជន។ ហើយស្ថាប័នទាំងនេះអាចដំណើរការប្រព្រឹត្តទៅដោយអង្គភាពការងារនីមួយៗមានរចនាសម្ព័ន្ធមួយច្បាស់លាស់ គឺក្នុងគោលដៅធ្វើយ៉ាងណា ដើម្បីធ្វើការអភិវឌ្ឍន៍ឲ្យមានភាពរីកចម្រើនប្រសើរឡើង។

ឧទាហរណ៍: សមាគមន៍ ក្រុមហ៊ុន ឬអង្គការមិនមែនរដ្ឋាភិបាលជាដើម។ល។

២.ស្ថាប័នជាតិសាធារណៈ

(National Public Institutions)

ស្ថាប័នជាតិសាធារណៈ គឺជាស្ថាប័នមួយ ដែលបានបង្កើតឡើង ដោយផ្អែកលើមូលដ្ឋានគតិយុត្តណាមួយ ឬផ្អែកលើអត្ថបទជាគោលច្បាប់ណាមួយ ជាពិសេស ស្ថាប័នទាំងឡាយនោះត្រូវបានបង្កើតឡើងដោយរដ្ឋ ឬដោយរដ្ឋធម្មនុញ្ញ ហើយស្ថាប័នទាំងអស់នោះសុទ្ធសឹងមានចែងនៅក្នុងច្បាប់រដ្ឋធម្មនុញ្ញរបស់រដ្ឋណាមួយជាកំណត់ ដែលបណ្តារដ្ឋនីមួយៗ តែងតែបង្កើតឲ្យមានស្ថាប័នសាធារណៈទៅជា៣ស្ថាប័នធំៗគឺ:

-ស្ថាប័ននយោបាយ

(Political Institutions)

-ស្ថាប័នរដ្ឋបាល

(Administrative Institutions)

-ស្ថាប័នតុលាការ

(Judicial Institutions)

ជំពូកទី២

ស្ថាប័ននយោបាយ

(Political Institutions)

ស្ថាប័ននយោបាយ គឺជាអង្គការរដ្ឋនានា ដែលបានបង្កើតឡើងដើម្បីប្រតិបត្តិ និងអនុវត្តច្បាប់ ដែលធ្វើការសម្របសម្រួលលើបញ្ហានានា ក្នុងការបង្កើតគោលនយោបាយរបស់រដ្ឋាភិបាលស្តីអំពីប្រព័ន្ធសេដ្ឋកិច្ច និងប្រព័ន្ធសង្គម ហើយម្យ៉ាងវិញទៀត ស្ថាប័ននេះ ក៏បានផ្តល់អ្នកតំណាងដល់ប្រជាពលរដ្ឋផងដែរ។

ឧទាហរណ៍:ស្ថាប័ននយោបាយរួមមាន គណបក្សនយោបាយ អង្គការនីតិប្បញ្ញត្តិមានរដ្ឋសភា និងព្រឹទ្ធសភា និងអង្គការនីតិប្រតិបត្តិមានរដ្ឋាភិបាលជាដើម ...។

ស្ថាប័ននយោបាយ អាចសំដៅទៅលើរចនាសម្ព័ន្ធចាត់តាំងនៃវិធានច្បាប់នានា និងគោលការណ៍ទាំងឡាយ ដែលបានប្រតិបត្តិការនៅក្នុងអង្គការស្ថាប័ននានាខាងលើ ដែលរួមមានគោលការណ៍មួយចំនួនដូចជា សិទ្ធិបោះឆ្នោត ការទទួលខុសត្រូវរបស់រដ្ឋាភិបាល និងការធានាខុសត្រូវដោយអង្គការរដ្ឋផ្សេងៗទៀត។[11]

ជារួមស្ថាប័ននយោបាយ គឺជាស្ថាប័ននានា ឬអង្គការរដ្ឋទាំងឡាយណា ដែលមានសមត្ថកិច្ចគ្រប់គ្រាន់ក្នុងការសម្រេចនូវរាល់កិច្ចការធំៗទាំងឡាយរបស់ជាតិ ហើយដែលកិច្ចការទាំងអស់នោះទាក់ទងទៅនឹងអាយុជីវិតរបស់ប្រទេសជាតិទាំងមូល។ ស្ថាប័ននយោបាយទាំងនោះរួមមាន:

- ស្ថាប័នព្រះមហាក្សត្រ(King Institution)
- ស្ថាប័ននីតិប្រតិបត្តិ(រាជរដ្ឋាភិបាល)(Executive Institution)
- ស្ថាប័ននីតិប្បញ្ញត្តិ (រដ្ឋសភា និងព្រឹទ្ធសភា)(Legislative Institution)
- ក្រុមប្រឹក្សាធម្មនុញ្ញ (តុលាការធម្មនុញ្ញ) (Constitutional Council)

---

[11] African history by Alistair Boddy-Evans,Definition "**Political institutions** are organizations which create, enforce, and apply laws; that mediate conflict; make (governmental) policy on the economy and social systems, otherwise provide representation for the populous. Examples of such political institutions include political parties, national assembly, and the government or the executive body and so on. The term 'Political Institutions' may also refer to the recognized structure of rules and principles within which the above organizations operate, including such concepts as the right to vote, responsible government, and accountability".

ជំពូកទី៣

ស្ថាប័នខ្មែរសម័យដើម

(Pre-era of Khmer Institutions)

ផ្នែកទី១

ស្ថាប័ននយោបាយមុនសម័យអង្គរ

(Political Institutions of Pre-Angkor Era)

ក.ព្រះមហាក្សត្រ

(King)

នៅសម័យនោះ ប្រទេសកម្ពុជាមានឈ្មោះថា "អាណាចក្រភ្នំ" ដែលមាន ព្រះមហាក្សត្រជាអ្នកដឹកនាំ ការគ្រប់គ្រងប្រទេសជាតិនៅសម័យនោះត្រូវបានរៀបចំនយោបាយឡើង តាមបែបបទប្រទេសឥណ្ឌា។ ព្រះរាជាតែងតែយកភ្នំ ធ្វើជាទីកន្លែងសក្ការបូជា ចំពោះព្រះមហេស្វរៈ គឺជាឈ្មោះព្រះឥសូរ ដែលបានសណ្ឋិតនៅលើភ្នំ និងមានតម្កល់លិង្គព្រះឥសូរនោះផងដែរ។

ការប្រណិបត្តិទាំងអស់នេះគឺដើម្បីឲ្យព្រះរាជាមានឋានៈជា ស្តេចភ្នំ ដែលជាអ្នកតំណាងឲ្យព្រះអាទិទេព ដែលធ្វើឲ្យស្តេចមានសិទ្ធិអំណាចខ្លាំងក្លាដូចជាព្រះអាទិទេពដែរ។[12]

ការគ្រប់គ្រងអាណាចក្រភ្នំនៅសម័យនោះ ព្រះមហាក្សត្រតែងតែធ្វើឲ្យប្រទេសជាតិមានភាពខ្លាំងក្លា ទឹកដីរីកធំទូលំទូលាយ ដោយការអនុវត្តន៍នយោបាយវាតទីពង្រីកទឹកដី ដោយវាយយកបណ្តាប្រទេសជិតខាងជាក់ធ្វើជាចំណុះ ព្រមទាំងចាប់យកទាហានទាំងនោះ ធ្វើជាឈ្លើយសឹកមកធ្វើជាទាសកររទៀតផង។

នៅក្នុងអាណាចក្រភ្នំប្រទេសកម្ពុជាគឺជាអធិរាជនៃអាណាចក្រ(King of empire) ដែលមានព្រះមហាក្សត្រ មានឋានៈជាស្តេចភ្នំ ជាមហារាជ និងជាស្តេចចក្រវាឡ ដែលមានរដ្ឋចាម រដ្ឋម៉ន រដ្ឋម៉ាឡាយូជាដើមជារដ្ឋចំណុះ ឬជាសមន្តរដ្ឋ។

ហេតុនេះហើយបានជាគេនិយាយថាអាណាចក្រភ្នំគឺជាអធិរាជនៃអាណាចក្រ ហើយព្រះមហាក្សត្រមានឋានៈជាមហារាជ ឬជាស្តេចចក្រវាឡ ដែលប្រទេសស្ថិតនៅក្រោមអំណាចអាណាចក្រភ្នំទាំងអស់ត្រូវតែនាំសួយសារអាករមកថ្វាយដល់ព្រះរាជាជារៀងរាល់ឆ្នាំ។

ព្រះរាជាខ្មែរនៅសម័យនោះ មានអំណាចទូលំទូលាយណាស់ បើសិនព្រះរាជាទ្រង់ចង់សម្រេចអ្វីៗហើយគឺគ្មាននរណាម្នាក់ហ៊ានជំទាស់ ឬប្រឆាំងឡើយ។

---

[12] ព្រះអាទិទេពធំៗមានបីគឺព្រះព្រហ្ម ព្រះនរាយណ៍(ព្រះវិស្ណុ) និងព្រះសិវៈ(ព្រះឥសូរ)។

ព្រះមហាក្សត្រ នៅមានព្រះរាជបរិវារ និងមន្ត្រីជាន់ខ្ពស់ នៅអមខាងឆ្វេងខាងស្តាំជាច្រើនទៀត ដែលមន្ត្រីនៅអមខាងស្តាំមានឋានៈធំជាងមន្ត្រីនៅអមខាងឆ្វេង ក្រៅពីនេះ នៅមានមន្ត្រីបរិវារជាច្រើននាក់ទៀត ដែលបានជួយដល់ព្រះមហាក្សត្រក្នុងការគ្រប់គ្រងអាណាចក្រទាំងមូល។[13]

ក្នុងវិស័យនយោបាយក្រៅប្រទេស អាណាចក្រភ្នំ បានចងស្ពានមេត្រីជាមួយប្រទេសធំៗ ដូចជា ប្រទេសឥណ្ឌា និងប្រទេសចិនដែលការធ្វើទំនាក់ទំនាក់អន្តរជាតិនេះសម្រាប់វិស័យដូចជា វិស័យនយោបាយ ពាណិជ្ជកម្ម និងវប្បធម៌។[14]

ចំណែកវិស័យតុលាការវិញ មិនមានលក្ខណៈច្បាស់លាស់ទេ អ្វីគ្រប់យ៉ាង គឺអាស្រ័យលើតែព្រះរាជាមួយអង្គគត់ សម្រាប់ប្រជារាស្ត្រធម្មតាវិញគឺគេផ្អែកលើអបិយជំនឿ ដូចជា បើមានអ្នកបាត់របស់របរអ្វីមួយ អ្នកបាត់ត្រូវយកបាយមួយពំនូតទៅដាក់នៅចំពោះព្រះភក្ត្រទេព្តារួចបន់ស្រន់អង្វរសុំឲ្យព្រះអង្គជួយបង្ហាញមុខជនទុច្ចរិត។ ស្អែកឡើងគេយកបាយទាំងនោះ ចែកឲ្យអ្នកបម្រើនៅក្នុងផ្ទះដើម្បីបរិភោគ នៅក្នុងមាត់ចោរនឹងមានហូរឈាមចេញយ៉ាងជាក់ស្តែង ចំណែកអ្នកល្អគឺញ៉ាំទៅមិនមានបញ្ហាអីកើតមានឡើងនោះទេ។[15]

ខ.ការគ្រងរាជសម្បត្តិ

(Reigns)

ការគ្រងរាជសម្បត្តិ ជាទូទៅធ្វើឡើងតាមរយៈរាជទាយាទ ដែលជាអ្នកស្នងរាជ្យបន្តពីព្រះរាជបិតា ហើយបានផ្ទេរទៅឲ្យរាជបុត្រណាមួយ គឺអាស្រ័យទៅដោយព្រះរាជាសព្វព្រះរាជហឫទ័យ បាននិយាយថា ការឡើងគ្រងរាជសម្បត្តិអាស្រ័យលើព្រះរាជាតែមួយអង្គឯងប៉ុណ្ណោះ ព្រះរាជាចង់តែងតាំងព្រះរាជបុត្រអង្គណាឡើងសោយរាជ្យក៏បានដែរប៉ុន្តែប្រសិនបើព្រះរាជាមិនមានព្រះរាជបុត្រា ដើម្បីឡើងសោយរាជ្យទេ គឺប្រជារាស្ត្រ និងនាមីនមន្ត្រីទាំងអស់ អាចលើកឲ្យមន្ត្រីធំណាម្នាក់ឲ្យឡើងសោយរាជ្យជំនួសព្រះមហាក្សត្របាន។

នៅអាណាចក្រភ្នំប្រទេសខ្មែរយើងបានកសាងអរិយធម៌មួយដ៏ត្រចះត្រចង់អស្ចារ្យ ហើយមានលក្ខណៈខ្ពង់ខ្ពស់ជាងអរិយធម៌ជនជាតិជិតខាងនៅក្នុងសម័យនោះ ទោះបីជាអរិយធម៌នោះពុំទាន់មានលក្ខណៈជាតិនិយមពិតប្រាកដនៅឡើយក៏ដោយ ក៏វាជាមរតកមួយដ៏សំខាន់សម្រាប់កូនចៅជំនាន់ក្រោយផងដែរ។

---

[13] តាមឯកសារប្រវត្តិវិទ្យា បោះពុម្ពផ្សាយដោយក្រសួងអប់រំឆ្នាំ១៩៩៤ ទំព័រ១៣។

[14] ត្រឹងងា ប្រវត្តិសាស្ត្រខ្មែរ បោះពុម្ពឡើងវិញ ដោយក្រសួងអប់រំ ឆ្នាំ២០០៣ ទំព័រ១០១។

[15] ត្រឹងងា ប្រវត្តិសាស្ត្រខ្មែរ បោះពុម្ពឡើងវិញ ដោយក្រសួងអប់រំ ឆ្នាំ២០០៣ ទំព័រ៩៩។

ផ្នែកទី២

ស្ថាប័ននយោបាយសម័យអង្គរ

(Political Institutions during Angkor Era)

ក.ព្រះមហាក្សត្រ

(King)

នៅសម័យអាណាចក្រអង្គរ ព្រះមហាក្សត្រមុននឹងឡើងគ្រងរាជសម្បត្តិ គេតែងតែប្រារព្ធធ្វើពិធីទេវរាជ ការប្រារព្ធពិធីនេះ គឺធ្វើឡើងដើម្បីឲ្យព្រះរាជាមានឋានៈស្មើនឹងអាទិទេព។

ព្រះរាជា តែងតែបានតាំងខ្លួនជាតំណាងឲ្យទេវៈ ឬអាទិទេពគ្រប់គ្រងនៅលើដែនដីដ៏ធំទូលាយ ព្រះរាជាខ្មែរ គឺជាម្ចាស់របស់ប្រជារាស្ត្រខ្មែរទាំងមូល នៅពេល ព្រះរាជាសោយទិវង្គតទៅ ព្រះអង្គត្រូវយាងទៅគង់នៅជាមួយអាទិទេព ដែលមានប្រាសាទភ្នំសម្រាប់តម្កល់លិង្គទេវរាជ។ ហើយប្រាសាទភ្នំនេះ នឹងក្លាយទៅជាផ្នូររបស់ព្រះមហាក្សត្រ សម្រាប់តម្កល់វិញ្ញាណអាទិទេពរបស់ព្រះអង្គតែមួយអង្គគត់។[16]

ខ.ការគ្រងរាជសម្បត្តិ

(Reigns)

ការឡើងគ្រងរាជសម្បត្តិ គឺធ្វើឡើងតាមរយៈរាជទាយាទដែលជាអ្នកត្រូវស្នងរាជ្យបន្តអំពីព្រះរាជបិតា ហើយការផ្ទេររាជសម្បត្តិត្រូវធ្វើតាមទំនៀមទម្លាប់ប្រពៃណីខ្មែរ ដែលត្រូវតែផ្ទេរទៅឲ្យបុត្រាច្បង ក៏ប៉ុន្តែបើសិនជាមិនមានព្រះរាជបុត្រាដើម្បីឡើងគ្រងរាជសម្បត្តិបន្តទេនោះ សព្វមុខមន្ត្រី ឬញាតិវង្សអាចលើក រាជវង្សានុវង្សណាម្នាក់ឲ្យឡើងសោយរាជ្យបន្តបាន។ ក្នុងករណីព្រះរាជាមានព្រះជន្មក្មេងពេក ព្រះរាជកិច្ចត្រូវធ្លាក់ទៅលើមហាឧបរាជ ឬព្រះរាជគ្រូ ជាអ្នកទទួលខុសត្រូវកិច្ចការទាំងឡាយជំនួសព្រះអង្គសិន។[17]

គ.អំណាចព្រះមហាក្សត្រ

(Powers of King)

ក្នុងប្រវត្តិសាស្ត្រប្រទេសកម្ពុជា បានចាត់ទុកថា ស្តេចខ្មែរមិនត្រឹមតែជា ប្រមុខដឹកនាំផ្នែករដ្ឋបាលប៉ុណ្ណោះទេ ព្រះអង្គ គឺជាប្រមុខ ក្នុងការដឹកនាំអំណាចទាំងអស់ ដែលមានអំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។ ព្រះអង្គជានិមិត្តរូបនៃអាទិទេព ការគោរពបូជាចំពោះព្រះមហាក្សត្រ ក៏ដូចជាការគោរពបូជាអាទិទេពដែរ ទាំងអស់នេះ គឺបានបន្សល់ទុក

[16] ត្រឹងងា ប្រវត្តិសាស្ត្រខ្មែរ បោះពុម្ពឡើងវិញ ដោយក្រសួងអប់រំ ឆ្នាំ២០០៣ ទំព័រ១០៨។

[17] ត្រឹងងា ប្រវត្តិសាស្ត្រខ្មែរបោះពុម្ពឡើងវិញ ដោយក្រសួងអប់រំឆ្នាំ២០០៣ទំព័រ១១១។

នៅក្នុងសិលាចារឹកស្តុកកក់ធំ និងនៅសម្បូរណ៍។

ព្រះរាជាតែងរៀបចំចាត់ចែងឲ្យកសាងប្រាសាទភ្នំនៅក្នុងរជ្ជកាលនីមួយៗ ដើម្បីបញ្ជាក់អំពីអំណាចរបស់ព្រះរាជា និងសម្រាប់តម្កល់លិង្គព្រះសិវៈទុកជាទីសក្ការៈ។

ចាប់តាំងពីព្រះរាជា គឺព្រះបាទជ័យវរ្ម័នទី២មក ព្រះមហាក្សត្រខ្មែរ ដែលបានសោយរាជ្យសុទ្ធសឹងតែជាស្តេចចក្រវាឡ ហើយស្តេចភាគច្រើនគឺជាស្តេច ដែលបានកាន់អំណាចផ្តាច់ការទាំងអស់ ហើយអំណាចទាំងអស់នោះ មានអំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងមានអំណាចតុលាការគឺស្ថិតនៅលើបុគ្គលស្តេចតែមួយអង្គឯងគត់ ស្តេចដែលអំណាចទាំងនោះ គឺជាអំណាចដែលគ្មានព្រំដែនកំណត់ឡើយ។

ព្រះមហាក្សត្រ មិនធ្វើអន្តរាគមន៍ណាមួយ ទៅលើបញ្ហាឯកជនទេ ដូចជា បណ្តាប្រទេសនៅអឺរ៉ុបខាងកើត ព្រះរាជាមិនធ្វើអន្តរាគមន៍ក្នុងការកែប្រែទំនៀមទម្លាប់ ដែលទាក់ទងទៅនឹងរឿងរដ្ឋប្បវេណី ឬរឿងព្រហ្មទណ្ឌរបស់ប្រជារាស្ត្រនៅក្នុងអាណាចក្រឡើយ ទាំងនេះធ្លាប់មានជាច្រើនសតវត្សរ៍ណាស់មកហើយ។

ការគ្រប់គ្រងដឹកនាំប្រទេសជាតិ គឺស្ថិតនៅលើឆន្ទៈរបស់ស្តេចតែមួយអង្គឯងគត់ គ្មានការពិគ្រោះយោបល់ គ្មានការពិភាក្សា គ្មានការប្រជុំណាមួយរបស់មន្ត្រី ឬអ្នកប្រជាធិបតេយ្យណាមកវិខានដល់អំណាចរបស់ព្រះមហាក្សត្រឡើយ។ ព្រះរាជា ជាអ្នកបង្កើតច្បាប់ ជាអ្នកអនុវត្តន៍ច្បាប់ ជាអ្នកដឹកនាំកងទ័ព និងជាមេទ័ពវាយបណ្តេញខ្មាំងសត្រូវព្រមទាំងវាយដណ្តើមកាន់កាប់ទឹកដីវាតទីយកបណ្តាប្រទេសជិតខាងជាក់ធ្វើជាចំណុះ(សមន្តរដ្ឋ) ហើយក៏ជាអ្នកដោះស្រាយបញ្ហា និងជាអ្នកកាត់ក្តីដោយព្រះទ័យផ្ទាល់របស់ព្រះអង្គឯងដែរ។

ព្រះមហាក្សត្រ ត្រូវបានប្រជារាស្ត្រចាត់ទុកថាដូចជា ម្ចាស់តែមួយអង្គគត់នៃទឹកដីអាណាចក្រទាំងមូល ហើយក៏ជាម្ចាស់អាណាចក្រតែ១អង្គគត់លើអ្វីៗគ្រប់បែបយ៉ាង ដែលមានរួមទាំងប្រជានុរាស្ត្រគ្រប់ជាន់ថ្នាក់ផងដែរ។

ឃ.ព្រះរាជវង្សានុវង្ស

(Royal Family)

ព្រះរាជវង្សានុវង្សជាទូទៅមានសិទ្ធិអំណាចគ្រប់បែបយ៉ាង ហើយត្រូវទទួលបានឋានៈជាឧបរាជ ជាស្តេចត្រាញ់ ជាមន្ត្រី ជាមេទ័ព ហើយព្រះរាជវង្សទាំងនោះ មានអំណាចខ្លាំងក្លាមិនចាញ់ព្រះរាជាគ្រងរាជ្យប៉ុន្មានទេ។ ចំពោះក្សត្រី ដែលមានអម្ប្រាជាក្សត្រ តែងតែត្រូវបានរៀបចំអភិសេកជាមួយអង្គក្សត្រដូចគ្នា ប៉ុន្តែបើមានស្វាមី ដែលស្ថិតក្នុងចំណោមប្រជារាស្ត្រវិញនៅពេលមានបុត្រ បុត្រនោះមិនអាចរាប់បញ្ចូលទៅក្នុងខ្សែរាជវង្សានុវង្សបានទេ។

ព្រះរាជាខ្មែរ ដែលមានតាំងពីមុនសម័យអង្គរ រហូតមកដល់សម័យអង្គរ គឺសុទ្ធសឹងជាអ្នកចម្បាំង ដែលព្រះមហាក្សត្រគ្រប់ៗអង្គ បានយល់ដឹងច្បាស់លាស់នូវករណីយកិច្ចក្នុងនាមជាស្តេច ទ្រង់តែងតែដឹកនាំកងទ័ពចេញច្បាំង ដោយផ្ទាល់ព្រះអង្គ ក្នុងការវាតទីដណ្តើមកាន់កាប់ទឹកដីនៃអាណាចក្រជិតខាង ដើម្បីបញ្ជាក់ អំពីសិទ្ធិអំណាច និងភាពខ្លាំងពូកែរបស់ស្តេចពីជំនាន់មួយទៅជំនាន់មួយ និងតាំងខ្លួនជាអធិរាជនៃអាណាចក្រទាំងមូល។

ខ.ព្រាហ្មណ៍ និងបព្វជិត

(Brahman and Monk)

ព្រាហ្មណ៍ និងបព្វជិត ព្រមទាំងអ្នកកាន់សាសនាផ្សេងៗទៀត ត្រូវបានគេបែងចែកជាបីក្រុមគឺ:

-ក្រុមទី១ គឺគេហៅថា ពួក ប៉ាន ឃាប (តាមទស្សនៈរបស់អ្នកប្រវត្តិសាស្ត្រ បារាំង គឺលោក ប៉ូល ពីលីយ៉ូបានហៅថា ប៉ាន ឃី)ដែលខ្មែរយើងហៅថា ពួកព្រាហ្មណ៍ ដែលមានសម្លៀកបំពាក់ដូចជាមនុស្សទូទៅដែរ ប៉ុន្តែខុសគ្នាត្រង់មាន ពាក់អំបោះសរពេញបញ្ចូលគ្នាមួយខ្សែចងជាប់នៅនឹងក ដែលជាសញ្ញាសំគាល់ប្រាប់ថា ជាអ្នកមានចំណេះចេះដឹងខ្ពង់ខ្ពស់ជាងគេ។

-ក្រុមទី២ គឺជាពួកជូគូ ដែលជាលោកសង្ឃ ជាអ្នកគោរពព្រះពុទ្ធសាសនា ហើយកោរសក់គ្រងចីវរពណ៌លឿង បញ្ចេញស្មាស្តាំ និមន្តដោយជើងទទេ ឆាន់ចង្ហាន់មួយដងក្នុងមួយថ្ងៃ។

-ក្រុមទី៣ គឺពួកប៉ាសុរី ឬពួកតាបស ស្លៀកសម្លៀកបំពាក់ ដូចអ្នកស្រុកធម្មតា ប៉ុន្តែមានជូតក្បាលក្រណាត់ពណ៌ស ឬពណ៌ក្រហម។[18]

---

[18] តាមឯកសាររបស់លោកជីវ តាក្វាន់ នៅសតវត្សទី១៣។

ផ្នែកទី៣

ស្ថាប័ននយោបាយក្រោយសម័យអង្គរ

(Post-Angkor Era of Political Institutions)

ក.ព្រះមហាក្សត្រ

(King)

ចាប់តាំងពីអង្គរត្រូវបានបោះបង់មក ការផ្លាស់ប្តូររាជវង្សក៏បានលេចឡើង ហើយបានបន្តរាជវង្សថ្មីដោយស្តេចតាត្រសក់ផ្អែម។ ចាប់ពីពេលនោះមកលទ្ធិទេវរាជ ក៏ត្រូវបានបញ្ចប់ផងដែរ ក៏ប៉ុន្តែព្រះមហាក្សត្រខ្មែរនៅតែមានឫទ្ធិអំណាចពិសិដ្ឋខ្លាំងក្លា មិនចាញ់ព្រះមហាក្សត្រមុនៗនោះទេ ដែលគេតែងនិយមហៅថា ព្រះសម្មតិទេព គឺមានន័យថា ជាអ្នកមានចំណេះដឹងមានការយល់ដឹង និងឫទ្ធិអំណាចខ្លាំងក្លាផុតលើសគេ ហើយដែលប្រជានុរាស្ត្រតែងតែគោរពកោតខ្លាច ហើយបានប្រៀបប្រដូចដូចជាទេវតាដែរ។[19]

ព្រះរាជាខ្មែរ នៅពេលសោយទីវង្គតទៅ តែងតែប្រារព្ធរៀបចំពិធីធ្វើបុណ្យទៅតាមទំនៀមទម្លាប់ប្រពៃណី ដោយយកព្រះសពទៅតម្កល់ទុកនៅក្នុងកោដ្ឋ ហើយត្រូវធ្វើបុណ្យ និងថ្វាយព្រះភ្លើងរួចហើយ ទើបយកបរមអដ្ឋិធាតុទៅបញ្ចុះនៅក្នុងចេតិយ ដែលតែងតែបានកសាងឡើងនៅលើកំពូលភ្នំ។

ខ.ការគ្រងរាជសម្បត្តិ

(Reigns)

ការឡើងគ្រងរាជសម្បត្តិត្រូវបានតែងតាំងអ្នកស្នងរាជ្យ ដែលហៅថា រាជទាយាទ ដែលត្រូវឡើងសោយរាជ្យបន្តពីព្រះមហាក្សត្រក្រោយពីព្រះមហាក្សត្រមុនបានសោយទិវង្គតទៅ ពេលនោះរាជបុត្រាច្បងបង្អស់ត្រូវឡើងសោយរាជ្យបន្ត ពេលខ្លះរាជបុត្រាប្អូនក៏អាចឡើងសោយរាជ្យជំនួសរាជបុត្រាច្បងបានដែរ ក៏ប៉ុន្តែប្រសិនបើស្តេចដែលឡើងសោយរាជ្យ ហើយមិនមានព្រះរាជបុត្រា ដើម្បីស្នងរាជ្យទេនោះ រាជបល្ល័ង្កនឹងត្រូវធ្លាក់ ទៅលើព្រះរាជអនុជរបស់ព្រះមហាក្សត្រជាបន្តបន្ទាប់គ្នានឹងឡើងសោយរាជ្យជាបន្ត។

ក្នុងករណីដែលមានមន្ត្រី ឬញាតិវង្សានុវង្សណាម្នាក់របស់ព្រះមហាក្សត្រ ដែលមិនត្រូវបានតែងតាំងដើម្បីឲ្យឡើងស្នងរាជ្យទេ ប៉ុន្តែស្រាប់តែបានឡើងសោយរាជ្យទៅវិញនោះ ដោយការប្រើប្រាស់កម្លាំងទ័ព ឬដោយប្រើមធ្យោបាយផ្សេងៗក៏ដោយក៏តាមបុរាណលោកតែងតែហៅ

[19] ត្រឹងងា ប្រវត្តិសាស្ត្រខ្មែរបោះពុម្ពឡើងវិញ ដោយក្រសួងអប់រំឆ្នាំ២០០៣ទំព័រ១៦៧។

ថាជាស្តេចជ្រែករាជ្យ។[20]

គ.អំណាចព្រះមហាក្សត្រ

(Powers of King)

ព្រះមហាក្សត្រ ជាគោលការណ៍កាន់កាប់អំណាចខ្ពស់បំផុត ជាប្រមុខរដ្ឋ ជាអ្នកដឹកនាំរដ្ឋ ជាអគ្គសេនាបតី ជាបុព្វជិតជាន់ខ្ពស់ ជាអ្នកបង្កើតច្បាប់ ហើយនិងជាចៅក្រមដ៏កំពូល។

ព្រះមហាក្សត្រគឺជាសមាជិកគ្រួសារដែលមានសិទ្ធិអំណាច និងបុព្វសិទ្ធិខ្លាំងក្លាពីបុព្វបុរស និងពីទំនៀមទម្លាប់ប្រពៃណីខ្មែរ ហើយបានប្រគល់ទៅឲ្យព្រះមហាក្សត្រ នៅពេលដែលព្រះអង្គ បានប្រារព្ធពិធីរៀបអភិសេក។

ព្រះមហាក្សត្រ មានសិទ្ធិអំណាចខ្លាំងក្លា ហើយជាទីសក្ការៈបូជារបស់ប្រជារាស្ត្រទូទាំង អាណាចក្រ និងព្រះមហាក្សត្រ ជាតួអង្គដែលមិនអាចរំលោភបំពានបានឡើយ។

ព្រះមហាក្សត្រ នៅតែជាមេទ័ព ជាអ្នកដឹកនាំកងកម្លាំងវាយបណ្តេញខ្មាំងសត្រូវ នៅគ្រប់ការឈ្លានពាន និងគ្រប់សមរភូមិ ដើម្បីការពារបូរណភាពទឹកដី និងអាណាចក្ររបស់ខ្លួន គ្រប់ពេលវេលាទាំងអស់ ព្រះរាជាខ្មែរដែលបានឡើងសោយរាជ្យ សុទ្ធតែបានបូជាសាច់ស្រស់ឈាមស្រស់ដែលជាគំរូវីរភាពដ៏ឧដ្ត្តុង្គឧត្តមរបស់បុព្វបុរសខ្មែរ។

ហេតុនេះហើយ ទើបយើងមើលឃើញថា សិទ្ធិអំណាចទាំងឡាយរបស់ព្រះរាជាសុទ្ធសឹងមានប្រភពចេញមកពីព្រះមហាក្សត្រទាំងអស់។[21]

ឃ.ព្រះរាជវង្សានុវង្ស និងមន្ត្រី

(Royal Family and Officials)

ជាទូទៅយើងឃើញថា ព្រះមហាក្សត្រ តែងតែមានព្រះរាជវង្សានុវង្សជាច្រើន ដែលត្រូវបានតែងតាំងឋានៈទៅតាមទំនៀមទម្លាប់ប្រពៃណីខ្មែរដូចតទៅៈ ឧកញ៉ោរាជ ឧបរាជ ឬមហាឧបរាជ និងមន្ត្រីជាដើម...។

១-ឧកញ៉ោរាជ

(Abdicated King)

ឧកញ៉ោរាជ គឺជាស្តេច ដែលបានដាក់រាជ្យ ឬផ្ទេររាជសម្បត្តិទៅឲ្យព្រះរាជបុត្រ ឬទៅឲ្យក្សត្រអង្គណាមួយ ដើម្បីបានឡើងសោយរាជបន្តនៅក្នុងអាណាចក្រ ឧកញ៉ោរាជ ជាទូទៅ គឺជាស្តេចដែលមានព្រះរាជឋានៈបន្ទាប់ពីព្រះមហាក្សត្រដែលកំពុងគ្រងរាជសម្បត្តិ។

[20] ត្រឹងងា ប្រវត្តិសាស្ត្រខ្មែរបោះពុម្ពឡើងវិញ ដោយក្រសួងអប់រំឆ្នាំ២០០៣ទំព័រ១៧២។

[21] ត្រឹងងា ប្រវត្តិសាស្ត្រខ្មែរបោះពុម្ពឡើងវិញ ដោយក្រសួងអប់រំឆ្នាំ២០០៣ទំព័រ១៧៤។

២-ឧបរាជ ឬមហាឧបរាជ

(Crown Princes)

ឧបរាជ ឬមហាឧបរាជ ត្រូវបានគេរៀបចំតែងតាំងសាច់សាលោហិត ខ្សែញាតិវង្ស និងមន្ត្រីជាន់ខ្ពស់បំផុតនៅក្នុងអាណាចក្រឲ្យឡើងកាន់មុខតំណែងដ៏ធំទាំងនេះ គឺដើម្បីជួយការងារទាំងឡាយរបស់ព្រះមហាក្សត្រគ្រប់បែបយ៉ាង។ ក្នុងករណីខ្លះ រាជបុត្រាច្បង ត្រូវបានតែងតាំងជាព្រះមហាក្សត្រ ប៉ុន្តែព្រះរាជអនុជក៏ត្រូវបានតែងតាំងជាឧបរាជ ឬមហាឧបរាជដែរ។

៣-មន្ត្រី

(Officials)

មន្ត្រីសម័យដើមគេនិយមហៅថា **ចៅហ្វាទឆ្ឆៈ**ដែលជាមន្ត្រីមានឋានៈតួនាទីខ្ពស់មិនចាញ់ឧបរាជ ឬមហាឧបរាជឡើយ ហើយមានមុខងារ ជាអ្នកបំពេញកិច្ចការសម្រេចព្រះរាជកិច្ច និងគ្រប់គ្រងដែនអាណាចក្រជាមួយព្រះមហាក្សត្រផងដែរ។

បន្ទាប់ពីចៅហ្វាទឆ្ឆៈ នៅមានតំណែងជាមន្ត្រីធំៗចំនួនបួនទៀត ដែលគេចាត់ទុកថា ជាជើងសសរនៃប្រាង្គប្រាសាទទាំងបួនគឺឈ្មោះថា**ចតុស្តម្ភ**។

មន្ត្រីធំទាំងបួននេះរួមមាន:

-ឧកញ៉ាក្រឡាហោម(រដ្ឋមន្ត្រីទំពាជើងទឹក)

-ឧកញ៉ាវាំង(រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង)

-ឧកញ៉ាយមរាជ(រដ្ឋមន្ត្រីក្រសួងយុត្តិធម៌)

-ឧកញ៉ាចក្រី(រដ្ឋមន្ត្រីទំពាជើងគោក)។

ក្រៅពីមន្ត្រីខាងលើ នៅមានមន្ត្រីហែហមជាច្រើនទៀតដែលមានដូចជា:

-ហោរា(ជាមន្ត្រីមានមុខងារជាអ្នកទស្សន៍ទាយ តាមក្បួនហោរា)

-ចៅជិត ចៅចម(ជាពួកស្ត្រី ជាព្រះរាជបរិវារបម្រើស្តេច ជាស្ត្រីស្នំស្តេច)

-ឬក៏មហាតលិកជាមន្ត្រី ដែលមានមុខងារគាល់បម្រើព្រះរាជាផ្ទាល់[22]។

[22] ត្រឹងងា ប្រវត្តិសាស្ត្រខ្មែរបោះពុម្ពឡើងវិញ ដោយក្រសួងអប់រំឆ្នាំ២០០៣ទំព័រ១៧១។

ផ្នែកទី៤

ស្ថាប័ននយោបាយសម័យអាណានិគមនិយមបារាំង

(Political Institutions in French Colonialism Era)

ស្ថាប័ននយោបាយខ្មែរ នៅក្នុងសម័យអាណានិគមនិយមបារាំងគឺបានពាក់ព័ន្ធនឹងការធ្វើទំនាក់ទំនងរវាងប្រទេសបារាំង និងប្រទេសកម្ពុជាព្រមទាំងរាជវង្សមហាក្សត្រខ្មែរផងដែរ។

ក.ទំនាក់ទំនងខ្មែរជាមួយបារាំង

(Relationship between Khmer and French)

ការធ្វើទំនាក់ទំនងដំបូងរវាងប្រទេសកម្ពុជា និងប្រទេសបារាំងគឺត្រូវបានទទួលបរាជ័យ ដោយមានការធ្វេសប្រហែសរបស់បារាំង និងការពារាំងពីសំណាក់ស្តេចសៀម ហេតុនេះការធ្វើទំនាក់ទំនងនៅក្នុងរាជ្យរបស់ព្រះបាទអង្គឌួងមិនបានជោគជ័យទេ ជាហេតុធ្វើឲ្យព្រះបាទអង្គឌួងមានការព្រួយព្រះហរទ័យយ៉ាងខ្លាំង ហើយក៏ប្រឈួន និងសោយទីវង្គតទៅនៅឆ្នាំ១៨៦០។[23]

ក្រោយពីព្រះបាទអង្គឌួងសោយទិវង្គតទៅ នាមឺនសព្វមុខមន្ត្រីទាំងទាំងអស់ បានលើកព្រះបាទ នរោត្តមឲ្យឡើងសោយរាជ្យបន្តនៅដើមរជ្ជកាលរបស់ព្រះអង្គគឺមានការបះបោរជាច្រើននៅក្នុងប្រទេសដើម្បីដណ្តើមរាជ្យ និងការឈ្លានពានពីសំណាក់ពួកចោរសៀម និងយួន។

ដើម្បីរំដោះប្រទេសជាតិ ឲ្យរួចផុតអំពីការជិះជាន់បណ្តាពួកចោរឈ្លានពាននៃពួកបរទេសទាំងនោះ ព្រះបាទនរោត្តម បានសម្រេចព្រះទ័យធ្វើទំនាក់ទំនងជាមួយប្រទេសបារាំង ដែលត្រូវបានចុះសន្ធិសញ្ញាមួយរវាងបារាំង និងខ្មែរនៅថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣ ដែលមានឈ្មោះថា “មិត្តភាពការការពារ និងពាណិជ្ជកម្ម” បន្ទាប់មកស្តេចសៀមក៏បានចាប់បង្ខំព្រះបាទ នរោត្តមឲ្យឡាយព្រះហស្តលេខាលើសន្ធិសញ្ញា ជាសម្ងាត់នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៨៦៣ ដើម្បីឲ្យស្តេចខ្មែរទទួលស្គាល់ការដាក់អាណានិគមនិយមរបស់សៀមមកលើប្រទេសខ្មែរ។

រហូតមកដល់ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៨៦៤ សន្ធិសញ្ញាបារាំង-ខ្មែរត្រូវបានផ្តល់សច្ចាប័នដោយអធិរាជណាប៉ូឡេអុងទី៣(NapoleonIII) ហើយបានផ្ញើថ្វាយព្រះនរោត្តម ដោយទទួលស្គាល់លើសន្ធិសញ្ញាបារាំង-ខ្មែរនៅថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣។

ដូចនេះរដ្ឋាភិបាលបារាំងត្រូវបានធានាការការពារព្រះរាជាខ្មែរ និងប្រទេសខ្មែរទាំងមូល ប៉ុន្តែព្រះចៅអធិរាជបារាំងមានសិទ្ធិតែងតាំង អេស៊ីដង់បារាំងម្នាក់ដាក់នៅអមព្រះរាជាខ្មែរ រីឯព្រះ

[23] លោក អាដេម៉ារ ឡឺក្លែរ ប្រវត្តិសាស្ត្រប្រទេសកម្ពុជា បោះពុម្ពនៅឆ្នាំ២០០៥ ទំព័រ ៣៩២។

រាជាខ្មែរក៏មានសិទ្ធិ តែងតាំងមន្ត្រីខ្មែរម្នាក់នៅអមទេសាភិបាលបារាំង ដែលប្រចាំនៅកូសាំងស៊ីន ដែរ ក្នុងករណីប្រទេសខ្មែរធ្វើទំនាក់ទំនងជាមួយកុងស៊ុល ជាមួយប្រទេសផ្សេងៗ ព្រះមហាក្សត្រ ខ្មែរត្រូវតែសុំការអនុញ្ញាតពីរាជរដ្ឋាភិបាលបារាំងជាមុនសិន។[24]

ព្រះចៅអធិរាជបារាំងបានសន្យាក្នុងការជួយការការពារ និងរៀបចំប្រទេសខ្មែរនៅសម័យ នោះឲ្យមានសុខសន្តិភាពឡើងវិញ ជៀសវាងការរំលោភឈ្លានពានអំពីសំណាក់បណ្តាប្រទេស ជិតខាង និងរៀបចំសណ្តាប់ធ្នាប់សាធារណៈឲ្យបានល្អប្រសើរឡើងព្រមទាំងជួយការការពារគ្រប់ ការរំលោភឈ្លានពពីសំណាក់ពួកចោរបរទេសនានាទាំងឡាយទៀតផង។

ខ.ទំនាក់ទំនងសៀមជាមួយបារាំង

(Relationship between Siam and French)

ដោយមានបំណងចង់បង្ហាញនូវតេទ្ធិពលរបស់ខ្លួន រាជរដ្ឋាភិបាលបារាំង បានបង្កើតសន្ធិ សញ្ញាជាមួយប្រទេសសៀមនៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៨៦៧ ដែលក្នុងនោះរដ្ឋាភិបាលបារាំង និងរដ្ឋាភិបាលសៀមបានសន្យាគ្នាដូចតទៅ:

-រាជរដ្ឋាភិបាលបារាំងបានសន្យាថា ប្រទេសបារាំងនឹងមិនវាយប្រទេសសៀមដាក់បញ្ចូល ទៅក្នុងអាណានិគមនិយមបារាំងទេ។

-សៀមបានសន្យាថា ប្រទេសសៀមនឹងប្រគល់សិទ្ធិទៅឲ្យប្រទេសបារាំង ជាអ្នកគ្រប់គ្រង ត្រួតត្រាលើប្រទេសខ្មែរជំនួសខ្លួនវិញ ប៉ុន្តែប្រទេសបារាំងក៏ត្រូវយល់ព្រមក្នុងការទទួលស្គាល់ថា ខេត្តបាត់ដំបង ខេត្តសៀមរាប និងស៊ីសុផុនត្រូវប្រគល់ឲ្យទៅសៀមជាអ្នកគ្រប់គ្រងវិញដែរ។

ដូចនេះ ការធ្វើសន្ធិសញ្ញារវាងប្រទេសបារាំង និងប្រទេសសៀម គឺដើម្បីធ្វើការបែងចែក ទឹកដីប្រទេសខ្មែរ និងផ្តល់ផលប្រយោជន៍ឲ្យគ្នាទៅវិញទៅមកតែប៉ុណ្ណោះ។

គ.ព្រះមហាក្សត្រខ្មែរ

(King)

ក្រោយពីបានបង្ក្រាបការបះបោលក្នុងប្រទេសដោយមហាឧបរាជស៊ីសុវត្ថិ និងមានជំនួយ ពីកងទ័ពបារាំងបានធ្វើឲ្យប្រទេសខ្មែរមានសុខសន្តិភាព ព្រះបាទនរោត្តមបានធ្វើទស្សនៈកិច្ចនៅ ក្នុងទីក្រុងមួយចំនួនដូចជា ហុងកុង ម៉ាកាវ កំងតុង និងទីក្រុងម៉ានីលនៅឆ្នាំ១៨៧២ ដើម្បីយល់ ដឹងអំពីវឌ្ឍនភាពក្នុងវិស័យសេដ្ឋកិច្ច និងសង្គម នៅបណ្តាប្រទេសមួយចំនួន ជាពិសេសការគ្រប់

[24] មាត្រា១សន្ធិសញ្ញាខ្មែរ បារាំងស្តីពី"មិត្តភាពការការពារ និងពាណិជ្ជកម្ម" ១១ សីហា ១៨៦៣។

គ្រងរដ្ឋបាល និងហិរញ្ញវត្ថុរបស់ពួកប្រទេសអឺរ៉ុប ព្រះបាទនរោត្តមបានធ្វើការពិភាក្សាជាមួយអ្នកតំណាងរបស់ប្រទេសបារាំងអំពីបញ្ហានានា ដើម្បីឲ្យប្រទេសជាតិរីកចម្រើនដូចប្រទេសផ្សេងៗ។

ដោយមានការគាំទ្រពីរដ្ឋាភិបាលបារាំង ព្រះបាទ នរោត្តមបានសម្រេចព្រះហរទ័យធ្វើការរៀបចំការងារគ្រប់គ្រង និងធ្វើកំណែទម្រង់ប្រទេសជាតិមួយចំនួនដែលមានដូចជា:ការរៀបចំរាជរដ្ឋាភិបាលខ្មែរ ព្រះរាជវង្សានុវង្ស ក្រុមប្រឹក្សារាជសម្បត្តិ និងមន្ត្រីជាន់ខ្ពស់ ដោយបានចេញព្រះរាជបញ្ញត្តិចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៨៧៧។

១-ការរៀបចំរាជរដ្ឋាភិបាល

(Organization The Government)

ព្រះបាទ នរោត្តម បានបង្កើតឲ្យមានក្រុមប្រឹក្សាមួយ ដែលមានមន្ត្រីជាន់ខ្ពស់ ចំនួន៥រូបមានឋានៈជារដ្ឋមន្ត្រី ដែលមានសិទ្ធិអំណាច អាចពិភាក្សាអំពីកិច្ចការរបស់ព្រះរាជាណាចក្រខ្មែរគ្រប់បែបយ៉ាង រាប់ទាំងការធ្វើកំណែទម្រង់ផ្សេងៗរបស់រដ្ឋការ ត្រួតពិនិត្យលើការអនុវត្តន៍ច្បាប់ ការធ្វើកិច្ចព្រមព្រៀងអន្តរជាតិផ្សេងៗជាមួយរាជរដ្ឋាភិបាល និងការរៀបចំបណ្តាអ្នកពាណិជ្ជករបរទេសទាំងឡាយដែលបានមកធ្វើជំនួញនៅក្នុងប្រទេសខ្មែរ។

កិច្ចការងារទាំងឡាយនោះ អាចដំណើរការប្រព្រឹត្តទៅបាន ដោយមិនចាំបាច់មានវត្តមានព្រះមហាក្សត្រខ្មែរក៏បានដែរ។[25]

២-ព្រះរាជវង្សានុវង្ស

(Royal Family)

នៅក្នុងព្រះរាជវង្សានុវង្សបានរៀបចំតួនាទី និងឋានៈរបស់រាជវង្សានុវង្ស ដែលមានឋានៈជាឧកញ៉ារាជ ឧបរាជ និងវររាជនី ដែលក្នុងតំណែងទាំងបីនេះ ត្រូវបានលុបបំបាត់ចោលមិនឲ្យមានទៀតទេ គឺចាប់ពីពេលដែលព្រះបាទ នរោត្តមសោយទីវង្គតទៅ។

ចំពោះរាជវង្សានុវង្សទាំងអស់ ត្រូវបានផ្តល់ជាប្រាក់បៀវត្សរ៍ និងកំណត់ការដំឡើងបៀវត្ស និងតួនាទីឋានៈដល់រាជវង្សានុវង្សទាំងនោះ គឺជាពិសេសព្រះរាជបុត្រា និងព្រះរាជបុត្រី ដើម្បីឲ្យមានជីវភាពសមរម្យចំណែកឯប្រាក់ចំណូលមួយភាគធំ ត្រូវយកទៅចំណាយលើកិច្ចការដែលជាប្រយោជន៍ដល់ប្រទេសជាតិ។[26]

ព្រះមហាក្សត្រ ទ្រង់គង់ជាម្ចាស់នៃដែនដីទាំងឡាយ នៅក្នុងអាណាចក្រទាំងមូល ដោយ

[25] ត្រឹងងា ប្រវត្តិសាស្ត្រខ្មែរបោះពុម្ពឡើងវិញដោយក្រសួងអប់រំឆ្នាំ២០០៣ទំព័រ២៦២។

[26] ត្រឹងងា ប្រវត្តិសាស្ត្រខ្មែរបោះពុម្ពឡើងវិញដោយក្រសួងអប់រំឆ្នាំ២០០៣ទំព័រ២៦១។

ព្រះអង្គក៏បានសន្យាថា នឹងពន្យាពេលនៃការជួលដីដល់ប្រជាកសិករសម្រាប់ធ្វើស្រែចំការឲ្យបានរយៈពេលវែងជាងមុន។[27]

៣-ក្រុមប្រឹក្សារាជសម្បត្តិ

(The Royal Council of the Throne)

ក្រុមប្រឹក្សារាជសម្បត្តិ គឺត្រូវបានបង្កើតឡើង ដែលមានតួនាទីសម្រាប់ធ្វើការជ្រើសតាំងព្រះមហាក្សត្រថ្មី ដើម្បីជំនួសព្រះមហាក្សត្រចាស់ ក្នុងករណីព្រះមហាក្សត្របានសោយទិវង្គត ក្រុមប្រឹក្សារាជសម្បត្តិនេះត្រូវធ្វើការជ្រើសរើសព្រះមហាក្សត្រថ្មីជាបន្ទាន់។

ក្រុមប្រឹក្សារាជសម្បត្តិមានសមាសភាពចំនួន៩រូបមានដូចជា:

-រេស៊ីដង់ជាន់ខ្ពស់បារាំងប្រចាំនៅប្រទេសខ្មែរជាអធិបតី។

-សេនាបតី ដែលមានរដ្ឋមន្ត្រីទាំង៥រូបនៅក្នុងគណៈរដ្ឋមន្ត្រី។

-មន្ត្រីបុព្វជិតជាន់ខ្ពស់ ដែលមានសម្តេចសង្ឃរាជទាំងពីរគណៈ។

-ព្រះមហាឧបរាជ ដែលមានព្រះបាទស៊ីសុវត្ថិជាសមាជិក។

ក្រោយពីព្រះបាទ នរោត្តមសោយទិវង្គតទៅនៅថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩០៤ វេលាម៉ោង៣ និង២០នាទីល្ងាច ត្រូវបានក្រុមប្រឹក្សារាជសម្បត្តិបើកសម័យប្រជុំធ្វើការជ្រើសរើសព្រះមហាក្សត្រថ្មីតាមប្រពៃណីទំនៀមទម្លាប់ខ្មែរ ហើយត្រូវបានក្រុមប្រឹក្សារាជសម្បត្តិ ធ្វើការជ្រើសតាំង ព្រះបាទស៊ីសុវត្ថិ ជាព្រះមហាក្សត្រខ្មែរដើម្បីឲ្យឡើងសោយរាជ្យបន្តក្នុងព្រះជន្ម៦៤ព្រះវស្សា។

៤-មន្ត្រីជាន់ខ្ពស់

(High Officials)

ក្រោយពេលដែលព្រះបាទស៊ីសុវត្ថិបានឡើងសោយរាជ្យសម្បត្តិ ជាព្រះមហាក្សត្រនៅក្នុងប្រទេសខ្មែរ រាជរដ្ឋាភិបាលបារាំងបានធ្វើការកំណត់អំពីមុខងារ និងតួនាទីរបស់មន្ត្រីជាន់ខ្ពស់ខ្មែរមួយចំនួនដូចខាងក្រោម:

-ឧកញ៉ាវាំង គឺជារដ្ឋមន្ត្រី ដែលដឹកនាំគ្រប់គ្រងកិច្ចការក្នុងរាជវាំង ក្រសួងហិរញ្ញវត្ថុ និងក្រសួងវិចិត្រសិល្បៈ។

-ឧកញ៉ាអគ្គមហាសេនា គឺជារដ្ឋមន្ត្រី ដែលជាអ្នកដឹកនាំគ្រប់គ្រងក្រសួងមហាផ្ទៃ និងក្រសួងធម្មការសាសនា។

-ឧកញ៉ាយមរាជ គឺជារដ្ឋមន្ត្រីដែលដឹកនាំគ្រប់គ្រងក្រសួងយុត្តធម៌។

[27] ត្រឹងងា ប្រវត្តិសាស្ត្រខ្មែរ បោះពុម្ពនៅឆ្នាំ១៩៧៣ ទំព័រ១៧៣។

-ឧកញ៉ាចក្រី គឺជារដ្ឋមន្ត្រី ដែលដឹកនាំគ្រប់គ្រងកិច្ចការសង្គ្រាម ក្រសួងសាធារណៈការ និងក្រសួងសិក្សាធិការ។

-ឧកញ៉ាក្រឡាហោមគឺជារដ្ឋមន្ត្រី ដែលដឹកនាំ និងគ្រប់គ្រងកិច្ចការកងទ័ពជើងទឹក និងក្រសួងពាណិជ្ជកម្ម ក្រសួងកសិកម្ម និងក្រសួងឧស្សាហកម្ម។

ដោយមានចលនាតស៊ូធ្វើការបះបោរ ពីសំណាក់ព្រះមហាក្សត្រខ្មែរ ពួកនាម៉ឺនសព្វមុខមន្ត្រី អ្នកស្នេហាជាតិខ្មែរ និងប្រជារាស្ត្រខ្មែរទូទាំងប្រទេសទើបរាជរដ្ឋាភិបាលប្រទេសបារាំងបានយល់ព្រមប្រគល់អំណាចមួយចំនួនមកឲ្យមហាក្សត្រខ្មែរវិញមានដូចជា:

-រាជរដ្ឋាភិបាលបារាំងបានយល់ព្រមប្រគល់អំណាចមកឲ្យព្រះរាជាខ្មែរ ដោយទុកតែរេស៊ីដង់ម្នាក់គត់នៅអមព្រះមហាក្សត្រខ្មែរ។

-កិច្ចការទាំងអស់ត្រូវប្រគល់មកឲ្យមន្ត្រីខ្មែរទាំងអស់។

-រាល់ការធ្វើកំណែទម្រង់ទាំងឡាយរបស់រេស៊ីដង់បារាំង ត្រូវមានការយល់ព្រមពីព្រះមហាក្សត្រខ្មែរជាមុនសិន។

នៅឆ្នាំ១៩០៤ ដោយសារមានការធ្វើអន្តរាគមន៍ពីប្រទេសបារាំង បារាំងក៏ឈានទៅបង្កើតសន្ធិសញ្ញាមួយជាមួយប្រទេសសៀមស្តីពីបញ្ហាព្រំដែន រវាងប្រទេសកម្ពុជាជាមួយប្រទេសសៀម។ ប្រទេសសៀមក៏បានយល់ព្រមប្រគល់ទឹកដីខ្មែរមកឲ្យប្រទេសខ្មែរយើងវិញ មានដូចជា ខេត្តស្ទឹងត្រែង ម្លូព្រៃ ទន្លេរពៅ និងកោះកុង។

រហូតមកដល់ឆ្នាំ១៩០៦ ប្រទេសសៀម ក៏បានយល់ព្រមប្រគល់ខេត្តបាត់ដំបង និងខេត្តសៀមរាបមកឲ្យខ្មែរទៀត ប៉ុន្តែប្រទេសសៀមបានកាត់យកខេត្តសុវិន្ទ ខេត្តបុរីរ៉ាម និងខេត្តគោកខណ្ឌបញ្ចូលទៅជាទឹកដីរបស់អាណាចក្រសៀមតែម្តង។[28]

បន្ទាប់មកប្រទេសបារាំង និងប្រទេសសៀម ក៏បានបង្កើតសន្ធិសញ្ញាមួយនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩០៧ ស្តីអំពីបញ្ហាព្រំដែនប្រទេសខ្មែរជាមួយប្រទេសសៀម ដែលការបង្កើតសន្ធិសញ្ញានេះបារាំងធ្វើឡើងក្នុងនាមជាខ្មែរហើយក៏ជាសន្ធិសញ្ញាបំពេញបន្ថែមទៅលើសន្ធិសញ្ញាដែលបានធ្វើនៅឆ្នាំ១៩០៤ដែរ ហើយបារាំងបានកាត់ដែនដីរបស់ខ្មែរមួយចំនួនទៀតដែលរួមមាន ដាន សៃ (Dan Sai) និងខេត្តត្រាច(ត្រាត)ត្រូវប្រគល់ឲ្យទៅប្រទេសសៀមតែម្តង។[29]

ព្រះបាទស៊ីសុវត្ថិ បានខិតខំទាំងកម្លាំងកាយទាំងកម្លាំងចិត្ត ដើម្បីធ្វើឲ្យប្រទេសជាតិមាន

[28] តាមឯកសារប្រវត្តិវិទ្យា បោះពុម្ពផ្សាយដោយក្រសួងអប់រំឆ្នាំ១៩៩៤ ទំព័រ១២០។

[29] ត្រឹងងា ប្រវត្តិសាស្ត្រខ្មែរ បោះពុម្ពនៅឆ្នាំ១៩៧៣ ទំព័រ១៨៥។

សុខសន្តិភាព និងការអភិវឌ្ឍន៍ឲ្យរីកចម្រើនព្រមទាំងធ្វើឲ្យប្រជារាស្ត្រមានជីវភាពសម្បូណ៌ធូរធារ ព្រះអង្គបានប្រកាសឲ្យប្រើនូវព្រះរាជបញ្ញត្តិចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩០៤ ដែលបានបញ្ជាឲ្យលុបចោលនូវការធ្វើទុក្ខបុកម្នេញលើរាងកាយនៃជនមានទោស និងជនដែលត្រូវចោទ។[30]

នៅក្នុងរាជ្យព្រះបាទស៊ីសុវត្ថិព្រះអង្គបានកសាងអនុវិទ្យាល័យព្រះស៊ីសុវត្ថិ ព្រះរាជបណ្ណាល័យ សាលាបាលីជាន់ខ្ពស់ សាលារចនា និងសាលាច្បាប់ព្រមទាំងផ្លូវថ្នល់នានាជាច្រើនទៀត។

ក្រោយពីព្រះបាទ ស៊ីសុវត្ថិបានសោយទិវង្គតនៅឆ្នាំ១៩២៧ ក្រុមប្រឹក្សារាជសម្បត្តិក៏បានជ្រើសរើសព្រះបាទមុនីវង្សឲ្យឡើងសោយរាជ្យបន្ត។

ព្រះបាទមុនីវង្សបានសោយទិវង្គត នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ១៩៤១ នៅពេលនោះ ក្រុមប្រឹក្សារាជបល្ល័ង្កបានធ្វើការបោះឆ្នោតជ្រើសរើសព្រះមហាក្សត្រ ហើយធ្វើការតែងតាំងព្រះមហាក្សត្រថ្មីគឺព្រះបាទ នរោត្តម សីហនុ ដែលមានព្រះជន្មាយុទើបតែ១៨ ព្រះវស្សាតែប៉ុណ្ណោះ ហើយព្រះអង្គគឺជាចៅទួតរបស់ស្តេច ព្រះបាទ នរោត្តមដើម្បីឲ្យឡើងសោយរាជ្យបន្ត។

[30] ត្រឹងងា ប្រវត្តិសាស្ត្រខ្មែរ បោះពុម្ពនៅឆ្នាំ១៩៧៣ ទំព័រ១៨៣។

ជំពូកទី៤

ស្ថាប័នខ្មែរសម័យទំនើប

(Modern era of Khmer Institutions)

ផ្នែកទី១

ស្ថាប័ននយោបាយសម័យសង្គមរាស្ត្រនិយម

(Political Institutions in Sangkumreasniyum)

ក្រោយពីទទួលបានឯករាជ្យ និងអធិបតេយ្យពេញលេញនៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ព្រះរាជាណាចក្រកម្ពុជា បានចាប់ផ្តើមអនុវត្តរបបនយោបាយមួយ តាមបែបផែនរបបសភានិយម ដែលមានរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ជាច្បាប់គ្រឹះ និងជាច្បាប់កំពូល។

រដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧បានចែងអំពីស្ថាប័ននយោបាយសំខាន់ៗដែលមានដូចជា ស្ថាប័នព្រះមហាក្សត្រ ស្ថាប័ននីតិប្បញ្ញត្តិ ដែលមានរដ្ឋសភា និងក្រុមប្រឹក្សាព្រះរាជាណាចក្រ ស្ថាប័ននីតិប្រតិបត្តិ មានរាជរដ្ឋាភិបាល និងសមាជជាតិ។

ក.ព្រះមហាក្សត្រ

(King)

ព្រះបាទនរោត្តមសីហនុ បានប្រសូត្រឡើងនាថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩២២ នៅរាជធានីភ្នំពេញ ព្រះអង្គគឺជាវីរក្សត្រ ដែលបានធ្វើការរំដោះប្រទេសជាតិ និងទាមទារឯករាជ្យឲ្យរួចផុតពីការត្រួតត្រាជិះជាន់របស់ពួកអាណានិគមនិយមបារាំង ដោយបានទទួលឯករាជ្យពិតប្រាកដ នៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣។ ព្រះបាទ នរោត្តម សីហនុ បានប្រកាសឲ្យដឹងពីការផ្លាស់ប្តូររបបនយោបាយគ្រប់គ្រងរដ្ឋ នៅថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៤៦ ដោយបានផ្លាស់ប្តូរពីរបបរាជានិយមផ្តាច់ការទៅជា"របបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ"វិញ។

ដោយបានការយកព្រះទ័យទុកដាក់របស់ព្រះបាទ នរោត្តម សីហនុ នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៤៦ ព្រះអង្គក៏បានរៀបចំធ្វើការបោះឆ្នោតជាសាកលមួយ ដើម្បីធ្វើការជ្រើសរើសតំណាងរាស្ត្រដើម្បីបង្កើតឲ្យមានសភាធម្មនុញ្ញមួយ ដែលជាអ្នកធ្វើការរៀបចំតាក់តែងបង្កើត និងអនុម័តរដ្ឋធម្មនុញ្ញ។ រដ្ឋធម្មនុញ្ញមួយត្រូវបានអនុម័ត នៅថ្ងៃ ទី០៦ ខែឧសភា ឆ្នាំ១៩៤៧ ជារដ្ឋធម្មនុញ្ញដែលបានបង្កើតដំបូងបំផុតនៅក្នុងព្រះរាជាណាចក្រកម្ពុជាយើង។

១-ការគ្រងរាជសម្បត្តិ

(Reigns)

កាលពីសម័យដើមព្រះរាជាណាចក្រកម្ពុជា ព្រះមហាក្សត្របានឡើងគ្រងរាជសម្បត្តិ ត្រូវ

បានធ្វើការតែងតាំងអ្នកស្នងរាជ្យ (រាជទាយាទ) ទៅតាមទំនៀមទម្លាប់ប្រពៃណីខ្មែរ ដើម្បីឲ្យឡើងគ្រងរាជសម្បត្តិបន្តពីព្រះមហាក្សត្រក្រោយពីព្រះមហាក្សត្របានសោយទិវង្គតទៅ នៅពេលនោះ រាជបុត្រាច្បងបង្អស់ត្រូវឡើងសោយរាជ្យសម្បត្តិបន្ត ករណីនេះ គឺជាមរតក ដែលមាននៅក្នុងរាជវង្ស ខ្មែរតាំងពីសម័យរាជ្យស្តេចមុនៗ ជាពិសេសក្នុងរាជព្រះបាទសម្តេច ព្រះហិរិរក្ស រាមាធិបតី ព្រះបាទ អង្គ ឌួង ចាប់ពីរាជរបស់ព្រះបាទនរោត្តមមកត្រូវបានបង្កើតឲ្យមានក្រុមប្រឹក្សារាជសម្បត្តិ សម្រាប់ធ្វើការបោះឆ្នោតជ្រើសរើសព្រះមហាក្សត្រថ្មីដើម្បីឡើងសោយរាជសម្បត្តិ។

ដូចនេះ ព្រះបាទ ស៊ីសុវត្ថិ ត្រូវបានក្រុមប្រឹក្សារាជសម្បត្តិធ្វើការបោះឆ្នោតជ្រើសរើសតែងតាំងឲ្យក្លាយជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។

ព្រះមហាក្សត្រ ក្នុងពេលសោយរាជ្យសម្បត្តិ ព្រះអង្គពុំមានសិទ្ធិអំណាច ធ្វើការតែងតាំងព្រះរាជទាយាទដើម្បីឲ្យឡើងគ្រងរាជសម្បត្តិបន្តទៅទៀតបានទេ។

ការឡើងគ្រងរាជសម្បត្តិ ត្រូវធ្វើឡើងតាមរយៈក្រុមប្រឹក្សារាជសម្បត្តិ ដែលក្រុមប្រឹក្សារាជសម្បត្តិអាចធ្វើការរៀបចំបោះឆ្នោតជ្រើសរើស និងតែងតាំងព្រះមហាក្សត្រថ្មីដោយការអនុម័តយកសម្លេងភាគច្រើនដោយប្រៀប។

ព្រះមហាក្សត្រ ជាទូទៅអាចឡើងសោយរាជ្យសម្បត្តិបានត្រូវមានព្រះជន្មាយុយ៉ាងតិច ១៨ព្រះវស្សា ក៏ប៉ុន្តែព្រះមហាក្សត្រ អាចឡើងគ្រងរាជសម្បត្តិមិនគ្រប់ព្រះជន្មាយុ១៨ព្រះវស្សាបាន ដោយក្រុមប្រឹក្សារាជសម្បត្តិអាចធ្វើការជ្រើសរើស តែងតាំងរាជវង្សានុវង្សណាម្នាក់ ដើម្បីបំពេញការងារដឹកនាំគ្រប់គ្រងជំនួសសិនក្នុងនាមជាព្រះរាជានុសិទ្ធិ។

សមាសភាពក្រុមប្រឹក្សារាជសម្បត្តិរួមមាន:

-ក្រុមសង្គហព្រះរាជវង្សានុវង្សអធិបតីជាប្រធាននៃក្រុមប្រឹក្សារាជសម្បត្តិ

-ប្រធានរដ្ឋសភា

-នាយករដ្ឋមន្ត្រី

-សម្តេចសង្ឃទាំងពីរគណៈ។[31]

២-អំណាចព្រះមហាក្សត្រ

(Powers of King)

ព្រះមហាក្សត្រ ទ្រង់ជាអគ្គប្រមុខរដ្ឋនៃព្រះរាជាណាចក្រកម្ពុជា អង្គព្រះមហាក្សត្រមិនអាចត្រូវបានរំលោភបំពានឡើយ ព្រះមហាក្សត្រជាទីសក្ការៈនៃប្រជានុរាស្ត្រខ្មែរទាំងមូល។

អង្គព្រះមហាក្សត្រ ត្រូវបានច្បាប់ការពារជាពិសេស ហើយក៏គ្មានការជំទាស់ ការប្រឆាំង

[31] មាត្រា២៨នៃរដ្ឋធម្មនុញ្ញសម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៤៧។

និងការប្រមាថមើលងាយផងដែរ។[32]

អំណាចគ្រប់បែបយ៉ាងទាំងអស់ត្រូវស្ថិតនៅក្រោមព្រះមហាក្សត្រតែមួយអង្គឯងគត់ ប៉ុន្តែអំណាចទាំងនោះ ត្រូវតែអនុវត្តន៍ឲ្យបានត្រឹមត្រូវ ដូចអ្វីដែលមានចែង នៅក្នុងច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ ១៩៤៧។[33]

អំណាចទាំងអស់ត្រូវបានបែងចែកឲ្យបានច្បាស់លាស់ ដែលរដ្ឋសភាជាអង្គការដែលមានអំណាចនីតិប្បញ្ញត្តិ ហើយត្រូវបំពេញការងារក្នុងព្រះបរមនាមនៃព្រះមហាក្សត្រ ហើយព្រះមហាក្សត្រជាអ្នកមានអំណាចផ្តួចផ្តើមធ្វើច្បាប់ និងតាក់តែងច្បាប់។[34]

អំណាចនីតិប្រតិបត្តិត្រូវបានកាន់កាប់ដោយគណៈរដ្ឋមន្ត្រីនៃព្រះរាជាណាចក្រ ដែលមានចែងនៅក្នុងច្បាប់។[35]

អំណាចតុលាការត្រូវបានកាន់កាប់ដោយតុលាការគ្រប់ជាន់ថ្នាក់នៅទូទាំងប្រទេស ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧។[36]

នៅខែ**ឧសភា** ឆ្នាំ**១៩៤៩** អាណានិគមនិយមបារាំង បានកាត់ទឹកដីកម្ពុជាក្រោមទៅឲ្យវៀតណាម។[37]

នៅខែ**កញ្ញា** ឆ្នាំ**១៩៤៩** រដ្ឋសភាមានបញ្ហាទាក់ទងទៅនឹងអំណាច ដែលធ្វើឲ្យរដ្ឋសភាជាតិមានការបែកបាក់គ្នា។ ហេតុនេះ ទើបព្រះមហាក្សត្រ ក៏បានប្រកាសកាន់អំណាចនីតិប្បញ្ញត្តិដែលធ្វើឲ្យព្រះអង្គមានអំណាចកាន់តែខ្លាំងក្លាថែមទៀតមានដូចជា:

-ព្រះមហាក្សត្រ ទ្រង់ជាអគ្គសេនាប្រមុខលើកងកម្លាំងទាហានទាំងឡាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា។[38]

-ព្រះមហាក្សត្រទ្រង់ជាអ្នកជ្រើសរើសនាយករដ្ឋមន្ត្រី ហើយតែងតាំងនាយករដ្ឋមន្ត្រីព្រមទាំងរដ្ឋមន្ត្រីនានា ហើយអាចព្រះរាជទានឋានន្តរស័ក្តិ ទៅដល់មន្ត្រីរាជការស៊ីវិល កងកម្លាំង និងទាហានជាដើមបាន។

---

[32] មាត្រា២០៥នៃក្រមព្រហ្មទណ្ឌសង្គមចាស់សម័យសង្គមរាស្ត្រនិយម។

[33] មាត្រា២១នៃរដ្ឋធម្មនុញ្ញសម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៤៧។

[34] មាត្រា២២នៃរដ្ឋធម្មនុញ្ញសម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៤៧។

[35] មាត្រា២៣នៃរដ្ឋធម្មនុញ្ញសម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៤៧។

[36] មាត្រា២៤នៃរដ្ឋធម្មនុញ្ញសម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៤៧។

[37] តាមឯកសារប្រវត្តិវិទ្យា បោះពុម្ពផ្សាយដោយក្រសួងអប់រំឆ្នាំ១៩៩៤ ទំព័រ១២៦។

[38] មាត្រា៤៥រដ្ឋធម្មនុញ្ញនៃព្រះរាជណាកម្ពុជាសម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៤៧។

-ព្រះមហាក្សត្រ ទ្រង់ជាអ្នកតែងតាំងចៅក្រមទាំងឡាយតាមសំណើរបស់ក្រុមប្រឹក្សាជាន់ខ្ពស់នៃតុលាការ។[39]

-ព្រះមហាក្សត្រទ្រង់ជាអធិបតីក្នុងការប្រជុំគណៈរដ្ឋមន្ត្រី។

-កំណត់ហេតុនៃការប្រជុំទាំងឡាយ របស់គណៈរដ្ឋមន្ត្រីទាំងអស់ ត្រូវតែនាំយកទៅក្រាបបង្គំថ្វាយព្រះមហាក្សត្រ។[40]

-ព្រះមហាក្សត្រ ទ្រង់អាចប្រាស្រ័យទាក់ទងដោយផ្ទាល់ ជាមួយរដ្ឋសភា ជាមួយក្រុមប្រឹក្សាព្រះរាជាណាចក្រ និងជាមួយសភាប្រចាំខេត្ត និងរាជធានីដោយព្រះរាជឱង្ការផ្ទាល់។[41]

-ព្រះមហាក្សត្រ ទ្រង់អាចត្រាស់បង្គាប់បញ្ជាមន្ត្រីជាន់ខ្ពស់គ្រប់ជាន់ថ្នាក់ ឲ្យចូលបង្គំគាល់ទៅតាមព្រះរាជហឫទ័យ ដើម្បីថ្លែងការណ៍ ឬត្រាស់បង្គាប់ ឬមានវិធានការរដ្ឋបាល ដែលព្រះមហាក្សត្រអាចចេញព្រះរាជប្រកាស ដើម្បីបំពេញសកម្មភាពបានគ្រប់បែបយ៉ាង និងគ្រប់ពេលវេលាទាំងអស់។

ព្រះមហាក្សត្រ អាចចេញព្រះរាជប្រកាស(Ordonnance Royal) ចាប់តាំងពីឆ្នាំ១៩១៣ រហូតមកដល់ឆ្នាំ១៩៤០ ក្រោយមកទើបត្រូវបានផ្លាស់ប្តូរមកប្រើជាព្រះរាជក្រមវិញ។

-រាល់លិខិតស្នាមមានលក្ខណៈជាផ្លូវការរបស់ព្រះមហាក្សត្រ ត្រូវតែមានការចុះហត្ថលេខារបស់ប្រធានក្រុមប្រឹក្សាគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីម្នាក់ ដែលត្រូវបានចុះហត្ថលេខាអមជាមួយ។

-ព្រះមហាក្សត្រ ចេញព្រះរាជក្រមប្រកាសឲ្យប្រើច្បាប់នានា ក្នុងរយៈពេល១០ថ្ងៃ ហើយបើជាការប្រញាប់ត្រូវបន្តយមកត្រឹម៥ថ្ងៃ ក្នុងរយៈពេលនៃការប្រកាសឲ្យប្រើច្បាប់ព្រះមហាក្សត្រអាចផ្ញើរាជសារទៅឲ្យរដ្ឋសភា និងក្រុមប្រឹក្សាព្រះរាជាណាចក្រពិចារណាច្បាប់នោះ សាជាថ្មីបានរដ្ឋសភា និងក្រុមប្រឹក្សាព្រះរាជាណាចក្រ ត្រូវតែសម្រេចជាថ្មីតាមព្រះរាជឱង្ការ ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧។[42]

-ព្រះមហាក្សត្រ ទ្រង់ជាអ្នកកោះប្រជុំរដ្ឋសភាបាន ហើយក៏អាចប្រកាសរំលាយរដ្ឋសភាបានដែរ ក៏ប៉ុន្តែត្រូវធ្វើការបោះឆ្នោតជ្រើសតាំងរដ្ឋសភាសាជាថ្មី មិនឲ្យលើសរយៈពេលពីរខែនោះឡើយ។[43]

---

[39] មាត្រា៤៣រដ្ឋធម្មនុញ្ញនៃព្រះរាជាណាកម្ពុជាសម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៤៧។

[40] មាត្រា៤០រដ្ឋធម្មនុញ្ញនៃព្រះរាជាណាកម្ពុជាសម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៤៧។

[41] មាត្រា៣៧រដ្ឋធម្មនុញ្ញនៃព្រះរាជាណាកម្ពុជាសម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៤៧។

[42] មាត្រា៣៦រដ្ឋធម្មនុញ្ញនៃព្រះរាជាណាកម្ពុជាសម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៤៧។

[43] មាត្រា៦២រដ្ឋធម្មនុញ្ញនៃព្រះរាជាណាកម្ពុជាសម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៤៧។

-ព្រះមហាក្សត្រអាចប្រើប្រាស់សិទ្ធិអំណាចតាមរយៈព្រះរាជសិទ្ធិក្នុងការលើកលែងទោស និងបន្ធូរបន្ថយទោសបានផងដែរ។[44]

នៅឆ្នាំ១៩៥៥ ព្រះបាទ នរោត្តម សីហនុ បានដាក់រាជសម្បត្តិ ហើយថ្វាយព្រះរាជបល្ល័ង្ក នេះថ្វាយទៅព្រះរាជបិតារបស់ព្រះអង្គ ដែលមានព្រះនាមថា ព្រះបាទ នរោត្តម សុរាម្រិតឲ្យឡើងគ្រងរាជ្យបន្តរហូតដល់ឆ្នាំ១៩៦០។

ខ.ស្ថាប័ននីតិប្បញ្ញត្តិ

(Legislative Institutions)

I-រដ្ឋសភា

(Assembly)

១.ទិដ្ឋភាពទូទៅ

(General Aspect)

នៅក្នុងប្រវត្តិសាស្ត្រនៃការបោះឆ្នោត និងឈរឈ្មោះឲ្យគេបោះឆ្នោត គឺមានការកម្រិតនូវសិទ្ធិសេរីភាព ដែលមានដូចជា ជនជាតិភាគតិច អ្នកកាន់សាសនា ជាតិសាសន៍ផ្សេងៗ និងស្ត្រីភេទជាដើមដែលអ្នកទាំងនោះពុំមានសិទ្ធិបោះឆ្នោតទេ។

នៅសហរដ្ឋអាមេរិករដ្ឋធម្មនុញ្ញនាឆ្នាំ១៧៨៧បានកម្រិតនូវសិទ្ធិ ដែលអ្នកមានសិទ្ធិបោះឆ្នោត និងអ្នកឈរឈ្មោះឲ្យគេបោះឆ្នោតបាន គឺសំដៅដល់អ្នកដែលមានជីធ្លីភេទប្រុស និងជាជនជាតិស្បែកស។

មកដល់សតវត្សរ៍ទី១៩នៅសហរដ្ឋអាមេរិក ការកម្រិតអំពីសិទ្ធិក្នុងការបោះឆ្នោតត្រូវបានលុបបំបាត់ចោល ហើយនៅឆ្នាំ១៩២០ស្ត្រីអាមេរិកដណ្តើមបានសិទ្ធិបោះឆ្នោត។

នៅអាមេរិកប៉ែកខាងត្បូង ពួកជនជាតិស្បែកខ្មៅ បានទាមទារសិទ្ធិបោះឆ្នោតបាននៅឆ្នាំ១៩៦០ និងនៅឆ្នាំ១៩៧១ ពលរដ្ឋអាមេរិកក្មេងៗមានសិទ្ធិបោះឆ្នោតនៅពេលដែលរដ្ឋាភិបាលសហរដ្ឋអាមេរិកបានបន្ថយអាយុពី២១ឆ្នាំមកត្រឹម១៨ឆ្នាំវិញ។

នៅប្រទេសបារាំង ប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោតពិតប្រាកដចាប់ពីឆ្នាំ១៨៤៨ ហើយស្ត្រីមានសិទ្ធិបោះឆ្នោតចាប់តាំងពីឆ្នាំ១៩៤៤រហូតមកដល់សព្វថ្ងៃ។

២.ប្រវត្តិរដ្ឋសភាខ្មែរ

(History of Khmer National Assembly)

តាមប្រវត្តិសាស្ត្រប្រទេសកម្ពុជាយើងរបបរាជានិយមផ្តាច់ការ គឺបានរៀបចំឲ្យមានស្ថាប័ន

[44] មាត្រា៤៣រដ្ឋធម្មនុញ្ញនៃព្រះរាជណាកម្ពុជាសម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៤៧។

តំណាងមួយមានឈ្មោះថា ស្ថាប័នពិគ្រោះយោបល់នៃប្រជាជនដើមដែលត្រូវបានចេញដោយព្រះរាជបញ្ញត្តិចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩១៣។

ក្រោយមក ក្រោមការដឹកនាំរបស់ព្រះបាទនរោត្តម សីហនុ ព្រះអង្គបានផ្លាស់ប្តូរពីស្ថាប័នពិគ្រោះយោបល់មកជាសភាតំណាងនៃប្រជាជនកម្ពុជាវិញ។

ការប្រកាន់យកលទ្ធិប្រជាធិបតេយ្យ គឺជាបំណងប្រាថ្នារបស់អ្នកស្នេហាជាតិអ្នកស្រឡាញ់យុត្តិធម៌ ហើយក៏ជាបំណងប្រាថ្នាដ៏ចំបងរបស់ប្រជារាស្ត្រខ្មែរទូទៅផងដែរ ទើបបានព្រះមហាក្សត្រ ព្រះបាទ នរោត្តម សីហនុ បានធ្វើការកែប្រែរបបនយោបាយគ្រប់គ្រងរដ្ឋ នៅថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៤៦ ដោយការផ្លាស់ពីរបបរាជានិយមផ្តាច់ការទៅជារបប“រាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ”វិញ។

នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៤៦ ព្រះបាទ នរោត្តម សីហនុ ព្រះអង្គក៏បានរៀបចំការបោះឆ្នោតជាសាកលមួយ ដោយធ្វើការជ្រើសរើសសភាធម្មនុញ្ញមួយ ក្នុងការអនុម័តពង្រាងទី១ នៃរដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជា ហើយក៏ដើម្បីបង្កើតឲ្យមានរដ្ឋសភាជាតិដែរ ក្នុងកាលៈទេសៈនោះ យើងឃើញថា គណបក្សប្រជាធិបតេយ្យនិយមកណ្តាល របស់ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ យុត្តិវង្ស បានទទួលលទ្ធផលឈ្នះឆ្នោត ដោយទទួលបានអាសនៈរហូតដល់៥០អាសនៈ គណបក្សសេរីភាពទទួលបាន១៤អាសនៈ ហើយគណបក្សជឿនលឿនទទួលបាន៣អាសនៈ នៅក្នុងចំណោមអាសនៈទាំងអស់៦៧។[45]

រដ្ឋធម្មនុញ្ញមួយត្រូវបានអនុម័តនៅថ្ងៃទី០៦ ខែឧសភា ឆ្នាំ១៩៤៧។

៣.រដ្ឋសភានៅឆ្នាំ១៩៤៧

(National Assembly 1947)

រដ្ឋសភាជាស្ថាប័នកំពូល និងជាស្ថាប័ន ដែលកាន់អំណាចនីតិប្បញ្ញត្តិ ហើយត្រូវបំពេញការកិច្ចរបស់ខ្លួន ដូចបានកំណត់ក្នុងច្បាប់រដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន។

-រដ្ឋសភា ត្រូវតាំងបទបញ្ជាផ្ទៃក្នុងមួយសម្រាប់បំពេញការងារ។[46]

-រដ្ឋសភាមានសិទ្ធិបញ្ចេញមតិតាំងច្បាប់ ដែលសិទ្ធិនេះរដ្ឋសភាមិនអាចប្រគល់ទៅឲ្យអ្នកណាបានឡើយ។[47]

-រដ្ឋសភា ជាអ្នកអនុម័តថវិកាជាតិមុនពេលដែលត្រូវចំណាយផ្សេងៗ ហើយបញ្ជីចំណូល

[45] Chandler David. A History of Cambodia, 2005, p.191.

[46] មាត្រា៦៤រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាសម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៤៧។

[47] មាត្រា៦៥រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាសម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៤៧។

ចំណាយក៏ត្រូវរដ្ឋសភាជាអ្នកយល់ព្រមដែរ។

-ការឲ្យប្រទេសផ្សេងទៀត ខ្ចីប្រាក់ពីប្រទេសយើង ឬការចងការប្រាក់របស់ប្រទេសជាតិត្រូវអនុម័តយល់ព្រមពីរដ្ឋសភា។[48]

៤ .នីតិវិធីនៃការចូលកាន់តំណែងរបស់សមាជិករដ្ឋសភា

(Procedure of Taking Office of National Assembly)

បន្ទាប់ពីប្រជាពលរដ្ឋខ្មែរបានបោះឆ្នោតគាំទ្របេក្ខជនជាប់ឆ្នោតទាំងអស់ តំណាងរាស្ត្រដែលជាប់ឆ្នោត ត្រូវបើកសម័យប្រជុំដំបូងនៃនីតិកាលនីមួយៗ រដ្ឋសភាត្រូវចាប់ដំណើរដោយតែងតាំងតំណាងរាស្ត្រពេញសិទ្ធិ តំណាងរាស្ត្រទាំងអស់ក៏ត្រូវបានតាំងសច្ចាប្រណិធាន នៅក្នុងទីប្រជុំចំពោះព្រះភ័ក្ត្ររបស់ព្រះមហាក្សត្រដូចតទៅ:

“ខ្ញុំសូមតាំងសច្ចាថា មានចិត្តស្មោះត្រង់ចំពោះព្រះមហាក្សត្រហើយនឹងរដ្ឋធម្មនុញ្ញ ហើយថានឹងខិតខំប្រឹងប្រែងធ្វើការដោយពេញកម្លាំងដើម្បីជាផលប្រយោជន៍ដល់ប្រទេសជាតិ”។

តំណាងរាស្ត្រដែលត្រូវបានជ្រើសតាំងដោយរដ្ឋសភាពេញសិទ្ធិហើយ ត្រូវតាំងសច្ចាប្រណិធានចំពោះព្រះភ័ក្ត្រព្រះមហាក្សត្រក្នុងឱកាសព្រះរាជពិធីចម្រើនព្រះជន្មវស្សា(តាំងតុ) ហើយនឹងបន្ទាប់គឺអ្នករាជការ(គណៈរដ្ឋមន្ត្រី)។[49]

៥. សមាជិករដ្ឋសភា

(Members of Parliament)

តំណាងរាស្ត្រ ដែលបានជ្រើសតាំងដោយរដ្ឋសភារួចហើយ នឹងក្លាយទៅជាសមាជិករដ្ឋសភា។ សមាជិកទាំងឡាយនៃរដ្ឋសភា ជាតំណាងរបស់ប្រជាជាតិខ្មែរទាំងមូល ពុំមែនគ្រាន់តែជាតំណាងប្រជាពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួនប៉ុណ្ណោះទេ។[50]

សមាជិករដ្ឋសភា គឺជាតំណាងរាស្ត្រ ដែលត្រូវបានប្រជាពលរដ្ឋខ្មែរបោះឆ្នោតជ្រើសរើសត្រូវទទួលប្រាក់បំណាច់ ដែលមានកំណត់ដោយប្រៀបស្មើទៅនឹងប្រាក់បៀវត្សនៃអ្នករាជការថ្នាក់ណាមួយនៃក្របខណ្ឌជាន់ខ្ពស់។[51]

៦.ការបោះឆ្នោតជ្រើសតាំង

(Elections)

[48] មាត្រា៦៧រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាសម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៤៧។
[49] មាត្រា៥៣រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាសម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៤៧។
[50] មាត្រា៥៤រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាសម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៤៧។
[51] មាត្រា៥៨រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាសម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៤៧។

៦.១.អ្នកដែលមានសិទ្ធិជ្រើសតាំង

(The Rights to Vote)

តាមរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ អ្នកដែលមានសិទ្ធិបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ គឺប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុ២០ឆ្នាំពេញលេញ ស្របតាមច្បាប់ស្តីពីការជ្រើសតាំងអ្នកតំណាងរាស្ត្រ។[52]

៦.២.អ្នកដែលមិនមានសិទ្ធិជ្រើសតាំង

(No Rights to Vote)

អ្នកដែលមិនមានសិទ្ធិជ្រើសតាំងអ្នកតំណាងរាស្ត្របានគឺសំដៅដល់អ្នកដែលមានដូចជា:

-អ្នកដែលត្រូវបានដកហូតសិទ្ធិពលរដ្ឋមានដូចជា ទណ្ឌឱិត អ្នកមិនមានសតិបញ្ញាល្អ។

-ទាហានក្នុងតំណែង និង

-បុព្វជិតគឺគ្មានសិទ្ធិជ្រើសតាំងអ្នកតំណាងរាស្ត្រទេ។[53]

៦.៣.លក្ខខណ្ឌនៃការឈរឈ្មោះ

(Conditions of Qualification Candidate)

អ្នកមានសិទ្ធិឈរឈ្មោះជាបេក្ខជន ដែលត្រូវគេជ្រើសតាំងជាតំណាងរាស្ត្របាននោះត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម:

-ជាបុរសមានសិទ្ធិជ្រើសរើសតំណាងរាស្ត្រទាំងឡាយ។

-មានអាយុយ៉ាងតិចម្តៃប្រាំឆ្នាំ(២៥)ឆ្នាំ

៦.៤.លក្ខខណ្ឌមិនអាចឈរឈ្មោះ

(Conditions of Disqualification Candidate)

តាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្របានចែងថា:

-បុរសដែលមិនគ្រប់អាយុ២៥ឆ្នាំ។

-អ្នកដែលគ្មានសិទ្ធិបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។[54]

-មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងកម្លាំងនគរបាលជាតិ ឬកងយោធ ពលខេមរភូមិន្ទក្នុងមុខតំណែង និងបុព្វជិតសាសនា ឬ

-ជនដែលត្រូវបានតុលាការ ផ្តន្ទាទោសដាក់ពន្ធនាគារពីបទល្មើសព្រហ្មទណ្ឌ (បឧក្រិដ្ឋ ឬ

[52] មាត្រា៤៩រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាសម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៤៧។

[53] មាត្រា៤៩រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាសម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៤៧។

[54] មាត្រា៤៩រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាសម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៤៧។

បទមជ្ឈិម)ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ ឬ

-ជនដែលត្រូវបានផ្តន្ទាទោសដកសិទ្ធិបោះឆ្នោត ឬ

-ជនវិកលចរិត ឬជនដែលស្ថិតនៅក្រោមអាណាព្យាបាល ដែលមានលិខិតស្នាមបញ្ជាក់ពីក្រសួងមានសមត្ថកិច្ច ឬ

-ជនដែលត្រូវដកហូតជាបណ្តោះអាសន្ននូវសិទ្ធិបោះឆ្នោត ឬជនដែលត្រូវបានលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ដោយគណៈកម្មាធិការជាតិ និងគណៈកម្មការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឬ

-សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ឬ

- សមាជិកក្រុមប្រឹក្សាជាន់ខ្ពស់នៃតុលាការ ឬ

- សមាជិកក្រុប្រឹក្សាព្រះរាជាណាចក្រ

៧.ការប្រជុំរដ្ឋសភា

(Meeting National Assembly)

ការបើកសម័យប្រជុំរដ្ឋសភា ត្រូវធ្វើនៅរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងសាលប្រជុំរបស់រដ្ឋសភា។[55]

ជាទូទៅការពិភាក្សា ក្នុងសម័យប្រជុំនៃរដ្ឋសភានីមួយៗ ត្រូវធ្វើឡើងដោយបើកចំហដល់មហាជន(ប្រជុំជាសាធារណៈ)។

ប៉ុន្តែរដ្ឋសភាអាចប្រជុំជាសម្ងាត់បាន តាមការស្នើសុំពីប្រធានរដ្ឋសភា ឬពីសមាជិករដ្ឋសភាយ៉ាងតិចចំនួន៥នាក់ ឬពីរាជរដ្ឋាភិបាល រដ្ឋសភាអាចបញ្ចេញមតិឲ្យប្រជុំជាសង្ងាត់បាន។[56]

ការប្រជុំរបស់រដ្ឋសភាជាទូទៅមានពីរ គឺការប្រជុំជាសាមញ្ញ និងជាវិសាមញ្ញ។

៧.១ ការប្រជុំជាសាមញ្ញ

(Ordinary Meeting)

រដ្ឋសភា ប្រជុំជាសាមញ្ញយ៉ាងតិចពីរដងក្នុងមួយឆ្នាំ សម័យប្រជុំនីមួយៗត្រូវមានថេរៈវេលាយ៉ាងតិចបីខែ ដែលត្រូវចាប់ផ្តើមនៅក្នុងខែកញ្ញា ក្រោមការត្រាស់បង្គាប់របស់ព្រះមហាក្សត្រ។[57]

៧.២ ការប្រជុំជាវិសាមញ្ញ

(Extra Ordinary Meeting)

[55] មាត្រា៦១រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាសម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៤៧។

[56] មាត្រា៦៩រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាសម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៤៧។

[57] មាត្រា៥៩រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាសម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៤៧។

ការប្រជុំជាវិសាមញ្ញ ជាការប្រជុំមួយដែលត្រូវបានកោះប្រជុំ ដោយក្រុមអភិបាលរដ្ឋសភា ដោយបានទទួលព្រះរាជបញ្ជាដោយសេចក្តីណែនាំពីគណៈរដ្ឋមន្ត្រី ដោយសេចក្តីស្នើសុំ១ភាគ៣ យ៉ាងតិចនៃចំនួនតំណាងរាស្ត្រទាំងមូល។[58]

ក្នុងករណីនេះ រយៀបវារៈជាក់លាក់នៃសម័យប្រជុំវិសាមញ្ញ ត្រូវផ្សព្វផ្សាយដល់ប្រជារាស្ត្រ ជាមួយនឹងថ្ងៃកំណត់ប្រជុំ។[59]

ក្នុងពេលបើកសម័យប្រជុំនីមួយៗ ត្រូវស្ថិតនៅក្រោមអធិបតីភាពរបស់ព្រះមហាក្សត្រ ឬ ព្រះរាជតំណាង មុនបើកសម័យប្រជុំទ្រង់អានព្រះរាជសារទៅកាន់រដ្ឋសភាដោយព្រះអង្គឯង។[60]

៨.ការអនុម័ត

(Adoption)

ការពិក្សារបស់រដ្ឋសភា នឹងអាចយកជាការបានលុះត្រាតែអនុម័តបានមតិ២ភាគ៣នៃចំនួនសមាជិករដ្ឋសភាដែលចូលរួមប្រជុំ។[61]

៩.អាណត្តិរដ្ឋសភា

(Parliament Mandate)

នីតិកាលរបស់រដ្ឋសភា មានអាណត្តិ៤ឆ្នាំ ហើយត្រូវផុតកំណត់នៅពេល ដែលរដ្ឋសភាថ្មីចូលកាន់តំណែង។

នៅពេលផុតនីតិកាលនីមួយៗ ប្រសិនបើមានហេតុបណ្តាលមកពីបញ្ហាណាមួយដែលមិនអាចធ្វើការបោះឆ្នោតឲ្យមានការជ្រើសតាំងតំណាងរាស្ត្រជាថ្មីទៀតបាន នោះព្រះមហាក្សត្រអាចប្រកាសបន្តនីតិកាលឲ្យវែងបានម្តងក្នុងមួយឆ្នាំ។[62]

រដ្ឋសភាមិនអាចត្រូវរំលាយមុនផុតអាណត្តិបានឡើយ វៀរលែងតែក្នុងករណីដែលរាជរដ្ឋាភិបាលត្រូវបានទម្លាក់ពីរដងក្នុងរយៈពេល១៨ខែ។

ករណីនេះ គណៈរដ្ឋមន្ត្រីក្រោយអាចកោះប្រជុំសម្រេចឲ្យរំលាយរដ្ឋសភាបាន ក្រោយអំពីបានទទួលសេចក្តីយល់ព្រម ពីប្រធានរដ្ឋសភា ព្រះមហាក្សត្រ ទ្រង់ត្រូវតែប្រកាសរំលាយរដ្ឋសភា

---

[58] ក្រុមអភិបាលរដ្ឋសភាគឺសំដៅដល់អ្នកដឹកនាំទាំឡាយនៅក្នុងអង្គការរដ្ឋសភាដែលសព្វថ្ងៃយើងហៅថាគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា។

[59] មាត្រា៦០រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាសម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៤៧។

[60]មាត្រា៦៣រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាសម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៤៧។

[61] មាត្រា៧១រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាសម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៤៧។

[62] មាត្រា៥១រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាសម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៤៧។

តាមសេចក្តីសម្រេចនោះ។

បទបញ្ញត្តិដែលមានក្នុងវគ្គខាងលើនេះនឹងយកមកប្រើបាន លុះត្រាតែរយៈពេលវេលា១៨ ១៨ខែដំបូងនៃនីតិកាលបានកន្លងផុតទៅ។[63]

១០.អំពីអភ័យឯកសិទ្ធិសភា

(Paliament Immunity)

តំណាងរាស្ត្រមានអភ័យឯកសិទ្ធិសភា អភ័យឯកសិទ្ធិនេះគឺ

-ជានាដល់ការបញ្ចេញមតិ និងយោបល់ ការអនុម័តច្បាប់ទាំងឡាយរបស់តំណាងរាស្ត្រ នៅក្នុងក្របខ័ណ្ឌនៃការបំពេញមុខងារ តួនាទីជាអ្នកតំណាងរាស្ត្រ គឺមានអភ័យឯកសិទ្ធិដាច់ខាត របស់តំណាងរាស្ត្រ។

-ជានាមិនឲ្យមានការចោទប្រកាន់ឬការចាប់ខ្លួនការឃាត់ខ្លួន ឬការឃុំខ្លួនតំណាងរាស្ត្រ ណាមួយឡើយគឺ**អភ័យឯកសិទ្ធិដោយប្រៀប**របស់តំណាងរាស្ត្រ។[64]

តំណាងរាស្ត្រស្ថិតក្នុងពេលវេលាជាសមាជិកភាព ដែលបានប្រព្រឹត្តបទល្មើសជាក់ស្តែង អ្នកតំណាងរាស្ត្រនោះ នឹងត្រូវចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនបានសមាជិករដ្ឋសភាណាមួយ បានពីបទមជ្ឈិម ឬបទឧក្រិដ្ឋ លុះត្រាតែមានការយល់ព្រម ពីរដ្ឋសភាជាមុនសិន។ ការឃុំខ្លួន ឬ ចោទប្រកាន់អ្នកតំណាងរាស្ត្រណាមួយត្រូវបង្អង់សិន បើរដ្ឋសភាបញ្ចេញមតិសុំដោយបានអនុម័ត សម្លេង៤ភាគ៥(៤/៥)នៃចំនួនសមាជិករដ្ឋសភា។[65]

II-ព្រឹទ្ធសភា

(Senate)

១.ទិដ្ឋភាពទូទៅ

(General Aspect)

ព្រឹទ្ធសភា គឺជាអង្គការនីតិប្បញ្ញត្តិដែលមានអំណាចនីតិប្បញ្ញត្តិ ហើយមានចរិតលក្ខណៈ ជាទ្វិកសភាឬសភាមានពីរថ្នាក់(Bicameral legislature)ការបែងចែកសភា(Parliament) ជាពីរ ថ្នាក់នេះបានកើតមានឡើង ជាលើកដំបូងនាសតវត្សរ៍ទី១៤នៅក្នុងប្រទេសអង់គ្លេស ដែលមាន សភាជាន់ទាប និងសភាជាន់ខ្ពស់។

---

[63] មាត្រា៧០រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាសម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៤៧។

[64] មាត្រា៥៥រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាសម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៤៧។

[65] មាត្រា៥៦រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាសម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៤៧។

ការបែងចែករបស់សភាជាពីរថ្នាក់នេះ បើផ្អែកទៅតាមទស្សនៈរបស់លោក ម៉ុងតេស្គីយើ (Montesquieu)[66] គឺបានកើតមានតាំងពីឆ្នាំ១៦៨៩ - ១៧៥៥ គឺក្នុងគោលបំណងឲ្យមានការស្រុះស្រួលគ្នារវាងគោលការណ៍អភិជនាធិបតេយ្យ និងប្រជារាស្ត្រសាមញ្ញក្នុងន័យនេះ គឺដើម្បីឲ្យមានតុល្យភាពនៃអំណាច ដៀសវាងការរំលោភបំពានអំណាចគ្នាទៅវិញទៅមក រវាងពួកអភិជនដែលជាពួកអ្នកមាន និងប្រជាពលរដ្ឋដែលជាប្រជារាស្ត្រសាមញ្ញធម្មតា។

២.ក្រុមប្រឹក្សាព្រះរាជាណាចក្រ

(The Royal Council)

ក្រុមប្រឹក្សាព្រះរាជាណាចក្រ ត្រូវបានបង្កើតជាលើកដំបូងនៅក្នុងសម័យសង្គមរាស្ត្រនិយមនាឆ្នាំ១៩៤៧ ដែលអង្គការនេះ បានដើរតួនាទីជាសភាជាន់ខ្ពស់ ឬព្រឹទ្ធសភា ហើយក៏ជាអង្គការដែលមានអំណាចនីតិប្បញ្ញត្តិ។ ក្រុមប្រឹក្សាព្រះរាជាណាចក្រ ជាស្ថាប័នមួយមានតួនាទីជាអង្គការនីតិប្បញ្ញត្តិ ដូចរដ្ឋសភាដែរ។

អង្គការនេះមានសិទ្ធិជាអ្នកត្រួតពិនិត្យផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់ ដែលរដ្ឋសភាបានការអនុម័តយល់ព្រម ជាលើកដំបូងរួចហើយ ព្រមទាំងបញ្ហានានា ដែលរាជរដ្ឋាភិបាលបានដាក់ឲ្យពិនិត្យ និងមានតួនាទីភារកិច្ចមួយទៀត គឺជួយសម្អាតការងាររាជការ (សកម្មភាពរដ្ឋបាល)។ ក៏ប៉ុន្តែ ក្រោយមកភារកិច្ចសម្អាតការងាររាជការរបស់ក្រុមប្រឹក្សាព្រះរាជាណាចក្រត្រូវបានលុបចោល ដោយព្រះរាជក្រមលេខ:១៦៦.បរ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ១៩៦៤ ដោយបានប្រគល់ភារកិច្ចនេះជូនទៅតុលាការប្រជាជនវិញ។[67]

ក្រុមប្រឹក្សាព្រះរាជាណាចក្រ (The Royal Council) ត្រូវបានជ្រើសតាំងឡើងសម្រាប់អាណត្តិ៤ឆ្នាំ[68] ហើយមានសមាជិកទាំងអស់២៤រូប ត្រូវបានជ្រើសរើសដោយការបោះឆ្នោតខ្លះ និងតែងតាំងខ្លះដែលក្នុងនោះរួមមាន:

-ព្រះមហាក្សត្រ ត្រូវតែងតាំងសមាជិកក្រុមប្រឹក្សាព្រះរាជាណាចក្រ ចំនួន២រូប ដែលព្រះមហាក្សត្រទ្រង់ជ្រើសតាំងក្នុងចំណោមបណ្តាព្រះរាជវង្សានុវង្ស។[69]

-រដ្ឋសភាធ្វើការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាព្រះរាជាណាចក្រ២រូប ដោយការ

---

[66] Charles Montesquieu (1689-1755) was born, France was ruled by an absolute king, Louis XIV, He was born into a noble family and educated in the Law, He traveled extensively throughout Europe, including England, where he studied the Parliament in 1722.

[67] មាត្រា៨២រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាសម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៤៧។

[68] មាត្រា៨០រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាសម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៤៧។

[69] មាត្រា៧៥រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាសម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៤៧។

អនុម័តតាមមតិភាគច្រើនដោយប្រៀប ហើយដែលត្រូវជ្រើសរើសក្រៅពីសមាជិករដ្ឋសភា។[70]

-សមាជិកក្រុមប្រឹក្សាព្រះរាជាណាចក្រមានចំនួន១០រូបត្រូវបានជ្រើសរើសឡើង ដោយការបោះឆ្នោតជាអសាកលដោយមិនចំពោះពីប្រជារាស្ត្រខ្មែរទូទាំងប្រទេសដែលតំណាងឲ្យតាមភូមិភាគ និងក្រុងភ្នំពេញ ដែលជ្រើសរើសតាមភូមិភាគ៨រូប និងក្រុងភ្នំពេញ២រូប។[71]

-ជ្រើសរើសពីតំណាងវិជ្ជាជីវៈផ្សេងៗចំនួន១០រូប ដែលត្រូវបានជ្រើសតាំងដោយការបោះឆ្នោតជាសាកល និងដោយចំពោះ។

ការរៀបចំក្រុមប្រឹក្សាព្រះរាជាណាចក្រ ស្របតាមបែបបទ និងលក្ខខណ្ឌ នៃការតែងតាំង និងការជ្រើសតាំងនៃទីប្រឹក្សាព្រះរាជាណាចក្រ។[72]

ក្រុមប្រឹក្សាព្រះរាជាណាចក្រ ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៤៨ ដែលមានសមាជិកទាំងអស់ចំនួន២៤រូប និងមានក្រុមប្រឹក្សាភិបាលចំនួន៤រូប ដែលជាអ្នកដឹកនាំអង្គការនេះ ក្រុមប្រឹក្សាភិបាល ត្រូវបានធ្វើការបោះឆ្នោតជ្រើសរើសឡើងនៅក្នុសមាជិកនានា ក្នុងចំណោមសមាជិកទាំងឡាយ នៃក្រុមប្រឹក្សាព្រះរាជាណាចក្រ។

ក្រុមប្រឹក្សាព្រះរាជាណាចក្រ ត្រូវបានបង្កើតឲ្យមានគណៈកម្មការជំនាញផ្សេងៗ ចំនួន៤ ដែលក្នុងនោះរួមមាន:

១-គណៈកម្មការហិរញ្ញវត្ថុ សេដ្ឋកិច្ច និងសាធារណការ។

២-គណៈកម្មការធម្មការ យុត្តិធម៌ និងរដ្ឋធម្មនុញ្ញ។

៣-គណៈកម្មការមហាផ្ទៃ ការបរទេស និងការពារប្រទេស។

៤-គណៈកម្មការសិក្សាធិការ វប្បធម៌ សុខាភិបាល និងបញ្ហាសង្គម។

នៅក្នុងគណៈកម្មការនីមួយៗត្រូវមានសមាសភាពសមាជិកចំនួន៥ប្រាំរូប។

ស្ថាប័នក្រុមប្រឹក្សាព្រះរាជាណាចក្រ មានក្រុមជាអ្នកជំនួយការមួយ ជាសេនាធិការផ្ទាល់ដែលមានអគ្គលេខាធិការ១រូប និងនាយប៊ុយរ៉ូ១រូប ដែលជាអ្នកមានចំណេះដឹងខ្ពង់ខ្ពស់ ហើយត្រូវបានធ្វើការជ្រើសរើសពីខាងរាជការព្រមទាំងស្មៀនចំនួន៧រូប ដែលធ្វើការជ្រើសរើសតាមរយៈការប្រឡងប្រជែង។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាព្រះរាជាណាចក្រ ត្រូវបានអនុវត្តន៍ទៅតាម

[70] មាត្រា៧៦រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាសម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៤៧។

[71] មាត្រា៧៧រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាសម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៤៧។

[72] មាត្រា៧៩រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាសម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៤៧។

បទបញ្ជាផ្ទៃក្នុងរបស់ស្ថាប័ននីតិប្បញ្ញត្តិ។

គ.ស្ថាប័ននីតិប្រតិបត្តិ(រាជរដ្ឋាភិបាល)

(Executive Institutions(Government))

យោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៤៧ នៅក្នុងជំពូកទី៩ គឺបានចែងថា"គណៈរដ្ឋមន្ត្រី ជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា"[73] គណៈរដ្ឋមន្ត្រីត្រូវមានសមាជិកយ៉ាងច្រើនត្រឹម១៦រូបរាប់បញ្ចូលទាំងរដ្ឋលេខាធិការផងដែរ។

១-ការបង្កើតរាជរដ្ឋាភិបាល

(Forming Government)

ការបង្កើតរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា នៅសម័យសង្គមរាស្ត្រនិយមត្រូវបានបង្កើតឡើងតាមរយៈក្របខ័ណ្ឌច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៤៧ ដែលបានកំណត់ថា នៅក្នុងនីតិកាលដំបូងនីមួយៗ ឬការលាឈប់របស់គណៈរដ្ឋមន្ត្រី ព្រះមហាក្សត្រទ្រង់ប្រឹក្សាជាមួយប្រធានរដ្ឋសភា និងប្រធានក្រុមប្រឹក្សាព្រះរាជាណាចក្រ និងប្រធានគណបក្សនានាដែលជាប់ឆ្នោត ព្រះមហាក្សត្រទ្រង់ចាត់ជនមួយរូប ជានាយករដ្ឋមន្ត្រីឲ្យធ្វើការជ្រើសរើសរដ្ឋមន្ត្រីផ្សេងទៀតឲ្យបង្កើតរាជរដ្ឋាភិបាល។ រាជរដ្ឋាភិបាលអាចទទួលការតែងតាំងបាន ហើយចូលកាន់តំណែងបានលុះត្រាតែរដ្ឋសភាបានបោះឆ្នោតផ្តល់សេចក្តីទុកចិត្តជាមុនសិន ដោយបោះឆ្នោតជាសាធារណៈ ដោយអនុម័តយកសម្លេងភាគច្រើនដាច់ខាត។[74]

២.ការទទួលខុសត្រូវរបស់សមាជិករាជរដ្ឋាភិបាល

(Responsibility of Government Members)

សមាជិកទាំងឡាយរាជរដ្ឋាភិបាល គឺទទួលខុសត្រូវរួម ចំពោះមុខរដ្ឋសភាអំពីនយោបាយទូទៅនៃគណៈរដ្ឋមន្ត្រី ហើយសមាជិករាជរដ្ឋាភិបាល១រូបៗ ត្រូវទទួលខុសត្រូវរៀងៗខ្លួន ចំពោះមុខនាយករដ្ឋមន្ត្រី អំពីកិច្ចការដែលខ្លួនបានប្រព្រឹត្ត(សកម្មភាពផ្ទាល់របស់ខ្លួន)មានចែងនៅក្នុងរដ្ឋធម្មនុញ្ញ១៩៤៧។[75]

រដ្ឋមន្ត្រីទាំងឡាយរបស់រាជរដ្ឋាភិបាល មិនអាចយកសម្អាងនៃសេចក្តីបង្គាប់បញ្ជា ដោយលាយលក្ខណ៍អក្សរឬដោយវាចាអំពីនរណាម្នាក់ដើម្បីដោះសាឲ្យរួចផុតពីការទទួលខុសត្រូវរបស់

[73] មាត្រា៩៦រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាសម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៤៧។

[74] មាត្រា៩៧រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាសម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៤៧។

[75] មាត្រា៩៨រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាសម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៤៧។

ខ្លួនបានឡើយ។

ក្នុងករណី បើមានអ្នកតំណាងរាស្ត្រ១រូប ឬច្រើនរូប បានតាំងសំណួរដោយវាចាក្តី ដោយលាយលក្ខណ៍អក្សរក្តី ឬតាំងសំណួរដេញដោលក្តីដើម្បីឲ្យរដ្ឋមន្ត្រីឆ្លើយដោះសាអំពីការប្រព្រឹត្តក្នុងមុខងារក្រសួងរបស់ខ្លួន នោះរដ្ឋមន្ត្រីត្រូវរាយការណ៍តាមសេចក្តីស្នើសុំជូនរដ្ឋសភាភ្លាម។[76]

បើរដ្ឋសភាបានពិភាក្សា និងបានព្រមព្រៀងគ្នារួចហើយ ទើបគណៈរដ្ឋមន្ត្រីអាចសុំឲ្យរដ្ឋសភាបញ្ចេញមតិអំពីសេចក្តីទុកចិត្តក្នុងគណៈរដ្ឋមន្ត្រីបាន។

ការស្នើសុំឲ្យរដ្ឋសភាបញ្ចេញមតិខាងលើ ជាការៈរបស់នាយករដ្ឋមន្ត្រីតែម្នាក់ឯងគត់កាល បើនាយករដ្ឋមន្ត្រីស្នើសុំឲ្យរដ្ឋសភាបញ្ចេញមតិ អំពីសេចក្តីទុកចិត្តនោះ ត្រូវបង្អង់ពេលវេលាយ៉ាងតិច១ថ្ងៃគត់គិតពីថ្ងៃដែលបានស្នើសុំ ទើបរដ្ឋសភាបញ្ចេញមតិអំពីរឿងនោះបាន ការបញ្ចេញមតិនេះត្រូវធ្វើឡើងដោយវិធីបោះឆ្នោតជាសាធារណៈ។ រដ្ឋសភានឹងអនុម័តសេចក្តីទុកចិត្តលើគណៈរដ្ឋមន្ត្រីនោះបាន លុះត្រាតែបានអនុម័តបានសម្លេងភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល បើរដ្ឋសភាមិនយល់ព្រមលើសេចក្តីទុកចិត្តទេនោះនាំឲ្យគណៈរដ្ឋមន្ត្រីត្រូវលាឈប់។[77]

ការបើរដ្ឋសភាបញ្ចេញមតិតាំងញ្ញត្តិបន្ទោស គណៈរដ្ឋមន្ត្រីនោះ រដ្ឋមន្ត្រីត្រូវលាឈប់ទាំងគណៈតែម្តង កាលបើតំណាងរាស្ត្រ ស្នើសុំឲ្យរដ្ឋសភាបញ្ចេញមតិតាំងញ្ញត្តិបន្ទោសគណៈរដ្ឋមន្ត្រីនោះរដ្ឋសភាត្រូវបង្អង់ពេលវេលាយ៉ាងតិច១ថ្ងៃគត់គិតពីថ្ងៃដែលបានស្នើសុំ ទើបរដ្ឋសភាបញ្ចេញមតិអំពីរឿងនោះបាន ការបញ្ចេញមតិនេះត្រូវធ្វើឡើង ដោយវិធីបោះឆ្នោតជាសាធារណៈ។ ឯការតាំងញ្ញត្តិបន្ទោសលើគណៈរដ្ឋមន្ត្រី នឹងអាចយកជាការបាន លុះត្រាតែបានអនុម័ត ដោយសម្លេងភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។[78]

រដ្ឋសភា អាចដកសេចក្តីទុកចិត្ត ចំពោះតែលើរដ្ឋមន្ត្រី ឬរដ្ឋលេខាធិការណាមួយក៏បាន ឬបញ្ចេញមតិបន្ទោសចំពោះតែទៅលើរូបរដ្ឋមន្ត្រីឬរដ្ឋលេខាធិការរូបណាមួយក៏បាន អាស្រ័យហេតុនេះរដ្ឋមន្ត្រី ឬរដ្ឋលេខាធិការនោះត្រូវដកខ្លួនចេញពីគណៈរដ្ឋមន្ត្រីក៏ប៉ុន្តែបើនាយករដ្ឋមន្ត្រីដំទាស់មិនព្រមឲ្យឈប់ចេញពីតំណែង នាយករដ្ឋមន្ត្រីត្រូវសុំឲ្យរដ្ឋសភាបញ្ចេញមតិ អំពីសេចក្តីទុកចិត្តចំពោះគណៈរដ្ឋមន្ត្រីទាំងមូលតែម្តង។[79]

---

[76] មាត្រា១០០រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាសម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៤៧។

[77] មាត្រា១០១រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាសម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៤៧។

[78] មាត្រា១០២រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាសម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៤៧។

[79] មាត្រា១០៣រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាសម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៤៧។

៣-កិច្ចប្រជុំគណៈរដ្ឋមន្ត្រី

(Meeting of Cabinet of Minister)

ជាទូទៅគណៈរដ្ឋមន្ត្រីត្រូវប្រជុំជារៀងរាល់សប្តាហ៍ ដូនកាលជាការប្រជុំធំ ដោយមានព្រះមហាក្សត្រ ឬនាយករដ្ឋមន្ត្រីជាគណៈអធិបតី ហើយដូនកាលជាការប្រជុំតូច។[80]

កិច្ចប្រជុំគឺជាដំណើរការប្រព្រឹត្តទៅលើការពិនិត្យ និងកែសម្រួលលើទិដ្ឋភាពទាំងទម្រង់ទាំងខ្លឹមសារគតិយុត្តនានា រួមទាំងផលប៉ះពាល់លើ ផ្នែកច្បាប់ សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងគោលនយោបាយរបស់រាជរដ្ឋាភិបាលផងដែរ។

រដ្ឋមន្ត្រីទាំងឡាយអាចចូលនិយាយការនៅក្នុងទីប្រជុំនៃសភាទាំងពីរ និងក្នុងទីការប្រជុំនៃគណៈកម្មការទាំងឡាយនៃសភាទាំងនោះបាន ហើយរដ្ឋមន្ត្រីទាំងនោះអាចបញ្ចេញមតិយោបល់គ្រប់បែបយ៉ាងនៅក្នុងការប្រជុំនីមួយៗ នៅពេលពិភាក្សានៅក្នុងការប្រជុំសភានីមួយៗរដ្ឋមន្ត្រីអាចចាត់តាំងអ្នកស្នងរាជការឲ្យជួយនិយាយការបានផងដែរ។[81]

៤.វិសមិតភាពនៃសមាជិករាជរដ្ឋាភិបាល

(Incompatibility of Government Members)

វិសមិតភាពសមាជិករាជរដ្ឋាភិបាល គឺជាការហាមឃាត់ ចំពោះសមាជិករាជរដ្ឋាភិបាលមិនឲ្យបំពេញមុខងារច្រើនក្នុងពេលតែមួយ ក្នុងអាណត្តិនយោបាយ និងសកម្មភាពខាងវិជ្ជាជីវៈ ខាងផ្នែកពាណិជ្ជកម្ម ឬឧស្សាហកម្ម ហើយនឹងការកាន់តំណែងណាមួយនៅក្នុងមុខងារសាធារណៈ។

ជនម្នាក់ អាចទទួលតំណែងជាតំណាងរាស្ត្រ ជាទីប្រឹក្សាព្រះរាជាណាចក្រ និងជារដ្ឋមន្ត្រីផងក៏បានដោយមិនមានវិសមិតភាពនោះទេ។

សមាជិកនៃអង្គការធំៗទាំងបីគឺមិនមានវិសមិតភាពទេ ដែលក្នុងនោះបានចែងទៀតថា "គ្មានវិសមិតភាពណាមួយទេ រវាងអាណត្តិសភា(The mandate of National Assembly) និងភារៈនៃសមាជិករាជរដ្ឋាភិបាល ដែលនឹងអាចយកទៅធ្វើជាសមាជិកនៃរដ្ឋសភា និងជាសមាជិកនៃក្រុមប្រឹក្សាព្រះរាជាណាចក្រ(The Royal Council) ឬក៏ឥស្សរជន ដែលមិនមែនជាសមាជិកនៃសភាទាំងពីរក៏អាចយកមកធ្វើជាសមាជិកនៃរាជរដ្ឋាភិបាលក៏បានដែរ"។[82]

រាជរដ្ឋាភិបាលនេះហើយ ត្រូវបានបំពេញបេសកកម្មនានា ដើម្បីបម្រើដល់ផលប្រយោជន៍

[80] មាត្រា១០៤រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាសម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៤៧។

[81] មាត្រា១០៥រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាសម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៤៧។

[82] មាត្រា៩៦វាក្យខណ្ឌទី២រដ្ឋធម្មនុញ្ញនៃសម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៤៧។

របស់ប្រជាពលរដ្ឋរស់នៅលើទឹកដី ដែលខ្លួនគ្រប់គ្រង។

ដើម្បីឆ្លើយតបទៅនឹង តម្រូវការចាំបាច់នូវជីវភាពរស់នៅប្រចាំថ្ងៃ របស់ប្រជាពលរដ្ឋនោះ រាជរដ្ឋាភិបាលបានបង្កើតស្ថាប័នរដ្ឋបាលនេះឡើង ដែលនៅជាមួយនឹងប្រជាពលរដ្ឋ បម្រើផលប្រយោជន៍ប្រជាពលរដ្ឋ ដែលអំណាចរដ្ឋបាលត្រូវបានប្រគល់ឲ្យអាជ្ញាធររដ្ឋបាលដើម្បីសម្រេចកិច្ចការនានាជាប្រយោជន៍ទូទៅផងដែរ ប៉ុន្តែរាល់ការប្រើអំណាចទាំងនេះត្រូវគោរពព្រំដែន ដែលច្បាប់បានកំណត់។

ដើម្បីបញ្ជាក់ អំពីព្រំដែននៃអំណាចនោះ យន្តការត្រួតពិនិត្យ ឬប្រព័ន្ធត្រួតពិនិត្យមួយចំនួនត្រូវបានបង្កើតឡើង ដើម្បីធ្វើការត្រួតពិនិត្យលើសកម្មភាពទាំងឡាយរបស់រដ្ឋបាល យន្តការនយោបាយធ្វើឡើងតាមរយៈរដ្ឋសភា យន្តការរដ្ឋបាលធ្វើឡើង ដោយរដ្ឋបាលខ្លួនឯងផ្ទាល់ តាមការប្រើអំណាចហានុក្រម។

រាជរដ្ឋាភិបាល ដែលបានបង្កើតឡើងនៅក្នុងសម័យសង្គមរាស្ត្រនិយម ចាប់ពីឆ្នាំ១៩៤៧ មកត្រូវបានធ្វើការផ្លាស់ប្តូរជាញឹកញាប់ក្នុងនោះរួមមាន:

-រាជរដ្ឋាភិបាលព្រះបាទ ស៊ីសុវត្ថិ យុត្តិវង្ស ចាប់ពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៤៦ ដល់ថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ១៩៤៧។

-រាជរដ្ឋាភិបាលព្រះបាទ ស៊ីសុវត្ថិ ធាយាវង្ស ពីថ្ងៃទី២៥ ខែកក្កដាឆ្នាំ១៩៤៧ ដល់ថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ១៩៤៨។

-រាជរដ្ឋាភិបាល ឈាន វ៉ែម ចាប់ពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ១៩៤៨ ដល់ថ្ងៃទី០៤ ខែសីហា ឆ្នាំ១៩៤៨។

-រាជរដ្ឋាភិបាល ប៉ែន នុត ចាប់ពីថ្ងៃទី១៥ ខែ សីហា ឆ្នាំ ១៩៤៨ ដល់ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ១៩៤៩។

-រាជរដ្ឋាភិបាល យ៉ែម សំបូរ ចាប់ពីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៤៩ ដល់ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៤៩។

-រាជរដ្ឋាភិបាល អៀវ កើស ចាប់ពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៤៩ ដល់ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៤៩។

-រាជរដ្ឋាភិបាល យ៉ែម សំបូរចាប់ពីថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ១៩៤៩ដល់ថ្ងៃទី០២ ខែឧសភា ឆ្នាំ១៩៥០។

-រាជរដ្ឋាភិបាល ព្រះបាទ ស៊ីសុវត្ថិ មុនីពង្ស ចាប់ពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ១៩៥០ ដល់ថ្ងៃទី០២ ខែមីនា ឆ្នាំ១៩៥១។

-រាជរដ្ឋាភិបាល អ៊ុម ឈាងស៊ុន ចាប់ពីថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៥១ ដល់ថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៥១។

-រាជរដ្ឋាភិបាល ហ៊ុយ កន្ទុលចាប់ពីថ្ងៃទី ១៣ ខែតុលា ឆ្នាំ១៩៥១ដល់ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៥២។

-រាជរដ្ឋាភិបាលព្រះបាទ នរោត្តម សីហនុ ចាប់ពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៥២ដល់ថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ១៩៥៣។

-រាជរដ្ឋាភិបាល ចាន់ ណាក ចាប់ពីថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ដល់ថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៥៤។

-រាជរដ្ឋាភិបាល ប៉ែន នុត ចាប់ពីថ្ងៃទី ១៨ ខែមេសា ឆ្នាំ១៩៥៤ ដល់ថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៥៥។

-រាជរដ្ឋាភិបាល ឡេង ង៉ែត ចាប់ពីថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៥៥ ដល់ថ្ងៃទី០៣ ខែតុលា ឆ្នាំ១៩៥៥។

-រាជរដ្ឋាភិបាលព្រះបាទ នរោត្តម សីហន ចាប់ពីថ្ងៃទី០៣ ខែតុលា ឆ្នាំ១៩៥៥ដល់ថ្ងៃទី៥ ខែមករា ឆ្នាំ១៩៥៦។

-រាជរដ្ឋាភិបាល អ៊ុម ឈាងស៊ុន ចាប់ពីថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៥៦ ដល់ថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ១៩៥៥។

-រាជរដ្ឋាភិបាលព្រះបាទ នរោត្តម សីហនុ ចាប់ពីថ្ងៃទី០១ ខែមីនា ឆ្នាំ១៩៥៦ ដល់ថ្ងៃទី ០៣ ខែមេសា ឆ្នាំ១៩៥៦។

-រាជរដ្ឋាភិបាល ឃឹម ទិត ចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ១៩៥៦ ដល់ថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ១៩៥៦។

-រាជរដ្ឋាភិបាលព្រះបាទ នរោត្តម សីហនុ ចាប់ពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៥៦ ដល់ថ្ងៃទី ២៥ ខែតុលា ឆ្នាំ១៩៥៦។

-រាជរដ្ឋាភិបាល សាន យុន ចាប់ពីថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៥៦ ដល់ថ្ងៃ ទី០៩ ខែមេសា ឆ្នាំ១៩៥៧។

-រាជរដ្ឋាភិបាលព្រះបាទ នរោត្តម សីហនុ ចាប់ពីថ្ងៃទី ០៩ ខែ មេសា ឆ្នាំ១៩៥៧ ដល់ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៥៧។

-រាជរដ្ឋាភិបាល ស៊ឹម វ៉ា ចាប់ពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៥៧ ដល់ថ្ងៃទី២១ ខែមករា ឆ្នាំ ១៩៥៨។

-រាជរដ្ឋាភិបាល ប៉ែន នុត ចាប់ពីថ្ងៃទី ២១ ខែមករា ឆ្នាំ ១៩៥៨ ដល់ ថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៥៨។

-រាជរដ្ឋាភិបាល ស៊ឹម វ៉ា ចាប់ពីថ្ងៃទី២៩ ខែ មេសា ឆ្នាំ១៩៥៨ ដល់ថ្ងៃ ទី១០ ខែកក្កដា ឆ្នាំ១៩៥៨។

-រាជរដ្ឋាភិបាលព្រះបាទ នរោត្តម សីហនុ ចាប់ពីថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ១៩៥៨ ដល់ ថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៦០។

-រាជរដ្ឋាភិបាល ផូ ព្រឿង ចាប់ពីថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៦០ ដល់ថ្ងៃទី២៨ ខែមករា ឆ្នាំ ១៩៦១។

-រាជរដ្ឋាភិបាលព្រះបាទ នរោត្តម សីហនុ ចាប់ពីថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៦១ ដល់ថ្ងៃ ទី០៦ ខែសីហា ឆ្នាំ១៩៦២។

-រាជរដ្ឋាភិបាល ចៅសែនកុសល ឈុំ ចាប់ពីថ្ងៃទី៦ ខែសីហា ឆ្នាំ១៩៦២ ដល់ថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៦២។

-រាជរដ្ឋាភិបាលព្រះបាទ នរោត្តម កន្ទុល ចាប់ពីថ្ងៃទី៦ ខែតុលា ឆ្នាំ១៩៦២ ដល់ថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៦៦។

-រាជរដ្ឋាភិបាលលន់ ណល់ ចាប់ពីថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៦៦ ដល់ថ្ងៃ ទី៣០ ខែមេសា ឆ្នាំ១៩៦៧។

-រាជរដ្ឋាភិបាលព្រះបាទ នរោត្តម សីហនុ ចាប់ពីថ្ងៃទី០១ ខែ ឧសភា ឆ្នាំ១៩៦៧ ដល់ថ្ងៃ ទី៣១ ខែមករា ឆ្នាំ១៩៦៨។

-រាជរដ្ឋាភិបាល ប៉ែន នុត ចាប់ពីថ្ងៃទី ៣១ ខែមករា ឆ្នាំ១៩៦៨ ដល់ ថ្ងៃទី១៣ ខែសីហា ឆ្នាំ១៩៦៩។

-រាជរដ្ឋាភិបាលលន់ ណល់ចាប់ពីថ្ងៃទី១៤ ខែសីហា ឆ្នាំ១៩៦៩ រហូតដល់ថ្ងៃទី១៨ ខែមីនាឆ្នាំ១៩៧០ គឺជារាជរដ្ឋាភិបាល ដែលមានឈ្មោះថា “រាជរដ្ឋាភិបាលស្រោចស្រង់ជាតិ”។[83]

រាជរដ្ឋាភិបាលរបស់លោកលន់ នល់គឺជារាជរដ្ឋាភិបាលចុងក្រោយគេបង្អស់នៅក្នុងសម័យរបបសង្គមរាស្ត្រនិយម។

នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៦៩ រដ្ឋមន្ត្រីមួយចំនួន ដែលស្មោះត្រង់ជាមួយព្រះបាទសម្តេច

[83] ពុយ គា រដ្ឋាភិបាលកម្ពុជាពីឆ្នាំ១៩៤៥ដល់ឆ្នាំ២០១០ បោះពុម្ពលើកទី២ទំព័រ៤ ដល់ទំព័រ៨៥។

នរោត្តម សីហនុ បានសុំលាលែងពីតំណែងនៅក្នុងរាជរដ្ឋាភិបាលជាបន្តបន្ទាប់។

នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ រដ្ឋសភា និងក្រុមប្រឹក្សាព្រះរាជាណាចក្របានកោះប្រជុំជាសម្ងាត់មួយ ដោយបោះឆ្នោតទម្លាក់ សម្តេច ព្រះនរោត្តម សីហនុ ពីតំណែងជាប្រមុខរដ្ឋ ដែល លោក ចេង ហេង ជាប្រធានរដ្ឋសភាពេលនោះ ត្រូវបានតែងតាំងជំនួសចាប់តាំងពីពេលនោះមក របបសង្គមរាស្ត្រនិយមត្រូវបានបញ្ចប់ជាស្ថាពរ ហើយរបបនយោបាយថ្មីមួយក៏ត្រូវបានបង្កើតឡើង គឺរបបសាធារណរដ្ឋខ្មែរ។

ឃ.សមាជជាតិ

(National Congress)

សម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៤៧បានកំណត់ឲ្យមានសមាជជាតិ។ ទោះបីសមាជជាតិតាមផ្លូវបច្ចេកទេស ដែលមិនមែនជាផ្នែកមួយនៃអង្គការនីតិប្បញ្ញត្តិក៏ដោយ ក៏គេអាចចាត់ទុកថាជា “គណៈកម្មាធិការផ្តល់យោបល់របស់ប្រជាពលរដ្ឋ” ដូចជារដ្ឋសភាជាតិដែរ គោលបំណងនៃសមាជជាតិ គឺដើម្បីធ្វើឲ្យប្រជាពលរដ្ឋបានជ្រាបដោយផ្ទាល់អំពីកិច្ចការ ដែលជាប្រយោជន៍ជាតិ និងផ្តល់វេទិកា ជូនដល់ប្រជាពលរដ្ឋម្នាក់ៗគឺដើម្បីលើកយកនូវបញ្ហាផ្សេងៗ និងសំណូមពរជូនចំពោះសមាជជាតិ។[84]

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទអាចចូលរួមក្នុងសមាជជាតិបានទាំងអស់។

សមាជជាតិ ត្រូវបើកធ្វើឡើងជារៀងរាល់ឆ្នាំ ហើយត្រូវប្រជុំយ៉ាងតិច២ដងក្នុង១ឆ្នាំ តាមរយៈការកោះអញ្ជើញរបស់នាយករដ្ឋមន្ត្រី ហើយស្ថិតនៅក្រោមព្រះរាជាធិបតីភាពរបស់ព្រះមហាក្សត្រ។ សមាជជាតិ គឺមិនអាចធ្វើច្បាប់ទេ ប៉ុន្តែអាចអនុម័តសេចក្តីស្នើយោបល់ សម្រាប់រាជរដ្ឋាភិបាល រដ្ឋសភា ឬព្រឹទ្ធសភាធ្វើការពិចារណា និងជួយដោះស្រាយ តាមរយៈសំណូមពរទាំងឡាយគ្រប់បែបយ៉ាងរបស់ប្រជារាស្ត្រ។[85]

រដ្ឋសភាអាចចាត់ចែងធ្វើប្រជាមតិឡើងបាន ចំពោះបញ្ហាទាំងឡាយណា ដែលជាសេចក្តីសម្រេចរបស់សមាជជាតិ។

[84] មាត្រា៩២រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាសម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៤៧។

[85] មាត្រា៩៣រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាសម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៤៧។

ផ្នែកទី២

ស្ថាប័ននយោបាយសម័យសាធារណរដ្ឋខ្មែរ

(Political Institutions in Khmer Republic)

ប្រទេសកម្ពុជា ត្រូវបានប្រកាសរបបនយោបាយគ្រប់គ្រងរដ្ឋថ្មី ទៅជាសាធារណរដ្ឋខ្មែរ នៅថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧០តាមបញ្ញត្តិលេខ:៤៤២/៧០បរចុះថ្ងៃទី0៨ ខែតុលា ឆ្នាំ១៩៧០ ស្ថាប័នកំពូលៗរបស់ព្រះរាជាណាចក្រកម្ពុជាត្រូវបានរក្សាទុកឲ្យនៅដដែលទាំងអស់ លើកលែងតែស្ថាប័នព្រះមហាក្សត្រត្រូវបានលុបបំបាត់ចោល។

នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៧២ រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋខ្មែរ ត្រូវបានប្រកាសឲ្យប្រើតាមបញ្ញត្តិលេខ:១៩១/៧២.បសខ។

រដ្ឋធម្មនុញ្ញឆ្នាំ១៩៧២បានចែងអំពីស្ថាប័ននយោបាយសំខាន់ៗ ដែលមានដូចជាស្ថាប័នប្រធានាធិបតី ស្ថាប័ននីតិប្បញ្ញត្តិដែលមានរដ្ឋសភា និងព្រឹទ្ធសភា ស្ថាប័ននីតិប្រតិបត្តិដែលមានរដ្ឋាភិបាល និងស្ថាប័នតុលាការធម្មនុញ្ញ។

ក.ប្រធានាធិបតី

(President)

សម័យសាធារណរដ្ឋខ្មែរ ប្រទេសកម្ពុជាយើង បានប្រកាន់យករបបនយោបាយមួយ ដែលបានយករបបនយោបាយរបស់សហរដ្ឋអាមេរិក មកធ្វើជាគំរូ គឺការអនុវត្តន៍របបប្រធានាធិបតីនិយម ដែលយកប្រធានាធិបតីជាធំ។

ប្រធានាធិបតីកាន់អំណាចនីតិប្រតិបត្តិ និងមានអនុប្រធានាធិបតី១រូប ធ្វើជាជំនួយការ។

ប្រធានាធិបតី និងអនុប្រធានាធិបតីត្រូវបានធ្វើការបោះឆ្នោតជ្រើសរើសនៅក្នុងពេលតែមួយដូចគ្នាដែលមានអាណត្តិ៥ឆ្នាំ។

ការបោះឆ្នោត ត្រូវធ្វើឡើងជាសាកល ដោយចំពោះ និងជាសម្ងាត់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរ។[86]

ប្រធានាធិបតីមានសិទ្ធិឈរឈ្មោះឲ្យគេបោះឆ្នោត បានត្រឹមតែពីរអាណត្តិទេ។

១-លក្ខខណ្ឌឈរឈ្មោះ

(Condition of the Candidates)

ជាទូទៅ អ្នកដែលអាចឈរឈ្មោះ បេក្ខជនប្រធានាធិបតី និងអនុប្រធានាធិបតីបានគឺត្រូវ

[86] មាត្រា២៤នៃរដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរឆ្នាំ១៩៧២។

មានលក្ខខណ្ឌដូចជា:

-ត្រូវមានសញ្ជាតិខ្មែរតាំងពីកំណើតរហូតមក

-កើតពីមាតា បិតាមានសញ្ជាតិជាខ្មែរ

-ត្រូវមានសហពទ្ធ ជាសញ្ជាតិខ្មែរពីកំណើត បើជាស្វាមី ភរិយា ឬជាស្វាមី ភរិយា ដែលពេញលក្ខណៈច្បាប់។

-ត្រូវមានអាយុយ៉ាងតិចសែសិប(៤០)ឆ្នាំគិតមកដល់ថ្ងៃបោះឆ្នោត

-ជាអ្នកមានសិទ្ធិ បោះឆ្នោតស្របតាមលក្ខខណ្ឌផ្សេងៗទៀត ដូចមានចែងក្នុងច្បាប់រៀបចំអង្គការ[87]។

២-តួនាទីរបស់ប្រធានាធិបតី

(The President's Roles)

ប្រធានាធិបតីមានតួនាទីសំខាន់ៗដូចជា:

-ជាអ្នកតែងតាំងរដ្ឋមន្ត្រីទី១ឬតែងតាំង ឬដកហូតតំណែងរបស់សមាជិករដ្ឋាភិបាល និងមន្ត្រីរាជការស៊ីវិល និងយោធាទាំងមូល។

-ប្រធានាធិបតីដឹកនាំការប្រជុំពិភាក្សានៃគណៈរដ្ឋមន្ត្រី ក្នុងករណីអវត្តមាន ប្រធានាធិបតីអនុប្រធានាធិបតីត្រូវដឹកនាំការប្រជុំជំនួសប្រធានាធិបតី។ ក្នុងករណី អនុប្រធានាធិបតីអវត្តមានទៀត រដ្ឋមន្ត្រីទី១អាចដឹកនាំអង្គប្រជុំដើម្បីបំពេញការងារជំនួសប្រធានាធិបតីបាន។[88]

-ប្រធានាធិបតីជាមេបញ្ជាការជាន់ខ្ពស់បំផុត លើកងទ័ពសាធារណរដ្ឋខ្មែរ

-ប្រធានាធិបតី តែងតាំងឯកអគ្គរដ្ឋទូត និងប្រេសិតវិសាមញ្ញជាតំណាងសាធារណរដ្ឋខ្មែរនៅក្រៅប្រទេស រីឯឯកអគ្គរដ្ឋទូត ឬរាជទូត និងប្រេសិតវិសាមញ្ញបរទេសត្រូវទទួលភារៈតាំងឲ្យនៅអមប្រធានាធិបតីនៃសាធារណរដ្ឋ។[89]

-ប្រធានាធិបតីនៃសាធារណរដ្ឋចុះហត្ថលេខាលើសន្ធិសញ្ញានិងអនុសញ្ញាអន្តរជាតិហើយផ្តល់សច្ចាប័នលើឯកសារទាំងនោះ គឺអាស្រ័យដោយការអនុម័តនៃសភាទាំពីរ។[90]

-ជាអ្នកផ្តល់គ្រឿងឥស្សរិយយសជាតិ លើកលែងទោស និងបន្ធូរបន្ថយទោស[91]

---

[87] មាត្រា២៥រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋខ្មែរ។

[88] មាត្រា៣៣រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋខ្មែរ។

[89] មាត្រា៣៧រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋខ្មែរ។

[90] មាត្រា៣៨រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋខ្មែរ។

[91] មាត្រា៤២រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋខ្មែរ។

-ប្រធានាធិបតីតែងតាំងរដ្ឋមន្ត្រីទី១ ហើយនឹងសមាជិករដ្ឋាភិបាលផ្សេងទៀតតាមសេចក្តីស្នើពីរដ្ឋមន្ត្រីទី១ ប្រធានាធិបតីមានសិទ្ធិបញ្ឈប់សមាជិករដ្ឋាភិបាលមួយរូបៗ ឬទាំងអស់គ្នាចេញពីមុខតំណែងរបស់ខ្លួនបាន។[92]

-ប្រធានាធិបតីចុះហត្ថលេខាលើក្រឹត្យ និងប្រកាសឲ្យប្រើច្បាប់

-ច្បាប់ដែលសហសភាបានបញ្ចេញមតិយល់ព្រមជាស្ថាពររួចហើយ ត្រូវតែប្រកាសឲ្យប្រើក្នុងរយៈពេល១៥ថ្ងៃ បន្ទាប់ពីពេល ដែលប្រធានាធិបតីនៃសាធារណរដ្ឋបានទទួលច្បាប់នោះមុនពេលផុតកំណត់រយៈពេលនេះ ប្រធានាធិបតីអាចស្នើសុំឲ្យសហសភាពិនិត្យ និងពិភាក្សានូវច្បាប់ឬមាត្រាខ្លះនៃច្បាប់នោះសាជាថ្មីឡើងវិញបាន។ការពិភាក្សា និងសម្រេចនេះត្រូវធ្វើឡើងក្នុងរយៈពេល២០ថ្ងៃយ៉ាងយូរ។[93]

ខ.អង្គការនីតិប្បញ្ញត្តិ

(Legislative Boby)

នៅក្នុងរបបសាធារណរដ្ឋខ្មែរ អង្គការនីតិប្បញ្ញត្តិត្រូវបានបង្កើតឡើងជាទ្វិកសភា(សភាពីរថ្នាក់) ដែលមានរដ្ឋសភា និងព្រឹទ្ធសភា ដែលអង្គការនេះមានចែងក្នុងជំពូកទី៥ នៃរដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរ។[94]

១-រដ្ឋសភា

(Assembly)

រដ្ឋសភាជាតិគឺមានសមាជិកយ៉ាងតិចចំនួន៨០នាក់ ហើយត្រូវបានបង្កើតឡើងដោយការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ដែលមានលក្ខណៈជាសាកលដោយចំពោះនិងជាសម្ងាត់ និងមានអាណត្តិ៤ឆ្នាំ។

តំណាងរាស្ត្រ អាចឈរឈ្មោះឲ្យគេបោះឆ្នោតសាជាថ្មីបាន ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរ។

អ្នកដែលអាចឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រគឺជាប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលត្រូវមានអាយុយ៉ាងតិច២៥ឆ្នាំហើយមានសិទ្ធិបោះឆ្នោត។[95]

ការបោះឆ្នោតជ្រើសរើស សមាជិករដ្ឋសភា និងសមាជិកព្រឹទ្ធសភាទាំង ពីរត្រូវបានកម្រិត

[92] មាត្រា៣៨រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋខ្មែរ។

[93] មាត្រា៣៥នៃរដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរ។

[94] មាត្រា៤៦នៃរដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរ។

[95] មាត្រា៤៧នៃរដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរ។

បែបបទ នៅក្នុងច្បាប់បោះឆ្នោតនៃសាធារណរដ្ឋខ្មែរ។[96]

ក្នុងករណី ដែលប្រទេសជាតិមានសង្គ្រាម ឬអសន្តិសុខមិនអាចធ្វើការបោះឆ្នោតទៅបាន ប្រធានាធិបតីអាចពន្យាអាណត្តិនៃការបោះឆ្នោតជ្រើសរើសសមាជិកសហសភាទាំងពីរបាន ប៉ុន្តែត្រូវមានការពិគ្រោះយោបល់ជាមួយតុលាការធម្មនុញ្ញជាមុនសិន។[97]

២-ព្រឹទ្ធសភា

(Senate)

ព្រឹទ្ធសភានៃសាធារណរដ្ឋខ្មែរត្រូវបានបង្កើតឡើង ដោយការបោះឆ្នោតជ្រើសរើសសមាជិកព្រឹទ្ធសភានីតិកាលទី១ ដែលប្រព្រឹត្តទៅត្រូវនឹងថ្ងៃអាទិត្យ ទី១៧ ខែកញ្ញា ឆ្នាំ១៩៧២ ដែលមានលក្ខណៈជាសាកល ជាសមូាត់ និងដោយចំពោះ ហើយបោះឆ្នោតសម្រាប់អាណត្តិ៦ឆ្នាំ។

សមាជិកព្រឹទ្ធសភាមានចំនួនពី២៨រូបទៅ៤០រូប ហើយដែលត្រូវបានធ្វើការផ្លាស់ប្តូរចំនួន ៣ក់កណ្តាលជារៀងរាល់៣ឆ្នាំម្តង។

សមាជិកព្រឹទ្ធសភាមានសមាសភាព ដែលត្រូវបានបោះឆ្នោតជ្រើសរើសមានដូចតទៅ:

-មកពីតំណាងតាមភូមិភាគទាំង៨ រួមមានចំនួនបីភាគប្រាំ(៣/៥)នៃចំនួនសមាជិកព្រឹទ្ធសភាសរុបដែលមានចំនួនស្មើនឹង២៤រូប។

-មកពីតំណាងរដ្ឋការស៊ីវិលមានចំនួនទាំងអស់មួយភាគប្រាំ(១/៥) នៃចំនួនសមាជិកសរុបដែលមានចំនួនស្មើនឹង៨រូប។

-មកពីតំណាងក្រុមប្រឹក្សាសេនានុភាព ត្រូវមានចំនួនមួយភាគប្រាំ(១/៥)នៃចំនួនសមាជិកសរុបដែលមានចំនួន៨រូប។[98]

ចំនួនសមាជិកព្រឹទ្ធសភា ដែលបានធ្វើការជ្រើសតាំង ដោយភូមិភាគនីមួយៗចំនួន២៤រូបត្រូវបានកំណត់ដូចតទៅ:

-ភូមិភាគពិសេសមានក្រុងភ្នំពេញ និងខេត្តកណ្តាល មានចំនួន៥អាសនៈ

-ភូមិភាគទី១មានខេត្តកំពង់ចាម ខេត្តព្រៃវែង និងខេត្តស្វាយរៀង មាន ចំនួន៤អាសនៈ

-ភូមិភាគទី២មានខេត្តកំពង់សោម ខេត្តតាកែវ ខេត្តកំពត ខេត្តកំពង់ស្ពឺ និងខេត្តកោះកុង មានចំនួន៤អាសនៈ

-ភូមិភាគទី៣ មានខេត្តកំពង់ឆ្នាំង ខេត្តពោធិសាត់ និងខេត្តបាត់ដំបងមានចំនួន៤អាសនៈ

[96] មាត្រា៥១នៃរដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរ។

[97] មាត្រា៤៩នៃរដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរ។

[98] មាត្រា៤៨នៃរដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរ។

-ភូមិភាគទី៤ មានខេត្តសៀមរាប ខេត្តកំពង់ធំ ខេត្តឧត្តរមានជ័យ និងខេត្ត ព្រះវិហារមានចំនួន៤អាសនៈ

-ភូមិភាគទី៥មានខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី និងខេត្តមណ្ឌលគិរីមានចំនួន៣អាសនៈ។

តាមភូមិភាគនីមួយៗត្រូវជ្រើសតាំងសមាជិកព្រឹទ្ធសភាតាមចំនួនអាសនៈដែលបានកំណត់ខាងលើ ដោយការបោះឆ្នោតជាសាកលដោយចំពោះ ជាសម្ងាត់ តាមសន្លឹកបញ្ជី ដែលបានទទួលសម្លេងឆ្នោតភាគច្រើនជាងគេត្រូវចាត់ទុកជាអ្នកជាប់ឆ្នោត។

ការជ្រើសតាំងតំណាងរដ្ឋការស៊ីវិលមានចំនួនមួយភាគប្រាំ(១/៥)នៃចំនួនសមាជិកសរុបដែលមានចំនួន៨រូបត្រូវបានជ្រើសរើសតាមក្រុមភូមិភាគនីមួយៗដូចតទៅៈ

-ភូមិភាគពិសេស និងភូមិភាគទី១មានចំនួន៣អាសនៈ

-ភូមិភាគទី២ និងភូមិភាគទី៣មានចំនួន៣អាសនៈ

-ភូមិភាគទី៤ និងភូមិភាគទី៥មានចំនួន២អាសនៈ

បេក្ខជន នៅក្នុងសន្លឹកបញ្ជី ដែលបានទទួលសម្លេងភាគច្រើនជាងគេ ត្រូវចាត់ទុកថា ជាអ្នកជាប់ឆ្នោត។

-ការជ្រើសរើសតំណាងក្រុមប្រឹក្សាសេនានុភាព គឺត្រូវមានចំនួនមួយភាគប្រាំ (១/៥) នៃចំនួនសមាជិកសរុបដែលមានចំនួន៨រូប ត្រូវបានជ្រើសរើស នៅក្នុងចំណោមបេក្ខជនជាទាហានទាំងឡាយដោយសម្លេងភាគច្រើន។

បុគ្គលដែលមានសិទ្ធិឈរឈ្មោះ ឲ្យគេបោះឆ្នោតជ្រើសតាំងជាសមាជិកព្រឹទ្ធសភាបាន គឺជាប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានអាយុយ៉ាងតិច៤០ឆ្នាំ ត្រូវគិតមកដល់ថ្ងៃបោះឆ្នោត និងអ្នកដែលបានបំពេញនូវលក្ខខណ្ឌ ដូចមានចែង ក្នុងច្បាប់បោះឆ្នោតជ្រើសរើសសមាជិករដ្ឋសភានីតិកាលទី១នៃរបបសាធារណរដ្ឋខ្មែរដែរ។

អង្គការព្រឹទ្ធសភា គឺជាអង្គការតំណាងឲ្យភូមិភាគផ្សេងៗ និងអង្គការធំៗ របស់រដ្ឋនៃរបបសាធារណរដ្ឋខ្មែរ។[99]

គ.អង្គការនីតិប្រតិបត្តិ

(Executive)

នៅសម័យសាធារណរដ្ឋខ្មែរតំណែងជានាយករដ្ឋមន្ត្រីត្រូវបានដំនួស ដោយរដ្ឋមន្ត្រីទី១ ហើយរដ្ឋមន្ត្រីទី១ ត្រូវបានទទួលបន្ទុកដឹកនាំគ្រប់គ្រងរដ្ឋាភិបាល និងអង្គការជាតិនានារបស់រដ្ឋា

[99] មាត្រា ៤៨នៃរដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរ។

កិបាលទាំងមូល ហើយរដ្ឋមន្ត្រីទី១និងសហជីវិននានារបស់រដ្ឋាភិបាល ក៏ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខប្រធានាធិបតីដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ។[100]

សមាជិករដ្ឋាភិបាលទាំងអស់ គឺមានវិសមិតភាពជាមួយ នឹងការកាន់តំណែងណាមួយនៅក្នុងមុខងារសោធារណៈផ្នែកពាណិជ្ជកម្ម ឧស្សាហកម្ម និងវិជ្ជាជីវៈណាមួយ។[101]

ឃ.តុលាការធម្មនុញ្ញ

(Constitutional Court)

របបសាធារណរដ្ឋខ្មែរគឺបានបង្កើតរដ្ឋធម្មនុញ្ញមួយនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧២។ រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋខ្មែរនេះ ក៏ត្រូវបានបង្កើតឲ្យមានប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ដែលមានឈ្មោះថា“តុលាការធម្មនុញ្ញ”។

តុលាការធម្មនុញ្ញ មានសមាជិកទាំងអស់មានចំនួន៦រូប ដែលត្រូវធ្វើការជ្រើសរើស និងតែងតាំងសម្រាប់អាណត្តិ៦ឆ្នាំ ហើយសមាជិកតុលាការធម្មនុញ្ញចំនួន៣ក់កណ្តាលត្រូវបានផ្លាស់ប្តូរដៀរៀងរាល់៣ឆ្នាំម្តង។

សមាជិកតុលាការធម្មនុញ្ញ គឺត្រូវធ្វើការជ្រើសរើសចេញពីបេក្ខជនជាបញ្ញវន្ត ឬអ្នកមានបទពិសោធន៍ការងារជាច្រើនឆ្នាំ ដែលមានការយល់ដឹងជ្រៅជ្រះផ្នែកច្បាប់ សេដ្ឋកិច្ច ឬផ្នែករដ្ឋបាល ហើយមានអាទិភាពជាងគេ ចំពោះអ្នកដែលមិនកាន់និន្នាការ គណបក្សនយោបាយ ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរ។[102]

សមាសភាពតុលាការធម្មនុញ្ញ ដែលត្រូវបានធ្វើការជ្រើសតាំងរួមមាន:

-សមាជិកតុលាការធម្មនុញ្ញ២រូប ត្រូវបានតែងតាំងដោយប្រធានាធិបតីដែលបានសម្រេចដោយគណៈរដ្ឋមន្ត្រី។

-សមាជិកតុលាការធម្មនុញ្ញ២រូបត្រូវបានជ្រើសរើស ដោយអង្គការនីតិប្បញ្ញត្តិគឺរដ្ឋសភា។

-សមាជិកតុលាការធម្មនុញ្ញ២រូបទៀត ត្រូវបានធ្វើការជ្រើសរើសដោយអង្គការនីតិប្បញ្ញត្តិគឺព្រឹទ្ធសភាដែលមិនមែនជាសមាជិកព្រឹទ្ធសភា។

សមាជិកតុលាការធម្មនុញ្ញទាំង៦រូបនេះ ត្រូវបានធ្វើការជ្រើសរើសប្រធាន១រូបដើម្បីធ្វើការដឹកនាំនៅក្នុងចំណោមសមាជិករបស់ខ្លួន។ ក្នុងករណី មានការបោះឆ្នោត ដើម្បីសម្រេចអំពីបញ្ហាការងារសំខាន់ៗអ្វីមួយ ត្រូវតែអនុម័តយកសម្លេងភាគច្រើនដាច់ខាត(៥០+១)ក៏ប៉ុន្តែ ប្រសិនបើមានសម្លេងបែកជាពីរស្មើគ្នា នោះសម្លេងរបស់ប្រធានតុលាការធម្មនុញ្ញ គឺជាសម្លេងមានឧត្តមានុ

[100] មាត្រា៤៣នៃរដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរ។

[101] មាត្រា៤៤នៃរដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរ។

[102] មាត្រា៩៣នៃរដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរ។

ភាពដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ។[103]

សមាជិករបស់តុលាការធម្មនុញ្ញមានតួនាទីសំខាន់ៗដូចជា:

-ត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់

-បកស្រាយចុងក្រោយនូវបញ្ញត្តិនៃរដ្ឋធម្មនុញ្ញ

-ដោះស្រាយវិវាទ ទាក់ទងទៅនឹងលទ្ធផលនៃការបោះឆ្នោតជ្រើសរើសប្រធានាធិបតី និងអនុប្រធានាធិបតី។

-ដោះស្រាយវិវាទនានាទាក់ទងទៅនឹងកិច្ចការបោះឆ្នោតជ្រើសរើសសមាជិករដ្ឋសភា និងសមាជិកព្រឹទ្ធសភា។

-ច្បាប់ដែលសហសភាបានអនុម័តរួចហើយ ប្រធានាធិបតីត្រូវបញ្ជូនទៅតុលាការធម្មនុញ្ញ ដើម្បីត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ក្នុងរយៈពេល១០ថ្ងៃ ថាតើច្បាប់ទាំងនោះវាស្របទៅនឹងរដ្ឋធម្មនុញ្ញ ឬមិនស្របរដ្ឋធម្មនុញ្ញដែរឬទេ ?

តុលាការធម្មនុញ្ញ អាចចេញសេចក្តីសម្រេចផ្តាក បើសិនច្បាប់នោះមានអធម្មនុញ្ញភាពនៃច្បាប់ ច្បាប់នោះមិនត្រូវបានប្រកាសឲ្យប្រើឡើយ ហើយក៏មិនអាចដាក់ឲ្យអនុវត្តន៍ផងដែរ។[104]

សមាជិករបស់តុលាការធម្មនុញ្ញ មានវិសមិតភាពទៅនឹងមុខងារជាមួយនឹងប្រធានាធិបតី អនុប្រធានាធិបតី សមាជិករដ្ឋាភិបាល សមាជិករដ្ឋសភា សមាជិកព្រឹទ្ធសភា សមាជិកតុលាការជាន់ខ្ពស់ និងតុលាការកំពូលដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ។[105]

[103] មាត្រា៩៣នៃរដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរ។

[104] មាត្រា៩៤រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋខ្មែរ។

[105] មាត្រា៩៥រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋខ្មែរ។

ផ្នែកទី៣

ស្ថាប័ននយោបាយសម័យកម្ពុជាប្រជាធិបតេយ្យ[106]

(Political Institutions of Democratic Kampuchea)

ក.ស្ថានភាពទូទៅ

(General Aspect)

ក្រោយពីប្រទេសជាតិត្រូវបានរំដោះទាំងស្រុងនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ រដ្ឋាភិបាលកុម្មុយនីស្តមួយ បានត្រូវបង្កើតឡើង ដោយផ្អែកទៅតាមគោលនយោបាយរបស់គណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាបានយកទស្សនៈមហាជន និងមាគ៌ាមហាជនជាធំ។[107]

ប្រទេសកម្ពុជាគឺជារដ្ឋឯករាជ្យ ឯកភាព សន្តិភាព អព្យាក្រឹត្យ មិនចូលបក្សសម្ព័ន្ធជាមួយប្តកណា អធិបតេយ្យ ប្រជាធិបតេយ្យក្នុងបូរណភាពដែនដីរបស់ខ្លួន។

ប្រទេសកម្ពុជា ជារដ្ឋរបស់ប្រជាជន កម្មករ កសិករ និងពលករកម្ពុជាទាំងអស់។

ប្រទេសកម្ពុជា ត្រូវបានប្រកាសឈ្មោះប្រទេសជាផ្លូវការថា"**កម្ពុជាប្រជាធិបតេយ្យ**" (Democratic Kampuchea)ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ។[108]

ខ.គណៈប្រធានរដ្ឋ

(State Presidium)

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានជ្រើសរើស និងតែងតាំងគណៈប្រធានរដ្ឋមួយដោយសភាតំណាងប្រជាជនកម្ពុជាសម្រាប់រយៈពេល៥ឆ្នាំ។

សមាសភាពគណៈប្រធានរដ្ឋមានដូចតទៅ[109]៖

-ប្រធាន ១រូប

-អនុប្រធានទី១ ១រូប

-អនុប្រធានទី២ ១រូប

គណៈប្រធានរដ្ឋ មានមុខងារជាតំណាងឲ្យរដ្ឋកម្ពុជាប្រជាធិបតេយ្យទាំងនៅក្នុងប្រទេសទាំងនៅក្រៅប្រទេសដែលស្ថិតក្នុងក្របខ័ណ្ឌរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ហើយស្របច្បាប់និងតាមមាគ៌ានយោបាយរបស់សភាតំណាងប្រជាជនកម្ពុជាទាំងមូល។

---

[106] របបកម្ពុជាប្រជាធិបតេយ្យខ្ញុំបានលើកឡើងគឺផ្អែកលើរដ្ឋធម្មនុញ្ញប៉ុន្តែរដ្ឋធម្មនុញ្ញនេះមិនបានយកមកអនុវត្តទេ។

[107] ទស្សនាវដ្តី ស្វែងរកការពិតលេខ១៦ចេញផ្សាយខែមេសា ឆ្នាំ២០០១ ទំព័រ៦។

[108] មាត្រា១រដ្ឋធម្មនុញ្ញនៃកម្ពុជាប្រជាធិបតេយ្យ។

[109] មាត្រា១១រដ្ឋធម្មនុញ្ញនៃកម្ពុជាប្រជាធិបតេយ្យ។

ក.រដ្ឋសភា

(Assembly)

នៅថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៧៦ រដ្ឋធម្មនុញ្ញមួយត្រូវបានបង្កើតឡើងដែលមានចែងពីសិទ្ធិអំណាច តួនាទីសំខាន់ៗរបស់ប្រជាជន កម្មករ កសិករ និងគ្រប់ស្រទាប់ប្រជាពលករផ្សេងៗទៀត ក្រៅពីនេះនៅមានកងទ័ពប្រជាជនបដិវត្តន៍កម្ពុជាផងដែរ។

រដ្ឋសភាគឺជាអង្គការនីតិប្បញ្ញត្តិដែលមានអំណាចធ្វើច្បាប់ ហើយក៏ជាអំណាចរបស់សភាតំណាងឲ្យប្រជាជន កម្មករ កសិករ និងពលករកម្ពុជាទូទាំងប្រទេសដែរ។

រដ្ឋសភាមានឈ្មោះជាផ្លូវការថា“សភាតំណាងប្រជាជនកម្ពុជា”។

សភាតំណាងប្រជាជនកម្ពុជា គឺមានសមាជិកទាំងអស់ចំនួន២៥០នាក់ ដែលជាតំណាងរបស់ប្រជាជនកម្ពុជាគ្រប់ស្រទាប់វណ្ណៈរួមទាំងជាតំណាងឲ្យកងទ័ពបដិវត្តន៍កម្ពុជា។

សមាជិកសភាតំណាងប្រជាជនត្រូវបានជ្រើសតាំងឡើង ដោយការបោះឆ្នោតពីប្រជាជនខ្មែរទូទាំងប្រទេសដោយផ្ទាល់ និងដោយសម្ងាត់ក្នុងរយៈពេល៥ឆ្នាំម្តង មានចែងក្នុងរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ។[110]

សមាជិកសភាតំណាងប្រជាជនកម្ពុជាទាំងនោះរួមមាន[111]៖

-តំណាងឲ្យកសិករមានចំនួន ១៥០នាក់

-តំណាងឲ្យកម្មករ និងពលករផ្សេងៗ ៥០នាក់

-តំណាងឲ្យកងទ័ពបដិវត្តន៍កម្ពុជា ចំនួន ៥០នាក់

ឃ.រដ្ឋាភិបាល

(Government)

រដ្ឋាភិបាល គឺជាអង្គការមួយដែលមានការកិច្ចអនុវត្តន៍ច្បាប់ និងអនុវត្តន៍មាគ៌ានយោបាយរបស់សភាតំណាងប្រជាជនកម្ពុជា។

រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ត្រូវបានជ្រើសតាំងឡើង ដោយសភាតំណាងប្រជាជនកម្ពុជា ហើយទទួលខុសត្រូវទាំងស្រុងចំពោះមុខសភាតំណាងប្រជាជនកម្ពុជាក្នុងកិច្ចដំណើរការរបស់ខ្លួន ទាំងនៅក្នុងប្រទេស ទាំងនៅក្រៅប្រទេស ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ។[112]

---

[110] មាត្រា៦រដ្ឋធម្មនុញ្ញនៃកម្ពុជាប្រជាធិបតេយ្យ។

[111] មាត្រា៥រដ្ឋធម្មនុញ្ញនៃកម្ពុជាប្រជាធិបតេយ្យ។

[112] មាត្រា៨នៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ។

រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ បានអនុវត្តន៍នូវគោលនយោបាយការបរទេស ក្នុងការចងចំណងមិត្តភាពយ៉ាងជិតស្និទ្ធជាមួយបណ្តាប្រទេសនៅលើសកលលោក។

រដ្ឋាភិបាលប្រកាន់ខ្ជាប់នូវនយោបាយឯករាជ្យ សន្តិភាព អព្យាក្រឹត្យ មិនចូលបក្សសម្ព័ន្ធណាឡើយ មិនអនុញ្ញាតឲ្យពួកបរទេសណាមកតាំងមូលដ្ឋានសឹកនៅក្នុងប្រទេសបានជាដាច់ខាត តស៊ូជាដាច់ខាតគ្រប់ការជ្រៀតជ្រែកពីសំណាក់ពួកបរទេសខាងក្រៅចូលកិច្ចការផ្ទៃក្នុងនានារបស់ប្រទេសកម្ពុជាទោះបីជាក្នុងរូបភាពណាក៏ដោយ ឬតាមមធ្យោបាយណាក៏ដោយ។

រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ គោរពបូរណភាពទឹកដីមិនជ្រៀតជ្រែកចូលទៅកិច្ចការផ្ទៃក្នុងនៃប្រទេសណាមួយឡើយ ហើយក៏មិនចូលបក្សសម្ព័ន្ធណាមួយជាខាច់ខាត។

ប្រទេសកម្ពុជាគឺស្ថិតនៅក្នុងលក្ខណៈជាមហាគ្រួសារ។

រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ បានខិតខំបង្កើនសាមគ្គីភាព ជាមួយប្រជាជនតតីយលោក នៅអាស៊ី អាហ្វ្រិក អាមេរិកឡាទីន និងប្រជាជន ដែលស្នេហាសន្តិភាព និងស្នេហាយុត្តិធម៌នៅក្នុងសាកលលោកទាំងមូល ហើយជួយគ្នាឧបត្ថម្ភគ្នាទៅវិញទៅមកយ៉ាងសកម្មដើម្បីតស៊ូប្រឆាំងពួកចក្រពត្តិនិយម អាណានិគមនិយមចាស់ថ្មីក្នុងគោលដៅ កសាងឯករាជ្យ សន្តិភាព មិត្តភាព ប្រជាធិបតេយ្យ យុត្តិធម៌ និងវឌ្ឍនភាពពិតប្រាកដនៅលើសាកលលោក។[113]

[113] មាត្រា២១នៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ។

ផ្នែកទី៤

ស្ថាប័ននយោបាយសាធារណរដ្ឋប្រជាមានិតកម្ពុជា

(Political Institutions of the People's Republic of Kampuchea)

ក.ស្ថានភាពទូទៅ

(General Aspect)

របបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានដួលរលំទាំងស្រុងនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ របបមួយថ្មី ត្រូវបានបង្កើតឡើងប្រជាពលរដ្ឋខ្មែរទូទាំងប្រទេស ហើយបានអបអរសាទរសប្បាយរីករាយនឹងជីវិតថ្មី ដែលប្រជាពលរដ្ឋគ្រប់រូបមិននឹកស្មានដល់ប្រជាពលរដ្ឋខ្មែរដែលរស់នៅ និងឆ្លងកាត់របបកម្ពុជាប្រជាធិបតេយ្យសុទ្ធតែបានយល់ច្បាស់ និងចងចាំជានិច្ច មិនអាចបំភ្លេចបាន ហើយក៏បានដឹងយ៉ាងច្បាស់ទៀតថា ជាថ្ងៃនៃកំណើតទី២របស់យើងទាំងអស់គ្នាផងដែរ។

រដ្ឋធម្មនុញ្ញមួយ ត្រូវបានបង្កើតឡើង នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៨១ ហើយត្រូវបានប្រធានក្រុមប្រឹក្សារដ្ឋប្រកាសឲ្យប្រើច្បាប់រដ្ឋធម្មនុញ្ញតាមក្រឹត្យលេខ០១.ក្រ.ចុះថ្ងៃទី២៧ខែមិថុនា ឆ្នាំ១៩៨១ ដែលប្រទេសកម្ពុជា នៅពេលនោះមានឈ្មោះថា "សាធារណរដ្ឋប្រជាមានិតកម្ពុជា" (People's Republic of Kampuchea)។ សាធារណរដ្ឋប្រជាមានិតកម្ពុជា ជារដ្ឋមួយមានឯករាជ្យ ភាពមានអធិបតេយ្យ មានបូរណភាពទឹកដី មានសុខសន្តិភាព មានប្រជាធិបតេយ្យ និងឈានជាជំហានៗឆ្ពោះទៅកាន់របបថ្មីមួយគឺរបបសង្គមសង្គមនិយម។[114]

ខ.ក្រុមប្រឹក្សារដ្ឋ

(Council of State)

ក្រុមប្រឹក្សារដ្ឋ គឺជាអង្គការស្ថាប័នរដ្ឋតំណាងឲ្យប្រទេសជាតិទាំងមូល ហើយក៏ជាអង្គការអចិន្ត្រៃយ៍របស់រដ្ឋសភាជាតិផងដែរ។

ក្រុមប្រឹក្សារដ្ឋ មានការកិច្ចរាយការណ៍អំពីសកម្មភាពរបស់ខ្លួនជូនរដ្ឋសភា។

១-សមាសភាពក្រុមប្រឹក្សារដ្ឋ

(Members of The Council of State)

ក្រុមប្រឹក្សារដ្ឋ ត្រូវបានបោះឆ្នោតជ្រើសតាំងឡើង នៅពេលប្រជុំលើកដំបូងនៃនីតិកាលថ្មីរបស់រដ្ឋសភា។ រដ្ឋសភាបោះឆ្នោតជ្រើសតាំងរួមមាន:

-ប្រធាន ១រូប

[114] មាត្រា១រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

-អនុប្រធាន ១រូប

-អគ្គលេខាធិការ ១រូប

-សមាជិកនៃក្រុមប្រឹក្សារដ្ឋចំនួន៤រូប។[115]

សមាសភាពក្រុមប្រឹក្សារដ្ឋ រួមមានប្រធានរដ្ឋ អនុប្រធានរដ្ឋ អគ្គលេខាធិការនិងសមាជិកមួយចំនួនទៀតដែលត្រូវបានជ្រើសតាំងឡើង គឺក្នុងចំណោមសមាជិករដ្ឋសភាទាំងឡាយនៃសភាជាតិមានចែងក្នុងរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។[116]

ក្រុមប្រឹក្សារដ្ឋត្រូវប្រជុំ១ដងក្នុង១ខែហើយត្រូវប្រជុំជារៀងរាល់ខែ។

ក្នុងករណីចាំបាច់ក្រុមប្រឹក្សារដ្ឋអាចប្រជុំជាវិសាមញ្ញបាន។

សេចក្តីសម្រេចទាំងឡាយ របស់ក្រុមប្រឹក្សារដ្ឋ អាចយកជាការបាន លុះត្រា តែបានការយល់ព្រមអនុម័តដោយមានសម្លេងរបស់សមាជិកក្រុមប្រឹក្សារដ្ឋចំនួនលើសពីពាក់កណ្តាលឡើងទៅ។[117]

ប្រធានក្រុមប្រឹក្សារដ្ឋកោះប្រជុំ និងធ្វើជាអធិបតីក្នុងការប្រជុំនានារបស់ក្រុមប្រឹក្សារដ្ឋ។[118]

២-តួនាទីក្រុមប្រឹក្សារដ្ឋ

(Roles of the Council of State)

កិច្ចការប្រទេសជាតិទាំងអស់ អាចអនុវត្តន៍ទៅបានលុះត្រាតែបានការអនុម័តយល់ព្រមពីក្រុមប្រឹក្សារដ្ឋជាមុនសិន ដែលក្រុមប្រឹក្សារដ្ឋមានតួនាទីដូចជា:

-ក្រុមប្រឹក្សារដ្ឋ ជាអ្នកកំណត់គោលការណ៍កោះអញ្ជើញ និងកោះប្រជុំនានានៃរដ្ឋសភាជាអ្នកធ្វើគម្រោងកម្មវិធីប្រជុំនានា កិច្ចការរៀបចំជាគម្រោងផ្សេង។ ក្រុមប្រឹក្សារដ្ឋត្រូវតែរួមសហការជាមួយប្រធានរដ្ឋសភាក្នុងកិច្ចការងារដែលបានលើកឡើងខាងលើ។[119]

-ក្រុមប្រឹក្សារដ្ឋត្រូវរាយការណ៍ជូនទៅរដ្ឋសភានូវការងាររបស់ខ្លួន នៅគ្រប់ការសម័យប្រជុំនីមួយៗរបស់រដ្ឋសភា។[120]

-ក្រុមប្រឹក្សារដ្ឋពិភាក្សាអនុម័ត និងត្រួតពិនិត្យកិច្ចការអនុវត្តន៍ផែនការក្នុងការកសាងក្រិត្យច្បាប់តាមសេចក្តីស្នើរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី។

---

[115] មាត្រា៨បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សារដ្ឋនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

[116] មាត្រា៥៩នៃរដ្ឋធម្មនុញ្ញសាធារណរដ្ឋប្រជាមានិតកម្ពុជា។

[117] មាត្រា១០បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សារដ្ឋនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

[118] មាត្រា១១បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សារដ្ឋនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

[119] មាត្រា១២បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សារដ្ឋនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

[120] មាត្រា១៣បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សារដ្ឋនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

ក្នុងករណីចាំបាច់ ក្រុមប្រឹក្សារដ្ឋអាចសម្រេចបង្កើតក្រុមប្រឹក្សាការពារជាតិ និងសមាជិកទាំងឡាយរួមមាន:

+ប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី

+រដ្ឋមន្ត្រីក្រសួងការពារប្រទេស

+រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

+រដ្ឋមន្ត្រីក្រសួងការបរទេស។[121]

-ក្រុមប្រឹក្សារដ្ឋ ចាត់តាំងក្បាលម៉ាស៊ីនជំនួយការជាចាំបាច់ នៅក្រោមការ ដឹកនាំរបស់អគ្គលេខាធិការក្រុមប្រឹក្សារដ្ឋ[122]។

-ប្រកាសឲ្យប្រើច្បាប់ និងចេញក្រឹត្យ ច្បាប់ និងបកស្រាយច្បាប់។

-ចេញសេចក្តីសម្រេចតែងតាំង និងដកហូតសមាជិកក្រុមប្រឹក្សារដ្ឋមន្ត្រី។

-ចេញសេចក្តីសម្រេចនិងរៀបចំការបោះឆ្នោតជ្រើសរើសសមាជិករដ្ឋសភា និងការកោះប្រជុំរដ្ឋសភា។

-តាមសំណើ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី តែងតាំង រំសាយ ឬដកឯកអគ្គរដ្ឋទូត ឬប្រេសិតសាធារណរដ្ឋប្រជាមានិតកម្ពុជានៅឯបរទេស និងនៅអមអង្គការអន្តរជាតិ។

-ត្រួតពិនិត្យការជំនុំជំរះ និងការប្រើសិទ្ធិអយ្យការ។

-ទទួលសារតាំងរបស់តំណាងការទូត។

-ផ្តល់សច្ចាប័ន ឬលុបចោលសន្ធិសញ្ញាអន្តរជាតិ លើកលែងតែក្នុងករណីចាំបាច់ ដែលត្រូវបានដាក់ជូនរដ្ឋសភាសម្រេច។

-កំណត់ និងប្រគល់គ្រឿងឥស្សរិយយស កំណត់ឋានន្តរសក្តិ និងឋានៈយោធាទូត តាមសំណើរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី។

-សម្រេចអនុគ្រោះបន្ធូរបន្ថយទោស និងលើកលែងទោស។

-បំពេញភារកិច្ចផ្សេងៗទៀត ដែលរដ្ឋសភាបានប្រគល់ជូន។[123]

៣-នីតិកាលរបស់ក្រុមប្រឹក្សារដ្ឋ

(Terms of the Council of State)

ក្រុមប្រឹក្សារដ្ឋ មាននីតិកាលស្មើនឹង នីតិកាលរបស់រដ្ឋសភាដែរ ដែលមានរយៈពេល៥ឆ្នាំ

[121] មាត្រា១៨បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សារដ្ឋនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

[122] មាត្រា១៩បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សារដ្ឋនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

[123] មាត្រា៦០នៃរដ្ឋធម្មនុញ្ញសាធារណរដ្ឋប្រជាមានិតកម្ពុជា។

នៅពេលផុតនីតិកាលរដ្ឋសភា ក្រុមប្រឹក្សារដ្ឋអាចបន្តសកម្មភាពរបស់ខ្លួនបានរហូតដល់រដ្ឋសភាថ្មីធ្វើការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារដ្ឋថ្មី។[124]

ក្នុងករណីប្រធានក្រុមប្រឹក្សារដ្ឋមានធុរៈ មិនអាចបំពេញមុខងារបាន ដោយមូលហេតុមកពីមានជំងឺ ឬត្រូវទៅបំពេញបេសកកម្មនៅបរទេសអនុប្រធានក្រុមប្រឹក្សារដ្ឋត្រូវទទួលភារកិច្ចចាត់ការជំនួស។[125]

គ.ក្រុមប្រឹក្សារដ្ឋមន្ត្រី

(Council of Ministers)

ក្រុមប្រឹក្សារដ្ឋមន្ត្រី ជារដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលជាអង្គការប្រតិបត្តិរបស់រដ្ឋសភាព្រមទាំងជាអង្គការរដ្ឋបាលជាន់ខ្ពស់បំផុត ទន្ទឹមនឹងនោះ ក៏ជាអង្គការគ្រប់គ្រងសេដ្ឋកិច្ច និងគ្រប់គ្រងសង្គមខ្ពស់បំផុតរបស់ប្រទេសជាតិទាំងមូល។

ក្រោមការដឹកនាំ បក្សប្រជាជនបដិវត្តន៍កម្ពុជា អនុលោមតាមរដ្ឋធម្មនុញ្ញ និងច្បាប់របស់រដ្ឋ ក្រុមប្រឹក្សារដ្ឋមន្ត្រីឯកភាពគ្រប់គ្រងការអនុវត្តរាល់ភារកិច្ចទាំងក្នុងប្រទេស និងទាំងខាងក្រៅប្រទេស ជាពិសេសភារកិច្ចខាងសេដ្ឋកិច្ច វប្បធម៌ និងសង្គមកិច្ច នៃសាធារណរដ្ឋប្រជាមានិតកម្ពុជាសំដៅការពារកសាងប្រទេសជាតិ និងបម្រើជីវភាពរស់នៅរបស់ប្រជាជនទាំងមូល[126]។

ក្រុមប្រឹក្សារដ្ឋមន្ត្រី ជាអង្គការដឹកនាំគ្រប់គ្រងរដ្ឋសង្គមដោយផ្ទាល់ និងជាអង្គការដឹកនាំពង្រីកសេដ្ឋកិច្ចជាតិ ដោយផ្ទាល់ព្រមទាំងរៀបចំក្បួនច្បាប់ទាំងឡាយឲ្យស្របនឹងរដ្ឋធម្មនុញ្ញ ច្បាប់ ក្រឹត្យ-ច្បាប់ ដើម្បីធ្វើការរៀបចំ និងសម្របសម្រួលសកម្មភាពនានាខាងសេដ្ឋកិច្ច នយោបាយ វប្បធម៌ និងសង្គមកិច្ច។[127]

ក្រុមប្រឹក្សារដ្ឋមន្ត្រី ជាអ្នកទទួលខុសត្រូវ ចំពោះមុខរដ្ឋសភា និងរាយការណ៍អំពីការងារទាំងឡាយរបស់ខ្លួនជូនអង្គការរដ្ឋសភាឲ្យបានជ្រាប។[128]

១-សមាសភាពក្រុមប្រឹក្សារដ្ឋមន្ត្រី

(Members of the Council of Ministers)

---

[124] មាត្រា៩បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សារដ្ឋនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

[125] មាត្រា៦១នៃរដ្ឋធម្មនុញ្ញសាធារណរដ្ឋប្រជាមានិតកម្ពុជា។

[126] មាត្រា១ច្បាប់ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី។

[127] មាត្រា៦ច្បាប់ស្តីពីសមត្ថកិច្ច និងនីតិវិធីនៃការធ្វើច្បាប់ និងបទបញ្ជា។

[128] មាត្រា៦៤រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

ក្រុមប្រឹក្សារដ្ឋមន្ត្រី មានប្រធាន អនុប្រធាន និងសមាជិក ដែលចំនួនអនុប្រធាន និងចំនួនសមាជិកក្រុមប្រឹក្សារដ្ឋមន្ត្រីត្រូវបានរដ្ឋសភាជាអ្នកកំណត់នៅក្នុងចន្លោះរបស់សម័យប្រជុំរដ្ឋសភា ក្រុមប្រឹក្សារដ្ឋមន្ត្រីទទួលខុសត្រូវចំពោះក្រុមប្រឹក្សារដ្ឋ និងរាយការណ៍អំពីការងារទាំងឡាយរបស់ខ្លួនជូនអង្គការក្រុមប្រឹក្សារដ្ឋបានជ្រាប។[129]

ក្រុមប្រឹក្សារដ្ឋមន្ត្រី ត្រូវបានរដ្ឋសភាបោះឆ្នោតជ្រើសតាំង នៅក្នុងសម័យប្រជុំលើកទី១នៃនីតិកាលនីមួយៗរបស់រដ្ឋសភា។

សមាសភាពក្រុមប្រឹក្សារដ្ឋមន្ត្រីរួមមាន:

-ប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី

-បណ្តាអនុប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី

-បណ្តារដ្ឋមន្ត្រី

ប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី ជាសមាជិកតំណាងរដ្ឋសភា រាល់សមាជិកផ្សេងៗទៀតរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីភាគច្រើនត្រូវធ្វើការជ្រើសរើសក្នុងចំណោមសមាជិកតំណាងរដ្ឋសភា។[130]

២-តួនាទី និងភារកិច្ចក្រុមប្រឹក្សារដ្ឋមន្ត្រី

(Roles and Duties of the Council of Ministers)

ក្រុមប្រឹក្សារដ្ឋមន្ត្រីមានតួនាទី និងភារកិច្ចដូចតទៅ:

-ក្រុមប្រឹក្សារដ្ឋមន្ត្រីមានភារកិច្ចទទួលខុសត្រូវ និងរាយការណ៍អំពីការងារទូទៅចំពោះមុខរដ្ឋសភានៅចន្លោះសម័យប្រជុំសាមញ្ញទាំងពីរនៃរដ្ឋសភា និងការទទួលខុសត្រូវរាយការណ៍អំពីការងារនៅចំពោះមុខក្រុមប្រឹក្សារដ្ឋ។[131]

-ចាត់ចែង និងធ្វើសកម្មភាពតាមលាក់ការណ៍ ប្រមូលផ្តុំប្រជាធិបតេយ្យ ឯកភាព ដឹកនាំចាត់ចែងបញ្ជារាល់សកម្មភាពប្រចាំថ្ងៃ រវាងក្រសួង និងក្រសួង រវាងក្រសួង និងមូលដ្ឋាន ព្រមជាមួយការលើកកម្ពស់ការៈទទួលខុសត្រូវរបស់បណ្តាសមមិត្តរដ្ឋមន្ត្រីលើកកម្ពស់ស្មារតីម្ចាស់ការរបស់គណៈកម្មាធិការប្រជាជន បដិវត្តន៍ខេត្ត ក្រុងលើគ្រប់ផ្នែកផែនការចរិកាសម្ភារៈកម្មាភិបាល និងអង្គការនានាតាមសេចក្តីកំណត់រួមរបស់រដ្ឋ។

ធ្វើទំនាក់ទំនង រវាងក្រសួងស្ថាប័ននានា ចំណុះក្រុមប្រឹក្សារដ្ឋមន្ត្រីជាមួយ នឹងគណៈកម្មា

---

[129] មាត្រា៦៥នៃរដ្ឋធម្មនុញ្ញសាធារណរដ្ឋប្រជាមានិតកម្ពុជា។

[130] មាត្រា២ច្បាប់ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី។

[131] មាត្រា៤ច្បាប់ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី។

ធិការប្រជាជនបដិវត្តន៍ខេត្តក្រុង ធ្វើទំនាក់ទំនងបែងចែកភារកិច្ចតាម ជាន់ថ្នាក់និងផ្សារភ្ជាប់ភារៈទទួលខុសត្រូវ និងកាតព្វកិច្ចចំពោះគ្នាទៅវិញទៅមក។

កំណត់សម្រេច ជាសមូហភាពនូវរាល់បញ្ហាធំៗរបស់រដ្ឋ ដែលស្ថិតនៅក្រោមសិទ្ធិ និងការកិច្ចរបស់ខ្លួន ជាពិសេសលើវិស័យសេដ្ឋកិច្ច ដែលមានចែងក្នុង ច្បាប់រួមចំណែកគ្នាក្នុងការទទួលខុសត្រូវការងាររបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី។[132]

-មានភារកិច្ចស្រាវជ្រាវ ពិចារណា ពិភាក្សាផ្លាស់ប្តូរយោបល់ និងពិនិត្យ ដើម្បីសម្រេចរាល់ផែនការ គោលនយោបាយ និងលក្ខន្តិកៈគ្រប់គ្រងសេដ្ឋកិច្ច និងក្បាលម៉ាស៊ីនគ្រប់គ្រងសេដ្ឋកិច្ចឲ្យបានត្រឹមត្រូវសមស្របតាមរដ្ឋធម្មនុញ្ញ គួបផ្សំជាមួយបណ្តាវិធានការ អប់រំ រដ្ឋបាល សេដ្ឋកិច្ចដើម្បីទប់ស្កាត់ និងពុះពារជំនះរាល់ឧបសគ្គ និងបាតុភាពមិនល្អដូចជាអាជ្ញានិយម នាម៉ឺននិយមខ្ជះខ្ជាយលោភលន់ រំលោភបំពានលើទ្រព្យសម្បត្តិរដ្ឋ និងផលប្រយោជន៍របស់ប្រជាជន ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ។[133]

-មានការៈធ្វើការវិភាគឲ្យបានជាក់ស្តែង ពិតប្រាកដនូវមាគ៌ា និងគោលនយោបាយទាំងនោះ ដើម្បីដាក់ចុះគោលការណ៍ គោលនយោបាយ ទិសដៅ និងភារកិច្ចតាមដំហាននីមួយៗ ក្នុងការស្តារ និងពង្រីកសេដ្ឋកិច្ច វប្បធម៌ អប់រំ សុខាភិបាល និងសង្គមកិច្ច ដឹកនាំក្នុងការធ្វើគម្រោងផែនការសេដ្ឋកិច្ច សង្គមកិច្ច និងគម្រោងថវិការដ្ឋដើម្បីដាក់ឆ្លងរដ្ឋសភា។

ក្រុមប្រឹក្សារដ្ឋមន្ត្រី ណែនាំការអនុវត្តលើផែនការ សេដ្ឋកិច្ច សង្គមកិច្ច និងថវិការដ្ឋ បន្ទាប់ពីបានឆ្លងរដ្ឋសភា ដើម្បីអនុម័ត និងសម្រេច។

ក្រុមប្រឹក្សារដ្ឋមន្ត្រីត្រូវក្តាប់ និងធ្វើការដោះស្រាយតាមដំហាននីមួយៗនូវគ្រប់បញ្ហា ដែលទាក់ទងស្មេរភាពរបស់គ្រឹះសេដ្ឋកិច្ចជាតិ។[134]

-កំណត់សម្រេចទិសដៅ និងរាល់គោលការណ៍សំខាន់ៗ និងការចាត់តាំង ការគ្រប់គ្រងគ្រឹះសេដ្ឋកិច្ចជាតិ និងគ្រប់គ្រងរដ្ឋ។ អនុលោមទៅតាមសំណូមពរនៃភារកិច្ច ក្នុងការគ្រប់គ្រងត្រូវដាក់ឲ្យអនុវត្តន៍នូវរាល់បែបបទរបៀបរបប និងការគ្រប់គ្រងសមស្រប ទៅនឹងស្ថានភាពពិសេសនៅក្នុងរយៈកាលនីមួយៗ។[135]

---

[132] មាត្រា៥ច្បាប់ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី។

[133] មាត្រា៦ច្បាប់ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី។

[134] មាត្រា៧ច្បាប់ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី។

[135] មាត្រា៨ច្បាប់ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី។

-ណែនាំអំពីការស្រាវជ្រាវ ពិចារណា និងការដាក់ឲ្យអនុវត្តន៍នូវរាល់គោលនយោបាយជាមូលដ្ឋានអំពីការគ្រប់គ្រងសេដ្ឋកិច្ចសង្គមកិច្ច និងការគ្រប់គ្រងរដ្ឋ។[136]

-ឯកភាពការគ្រប់គ្រងប្រាក់កាស និងរូបិយប័ណ្ណ ការឲ្យខ្ចីប្រាក់ហិរញ្ញវត្ថុ ប្រាក់បៀវត្សរ៍ និងតម្លៃ។ ឯកភាពគ្រប់គ្រងបំផុសជំរុញ និងលើកទឹកចិត្តលក្ខណៈជាបុគ្គល និងជាសមូហភាព របស់ប្រជាជនដើម្បីបម្រើដល់សំណូមពរការពារកសាងមាតុភូមិ។

កសាង និងពង្រីក រាល់កងកម្លាំងប្រដាប់អាវុធ បង្កើនកងកម្លាំងសន្តិសុខ ធានារ៉ាប់រងនូវរាល់សន្តិសុខនយោបាយ និងសណ្តាប់ធ្នាប់សង្គម។[137]

-ឯកភាពការគ្រប់គ្រងនូវរាល់សកម្មភាពខាងសេដ្ឋកិច្ច វប្បធម៌ និងការទូទាត់របស់រដ្ឋ។ ដឹកនាំអនុវត្តន៍រាល់កិច្ចព្រមព្រៀង ពាណិជ្ជកម្ម សហប្រតិបត្តិការ សេដ្ឋកិច្ច និងវប្បធម៌ ដែលបានចុះហត្ថលេខាជាមួយបរទេស។[138]

-ណែនាំរាល់សកម្មភាព ត្រួតពិនិត្យជាមូលដ្ឋាន អំពីសេដ្ឋកិច្ច និងសង្គមកិច្ច ដែលមានដីធ្លី ធនធានធម្មជាតិ មូលដ្ឋានសម្ភារៈបច្ចេកទេស ពលករ .....ដើម្បីបម្រើដល់ការស្តារ និងការកសាងអភិវឌ្ឍន៍ប្រទេសជាតិ។[139]

-ណែនាំដល់ការស្រាវជ្រាវ ពិចារណា និងពង្រីកវិទ្យាសាស្ត្របច្ចេកទេស បម្រើផលិតកម្ម ដើម្បីប្រយុទ្ធដោះស្រាយជីវភាពជូនប្រជាជន។[140]

-ជាអ្នកធ្វើសេចក្តីព្រាងច្បាប់ឬសេចក្តីព្រាងក្រឹត្យ-ច្បាប់ និងជាអ្នករៀបចំធ្វើគម្រោងផ្សេងៗទៀត ដើម្បីដាក់ជូនរដ្ឋសភា និងក្រុមប្រឹក្សារដ្ឋអនុម័តសម្រេច។

-ជាអង្គការអនុវត្តន៍ច្បាប់ អនុវត្តន៍រដ្ឋធម្មនុញ្ញ អនុវត្តន៍ក្រឹត្យ-ច្បាប់ និងអនុវត្តន៍អំពីគោលនយោបាយរបស់ខ្លួនទាំងក្នុងប្រទេស និងក្រៅប្រទេស។

-ជាអ្នកធ្វើ និងអនុវត្តន៍កម្មវិធី សេដ្ឋកិច្ច វប្បធម៌ និងថវិការដ្ឋ។ លុបបំបាត់ផលអាក្រក់ដែលបានបន្សល់ទុកនៅក្នុងរបបចាស់មុនៗកែលម្អជីវភាពរបស់ប្រជាជន និងយកចិត្តទុកដាក់ដល់សុខមាលភាពរបស់ប្រជាជន។

-កសាង និងពង្រឹងអង្គការរដ្ឋ ពីថ្នាក់មជ្ឈិម ដល់ថ្នាក់មូលដ្ឋាន ការបណ្តុះបណ្តាល និង

---

[136] មាត្រា៩ច្បាប់ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី។

[137] មាត្រា១០ច្បាប់ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី។

[138] មាត្រា១១ច្បាប់ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី។

[139] មាត្រា១២ច្បាប់ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី។

[140] មាត្រា១៣ច្បាប់ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី។

គ្រប់គ្រងកម្មាភិបាល កម្មករ និងបុគ្គលិករបស់រដ្ឋ។

-ធានារ៉ាប់រង ក្នុងការដឹកនាំការងាររបស់ទីស្តីការរដ្ឋមន្ត្រី និងស្ថាប័ននានា ដែលស្ថិតនៅក្រោមឱវាទក្រុមប្រឹក្សារដ្ឋមន្ត្រី ដើម្បីធ្វើឲ្យមានឯកភាព និងការរ៉ាប់រងនៅក្នុងដឹកនាំការងាររបស់គណៈកម្មាធិការប្រជាជនបដិវត្តន៍នៅតាមមូលដ្ឋានគ្រប់ជាន់ថ្នាក់ឲ្យមានឯកភាព។

-ផ្អាកការអនុវត្តន៍កែប្រែ ឬលុបចោលអនុសញ្ញា និងសេចក្តីណែនាំមិនសមស្របរបស់រដ្ឋមន្ត្រី និងរបស់ប្រធានស្ថាប័នរដ្ឋនានា។

-កសាង និងរៀបចំ ពង្រឹកក្បាលម៉ាស៊ីនគ្រប់គ្រងរដ្ឋ គ្រប់គ្រងសេដ្ឋកិច្ច ចាប់ពីថ្នាក់មជ្ឈិមរហូតដល់ថ្នាក់មូលដ្ឋាន។ឯកភាពការគ្រប់គ្រងក្របខ័ណ្ឌ អង្គការលេខរបស់រដ្ឋនៅទូទាំងប្រទេស ឯកភាពការគ្រប់គ្រង ការអនុវត្តរាល់របបគោលនយោបាយចំពោះ យុទ្ធជន កងកម្លាំង សន្តិសុខ កម្មាភិបាល កម្មករ បុគ្គលិក កងឈ្លប និងកម្មាភិបាលភូមិ ឃុំ។ ក្បាលម៉ាស៊ីនគ្រប់គ្រង ត្រូវមានលក្ខណៈសម្បត្តិសមស្រប ធ្វើឲ្យមានប្រសិទ្ធភាព មានមុខងារភារកិច្ច មានរបៀបរបបធ្វើការងារច្បាស់លាស់ និងមានប្រជុំជីវភាពទៀងទាត់។ ក្នុងករណីចាំបាច់ ក្រុមប្រឹក្សារដ្ឋមន្ត្រីអាចកំណត់សម្រេចធ្វើការកែប្រែព្រំប្រទល់ ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់តាមសំណើរបស់គណៈកម្មាធិការប្រជាជនបដិវត្តន៍ខេត្តក្រុង។[141]

-ផ្អាកការអនុវត្តកែប្រែឬលុបចោលនូវសេចក្តីសម្រេចចិត្ត និងសេចក្តីណែនាំមិនសមស្របរបស់គណៈកម្មាធិការប្រជាជនបដិវត្តន៍កម្ពុជាគ្រប់ជាន់ថ្នាក់។

-កំណត់ព្រំដែនក្រុង សង្កាត់ ខេត្ត ស្រុក និងឃុំ។

-ការពារផលប្រយោជន៍របស់ប្រជាជន រក្សាសន្តិសុខ សន្តិភាព របៀប របបសណ្តាប់ធ្នាប់សាធារណៈការការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ប្រជាពលរដ្ឋ។

-រៀបចំគម្រោងផែនការបណ្តុះបណ្តាល និងបំប៉ននៅក្នុងជួរកម្មាភិបាល ដើម្បីគ្រប់គ្រងរដ្ឋ គ្រប់គ្រងសេដ្ឋកិច្ច និងជួរកម្មករបច្ចេកទេស ឲ្យមានគុណសម្បត្តិ នយោបាយល្អមានចំណេះដឹង អំពីការគ្រប់គ្រងសេដ្ឋកិច្ច គ្រប់គ្រងរដ្ឋមានសមត្ថភាព ក្នុងការចាត់ចែង និងគ្រប់គ្រងដោយអនុវត្តន៍តាមរដ្ឋធម្មនុញ្ញ និងច្បាប់របស់រដ្ឋ។[142]

-ពង្រឹង និងការបង្កើនកម្លាំងការពារជាតិ អនុវត្តន៍ការប្រមូលផ្តុំកម្លាំងកងទ័ពចេញបម្រាមគោចរ និងចាត់វិធានការណ៍ចាំបាច់ផ្សេងៗដើម្បីការពារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈបម្រើផលប្រយោជន៍ចំពោះប្រជាពលរដ្ឋ និងចំពោះផលប្រយោជន៍ជាតិ។

---

[141] មាត្រា១៥ច្បាប់ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី។

[142] មាត្រា១៦ច្បាប់ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី។

-អនុវត្តន៍លើសន្ធិសញ្ញាអន្តរជាតិទាំងឡាយ ដែលបានធ្វើកិច្ចព្រមព្រៀងជាមួយគ្នា រវាងបណ្តាប្រទេសនានានៅលើពិភពលោក។

-បំពេញភារកិច្ចផ្សេងៗទៀត ដែលរដ្ឋសភា និងក្រុមប្រឹក្សារដ្ឋបានប្រគល់ឲ្យ។[143]

ប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី ដឹកនាំការងាររបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ហើយធ្វើជាអធិបតីនៅក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី។

អនុប្រធានជួយប្រធាន និងកាន់កាប់មុខងារជាប្រធាន ក្នុងករណី ដែលប្រធានអវត្តមាន សមាជិកម្នាក់ៗរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ត្រូវទទួលខុសត្រូវអំពីសកម្មភាពរបស់ខ្លួន និងទទួលខុសត្រូវរួមគ្នាជាមួយសមាជិកក្រុមប្រឹក្សារដ្ឋមន្ត្រីផ្សេងៗទៀត និងអំពីសកម្មភាពនានារបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី។[144]

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ត្រូវតែមានសមាជិកភាគច្រើនជាអ្នកអនុម័តសម្រេចអំពីកិច្ចការទាំងឡាយរបស់ប្រទេសជាតិ គឺត្រូវមានក្រុមប្រឹក្សារដ្ឋមន្ត្រីទាំងមូលយល់ព្រម ទើបអាចយកជាការបាន។

៣-ការប្រជុំក្រុមប្រឹក្សារដ្ឋមន្ត្រី

(Meeting of the Council of Ministers)

ការប្រជុំរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីស្ថិតក្រោមរូបភាពពីរយ៉ាងគឺ

ប្រជុំអចិន្ត្រៃយ៍ និងប្រជុំពេញអង្គ(សមូហភាព)។

៣.១.ការប្រជុំអចិន្ត្រៃយ៍

(The Permanent Meeting)

ការប្រជុំអចិន្ត្រៃយ៍របស់ក្រុមប្រឹក្សារដ្ឋមន្ត្រីមានសមាសភាពដូចតទៅ:

-សមមិត្តប្រធាន

-បណ្តាសមមិត្តអនុប្រធាន

-សមមិត្តរដ្ឋមន្ត្រីទទួលបន្ទុកខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី។

ការប្រជុំអចិន្ត្រៃយ៍ជាទូទៅត្រូវធ្វើឡើង១ដងក្នុង១សប្តាហ៍ គឺកំណត់យកថ្ងៃណាមួយដោយមិនគិតពីការប្រជុំជាវិសាមញ្ញឡើយ។[145]

---

[143] មាត្រា៦៦រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

[144] មាត្រា៦៧រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

[145] មាត្រា២៣ច្បាប់ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី។

ការប្រជុំនេះ គឺត្រូវពិភាក្សារាល់បញ្ហានានាសំដៅត្រៀមរៀបចំសម្រាប់ការ ប្រជុំពេញអង្គ (សមូហភាព)របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី និងពិភាក្សាអំពីវិធានការណ៍ជាក់ស្តែង សម្រាប់អនុវត្តន៍នូវរាល់សេចក្តីសម្រេចរបស់អង្គប្រជុំពេញអង្គ(សមូហភាព)ត្រូវចាត់ចែង សម្របសម្រួលសហប្រតិបត្តិការ និងឯកភាពដឹកនាំរាល់សកម្មភាពប្រចាំថ្ងៃ រវាងក្រសួង និងក្រសួង រវាងក្រសួង និងមូលដ្ឋាន ត្រួតពិនិត្យទៅលើក្រសួង និងគណៈកម្មាធិការប្រជាជនបដិវត្តន៍មូលដ្ឋាន អំពីការអនុវត្តសេចក្តីសម្រេចផែនការរដ្ឋ និងថវិការដ្ឋ។[146]

សមមិត្តប្រធាន បណ្តាសមមិត្តអនុប្រធាន និងបណ្តាសមមិត្តរដ្ឋមន្ត្រី ដែលត្រូវទទួលបន្ទុកឧទ្ទកាល័យអគ្គលេខាធិការ ក្រុមប្រឹក្សារដ្ឋមន្ត្រីធ្វើការតាមលាក់ការណ៍របស់សមូហភាព ការកំណត់សម្រេច និងចាត់តាំងឲ្យទទួលបន្ទុកក្នុងម្នាក់ៗនូវការងារមួយចំនួនធំ ក្រោមការចាត់ចែងសម្របសម្រួលសហប្រតិបត្តិការ និងឯកភាពដឹកនាំរបស់សមមិត្តប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី។[147]

រាល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ត្រូវបានប្រកាសឲ្យប្រើតាមរូបភាពជាសេចក្តីសម្រេចអនុមតិ អនុក្រឹត្យ សេចក្តីសម្រេច និងសារាចរ។[148]

៣.២.ការប្រជុំពេញអង្គ(សមូហភាព)

(Plenary Meeting(Collectivity))

ប្រជុំពេញអង្គ(សមូហភាព)របស់ក្រុមប្រឹក្សារដ្ឋមន្ត្រីមានសមាសភាព:

-សមមិត្តប្រធាន

-បណ្តាសមមិត្តអនុប្រធាន

-បណ្តាសមមិត្តរដ្ឋមន្ត្រីជាសមាជិក។[149]

ការប្រជុំពេញអង្គ(សមូហភាព)របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ជាទូទៅត្រូវធ្វើឡើង១ដងក្នុង១ខែដោយមិនគិតពីការប្រជុំជាវិសាមញ្ញឡើយ។

បណ្តាសមមិត្តសមាជិករបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ត្រូវចូលរួមស្តាប់ខ្លឹមសារទាំងឡាយនៅក្នុងគ្រប់ការប្រជុំពេញអង្គ(សមូហភាព) ដោយពិភាក្សា និងកំណត់សម្រេចរាល់បញ្ហា ដែលស្ថិតនៅក្រោមសិទ្ធិ និងភារកិច្ចរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី។

សមមិត្តរដ្ឋមន្ត្រីណាដែលអវត្តមាន ត្រូវរាយការណ៍ជូន សមមិត្តប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី

---

[146] មាត្រា២៤ច្បាប់ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី។

[147] មាត្រា២៥ច្បាប់ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី។

[148] មាត្រា២៦ច្បាប់ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី។

[149] មាត្រា១៨ច្បាប់ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី។

ដោយអាស្រ័យទៅតាមអង្គប្រជុំនីមួយៗអាចបានការអនុញ្ញាតឲ្យសមមិត្តរដ្ឋមន្ត្រី គឺត្រូវចាត់តាំងសមមិត្តអនុរដ្ឋមន្ត្រី១រូបជាតំណាងជួសមុខឲ្យចូលប្រជុំ។

អ្នកដែលបានចាត់តាំងឲ្យទៅជំនួស មានសិទ្ធិក្នុងការបញ្ចេញមតិយោបល់ ក៏ប៉ុន្តែគឺគ្មានសិទ្ធិអនុម័តសម្រេចឡើយ។[150]

ការប្រជុំពេញអង្គ(សមូហភាព)របស់ក្រុមប្រឹក្សារដ្ឋមន្ត្រីពិភាក្សា និងកំណត់សម្រេចនូវរាល់បញ្ហាធំៗ និងសំខាន់ៗដូចតទៅ:

-ពិភាក្សា និងកំណត់សម្រេច នូវរាល់គោលការណ៍គោលនយោបាយ និងវិធានការធំៗសម្រាប់អនុវត្តន៍រាល់សេចក្តីសម្រេច របស់មជ្ឈិមបក្ស រដ្ឋសភា និងរបស់ក្រុមប្រឹក្សារដ្ឋ។

-ពិភាក្សា និងឆ្លងរាល់គម្រោងផែនការរដ្ឋ និងថវិការដ្ឋ មុនពេល ដែលត្រូវដាក់ឆ្លងជូនរដ្ឋសភាធ្វើការសម្រេច។

-ពិភាក្សា និងឆ្លងរាល់សេចក្តីព្រាងច្បាប់ ក្រឹត្យ-ច្បាប់ នៅមុនពេល ដែលត្រូវឆ្លងរដ្ឋសភា និងក្រុមប្រឹក្សារដ្ឋធ្វើការសម្រេច។

-ពិភាក្សា និងឆ្លងនូវរាល់គម្រោង អំពីអង្គការចាត់តាំងក្បាលម៉ាស៊ីនគ្រប់គ្រងកម្មាភិបាលរបស់បណ្តាក្រសួងស្ថាប័ននានាដែលចំណុះឲ្យក្រុមប្រឹក្សារដ្ឋមន្ត្រី និងគណៈកម្មាធិការប្រជាជនបដិវត្តន៍នៅគ្រប់មូលដ្ឋាន។[151]

-ការប្រជុំពេញអង្គ (សមូហភាព) របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ជាទូទៅត្រូវធ្វើឡើងតាមរយៈការកោះប្រជុំ និងជាអធិបតីរបស់សមមិត្តប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី ក្នុងករណី សមមិត្តប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រីអវត្តមាន គឺត្រូវប្រគល់សិទ្ធិទៅឲ្យសមមិត្ត អនុប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី១រូបជាអ្នកកោះប្រជុំ និងធ្វើជាគណៈអធិបតី។[152]

រាល់សេចក្តីសម្រេច របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ចាំបាច់គឺត្រូវតែបានការអនុម័តយល់ព្រមពីសមាជិកក្រុមប្រឹក្សារដ្ឋមន្ត្រីដែលមានវត្តមាននៅក្នុងអង្គប្រជុំ ហើយបានការអនុម័ត ដោយមានសម្លេងចំនួនជាងពាក់កណ្តាលឡើងទៅ។[153]

៤-នីតិកាលក្រុមប្រឹក្សារដ្ឋមន្ត្រី

(Terms of the Council of Ministers)

[150] មាត្រា១៩ច្បាប់ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី។

[151] មាត្រា២០ច្បាប់ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី។

[152] មាត្រា២១ច្បាប់ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី។

[153] មាត្រា២២ច្បាប់ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី។

អាណត្តិរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីគឺមានកំណត់ស្មើនឹងនីតិកាលរបស់រដ្ឋសភា នៅពេលផុតនីតិកាលរដ្ឋសភា ក្រុមប្រឹក្សារដ្ឋមន្ត្រីអាចបន្តសកម្មភាពរបស់ខ្លួន រហូតដល់រដ្ឋសភាធ្វើការជ្រើសតាំងក្រុមប្រឹក្សារដ្ឋមន្ត្រីថ្មីបាន។[154]

ឃ.រដ្ឋសភា

(Assembly)

រដ្ឋសភា គឺជាអង្គការកំពូលនៃរដ្ឋអំណាច និងជាអង្គការតំណាងជាន់ខ្ពស់ របស់ប្រជាជននៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

រដ្ឋសភាគឺជាអង្គការតែមួយគត់ ដែលមានសិទ្ធិអំណាចធ្វើច្បាប់។[155]

សមាជិករដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា គឺត្រូវបានធ្វើការជ្រើសរើសឡើងតាមរយៈការបោះឆ្នោតជាសាកល ដោយស្មើភាព ដោយចំពោះ និងដោយសម្ងាត់។[156]

ពលរដ្ឋនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ សុទ្ធតែមានសិទ្ធិទៅបោះឆ្នោតបានទាំងអស់ ដោយឥតប្រកាន់ជនជាតិ ភេទ សមាសភាពនៅក្នុងសង្គមជំនឿ សាសនា និងកម្រិតវប្បធម៌ឡើយ។

ពលរដ្ឋដែលកំពុងបម្រើការក្នុងកងកម្លាំងប្រដាប់អាវុធ ប្រជាជនបដិវត្តន៍កម្ពុជា ព្រមទាំងបព្វជិតមានសិទ្ធិបោះឆ្នោត និងឈរឈ្មោះឲ្យគេបោះឆ្នោត ដើម្បីទទួលបានការធ្វើជាសមាជិករដ្ឋសភាដូចពលរដ្ឋផ្សេងៗទៀតដែរ។

អ្នកឈរឈ្មោះឲ្យគេបោះឆ្នោត ដើម្បីជ្រើសរើសជាសមាជិករដ្ឋសភា ត្រូវមានអាយុចាប់ពី២១ឆ្នាំឡើងទៅ។[157]

រដ្ឋសភាត្រូវមានសមាជិករដ្ឋសភាទាំងអស់ចំនួន១១៧រូប។[158]

សមាជិករដ្ឋសភាត្រូវបានប្រជាជនកម្ពុជា ធ្វើការជ្រើសរើស នៅតាមមណ្ឌលបោះឆ្នោតនីមួយៗដែលមាននៅតាមខេត្ត និងក្រុង។[159]

---

[154] មាត្រា៦៨ និងមាត្រា៦៩រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

[155] មាត្រា៤៥រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

[156] មាត្រា២ស្តីពីច្បាប់បោះឆ្នោតជ្រើសរើសសមាជិករដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

[157] មាត្រា២ស្តីពីច្បាប់បោះឆ្នោតជ្រើសរើសសមាជិករដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

[158] មាត្រា៧ស្តីពីច្បាប់បោះឆ្នោតជ្រើសរើសសមាជិករដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

[159] មាត្រា៨ស្តីពីច្បាប់បោះឆ្នោតជ្រើសរើសសមាជិករដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

ចំនួនសមាជិករដ្ឋសភា នៅក្នុងមណ្ឌលនីមួយៗ ត្រូវកំណត់ទៅតាមបរិមាណប្រជាជននៃមណ្ឌលទាំងនោះ។ ក៏ប៉ុន្តែ ចំពោះទីក្រុងភ្នំពេញ និងក្រុងកំពង់សោម ដែលជាមណ្ឌលឧស្សាហកម្ម និងចំពោះខេត្តដែលមានប្រជាជនរស់នៅច្រើន ត្រូវមានការអនុគ្រោះអំពីបរិមាណប្រជាជន ដើម្បីឲ្យកម្មករឲ្យជនជាតិមានចំនួនតំណាងរបស់ខ្លួនសមល្មមនៅក្នុងរដ្ឋសភា។[160]

ចំនួនអាសនៈដែលត្រូវធ្វើការបោះឆ្នោតជ្រើសរើសនៅតាមបណ្តាខេត្ត និងក្រុងនៃមណ្ឌលបោះឆ្នោតនីមួយៗរួមមាន:

-នៅក្រុងភ្នំពេញមាន១២អាសនៈ
-ក្រុងកំពង់សោមមាន៣អាសនៈ
-ខេត្តកំពង់ចាមមាន១៣អាសនៈ
-ខេត្តកណ្តាលមាន១០អាសនៈ
-ខេត្តព្រៃវែងមាន៩អាសនៈ
-ខេត្តបាត់ដំបងមាន១១អាសនៈ
-ខេត្តតាកែវមាន៨អាសនៈ
-ខេត្តសៀមរាបមាន៦អាសនៈ
-ខេត្តកំពង់ធំមាន៥អាសនៈ
-ខេត្តស្វាយរៀងមាន៥អាសនៈ
-ខេត្តកំពង់ស្ពឺមាន៥អាសនៈ
-ខេត្តកំពតមាន៦អាសនៈ
-ខេត្តកំពង់ឆ្នាំងមាន៤អាសនៈ
-ខេត្តព្រះវិហារមាន៣អាសនៈ
-ខេត្តក្រចេះមាន៤អាសនៈ
-ខេត្តពោធិ៍សាត់មាន៤អាសនៈ
-ខេត្តស្ទឹងត្រែងមាន២អាសនៈ
-ខេត្តកោះកុងមាន២អាសនៈ
-ខេត្តរតនគិរីមាន៣អាសនៈ
-ខេត្តមណ្ឌលគិរីមាន២អាសនៈ។

[160] មាត្រា៩ស្តីពីច្បាប់បោះឆ្នោតជ្រើសរើសសមាជិករដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

១-ការចូលកាន់តំណែង

(Taking office)

ការចូលកាន់តំណែងរបស់សមាជិករដ្ឋសភានីមួយៗ ក្រោយពីការប្រកាសលទ្ធផលនៃការបោះឆ្នោត ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា ត្រូវធ្វើការកោះអញ្ជើញសមាជិករដ្ឋសភាទាំងអស់ដើម្បីបើកសម័យប្រជុំលើកទី១ ក្រោយពេលបោះឆ្នោត ៦០ថ្ងៃយ៉ាងយូរ។[161]

មុនចូលកាន់តំណែង រដ្ឋសភាប្រកាសតែងតាំងសមាជិករដ្ឋសភាដោយធ្វើការជ្រើសតាំងជាបឋមនូវគណៈកម្មការមួយ ដើម្បីធ្វើការត្រួតពិនិត្យទៅលើភាពត្រឹមត្រូវ ឬភាពមិនត្រឹមត្រូវរបស់តំណាងប្រជាជន។

គណៈកម្មការត្រួតពិនិត្យធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភាសម្រេច។[162]

២-អាណត្តិសភា

(Parliament Mandate)

នីតិកាលរបស់រដ្ឋសភា មានកំណត់រយៈពេល៥ឆ្នាំ ក្នុងកំឡុងពេល៣ខែមុនផុតកំណត់នីតិកាលរបស់ខ្លួនក្រុមប្រឹក្សារដ្ឋត្រូវធ្វើការសម្រេច និងដឹកនាំការរៀបចំការបោះឆ្នោតជ្រើសរើសសមាជិកតំណាងប្រជាជនរដ្ឋសភាសម្រាប់នីតិកាលថ្មី។

នៅក្នុងពេលមានសង្គ្រាម ឬស្ថិតក្នុងកាលៈទេសៈពិសេសដទៃទៀត រដ្ឋសភាក៏អាចធ្វើការប្រកាសបន្តនីតិកាលរបស់ខ្លួនបាន។[163]

៣-ការកោះប្រជុំរដ្ឋសភា

(Convocation of Parliament)

រដ្ឋសភា ត្រូវបើកសម័យប្រជុំលើកដំបូង៦០ថ្ងៃយ៉ាងយូរ ក្រោយពេលបោះឆ្នោតតាមរយៈការកោះប្រជុំរបស់ក្រុមប្រឹក្សារដ្ឋ។

ជាទូទៅរដ្ឋសភា បើកសម័យប្រជុំជាសាមញ្ញ២ដងក្នុង១ឆ្នាំ និងអាចបើកសម័យប្រជុំជាវិសាមញ្ញបានក្នុងករណីក្រុមប្រឹក្សារដ្ឋយល់ឃើញថាជាការចាំបាច់។[164]

ជារៀងរាល់ឆ្នាំរដ្ឋសភា ត្រូវបើកសម័យប្រជុំលើកទី១នៅចុងត្រីមាសទី២ និងសម័យប្រជុំលើកទី២នៅចុងត្រីមាសទី។

---

[161] មាត្រា៤៩ស្តីពីច្បាប់បោះឆ្នោតជ្រើសរើសសមាជិករដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

[162] មាត្រា៥០ស្តីពីច្បាប់បោះឆ្នោតជ្រើសរើសសមាជិករដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

[163] មាត្រា៤៧រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

[164] មាត្រា៤៩រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

រដ្ឋសភា អាចបើកសម័យប្រជុំជាវិសាមញ្ញបាន តាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សារដ្ឋត្រូវធ្វើតាមសេចក្តីស្នើរបស់ប្រធានរដ្ឋសភា ឬតាមសេចក្តីស្នើរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី។[165]

រដ្ឋសភាត្រូវប្រជុំដោយបើកចំហ(សាធារណៈ)។ប៉ុន្តែរដ្ឋសភាក៏អាចប្រជុំជាសម្ងាត់បានដែរ តាមសេចក្តីស្នើរបស់ក្រុមប្រឹក្សារដ្ឋ តាមសេចក្តីស្នើរបស់ប្រធានរដ្ឋសភា ឬក៏តាមសេចក្តីស្នើរបស់ប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី។[166]

នៅក្នុងសម័យប្រជុំជាសាមញ្ញទាំងឡាយរបស់រដ្ឋសភាក្រុមប្រឹក្សារដ្ឋ និងក្រុមប្រឹក្សារដ្ឋមន្ត្រីត្រូវរាយការណ៍អំពីកិច្ចការទាំងឡាយរបស់ខ្លួនជូនរដ្ឋសភា។[167]

នៅគ្រប់សម័យប្រជុំរបស់រដ្ឋសភា សមាជិករដ្ឋសភាមានភារកិច្ចចូលរួមប្រជុំនៅពេលណាបើកសម័យប្រជុំនីមួយៗរបស់រដ្ឋសភា សមាជិករដ្ឋសភាទាំងអស់ គឺត្រូវបានប្រធានរដ្ឋសភាជូនដំណឹងជាមុនអំពីកាលបរិច្ឆេទ និងខ្លឹមសារនៃការប្រជុំយ៉ាងតិចបំផុត ក៏រយៈពេល៨ថ្ងៃមុននៃការប្រជុំ។[168]

៤-សមាជិករដ្ឋសភា

(Members of Parliament)

សមាជិករដ្ឋសភាត្រូវស្មោះត្រង់នឹងមាតុភូមិ ត្រូវអនុវត្តន៍ឲ្យបានត្រឹមត្រូវ និងច្បាស់លាស់នូវមាគ៌ានយោបាយរបស់បដិវត្តន៍អនុវត្តន៍យ៉ាងហ្មត់ចត់គោរយរដ្ឋធម្មនុញ្ញ តាមសេចក្តីសម្រេចរបស់រដ្ឋសភាតាមច្បាប់របស់រដ្ឋ និងយកអស់កម្លាំងចិត្ត កម្លាំងកាយធ្វើការងារ ដើម្បីបម្រើផលប្រយោជន៍ប្រជាជន។[169]

សមាជិករដ្ឋសភាត្រូវទទួលខុសត្រូវចំពោះមុខប្រជាជនដែលជាម្ចាស់ឆ្នោត ទន្ទឹមនឹងនេះក៏ត្រូវទទួលខុសត្រូវ ចំពោះមុខរដ្ឋសភានៅក្នុងការអនុវត្តភារកិច្ច និងកិច្ចការសំខាន់ៗរបស់ខ្លួនក្នុងនាមជាសមាជិករបស់ខ្លួន។[170]

សមាជិករដ្ឋសភា ត្រូវរក្សាចំណងទាក់ទងយ៉ាងជិតស្និតជាមួយនឹងបណ្តាគណៈកម្មាធិការប្រជាជន គណៈកម្មាធិការរណសិរ្ស អង្គការមហាជននានា និងអ្នកបោះឆ្នោត នៅតាមមណ្ឌល

---

[165] មាត្រា១បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

[166] មាត្រា២បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

[167] មាត្រា៣បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

[168] មាត្រា៣៤បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

[169] មាត្រា២០បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

[170] មាត្រា២១បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

បោះឆ្នោតរបស់ខ្លួន។[171]

សមាជិករដ្ឋសភា ត្រូវរាយការណ៍ជូនប្រជាជនដែលជាម្ចាស់ឆ្នោត យ៉ាងតិចបំផុតមួយដងក្នុងមួយឆ្នាំអំពីការបំពេញភារកិច្ចជាតំណាងរបស់ខ្លួន។

ការជួបប្រាស្រ័យ រវាងសមាជិករដ្ឋសភា និងអ្នកបោះឆ្នោតអាចដំណើរការឡើង ដោយមានការជួយរៀបចំនិងការឧបត្ថម្ភរបស់គណៈកម្មាធិការប្រជាជន និងគណៈកម្មាធិការរណសិរ្ស នៅតាមមូលដ្ឋាន។[172]

សមាជិករដ្ឋសភា ដែលមិនអាចបំពេញភារកិច្ចរបស់ខ្លួនបាន គឺមិនសមនឹងជំនឿទុកចិត្តរបស់ប្រជាជន ប្រជាជនអាចត្រូវបោះឆ្នោតនៅមណ្ឌល ដែលបានបោះឆ្នោតឲ្យសមាជិករូបនោះដកហូតចេញមុនពេលចប់នីតិកាលរបស់ខ្លួនបាន។

រដ្ឋសភា អាចពិនិត្យ និងសម្រេចក្នុងការដកហូតសមាជិករដ្ឋសភារូបណា ដែលមិនសក្តិសមចេញពីសមាជិករដ្ឋសភា។[173]

សមាជិករដ្ឋសភាត្រូវទទួលបានមុនពេលប្រជុំ នូវរបាយការណ៍ និងឯកសារ ដែលចាំបាច់ផ្សេងៗដែលត្រូវបានលើកឡើង ដើម្បីធ្វើការពិភាក្សា ដោះស្រាយបញ្ហា និងអនុម័តនៅពេលប្រជុំរដ្ឋសភានាពេលខាងមុខ។[174]

សមាជិករដ្ឋសភា មានការកិច្ចចូលរួមប្រជុំនៅគ្រប់សម័យប្រជុំរបស់រដ្ឋ សភា។ ប្រសិនបើមិនអាចចូលរួមប្រជុំដោយមូលហេតុណាមួយ សមាជិករដ្ឋសភានោះគឺត្រូវរាយការណ៍ជូនប្រធានរដ្ឋសភាឲ្យបានជ្រាប។[175]

សមាជិករដ្ឋសភា មានការកិច្ចស្រាវជ្រាវ និងផ្ញើទៅឲ្យស្ថាប័ននានា ដែលមានទំនាក់ទំនងដើម្បីធ្វើការត្រួតពិនិត្យ និងដោះស្រាយ ចំពោះសេចក្តីតវ៉ា ការចោទប្រកាន់ ញ្ញត្តិរបស់ប្រជាជន និងសំណូមពរ ដោយបានការអនុម័តសម្រេចពីរដ្ឋសភារួចហើយ។

សមាជិករដ្ឋសភា ត្រូវតាមដានបញ្ហាទាំងនោះដើម្បីធ្វើការដោះស្រាយ បើការដោះស្រាយមិនសមស្រប ឬមានការយឺតយ៉ាវសមាជិករដ្ឋសភាត្រូវលើកបញ្ហានេះ ជូនដល់ស្ថាប័ន ដែលមាន

---

[171] មាត្រា២២បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

[172] មាត្រា២៨បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

[173] មាត្រា៣១បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

[174] មាត្រា៣៤បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

[175] មាត្រា២៣បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

ការទាក់ទងនោះ ត្រូវធ្វើការដោះស្រាយឲ្យបានឆាប់រហ័ស ឬស្នើដល់ថ្នាក់លើរបស់ស្ថាប័ននោះ ឲ្យជួយដោះស្រាយធ្វើអន្តរាគមន៍ជាបន្ទាន់។

សមាជិករដ្ឋសភា ត្រូវជម្រាបជូនដំណឹងដល់អ្នកលើកបញ្ហាទាំងនោះ ឲ្យបានដឹងអំពីការកិច្ចដែលសមាជិករដ្ឋសភាបានធ្វើ។[176]

នៅគ្រប់សម័យប្រជុំរបស់រដ្ឋសភា សមាជិករដ្ឋសភាគឺមានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិតាមទស្សនៈរបស់ខ្លួន ស្តីអំពីបញ្ហានានា ដែលសមាជិករដ្ឋសភាយល់ឃើញថា ជាការចាំបាច់ត្រូវលើកឡើងដើម្បីឲ្យរដ្ឋសភាធ្វើការត្រួតពិនិត្យ និងសម្រេច។

នៅក្នុងជីវភាពតាមក្រសួងមន្ទីរ សហគ្រាស និងក្នុងសង្គមសមាជិករដ្ឋសភាត្រូវធ្វើការបញ្ចេញមតិ និងធ្វើសកម្មភាពឲ្យបានត្រឹមត្រូវ ទៅតាមសេចក្តីសម្រេចចិត្តរបស់រដ្ឋសភាតាមមាគ៌ានយោបាយរបស់បក្ស និងតាមច្បាប់របស់រដ្ឋ។[177]

៥-ប្រធានរដ្ឋសភា

(President of Parliamant)

ប្រធានរដ្ឋសភា ជាអ្នកបើក និងបិទសម័យប្រជុំនានារបស់រដ្ឋសភា ហើយធ្វើជាអធិបតីនៅក្នុងគ្រប់សម័យប្រជុំ ដើម្បីធានាវ៉ាប់រងដល់ការអនុវត្តនូវកម្មវិធីការងារ និងបទបញ្ជាផ្ទៃក្នុងនៃសម័យប្រជុំរបស់រដ្ឋសភា[178]។

ប្រធានរដ្ឋសភាជាអ្នកចុះហត្ថលេខាក្នុការទទួលអាញ្ញាត្តិច្បាប់ និងសេចក្តីសម្រេចនានាដែលរដ្ឋសភា ត្រូវបានអនុម័តរក្សាទំនាក់ទំនងជាមួយសមាជិករដ្ឋសភា ជាមួយក្រុមប្រឹក្សារដ្ឋមន្ត្រី ក្រុមប្រឹក្សាទូទាំងប្រទេស រណសិរ្សសាមគ្គី កសាង ការពារមាតុភូមិនៃកម្ពុជា និងបណ្តាអង្គការមហាជននានា។[179]

ប្រធានរដ្ឋសភា មានសិទ្ធិចូលរួម គ្រប់សម័យប្រជុំរបស់ក្រុមប្រឹក្សារដ្ឋ និងរក្សាទំនាក់ទំនងជាមួយនឹងក្រុមប្រឹក្សារដ្ឋ។[180]

ប្រធានរដ្ឋសភា អនុវត្តន៍ការៈទាក់ទងអន្តរជាតិទាំងឡាយនៃរដ្ឋសភា។

---

[176] មាត្រា២៧បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

[177] មាត្រា២៩បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

[178] មាត្រា៣៦ច្បាប់ស្តីពីការរៀបចំរដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

[179] មាត្រា៣៧ច្បាប់ស្តីពីការរៀបចំរដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

[180] មាត្រា៣៨ច្បាប់ស្តីពីការរៀបចំរដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

ប្រធានរដ្ឋសភា មានសិទ្ធិចូលរួមក្នុងសន្និបាត ប្រធានគណៈកម្មការទាំងឡាយរបស់រដ្ឋសភា កោះប្រជុំ និងដឹកនាំសន្និបាតរបស់ប្រធានគណៈកម្មការនានា ដើម្បីធ្វើការសម្របសម្រួល និងសហប្រតិបត្តិការក្នុងកម្មវិធីបំពេញការងាររបស់គណៈកម្មការទាំងនោះ។[181]

ប្រធានរដ្ឋសភា ដឹកនាំអង្គប្រជុំរបស់រដ្ឋសភា ទទួលបទបញ្ញត្តិច្បាប់ និងសេចក្តីសម្រេចចិត្តនានាដែលរដ្ឋសភាបានអនុម័ត ហើយធានាការរ៉ាប់រង ចំពោះការអនុវត្តបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា និងរក្សាចំណងទាក់ទងនឹងក្រុមប្រឹក្សារដ្ឋមន្ត្រី គណៈកម្មាធិការ រណសិរ្ស អង្គការមហាជននានាជាមួយសមាជិករដ្ឋសភាទាំងឡាយ និងអនុវត្តន៍ការទំនាក់ទំនងអន្តរជាតិទាំងឡាយនៃអង្គការរដ្ឋសភា។

ប្រធានរដ្ឋសភា មានសិទ្ធិចូលរួមគ្រប់ការប្រជុំនានានៃក្រុមប្រឹក្សារដ្ឋ ព្រមទាំងរក្សាចំណងទាក់ទងជាមួយក្រុមប្រឹក្សារដ្ឋ។

ប្រធានរដ្ឋសភា ត្រូវរៀបចំ និងដំណើរការឲ្យបានឆាប់រហ័ស ក្នុងការបង្កើតគណៈកម្មាធិការមួយចំនួនរបស់អង្គការរដ្ឋសភា និងណែនាំគណៈកម្មាធិការរបស់រដ្ឋសភាទាំងនោះ ឲ្យធ្វើសកម្មភាព ដែលមានគណៈកម្មាធិការនីតិកម្ម(ឲ្យធ្វើច្បាប់)មានគណៈកម្មាធិការសេដ្ឋកិច្ច និងថវិកា គណៈកម្មាធិការវប្បធម៌ និងសង្គមកិច្ច របបកំណត់របស់គណៈកម្មាធិការទាំងនេះ ត្រូវបានកំណត់ជាក្រោយ។

អនុប្រធានរបស់រដ្ឋសភាទាំងឡាយ ត្រូវបានបែងចែកការកិច្ចជាជំនួយការឲ្យរដ្ឋសភាក្នុងតួនាទីផ្សេង។

-អនុប្រធាន១រូប ជាអ្នកទទួលបន្ទុករក្សាចំណងទាក់ទងជាមួយក្រុមប្រឹក្សារដ្ឋមន្ត្រី។

-អនុប្រធាន១រូប ជាអ្នកទទួលបន្ទុករក្សាចំណងទាក់ទងជាមួយ នឹងរណសិរ្ស អង្គការមហាជននានា និងជាមួយសមាជិកទាំងឡាយរបស់រដ្ឋសភា។

-អនុប្រធាន១រូប ជាអ្នកទទួលបន្ទុកដោយឡែក នៅក្នុងការងាររក្សាចំណងទាក់ទងការងារជាមួយរដ្ឋសភានៃបណ្តាប្រទេសនានានៅលើពិភពលោក។[182]

-អនុប្រធានរដ្ឋសភា ត្រូវជួយដល់ប្រធានរដ្ឋសភា នៅក្នុងមុខងារទាំងឡាយរបស់ប្រធានរដ្ឋសភា ហើយដែលលេខាធិការរបស់រដ្ឋសភា ត្រូវធ្វើកំណត់ហេតុផ្សេងៗនៃគ្រប់ការប្រជុំរបស់រដ្ឋសភា និងការបំពេញតួនាទីការកិច្ចសំខាន់ៗ ដែលត្រូវបានអនុវត្តន៍ឲ្យបានត្រឹមត្រូវនូវសកម្មភាព

[181] មាត្រា៤០ច្បាប់ស្តីពីការរៀបចំរដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

[182] មាត្រា៦បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

ការងារទាំងឡាយដែលប្រធានរដ្ឋសភាបានប្រគល់ឲ្យ។[183]

រដ្ឋសភាត្រូវចាត់តាំងគណៈកម្មការផ្សេងៗដែលចាំបាច់ដើម្បីជួយរដ្ឋសភា និងក្រុមប្រឹក្សារដ្ឋ ក្នុងការត្រួតពិនិត្យមើលលើសេចក្តីព្រាងច្បាប់ សេចក្តីព្រាងក្រឹត្យ គម្រោងកម្មវិធី សេដ្ឋកិច្ចវិការដ្ឋ និងគម្រោងផ្សេងៗ ដែលរដ្ឋសភា ឬក្រុមប្រឹក្សារដ្ឋបានប្រគល់ឲ្យ។[184]

ប្រធានរដ្ឋសភា ក្រុមប្រឹក្សារដ្ឋ ក្រុមប្រឹក្សារដ្ឋមន្ត្រី គណៈកម្មការនានារបស់អង្គរដ្ឋសភា ប្រធានគណៈកម្មាធិការមជ្ឈិម រណសិរ្ស កសាងមាតុភូមិកម្ពុជា ប្រធានសហជីពប្រធានយុវជនបដិវត្តន៍កម្ពុជា ប្រធានសមាគមនារីកម្ពុជា មានសិទ្ធិធ្វើសេចក្តីព្រាងច្បាប់ដាក់ជូនរដ្ឋសភាធ្វើការពិភាក្សា ឬប្រគល់ឲ្យគណៈកម្មាធិការនានានៃរដ្ឋសភា ធ្វើការត្រួតពិនិត្យជាមុនសិនមុនពេលដាក់ជូនរដ្ឋសភាធ្វើការពិភាក្សា និងអនុម័តសម្រេច។[185]

៦-ការអនុម័ត

(Adoption)

រដ្ឋសភាធ្វើការតាមរបបមហាសន្និបាត។

រដ្ឋសភាអនុម័តច្បាប់ និងសេចក្តីសម្រេចផ្សេងៗទៀត ទៅតាមមតិយល់ព្រមលើសពីពាក់កណ្តាលនៃសមាជិកដែលបានចូលរួម។

រដ្ឋសភា អនុម័តរដ្ឋធម្មនុញ្ញ និងកែប្រែរដ្ឋធម្មនុញ្ញ តាមមតិយល់ព្រមពីរភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងអស់។ រដ្ឋសភាត្រូវអនុម័តនូវសេចក្តីព្រាងគម្រោង និងរបាយការណ៍នានាទៅតាមនីតិវិធីដោយការលើកដៃ។[186]

ច្បាប់ដែលរដ្ឋសភា បានអនុម័តសម្រេចរួចហើយ៣០ថ្ងៃយ៉ាងយូរក្រុមប្រឹក្សារដ្ឋគឺត្រូវធ្វើការប្រកាសឲ្យប្រើជាសាធារណៈ។[187]

៧-សិទ្ធិអំណាចរដ្ឋសភា

(Power of Parliament)

ជាទូទៅរដ្ឋសភាមានសិទ្ធិអំណាចជាច្រើនដូចជា:

---

[183] មាត្រា៥១រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

[184] មាត្រា៥២នៃរដ្ឋធម្មនុញ្ញសាធារណរដ្ឋប្រជាមានិតកម្ពុជា។

[185] មាត្រា៨បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

[186] មាត្រា៥បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

[187] មាត្រា៥៤ មាត្រា៥៥នៃរដ្ឋធម្មនុញ្ញសាធារណរដ្ឋប្រជាមានិតកម្ពុជា។

-អនុម័ត ឬកែប្រែច្បាប់រដ្ឋធម្មនុញ្ញ និងច្បាប់នានា។

-ត្រួតពិនិត្យការអនុវត្តរដ្ឋធម្មនុញ្ញ និងការអនុវត្តច្បាប់។

-កំណត់គោលនយោបាយក្នុងប្រទេស និងក្រៅប្រទេស។

-អនុម័តកម្មវិធី សេដ្ឋកិច្ច វប្បធម៌ និងថវិការដ្ឋ។

-បង្កើត ឬលុបចោលទីស្តីការរដ្ឋមន្ត្រី ឬស្ថាប័នថ្នាក់ស្មើទីស្តីការរដ្ឋមន្ត្រី។

-ត្រួតពិនិត្យសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋ និងក្រុមប្រឹក្សារដ្ឋមន្ត្រី។

-បង្កើតកែប្រែ ឬលុបចោលពន្ធដារ។

-កំណត់អំពីការលើកលែងទោសជាទូទៅ។

-ផ្តល់សច្ចាប័ន ឬលុបចោលសន្ធិសញ្ញាអន្តរជាតិ ក្នុងករណីដែលក្រុមប្រឹក្សារដ្ឋបានជូនទៅរដ្ឋសភាដើម្បីធ្វើការអនុម័តសម្រេច។

-ជាអ្នកបោះឆ្នោតជ្រើសតាំងប្រធានរដ្ឋសភា អនុប្រធានរដ្ឋសភា និងលេខាធិការរដ្ឋសភា តាមបញ្ជីឈ្មោះឧទ្ទេសនាមបេក្ខជន ដែលមានបញ្ជាក់តំណែងនៃមនុស្សម្នាក់ៗ ដែលអាស្រ័យដោយប្រធានក្រុមប្រឹក្សារដ្ឋនៃនីតិកាលមុនៗ ដែលឧទ្ទេសនាមបន្ទាប់ពីបាន ស្ទាបស្ទង់មតិរបស់សមាជិករដ្ឋសភានានា ដោយធ្វើការពិគ្រោះប្តូរយោបល់ក្នុងរណសិរ្ស។[188]

-ជាអ្នកបោះឆ្នោតជ្រើសតាំងប្រធាន អនុប្រធាន អគ្គលេខាធិការ និងសមាជិកនានានៃក្រុមប្រឹក្សារដ្ឋក្នុងចំណោមសមាជិករដ្ឋសភា តាមបញ្ជីឈ្មោះឧទ្ទេសនាមរបស់បេក្ខជន ដែលមានបញ្ជាក់តំណែងនៃមនុស្សម្នាក់ៗ ដែលអាស្រ័យដោយប្រធានរដ្ឋសភា ឧទ្ទេសនាមបន្ទាប់ពីបានស្ទាបស្ទង់មតិរបស់សមាជិករដ្ឋសភាទាំងឡាយ ដោយធ្វើការពិគ្រោះ ប្តូរយោបល់នៅក្នុងអង្គការណសិរ្ស។[189]

-ជាអ្នកបោះឆ្នោតជ្រើសតាំង ប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី ក្នុងចំណោមសមាជិករដ្ឋសភា ដែលអាស្រ័យទៅដោយប្រធានក្រុមប្រឹក្សារដ្ឋជាអ្នកឧទ្ទេសនាម បន្ទាប់ពីបានស្ទាបស្ទង់មតិអំពីសមាជិករដ្ឋសភាទាំងឡាយ។[190]

-ជាអ្នកបោះឆ្នោតជ្រើសតាំងបណ្តាអនុប្រធាន និងសមាជិកផ្សេងៗទៀត របស់ក្រុមប្រឹក្សារដ្ឋមន្ត្រីជាសំខាន់ គឺធ្វើការជ្រើសរើស ក្នុងចំណោមសមាជិករដ្ឋសភា តាមបញ្ជីឈ្មោះឧទ្ទេសនាមបេក្ខជន ដែលមានបញ្ជាក់ អំពីតំណែងរបស់មនុស្សម្នាក់ៗ ដែលអាស្រ័យទៅដោយ ប្រធានក្រុម

[188] មាត្រា៧ច្បាប់ស្តីពីការរៀបចំរដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

[189] មាត្រា៨ច្បាប់ស្តីពីការរៀបចំរដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

[190] មាត្រា៩ច្បាប់ស្តីពីការរៀបចំរដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

ប្រឹក្សារដ្ឋមន្ត្រី។[191]

-រដ្ឋសភា ជាអង្គកម្រើសតាំងបណ្តាអ្នកដឹកនាំនៃស្ថាប័នរដ្ឋខ្ពស់បំផុតទាំងឡាយដូចពោលខាងលើតាមនីតិវិធីបោះឆ្នោតជាសម្ងាត់។[192]

-សម័យប្រជុំជាសាមញ្ញនានារបស់រដ្ឋសភា ក្រុមប្រឹក្សារដ្ឋ និងក្រុមប្រឹក្សារដ្ឋមន្ត្រី គឺត្រូវរាយការណ៍អំពីសកម្មភាពរបស់ខ្លួនជូនរដ្ឋសភាបានជ្រាប។[193]

-រដ្ឋសភា អនុម័តសម្រេចលើផែនការរដ្ឋ និងថវិការដ្ឋ ដែលក្រុមប្រឹក្សារដ្ឋមន្ត្រីបានលើកជូនរដ្ឋសភាដើម្បីត្រួតពិនិត្យ និងអនុម័ត។[194]

-បោះឆ្នោតជ្រើសតាំង ឬរំសាយប្រធាន អនុប្រធាន អគ្គលេខាធិការ និងសមាជិកដទៃទៀតនៃក្រុមប្រឹក្សារដ្ឋ បោះឆ្នោតជ្រើសតាំង ឬរំសាយប្រធាន អនុប្រធាន និងសមាជិកក្រុមប្រឹក្សារដ្ឋមន្ត្រី។[195]

សមាជិករដ្ឋសភាត្រូវតែមានសិទ្ធិក្នុងការសួរដេញដោលដល់ក្រុមប្រឹក្សារដ្ឋ ក្រុមប្រឹក្សារដ្ឋមន្ត្រី ប្រធានរដ្ឋសភា។ ចំពោះស្ថាប័នរដ្ឋ និងអ្នកដែលត្រូវបានសួរដេញដោលត្រូវតែឆ្លើយ នៅក្នុងសម័យប្រជុំពេញអង្គរដ្ឋសភា។[196]

សមាជិករដ្ឋសភា មានកាតព្វកិច្ចគោរពបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា ជាគំរូក្នុងការអនុវត្តរដ្ឋធម្មនុញ្ញ ឬច្បាប់ទាំងឡាយ ដែលមានភារកិច្ចអនុវត្តន៍ និងដំណើរការប្រព្រឹត្តទៅឲ្យសមស្របតាមសេចក្តីសម្រេចរបស់រដ្ឋសភា។

សមាជិករដ្ឋសភារូបណា ដែលមិនបានអនុវត្តន៍បំពេញភារកិច្ចរបស់ខ្លួនគឺអាចនឹងត្រូវបានរំសាយចោលទៅតាមផ្លូវច្បាប់។

៨-អភ័យឯកសិទ្ធិសភា

(Parliament Immunity)

សមាជិករដ្ឋសភាត្រូវមានអភ័យឯកសិទ្ធិសមាជិករដ្ឋសភារូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ ឬចាប់ខ្លួន ឬឃុំឃាំង ដោយហេតុអំពីសម្តែងយោបល់ ឬបញ្ចេញមតិ ក្នុងការបំពេញ

---

[191] មាត្រា១០ច្បាប់ស្តីពីការរៀបចំរដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

[192] មាត្រា១១ច្បាប់ស្តីពីការរៀបចំរដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

[193] មាត្រា១២ច្បាប់ស្តីពីការរៀបចំរដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

[194] មាត្រា១៣ច្បាប់ស្តីពីការរៀបចំរដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

[195] មាត្រា៤៨នៃរដ្ឋធម្មនុញ្ញសាធារណរដ្ឋប្រជាមានិតកម្ពុជា។

[196] មាត្រា៥៧នៃរដ្ឋធម្មនុញ្ញសាធារណរដ្ឋប្រជាមានិតកម្ពុជា។

មុខងាររបស់ខ្លួនសោះឡើយ។

ការចោទប្រកាន់ ឬការចាប់ខ្លួន ឬការឃុំខ្លួនសមាជិករដ្ឋសភារូបណាមួយ នឹងអាចធ្វើទៅបានលុះត្រាតែមានការយល់ព្រមអំពីរដ្ឋសភា ឬពីក្រុមប្រឹក្សារដ្ឋជាមុនសិន ហើយក៏ត្រូវដាក់ប្រជុំរដ្ឋសភា ដើម្បីធ្វើការអនុម័តសម្រេចនៅក្នុងចន្លោះសម័យប្រជុំរដ្ឋសភា វៀរលែងតែក្នុងករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង។ ក្នុងករណីខាងក្រោយនេះ ក្រសួងមានសមត្ថកិច្ចត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា ឬជូនទៅក្រុមប្រឹក្សារដ្ឋជាបន្ទាន់ដើម្បីធ្វើការសម្រេច។

សេចក្តីរាយការណ៍របស់ក្រុមប្រឹក្សារដ្ឋ ត្រូវតែដាក់ជូនរដ្ឋសភាធ្វើការអនុម័តនៅក្នុងសម័យប្រជុំរដ្ឋសភានាពេលខាងមុខ។[197]

សមាជិករដ្ឋសភារូបណា ដែលបានប្រព្រឹត្តល្មើសទៅនឹងច្បាប់ ហើយត្រូវបានតុលាការកាត់ទោសឲ្យជាប់ក្នុងមន្ទីរឃុំឃាំងនោះ សមាជិករូបនោះត្រូវបាត់បង់សិទ្ធិជាសមាជិករដ្ឋសភា។

សមាជិករដ្ឋសភា អាចស្នើសុំលាលែង ពីតំណែងសមាជិករដ្ឋសភារបស់ខ្លួនបានជាបន្ទាន់ដោយមូលហេតុមិនអាចបំពេញភារកិច្ចក្នុងឋានៈជាសមាជិករដ្ឋសភា។

ការលាលែងចេញពីតំណែងនៃសមាជិករដ្ឋសភា គឺអាស្រ័យទៅដោយរដ្ឋសភាជាអ្នកត្រួតពិនិត្យ និងសម្រេច។[198]

[197] មាត្រា៥៦នៃរដ្ឋធម្មនុញ្ញសាធារណរដ្ឋប្រជាមានិតកម្ពុជា។

[198] មាត្រា៣១បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

ជំពូកទី៥

ស្ថាប័ននយោបាយព្រះរាជាណាចក្រកម្ពុជា

(Political Institutions of Kingdom of Cambodia)

សម័យពីឆ្នាំ១៩៩៣មកដល់បច្ចុប្បន្ន

(1993 to Present)

ស្ថានភាពទូទៅ

(General Situation)

ដោយមានកិច្ចព្រមព្រៀងទីក្រុងប៉ារីសនៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ដែលបានព្រមព្រៀងគ្នា រវាងភាគីអ្នកដឹកនាំខ្មែរជាច្រើនរូប គណបក្សនយោបាយមួយដែលមានគណបក្សប្រជាជនជាអ្នកដឹកនាំក្នុងប្រទេស និងភាគីជម្លោះគឺមានចលនាត្រីភាគី ដែលមានគណបក្សហ្វុនស៊ិនប៉ិច គណបក្សប្រជាធិបតេយ្យសេរីនិយម ព្រះពុទ្ធសាសនា និងអ្នកដឹកនាំកម្ពុជាប្រជាធិបតេយ្យដែលបានតស៊ូនៅតាមព្រំដែនកម្ពុជាថៃ និងដោយមានការជួយជ្រោមជ្រែងអំពីអង្គការសហប្រជាជាតិ ប្រទេសកម្ពុជាត្រូវបានរៀបចំធ្វើការការបោះឆ្នោតជាសាកលមួយនៅថ្ងៃទី២៣ដល់ថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៣។

ប្រជាពលរដ្ឋខ្មែរទូទាំងប្រទេសក៏បាននាំគ្នាទៅបោះឆ្នោត ដើម្បីធ្វើការជ្រើសរើសតំណាងរាស្ត្រសម្រាប់ទូទាំងប្រទេសកម្ពុជា ដែលមានចំនួន១២០រូប ដោយអនុវត្តន៍យកតាមប្រព័ន្ធបោះឆ្នោតសមាមាត្រ។

ខណៈពេលនោះ មានចំនួន២០គណបក្សដែលបានចូលរួមក្នុងការដណ្តើមសន្លឹកឆ្នោត។ ជាលទ្ធផលចុងក្រោយ គឺគណៈបក្សហ្វុនស៊ិនប៉ិចទទួលបានចំនួន៥៨អាសនៈ គណបក្សប្រជាជនទទួលបាន៥១អាសនៈ គណបក្សសេរីនិយមព្រះពុទ្ធសាសនា ទទួលបានចំនួន១០អាសនៈ និងគណបក្សម៉ូលីណាការទទួលបានចំនួន១អាសនៈសរុបទាំងអស់មានចំនួន១២០អាសនៈ។

សភាធម្មនុញ្ញត្រូវបានកោះប្រជុំលើកទី១នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៩៣។ ចាប់តាំងពីពេលនោះមកសភាធម្មនុញ្ញ បានចាប់ដំណើរការរបស់ខ្លួន ដោយការរៀបចំតាក់តែងសេចក្តីព្រាងរដ្ឋធម្មនុញ្ញ និងដាក់ពិភាក្សាលើសេចក្តីព្រាងរដ្ឋធម្មនុញ្ញនេះ។

សភាធម្មនុញ្ញបានដំណើរការយ៉ាងសកម្ម ហើយបានអនុម័តរដ្ឋធម្មនុញ្ញមួយនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣។ នៅក្នុងការអនុម័តរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជានេះ គឺមានសម្លេង ៩៧%គាំទ្រ ហើយត្រូវបានព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា បានឡាយព្រះហស្តលេខា

ប្រកាសឲ្យប្រើ នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ដោយអនុវត្តន៍តាមរបបលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស និងរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ។

ប្រទេសកម្ពុជាជាព្រះរាជាណាចក្រ ដែលមានព្រះមហាក្សត្រទ្រង់ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងតាមលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។

ព្រះរាជាណាចក្រកម្ពុជា ជារដ្ឋឯករាជ្យ អធិបតេយ្យ សន្តិភាព អព្យាក្រឹត្យ អចិន្ត្រៃយ៍ និង មិនចូលបក្សសម្ព័ន្ធ។[199]

ហេតុនេះហើយ យើងឃើញថា នៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាក៏បានចែង អំពីស្ថាប័នធំៗទាំងបី:

-ស្ថាប័ននយោបាយ

-ស្ថាប័នរដ្ឋបាល

-ស្ថាប័នតុលាការ។

ចំណែកឯស្ថាប័ននយោបាយត្រូវបានបង្កើតឲ្យមានស្ថាប័នជាច្រើនរួមមាន:

-ស្ថាប័នព្រះមហាក្សត្រ

-ស្ថាប័ននីតិប្រតិបត្តិ(រាជរដ្ឋាភិបាល)

-ស្ថាប័ននីតិបញ្ញត្តិ(រដ្ឋសភា និងព្រឹទ្ធសភា)

-ស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញ

-និងស្ថាប័នផ្សេងៗទៀត។

[199] មាត្រា១រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

ផ្នែកទី១

ព្រះមហាក្សត្រ

(King)

ស្ថាប័នព្រះមហាក្សត្រ គឺជាស្ថាប័នដំបូងបង្អស់ ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

ប្រទេសកម្ពុជា ជាព្រះរាជាណាចក្រដែលមានស្តេចសោយរាជ្យ ព្រះមហាក្សត្រកម្ពុជាទ្រង់ឡើងគ្រងរាជសម្បត្តិប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ។

ព្រះមហាក្សត្រ ទ្រង់ជាព្រះប្រមុខរដ្ឋអស់មួយជីវិត អង្គព្រះមហាក្សត្រមិនត្រូវបាននរណាម្នាក់រំលោភបំពានបានឡើយ។[200]

ក.ការជ្រើសរើសព្រះមហាក្សត្រ

(King Selection)

ការជ្រើសរើសព្រះមហាក្សត្រដើម្បីឡើងគ្រងរាជសម្បត្តិគឺត្រូវធ្វើឡើងតាមរយៈក្រុមប្រឹក្សារាជសម្បត្តិ គឺបានសេចក្តីថា ព្រះមហាក្សត្រ ព្រះអង្គពុំអាចចាត់តាំងជាព្រះរាជទាយាទ ដើម្បីឲ្យឡើងគ្រងរាជសម្បត្តិបន្ត ដោយព្រះទ័យព្រះអង្គផ្ទាល់បានឡើយ។ ការជ្រើសរើសព្រះមហាក្សត្រថ្មី គឺត្រូវធ្វើឡើងតាមរយៈរបបជ្រើសតាំង មិនមែនតាមរយៈការតែងតាំងដូចរបបមុនៗនោះទេ។

រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បានចែងថា "របបរាជានិយមនៅកម្ពុជា គឺជារបបជ្រើសតាំង" មិនមែនជារបបតែងតាំងព្រះមហាក្សត្រដូចសម័យដើមឡើយ។[201]

ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានជ្រើសរើសចេញពីសមាជិកនៃព្រះរាជវង្សានុវង្សខ្មែរដែលមានព្រះជន្មាយុយ៉ាងតិច៣០ព្រះវស្សា ហើយដែលជាព្រះរាជបច្ឆាញាតិ(ខ្សែ)នៃព្រះបាទ **អង្គឌួង** ព្រះបាទ **នរោត្តម** ឬព្រះបាទ **ស៊ីសុវត្ថិ**។[202]

ដូចនេះតំណែងជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាមិនត្រូវបានបើកចំហសម្រាប់ឲ្យមនុស្សទូទៅគ្រប់រូបឡើយ។

ចំណែកឯ ព្រះជាយានៃព្រះមហាក្សត្រវិញ ក៏ត្រូវមានព្រះរាជឋានៈជា ព្រះអគ្គមហេសី

---

[200] មាត្រា៧រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[201] មាត្រា១០រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[202] មាត្រា១៤ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

នៃព្រះរាជាណាចក្រកម្ពុជាដែរ។[203]

ព្រះរាជអគ្គមហេសី ពុំមានសិទ្ធិធ្វើនយោបាយ ឬកាន់ព្រះរាជតួនាទីជាប្រមុខរដ្ឋ ឬប្រមុខរាជរដ្ឋាភិបាល ឬកាន់តួនាទីរដ្ឋបាល ឬនយោបាយណាមួយឡើយ។

អគ្គមហេសីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទុកព្រះរាជកាយពល បំពេញព្រះរាជភារៈបម្រើផលប្រយោជន៍សង្គម មនុស្សធម៌ សាសនា និងជួយព្រះមហាក្សត្រក្នុងរាជកិច្ចផ្នែកពិធីការ និងការទូតដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ។[204]

នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ក្រុមប្រឹក្សារាជសម្បត្តិត្រូវបានជ្រើសរើសព្រះអង្គម្ចាស់ព្រះបាទ នរោត្តម សីហនុ ជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។ ព្រះអគ្គមហេសីនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានតែងតាំងដោយព្រះមហាក្សត្រកម្ពុជាព្រះបាទ នរោត្តម សីហនុ តាមសេចក្តីស្នើសុំពីក្រុមប្រឹក្សារាជសម្បត្តិ ស្តីអំពីព្រះរាជឋានៈរបស់ព្រះអគ្គមហេសីព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ដោយមានព្រះនាមថា ព្រះអគ្គមហេសី នរោត្តម មុនីនាថ សីហនុ ដែលត្រូវបានតែងតាំងដោយ ព្រះរាជក្រឹត្យចុះថ្ងៃទី៣ ខែតុលា ឆ្នាំ១៩៩៣។

ខ.ក្រុមប្រឹក្សារាជសម្បត្តិ

(Council of Throne)

ក្រុមប្រឹក្សារាជសម្បត្តិ គឺត្រូវបានបង្កើតឡើងជាអចិន្ត្រៃយ៍ ហើយមានតួនាទីសម្រាប់ជ្រើសតាំងព្រះមហាក្សត្រថ្មីជំនួសព្រះមហាក្សត្រចាស់ ក្នុងករណីព្រះអង្គបានចូលនិវត្តន៍ ឬសោយទីវង្គត នោះក្រុមប្រឹក្សារាជសម្បត្តិ ត្រូវធ្វើការជ្រើសរើសព្រះមហាក្សត្រថ្មីជាបន្ទាន់ គឺមិនឲ្យលើសពីរយៈពេល៧ថ្ងៃឡើយ។

១-សមាសភាពក្រុមប្រឹក្សារាជសម្បត្តិ

(Members of the Council of Throne)

ក្រុមប្រឹក្សារាជសម្បត្តិមានសមាសភាពចំនួន៩រូបដែលមានដូចជា:[205]

១-ប្រធានព្រឹទ្ធសភា	ជាប្រធាន
២-ប្រធានរដ្ឋសភា	ជាអនុប្រធានទី១
៣-នាយករដ្ឋមន្ត្រី	ជាអនុប្រធានទី២

[203] មាត្រា១៥ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។

[204] មាត្រា១៦រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។

[205] មាត្រា១៣ថ្មីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។

៤-សម្តេចព្រះសង្ឃរាជគណៈមហានិកាយ	ជាសមាជិក
៥- សម្តេចព្រះសង្ឃរាជគណៈធម្មយុត្តិកនិកាយ	ជាសមាជិក
៦-អនុប្រធានទី១នៃព្រឹទ្ធសភា	ជាសមាជិក
៧-អនុប្រធានទី១នៃរដ្ឋសភា	ជាសមាជិក
៨-អនុប្រធានទី២នៃព្រឹទ្ធសភា	ជាសមាជិក
៩-អនុប្រធានទី២នៃរដ្ឋសភា	ជាសមាជិក

ព្រះមហាក្សត្រ ដែលត្រូវបានជ្រើសតាំង គឺត្រូវតែស្ថិតក្នុងព្រះរាជវង្សានុវង្សខ្មែរដែលមានព្រះជន្មាយុយ៉ាងតិច៣០ព្រះវស្សា ហើយត្រូវឆ្លងកាត់ធ្វើការបោះឆ្នោតជ្រើសរើសដោយក្រុមប្រឹក្សាមួយក្នុងការបោះឆ្នោតនេះត្រូវមានសមាសសភាពសមាជិកក្រុមប្រឹក្សារាជសម្បត្តិចូលរួមបោះឆ្នោតទាំង៩រូប។ ដែលក្រុមប្រឹក្សារាជសម្បត្តិនេះ មានមុខងារតែមួយគត់ គឺធ្វើការបោះឆ្នោតជ្រើសរើសព្រះមហាក្សត្រថ្មី។

ព្រះរាជវង្សានុវង្ស ត្រូវបានរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ កំណត់អំពីសិទ្ធិអំណាចច្បាស់លាស់ក្នុងការជ្រើសរើសព្រះមហាក្សត្រថ្មីត្រូវស្ថិតនៅលើក្រុមប្រឹក្សារាជសម្បត្តិដែលក្រុមប្រឹក្សានេះមានសមាសភាពជាអ្នកនយោបាយផង និងមិនមែនជាអ្នកនយោបាយផង។

ជាទូទៅ ប្រធានក្រុមប្រឹក្សារាជសម្បត្តិ គឺជាអ្នកដឹកនាំអង្គប្រជុំក្រុមប្រឹក្សា ហើយទទួលអាញ្ញាត្តិច្បាប់ និងសេចក្តីសម្រេចនានា ដែលក្រុមប្រឹក្សារាជសម្បត្តិ បានអនុម័តរៀបចំចាត់ចែងនិងរ៉ាប់រងនូវការអនុវត្តច្បាប់ទាំងឡាយ ដែលទាក់ទងទៅនឹងការឡើងគ្រងរាជសម្បត្តិ របស់ព្រះមហាក្សត្រ។[206]

ក្នុងករណី ប្រធានក្រុមប្រឹក្សារាជសម្បត្តិអវត្តមាន ពុំមានលទ្ធភាពបំពេញការងារនេះបានដោយមានមូលហេតុច្បាស់លាស់ អនុប្រធានក្រុមប្រឹក្សាត្រូវទទួលភារកិច្ចចាត់ចែងជំនួស[207]។

ក្នុងករណី ប្រធាន និងអនុប្រធានក្រុមប្រឹក្សារាជសម្បត្តិអវត្តមានឬពុំមានលទ្ធភាពបំពេញមុខងារនេះបានដោយមានមូលហេតុច្បាស់លាស់ក្រុមប្រឹក្សាត្រូវដឹកនាំដោយៈ

-អនុប្រធានទី១ព្រឹទ្ធសភាជាប្រធាន។

-អនុប្រធានទី១រដ្ឋសភាជាអនុប្រធាន។[208]

---

[206] មាត្រា៤ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិ។

[207] មាត្រា៥ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិ។

[208] មាត្រា៦ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិ។

រដ្ឋមន្ត្រី ក្រសួងព្រះបរមរាជវាំង ត្រូវទទួលបន្ទុករៀបចំទីកន្លែងប្រជុំ និងទីកន្លែងសម្រាប់ធ្វើការ និងធ្វើកំណត់ហេតុនៃកិច្ចប្រជុំក្រុមប្រឹក្សារាជសម្បត្តិ។[209]

២-ការរៀបចំ និងការប្រព្រឹត្តទៅក្រុមប្រឹក្សារាជសម្បត្តិ

(Organization and Functioning of Council of Throne)

ប្រធានក្រុមប្រឹក្សារាជសម្បត្តិ ជាអ្នកកោះប្រជុំក្រុមប្រឹក្សា ប៉ុន្តែសមាជិក៣រូបយ៉ាងតិច ក៏អាចលើកសំណើឲ្យធ្វើការកោះប្រជុំក្រុមប្រឹក្សារាជសម្បត្តិបានផងដែរ។

កិច្ចប្រជុំរបស់ក្រុមប្រឹក្សារាជសម្បត្តិ អាចដំណើរការទៅបាន លុះត្រាតែមានសមាជិកយ៉ាងតិច៧រូបបានចូលរួមប្រជុំ នៅក្នុងការពិភាក្សានៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សារាជសម្បត្តិ ត្រូវចាត់ទុកជាការសម្ងាត់។[210]

ការអនុម័តសម្រេចរបស់ក្រុមប្រឹក្សារាជសម្បត្តិ ត្រូវតែយកតាមមតិភាគច្រើនដាច់ខាត គឺមានចំនួនប្រាំសម្លេងឡើងទៅដោយការបោះឆ្នោតជាសម្ងាត់។[211]

សមាជិកក្រុមប្រឹក្សារាជសម្បត្តិ មានចំនួនចាប់ពីបី(៣)រូបឡើងទៅ អាចធ្វើឧទ្ទេសនាមបេក្ខជនជាព្រះមហាក្សត្រថ្មីមួយអង្គបាន សមាជិកក្រុមប្រឹក្សារាជសម្បត្តិ១រូប មានសិទ្ធិឧទ្ទេសនាមបានបេក្ខជនតែមួយអង្គប៉ុណ្ណោះ។[212]

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សារាជសម្បត្តិស្តីពីការជ្រើសរើសព្រះមហាក្សត្រថ្មីត្រូវតែមានការផ្សព្វផ្សាយជាសាធារណៈដោយរដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង។[213]

មុននឹងឡើងគ្រងរាជសម្បត្តិ ព្រះមហាក្សត្រថ្មីទ្រង់ត្រូវថ្លែងសច្ចាប្រណិធាន ដូចមានចែងក្នុងឧបសម្ព័ន្ធ៤នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ហើយនៅថ្ងៃបន្ទាប់ អំពីថ្ងៃដែលក្រុមប្រឹក្សារាជសម្បត្តិបានចេញសេចក្តីសម្រេច និងប្រកាសផ្សព្វផ្សាយរួចមក។[214]

ព្រះបាទ នរោត្តម សីហមុនី ត្រូវបានក្រុមប្រឹក្សារាជសម្បត្តិធ្វើការបោះឆ្នោតជ្រើសរើស ជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០៤ ដែលមានសម្តេច ជា ស៊ីម ក្នុងឋានៈជាប្រធានក្រុមប្រឹក្សារាជសម្បត្តិ និងបានចុះហត្ថលេខាលើសេចក្តីសម្រេចស្តីពី

---

[209] មាត្រា៧ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិ។

[210] មាត្រា៨ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិ។

[211] មាត្រា៩ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិ។

[212] មាត្រា១២ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិ។

[213] មាត្រា១៣ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិ។

[214] មាត្រា១៤ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិ។

ការជ្រើសរើសព្រះមហាក្សត្រថ្មី។[215]

គ.ព្រះរាជតួនាទីព្រះមហាក្សត្រ

(Roles of King)

ប្រទេសកម្ពុជាគឺជាព្រះរាជាណាចក្រ ដែលមានព្រះមហាក្សត្រសោយរាជ្យ ហើយទ្រង់ត្រូវប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។

ព្រះមហាក្សត្រ ព្រះអង្គទ្រង់ជានិមិត្តរូបនៃឯកភាពជាតិ និងនីរន្តរភាពជាតិ ជានាបាននូវឯករាជ្យជាតិ អធិបតេយ្យ និងបូរណភាពទឹកដី ហើយជានាការគោរពសិទ្ធិមនុស្ស និងសេរីភាពរបស់ប្រជាពលរដ្ឋ និងការគោរពសន្ធិសញ្ញាអន្តរជាតិ។[216]

ចំពោះព្រះរាជតួនាទីរបស់ព្រះមហាក្សត្រមានដូចជា:

-ព្រះមហាក្សត្រជាប្រមុខរដ្ឋ

-ជាមេបញ្ជាការកំពូលនៃកងយោធពលខេមរភូមិន្ទ

-ព្រះមហាក្សត្រជាប្រមុខស្ថាប័នតុលាការ

១-ព្រះមហាក្សត្រជាប្រមុខរដ្ឋ

(King as a Head of State)

រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣បានថ្វាយព្រះមហាក្សត្រនូវព្រះរាជតួនាទីជាប្រមុខរដ្ឋ។ ព្រះមហាក្សត្រទ្រង់ជាប្រមុខរដ្ឋអស់មួយជីវិត។[217]

នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ក្រុមប្រឹក្សារាជសម្បត្តិត្រូវបានធ្វើការជ្រើសរើស ព្រះបាទ នរោត្តម សីហនុ ជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។

នៅក្នុងព្រះរាជឋានៈជាប្រមុខរដ្ឋ ព្រះមហាក្សត្រទ្រង់ត្រូវបានបំពេញព្រះរាជកិច្ច ជាអ្នកទទួលស្វាគមន៍បណ្តាព្រះមហាក្សត្រ ព្រះមហាក្សត្រីយ៍ ប្រមុខរដ្ឋ ប្រមុខនៃរដ្ឋាភិបាល និងបណ្តាគណៈប្រតិភូផ្សេងៗ ដែលបានមកបំពេញទស្សនកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ក្នុងព្រះរាជតួនាទីជាប្រមុខរដ្ឋ ព្រះបាទ នរោត្តម សីហនុ បានទទួលម្ចាស់ក្សត្រីយ៍ដាយអាណា(Diana)នៃចក្រភពអង់គ្លេស ព្រះអង្គម្ចាស់អាគីស៊ីណូ(Akishino) និងព្រះអង្គម្ចាស់ក្សត្រីយ៍ នៃព្រះរាជាណាចក្រជប៉ុន លោកប្រធានាធិបតី ហ្សាង ហ្សឺមិញ ជាប្រមុខរដ្ឋនៃសាធារណរដ្ឋប្រជាមានិតចិន និងលោកប្រធានាធិបតី ឡេឌឹក អាញ់ ជាប្រមុខរដ្ឋនៃសាធារណរដ្ឋសង្គមនិយម

---

[215] សេចក្តីសម្រេចរបស់ក្រុមប្រឹក្សារាជសម្បត្តិលេខករស/សសរ/១០០៤/០០១ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៤។

[216] មាត្រា៨រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[217] មាត្រា៧រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

វៀតណាម។

ព្រះមហាក្សត្រខ្មែរ ទ្រង់បានទទួលសារតាំងពីឯកអគ្គរាជទូត រដ្ឋទូត និងបានទទួលមន្ត្រីជាន់ខ្ពស់ផ្សេងៗទៀតជាច្រើននាក់ផងដែរ។

២-ជាមេបញ្ជាការកំពូលនៃកងយោធពលខេមរភូមិន្ទ

(As Top Commander of Royal Cambodia Armed Forces)

រដ្ឋធម្មនុញ្ញបានថ្វាយព្រះរាជតួនាទី“ព្រះមហាក្សត្រកម្ពុជា គឺជាមេបញ្ជា ការកំពូលនៃកងយោធពលខេមរភូមិន្ទ”។ ក្នុងព្រះរាជតួនាទីនេះ និងជាព្រះប្រមុខរដ្ឋ ព្រះមហាក្សត្រមានអំណាចក្នុងការតែងតាំង អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ ដើម្បីបញ្ជាលើកងយោធពលខេមរភូមិន្ទទាំងមូល។

ព្រះបាទ នរោត្តម សីហនុ ព្រះអង្គទ្រង់ ក៏ជាមេបញ្ជាការកំពូលមួយអង្គនៃកងយោធពលខេមរភូមិន្ទ ប៉ុន្តែព្រះអង្គ គឺគ្រាន់តែជាមេបញ្ជាការជានិមិត្តរូប និងមានលក្ខណៈតែក្នុងពិធីការតែប៉ុណ្ណោះ។ នៅក្នុងរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ ក៏ត្រូវបានបង្កើតតំណែងអគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទផងដែរ។[218]

ទោះបីជាយ៉ាងណាក៏ដោយ ក៏តំណែងនាយអគ្គសេនាធិការ នាយអគ្គសេ នាធិការរង និងឧត្តមសេនីយ៍ឡើងទៅត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ។

ដូចនេះ មុខងារអគ្គមេបញ្ជាការ និងអគ្គមេបញ្ជាការរង ដែលមានឋានៈខ្ពស់ជាងនាយអគ្គសេនាធិការ និងនាយអគ្គសេនាធិការរង ក៏ត្រូវបានតែងតាំងផ្លាស់ប្តូរ និងបញ្ចប់ការកិច្ច ដោយព្រះរាជក្រឹត្យដែរ។

ក្នុងព្រះរាជតួនាទីជាព្រះប្រមុខរដ្ឋ និងជាមេបញ្ជាការកំពូល ព្រះមហាក្សត្រទ្រង់ក៏មានសិទ្ធិតែងតាំង អគ្គមេបញ្ជាការ អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទបាន ក៏ប៉ុន្តែត្រូវធ្វើឡើងតាមរយៈសំណើរបស់នាយករដ្ឋមន្ត្រី។

ម្យ៉ាងទៀត រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ គឺបានពិពណ៌នាអំពីរបបនយោបាយ និងរចនាសម្ព័ន្ធគ្រប់គ្រងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាជាព្រះរាជាណាចក្រមួយដែលប្រកាន់យករបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ និងតាមលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។

ក្នុងឋានៈជារដ្ឋអធិបតេយ្យ កងកម្លាំងយោធាជាចំខាតគឺត្រូវតែស្ថិតនៅជាកងកម្លាំងអព្យាក្រឹត្យដោយមិនប្រកាន់និន្នាការគណៈបក្សនយោបាយណាមួយឡើយ។

---

[218] មាត្រា២៣រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

ភារកិច្ចជាចំបងនៃកងកម្លាំងយោធា គឺដើម្បីការការពារអធិបតេយ្យរដ្ឋក្នុងការទប់ទល់នឹងការវាយប្រហារពីកម្លាំងទ័ពនៃបណ្តារដ្ឋដទៃទៀត ការធ្វើវិទ្ធង្សានានិងការបំបែកបំបាក់ផ្ទៃក្នុង។

កិច្ចការការពារសន្តិសុខរដ្ឋ គឺជាភារកិច្ចដ៏សំខាន់នៃរដ្ឋអធិបតេយ្យនីមួយៗហើយការផ្តល់កិច្ចការពារសន្តិសុខរដ្ឋ គឺជាភារកិច្ចដ៏ធំធេង និងភាពចាំបាច់របស់រាជរដ្ឋាភិបាល ដែលអាចប្រើប្រាស់បាននូវកងកម្លាំងគ្រប់ប្រភេទសម្រាប់គ្រប់កិច្ចការការពារសន្តិសុខរបស់ប្រទេសជាតិ។

ព្រះមហាក្សត្រ ក្នុងឋានៈជាព្រះប្រមុខរដ្ឋ ព្រះអង្គទ្រង់គង់នៅជាអព្យាក្រឹត្យ និងមិនកាន់គណបក្សនយោបាយណាមួយឡើយ។ “ព្រះមហាក្សត្រ ព្រះអង្គទ្រង់ជានិមិត្តរូបនៃឯកភាពជាតិ និងនិរន្តរភាពជាតិ ”។

ព្រះអង្គទ្រង់ជាអ្នកធានានូវឯករាជ្យជាតិ អធិបតេយ្យ និងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ហើយទ្រង់ក៏ជាអ្នកធានាការគោរពសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋ និងការគោរពសន្ធិសញ្ញាអន្តរជាតិ។

នៅក្នុងនោះ មហាក្សត្រ ក៏បានចេញព្រះរាជក្រឹត្យចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ១៩៩៣ ដែលត្រូវបានតែងតាំងព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ជានាយករដ្ឋមន្ត្រីទី១ និងសម្តេច ហ៊ុន សែនជានាយករដ្ឋមន្ត្រីទី២នៃរាជរដ្ឋាភិបាលកម្ពុជា អណត្តិទី១នៃរដ្ឋសភា និងជាសហអគ្គមេបញ្ជាការនៃកម្លាំងប្រដាប់អាវុធជាតិកម្ពុជា បន្ទាប់ពីព្រះអង្គ និងសម្តេច បានទទួលអំណាចពិសេសអំពីញ្ញាត្តិសម្រេចចិត្តមួយរបស់សភាធម្មនុញ្ញនៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៩៣។

សហអគ្គមេបញ្ជាការទាំងពីរ ត្រូវតែមានសិទ្ធិអំណាចស្មើៗគ្នា ការតែងតាំងនេះ មិនត្រូវបានជ្រើសរើសក្នុងក្របខ័ណ្ឌនៃរដ្ឋធម្មនុញ្ញទេ ពីព្រោះថា ២ខែ២២ថ្ងៃក្រោយការតែងតាំង គឺនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ទើបបានរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានប្រកាសឲ្យប្រើ។ នៅថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៩ ទើបមានព្រះរាជក្រឹត្យមួយ ត្រូវបានតែងតាំងអគ្គមេបញ្ជាការ និងមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទដោយយោងទៅលើក្របខណ្ឌរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣។

ព្រះរាជក្រឹត្យឆ្នាំ១៩៩៩ បានតែងតាំង:

- ឧត្តមសេនីយ៍ឯក កែ គឹមយ៉ាន គឺជាអគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទនៃព្រះរាជាណាចក្រកម្ពុជា។

- ឧត្តមសេនីយ៍ឯក ផ្កាយមាស៤ គន់ គីម គឺជាអគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទនៃព្រះរាជាណាចក្រកម្ពុជា។

- ឧត្តមសេនីយ៍ឯក ប៉ុល សារឿន គឺជាអគ្គមេបញ្ជាការរង

- ឧត្តមសេនីយ៍ឯក ខាន់ សារឿន អគ្គមេបញ្ជាការរង
- ឧត្តមសេនីយ៍ឯក មាស សុភា អគ្គមេបញ្ជាការរង

ការតែងតាំងនេះ គឺធ្វើឡើងតាមសំណើរបស់នាយករដ្ឋមន្ត្រី ដែលចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៩។ នាយករដ្ឋមន្ត្រី បានធ្វើការស្នើសុំការតែងតាំង អគ្គមេបញ្ជាការ និងអគ្គមេបញ្ជាការរងនៃកងកម្លាំងយោធពលខេមរភូមិន្ទ ដែលចេញព្រះរាជក្រឹត្យតែងតាំង ដោយព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។

គោលបំណងនៃរដ្ឋធម្មនុញ្ញ ក្នុងការថ្វាយព្រះរាជតួនាទីជាព្រះប្រមុខរដ្ឋ នូវព្រះរាជសិទ្ធិតែងតាំងអគ្គមេបញ្ជាការ និងអគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ ត្រូវធ្វើឡើងតាមរយៈសំណើរបស់នាយករដ្ឋមន្ត្រី គឺស្របតាមអំណាចដូចដែលមានចែងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣[219] ដើម្បីដាក់កងយោធពលខេមរភូមិន្ទឲ្យស្ថិតនៅក្នុងភាពអព្យាក្រឹត្យបរិបូរណ៍ពិតប្រាកដ មិនចំពោះនយោបាយណាមួយ ឬគណបក្សនយោបាយណាមួយឡើយ ដែលជាអ្នកការពារមិនឲ្យមានអំណាចផ្តាច់ការណាមួយ ឬពីសំណាក់អ្នកនយោបាយ និងធ្វើឲ្យកងយោធពលខេមរភូមិន្ទ គឺជាកងយោធពលខេមរភូមិន្ទរបស់រដ្ឋ ដើម្បីការពារទឹកដីការពារប្រជាពលរដ្ឋ និងប្រទេសជាតិខ្លួន។

៣-ព្រះមហាក្សត្រជាប្រមុខស្ថាប័នតុលាការ

(King as a Head of Court)

រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បានថ្វាយព្រះមហាក្សត្រកម្ពុជា នូវព្រះរាជឋានៈជាប្រមុខនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមគឺត្រូវស្ថិតនៅក្រោមអធិបតីភាពរបស់ព្រះមហាក្សត្រ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គឺជាស្ថាប័នដ៏កំពូលនៃអង្គតុលាការ ដែលមានព្រះមហាក្សត្រទ្រង់ជាព្រះប្រធានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។[220]

ព្រះអង្គទ្រង់អាចចាត់តាំងព្រះរាជតំណាងណាម្នាក់ឲ្យមកធ្វើជាអធិបតីនៃអង្គប្រជុំរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងមានរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជាសមាជិក។[221]

ព្រះមហាក្សត្រ មានភារកិច្ចធានាឯករាជ្យភាពនៃតុលាការ ដាច់ចេញពីអំណាចពីរផ្សេងទៀតគឺអំណាចនីតិប្រតិបត្តិ និងអំណាចនីតិប្បញ្ញត្តិ។

ចៅក្រមមិនត្រូវទទួលការគាបសង្កត់ ឬការគម្រាមកំហែងពីសំណាក់ អំណាចណាមួយឡើយ។ សមាជិកទាំងអស់នៃឧត្តមក្រុមប្រឹក្សានេះ ក៏ត្រូវបានតែងតាំង ដោយព្រះមហាក្សត្រ។

---

[219] មាត្រា២៣រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[220] ច្បាប់នេះគឺច្បាប់ចាស់ដែលបានចែងមុនឆ្នាំ២០១៨។

[221] មាត្រា៣ស្តីពីច្បាប់រៀបចំ និងការប្រព្រឹត្តទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលត្រូវបានបង្កើតឡើងដើម្បីជួយដល់ព្រះមហាក្សត្រ ក្នុងការធានាការពារឯករាជ្យភាពនៃអំណាចតុលាការ និងធានាឲ្យបាននូវរិដ្ឋាជីវៈរបស់ចៅក្រម ធានាការប្រព្រឹត្តទៅរបស់សាលាដំរះក្តីនៃព្រះរាជាណាចក្រកម្ពុជា ឲ្យមានដំណើរការល្អ មានឯករាជ្យភាព និងភាពយុត្តិធម៌ឲ្យកាន់តែប្រសើរឡើង។

ដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គឺជាស្ថាប័នជាន់ខ្ពស់បំផុតនៃតុលាការ ហើយព្រះមហាក្សត្រ ទ្រង់ជាប្រមុខនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ព្រះមហាក្សត្រ ក៏ត្រូវជាប្រមុខនៃអង្គការតុលាការនៃព្រះរាជាណាចក្រកម្ពុជាផងដែរ។

ដូចនេះ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ព្រះអង្គ ទ្រង់មិនគ្រាន់តែជាប្រមុខរដ្ឋ និងជាមេបញ្ជាការកំពូលរបស់កងទ័ពជាតិនៃព្រះរាជាណាចក្រកម្ពុជាប៉ុណ្ណោះទេ ព្រះអង្គទ្រង់ថែមទាំងជាប្រមុខនៃស្ថាប័នតុលាការទៀតផង។

ប៉ុន្តែព្រះអង្គ ទ្រង់ពុំមានសិទ្ធិអំណាច ឬឥទ្ធិពលណាមួយមកលើតុលាការឡើយ ដោយហេតុថា “ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គឺជាអ្នកសម្រេច និងលើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រអំពីការតែងតាំងការផ្លាស់ប្តូរមុខងារ និងការដាក់ឲ្យនៅទំនេរនៃក្របខ័ណ្ឌការដកហូតការងារចៅក្រម និងព្រះរាជអាជ្ញាទាំងអស់គឺជាសិទ្ធិរបស់ក្រុមប្រឹក្សា”។[222]

ឧត្តមក្រុមប្រឹក្សានេះ អាចផ្តល់ជាយោបល់ ចំពោះការដំឡើងថ្នាក់ និងការដំឡើងឋានន្តរស័ក្តិឲ្យចៅក្រម និងព្រះរាជអាជ្ញាទាំងអស់។

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជាអ្នកលើកសំណើធ្វើសេចក្តីព្រាង ព្រះរាជក្រឹត្យ ថ្វាយព្រះមហាក្សត្រចំពោះការតែងតាំង ការផ្លាស់ប្តូរ និងការដកហូតមុខងារ។

ស្ថិតក្នុងមុខងារ ក្នុងការដាក់ទោសវិន័យចំពោះចៅក្រម និងព្រះរាជអាជ្ញានានា ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវកោះប្រជុំក្រោមរូបភាពជាក្រុមប្រឹក្សាវិន័យ ក្រោមអធិបតីភាពនៃប្រធានតុលាការកំពូល ឬអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល។ ព្រះមហាក្សត្រ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌មិនចូលរួមក្នុងការប្រជុំដាក់ទោសវិន័យនេះឡើយ។[223]

យោងតាមច្បាប់ស្តីអំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ព្រះមហាក្សត្រ ដែលទ្រង់ជាប្រធាន ដូចនេះ ការដាក់វិន័យចំពោះ ប្រធានតុលាការកំពូល ឬអគ្គព្រះរាជអាជ្ញា អមតុលាការកំពូល ក្រុមប្រឹក្សាវិន័យត្រូវស្ថិតនៅក្រោមព្រះរាជធិបតីភាពព្រះមហា

[222] មាត្រា១១ស្តីពីច្បាប់រៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

[223] មាត្រា១២ស្តីពីច្បាប់រៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

ក្សត្រ ឬព្រះរាជតំណាងជានិច្ច។

ឃ-អំណាចព្រះមហាក្សត្រ

(Power of King)

រដ្ឋធម្មនុញ្ញ១៩៩៣ ក៏បានថ្វាយព្រះមហាក្សត្រ នូវអំណាចមួយចំនួន ដែលភាគច្រើននៃអំណាចទាំងនេះព្រះអង្គអាចប្រើប្រាស់បានតាមរយៈអង្គការរដ្ឋ ឬស្ថាប័នរដ្ឋ ដែលកាន់អំណាចមានរដ្ឋសភា ឬព្រឹទ្ធសភា(អង្គការនីតិប្បញ្ញត្តិ) រាជរដ្ឋាភិបាល(អង្គការនីតិប្រតិបត្តិ)ឬឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម(ស្ថាប័នកំពូលនៃអង្គតុលាការ) ត្រូវតែមានការអនុម័តយល់ព្រមជាមុនសិន ឬក៏ជាការផ្តល់ជាអនុសាសន៍ថ្វាយព្រះមហាក្សត្រពីព្រះរាជសកម្មភាពផ្សេងៗដែលត្រូវបំពេញ។

រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣បានកំណត់នូវសិទ្ធិ និងអំណាចថ្វាយព្រះមហាក្សត្រក្នុងការបំពេញព្រះរាជសកម្មភាពរួមគ្នា និងតាមរយៈការស្នើសុំពីអង្គការស្ថាប័នរដ្ឋដទៃៗទៀតផងដែរ អំណាចព្រះមហាក្សត្រតាមរយៈរដ្ឋធម្មញ្ញប្រទានរួមមាន:

-អំណាចតែងតាំង និងការដកហូត

-អំណាចប្រកាសឲ្យប្រើច្បាប់

-អំណាចប្រកាសសង្គ្រាម និងភាពអាសន្ន

-អំណាចលើកលែងទោស។

១-អំណាចតែងតាំង និងការដកហូត

(Power of Nomination and Revocation)

ក្នុងព្រះរាជឋានៈជាព្រះប្រមុខរដ្ឋនៃព្រះរាជាណាចក្រកម្ពុជារដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ថ្វាយព្រះមហាក្សត្រនូវអំណាចតែងតាំង និងអំណាចដកហូតមន្ត្រីជាន់ខ្ពស់នៃអង្គការរដ្ឋបានតាមរយៈអំណាចនេះព្រះមហាក្សត្រអាចប្រើប្រាស់បានដូចជា:

ព្រះមហាក្សត្រ មានសិទ្ធិអំណាចក្នុងការដំឡើងឋានៈ សម្រាប់ឲ្យមន្ត្រីជាន់ខ្ពស់រាជការស៊ីវិល ឧត្តមសេនីយផ្នែកយោធា ឧត្តមសេនីយអាវុធហត្ថ និងឧត្តមសេនីយផ្នែកនគរបាល ព្រមទាំងការដាក់ទណ្ឌកម្មដល់មន្ត្រីជាន់ខ្ពស់នៃអង្គការរដ្ឋណាមួយ ឬស្ថាប័នរបស់រដ្ឋណាមួយបាន ហើយដែលជាប្រភពនៃអំណាចដ៏សំខាន់របស់ប្រមុខរដ្ឋផងដែរ។

អំណាចទាំងពីរបញ្ចូលគ្នាគឺបានជាមូលដ្ឋានគ្រឹះនៃអំណាចរបស់ព្រះមហាក្សត្រ និងការបណ្តុះឆន្ទៈរបស់សមាជិកនៃអង្គការស្ថាប័នរដ្ឋ ព្រមទាំងសមាជិករបស់រដ្ឋទាំងឡាយ ដើម្បីឲ្យពួកគេមានស្វាមីភក្តិចំពោះប្រមុខរដ្ឋ និងរដ្ឋ ហើយខិតខំកសាងគុណសម្បត្តិចំពោះព្រះប្រមុខរដ្ឋ និងចំពោះប្រទេសជាតិផងដែរ។

១.១-ការតែងតាំង

(Nomination)

ព្រះមហាក្សត្រទ្រង់តែងតាំងនាយករដ្ឋមន្ត្រី និងទ្រង់តែងតាំងគណៈរដ្ឋមន្ត្រី តាមបែបបទដែលមានចែងក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ។

ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ គណៈរដ្ឋមន្ត្រី ក៏បានបញ្ជាក់ថា "សមាជិករាជរដ្ឋាភិបាលទាំងអស់ ត្រូវតែតែងតាំងដោយព្រះរាជក្រឹត្យ ក្រោយពីបានសម្រេចសេចក្តីអនុម័តទុកចិត្តពីរដ្ឋសភា"។ ច្បាប់នេះបន្ថែមទៀតថា "អនុរដ្ឋលេខាធិការដែលមិនមែនជាសមាជិករាជរដ្ឋាភិបាល និងមិនមែនជាមន្ត្រីជាន់ខ្ពស់រដ្ឋបាលអចិន្ត្រៃយ៍ត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យផងដែរ ដែលធ្វើឡើងតាមសំណើរបស់នាយករដ្ឋមន្ត្រី" ។

ព្រះមហាក្សត្រមានព្រះរាជសិទ្ធិតែងតាំងសមាសភាពសមាជិកព្រឹទ្ធសភាចំនួនពីរបួនដែលត្រូវបានតែងតាំងតាមការសព្វព្រះទ័យរបស់ព្រះមហាក្សត្រ។[224]

ព្រះមហាក្សត្រមានព្រះរាជសិទ្ធិក្នុងការតែងតាំង សមាសភាពរបស់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញចំនួនបីរូប។[225]

ក្រៅពីនេះ ព្រះមហាក្សត្រមានព្រះរាជសិទ្ធិ ក្នុងការតែងតាំងមន្ត្រីនៅក្នុងក្រសួងព្រះបរមរាជវាំង ដែលមានឧត្តមក្រុមប្រឹក្សាផ្ទាល់របស់ព្រះមហាក្សត្រ មានមន្ត្រីនៅក្នុងព្រះរាជខុទ្ទកាល័យ ក្រុមប្រឹក្សាយោធាព្រះមហាក្សត្រ និងក្រុមសម្តេចឪជាដើម។

ជាមួយនឹងអំណាចតែងតាំងរបស់ព្រះមហាក្សត្រទ្រង់ក៏មានអំណាចដកហូតមុខតំណែងសមាជិករាជរដ្ឋាភិបាលណាម្នាក់ ឬរាជរដ្ឋាភិបាលទាំងមូលក៏បាន ក្រោយពីពេលដែលរដ្ឋសភាបានបោះឆ្នោតអនុម័តសំដែងសេចក្តីមិនទុកចិត្តហើយនោះ។

១.២-តែងតាំងដកហូតមន្ត្រីរាជការជាន់ខ្ពស់ស៊ីវិល និងយោធា

(Nominating Revoking High Civil Officials and Soldiers)

ក្រៅពីអំណាចតែងតាំង និងដកហូតតំណែងសមាជិករាជរដ្ឋាភិបាល ព្រះមហាក្សត្រ ទ្រង់នៅមានអំណាចតែងតាំងដកហូតមួយទៀតដែលសំខាន់ សម្រាប់ព្រះរាជបេសកកម្មរបស់ព្រះអង្គក្នុងព្រះរាជឋានៈជាព្រះប្រមុខរដ្ឋ ។

រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បានថ្វាយព្រះអង្គនូវអំណាច ក្នុងការតែងតាំង និងដកហូតមន្ត្រី

[224] មាត្រា១០០ថ្មីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[225] មាត្រា១៣៧ថ្មីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

រាជការជាន់ខ្ពស់ស៊ីវិល និងយោធា ។

តាមសេចក្តីស្នើពីគណៈរដ្ឋមន្ត្រីព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យ តែងតាំង ផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ច មន្ត្រីជាន់ខ្ពស់ស៊ីវិល និងយោធា ឯកអគ្គរាជទូត និងប្រេសិតវិសាមញ្ញ និងពេញសមត្ថភាព។

តាមសេចក្តីស្នើសុំ របស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ព្រះមហាក្សត្រ ទ្រង់ឡាយព្រះហស្តលេខា លើព្រះរាជក្រឹត្យតែងតាំង ផ្លាស់ប្តូរ ឬដកហូតមុខងារ ចៅក្រម ឬព្រះរាជអាជ្ញាក្នុងផ្នែកយុត្តាធិការបាន។ ច្បាប់ស្តីអំពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីក៏បានបញ្ជាក់អំពីប្រភេទមន្ត្រីរាជការជាន់ខ្ពស់ទាំងមន្ត្រី រាជការស៊ីវិល និងយោធាដែលត្រូវបានតែងតាំងដោយព្រះមហាក្សត្រ ។

នាយករដ្ឋមន្ត្រីលើកសំណើ ថ្វាយព្រះមហាក្សត្រ ដើម្បីធ្វើការតែងតាំង ផ្លាស់ប្តូរ បញ្ចប់ការកិច្ចនូវមន្ត្រីជាន់ខ្ពស់ស៊ីវិល និងយោធាដោយព្រះរាជក្រឹត្យដូចតទៅ:

-ទេសាភិបាល ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា

-ទីប្រឹក្សារាជរដ្ឋាភិបាល ទីប្រឹក្សានាយករដ្ឋមន្ត្រី

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-អគ្គលេខាធិការក្រសួង អគ្គនាយកក្រសួង

-ប្រតិភូរាជរដ្ឋាភិបាល

-អភិបាលខេត្ត-រាជធានី

-ឯកអគ្គរាជទូត

-ប្រេសិតវិសាមញ្ញ និងពេញសមត្ថភាព

-នាយអគ្គសេនាធិការ និងនាយអគ្គសេនាធិការង

-ឧត្តមសេនីយ៍ឡើងទៅ

មុខងារក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ស៊ីវិល និងយោធាមួយចំនួនផ្សេងទៀត ត្រូវបានតែងតាំង ផ្លាស់ប្តូរ បញ្ចប់ការកិច្ចដោយព្រះរាជក្រឹត្យដែលស្របតាមការកំណត់ក្នុងលិខិតបទដ្ឋានដោយឡែកដែលបានបង្កើតដោយស្ថាប័ននោះ។[226] តាមការកំណត់ លិខិតបទដ្ឋានគតិយុត្តិដោយឡែក ដែលបង្កើតដោយស្ថាប័ននោះ។

ហេតុនេះ មាត្រា១៤ នៃច្បាប់ស្តីអំពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ក៏បាន

[226] មាត្រា១៤ច្បាប់ស្តីពីច្បាប់រៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី។

បញ្ជាក់បន្ថែមលើរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ដោយយោងតាមសេចក្តីស្នើរបស់គណៈរដ្ឋមន្ត្រីព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខា លើព្រះរាជក្រឹត្យតែងតាំង ផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ច ចំពោះមន្ត្រីរាជការជាន់ខ្ពស់ស៊ីវិល យោធា ឯកអគ្គ រាជទូត និងប្រេសិតវិសាមញ្ញ និងពេញសមត្ថភាព។[227]

១.៣-ប្រទានគ្រឿងឥស្សរិយយស

(Giving Decoration)

រដ្ឋមធ្មនុញ្ញឆ្នាំ១៩៩៣បានថ្វាយព្រះមហាក្សត្រនូវអំណាចក្នុងការប្រទានគ្រឿងឥស្សរយសថ្នាក់ជាតិ និងឋានន្តរស័ក្តិ ឋានៈដល់វីរជន ឥស្សរជន និងមន្ត្រីជាន់ខ្ពស់ស៊ីវិល និងយោធានៅក្នុងព្រះរាជតួនាទីជាព្រះប្រមុខរដ្ឋ។

តាមរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣បានចែងទៀតថា“ព្រះមហាក្សត្រទ្រង់ជាអ្នកបង្កើតនិងប្រទានគ្រឿងឥស្សរិយយសជាតិតាមសេចក្តីស្នើសុំពីគណៈរដ្ឋមន្ត្រី។

ព្រះមហាក្សត្រ ទ្រង់សម្រេចប្រទានឋានន្តរស័ក្តិ និងឋានៈ យោធានានា និងមន្ត្រីរាជការស៊ីវិលទៅតាមច្បាប់កំណត់។[228]

តាមរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣មានតែប្រមុខរដ្ឋទេដែលមានសិទ្ធិអំណាចក្នុងការប្រទានឋានៈបុណ្យស័ក្តិដល់អ្នកដែលមានគុណបំណាច់ និងគុណសម្បត្តិចំពោះរដ្ឋ និងជាតិ ដែលមានគោរម្យងារ“សម្តេច ឧកញ៉ា និងអ្នកឧកញ៉ា” ជាឋានៈមួយដែលមានតែព្រះមហាក្សត្រទេ ទើបមានសិទ្ធិអំណាចផ្តល់ឲ្យទៅតាមប្រពៃណីរបស់ខ្មែរ និងតាមស្មារតីនៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ “សម្តេច” ជាងារខ្ពស់ជាងគេបំផុតក្នុងឋានានុក្រមស័ក្តិក្នុងថ្នាក់មន្ត្រីរាជការជាន់ខ្ពស់ឥស្សរជននយោបាយ និងមន្ត្រីសង្ឃជាន់ខ្ពស់។

ព្រះមហាក្សត្រអាចចេញព្រះរាជក្រឹត្យតែងតាំងប្រទានឲ្យទៅតាមគុណសម្បត្តិ និងគុណបំណាច់ដ៏ធំធេងដែលមន្ត្រីរាជការជាន់ខ្ពស់ ឥស្សរជននយោបាយ និងមន្ត្រីសង្ឃទាំងនោះមានចំពោះរដ្ឋ ចំពោះព្រះពុទ្ធសាសនា ចំពោះរាជបល្ល័ង្ក និងចំពោះជាតិ ក្នុងព្រះរាជឋានៈព្រះអង្គជាព្រះប្រមុខរដ្ឋ។

ព្រះមហាក្សត្រ ទ្រង់បានតែងតាំងមន្ត្រីជាន់ខ្ពស់សម្រាប់គោរម្យងារជា “សម្តេច” ចំពោះឥស្សរជននយោបាយកំពូលៗ ដែលជាអ្នកមានគុណបំណាច់ចំពោះជាតិមាតុភូមិ និងឥស្សរជនជាន់ខ្ពស់នានាដែលអ្នកនយោបាយទាំងនោះរួមមាន:

---

[227] មាត្រា២១រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[228] មាត្រា២៩រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

-ឯកឧត្តម ជា ស៊ីមត្រូវបានតែងតាំងគោរម្យងារជា"សម្តេច ជា ស៊ីម"នៃព្រះរាជាណាចក្រកម្ពុជា ដោយព្រះរាជក្រឹត្យចុះថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៩៣។

ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ បានចេញព្រះរាជក្រឹត្យជារួមមួយ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ១៩៩៤ ដែលបានតែងតាំងឥស្សរជនមួយចំនួនដូចជា:

-ឯកឧត្តម ហ៊ុន សែន ត្រូវបានតែងតាំងជា "សម្តេច ហ៊ុន សែន"

-ឯកឧត្តម ហេង សំរិន ត្រូវបានតែងតាំងជា "សម្តេច ហេង សំរិន"

-ឯកឧត្តម ចៅសែន កុសល ឈុំ ត្រូវបានតែងតាំងជា "សម្តេច ចៅសែន កុសល ឈុំ"

-ឯកឧត្តម ញឹក ជូឡុង ត្រូវបានតែងតាំងជា "សម្តេច ញឹក ជូឡុង"

-ឯកឧត្តម សឺន សាន ត្រូវបានតែងតាំងជា "សម្តេច សឺន សាន"

-ឯកឧត្តម ងោ ហ៊ូ ត្រូវបានតែងតាំងជា "សម្តេច ងោ ហ៊ូ"

-ព្រះសង្ឃរាជ ទេព វង្សបានតែងតាំងជាសម្តេចសង្ឃគណៈមហានិកាយ

-ព្រះសង្ឃរាជ ប៊ូ គ្រី ត្រូវបានតែងតាំងជាសម្តេចសង្ឃ គណៈធម្មយុត្តិនិកាយ ។

ក្រៅពីនេះ នៅមានការដំឡើងឋានៈនៃសមាជិក នៅក្នុងព្រះរាជវង្សានុវង្សផងដែរ ដែលជាមូលដ្ឋាននៃព្រះរាជបុព្វសិទ្ធិតាមប្រពៃណី និងស្មារតីនៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ដោយឈរលើមូលដ្ឋាននេះ ព្រះមហាក្សត្រ ទ្រង់បានចេញព្រះរាជក្រឹត្យតែងតាំង:

-សម្តេចក្រុមហ្លួង នរោត្តម រណឫទ្ធិ ត្រូវបានតែងតាំង ទៅជា "សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ នៃព្រះរាជាណាចក្រកម្ពុជា" ដោយព្រះរាជក្រឹត្យមួយគ្មានលេខ និងគ្មានកាលបរិច្ឆេទ។

-ព្រះអង្គម្ចាស់ នរោត្តម សីរីវុឌ្ឍន៍ ត្រូវបានដំឡើងទៅជា "ស្តេចក្រុមឃុន"។

-ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ជីវន្តមុនីវ័ក្សត្រូវដំឡើងជា"ស្តេចក្រុមឃុន" ដែលត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យលេខនស/រកត/០៩០០/១៦៥ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០២។

"ងារ ឬឋានៈ" ដែលព្រះមហាក្សត្របានប្រទានទាំងអស់នោះ ពុំមានអំណាច ឬឥទ្ធិពលអ្វីមកលើការងាររដ្ឋបាល ឬនយោបាយនៃព្រះរាជាណាចក្រកម្ពុជាទេ ប៉ុន្តែ ជាងារ ឬជាឋានៈសម្រាប់ប្រើប្រាស់ជាកិត្តិយសក្នុងពិធីការព្រះបរមរាជវាំង ឬក្នុងពិធីការផ្សេងៗទៀត ឬក្នុងនាមជាវីរជនដ៏ឆ្នើមរបស់ជាតិតែប៉ុណ្ណោះ។

ងារ"ឧកញ៉ា"គឺជាងារសម្រាប់ផ្តល់ឋានៈឲ្យដល់បណ្តាពាណិជ្ជករ ឬមន្ត្រីរាជការជាន់ខ្ពស់ ឬឥស្សរជននយោបាយជាដើម។

ព្រះមហាក្សត្រចេញព្រះរាជក្រឹត្យតែងតាំងងារជា"ឧកញ៉ា" ដល់មន្ត្រីជាន់ខ្ពស់ ឬឥស្សរជននយោបាយដែលមានគុណបំណាច់ក្នុងការជួយជាតិ ។

ខាងក្រោមនេះ ជាឧទាហរណ៍ខ្លះៗនៃឥស្សរជននយោបាយនានា ដែលបានទទួលការតែងតាំងឲ្យមានងារជា "ឧកញ៉ា" ដោយព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា:

-ឯកឧត្តម គង់ សំអុល ត្រូវបានដំឡើងឋានៈជា "អ្នកឧកញ៉ាចៅហ្វាវាំង" ដែលមានឋានៈស្មើឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង។

-ឯកឧត្តម ញឹម វណ្ណដា ត្រូវបានតែងតាំងជា "អ្នកឧកញ៉ា"

អ្នកឧកញ៉ាអាចឡើងឋានៈដល់ថ្នាក់ងារជា "សម្តេច" ដែលជាងារខ្ពស់ ជាងងារឧកញ៉ា។ ទោះយ៉ាងណាក៏ដោយ ក៏នៅមានពាណិជ្ជករជាច្រើនអ្នកទៀត ដែលត្រូវបានតែងតាំងឲ្យមានងារជា"ឧកញ៉ា ឬអ្នកឧកញ៉ា"យ៉ាងច្រើន ដែលភាគច្រើនជាអ្នកជំនួញធំៗ។ អ្នកឧកញ៉ាទាំងនោះជាទូទៅត្រូវបានផ្តល់វិភាគទានកសាងជាតិ ឬជួយជាតិ ឬអ្នកមានគុណបំណាច់ចំពោះជាតិ ដែលមានទឹកប្រាក់កំណត់សព្វថ្ងៃរហូតដល់"១០"ម៉ឺនដុល្លាអាមេរិក ឬច្រើនជាងនេះសម្រាប់ជាថ្នូរនឹងងារជា"ឧកញ៉ា"។

ងារជា "ឧត្តមសេនីយ៍ផ្កាយមាស៤" ត្រូវបានតែងតាំងដូចជា:

-ឯកឧត្តម ឧត្តមសេនីយ៍ឯក កែ គឹមយ៉ាន

-ឯកឧត្តម ឧត្តមសេនីយ៍ឯក គន់ គីម

-ឯកឧត្តម ឧត្តមសេនីយ៍ឯក ហុក ឡង់ឌី

ក្រៅពីនេះ នៅមានងារជា "ឯកឧត្តម" ត្រូវបានប្រទានឲ្យទៅសមាជិករាជរដ្ឋាភិបាលមន្ត្រីជាន់ខ្ពស់ស៊ីវិល និងមន្ត្រីយោធាយ៉ាងច្រើនសន្ធឹកសន្ធាប់ទៀត នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដែលក្នុងនោះរួមមាន:

-នាយករដ្ឋមន្ត្រី

-ឧបនាយករដ្ឋមន្ត្រី

-ទេសរដ្ឋមន្ត្រី

-រដ្ឋមន្ត្រី

-រដ្ឋលេខាធិការ

-អនុរដ្ឋលេខាធិការ

-ឯកអគ្គរាជទូត

-អគ្គនាយក

-ប្រតិភូរាជរដ្ឋាភិបាល

-អភិបាលខេត្ត អភិបាលរាជធានី

-អគ្គលេខាធិការ អគ្គលេខាធិការរងព្រឹទ្ធសភា
-អគ្គលេខាធិការ អគ្គលេខាធិការរងរដ្ឋសភា
-សមាជិករដ្ឋសភា សមាជិកព្រឹទ្ធសភា
-ប្រធាន និងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ
-សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
-ទីប្រឹក្សាក្រុមប្រឹក្សាធម្មនុញ្ញ
-ទីប្រឹក្សារាជរដ្ឋាភិបាល
-ទីប្រឹក្សានាយករដ្ឋមន្ត្រី ។ល។

"មេដាយព្រះរាជាណាចក្រកម្ពុជា" ត្រូវបានព្រះមហាក្សត្រទ្រង់សព្វព្រះរាជហរទ័យព្រះរាជប្រទានដល់ឥស្សរជនជាន់ខ្ពស់នានានៃប្រទេសកម្ពុជា។

ព្រះមហាក្សត្រ នរោត្តម សីហនុ ទ្រង់បានប្រោសប្រទាននូវ "មេដាយ ព្រះរាជាណាចក្រកម្ពុជា"ជូនឥស្សរជនជាន់ខ្ពស់ចំនួន៤៤រូប នៅថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៨ តាមលំដាប់ថ្នាក់ដូចខាងក្រោម:

-"មហាសិរីវឌ្ឍន៍ នៃព្រះរាជាណាចក្រកម្ពុជា" ជូនទៅសម្តេច ហ៊ុន សែន
-"មហាសេនានៃព្រះរាជាណាចក្រកម្ពុជា" ត្រូវបានជូនឯកឧត្តម អ៊ឹង ហួត
-ឯកឧត្តម ស ខេង និងឯកឧត្តម អ៊ឹង គៀត
-"ធិបឌីនៃព្រះរាជាណាចក្រកម្ពុជា" ជូនទៅឯកឧត្តម គាត ឈន់ ឯកឧត្តម អ៊ុង ផន ឯកឧត្តម វណ្ណ ម៉ូលីវណ្ណ និងឯកឧត្តម ចែម សួន។

-"សេនា នៃព្រះរាជាណាចក្រកម្ពុជា" ជូនទៅឯកឧត្តម សុខ អាន ឯកឧត្តម ណា ឌីតាន់ ឯកឧត្តម ទៀ បាញ់ ឯកឧត្តម ទា ចំរ៉ាត់ ឯកឧត្តម អៀ ដូគឹមម៉េង ឯកឧត្តម យូ ហុកគ្រី ឯកឧត្តម អៀង ម៉ូលី ឯកឧត្តម តាវ សេងហួរ ឯកឧត្តម ចម ប្រសិទ្ធ ឯកឧត្តម ពូ សុធីរៈ ឯកឧត្តម ជា ចាន់តូ ឯកឧត្តម ឈា ថាំង ឯកឧត្តម នុត ណារាំង ឯកឧត្តម ម៉ុក ម៉ារ៉េត ឯកឧត្តម ញឹម វណ្ណដា ។

-"អស្សប្ញទ្ធី នៃព្រះរាជាណាចក្រកម្ពុជា" ត្រូវបានប្រទានជូនទៅឯកឧត្តម សុំ ម៉ានិត ឯកឧត្តម នូវ ភានុន ឯកឧត្តម ចាយ សាំងឃុន ឯកឧត្តម អ៊ឹម ឈុន លឹម ឯកឧត្តម ឯម សំអាន ឯកឧត្តម គៀង វ៉ាង ឯកឧត្តម អ៊ុច គឹមអន ឯកឧត្តម ខៀវ កញ្ញារិទ្ធ ឯកឧត្តម ត្រាំ អ៊ីវតឹក ឯកឧត្តម ឈា សុង ឯកឧត្តម គា សាហាន ឯកឧត្តម អ៊ិត ប្រាង ឯកឧត្តម ប្រាក់ សុខ និងលោកជំទាវ ស៊ិន សិរី ។

នៅមានគ្រឿងឥស្សរិយយសយ៉ាងច្រើនសន្ធឹកសន្ធាប់ទៀតដែលព្រះមហាក្សត្រក្នុងព្រះរាជហា

ន:ជាព្រះប្រមុខរដ្ឋ បានព្រះរាជទានដល់ វរជន ឥស្សរជនជាន់ខ្ពស់ និងមន្ត្រីរាជការស៊ីវិល និងយោធានៃព្រះរាជាណាចក្រកម្ពុជា ដែលបានខិតខំយកអស់កម្លាំងកាយចិត្ត សាងគុណសម្បត្តិដ៏ឧត្តុង្គឧត្តមជូនជាតិមាតុភូមិ ។

ព្រះមហាក្សត្រនរោត្តម សីហនុ ទ្រង់បានព្រះរាជទានគ្រឿងឥស្សរិយយសមុនីសារាកណ្ឌ ថ្នាក់"ធិបឌិន" នៅថ្ងៃទី២៤ ខែមករា ឆ្នាំ២០០២ ជូនដល់ឯកឧត្តមដែលជាតំណាងរាស្ត្រ និងជូនចំពោះឥស្សរជននយោបាយជាន់ខ្ពស់នានា ដែលមានឋាន:ដ៏ឧត្តុង្គឧត្តមនៃព្រះរាជាណាចក្រកម្ពុជាយើងជាច្រើនរូបផ្សេងទៀត។

ដូចនេះ យោងតាមរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណ:រដ្ឋមន្ត្រី និងដោយឈរលើមូលដ្ឋានជាក់ស្តែងរបស់ព្រះមហា ក្សត្រខ្មែរនៃព្រះរាជាណាចក្រកម្ពុជា ក្នុងព្រះរាជឋាន:ជាប្រមុខរដ្ឋ ព្រះអង្គមានសិទ្ធិអំណាចចាត់តាំង តែងតាំង ប្រទានឋានន្តរស័ក្តិឋាន: និងគ្រឿងឥស្សរិយយសដល់វីរជន ឥស្សរជន និងមន្ត្រីជាន់ខ្ពស់នៃព្រះរាជាណាចក្រកម្ពុជាបានទាំងអស់ ។

ការកាន់កាប់អំណាចទាំងនេះ បានធ្វើឲ្យព្រះមហាក្សត្រខ្មែរស្ថិតក្នុងតំណែងដ៏មានឥទ្ធិពល និងសិទ្ធិអំណាចនៅក្នុងរដ្ឋស្របទៅតាមនីតិវិធីច្បាប់ក្នុងព្រះរាជឋាន:ព្រះអង្គជាព្រះប្រមុខរដ្ឋ។

ម្យ៉ាងទៀតរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ក៏បានថ្វាយព្រះមហាក្សត្រនូវព្រះរាជតួនាទីជាអ្នកធានាដំណើរការប្រព្រឹត្តទៅនៃអំណាចសាធារណៈ ដើម្បីឲ្យមានភាពត្រឹមត្រូវ និងមានប្រសិទ្ធភាពខ្ពស់ស្របតាមរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣។[229]

ក្នុងព្រះរាជតួនាទីជាព្រះប្រមុខរដ្ឋ ព្រះមហាក្សត្រក៏អាចប្រទានដំឡើងឋាន: និងផ្លាស់ប្តូរបញ្ចប់ការកិច្ច ដើម្បីឲ្យអង្គការរដ្ឋមានដំណើរការប្រកបដោយប្រសិទ្ធភាពខ្ពស់ មានភាពត្រឹមត្រូវ និងទៀងទាត់។

ក្រៅពីអំណាច ដកមន្ត្រីរាជការជាន់ខ្ពស់ស៊ីវិល និងយោធា ព្រះមហាក្សត្រ ទ្រង់ក៏នៅមានសិទ្ធិអំណាចប្រកាសរំលាយរដ្ឋាភិបាលទាំងមូល ឬឥស្សរជនជាន់ខ្ពស់ឯទៀតៗ ក្រោយពីរដ្ឋសភាបានបោះឆ្នោតសម្តែងឆន្ទៈមិនផ្តល់សេចក្តីទុកចិត្ត ឬបានបោះឆ្នោតទម្លាក់រាជរដ្ឋាភិបាលជាដើម។

ទោះយ៉ាងណាក៏ដោយ ការតែងតាំង ការដំឡើងឋានន្តរស័ក្តិ ឬគ្រឿងឥស្សរិយយស និងការដកហូតតំណែងទាំងអស់ខាងលើនេះ គឺមិនមែនជាព្រះរាជអំណាច ពិតប្រាកដរបស់ព្រះមហាក្សត្រ សព្វព្រះរាជហឫទ័យនោះទេ គឺគ្រាន់តែជាទម្រង់នៃនីត្យានុកូលភាព សម្រាប់បំពេញលក្ខ

[229] មាត្រា៩រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

ណៈទម្រង់ នៃសេចក្តីសម្រេចចិត្តរបស់រដ្ឋសភា ឬរាជរដ្ឋាភិបាល ឬឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមតែប៉ុណ្ណោះ នៅក្នុងក្របខ័ណ្ឌនៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ដែលបានចែងថា "ព្រះមហាក្សត្រសោយរាជ្យ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ" សិទ្ធិអំណាចទាំងនេះជាព្រះរាជសិទ្ធិអំណាចរបស់ព្រះមហាក្សត្រ ដែលស្ថិតក្នុងព្រះរាជតួនាទីជាព្រះប្រមុខរដ្ឋតែប៉ុណ្ណោះ។

ព្រះមហាក្សត្រ អាចប្រើប្រាស់អំណាចទាំងនេះបានលុះត្រាតែក្រោយពីអង្គការស្ថាប័នរដ្ឋដែលមានអង្គការនីតិប្បញ្ញត្តិ អង្គការនីតិប្រតិបត្តិ ឬឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមបានអនុម័តសម្រេចរួចស្រេចហើយ។

ព្រះរាជតួនាទីរបស់ព្រះមហាក្សត្រគឺគ្រាន់តែឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យក្នុងការតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចទៅលើនីតិវិធីច្បាប់ដែលបានសម្រេចរួចហើយ។

សិទ្ធិអំណាចក្នុងការសម្រេចទាំងនោះ ត្រូវបានផ្តល់ទៅឲ្យអង្គការរដ្ឋផ្សេងៗទៀត ដែលជាអង្គការបង្កើតឡើងដោយរដ្ឋធម្មនុញ្ញ រួមមាន អង្គនីតិប្បញ្ញត្តិ(រដ្ឋសភា និងព្រឹទ្ធសភា) អង្គនីតិប្រតិបត្តិ(រាជរដ្ឋាភិបាល) និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជាដើម។

ការតែងតាំងនាយករដ្ឋមន្ត្រី គឺជាសិទ្ធិរបស់រដ្ឋសភា មិនមែនសិទ្ធិព្រះមហាក្សត្រទេ ដែលប្រធាន និងអនុប្រធានទាំងពីររបស់រដ្ឋសភាជាអ្នកសម្រេចចិត្តលើកសំណើ តើឥស្សរជនរូបណាជាបេក្ខភាពនាយករដ្ឋមន្ត្រី?ហើយការតែងតាំងគណៈមន្ត្រីក៏មិនមែនជាសិទ្ធិរបស់ព្រះមហាក្សត្រដែរ អង្គការដែលអាចសម្រេចអំពីបេក្ខភាព និងសមាជិកគណៈរដ្ឋមន្ត្រី គឺជាសមត្ថកិច្ចរបស់អង្គការនីតិប្បញ្ញត្តិ(រដ្ឋសភា)។ ហើយចំពោះការសម្រេចថាតើឥស្សរជនរូបណាខ្លះ នឹងធ្វើជាប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត ឬអភិបាលរងខេត្ត អភិបាលរាជធានី ឯកអគ្គរាជទូត ទេសាភិបាល ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា អគ្គលេខាធិការរាជរដ្ឋាភិបាល ទីប្រឹក្សារាជរដ្ឋាភិបាល ទីប្រឹក្សានាយករដ្ឋមន្ត្រី នាយអគ្គសេនាធិការ នាយអគ្គសេនាធិការរង ឧត្តមសេនីយ៍ទាំងឡាយ?គឺអាស្រ័យដោយអង្គការនីតិប្រតិបត្តិ ដែលមាននាយករដ្ឋមន្ត្រីជាអ្នករៀបចំ ដើម្បីឲ្យអ្នកទាំងនោះបានទៅកាន់តំណែងនានានៅក្នុងស្ថាប័នរដ្ឋ ដែលរាជរដ្ឋាភិបាលបានប្រគល់ឲ្យ។

ការរៀបចំ និងការស្នើសុំតែងតាំង គឺត្រូវធ្វើឡើងតាមរយៈនាយករដ្ឋមន្ត្រី ដែលត្រូវបានចេញព្រះរាជក្រឹត្យតែងតាំងដោយព្រះមហាក្សត្រ។ ព្រះមហាក្សត្រ ទ្រង់ពុំមានសិទ្ធិអំណាចដើម្បីប្រឆាំងជំទាស់បានទេ ព្រះមហាក្សត្រ ទ្រង់ត្រូវប្រតិបត្តិតាមរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ដែលបានចែងថា:ប្រទេសកម្ពុជាជាព្រះរាជាណាចក្រ ដែលមានព្រះមហាក្សត្រទ្រង់ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងតាមរបបលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។[230]

[230] មាត្រា១រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

២-អំណាចប្រកាសឲ្យប្រើប្រាស់ច្បាប់

(Power to Declare Promulgate)

ព្រះមហាក្សត្រ ទ្រង់មានសិទ្ធិអំណាចឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឲ្យប្រើប្រាស់ច្បាប់រដ្ឋធម្មនុញ្ញ និងច្បាប់ផ្សេងៗទៀត។

ស្របតាមរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ដែលបានចែងថា ព្រះមហាក្សត្រ ទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រម ប្រកាសឲ្យប្រើរដ្ឋធម្មនុញ្ញ ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ ទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យតាមសេចក្តីស្នើសុំពីគណៈរដ្ឋមន្ត្រី។[231]

រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ បានបញ្ជាក់បន្ថែមទៀតថា “ច្បាប់ដែលរដ្ឋសភា បានអនុម័ត និងព្រឹទ្ធសភា បានពិនិត្យចប់សព្វគ្រប់ហើយ ត្រូវបានព្រះមហាក្សត្រ ឡាយព្រះហស្តលេខាប្រកាសឲ្យប្រើ ហើយត្រូវបានចូលជាធរមាននៅរាជធានីភ្នំពេញ ក្នុងរយៈពេល១០ថ្ងៃ ក្រោយពីថ្ងៃប្រកាសឲ្យប្រើ និងចូលជាធរមាននៅទូទាំងប្រទេសក្នុងរយៈពេល២០ថ្ងៃ ក្រោយពីថ្ងៃដែលប្រកាសឲ្យប្រើ ប៉ុន្តែប្រសិនបើច្បាប់នោះ បានចែងថា ជាការប្រញាប់ ច្បាប់នោះត្រូវតែចូលជាធរមានភ្លាមនៅទូទាំងព្រះរាជាណាចក្រកម្ពុជា បន្ទាប់ពីថ្ងៃដែលបានប្រកាសឲ្យប្រើ។[232]

ច្បាប់ដែលព្រះមហាក្សត្រ ទ្រង់បានឡាយព្រះហស្តលេខាក្នុងការប្រកាសឲ្យប្រើគឺត្រូវតែចុះក្នុងរាជកិច្ច និងផ្សព្វផ្សាយនៅទូទាំងប្រទេសឲ្យទាន់ពេលវេលាតាមកាលកំណត់ខាងលើ។

ច្បាប់ដែលប្រកាសឲ្យប្រើដោយប្រមុខរដ្ឋ ត្រូវមានសុពលភាព និងមានអនុភាពគតិយុត្តិទូទាំងប្រទេស ហើយដែលប្រជាពលរដ្ឋទាំងអស់ត្រូវតែគោរព និងប្រតិបត្តិតាម។

ដូច្នេះ ព្រះមហាក្សត្រក្នុងព្រះរាជតួនាទី ជាប្រមុខរដ្ឋការឡាយព្រះហស្តលេខាលើព្រះរាជក្រម និងព្រះរាជក្រឹត្យគឺជាព្រះរាជកិច្ចរបស់ព្រះមហាក្សត្រ។

រាល់សេចក្តីសម្រេចធ្វើឡើងដែលមានលក្ខណៈជាបទបញ្ជា គឺជាភារកិច្ចរបស់អង្គការនីតិប្រតិបត្តិ និងអាជ្ញាធររដ្ឋបាលដទៃទៀត។

រាល់សេចក្តីសម្រេចដែលចេញបទបញ្ជាគឺជាភារកិច្ចរបស់រាជរដ្ឋាភិបាល ឬគណៈរដ្ឋមន្ត្រី ព្រះមហាក្សត្រ ក្នុងព្រះរាជតួនាទីប្រមុខរដ្ឋ គឺជាអ្នកផ្តល់នីត្យានុកូលភាព ដល់រាល់បទបញ្ជាទាំងនោះ ដែលបានធ្វើសេចក្តីសម្រេចឡើង ដោយគណៈរដ្ឋមន្ត្រី តាមរយៈព្រះហស្តលេខាលើព្រះរាជក្រឹត្យគឺស្ថិតក្នុងលក្ខខណ្ឌរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ដែលចែងថាព្រះមហាក្សត្រទ្រង់ឡាយព្រះហស្ត

[231] មាត្រា២៨រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[232] មាត្រា៩៣រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

លេខាលើព្រះរាជក្រមប្រកាសឲ្យប្រើច្បាប់ដែលរដ្ឋសភា និងព្រឹទ្ធសភាបានអនុម័ត និងពិនិត្យចប់សព្វគ្រប់រួចហើយ និងលើព្រះរាជក្រឹត្យតាមសេចក្តីស្នើសុំរបស់គណៈរដ្ឋមន្ត្រី។

បន្ថែមលើអំណាចឡាយព្រះហស្តលេខា ប្រកាសឲ្យប្រើច្បាប់ ព្រះមហាក្សត្រ ក្នុងព្រះរាជតួនាទីជាព្រះប្រមុខរដ្ឋ។

រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ដែលបានចែងថាព្រះមហាក្សត្រទ្រង់មានព្រះរាជសិទ្ធិអំណាចឡាយព្រះហស្តលេខា លើសន្ធិសញ្ញាអន្តរជាតិ និងអនុសញ្ញាអន្តរជាតិ ក៏ប៉ុន្តែទ្រង់ប្រទានផ្តល់សច្ចាប័នលើសន្ធិសញ្ញា និងអនុសញ្ញាទាំងនោះក្រោយពេលបានទទួលការអនុម័តនិងយល់ព្រមពីរដ្ឋសភា និងព្រឹទ្ធសភាចប់សព្វគ្រប់ហើយ។[233]

៣-អំណាចប្រកាសសង្គ្រាម និងភាពអាសន្ន

(Power to Declare a War and Emergency)

ព្រះមហាក្សត្រទ្រង់នៅមានព្រះរាជសិទ្ធិអំណាចប្រកាសភាពអាសន្ននិងប្រកាសសង្គ្រាមក្នុងកាលៈទេសៈពិសេស។

រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បានចែងទៀតថា“នៅពេលប្រទេសជាតិប្រឈមមុខនឹងគ្រោះថ្នាក់ព្រះមហាក្សត្រ ទ្រង់ប្រកាសប្រទានដំណឹងជាសាធារណៈដាក់ប្រទេសជាតិឲ្យស្ថិតក្នុងភាពអាសន្នក្រោយពីបានមតិឯកភាពអំពីនាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា និងប្រធានព្រឹទ្ធសភា”។[234]

រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បានបន្ថែមទៀតថា “ព្រះមហាក្សត្រ ទ្រង់ប្រកាសសង្គ្រាមក្រោយមានការអនុម័តពីរដ្ឋសភា និងព្រឹទ្ធសភា”។[235]

ព្រះមហាក្សត្រ ទ្រង់ឥតមានសិទ្ធិប្រើអំណាចទាំងនេះតែព្រះអង្គឯងបានទេ។ ជាទូទៅព្រះមហាក្សត្រ អាចប្រើអំណាចទាំងនេះបានលុះណាតែមានការចូលរួមសម្រេចពីអង្គការស្ថាប័នរដ្ឋផ្សេងៗទៀតដែលមានអង្គការនីតិប្បញ្ញត្តិ និងអង្គការនីតិប្រតិបត្តិជាដើម។

ស្ថាប័នទាំងនេះទើបមានអំណាចពិតប្រាកដរីឯព្រះមហាក្សត្រទ្រង់គឺគ្រាន់តែជាអ្នកអនុវត្តតាមទម្រង់នីតិវិធីដើម្បីឲ្យមានភាពស្របច្បាប់តែប៉ុណ្ណោះ។

សរុបសេចក្តីមក យើងអាចនិយាយបានថា ព្រះមហាក្សត្រមានអំណាចប្រកាសសង្គ្រាមប៉ុន្តែសេចក្តីប្រកាសនេះអាចធ្វើទៅបាន លុះណាតែរដ្ឋសភាបានអនុម័តរួចហើយ ព្រះមហាក្សត្រ

---

[233] មាត្រា២៦រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[234] មាត្រា២២រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[235] មាត្រា២៤ វាក្យខណ្ឌទី២ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

មានព្រះរាជអំណាចប្រកាសជាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ប៉ុន្តែលុះត្រាតែមានការឯកភាពយល់ព្រមពីប្រធានរដ្ឋសភា ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រីរួចហើយ។

នៅក្នុងករណី នៃការប្រកាសសង្គ្រាម ការប្រកាសជាក់ប្រទេសជាតិ ស្ថិតក្នុងភាពអាសន្ន រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បានតម្រូវឲ្យព្រះមហាក្សត្រ ផ្តល់សច្ចាប័នលើអ្វី ដែលរដ្ឋសភា ព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រីបានអនុម័តសម្រេចរួចហើយដែរ។

៤-អំណាចលើកលែងទោស

(Power to Pardon)

គ្រប់អំណាចទាំងអស់របស់ព្រះមហាក្សត្រ មានទិដ្ឋភាពជារួមមួយ គឺជាអំណាចសុទ្ធតែតម្រូវឲ្យមានការអនុម័តយល់ព្រម ឬការចូលរួមពីស្ថាប័នដទៃៗទៀតមានដូចជាអង្គការនីតិប្បញ្ញត្តិ អង្គការនីតិប្រតិបត្តិ ឬឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ទើបព្រះមហាក្សត្រ អាចបំពេញព្រះរាជកិច្ចបានដោយព្រះអង្គផ្ទាល់។

នីតិវិធីច្បាប់ទាំងនេះគឺស្របទៅនឹងគោលការណ៍រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ដែលបានចែងថា “ព្រះមហាក្សត្រសោយរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ”។[236]

ទោះយ៉ាងណាក៏ដោយ រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ក៏បានថ្វាយព្រះមហាក្សត្រនូវព្រះរាជសិទ្ធិអំណាចយ៉ាងច្បាស់លាស់ និងពិតប្រាកដក្នុងព្រះរាជកិច្ច ដោយឯករាជ្យលើការលើកលែងទោសក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បានចែងថា “ព្រះមហាក្សត្រទ្រង់មានព្រះរាជសិទ្ធិ បន្ធូរបន្ថយទោស និងការលើកលែងទោស”។[237]

នៅពេលព្រះមហាក្សត្រ បានធ្វើការលើកលែងទោសដល់ជនណាមួយ ដែលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ដែលមានបទមជ្ឈិម ឬបទឧក្រិដ្ឋ ឬ បានប្រព្រឹត្តខុសច្បាប់របស់រដ្ឋ អ្នកប្រព្រឹត្តបទល្មើសទាំងនោះ មិនអាចត្រូវបានគេដាក់ទណ្ឌកម្មបានឡើយ ឬទណ្ឌកម្មអាចត្រូវបានកាត់បន្ថយ ឬការលើកលែងទោសដែលធ្វើឡើងដោយព្រះមហាក្សត្រ ។

ទណ្ឌិត ដែលជាតំណាងរាស្ត្រ ហើយត្រូវបានព្រះមហាក្សត្រ លើកលែងទោសឲ្យតំណាងរាស្ត្រ ឬសមាជិករដ្ឋសភានោះ នឹងទទួលបានសុពលភាព ដោយមានអភ័យឯកសិទ្ធិ និងបុព្វសិទ្ធិឡើងវិញដោយស្វ័យប្រវត្តិ។

ដូចជាលោកអៀង សារី ដែលអតីតជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការបរទេសនៅក្នុង

---

[236] មាត្រា៧រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[237] មាត្រា២៧រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

អតីតរបបកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-៧៩) ត្រូវបានគេមើលឃើញយ៉ាងទូលំទូលាយថា ជាអ្នកស្ថាបនិកម្នាក់ ក្នុងចំណោមអ្នកស្ថាបនិកដ៏សំខាន់ បន្ទាប់ពីនាយករដ្ឋមន្ត្រី ប៉ុល ពត នៅក្នុងរបបវាលពិឃាដខ្មែរក្រហម ដែលបានផ្តល់ផលវិបាកធ្ងន់ធ្ងរ និងប្រកបដោយបដិវាទកម្មដ៏ខ្លាំងក្លា ត្រូវបានព្រះមហាក្សត្រចេញព្រះរាជក្រឹត្យលើកលែងទោស។

ការលើកលែងទោសសំខាន់ៗជាច្រើនផ្សេងទៀតដែលព្រះមហាក្សត្រខ្មែរបានបំពេញព្រះរាជតួនាទី ជាក់ស្តែងត្រូវបានលើកលែងដោយព្រះមហាក្សត្រ ព្រះបាទ នរោត្តម សីហនុ រួមមាន:

-“ការលើកលែងទោសដល់លោក យឹម សុខា នៅខែកក្កដា ឆ្នាំ១៩៩៦ ដែលលោក យឹម សុខា ត្រូវបានតុលាការកំពូលនៃព្រះរាជាណាចក្រកម្ពុជានៅក្រុងភ្នំពេញបានកាត់ទោសឲ្យលោកជាប់គុកចំនួន១ឆ្នាំពីបទសរសេរអត្ថបទរិះគន់មេដឹកនាំរាជរដ្ឋាភិបាល។

ដោយមានការលើកលែងទោសពីព្រះមហាក្សត្រ លោក យឹម សុខា ត្រូវបានដោះលែងវិញនៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ១៩៩៦”។

-ការលើកលែងទោសដល់អតីតមេដឹកនាំធ្វើរដ្ឋប្រហារជាច្រើនរូបនាឆ្នាំ១៩៩៧ ដែលត្រូវបានតុលាការកំពូលកាត់ទោសពីបទធ្វើរដ្ឋប្រហារផ្តួលរំលំរាជរដ្ឋាភិបាល។

មេដឹកនាំរដ្ឋប្រហារទាំងនោះរួមមាន:

+ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ដែលជានាយករដ្ឋមន្ត្រីទី១នៃរាជរដ្ឋាភិបាលកម្ពុជាពីឆ្នាំ ១៩៩៣-១៩៩៧ជាប្រធានគណបក្សហ៊្វុនស៊ិនប៉ិច និងជាព្រះរាជបុត្រនៃព្រះមហាក្សត្រ ព្រះបាទ នរោត្តម សីហនុ។

+ឧត្តមសេនីយ៍ឯក ញឹក ប៊ុនឆៃ អតីតជាអគ្គសេនាធិការរងទី១នៃកងទ័ពជាតិកម្ពុជា និងជាមន្ត្រីជាន់ខ្ពស់នៃគណបក្សរាជានិយមហ៊ុន សុិនប៉ិច។

+ឧត្តមសេនីយ៍ ខាន់ សារឿន មេបញ្ជាការភូមិភាគនៃកងទ័ពជាតិកម្ពុជា និងជាមន្ត្រីជាន់ខ្ពស់នៃគណបក្សហ៊្វុនស៊ិនប៉ិច។

+ឧត្តមសេនីយ៍ ឡៃ វីរៈ អតីតមេបញ្ជាការកងពលនៃកងទ័ពជាតិកម្ពុជា និងជាមន្ត្រីជាន់ខ្ពស់នៃគណបក្ស ហ៊ុន សុិនប៉ិច។

+ឯកឧត្តម ឧត្តមសេនីយ៍ទោ សេរី កុសល ជាអតីតអភិបាលរងទី១នៃខេត្តបាត់ដំបង និងជាមន្ត្រីជាន់ខ្ពស់ ហ៊ុន សុិនប៉ិច។

+មន្ត្រីជាន់ខ្ពស់ស៊ីវិល និងយោធា នៃគណបក្សហ៊្វុន សុិនប៉ិច ជាច្រើនរូបផ្សេងទៀត ក៏ត្រូវបានលើកលែងទោសទាំងអស់ផងដែរ។

ជាទូទៅ គ្រប់ការលើកលែងទោស និងការបន្ធូរបន្ថយទោសទាំងឡាយរបស់ព្រះមហាក្សត្រ

គឺត្រូវធ្វើឡើងតាមរយៈសេចក្តីស្នើសុំរបស់អង្គការស្ថាប័នរដ្ឋ ជាពិសេសតាមរយៈការស្នើឡើងអំពីនាយករដ្ឋមន្ត្រី។

ក្នុងករណីការបន្ធូរបន្ថយទោស ជាទូទៅគឺត្រូវធ្វើឡើងតាមរយៈលោកប្រធានគុកដែលជាអ្នកលើកសំណើមកក្រសួងយុត្តិធម៌ ទើបរដ្ឋមន្ត្រីនៃក្រសួងយុត្តិធម៌រៀបចំធ្វើសំណើជូនមកលោកនាយករដ្ឋមន្ត្រី ទើបនាយករដ្ឋមន្ត្រី ធ្វើសំណើមកព្រះមហាក្សត្រ ដើម្បីព្រះមហាក្សត្រ ទ្រង់ចេញព្រះរាជក្រឹត្យបន្ធូរបន្ថយទោសតាមការស្នើសុំតែម្តង។

២.ការិយាល័យប្រតិបត្តិរបស់ព្រះមហាក្សត្រ

(Executive Office of King)

"ព្រះបរមរាជវាំង"គឺជាក្រសួងស្ថាប័នរដ្ឋមួយ ដែលត្រូវបានបង្កើតឡើង ដោយព្រះក្រឹត្យលេខ NS/KRT/៣៤ ចុះនៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ១៩៩៥ ដែលមានឈ្មោះថា "ក្រសួងព្រះបរមរាជវាំង" ដែលដឹកនាំដោយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ និងមានមន្ត្រីបុគ្គលិកដូចក្រសួងឯទៀតៗនៃរាជរដ្ឋាភិបាលផងដែរ។

ក្នុងក្រសួងព្រះបរមរាជវាំង មានការិយាល័យប្រតិបត្តិមួយចំនួន សម្រាប់ជួយការងារដល់ព្រះមហាក្សត្រដែលការិយាល័យទាំងនោះរួមមាន:

-ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ
-ក្រុមប្រឹក្សាយោធាព្រះមហាក្សត្រ
-ឧត្តមក្រុមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ
-ក្រុមសម្តេចឪ

១-ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

(King's Royal Office)

នៅក្នុងព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ មានមន្ត្រីជាច្រើនប្រភេទគឺ:

-ក្រុមអ្នកឧកញ៉ាចៅហ្វាវាំង
-ក្រុមជំនិតព្រះមហាក្សត្រ
-មន្ត្រីអចិន្ត្រៃយ៍
-មន្ត្រីកិត្តិយស ។

១.១.ក្រុមអ្នកឧកញ៉ាចៅហ្វាវាំង

(Royal Chief Mandarin)

ក្រុមអ្នកឧកញ៉ា គឺស្ថិតនៅក្រោមការគ្រប់គ្រងដឹកនាំរបស់អ្នកឧកញ៉ា ចៅហ្វាវាំង ហើយ

ជាអ្នកដឹកនាំគ្រប់គ្រង និងក្តោបក្តាប់កិច្ចការរដ្ឋបាលទាំងអស់នៅក្នុងក្រសួងព្រះបរមរាជវាំង។

អ្នកឧកញ៉ាចៅហ្វាវាំង និងមន្ត្រីជាន់ខ្ពស់ជាច្រើនទៀត ត្រូវបានតែងតាំងដោយព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាតាមសំណើរបស់ឥស្សរជននយោបាយកំពូលៗ។

ឯកឧត្តម គង់ សំអុល គឺជាអតីតជារដ្ឋមន្ត្រីក្រសួងកសិកម្មនៃរាជរដ្ឋាភិបាលកម្ពុជា និងជាមន្ត្រីជាន់ខ្ពស់របស់គណបក្សប្រជាជនកម្ពុជា ក៏ត្រូវបានតែងតាំងជា "អ្នកឧកញ៉ា ចៅហ្វាវាំង" ដោយព្រះរាជក្រឹត្យចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ១៩៩៤ ជាឧបនាយករដ្ឋមន្ត្រីព្រះបរមរាជវាំង ។

ឯកឧត្តម មិន ឃិន ក៏ត្រូវបានតែងតាំង ជារដ្ឋលេខាធិការនៃព្រះបរមរាជវាំង នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៣ តាមសំណើរបស់សម្តេច ជា ស៊ីម ជាប្រធានរដ្ឋសភា និងជាប្រធានគណបក្សប្រជាជនកម្ពុជា។

ឯកឧត្តម គុយ សុផល ឯកឧត្តម មាយ សំភួន ឯកឧត្តម ជុំ ងឿន ត្រូវបានតែងតាំងជារដ្ឋលេខាធិការនៃក្រសួងព្រះបរមរាជវាំង ដោយព្រះរាជក្រឹត្យចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ១៩៩៨ ។

ឯកឧត្តម អន ស៊ាម ឯកឧត្តម ឈា ហន ឯកឧត្តម អ៊ុំ ឯម ត្រូវបានតែងតាំង ជាអនុរដ្ឋលេខាធិការនៃក្រសួងព្រះបរមរាជវាំង ដោយព្រះរាជក្រឹត្យ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ១៩៩៨។

ការតែងតាំង និងការដេកហូតឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ និងមន្ត្រីជាន់ខ្ពស់ឯទៀតៗនៃក្រសួងព្រះបរមរាជវាំងពុំមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ និងក្នុងច្បាប់រដ្ឋសភាណាមួយឡើយ។

១.២.ក្រុមជំនិតព្រះមហាក្សត្រ

(Intimate Team of King)

មន្ត្រីជំនិតរបស់ព្រះមហាក្សត្រ គឺមានមន្ត្រីអចិន្ត្រៃយ៍ និងមន្ត្រីកិត្តិយស។ មន្ត្រីទាំងអស់នេះសុទ្ធសឹងតែត្រូវបានជ្រើសរើស និងតែងតាំងដោយផ្ទាល់តាមការសព្វព្រះទ័យរបស់ព្រះមហាក្សត្រ ដោយព្រះរាជក្រឹត្យទាំងអស់។

មន្ត្រីទាំងពីរក្រុមនេះ គឺសុទ្ធសឹងតែធ្វើការ នៅក្នុងព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រដែរ ប៉ុន្តែមិនចំណុះអ្នកឧកញ៉ាចៅហ្វាវាំងនៃក្រសួងព្រះបរមរាជវាំងទេ។

១.៣.មន្ត្រីអចិន្ត្រៃយ៍

(Permanent Officials)

មន្ត្រីទាំងនោះមានឋានៈទៅតាមព្រះរាជក្រឹត្យកំណត់ដូចជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ឯកអគ្គរាជទូត ដែលក្រុមមន្ត្រីអចិន្ត្រៃយ៍រួមមាន:

+ឯកឧត្តម ជា កុសល អនុរដ្ឋលេខាធិការព្រះបរមរាជវាំង ។

+ឯកឧត្តម ជួយ ហឿន អនុរដ្ឋលេខធិការព្រះបរមរាជវាំង ។

១.៤.មន្ត្រីកិត្តិយស

(Honorary Officials)

មន្ត្រីកិត្តិយសមានតួនាទីជាអ្នកជួយដល់ព្រះមហាក្សត្រក្នុងពិធីការរបស់ព្រះបរមរាជវាំង មន្ត្រីកិត្តិយសត្រូវមានឋានៈទៅតាមព្រះមហាក្សត្រព្រះប្រទានឲ្យជា"រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ឯកអគ្គរាជទូត" ដូចគ្នាទៅនឹងមន្ត្រីអចិន្ត្រៃយ៍ដែរ។ ក្នុងចំណោមមន្ត្រីកិត្តិយសដែលត្រូវបានព្រះមហាក្សត្រ នរោត្តម សីហនុ បានតែងតាំងរួមមាន:

+ឯកឧត្តម ងិន ឈន ត្រូវបានតែងតាំងជាសមាជិកកិត្តិយសនៃខុទ្ទកាល័យរបស់ព្រះមហាក្សត្រដែលមានឋានៈស្មើនឹងរដ្ឋមន្ត្រី។

+ឯកឧត្តម វេជ្ជបណ្ឌិត ច័ន្ទ ថោងសេរី ក៏ត្រូវបានតែងតាំងជាសមាជិកកិត្តិយសនៃព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រដែលមានឋានៈស្មើឯកអគ្គរាជទូត ដោយព្រះរាជក្រឹត្យចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៤។

២-ក្រុមប្រឹក្សាយោធាព្រះមហាក្សត្រ

(Soldier Council of King)

ឧត្តមក្រុមប្រឹក្សាយោធាមួយត្រូវបានព្រះមហាក្សត្របង្កើតឲ្យមានឡើងដើម្បីធ្វើការពិភាក្សានិងពិគ្រោះយោបល់ អំពីកិច្ចការយោធាទូទៅរបស់រដ្ឋ ដែលការបង្កើតនេះ គឺមិនស្ថិតក្រោមច្បាប់រដ្ឋធម្មនុញ្ញ និងលិខិតបទដ្ឋាននានារបស់ព្រះរាជាណាចក្រកម្ពុជានោះទេហើយដែលពុំមានចែងអំពីក្រុមប្រឹក្សានេះទេ។

ឥស្សរជនជាន់ខ្ពស់ ដែលមានស្វាមីភក្តិចំពោះព្រះរាជបល្ល័ង្ក និងព្រះមហាក្សត្រត្រូវបានតែងតាំងជាសមាជិកនៃឧត្តមក្រុមប្រឹក្សានេះដែរឥស្សរជនទាំងនោះមានដូចជា:

+ឯកឧត្តម ឧត្តមសេនីយ៍ ទេព បែន ត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សាយោធាព្រះមហាក្សត្រដោយព្រះរាជក្រឹត្យចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ១៩៩៣។

+ឯកឧត្តម ឧត្តមសេនីយ៍ សក់ ស៊ុតសាខន ត្រូវបានតែងតាំងជាសមាជិកនៃក្រុមប្រឹក្សាយោធាព្រះមហាក្សត្រដោយព្រះរាជក្រឹត្យចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៣។

៣-ឧត្តមក្រុមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ

(Top Council of King)

ការបង្កើតស្ថាប័នឧត្តមក្រុមប្រឹក្សាផ្ទាល់របស់ព្រះមហាក្សត្រជាព្រះរាជសិទ្ធិតាមប្រពៃណីនិងទាំងតាមស្មារតីនៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ដែលបានថ្វាយព្រះមហាក្សត្រនូវព្រះរាជតួនាទីនេះ។

ឧត្តមក្រុមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ ជាទីប្រឹក្សាជាន់ខ្ពស់របស់ព្រះមហាក្សត្រដែលមានតួនាទីជាអ្នក ផ្តល់យោបល់អំពីកិច្ចការទូទៅ និងការងារធំៗទាំងឡាយរបស់រដ្ឋ ដើម្បីថ្វាយដល់ព្រះមហាក្សត្របានជ្រាប។

ព្រះមហាក្សត្រ បានប្រទានឋានៈជាឧបនាយករដ្ឋមន្ត្រី ដល់គ្រប់ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រទាំងអស់តាមព្រះរាជក្រឹត្យចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៣។

តំណែងជាឧបនាយករដ្ឋមន្ត្រី ដែលជាឧត្តមប្រឹក្សាផ្ទាល់ គឺពុំមានចែងក្នុងរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ និងច្បាប់របស់រដ្ឋសភាណាមួយឡើយ។ ហើយតំណែងទាំងនេះពុំមានឥទ្ធិពល និងសិទ្ធិអំណាចអ្វីទៅលើអង្គការរដ្ឋបាលរបស់រដ្ឋឡើយ គឺគ្រាន់តែសម្រាប់តែក្នុងពិធីការរបស់ព្រះបរមរាជវាំងតែប៉ុណ្ណោះ ដែលបានផ្តល់វិរជនកំពូល។ ដែលភាគច្រើន គឺសុទ្ធតែជាអ្នកដែលមានស្វាមីភក្តិចំពោះរាជបល្ល័ង្ក និងអ្នកដែលបានដង្ហែតាមព្រះមហាក្សត្ររាប់ទសវត្សរ៍មកហើយ ដែលត្រូវបានព្រះមហាក្សត្រ តែងតាំងឲ្យកាន់តំណែងដ៏ឧត្តុង្គឧត្តមទាំងនេះ។

វិរជន ដែលត្រូវបានតែងតាំង ជាឧត្តមក្រុមប្រឹក្សាផ្ទាល់របស់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាមានឋានៈស្មើឧបនាយករដ្ឋមន្ត្រីមាន:

+សម្តេច ញឹក ជូឡុង

+សម្តេច បវរសេដ្ឋា សឺន សាន

+សម្តេច ងោ ហ៊ូ

+ឯកឧត្តម ចៅសែនកុសល ឈុំ

+ឯកឧត្តម ហេង សំរិន ដោយព្រះរាជក្រឹត្យចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៣

+លោកជំទាវ ស៊ុំ នីផា ដោយព្រះរាជក្រឹត្យចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៩៩។

៤-ក្រុមសម្តេចឪ

(Team Father King)

ព្រះមហាក្សត្រ ព្រះបាទ នរោត្តម សីហនុ ទ្រង់បានចេញព្រះរាជក្រឹត្យចុះថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ១៩៩៣ បង្កើតឲ្យមានក្រុមសម្តេចឪឡើង ដោយព្រះរាជតម្រិះរបស់ព្រះអង្គ។

ក្រុមសម្តេចឪគឺជាក្រុមចុះអន្តរាគមន៍ជួយសង្គ្រោះប្រជារាស្ត្រក្រីក្រដែលមានភារកិច្ចជួយឧបត្ថម្ភ និងជួយសង្គ្រោះប្រជារាស្ត្រជាបន្ទាន់ ក្នុងករណីជួបការលំបាក ការខ្វះខាតព្រមទាំងមានគ្រោះធម្មជាតិជាដើម ក្រុមសម្តេចឪមានសមាសភាពដូចតទៅ:

+ឯកឧត្តម គង់ សំអុល ឧបនាយករដ្ឋមន្ត្រី ជារដ្ឋមន្ត្រីព្រះបរមរាជវាំងជាប្រធាន

+ឯកឧត្តម កែវ ពុទ្ធរស្មី រដ្ឋមន្ត្រីព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រជាអនុប្រធាន

+ឯកឧត្តម ជា ពន្លក ជាសមាជិក

+ឯកឧត្តម សូ ស៊ីឌីម ជាសមាជិក

+ឯកឧត្តម ឌុក ឌិន ជាសមាជិក

+ឯកឧត្តម ឌុក ឌៀន ជាសមាជិក

+ឯកឧត្តម លឹម គានហោ ប្រធាននាយកដ្ឋានធារាសាស្ត្រ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ជាសមាជិក។

+ឯកឧត្តម អ៊ុំ ឯក ជាប្រធាននាយកដ្ឋានឧបត្ថម្ភ និងសង្គ្រោះប្រជានុរាស្ត្រ អគ្គនាយកដ្ឋានព្រះបរមរាជវាំងជាសមាជិក។

+ឯកឧត្តម យឹម សុខា សមាជិកការនៃបង្កើតគណៈកម្មការ និងការតែងតាំងសម្រាប់កិច្ចការងារក្នុងព្រះបរមរាជវាំងទាំងមូល។

ផ្នែកទី២

នីតិប្រតិបត្តិ(រាជរដ្ឋាភិបាល)

(The Executive Government)

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាជាអង្គការនីតិប្រតិបត្តិ ដែលមានគណៈរដ្ឋមន្ត្រីជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

គណៈរដ្ឋមន្ត្រីត្រូវបានដឹកនាំដោយនាយករដ្ឋមន្ត្រីមួយរូប អមដោយឧបនាយករដ្ឋមន្ត្រីរួមទាំងមានទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាសមាជិក។[238]

រាជរដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជាគ្រប់គ្រងប្រទេសដោយផ្តាល់ដឹកនាំកសាង និងពង្រីកសេដ្ឋកិច្ចជាតិសំដៅអភិវឌ្ឍន៍ប្រទេសជាតិទាំងមូលលើគ្រប់វិស័យ។

ក.បែបបទនៃការរៀបចំរាជរដ្ឋាភិបាល

(Form of Organizing Government)

១-ការបង្កើតរាជរដ្ឋាភិបាល

(Forming Government)

ការបង្កើតរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ននេះ ត្រូវស្ថិតនៅក្នុងក្របខ័ណ្ឌពីរយ៉ាងគឺ ការបង្កើតរាជរដ្ឋាភិបាលដោយផ្អែកលើក្របខ័ណ្ឌច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ដែលមានចែងនៅក្នុងមាត្រា៨២ និងមាត្រា១១៩ថ្មីនៃការបង្កើតរាជរដ្ឋាភិបាលកម្ពុជាដោយផ្អែកលើក្របខ័ណ្ឌច្បាប់រដ្ឋធម្មនុញ្ញបន្ថែមនៃព្រះរាជាណាចក្រកម្ពុជា។

១.១.ការបង្កើតរាជរដ្ឋាភិបាលតាមមាត្រា១១៩ថ្មី

(Forming Royal Government through the new Article 119)

តាមសេចក្តីស្នើពីប្រធានដោយមានមតិឯកភាពពីអនុប្រធានទាំងពីរនៃរដ្ឋសភាព្រះមហាក្សត្រ ទ្រង់ចាត់តាំងវីរជនមួយរូបក្នុងចំណោមតំណាងរាស្ត្រនៃគណបក្ស ដែលឈ្នះឆ្នោតឲ្យបង្កើតរាជរដ្ឋាភិបាល។ វីរជន ដែលត្រូវបានចាត់តាំងនោះគឺត្រូវនាំសហការី ដែលជាតំណាងរាស្ត្រ ឬជាសមាជិកគណបក្សតំណាងនៅក្នុងរដ្ឋសភា ដែលផ្តួរផ្តង់ឲ្យកាន់តំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាលទៅសុំសេចក្តីទុកចិត្តពីរដ្ឋសភា។ កាលបើរដ្ឋសភា បានបោះឆ្នោតផ្តល់សេចក្តីទុកចិត្តហើយនោះ ព្រះមហាក្សត្រទ្រង់ចេញព្រះរាជក្រឹត្យតែងតាំងគណៈរដ្ឋមន្ត្រីទាំងមូល។

---

[238] មាត្រា១១៨រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។ សមាសភាពគណៈរដ្ឋមន្ត្រីរាជរដ្ឋាភិបាលកម្ពុជាអាណត្តិទី៦នៃរដ្ឋសភាមិនបានរាប់បញ្ចូលរដ្ឋលេខាធិការទៅជាសមាជិករាជរដ្ឋាភិបាលដូចមុនៗទៀតទេ។

មុនចូលកាន់តំណែងគណៈរដ្ឋមន្ត្រី ត្រូវធ្វើសច្ចាប្រណិធានដូចមានខ្លឹមសារដែលចែងក្នុងឧបសម្ព័ន្ធ៦នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣។[239]

នៅក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋ តាមបែបផែនរបបសភានិយម រដ្ឋសភាជាអ្នកបង្កើតរាជរដ្ឋាភិបាល។ បានសេចក្តីថា បន្ទាប់ពីរដ្ឋសភាបានបង្កើតហើយ គណបក្ស ដែលមានសម្លេងច្រើនជាងគេក្នុងរដ្ឋសភា ត្រូវបញ្ជូនបេក្ខភាពជានាយករដ្ឋមន្ត្រីទៅរដ្ឋសភាជាតិ បន្ទាប់មកទើបសុំសេចក្តីទុកចិត្តពីរដ្ឋសភា ក្រោយពីទទួលបានសេចក្តីទុកចិត្តពីរដ្ឋសភារួចហើយ ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាចេញព្រះរាជក្រឹត្យ តែងតាំង ហើយបេក្ខភាពនាយករដ្ឋមន្ត្រី ត្រូវតែមានសិទ្ធិគ្រប់គ្រាន់ក្នុងការរៀបចំរាជរដ្ឋាភិបាល ដោយផ្តល់ផ្តែងឲ្យកាន់តំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាល ហើយទៅសុំសេចក្តីទុកចិត្តពីរដ្ឋសភា។

ក្រោយអំពីរដ្ឋសភា បានបោះឆ្នោតអនុម័តផ្តល់សេចក្តីទុកចិត្ត ដោយសម្លេងភាគច្រើនពីរភាគបី(២/៣)នៃចំនួនសមាជិករដ្ឋសភាទាំងមូល(មុនឆ្នាំ២០០៦)។ ក្រោយឆ្នាំ២០០៦មក ការអនុម័តផ្តល់សេចក្តីទុកចិត្ត ដោយសម្លេងភាគច្រើនជាច់ខាត(៥០+១)នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

១.២.ការបង្កើតរាជរដ្ឋាភិបាលផ្អែកតាមច្បាប់ធម្មនុញ្ញបន្ថែម

(Establishment of Royal Government based on Additional National Constitution)

ក្នុងករណីដែលយល់ឃើញថានីតិវិធីនៃការបង្កើតរាជរដ្ឋាភិបាលតាមរយៈមាត្រា៨២ និងមាត្រា១១៩ថ្មីនៃរដ្ឋធម្មនុញ្ញមិនអាចអនុវត្តន៍ទៅបាន ដូចនេះ រដ្ឋសភាត្រូវអនុវត្តន៍ទៅតាមនីតិវិធីច្បាប់ធម្មនុញ្ញបន្ថែម។ តាមសំណើរបស់គណបក្សនយោបាយ ដែលមានអាសនៈនៅក្នុងរដ្ឋសភាច្រើនជាងគេ ឬគណបក្សមានតំណាងរាស្ត្រច្រើនជាងគេនៅក្នុងរដ្ឋសភា អាចដំណើរការការបោះឆ្នោតជាកញ្ចប់ដើម្បីធ្វើការជ្រើសតាំងប្រធាន និងអនុប្រធានទី១ អនុប្រធានទី២នៃរដ្ឋសភាក៏ដូចជាប្រធាន អនុប្រធាន និងលេខាធិការនៃគណៈកម្មការនានារបស់រដ្ឋសភានៅក្នុងពេលជាមួយគ្នា និងការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តចំពោះការបង្កើតរាជរដ្ឋាភិបាល។[240]

ការរៀបចំបញ្ជីរាយនាមបេក្ខជនដើម្បីធ្វើការបោះឆ្នោតជ្រើសតាំង និងផ្តល់សេចក្តីទុកចិត្ត ត្រូវអនុវត្តន៍ទៅតាមនីតិវិធីដូចតទៅ៖

-បញ្ជីរាយនាមបេក្ខជនជាប្រធាន និងអនុប្រធានទី១ អនុប្រធានទី២នៃរដ្ឋសភា ក៏ដូចជា

[239] មាត្រា១១៩ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[240] មាត្រា៣រដ្ឋធម្មនុញ្ញបន្ថែមនៃព្រះរាជាណាចក្រកម្ពុជា។

ប្រធាន និងអនុប្រធានគណៈកម្មការជំនាញនានាទាំងអស់នៃរដ្ឋសភាត្រូវបានរៀបចំនិងស្នើឡើងដោយគណបក្សនយោបាយណាមួយដែលព្រមព្រៀងគ្នា ដើម្បីបង្កើតរាជរដ្ឋាភិបាលចម្រុះ ហើយត្រូវផ្ញើជូនព្រឹទ្ធសមាជិក[241]នៃរដ្ឋសភា។

-តាមសេចក្តីស្នើ អំពីគណបក្សនយោបាយ ដែលមានចំនួនអាសនៈច្រើនជាងគេនៅក្នុងរដ្ឋសភា តាមរយៈព្រឹទ្ធសមាជិកនៃរដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូបក្នុងចំណោមតំណាងរាស្ត្រនៃគណបក្សនយោបាយ ដែលឈ្នះឆ្នោត ដើម្បីបង្កើតរាជរដ្ឋាភិបាល។ វរជនដែលត្រូវបានចាត់តាំងនោះ ត្រូវរៀបចំផ្គូរផ្គងឲ្យកាន់តំណែងផ្សេងៗ នៅក្នុងរាជរដ្ឋាភិបាល រួចផ្ញើបញ្ជីរាយនាមសមាជិកគណៈរដ្ឋមន្ត្រីទាំងអស់ដើម្បីជូនមកព្រឹទ្ធសមាជិកនៃរដ្ឋសភា។

-ព្រឹទ្ធសមាជិករបស់រដ្ឋសភា ត្រូវរៀបចំបញ្ជីរាយនាមដាក់ជាកញ្ចប់មួយនូវបេក្ខជនដែលជាប្រធាន អនុប្រធាននៃរដ្ឋសភា ក៏ដូចជាប្រធាន និងអនុប្រធានគណៈកម្មការជំនាញទាំងអស់នៃរដ្ឋសភា។ ព្រមទាំងបេក្ខជននាយករដ្ឋមន្ត្រី និងសមាជិកទាំងអស់របស់រាជរដ្ឋាភិបាល ដើម្បីដាក់ជូនរដ្ឋសភាបោះឆ្នោតអនុម័តដើម្បីផ្តល់សេចក្តីទុកចិត្ត។[242]

នៅក្នុងដំណើរការនៃការបោះឆ្នោតជាកញ្ចប់នេះ សមាជិករដ្ឋសភាមិនអាចជជែកពិភាក្សាអ្វីឡើយ ហើយក៏មិនអាចមានការពន្យល់អ្វីអំពីការបោះឆ្នោតនេះ ក្រោយការប្រកាសលទ្ធផលនៃការបោះឆ្នោតជាកញ្ចប់នេះដែរ។

សមាជិករដ្ឋសភា ត្រូវធ្វើការបោះឆ្នោតជាកញ្ចប់ គឺអនុមត័ព្រម ឬមិនព្រមចំពោះបញ្ជីរាយនាមជាកញ្ចប់មួយដែលព្រឹទ្ធសមាជិករដ្ឋសភាបានដាក់ជូន។ ការបោះឆ្នោតអនុម័តនេះ គឺត្រូវធ្វើឡើងទៅតាមនីតិវិធីដោយការលើកដៃ។[243]

ការបោះឆ្នោតអនុម័តជាកញ្ចប់ត្រូវអនុម័ត យកសម្លេងតាមមតិភាគច្រើនដាច់ខាត(50+1)នៃចំនួនសមាជិករដ្ឋសភាទាំងមូល។

ក្នុងករណីការបោះឆ្នោតជុំទីមួយមិនបានសម្រេចទេ ត្រូវអនុវត្តន៍តាមនីតិវិធីដដែលៗនេះចំពោះការបោះឆ្នោតនៅជុំក្រោយៗជាបន្តបន្ទាប់ទៀត។[244]

ជាទូទៅការបង្កើតរាជរដ្ឋាភិបាលនៅក្នុងរបបសភានិយមគឺត្រូវធ្វើយ៉ាងណាដើម្បីស្វែងរកអំណាចឲ្យមានតុល្យភាពនឹងគ្នារវាងរដ្ឋសភា និងរាជរដ្ឋាភិបាល។ ដោយផ្អែកលើទ្រឹស្តីតុល្យភាព

[241] ព្រឹទ្ធសមាជិក គឺសំដៅដល់សមាជិកណាដែលមានអាយុច្រើនជាងនៅក្នុងរដ្ឋសភា ឬព្រឹទ្ធសភា។

[242] មាត្រា៤រដ្ឋធម្មនុញ្ញបន្ថែមនៃព្រះរាជាណាចក្រកម្ពុជា។

[243] មាត្រា៥រដ្ឋធម្មនុញ្ញបន្ថែមនៃព្រះរាជាណាចក្រកម្ពុជា។

[244] មាត្រា៥រដ្ឋធម្មនុញ្ញបន្ថែមនៃព្រះរាជាណាចក្រកម្ពុជា។

នេះគឺទាមទារឲ្យដាក់ស្ថាប័នទាំងពីរនេះមានភាពស្មើគ្នា ក៏ប៉ុន្តែតាមការអនុវត្តជាក់ស្តែងបញ្ហានេះពិបាករកបានណាស់។

ស្របតាមការវិវឌ្ឍន៍របស់សង្គមជាតិការអនុវត្តរបបសភានិយមនៅក្នុងពិភពលោក យើងសង្កេតឃើញថា មានពីរករណីគឺមានការគៀបសង្កត់អំណាចពីរាជរដ្ឋាភិបាលទៅលើរដ្ឋសភា និងរដ្ឋសភាមានអំណាចគៀបសង្កត់ទៅលើរាជរដ្ឋាភិបាល។

នៅប្រទេសអង់គ្លេស គេបានអនុវត្តន៍របបសភានិយមដែរ ប៉ុន្តែបែរជារាជរដ្ឋាភិបាលមានសកម្មភាពមានអំណាច គ្របដណ្តប់ទៅលើអំណាចនយោបាយដឹកនាំរដ្ឋសភា ព្រមទាំងមានការណែនាំការងាររបស់រដ្ឋសភាដែលត្រូវបំពេញសកម្មភាពនោះដើម្បីជួយសម្រួលការងារផ្សេងៗដល់រាជរដ្ឋាភិបាលក្នុងការបំពេញសកម្មភាពរបស់ខ្លួនឲ្យកាន់តែមានប្រសិទ្ធភាពឡើង។

នៅប្រទេសបារាំង គេបានអនុវត្តន៍ជាបន្តរហូតដល់ឆ្នាំ១៩៥៨ គឺរដ្ឋសភាជាអ្នកមានសិទ្ធិអំណាចគ្របដណ្តប់ទៅលើរដ្ឋាភិបាល ដោយរដ្ឋសភាសំអាងថា រដ្ឋាភិបាលបានបង្កើតឡើងតាមរយៈរដ្ឋសភា ហើយតំណាងឆន្ទៈជាតិមានលក្ខណៈតិចជាងរដ្ឋសភា។

ហេតុនេះ ដើម្បីឲ្យដំណើរការជាតួបនីយកម្មអំណាច ហើយអាចអនុវត្តន៍របបមួយ ដែលមានលទ្ធិប្រជាធិបតេយ្យពិតប្រាកដគឺទាមទារឲ្យមាន:

-ប្រជាពលរដ្ឋទាំងមូល ត្រូវមានមនសិការច្បាស់លាស់ ហើយត្រូវដឹងថា ខ្លួនជាម្ចាស់ដើមបំផុតនៃអំណាច ហើយខ្លួនត្រូវទាមទារឲ្យមានការត្រួតពិនិត្យ និងការប្រើប្រាស់អំណាចរបស់អ្នកដឹកនាំត្រូវហើយមានមធ្យោបាយក្នុងការអនុវត្តន៍អំណាចនេះផងដែរ។

-រដ្ឋាភិបាល ឬអ្នកដឹកនាំរដ្ឋ ត្រូវយល់ព្រមទទួលយកនូវការប្រើប្រាស់អំណាចរបស់ប្រជាពលរដ្ឋ និងការត្រួតពិនិត្យមកលើអំណាចមួយ រួមទាំងអាជ្ញាធររបស់ខ្លួន។[245]

២-លក្ខខណ្ឌបេក្ខភាពនាយករដ្ឋមន្ត្រី

(Conditional of Prime Minister Candidature)

អាចជាបេក្ខភាពនាយករដ្ឋមន្ត្រីបានត្រូវមានលក្ខខណ្ឌពីរៈ

-ជាច់ខាតត្រូវតែជាតំណាងរាស្ត្រនៅក្នុងមណ្ឌលណាមួយ ។

-ជាតំណាងរាស្ត្រស្ថិតនៅក្នុងគណបក្សដែលឈ្នះឆ្នោតនៅក្នុងរដ្ឋសភា ។

នាយករដ្ឋមន្ត្រីត្រូវតែជាសមាជិករដ្ឋសភា រីឯសមាជិករាជរដ្ឋាភិបាលឯទៀតៗអាចជ្រើសរើសពីក្នុងចំណោមសមាជិករដ្ឋសភា ឬក្រៅពីសមាជិករដ្ឋសភា ក៏ប៉ុន្តែអាចជាសមាជិកគណបក្សណា

[245] សុន្ទរកថា ដែលថ្លែងដោយឯកឧត្តម ងួន ញ៉ិល ធ្វើឡើងនៅថ្ងៃទី២៣-២៤ ខែឧសភា ឆ្នាំ២០០០ នៅវិមានរដ្ឋាភិបាលវត្តភ្នំ។

មួយដែលមានតំណាងនៅក្នុងរដ្ឋសភា សមាជិករាជរដ្ឋាភិបាលទាំងអស់ ត្រូវតែងតាំងដោយព្រះរាជក្រឹត្យក្រោយពីបានសេចក្តីអនុម័តផ្តល់សេចក្តីទុកចិត្តពីរដ្ឋសភារួចហើយ។

ខ.សមាសភាពរាជរដ្ឋាភិបាល

(Royal Government Composition)

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា គឺជាអង្គការនីតិប្រតិបត្តិដែលមានភារកិច្ចកំណត់ និងអនុវត្តន៍នយោបាយរបស់រដ្ឋ ស្របតាមគោលការណ៍ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ រាជរដ្ឋាភិបាលធានាដល់ការអនុវត្តន៍ច្បាប់ និងដឹកនាំកិច្ចការទាំងឡាយទូទៅរបស់រដ្ឋលើកលែងតែកិច្ចការណាដែលជាសមត្ថកិច្ចរបស់អង្គនីតិប្បញ្ញត្តិ និងអង្គការតុលាការតែប៉ុណ្ណោះ។[246]

រាជរដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជាគ្រប់គ្រងបញ្ជាប្រើប្រាស់យោធា នគរបាល កម្លាំងប្រដាប់អាវុធផ្សេងៗទៀត និងការងាររដ្ឋបាលក្នុងការធ្វើសកម្មភាពផ្សេងៗរបស់ខ្លួនបាន។[247]

រាជរដ្ឋាភិបាល ដឹកនាំកិច្ចការទូទៅរបស់រដ្ឋ តាមកម្មវិធីនយោបាយ និងផែនការរបស់រដ្ឋដែលរដ្ឋសភាបានអនុម័ត។[248]

សមាសភាពនៃសមាជិករាជរដ្ឋាភិបាល ឬសមាជិកគណៈរដ្ឋមន្ត្រីរួមមាន:

-ឧបនាយករដ្ឋមន្ត្រី

-ទេសរដ្ឋមន្ត្រី

-រដ្ឋមន្ត្រី

សមាជិករាជរដ្ឋាភិបាលកម្ពុជាទាំងអស់ ត្រូវបានតែងតាំង ដោយព្រះរាជក្រឹត្យក្រោយពីបានផ្តល់សេចក្តីអនុម័តទុកចិត្តពីរដ្ឋសភារួចហើយ។[249]

រដ្ឋលេខាធិការ មិនមែនជាសមាជិករាជរដ្ឋាភិបាលទេ ក៏ប៉ុន្តែត្រូវបានតែងតាំងដោយព្រះមហាក្សត្រតាមរយៈព្រះរាជក្រឹត្យតាមសំណើរបស់លោកនាយករដ្ឋមន្ត្រី។

អនុរដ្ឋលេខាធិការមិនមែនជាសមាជិករាជរដ្ឋាភិបាល ឬសមាជិកគណៈរដ្ឋមន្ត្រីទេ ហើយក៏មិនមែនជាភ្នាក់ងារ រដ្ឋបាលអចិន្ត្រៃយ៍ដែរ នៅពេលណាដែលរាជរដ្ឋាភិបាលត្រូវបានលាលែង ឬរំលាយហានៈអនុរដ្ឋលេខាធិការក៏ត្រូវអស់តំណែងដែរ។[250]

---

[246] មាត្រា១ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី។

[247] មាត្រា២ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី។

[248] មាត្រា៣ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី។

[249] មាត្រា៤ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី។

[250] មាត្រា៧ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី។

នៅពេលផុតនីតិកាលរបស់រដ្ឋសភាឬនៅពេលផ្លាស់ប្តូររាជរដ្ឋាភិបាល រាជរដ្ឋាភិបាលដែលត្រូវចេញពីតំណែងមានភារកិច្ចដឹកនាំការងារប្រចាំថ្ងៃតែប៉ុណ្ណោះ។

គ.គណៈរដ្ឋមន្ត្រី និងសមត្ថកិច្ចនាយករដ្ឋមន្ត្រី

(Cabinet of Minister and Prime-minister Competency)

១-គណៈរដ្ឋមន្ត្រី

(Cabinet of Minister)

រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា បានផ្តល់អំណាចដល់សមាជិកផ្សេងៗទៀតរបស់រាជរដ្ឋាភិបាល ដើម្បីឲ្យអនុវត្តន៍រួមគ្នាក្នុងក្របខ័ណ្ឌគណៈរដ្ឋមន្ត្រី ដែលមានលក្ខណៈជាសហសេវិកដែលតួនាទីទាំងនោះរួមមាន:

គណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលត្រូវបានចូលរួមរាយការណ៍ ដើម្បីទូលថ្វាយដល់ព្រះមហាក្សត្រ ជាមួយនាយករដ្ឋមន្ត្រីដើម្បីបានជ្រាបជាពត៌មានអំពីសភាពការណ៍នានារបស់ប្រទេសជាតិឲ្យបានពីរដងក្នុង១ខែ។[251]

តាមសេចក្តីស្នើរបស់គណៈរដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខា នៅលើព្រះរាជក្រឹត្យតែងតាំង ផ្លាស់ប្តូរ បញ្ចប់ភារកិច្ចរបស់មន្ត្រីជាន់ខ្ពស់ស៊ីវិលយោធា ឯកអគ្គរាជទូត និងប្រេសិតវិសាមញ្ញ និងពេញសមត្ថភាព។[252]

តាមសេចក្តីស្នើសុំពីគណៈរដ្ឋមន្ត្រី ព្រះមហាក្សត្រ ទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឲ្យប្រើរដ្ឋធម្មនុញ្ញ ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ និងទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យ។[253]

តាមសេចក្តីស្នើសុំពីគណៈរដ្ឋមន្ត្រី ព្រះមហាក្សត្រ ទ្រង់បង្កើត និងប្រទានគ្រឿងឥស្សរិយយសជាតិ។ ព្រះមហាក្សត្រទ្រង់សម្រេចប្រទានឋានន្តរសក្តិ ឋានៈ យោធា និងស៊ីវិលទៅតាមការកំណត់របស់ច្បាប់។[254]

គណៈរដ្ឋមន្ត្រីត្រូវប្រជុំការងារជារៀងរាល់សប្តាហ៍គឺជាការប្រជុំធំ ឬក៏ជាការប្រជុំត្រួតពិនិត្យស្រាវជ្រាវ អង្គប្រជុំធំជាទូទៅត្រូវតែដឹកនាំដោយនាយករដ្ឋមន្ត្រី ហើយដែលនាយករដ្ឋមន្ត្រីអាចប្រគល់ភារកិច្ចដូនឧបនាយករដ្ឋមន្ត្រីឲ្យដឹកនាំអង្គប្រជុំពិនិត្យស្រាវជ្រាវបាន។

---

[251] មាត្រា២០រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[252] មាត្រា២១រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[253] មាត្រា២៨រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[254] មាត្រា២៩រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

កំណត់ហេតុនៃការប្រជុំទាំងអស់របស់គណៈរដ្ឋមន្ត្រី ត្រូវតែផ្ញើថ្វាយព្រះមហាក្សត្រដើម្បីទ្រង់បានជ្រាប។[255]

២-កិច្ចប្រជុំគណៈរដ្ឋមន្ត្រី

(Meeting of Cabinet of Minister)

ការប្រជុំនៅទីស្តីការគណៈរដ្ឋមន្ត្រី ជាទូទៅអាចប្រជុំជាដំណាក់កាលដូចតទៅ:

២.១.កិច្ចប្រជុំលើកទី១

(First Meeting)

កិច្ចប្រជុំលើកទី១ គឺជាកិច្ចប្រជុំ ដែលធ្វើឡើងដោយមានការចូលរួម មកពីតំណាងក្រសួង និងស្ថាប័ននានារបស់រដ្ឋជាមួយបណ្តាក្រុមប្រឹក្សា មានក្រុមប្រឹក្សាអ្នកច្បាប់ និងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។

កិច្ចប្រជុំអាចដំណើរការប្រព្រឹត្តទៅលើការពិនិត្យ និងកែសម្រួលលើទិដ្ឋភាពទាំងទម្រង់ទាំងខ្លឹមសារគតិយុត្តនានា រួមទាំងផលប៉ះពាល់ផ្នែកច្បាប់ ផ្នែកសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងគោលនយោបាយរបស់រាជរដ្ឋាភិបាលផងដែរ។

កិច្ចប្រជុំលើកទី១ ត្រូវបានដឹកនាំអង្គប្រជុំជាសហប្រធាន ដែល១រូបមកពីក្រុមប្រឹក្សាអ្នកច្បាប់ ១រូបមកពីក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។

គ្រប់លិខិតបទដ្ឋានគតិយុត្តនានា ឬសេចក្តីព្រាងច្បាប់ ឬសេចក្តីព្រាងអនុក្រឹត្យ និងគោលនយោបាយទាំងឡាយរបស់រាជរដ្ឋាភិបាល ដែលបានបញ្ជូនមកពីបណ្តាក្រសួង និងស្ថាប័នរដ្ឋនានាត្រូវឆ្លងកាត់ការប្រជុំត្រួតពិនិត្យនៃកិច្ចប្រជុំលើកទី១នេះជាមុនសិន។

ក្រោយពីការប្រជុំត្រួតពិនិត្យ និងផ្តល់យោបល់ លើកិច្ចប្រជុំលើកទីមួយនេះរួចហើយ ទើបលិខិតបទដ្ឋានគតិយុត្តនានា សេចក្តីព្រាងច្បាប់ សេចក្តីព្រាងអនុក្រឹត្យព្រមទាំងគោលនយោបាយទាំងឡាយរបស់រាជរដ្ឋាភិបាលត្រូវដាក់បញ្ចូលទៅក្នុងកិច្ចប្រជុំអន្តរក្រសួងបន្តទៅទៀត។

២.២.កិច្ចប្រជុំអន្តរក្រសួង

(Inter Ministries Meeting)

ការប្រជុំអន្តរក្រសួងត្រូវបានដឹកនាំអង្គប្រជុំដោយនាយករដ្ឋមន្ត្រីផ្ទាល់ ឬដោយឧបនាយករដ្ឋមន្ត្រីណាម្នាក់តាមរយៈការប្រគល់សិទ្ធិពីនាយករដ្ឋមន្ត្រី ដើម្បីដឹកនាំការប្រជុំការងារ ក៏ប៉ុន្តែអាចប្រគល់តួនាទីជូនទៅរដ្ឋលេខាធិការនៅទីស្តីការគណៈរដ្ឋមន្ត្រី ឬអគ្គលេខាធិការរាជរដ្ឋាភិបាលជា

[255] មាត្រា១២៣រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

អ្នកដឹកនាំការប្រជុំនោះក៏បាន។

ការប្រជុំអន្តរក្រសួងនេះគឺត្រូវមានការចូលរួមពីសាមីក្រសួង ពីក្រសួងពាក់ព័ន្ធ ពីតំណាងក្រុមប្រឹក្សាអ្នកច្បាប់ពីតំណាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងនាយកដ្ឋានជំនាញរបស់ទីស្តីការគណៈរដ្ឋមន្ត្រី។

ការប្រជុំនេះ ដំណើរការប្រព្រឹត្តទៅដូចការប្រជុំតាមជំនាញបច្ចេកទេសដែរ ប៉ុន្តែមានការចូលរួមពីសំណាក់ តំណាងក្រសួង ស្ថាប័ននានា ដែលមានលក្ខណៈទូលំទូលាយជាងកិច្ចប្រជុំជាធម្មតា ហើយធ្វើការពិនិត្យកែសម្រួល និងផ្តល់យោបល់រួចទើបដាក់ចូលទៅក្នុងកិច្ចប្រជុំពេញអង្គរបស់គណៈរដ្ឋមន្ត្រីតែម្តង។

២.៣.កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី

(Gather Meeting of Cabinet of Minister)

ការប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ត្រូវដឹកនាំដោយនាយករដ្ឋមន្ត្រីផ្ទាល់ កិច្ចប្រជុំនេះ ត្រូវធ្វើឡើងនៅទីស្តីការគណៈរដ្ឋមន្ត្រី ដែលមានសមាសភាពអ្នកចូលរួមមាន: ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋមន្ត្រីជាប្រតិភូអមនាយករដ្ឋមន្ត្រី។

កិច្ចប្រជុំពេញអង្គត្រូវបានរៀបចំតាមរបៀបវារៈដោយអគ្គលេខាធិការរបស់រាជរដ្ឋាភិបាលដែលបានការអនុញ្ញាតពីនាយករដ្ឋមន្ត្រី។ បន្ទាប់មករបៀបវារៈនោះ ត្រូវផ្ញើជូនសមាជិករាជរដ្ឋាភិបាលទាំងអស់ ព្រមទាំងអ្នកពាក់ព័ន្ធទាំងឡាយ ដែលជាប់ទាក់ទងទៅនឹងបញ្ហានានា ដែលមានចែងនៅក្នុងរបៀបវារៈ។

អគ្គលេខាធិការនៃរាជរដ្ឋាភិបាល គឺត្រូវចូលរួមប្រជុំគ្រប់កិច្ចប្រជុំនានារបស់គណៈរដ្ឋមន្ត្រី និងជាអ្នករៀបចំធ្វើរបាយការណ៍សង្ខេបខ្លឹមសារនៃសេចក្តីសម្រេចរបស់គណៈរដ្ឋមន្ត្រីជាឯកសារសង្ខេប និងឯកសារវិភាគ ផ្តល់យោបល់គ្រប់បែបយ៉ាង ដែលឯកសារទាំងនេះត្រូវតម្កល់ទុកនៅទីស្តីការគណៈរដ្ឋមន្ត្រី។

អគ្គលេខាធិការ១រូប អមដោយអគ្គលេខាធិការរងនៃរាជរដ្ឋាភិបាលដែលជាអ្នកដឹកនាំអគ្គលេខាធិការដ្ឋាន ដែលជាសេនាធិការផ្ទាល់បម្រើឲ្យរាជរដ្ឋាភិបាល ហើយបំពេញសកម្មភាពផ្សេងទៀត ក្នុងការសម្របសម្រួលការងាររបស់រាជរដ្ឋាភិបាល ក្នុងការធ្វើទំនាក់ទំនងជាមួយអង្គការរដ្ឋសភា ដែលពាក់ព័ន្ធការងារបច្ចេកទេសនានា ព្រមទាំងការងាររដ្ឋបាលទាំងឡាយដោយការទទួលការងារផ្ទាល់ពីនាយករដ្ឋមន្ត្រី។

អគ្គលេខាធិការរាជរដ្ឋាភិបាលទាមទារឲ្យមានសមត្ថភាពខ្ពស់ ក្នុងការបំពេញសកម្មភាពទាំងផ្នែកបច្ចេកទេសទាំងផ្នែកនយោបាយ។

សេចក្តីជូនដំណឹងជាផ្លូវការ ដែលត្រូវបានផ្តល់យោបល់ និងតែងតាំងរួចហើយត្រូវបានអ្នកនាំពាក្យនៃរាជរដ្ឋាភិបាល ត្រូវធ្វើអត្ថាធិប្បាយ នៅពេលការប្រជុំគណៈរដ្ឋមន្ត្រីបានបញ្ចប់ភ្លាមហើយត្រូវធ្វើការផ្សព្វផ្សាយជាបន្ទាន់។

ក្រោយពីកិច្ចប្រជុំពេញអង្គ គណៈរដ្ឋមន្ត្រីបានត្រួតពិនិត្យ និងសម្រេចចប់សព្វគ្រប់ហើយលិខិតបទដ្ឋានគតិយុត្តទាំងឡាយនោះត្រូវយកទៅអនុវត្តន៍ភ្លាមតែម្តងក្រោយពីនាយករដ្ឋមន្ត្រីបានចុះហត្ថលេខា។ ក៏ប៉ុន្តែប្រសិនបើលិខិតបទដ្ឋានគតិយុត្តទាំងឡាយណា ដែលត្រូវដាក់ជូនរដ្ឋសភា និងព្រឹទ្ធសភាត្រូវបញ្ជូនទៅតាមនីតិវិធីច្បាប់ជាបន្តបន្ទាប់ទៅទៀត។

៣-តួនាទី និងសមត្ថកិច្ចនាយករដ្ឋមន្ត្រី

(Roles and Competence of Prime-Minister)

នាយករដ្ឋមន្ត្រី ជាប្រមុខរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា មានភារកិច្ចទទួលខុសត្រូវរួមគ្នាជាមួយសមាជិកទាំងឡាយនៃរាជរដ្ឋាភិបាល នៅចំពោះមុខរដ្ឋសភាអំពីនយោបាយទូទៅ និងអំពីសកម្មភាពរួមរបស់រាជរដ្ឋាភិបាលទាំងមូល។[256]

-នាយករដ្ឋមន្ត្រី ជាអ្នកដឹកនាំការងារទាំងមូលរបស់គណៈរដ្ឋមន្ត្រី។

- នាយករដ្ឋមន្ត្រីមានសិទ្ធិអំណាចចេញបទបញ្ជាចាំបាច់នានា ដើម្បីអនុវត្តន៍ច្បាប់ដែលរដ្ឋសភាបានអនុម័ត ដែលមានដូចជាច្បាប់ អនុក្រឹត្យ និងសេចក្តីសម្រេចផ្សេងៗ។

- នាយករដ្ឋមន្ត្រី ត្រូវដឹកនាំការងាររបស់គណៈរដ្ឋមន្ត្រី និងចាត់ចែងបញ្ជារាល់សកម្មភាពរបស់រាជរដ្ឋាភិបាលទាំងមូលលើគ្រប់វិស័យ។

- នាយករដ្ឋមន្ត្រីជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំគណៈរដ្ឋមន្ត្រី។ ការប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីត្រូវដោះស្រាយ និងសម្រេចនូវរាល់កិច្ចការទូទៅរបស់រាជរដ្ឋាភិបាលទាំងមូល។

- នាយករដ្ឋមន្ត្រីអាចប្រគល់សិទ្ធិជូនទៅសមាជិករាជរដ្ឋាភិបាលណាម្នាក់ ដើម្បីធ្វើការកោះប្រជុំ និងធ្វើជាអធិបតីភាពនៃអង្គប្រជុំអន្តរក្រសួងបាន ប៉ុន្តែគ្មានសិទ្ធិសម្រេចក្នុងនាមជារាជរដ្ឋាភិបាលបានឡើយ។

- នាយករដ្ឋមន្ត្រី ដឹកនាំការចរចា និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងអន្តរជាតិផ្សេងៗ មានដូចជា: វិស័យពាណិជ្ជកម្ម កិច្ចសហប្រតិបត្តិការ សេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រ បច្ចេកទេស ការពារជាតិ និងលើគ្រប់វិស័យផ្សេងៗទៀត។

- នាយករដ្ឋមន្ត្រី ដឹកនាំធ្វើកិច្ចព្រមព្រៀងផ្សេងៗជាមួយបណ្តាប្រមុខរដ្ឋាភិបាលនៃបណ្តា

[256] មាត្រា៨ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី។

ប្រទេសដទៃទៀត ដែលមានកិច្ចព្រមព្រៀងពាណិជ្ជកម្ម វិស័យយោធា និងបណ្តាជំនួយនានារបស់បរទេស ឬអង្គការអន្តរជាតិផ្សេងៗ។

- នាយករដ្ឋមន្ត្រី អាចប្រកាសទទួលស្គាល់រដ្ឋាភិបាលនៃប្រទេសណាមួយផ្សេងទៀតបានក្នុងនាមជាប្រមុខការទូតនៃប្រទេសជាតិមួយ។

- នាយករដ្ឋមន្ត្រីចុះហត្ថលេខាលើអនុក្រឹត្យ លើសេចក្តីសម្រេច និងសារាចរផ្សេងៗរបស់គណៈរដ្ឋមន្ត្រី និងលើលិខិតបទដ្ឋានទាំងឡាយ ដែលមានអានុភាពគតិយុត្តទូទៅរបស់រាជរដ្ឋាភិបាលហើយត្រូវចុះក្នុងរាជកិច្ច។[257]

-នាយករដ្ឋមន្ត្រី លើកសំណើដល់គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ដើម្បីធ្វើការកោះប្រជុំរដ្ឋសភាជាវិសាមញ្ញ ដោយលើកសំណើ ស្តីអំពីសេចក្តីព្រាងច្បាប់ និងសំណើតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចរបស់សមាជិករាជរដ្ឋាភិបាលនានា ជូនរដ្ឋសភាជាតិ ដើម្បីធ្វើការអនុម័ត និងសម្រេច។

- នាយករដ្ឋមន្ត្រីមានភារកិច្ចត្រួតពិនិត្យលើការងារសកម្មភាពនានា និងការរៀបចំផែនការសេដ្ឋកិច្ចជាតិ រៀបចំថវិកាជាតិ និងការរៀបចំផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិរយៈពេលវែង។

- នាយករដ្ឋមន្ត្រីត្រូវលើកសំណើថ្វាយព្រះមហាក្សត្រ ដើម្បីតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចដោយព្រះរាជក្រឹត្យនូវមន្ត្រីរាជការជាន់ខ្ពស់ស៊ីវិល នគរបាល និងយោធាដូចតទៅ[258]៖

+ ទេសាភិបាល ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា។
+ ទីប្រឹក្សារាជរដ្ឋាភិបាល ទីប្រឹក្សានាយករដ្ឋមន្ត្រី។
+ អគ្គលេខាធិការរាជរដ្ឋាភិបាល។
+ អគ្គលេខាធិការក្រសួង អគ្គនាយកក្រសួង។
+ ប្រតិភូរាជរដ្ឋាភិបាល។
+ អភិបាលខេត្ត-រាជធានី។
+ ឯកអគ្គរាជទូត។
+ ប្រេសិតវិសាមញ្ញ និងពេញសមត្ថភាព។
+ នាយអគ្គសេនាធិការ និងនាយអគ្គសេនាធិការរង។
+ ឧត្តមសេនីយ៍ឡើងទៅ។

[257] មាត្រា៩ដល់មាត្រា១៣ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី។

[258] មាត្រា១៤ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី។

មុខងារ និងក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ស៊ីវិល និងយោធាមួយចំនួនផ្សេងៗទៀត នឹងត្រូវបានតែងតាំង ផ្លាស់ប្តូរ បញ្ចប់ភារកិច្ច ដោយព្រះរាជក្រឹត្យដែរ ស្របតាមការកំណត់ក្នុងលិខិតបទដ្ឋានដោយឡែកដែលបង្កើតដោយស្ថាប័ននោះ។

- នាយករដ្ឋមន្ត្រីជាអ្នកតែងតាំងផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចដោយចេញអនុក្រឹត្យនូវរាល់មន្ត្រីជាន់ខ្ពស់ស៊ីវិល យោធា មន្ត្រីការទូត ភារធារី ឬអគ្គកុងស៊ុល អគ្គនាយករង អគ្គលេខាធិការរងក្រសួង ប្រធាននាយកដ្ឋាន និងអភិបាលរងខេត្ត រាជធានី អភិបាលស្រុក ខណ្ឌ ដូចដែលមិនមានចែងក្នុងមាត្រា១៤ លើកលែងតែមន្ត្រីដែលមានចែងក្នុងមាត្រា២៨នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី។[259]

- នាយករដ្ឋមន្ត្រីមានភារកិច្ចត្រួតពិនិត្យការងារសកម្មភាពនានានៃការរៀបចំ និងការប្រព្រឹត្តទៅ និងការទទួលខុសត្រូវរបស់សមាជិករាជរដ្ឋាភិបាល ហើយមានសិទ្ធិដក និងដាក់ជំនួសនូវសមាជិករាជរដ្ឋាភិបាលតាមបែបបទ និងនីតិវិធីជាធរមាន។

- នាយករដ្ឋមន្ត្រី ជាអ្នកកំណត់ក្របខ័ណ្ឌសកម្មភាពទូទៅរបស់ក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងការពារជាតិជាអ្នកទទួលខុសត្រូវលើផ្នែករដ្ឋបាលទូទៅ និងជាអ្នកផ្តល់សម្ភារៈ និងថវិកាសម្រាប់ផ្គត់ផ្គង់កសាងកម្លាំងរាជអាវុធហត្ថ។

អគ្គសេនាធិការកងយោធពលខេមរភូមិន្ទមានភារៈគ្រប់គ្រងសំដៅហ្វឹកហ្វឺនកសាងរៀបចំកងរាជអាវុធហត្ថឲ្យរីកចម្រើន ដើម្បីមានសមត្ថភាពគ្រប់គ្រាន់ ក្នុងការជានាវ៉ាប់រងតួនាទី និងភារកិច្ចរបស់ខ្លួនបានល្អប្រសើរ។[260]

- នាយករដ្ឋមន្ត្រី ជាអ្នកសម្រេចកំណត់ភារកិច្ច ចំពោះកងកម្លាំងអាវុធហត្ថមួយចំនួនជាក់ស្តែង ក្នុងការតែងតាំង និងការរៀបចំស្ថាប័នលើសំណើមេបញ្ជាការ និងអធិការកងរាជអាវុធហត្ថដែលបានពិភាក្សា ផ្លាស់ប្តូរយោបល់ជាមួយសហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអគ្គលេខាធិការកងយោធពលខេមរភូមិន្ទ។[261]

- ក្នុងករណីពិសេស ឬករណីប្រធានសក្តិណាមួយ នាយករដ្ឋមន្ត្រីមានសិទ្ធិ ក្នុងការបញ្ជាចំណាយ ក្រៅពីការកំណត់ក្នុងថវិកាជាតិ ដើម្បីដោះស្រាយកិច្ចការចាំបាច់ និងបន្ទាន់ រួចហើយរាយការណ៍ជូនរដ្ឋសភាភ្លាម។[262]

---

[259] មាត្រា១៥ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី។

[260] មាត្រា២ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាវុធហត្ថ។

[261] មាត្រា១៤ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាវុធហត្ថ។

[262] មាត្រា ១៦ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី។

- នាយករដ្ឋមន្ត្រីមានសិទ្ធិផ្តួចផ្តើមធ្វើសេចក្តីព្រាងច្បាប់ ការផ្តើមគំនិតសើរើ និងធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ។[263]

- នាយករដ្ឋមន្ត្រីមានសិទ្ធិបញ្ជូនច្បាប់ដែលរដ្ឋសភា និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ ទៅឲ្យក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីពិនិត្យអំពីធម្មនុញ្ញភាពនៃច្បាប់បាន នៅមុនពេលត្រូវបានប្រកាសឲ្យប្រើច្បាប់នោះ។

- នាយករដ្ឋមន្ត្រីមានសិទ្ធិបញ្ជូនច្បាប់នានា ដែលបានប្រកាសឲ្យប្រើរួចហើយ ទៅឲ្យក្រុមប្រឹក្សាធម្មនុញ្ញត្រួតពិនិត្យអំពីធម្មនុញ្ញភាពនៃច្បាប់នោះបាន។[264]

- នាយករដ្ឋមន្ត្រីមានសមត្ថកិច្ចបោះឆ្នោតជ្រើសរើសព្រះមហាក្សត្រថ្មី។[265]

- នាយករដ្ឋមន្ត្រី ដឹកនាំគណៈរដ្ឋមន្ត្រីចូលបង្គំគាល់ព្រះមហាក្សត្រពីរដងក្នុងមួយខែ និងរាយការណ៍ទូលថ្វាយ អំពីបញ្ហានយោបាយ សេដ្ឋកិច្ច និងសភាពការណ៍ទាំងឡាយរបស់ប្រទេសជាតិដើម្បីឲ្យព្រះមហាក្សត្រទ្រង់បានជ្រាប។[266]

- នាយករដ្ឋមន្ត្រីក៏អាចកោះអញ្ជើញឲ្យចូលរួមក្នុងសមាជជាតិបាន ដែលធ្វើឡើងមួយដងក្នុងមួយឆ្នាំនៅដើមខែធ្នូ។[267]

- នាយករដ្ឋមន្ត្រីចូលរួមផ្តល់មតិឯកភាពជាមួយប្រធានរដ្ឋសភា និងប្រធានព្រឹទ្ធសភានៅមុនពេលព្រះមហាក្សត្រ ទ្រង់ប្រកាសប្រទានដំណឹងជាសាធារណៈ ដាក់ប្រទេសជាតិស្ថិតនៅក្នុងភាពអាសន្ន។[268]

- នាយករដ្ឋមន្ត្រីមានសិទ្ធិស្នើសុំឲ្យរដ្ឋសភាប្រជុំជាសម្ងាត់បាន។[269]

៤-តួនាទី និងសមត្ថកិច្ចឧបនាយករដ្ឋមន្ត្រី

(Roles and Competence of Deputy Prime Minister)

ឧបនាយករដ្ឋមន្ត្រី ជាសមាជិករាជរដ្ឋាភិបាល ដែលមានអាសនានុក្រមខ្ពស់ជាងសមាជិករាជរដ្ឋាភិបាលដទៃទៀត។

---

[263] មាត្រា១៥១ថ្មីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ។

[264] មាត្រា១៤០ថ្មី មាត្រា១៤១ថ្មីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[265] មាត្រា១៣ថ្មីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[266] មាត្រា២០រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[267] មាត្រា១៤៨ថ្មីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[268] មាត្រា២២ថ្មីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[269] មាត្រា៨៨ថ្មីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

ឧបនាយករដ្ឋមន្ត្រីមានតួនាទី និងភារកិច្ចដូចតទៅ:

-ឧបនាយករដ្ឋមន្ត្រី ជួយការងារនាយករដ្ឋមន្ត្រី តាមការប្រគល់សិទ្ធិចំពោះ មុខពីនាយករដ្ឋមន្ត្រី។

-ឧបនាយករដ្ឋមន្ត្រី អាចបំពេញកិច្ចការទាំងឡាយបានតាមរយៈការប្រគល់សិទ្ធិអំពីនាយករដ្ឋមន្ត្រីក្នុងករណីដែលនាយករដ្ឋមន្ត្រីអវត្តមាន។

-កិច្ចការណា ដែលទាក់ទងនឹងការដឹកនាំរួមរបស់រាជរដ្ឋាភិបាល ប្រសិនបើគ្មានការយល់ព្រមពីនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រីគ្មានសិទ្ធិសម្រេចឡើយ។[270]

ក្នុងពេលឧបនាយករដ្ឋមន្ត្រី ទទួលកិច្ចការជំនួស តាមការប្រគល់សិទ្ធិចំពោះមុខនាយករដ្ឋមន្ត្រី ពេលនោះឧបនាយករដ្ឋមន្ត្រីមានតួនាទីជា "នាយករដ្ឋមន្ត្រីស្តីទី"។

៥-តួនាទី និងសមត្ថកិច្ចទេសរដ្ឋមន្ត្រី

(Roles and Competence Minister of State)

ទេសរដ្ឋមន្ត្រី មួយចំនួនមានតួនាទីជាអ្នកដឹកនាំក្រសួង និងទេសរដ្ឋមន្ត្រីមួយចំនួនទៀតមិនមានតួនាទីដឹកនាំក្រសួងទេ ប៉ុន្តែត្រូវទទួលបន្ទុកបេសកកម្មពិសេស អាចទទួលភារកិច្ចតាមការកំណត់របស់នាយករដ្ឋមន្ត្រី។[271]

ទេសរដ្ឋមន្ត្រី ទទួលបន្ទុកកិច្ចការជំជាងរដ្ឋមន្ត្រី ហើយតាមធម្មតាមានតួនាទី ជាអ្នកធ្វើការសម្របសម្រួលជាមួយរដ្ឋមន្ត្រីនៃក្រសួងស្ថាប័នដទៃទៀត។

ទេសរដ្ឋមន្ត្រី គឺមានសិទ្ធិអំណាចមិនខុសប្លែកអ្វីពីរដ្ឋមន្ត្រីទេ ប៉ុន្តែមានងារជាទេសរដ្ឋមន្ត្រីត្រូវបាននាយករដ្ឋមន្ត្រីផ្តល់ឲ្យទៅអ្នកណាម្នាក់ដើម្បីបញ្ជាក់អំពីការគោរពជាអ្នកនយោបាយដែលមានបទពិសោធន៍ច្រើនឆ្នាំជាងគេក្នុងឋានៈជាអតីតរដ្ឋមន្ត្រី ដែលនៅក្នុងគណៈរដ្ឋមន្ត្រីយូរឆ្នាំជាងតែប៉ុណ្ណោះ។

នៅក្នុងពិធីបុណ្យជាតិធំៗ ឬបុណ្យអន្តរជាតិ ឬការអញ្ជើញឲ្យចូលរួមក្នុងពីធីផ្លូវការអ្វីមួយ ទេសរដ្ឋមន្ត្រីត្រូវបានគេចាត់ទុកថាជាមនុស្សដែលមានអាទិភាពជាង។

ជាទូទៅ ទេសរដ្ឋមន្ត្រីអាចមានទីប្រឹក្សាបច្ចេសទេសមួយរូបឬច្រើនរូប និងមានជំនួយការជាច្រើនរូបទៀតដែលត្រូវទទួលបន្ទុកផ្សេងៗគ្នា។

នៅក្នុងរាជរដ្ឋាភិបាលអាណត្តិទី៤នៃរដ្ឋសភាមានទេសរដ្ឋមន្ត្រីចំនួន១៦រូប។

---

[270] មាត្រា១៩ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី។

[271] មាត្រា២០ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី។

នៅក្នុងរាជរដ្ឋាភិបាលអាណត្តិទី៥នៃរដ្ឋសភាមានទេសរដ្ឋមន្ត្រីចំនួន១៥រូប។
នៅក្នុងរាជរដ្ឋាភិបាលអាណត្តិទី៦នៃរដ្ឋសភាមានទេសរដ្ឋមន្ត្រីចំនួន១៧រូប។

៦-តួនាទី និងសមត្ថកិច្ចរដ្ឋមន្ត្រី

(Roles and Competence Minister)

រដ្ឋមន្ត្រីមានពីរប្រភេទ រដ្ឋមន្ត្រីមិនគ្រប់គ្រងក្រសួង និងរដ្ឋមន្ត្រីគ្រប់គ្រប់ក្រសួង។

រដ្ឋមន្ត្រីទាំងឡាយណា ដែលមិនដឹកនាំក្រសួង គឺអាចទទួលភារកិច្ចតាមការកំណត់របស់នាយករដ្ឋមន្ត្រីដែលមានរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី។

រដ្ឋមន្ត្រីទាំងឡាយណានៃរាជរដ្ឋាភិបាលដែលបានប្រគល់ភារកិច្ចក្នុងការដឹកនាំ គ្រប់គ្រងក្រសួង ឬរដ្ឋលេខាធិការដ្ឋានហៅថាប្រធានស្ថាប័ន។

នៅក្នុងភារកិច្ចដឹកនាំគ្រប់គ្រងក្រសួង រដ្ឋមន្ត្រីមានមុខងារពីរគឺ មុខងារជាអ្នកនយោបាយ និងមុខងារជាអ្នកដឹកនាំការងាររដ្ឋបាលទូទៅរបស់ក្រសួង។

នៅក្នុងតួនាទី ជាអ្នកនយោបាយ រដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលទទួលខុសត្រូវរួមគ្នាចំពោះមុខរដ្ឋសភាអំពីនយោបាយទូទៅរបស់រាជរដ្ឋាភិបាល និងទទួលខុសត្រូវចំពោះមុខនាយករដ្ឋមន្ត្រី និងចំពោះមុខរដ្ឋសភាអំពីការដែលខ្លួនបានប្រព្រឹត្ត។[272]

ក្នុងករណីដែលក្រសួងត្រូវបានដឹកនាំ និងគ្រប់គ្រងដោយសហរដ្ឋមន្ត្រី រដ្ឋមន្ត្រីទាំងពីរូបមានសិទ្ធិអំណាចស្មើគ្នា ហើយត្រូវឈរលើគោលការណ៍ជាសហព័ទ្ធសម្រេច។[273]

ក្រសួងដែលដឹកនាំដោយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការ រដ្ឋមន្ត្រីជាប្រធានស្ថាប័ន ឯរដ្ឋលេខាធិការជាអនុប្រធានស្ថាប័នហើយត្រូវអនុវត្តន៍ការកិច្ចទាំងនោះតាមការប្រគល់ឲ្យពីនាយករដ្ឋមន្ត្រី និងប្រធានស្ថាប័ន ត្រូវដឹកនាំការងារនៅក្នុងអង្គភាពចំណុះ តាមការទទួលខុសត្រូវផ្ទាល់របស់ខ្លួន រាល់បញ្ហាធំៗរបស់ក្រសួង រដ្ឋមន្ត្រីត្រូវពិគ្រោះយោបល់ជាមួយរដ្ឋលេខាធិការ មុនពេលធ្វើសេចក្តីសម្រេចជាស្ថាពរជាក្រោយ។

រដ្ឋមន្ត្រីគ្រប់គ្រងដឹកនាំបុគ្គលិកមន្ត្រីរាជការដែលជាភ្នាក់ងាររដ្ឋបាលកណ្តាល ភ្នាក់ងាររដ្ឋបាលថ្នាក់ក្រោមជាតិ និងមន្ត្រីរាជការដែលស្ថិតនៅក្រោមឱវាទរបស់ខ្លួន។

រដ្ឋមន្ត្រីមានសិទ្ធិលើកសំណើតែងតាំង ផ្លាស់ប្តូរ បញ្ចប់ភារកិច្ច នូវមន្ត្រីរាជការ នៅក្រោមឱវាទតាមបែបបទនីតិវិធីជាធរមានចាប់ពីនាយកដ្ឋានទៅដល់អគ្គនាយករង ឬអគ្គលេខាធិការរង

[272] មាត្រា១២១ថ្មីនៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ។

[273] មាត្រា២៣ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី។

ឬថ្នាក់ប្រហាក់ប្រហែលប្រគល់ជូននាយករដ្ឋមន្ត្រីដើម្បីចេញអនុក្រឹត្យ។

រដ្ឋមន្ត្រីមានសិទ្ធិតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការក្រោមឱវាទតាមបែបបទនីតិវិធីជាធរមាន ដែលត្រូវចេញដោយប្រកាសរបស់ក្រសួងចាប់ពីមន្ត្រីរាជការថ្នាក់ធម្មតារហូតដល់ថ្នាក់អនុប្រធាននាយកដ្ឋាន និងថ្នាក់ប្រហាក់ប្រហែល។[274]

រដ្ឋមន្ត្រីអាចចេញជាប្រកាសដើម្បីបង្កើត និងរៀបចំរចនាសម្ព័ន្ធក្រសួង ព្រមទាំងរដ្ឋលេខាធិការដ្ឋានចាប់ពីថ្នាក់អនុប្រធាននាយកដ្ឋានចុះក្រោម។

រដ្ឋមន្ត្រីមានសិទ្ធិចេញប្រកាសសេចក្តីសម្រេច និងសារាចរណែនាំផ្សេងៗបាន។

ជាទូទៅរដ្ឋមន្ត្រីអាចមានទីប្រឹក្សាបច្ចេសទេសមួយរូប ឬច្រើនរូប និងមានជំនួយការជាច្រើនរូបទៀតដែលត្រូវទទួលបន្ទុកផ្សេងៗគ្នា។

៧-តួនាទី និងសមត្ថកិច្ចរដ្ឋលេខាធិការ

(Roles and Competence Secretary of State)

រដ្ឋលេខាធិការមានបីប្រភេទដែលមាន រដ្ឋលេខាធិការស្វយ័ត រដ្ឋលេខាធិការអមទីស្តីការគណៈរដ្ឋមន្ត្រី ឬរដ្ឋលេខាធិការអមនាយករដ្ឋមន្ត្រី និងរដ្ឋលេខាធិការអមរដ្ឋមន្ត្រី។

៧.១.រដ្ឋលេខាធិការស្វយ័ត[275]

(Autonomous Secretary of State)

រដ្ឋលេខាធិការ ដែលជាប្រធានស្ថាប័នចំណុះផ្ទាល់ទីស្តីការគណៈរដ្ឋមន្ត្រីដែលបានដឹកនាំការងាររបស់ស្ថាប័ននោះក្រោមការគ្រប់គ្រងផ្ទាល់ពីនាយករដ្ឋមន្ត្រី។

ក៏ប៉ុន្តែនាយករដ្ឋមន្ត្រី អាចប្រគល់សិទ្ធិឲ្យរដ្ឋមន្ត្រី ឬរដ្ឋលេខាធិការណាម្នាក់ ដើម្បីដឹកនាំគ្រប់គ្រងក៏បានដែរ។[276]

ប្រធានស្ថាប័នមានទួនាទីភារកិច្ចដឹកនាំ គ្រប់គ្រងអង្គភាពចំណុះក្នុងក្របខ័ណ្ឌសមត្ថកិច្ចដែលកំណត់ដោយច្បាប់រដ្ឋ។

ប្រធានស្ថាប័ន ជាអ្នកដឹកនាំការងារក្នុងស្ថាប័ន និងគ្រប់គ្រងបុគ្គលិកមន្ត្រីរាជការ ដែលជាភ្នាក់ងាររដ្ឋបាលកណ្តាល និងរដ្ឋបាលមូលដ្ឋាននៅក្រោមឱវាទ។

---

[274] មាត្រា២៨ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី។

[275] រដ្ឋលេខាធិការស្វយ័តនេះមានតែនៅក្នុងរាជរដ្ឋាភិបាលអាណត្តិមុនៗនៃរដ្ឋសភាតែប៉ុណ្ណោះចាប់ពីរាជរដ្ឋាភិបាលអាណត្តិទី៦នៃរដ្ឋសភាមកតំណែងរដ្ឋលេខាធិការស្វយ័តមិនមានតទៅទៀតនោះទេ។

[276] មាត្រា២៧ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី។

ប្រធានស្ថាប័ន មានសិទ្ធិលើកសំណើ តែងតាំង ផ្លាស់ប្តូរ បញ្ចប់ភារកិច្ច មន្ត្រីរាជការក្រោមឱវាទរបស់ខ្លួន តាមបែបបទនីតិវិធីជាធរមានចាប់ពីថ្នាក់ប្រធាននាយកដ្ឋាន វរសេនីយ៍ និងថ្នាក់ប្រហាក់ប្រហែលឡើងទៅ។

ប្រធានស្ថាប័ន មានសិទ្ធិ តែងតាំង ផ្លាស់ប្តូរ បញ្ចប់ភារកិច្ចមន្ត្រីរាជការក្រោមឱវាទតាមបែបបទនីតិវិធីជាធរមាន ដោយចេញប្រកាសតែងតាំង ចាប់ពីថ្នាក់ក្រោមប្រធាននាយកដ្ឋាន និងថ្នាក់ប្រហាក់ប្រហែល។

ការរៀបចំរចនាសម្ព័ន្ធ និងការប្រព្រឹត្តទៅរបស់ក្រសួងស្ថាប័នរដ្ឋ រដ្ឋលេខាធិការដ្ឋាន ចាប់ពីថ្នាក់ក្រោមនាយកដ្ឋានចុះ ត្រូវកំណត់ដោយប្រកាស។[277]

ប្រធានស្ថាប័នមានសិទ្ធិចេញប្រកាស និងសារាចរផ្សេងៗបាន។

សារាចរ គឺជាអត្ថបទ សម្រាប់បំភ្លឺអំពីកិច្ចការណាមួយ និងធ្វើការណែនាំ។ ប្រកាស ឬសារាចររបស់ស្ថាប័នណាមួយមិនអាចចែងអំពីកិច្ចការអ្វីមួយ ដែលមិនស្ថិតក្នុងវង្វង់ ឬក្របខ័ណ្ឌសមត្ថកិច្ចរបស់ស្ថាប័នឡើយ ហើយពុំអាចផ្ទុយជាមួយលិខិតបទដ្ឋានគតិយុត្តនានា មានដូចជាអនុក្រឹត្យ ឬសារាចររបស់រាជរដ្ឋាភិបាលបានឡើយ ជាទូទៅត្រូវតែឲ្យស្របទៅនឹងលិខិតបទដ្ឋានគតិយុត្តទាំងនោះជានិច្ច។

៧.២.រដ្ឋលេខាធិការជាអនុប្រធានស្ថាប័ន

(Secretary of State as a Vice-President of Institutions)

-រដ្ឋលេខាធិការត្រូវអនុវត្តន៍ការងារផ្សេងៗតាមការប្រគល់ជូនពីរដ្ឋមន្ត្រី។

-រាល់កិច្ចការ និងបញ្ហាធំៗ រដ្ឋលេខាធិការអាចពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រី មុននឹងធ្វើសេចក្តីសម្រេចជាស្ថាពរ។[278]

៧.៣.រដ្ឋលេខាធិការអមទីស្តីការគណៈរដ្ឋមន្ត្រី

(Advisor State Secretary Cabinet Office)

ឬរដ្ឋលេខាធិការអមនាយករដ្ឋមន្ត្រី

(Secretary of State Escort Prime-Minister)

រដ្ឋលេខាធិការអមទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋលេខាធិការអមនាយករដ្ឋមន្ត្រី គឺជារដ្ឋលេខាធិការ ដែលធ្វើការងារជាប់ជាមួយនាយករដ្ឋមន្ត្រី ដែលមានភារកិច្ចចាត់ចែងរៀបចំការងាររដ្ឋបាល

[277] មាត្រា៣០ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី។

[278] មាត្រា២៤ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី។

ទាំងឡាយរបស់នាយករដ្ឋមន្ត្រី។ រដ្ឋលេខាធិការប្រភេទនេះមិនមានក្រសួងផ្ទាល់របស់ខ្លួនទេ។

៨-តួនាទី និងសមត្ថកិច្ចអនុរដ្ឋលេខាធិការ

(Roles and Competence Of Under Secretary of State)

អនុរដ្ឋលេខាធិការត្រូវជួយបំពេញការងារនៅក្នុងក្រសួងនីមួយៗតាមការប្រគល់ភារកិច្ចពីប្រធានស្ថាប័ន។[279]

ចំណាំ រដ្ឋមន្ត្រីឬសហរដ្ឋមន្ត្រីដែលទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីអមដោយរដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការព្រមទាំងមានអគ្គលេខាធិការរាជរដ្ឋាភិបាលផងនោះ ធ្វើការគ្រប់គ្រងចាត់ចែងការងារទីស្តីការគណៈរដ្ឋមន្ត្រីសម្របសម្រួល និងការងារប្រចាំថ្ងៃនៃគណៈរដ្ឋមន្ត្រីក្រោមការទទួលខុសត្រូវផ្ទាល់របស់នាយករដ្ឋមន្ត្រី។

៩-មុខងារ និងសមត្ថកិច្ចក្រសួង

(Roles and Competence of Ministry)

ក្រសួងស្ថាប័ននីមួយៗ ដែលបានបង្កើតឡើងត្រូវបង្កើតដោយច្បាប់ដែលបានការអនុម័តយល់ព្រម ដោយសម្លេងភាគច្រើនដាច់ខាត(50+1)ពីរដ្ឋសភា និងប្រកាសឲ្យប្រើដោយព្រះរាជក្រឹត្យបន្ទាប់ពីមានសេចក្តីស្នើសុំពីនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល។

នៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ បានចែងអំពីការបង្កើតក្រសួងស្ថាប័ននានា នៅក្នុងរាជរដ្ឋាភិបាលការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ត្រូវកំណត់ក្នុងច្បាប់[280] និងច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមផងដែរ។[281]

ក្រសួងស្ថាប័ននីមួយៗជាអង្គភាព ដែលស្ថិតនៅក្រោមការដឹកនាំរបស់រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការដែលតំណាងឲ្យរាជរដ្ឋាភិបាល។

ក្រសួងស្ថាប័ននីមួយៗអាចមានទីប្រឹក្សា និងជំនួយការតាមការចាំបាច់។[282]

ក្រសួង ស្ថាប័ននីមួយៗ ដែលមានមុខងារ ជាអ្នកទទួលភារកិច្ចអនុវត្តន៍តាមទិសដៅ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលរដ្ឋសភាបានអនុម័តដើម្បីធានាការអនុវត្តន៍នូវផែនការ

---

[279] មាត្រា២៦ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី។

[280] មាត្រា១២៧ថ្មីនៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[281] ព្រះរាជក្រមលេខ០២/នស/៩៥ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤។

[282] មាត្រា៤៥ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី។

នយោបាយរបស់រដ្ឋ ប្រកបទៅដោយប្រសិទ្ធភាពខ្ពស់ និងអាចដំណើរការទៅឲ្យបានល្អប្រសើរ។ ក្រសួង ស្ថាប័ននីមួយៗ ចាំបាច់ត្រូវបង្កើតឲ្យមានអង្គភាពនានាជាច្រើន ដែលចំណុះផ្ទាល់ឲ្យខ្លួន ដើម្បីបម្រើការងារទាំងឡាយរបស់ក្រសួងស្ថាប័នរដ្ឋ។

១០-ក្រសួង និងស្ថាប័នរដ្ឋ

(Ministry and Public Institutions)

ការបង្កើតក្រសួងត្រូវកំណត់ដោយច្បាប់។ ក្រសួងនីមួយៗត្រូវអនុវត្តសមត្ថកិច្ចស្របតាមច្បាប់ដែលបានបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងហានៈចាប់ពីថ្នាក់នាយកដ្ឋានទៅត្រូវកំណត់ដោយអនុក្រឹត្យ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងហានៈចាប់ពីថ្នាក់នាយកដ្ឋានចុះក្រោមត្រូវកំណត់ដោយប្រកាស។ ក្នុងករណីមានវិវាទសមត្ថកិច្ចរវាងក្រសួងពីរ ឬច្រើន គណៈរដ្ឋមន្ត្រីជាអ្នកពិនិត្យ និងសម្រេច។[283]

ក្រសួងស្ថាប័ននីមួយៗដែលបានបង្កើតឡើង សម្រាប់ជួយកិច្ចការប្រចាំថ្ងៃរបស់រាជរដ្ឋាភិបាលដែលរាជរដ្ឋាភិបាលអាណត្តិនីមួយៗនៃរដ្ឋសភា គឺត្រូវបានបង្កើតឲ្យមានក្រសួង និងស្ថាប័នជំនាញចំនួន២៦(មុនឆ្នាំ២០១៣) និងរដ្ឋលេខាធិការដ្ឋាន២គឺៈ[284]

-ទីស្តីការគណៈរដ្ឋមន្ត្រី

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានបង្កើតឡើងទីស្តីការគណៈរដ្ឋមន្ត្រីដើម្បីធ្វើជាសេនាធិការ ជូនរាជរដ្ឋាភិបាល សម្រាប់ធ្វើការសម្របសម្រួលការងារប្រចាំថ្ងៃរបស់គណៈរដ្ឋមន្ត្រីក្រោមការដឹកនាំរបស់នាយករដ្ឋមន្ត្រី។

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី មានតួនាទីគ្រប់គ្រង និងចាត់ចែងការងារនៅទីស្តីការគណៈរដ្ឋមន្ត្រី។[285]

ទីស្តីការគណៈរដ្ឋមន្ត្រីត្រូវមានរដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការមួយចំនួនតាមការចាំបាច់ ហើយរដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការត្រូវបំពេញការកិច្ច តាមការប្រគល់ជូនពីរដ្ឋមន្ត្រីទទួលបន្ទុកគណៈរដ្ឋមន្ត្រី។[286]

---

[283] មាត្រា៣៩ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី។

[284] រាជរដ្ឋាភិបាលអាណត្តិទី៦នៃរដ្ឋសភា បានបង្កើតឲ្យមានក្រសួង និងស្ថាប័នជំនាញចំនួន២៨ និងរដ្ឋលេខាធិការដ្ឋាន១គឺរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល។

[285] មាត្រា៣៤ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី។

[286] មាត្រា៣៥ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី។

ទីស្តីការគណៈរដ្ឋមន្ត្រីគឺត្រូវបានដឹកនាំដោយរដ្ឋមន្ត្រី និងអមដោយរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ព្រមទាំងមានអគ្គលេខាធិការរាជរដ្ឋាភិបាលផងដែរ ធ្វើការគ្រប់គ្រង ចាត់ចែងការងារទីស្តីការគណៈរដ្ឋមន្ត្រី និងសម្របសម្រួលការងារប្រចាំថ្ងៃរបស់គណៈរដ្ឋមន្ត្រីក្រោមការទទួលខុសត្រូវរបស់នាយករដ្ឋមន្ត្រី។

-ក្រសួងមហាផ្ទៃ

ក្រសួងមហាផ្ទៃមានសមត្ថកិច្ចដឹកនាំគ្រប់គ្រងការងាររដ្ឋបាល គ្រប់ជាន់ថ្នាក់ដឹកនាំគ្រប់គ្រងនគរបាលថ្នាក់ជាតិការពារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពជូនប្រជាពលរដ្ឋ និងសង្គមជាតិទូទាំងព្រះរាជាណាចក្រកម្ពុជា។

-ក្រសួងការពារជាតិ

ក្រសួងការពារជាតិមានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងលើវិស័យការពារជាតិដើម្បីការពារបូរណភាពទឹកដីការពារអធិបតេយ្យនៃព្រះរាជាណាចក្រកម្ពុជា។

-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិមានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងទៅលើវិស័យការបរទេស និងទំនាក់ទំនងអន្តរជាតិ។

-ក្រសួងអប់រំយុវជន និងកីឡា

ក្រសួងអប់រំយុវជន និងកីឡាមានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងលើវិស័យអប់រំជាពិសេសការរៀបចំបណ្តុះបណ្តាលសិស្ស និស្សិតឲ្យទទួលបានចំណេះដឹងគ្រប់កម្រិត និងគ្រប់គ្រងមន្ត្រីបុគ្គលិករាជការសាស្ត្រាចារ្យ រួមទាំងបញ្ហាកីឡានៅទូទាំងប្រទេស។

-ក្រសួងសុខាភិបាល

ក្រសួងសុខាភិបាលមានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងលើវិស័យសុខាភិបាលក្នុងការផ្តល់សេវាកម្មថែទាំសុខភាព និងព្យាបាលជំងឺជូនប្រជាពលរដ្ឋទូទាំងប្រទេស។

-ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល

ក្រសួងឧស្សាហកម្មរ៉ែ និងថាមពលមានសមត្ថកិច្ចដឹកនាំនិងគ្រប់គ្រងលើវិស័យឧស្សាហកម្មរ៉ែ និងថាមពលនៃព្រះរាជាណាចក្រកម្ពុជា។

-ក្រសួងយុត្តិធម៌

ក្រសួងយុត្តិធម៌មានសមត្ថកិច្ចដឹកនាំគ្រប់គ្រងមន្ត្រីរាជការ និងអង្គភាពមួយចំនួនដែលស្ថិតក្រោមចំណុះលើវិស័យយុត្តិធម៌ មាននៅតាមតុលាការជាន់ទាប និងតុលាការជាន់ខ្ពស់គ្រប់ថ្នាក់នៃព្រះរាជាណាចក្រកម្ពុជា។

-ក្រសួងសារព័ត៌មាន

ក្រសួងសារព័ត៌មាន មានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងលើវិស័យព័ត៌មាន វិទ្យុ ទូរទស្សន៍ កាសែត ទស្សនាវដ្តី និងគ្រប់បណ្តាញព័ត៌មានទូទាំងប្រទេស។

-ក្រសួងផែនការ

ក្រសួងផែនការមានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងទៅលើវិស័យផែនការស្តីពីក្នុងការរៀបចំផែនការ និងកំណត់ទិសដៅដើម្បីកសាងអភិវឌ្ឍន៍ប្រទេសជាតិ។

-ក្រសួងសាធារណការ និងដឹកជញ្ជូន

ក្រសួងសាធារណការ និងដឹកជញ្ជូន មានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងលើវិស័យសាធារណៈការគមនាគមន៍ និងដឹកជញ្ជូននៃព្រះរាជាណាចក្រកម្ពុជា។

-ក្រសួងអភិវឌ្ឍន៍ជនបទ

ក្រសួងអភិវឌ្ឍន៍ជនបទមានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងលើវិស័យអភិវឌ្ឍន៍នៅតាមបណ្តាជនបទនានាទូទាំងព្រះរាជាណាចក្រកម្ពុជា។

-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ គឺមានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងលើវិស័យវប្បធម៌ និងវិចិត្រសិល្បៈនៅព្រះរាជាណាចក្រកម្ពុជា។

-ក្រសួងបរិស្ថាន

ក្រសួងបរិស្ថាន មានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងលើវិស័យបរិស្ថាន ការអភិរក្សនៅតាមតំបន់ទេសចរណ៍ ធនធានធម្មជាតិ គុណភាពប្រព័ន្ធអេកូឡូស៊ី សោភ័ណភាពទីក្រុង សុខមាលភាពសង្គម ការបំពុលបរិស្ថាន និងការប្រែប្រួលអាកាសធាតុនៃព្រះរាជាណាចក្រកម្ពុជា។

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងទៅលើវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជំរុញការកសាងអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ។

-ក្រសួងពាណិជ្ជកម្ម

ក្រសួងពាណិជ្ជកម្ម មានសមត្ថកិច្ចដឹកនាំ គ្រប់គ្រងលើវិស័យពាណិជ្ជកម្មនៅក្នុងប្រទេស និងក្រៅប្រទេសដើម្បីស្តារសេដ្ឋកិច្ចជាតិឲ្យរីកចម្រើន។

-ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងលើវិស័យកសិកម្មជាំដំណាំគ្រប់ប្រភេទជម្រុញផ្នែករុក្ខាប្រមាញ់ និងនេសាទឲ្យបានខ្លាំងក្លា។

-ក្រសួងទេសចរណ៍

ក្រសួងទេសចរណ៍ មានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងលើវិស័យទេសចរណ៍ ហើយបានខិតខំរៀបចំតំបន់ទេសចរណ៍ឲ្យមានកម្រិត បង្កើនតំបន់ទេសចរណ៍ទាក់ទាញភ្ញៀវជាតិ និងអន្តរជាតិ ដើម្បីបង្កើនចំណូលថវិកាជាតិ។

-ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍មានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងលើវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍នៃព្រះរាជាណាចក្រកម្ពុជា។

-ក្រសួងធម្មការ និងសាសនា

ក្រសួងធម្មការ និងសាសនា មានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងទៅលើវិស័យធម្មការ និងសាសនា ជាពិសេសវិស័យព្រះពុទ្ធសាសនានៅក្នុងព្រះរាជាណាចក្រកម្ពុជា។

-ក្រសួងធនធានទឹក និងឧតុនិយ

ក្រសួងធនធានទឹក និងឧតុនិយម មានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងលើវិស័យធនធានទឹក និងឧតុនិយម ជម្រុញការកសាងប្រព័ន្ធស្រោចស្រព មានធារាសាស្ត្រ ឧតុនិយម ដើម្បីពង្រឹងវិស័យកសិកម្មនៅព្រះរាជាណាចក្រកម្ពុជា។

-ក្រសួងកិច្ចការនារី

ក្រសួងកិច្ចការនារីមានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងលើវិស័យកិច្ចការនារី ជំរុញការពង្រឹងបញ្ហា Gender ឲ្យប្រសើរឡើងនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងលើវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៃព្រះរាជាណាចក្រកម្ពុជា។

-ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់

ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ដែលមានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងលើវិស័យរៀបចំដែនដីនគរូបនីយកម្ម និងសំណង់នៅព្រះរាជាណាចក្រកម្ពុជា។

-ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច

ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ចមានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងលើវិស័យទំនាក់ទំនងរវាងរាជរដ្ឋាភិបាលជាមួយនឹងអង្គការរដ្ឋសភាព្រឹទ្ធសភា និងជម្រុញលើបញ្ហាអធិការកិច្ចឲ្យមានប្រសិទ្ធភាពខ្ពស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាគឺមានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងលើវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានៅទូទាំងប្រទេស។

១១.រដ្ឋលេខាធិការដ្ឋានចំណុះទីស្តីការគណៈរដ្ឋមន្ត្រី

(Secretariat of State under the Cabinet of the Council of Ministers)

រដ្ឋលេខាធិការដ្ឋានចំណុះទីស្តីការគណៈរដ្ឋមន្ត្រីចំនួន២គឺ៖[287]

-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ មានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងលើមន្ត្រីរាជការ និងវិស័យមុខងារសាធារណៈទូទាំងព្រះរាជាណាចក្រកម្ពុជា។

-រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល

រដ្ឋលេខាធិការដ្ឋាន អាកាសចរណ៍ស៊ីវិល គឺមានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងលើវិស័យអាកាសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូល។

ឃ.ការទទួលខុសត្រូវរបស់សមាជិករាជរដ្ឋាភិបាល

(Responsibility of Government Members)

សមាជិកទាំងឡាយនៃរាជរដ្ឋាភិបាលទទួលខុសត្រូវរួម ចំពោះមុខរដ្ឋសភាអំពីនយោបាយទូទៅរបស់រាជរដ្ឋាភិបាល។ សមាជិករាជរដ្ឋាភិបាលគ្រប់ៗរូប ត្រូវទទួលខុសត្រូវរៀងៗខ្លួនចំពោះមុខនាយករដ្ឋមន្ត្រី និងចំពោះមុខរដ្ឋសភាអំពីកិច្ចការ ដែលខ្លួនបានប្រព្រឹត្ត(សកម្មភាពផ្ទាល់របស់ខ្លួន)ដែលមានចែងរដ្ឋធម្មនុញ្ញ១៩៩៣។[288]

សមាជិករបស់រាជរដ្ឋាភិបាលទាំងឡាយ មិនអាចយកសំអាងនៃសេចក្តីបង្គាប់ដោយលាយលក្ខណ៍អក្សរ ឬដោយវាចារអំពីនរណាម្នាក់ ដើម្បីដោះសាឲ្យរួចផុតពីការទទួលខុសត្រូវរបស់ខ្លួនបានឡើយ។

នាយករដ្ឋមន្ត្រីជាប្រមុខនៃរាជរដ្ឋាភិបាលកម្ពុជា ដែលមានភារកិច្ចទទួលខុសត្រូវរួមជាមួយសមាជិកទាំងឡាយរបស់រាជរដ្ឋាភិបាល នៅចំពោះមុខរដ្ឋសភាអំពីនយោបាយទូទៅ និងសកម្មភាពរួមនៃរាជរដ្ឋាភិបាលទាំងមូល។

សមាជិកមួយរូបៗនៃរាជរដ្ឋាភិបាល ត្រូវទទួលទណ្ឌកម្មពីបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលខ្លួន

---

[287] ចាប់ពីរាជរដ្ឋាភិបាលអាណត្តិទី៥នៃរដ្ឋសភាមក រដ្ឋលេខាធិការដ្ឋានមានតែមួយទេនៅក្នុងព្រះរាជាណាចក្រកម្ពុជាចំណែកឯរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈត្រូវបានប្តូរទៅជាក្រសួងមុខងារសាធារណៈវិញ។

[288] មាត្រា១២១ថ្មីនៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ។

បានប្រព្រឹត្តក្នុងការបំពេញការងាររបស់ខ្លួន ករណីនេះបើសិនជាសមាជិករាជរដ្ឋាភិបាលណាម្នាក់បានធ្វើខុសជាទម្ងន់ក្នុងការបំពេញការងាររបស់ខ្លួន រដ្ឋសភាអាចសម្រេចប្តឹងទៅតុលាការមានសមត្ថកិច្ច។ រដ្ឋសភាសម្រេចក្នុងរឿងនេះ ដោយវិធីបោះឆ្នោតជាសម្ងាត់ តាមមតិភាគច្រើនដាច់ខាត (50បូក១)នៃសមាជិករដ្ឋសភាទាំងមូល។[289]

១.វិសមិតភាពនៃសមាជិករាជរដ្ឋាភិបាល

(Incompatibility of Government Members)

វិសមិតភាពរបស់សមាជិករាជរដ្ឋាភិបាល គឺហាមឃាត់ចំពោះសមាជិករាជរដ្ឋាភិបាលមិនឲ្យបំពេញមុខងារច្រើនក្នុងពេលតែមួយ ក្នុងអាណត្តិនយោបាយ និងសកម្មភាពខាងវិជ្ជាជីវៈ ខាងផ្នែកពាណិជ្ជកម្ម ឬឧស្សាហកម្ម ហើយនឹងការកាន់តំណែងណាមួយនៅក្នុងមុខងារសាធារណៈ។

សមាជិករាជរដ្ឋាភិបាលឬសមាជិកគណៈរដ្ឋមន្ត្រីអាចនៅជាតំណាងរាស្ត្រផងដែរ ប៉ុន្តែមានឋានៈជាតំណាងរាស្ត្រធម្មតា គឺសមាជិករូបនោះមិនមានមុខតំណែងណាមួយ នៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ និងនៅក្នុងគណៈកម្មការនានានៃរដ្ឋសភាឡើយ។

រាជរដ្ឋាភិបាល គឺតំណាងឲ្យអំណាចកណ្តាលដែលទទួលបាននូវភាពស្របច្បាប់របស់ខ្លួនដែលផ្អែកទៅលើការបោះឆ្នោតដោយគោរពគោលការណ៍ប្រជាធិបតេយ្យ។

ស្ថាប័នរាជរដ្ឋាភិបាលនេះ ហើយត្រូវបានបំពេញបេសកកម្មនានាដើម្បីបម្រើផលប្រយោជន៍របស់ប្រជាពលរដ្ឋរស់នៅលើទឹកដី ដែលខ្លួនគ្រប់គ្រង ដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋរាជរដ្ឋាភិបាល គឺបានបង្កើតស្ថាប័នរដ្ឋបាលនេះឡើងដែលនៅជាមួយនឹងប្រជាពលរដ្ឋ គឺបម្រើផលប្រយោជន៍ប្រជាពលរដ្ឋ។ អំណាចរដ្ឋបាលត្រូវបានប្រគល់ឲ្យអាជ្ញាធររដ្ឋបាល ដើម្បីសម្រេចកិច្ចការនានាជាប្រយោជន៍ទូទៅផងដែរ ប៉ុន្តែរាល់ការប្រើអំណាចទាំងនេះត្រូវតែគោរពព្រំដែនដែលច្បាប់បានកំណត់។

ដើម្បីបញ្ជាក់ពីព្រំដែននៃអំណាចនោះ យន្តការនៃត្រួតពិនិត្យមួយចំនួន ឬប្រព័ន្ធត្រួតពិនិត្យមួយចំនួនត្រូវបានបង្កើតឡើង ដើម្បីធ្វើការត្រួតពិនិត្យលើសកម្មភាពទាំងឡាយរបស់រដ្ឋបាល យន្តការនយោបាយត្រូវធ្វើឡើងតាមរយៈរដ្ឋសភា យន្តការរដ្ឋបាលធ្វើឡើង ដោយរដ្ឋបាលខ្លួនឯងផ្ទាល់តាមការប្រើអំណាចហានុក្រម។

ព្រះរាជាណាចក្រកម្ពុជា បានប្រើប្រាស់ និងពង្រីកបន្ថែម ក្នុងគោលដៅស្វែងរកប្រសិទ្ធភាព តម្លាភាព និងការគ្រប់គ្រងកិច្ចការរដ្ឋបាលឲ្យប្រសើរឡើង។

---

[289] មាត្រា១២៦ថ្មីនៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

ផ្នែកទី៣

នីតិប្បញ្ញត្តិ(រដ្ឋសភា)

(Legislative of National Assembly)

អង្គការនីតិប្បញ្ញត្តិ ជាអង្គការកំពូលមួយនៅក្នុងចំណោមអង្គការកំពូលពីរទៀត រាជរដ្ឋាភិបាល និងតុលាការ។ អង្គការនីតិប្បញ្ញត្តិ គឺអង្គការដែលមានអំណាចនីតិប្បញ្ញត្តិ រួមមាន អំណាចតាក់តែងច្បាប់ ធ្វើច្បាប់ និងអនុម័តច្បាប់។

អង្គការនីតិប្បញ្ញត្តិទាំងនេះរួមមាន រដ្ឋសភា និងព្រឹទ្ធសភា។

កិច្ចព្រមព្រៀងទីក្រុងប៉ារីស រវាងភាគីជម្លោះខ្មែរទាំងបួននៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ បាននាំមកនូវរបបនយោបាយប្រជាធិបតេយ្យ សេរីពហុបក្ស មានឆន្ទៈពិតៗប្រជាពលរដ្ឋខ្មែរស្ទើរ ៩០%នៃចំនួនជាង៤លាន៧សែននាក់ ដែលបានទៅបោះឆ្នោត ដើម្បីជ្រើសរើសតំណាងរបស់ខ្លួនស្របច្បាប់ ដោយសេរី និងយុត្តិធម៌។

តាមរយៈ ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៩៣។ ការជ្រើសរើសសភាធម្មនុញ្ញ និងសភាជាតិដើម្បីឈានឆ្ពោះទៅការបង្កើតរាជរដ្ឋាភិបាលប្រជាធិបតេយ្យមួយពេញលេញ។

បន្ទាប់ពីរដ្ឋធម្មនុញ្ញត្រូវបានអនុម័តនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ ហើយត្រូវបានចូលជាធរមាននៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ សភាធម្មនុញ្ញក៏ត្រូវបានរលាយបាត់ទៅវិញនៅពេលដែលរដ្ឋសភាត្រូវបានបង្កើតឡើង។

ក.អំពីរដ្ឋសភា

(About National Assembly)

រដ្ឋសភាជាស្ថាប័នកំពូល និងជាស្ថាប័ន ដែលកាន់អំណាចនីតិប្បញ្ញត្តិ ហើយត្រូវបំពេញការកិច្ចរបស់ខ្លួន ដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន។

-រដ្ឋសភា ជាអ្នកអនុម័តថវិកាជាតិ ផែនការរដ្ឋ ការឲ្យរដ្ឋគេខ្ចីប្រាក់ពីប្រទេសយើង ឬការឲ្យរដ្ឋយើងខ្ចីប្រាក់ពីគេ។ តាមរយៈការសន្យានានាផ្នែកហរិញ្ញវត្ថុ និងការបង្កើតការកែប្រែ ឬការលុបចោលពន្ធដារ។

-រដ្ឋសភា ឲ្យសេចក្តីយល់ព្រមចំពោះគណនីរដ្ឋបាល។

-រដ្ឋសភា អនុម័តច្បាប់ស្តីពីការលើកលែងទោសជាទូទៅ។

-រដ្ឋសភាអនុម័តយល់ព្រម ឬលុបចោលសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ។

-រដ្ឋសភា អនុម័តច្បាប់ស្តីពីការប្រកាសសង្គ្រាម។

រដ្ឋសភាបោះឆ្នោតអនុម័តបញ្ហាខាងលើនេះ អាចប្រព្រឹត្តទៅដោយមតិភាគច្រើនដាច់ខាត (៥០+១)នៃសមាជិករដ្ឋសភាទាំងមូល។

រដ្ឋសភាជាអ្នកបោះឆ្នោតទុកចិត្ត ក្នុងការបង្កើតរាជរដ្ឋាភិបាលតាមមតិភាគច្រើនដាច់ខាត (៥០+១)នៃចំនួនសមាជិករដ្ឋសភាទាំងមូល។[290]

រដ្ឋសភា មិនមានអំណាចតុលាការទេ ក៏ប៉ុន្តែរដ្ឋសភាអាចអនុម័តច្បាប់ ដើម្បីកំណត់អំពីសមាសភាព និងមុខងារនានារបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងមុខងារផ្សេងៗទៀតរបស់តុលាការបាន។[291]

រដ្ឋសភាមិនមានអំណាចនីតិប្រតិបត្តិទេ ប៉ុន្តែរដ្ឋសភាមានអំណាចអនុម័តច្បាប់ស្តីអំពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី និងច្បាប់ផ្សេងៗទៀតស្តីពីមុខងាររបស់រាជរដ្ឋាភិបាលស្របតាមរដ្ឋធម្មនុញ្ញ។[292]

១.ការប្រជុំរដ្ឋសភា

(Meeting National Assembly)

ការបើកសម័យប្រជុំរដ្ឋសភាត្រូវតែធ្វើនៅរាជធានីភ្នំពេញ នៅក្នុងសាលប្រជុំរបស់រដ្ឋសភា រដ្ឋសភាមិនអាចអនុវត្តន៍អំណាចរបស់ខ្លួនជាសម្ងាត់បានទេ ជាទូទៅរាល់គ្រប់សម័យប្រជុំរបស់រដ្ឋសភាត្រូវធ្វើឡើងជាសាធារណៈ។

រដ្ឋសភាអាចប្រជុំជាសម្ងាត់បាន តាមការស្នើសុំពីប្រធានរដ្ឋសភា ឬការស្នើពីសមាជិកចំនួនមួយភាគដប់យ៉ាងតិចនៃសមាជិករដ្ឋសភាពីព្រះមហាក្សត្រ ឬពីនាយករដ្ឋមន្ត្រី។[293]

ការប្រជុំរបស់រដ្ឋសភាជាទូទៅមានពីរ គឺការប្រជុំជាសាមញ្ញ និងជាវិសាមញ្ញ។

២.ការប្រជុំជាសាមញ្ញ

(Ordinary Meeting)

រដ្ឋសភា ប្រជុំជាសាមញ្ញពីរដងក្នុងមួយឆ្នាំ ហើយនៅក្នុងសម័យប្រជុំនីមួយៗត្រូវមានថេរៈវេលាយ៉ាងតិចបីខែ។

៣.ការប្រជុំជាវិសាមញ្ញ

(Extra Ordinary Meeting)

---

[290] មាត្រា៩០ថ្មីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[291] មាត្រា១៣៤ថ្មី និងមាត្រា១៣៥ថ្មីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[292] មាត្រា១២៧ថ្មីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[293] មាត្រា៨៨រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

ការប្រជុំជាវិសាមញ្ញ គឺជាការប្រជុំមួយនៅចន្លោះសម័យប្រជុំជាសាមញ្ញដែលការប្រជុំនេះអាចធ្វើទៅបាន ក្នុងករណី មានការចាំបាច់ និងជាបន្ទាន់ណាមួយទាក់ទងទៅនឹងបញ្ហាសំខាន់ៗរបស់ប្រទេសជាតិ។

រដ្ឋសភា អាចកោះប្រជុំជាវិសាមញ្ញបាន បើសិនមានសំណូមពរអំពីព្រះមហាក្សត្រ ឬតាមសេចក្តីស្នើសុំពីនាយករដ្ឋមន្ត្រី ឬមានការស្នើសុំពីសមាជិករដ្ឋសភា ដែលមានចំនួនមួយភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងមូល។ ក្នុងករណីនេះ របៀបវារៈជាក់លាក់នៃសម័យប្រជុំវិសាមញ្ញ ត្រូវផ្សព្វផ្សាយដល់ប្រជារាស្ត្រជាមួយនឹងថ្ងៃកំណត់ប្រជុំ។[294]

៤.ការប្រជុំរាល់ថ្ងៃ

(Daily Meeting)

ការប្រជុំរាល់ថ្ងៃជាប្រចាំគឺធ្វើឡើងនៅពេលប្រទេសជាតិស្ថិតក្នុងភាពចាំបាច់ ឬក្នុងកាលៈទេសៈ ដែលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន រដ្ឋសភាប្រជុំរាល់ថ្ងៃជាប់ជាប្រចាំ រដ្ឋសភាមានសិទ្ធិសម្រេចបញ្ចប់កាលៈទេសៈពិសេសខាងលើនេះ កាលបើសភាពការណ៍អនុញ្ញាត។

បើរដ្ឋសភាមិនអាចប្រជុំបានទេ ដោយមូលហេតុចាំបាច់ជាអាទិ៍ នៅពេលដែលកម្លាំងពួកបរទេសបានចូលមកកាន់កាប់ទឹកដី ការប្រកាសភាពអាសន្ននឹងត្រូវបន្តទៅមុខជាស្វ័យប្រវត្តិ។

នៅពេលដែលប្រទេសជាតិ ស្ថិតនៅក្នុងភាពអាសន្ន រដ្ឋសភាមិនអាចត្រូវរំលាយជាដាច់ខាតបានឡើយ។[295]

ការប្រជុំរដ្ឋសភាទាំងអស់ខាងលើនឹងយកជាការបានលុះត្រាតែមាន:

-កូរ៉ុមមានចំនួនលើសពីពីរភាគបី(២/៣)នៃចំនួនសមាជិករដ្ឋសភាទាំងមូល គឺសម្រាប់ការអនុម័តច្បាប់ទាំងឡាយណា ដែលតម្រូវឲ្យយកមតិភាគច្រើនពីរភាគបី(២/៣)នៃចំនួនសមាជិករដ្ឋសភាទាំងមូល។

-កូរ៉ុម មានចំនួនលើសពីពាក់កណ្តាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល គឺសម្រាប់ការអនុម័តបញ្ហាទាំងឡាយណា ដែលបានតម្រូវឲ្យយក មតិភាគច្រើនដាច់ខាត(៥០+១)នៃចំនួនសមាជិករដ្ឋសភាទាំងមូល។[296]

សមាជិករដ្ឋសភាដែលអវត្តមានត្រូវបានចុះក្នុងបញ្ជីអវត្តមានរបស់សមាជិករដ្ឋសភា ហើយបញ្ជីនេះត្រូវបានប្រកាសដោយប្រធានរដ្ឋសភា និងដោយបញ្ជាក់អំពីមូលហេតុផងដែរ។

---

[294] មាត្រា៨៣រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[295] មាត្រា៨៦រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[296] មាត្រា៨៨រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

ប្រធានរដ្ឋសភា ត្រូវប្រកាសផ្អាកការប្រជុំប្រសិនបើចំនួនកូរ៉ុមមិនគ្រប់នៅក្នុងរយៈពេល១៥ នាទីបន្ទាប់ពីហួសពេលកំណត់នៃការចាប់ផ្តើមប្រជុំរបស់រដ្ឋសភា។[297]

៥.ការអនុម័ត

(Adoption)

ការអនុម័តច្បាប់ជាទូទៅ គេត្រូវពិនិត្យលើកម្មវត្ថុបន្ទាប់មកទើបត្រួតពិនិត្យលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ហើយត្រូវចាប់ផ្តើមពិភាក្សាដោយអង្គសភា ដែលការពិភាក្សាលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ត្រូវធ្វើដូចតទៅ:

-អង្គសភាត្រូវពិភាក្សា និងអនុម័តទៅលើខ្លឹមសារទាំងមូលត្រូវបញ្ចេញមតិថាតើគួរទទួលពិចារណាឬទេ ?

-អង្គសភាត្រូវពិភាក្សា និងអនុម័តទៅលើមួយមាត្រាម្តងៗក៏បាន ឬក៏ពិភាក្សា និងអនុម័តទៅលើមួយជំពូកម្តងៗក៏បាន។

អង្គសភា អាចប្រើនីតិវិធីពិភាក្សាជាសង្ខេបបាន ដោយពិភាក្សាតែលើមាត្រាណា ឬជំពូកណា ដែលមានសំណើធ្វើវិសោធនកម្ម ជាលាយលក្ខណ៍អក្សរ ដូចមានចែងក្នុងប្រការទាំងឡាយខាងលើនេះ។

ករណីដែលនឹងត្រូវប្រើនីតិវិធីណាមួយខាងលើ គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាត្រូវជូនព័ត៌មានដល់អ្នកតំណាងរាស្ត្រជាមុនសិន។

-អង្គសភា អាចអនុម័តលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ទាំងមូលបាន។[298]

-ការអនុម័តទាំងឡាយណារបស់រដ្ឋសភា ដែលផ្ទុយនឹងគោលការណ៍រក្សាការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ហើយដែលនាំឲ្យប៉ះពាល់ដល់ឯករាជ្យនយោបាយ ឬការគ្រប់គ្រងរដ្ឋបាលរបស់ប្រទេសជាតិនឹងត្រូវចាត់ទុកជាការអសារសូន្យ។ ហើយក្រុមប្រឹក្សាធម្មនុញ្ញជាអង្គការតែមួយគត់ដែលមានសមត្ថកិច្ចសម្រេចពីមោឃភាពនេះបាន។[299]

៥.១.ការប្រើចំនួននៃការអនុម័តដោយរដ្ឋសភា

(Using kind of Numbers of Adopted by National Assembly)

ជាទូទៅរដ្ឋសភាគឺជាអង្គការដែលមានសមត្ថកិច្ចជាអ្នកសម្រេចអនុម័តទៅលើបញ្ហានានា

[297] ប្រការ៤៧ថ្មីបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

[298] ប្រការ២៩បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

[299] មាត្រា៩២រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

របស់ប្រទេសជាតិទាំងមូល តាមការកំណត់រដោយច្បាប់ ដែលព្រះរាជាណាចក្រកម្ពុជាយើងបានអនុវត្តន៍របបសភានិយម មានន័យថា ប្រទេសយើងយកសភាជាធំ កិច្ចការប្រទេសជាតិទាំងអស់អាចអនុវត្តន៍ទៅបានលុះត្រាតែមានការអនុម័តយល់ព្រមពីរដ្ឋសភាជាមុន។

ហេតុនេះ នៅក្នុងរដ្ឋសភាប្រទេសកម្ពុជាយើងបានប្រើប្រាស់នីតិវិធី និងប្រភេទចំនួននៃការអនុម័តដូចតទៅ:

-ការអនុម័តដោយសម្លេងភាគច្រើនបីភាគបួន(៣/៤)

-ការអនុម័តដោយសម្លេងភាគច្រើនពីរភាគបី(២/៣)

-ការអនុម័តដោយសម្លេងភាគច្រើនដាច់ខាត(៥០+១)

-និងការអនុម័តដោយសម្លេងភាគច្រើនដោយប្រៀប

ការអនុម័តទាំងអស់ខាងលើនេះត្រូវបានអនុវត្តន៍នៅក្នុងរដ្ឋសភាអាណត្តិទី៦សព្វថ្ងៃ។

៥.១.១.ការអនុម័តដោយសម្លេងភាគច្រើនបីភាគបួន(៣/៤)

(Adopted by a Three of Four of Majority)

ការអនុម័តដោយសម្លេងបីភាគបួន ដែលអាចយកជាការបាន លុះត្រាតែការអនុម័តនោះបានចំនួនសម្លេងស្មើនឹងចំនួនសមាជិករដ្ឋសភាទាំងអស់ គុណនឹង៣ហើយចែកនឹង៤ គឺកៅសិបបួនសម្លេងឡើងទៅរហូតដល់១២៥សម្លេងទើបអាចយកជាការបាន។

ឧទាហរណ៍ ចំនួនសមាជិករដ្ឋសភាសរុប ១២៥*៣:៤ = ៩៤

សំគាល់ ការប្រើប្រាស់ក្នុងការអនុម័ត ដោយសម្លេងបីភាគបួន**(៣/៤)នេះ** រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាយើងសព្វថ្ងៃ នៅប្រើចំពោះតែ**ករណីមួយគត់**គឺការអនុម័តមិនឲ្យចាប់ខ្លួនសមាជិករដ្ឋសភាណាមួយ។[300]

៥.១.២.ការអនុម័តដោយសម្លេងភាគច្រើនពីរភាគបី(២/៣)

(Adopted by a Two of Three of Majority)

ការអនុម័តដោយសម្លេងពីរភាគបី(២/៣)ដែលអាចយកជាការបានលុះត្រាតែការអនុម័តនោះបានចំនួនសម្លេងស្មើនឹងចំនួនសមាជិករដ្ឋសភាទាំងអស់គុណនឹង២ហើយចែកនឹង៣គឺប៉ែតសិបបួនសម្លេងឡើងទៅរហូតដល់១២៥សម្លេងទើបអាចយកជាការបាន។

ឧទាហរណ៍ ចំនួនសមាជិករដ្ឋសភាសរុប ១២៥*២:៣ = ៨៤

[300] វាក្យខ័ណ្ឌចុងក្រោយមាត្រា៨០រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

សំគាល់:ការប្រើប្រាស់នៅក្នុងការអនុម័តដោយសម្លេងពីរភាគបី(**២/៣**)**នេះរដ្ឋសភានៃ**ព្រះរាជាណាចក្រកម្ពុជាយើងសព្វថ្ងៃ នៅប្រើសម្រាប់ការអនុម័តមានចំនួនតែ៣ករណីនេះទេគឺ:

ករណីទី១-ការអនុម័តដកអភ័យឯកសិទ្ធិសមាជិករដ្ឋសភាណាមួយ។[301]

ករណីទី២-ការអនុម័តក្នុងការសើរើ ឬធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ។[302]

ករណីទី៣-ការអនុម័តក្នុងការប្រកាសបន្តនីតិកាលរបស់រដ្ឋសភាត្រូវបានអនុម័តដោយសម្លេងភាគច្រើនពីរភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងមូល។[303]

៥.១.៣.ការអនុម័តសម្លេងភាគច្រើនដោយប្រៀប

(Adopted by comparative Majority)

ការអនុម័តដោយសម្លេងភាគច្រើនដោយប្រៀប គឺជាការអនុម័ត ឬបោះឆ្នោតដោយធ្វើការប្រៀបធៀបចំនួននៃការអនុម័ត ឬបោះឆ្នោតឲ្យ ជាមួយនឹងចំនួននៃការអនុម័ត ឬបោះឆ្នោតឲ្យដូចគ្នាដោយមិនគិតចំនួនកំណត់ប៉ុន្មាននោះទេ។ លទ្ធផលចំនួនសម្លេងដែលទទួលបានច្រើនជាងគេគឺជាចំនួនដែលអាចយកជាការបាន។

ឧទាហរណ៍ រដ្ឋសភាបានធ្វើការបោះឆ្នោតជ្រើសរើសសមាជិកព្រឹទ្ធសភា២រូប តាមមតិភាគច្រើនដោយប្រៀប។ នៅពេលនោះមានអ្នកដាក់ពាក្យឈរឈ្មោះចំនួន៦រូប ដូចនេះ រដ្ឋសភាត្រូវធ្វើការបោះឆ្នោតជ្រើសរើសយក សមាជិកចំនួន២រូបណាដែលមានសម្លេងឆ្នោតច្រើនជាងគេដោយសមាជិករដ្ឋសភា ត្រូវធ្វើការបោះឆ្នោតទាំង១២៥រូប ដោយជ្រើសរើសយក១រូប ដែលខ្លួនពេញចិត្ត។ ជាលទ្ធផល:

-បុគ្គល A ទទួលបានសម្លេងឆ្នោត ៣០

-បុគ្គល B ទទួលបានសម្លេងឆ្នោត ៣៥

-បុគ្គល C ទទួលបានសម្លេងឆ្នោត ២៥

-បុគ្គល D ទទួលបានសម្លេងឆ្នោត ១៥

-បុគ្គល E ទទួលបានសម្លេងឆ្នោត ១៥

-បុគ្គល F ទទួលបានសម្លេងឆ្នោត ៣

ចំណែក២សម្លេងទៀតអនុប្បវាទ សរុបសម្លេងបោះឆ្នោតរបស់សមាជិករដ្ឋសភាទាំងអស់

[301] មាត្រា៨០រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[302] មាត្រា១៥៣រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[303] វាក្យខ័ណ្ឌចុងក្រោយមាត្រា៧៨រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

មានចំនួន១២៥រូប។

ដូចនេះ អ្នកដែលអាចក្លាយជាសមាជិកព្រឹទ្ធសភាទី១នៃការជ្រើសរើស គឺបុគ្គលB ទទួលបានសម្លេងឆ្នោត៣៥ ដោយយកចំនួនសម្លេងដែលបុគ្គល B ទទួលបានមានចំនួនច្រើនជាងគេ បើប្រៀបធៀបជាមួយបុគ្គលផ្សេងទៀត។

អ្នកដែលអាចក្លាយជាសមាជិកព្រឹទ្ធសភាទី២ គឺបុគ្គលAគាត់ទទួលបានសម្លេងឆ្នោត៣០ ដោយយកចំនួនសម្លេងដែលបុគ្គលAទទួលបានប្រៀបធៀបជាមួយនឹងបុគ្គលដែលនៅសល់ផ្សេងទៀតគឺគាត់មានចំនួនច្រើនជាងគេ។

ការអនុម័តដោយសម្លេងភាគច្រើនដោយប្រៀបនេះត្រូវបានចែកចេញជា២ទៀតគឺ:

+ការអនុម័តដោយសម្លេងភាគច្រើនដោយប្រៀប ដោយមានសម្លេងច្រើនជាង។

+ការអនុម័ត ដោយសម្លេងភាគច្រើនដោយប្រៀប ករណីសម្លេងបែកជាពីរស្មើគ្នា នោះគឺសម្លេងប្រធានជាសម្លេងមានឧត្តមានុភាព។

សំគាល់: ការប្រើប្រាស់នៅក្នុងការអនុម័ត ដោយសម្លេងភាគច្រើនដោយប្រៀបនេះ រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាយើងសព្វថ្ងៃនៅប្រើសម្រាប់អនុម័តមានចំនួនតែ២ករណីទេគឺ:

ករណីទី១ រដ្ឋសភា ជាអ្នកធ្វើការបោះឆ្នោតជ្រើសរើសសមាជិកព្រឹទ្ធសភា២រូបតាមមតិភាគច្រើនដោយប្រៀប។[304]

ករណីទី២ គឺរដ្ឋសភាជាអ្នកធ្វើការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ២រូបលើកទី១យកសម្លេងភាគច្រើនដាច់ខាត(បើមិនបាន)ត្រូវបោះឆ្នោតលើកទី២យកសម្លេងភាគច្រើនដោយប្រៀប។[305]

៥.១.៤.ការអនុម័តដោយសម្លេងភាគច្រើនដាច់ខាត(៥0%+១)

(Absolute Majority of Approval)

ការអនុម័តដោយសម្លេងភាគច្រើនដាច់ខាត(៥0%+១) គឺជាការអនុម័ត ដែលអាចយកជាការបាន លុះត្រាតែការអនុម័តនោះ បានចំនួនសម្លេងស្មើនឹង ចំនួនសមាជិករដ្ឋសភាទាំងអស់ចែកនឹង២ហើយបូកនឹង១គឺបានចំនួនហុកសិបបួន(៦៤)សម្លេងឡើងទៅ រហូតដល់១២៥សម្លេងទើបអាចយកជាការបាន។

[304] មាត្រា១០០ថ្មីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[305] មាត្រា៣ច្បាប់ស្តីពីច្បាប់ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

ឧទាហរណ៍ ចំនួនសមាជិករដ្ឋសភាសរុប ១២៥:២+១ = ៦៤

កំណត់សំគាល់: ក្រៅតែអំពីការអនុម័តដោយសម្លេងបីភាគបួន(**៣/៤**) ដែលមានតែ ១ករណី ការអនុម័តដោយសម្លេងពីរភាគបី(២/៣) ដែលមានតែ៣ករណី និងការអនុម័តដោយសម្លេងភាគច្រើនដោយប្រៀបដែលមានតែ២ករណីទាំងប៉ុន្មាននេះចេញ គឺគ្រប់ករណីទាំងអស់នៃការអនុម័តរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាយើងសព្វថ្ងៃ សុទ្ធតែត្រូវប្រើប្រាស់ ការអនុម័តដោយសម្លេងភាគច្រើនជាច់ខាត(៥០%+១)ទាំងអស់ មិនថាករណីនេះ ឬករណីណានោះទេ។

៥.២.នីតិវិធីនៃការអនុម័តបោះឆ្នោត

(Procedure of Adopting)

រដ្ឋសភាអាចអនុម័តទាក់ទងបញ្ហាផ្សេងៗទៅតាមនីតិវិធីបីយ៉ាងគឺ:

ការអនុម័តបោះឆ្នោតដោយវិធីលើកដៃ ការអនុម័តបោះឆ្នោតជាចំហ និងការអនុម័តបោះឆ្នោតដោយសម្ងាត់។

៥.២.១ ការអនុម័តដោយវិធីលើកដៃ

(Adoption by Raising Hand)

ការអនុម័តដោយការលើកដៃ គឺប្រធាន និងលេខាទាំងឡាយជាអ្នករាប់ចំនួនសមាជិកដែលត្រូវលើកដៃអនុម័ត។ បើប្រធាន និងលេខាយល់ឃើញថាការលើកដៃអនុម័តនេះ មិនបានច្បាស់លាស់ទេនោះត្រូវធ្វើទៅតាមនីតិវិធីដដែលសាជាថ្មីម្តងទៀត។[306]

ក្រោយពីបោះឆ្នោតរួចស្រេចហើយ លេខាធិការរាប់សន្លឹកឆ្នោត ក្រោយពីរាប់សន្លឹកឆ្នោតប្រធានរដ្ឋសភាត្រូវប្រកាសលទ្ធផលជូនអង្គសភាស្តាប់។[307]

កាលបើការលើកដៃអនុម័តបានរហូតទៅដល់ពីរដងហើយ នៅតែមិនទាន់ទទួលបានលទ្ធផលច្បាស់លាស់ទេនោះ គឺគេត្រូវអនុវត្តន៍ការអនុម័តបោះឆ្នោតជាចំហវិញ។[308]

៥.២.២ ការអនុម័តបោះឆ្នោតជាចំហ

(Adoption by Opened Election)

ការអនុម័តបោះឆ្នោតជាចំហគឺជាការបោះឆ្នោតដែលមានអាជ្ញាសភាជាអ្នកកាន់ហិបឆ្នោតដើរប្រមូលយកសន្លឹកឆ្នោតពីសមាជិករដ្ឋសភា។

---

[306] ប្រការ៣៧នៃបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា។

[307] វាក្យខ័ណ្ឌចុងក្រោយប្រការ៣៨ថ្មីនៃបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា។

[308] ប្រការ៣៨ថ្មីនៃបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា។

សមាជិករដ្ឋសភាត្រូវតែសរសេរឈ្មោះរបស់ខ្លួននៅលើសន្លឹកឆ្នោតដែលសន្លឹកឆ្នោតមានសណ្ឋានបីពណ៌ គឺមានពណ៌ខៀវគឺមានន័យថា មិនយល់ព្រម រីឯពណ៌សគឺមានន័យថា យល់ព្រម និងពណ៌សឆ្នូតខៀវ គឺមានន័យថា អនុប្បវាទ។[309]

ក្រោយពីបានបោះឆ្នោតរួចស្រេចហើយ លេខាធិការត្រូវរាប់សន្លឹកឆ្នោតហើយ ប្រធានរដ្ឋសភាជាអ្នកប្រកាសជូនអង្គសភាទាំងមូលឲ្យបានជ្រាប។

ការអនុម័ត បោះឆ្នោតជាចំហនៅលើវេទការ គឺជាការបោះឆ្នោតអនុម័តមួយប្រភេទ ដែលសមាជិករដ្ឋសភាម្នាក់ៗត្រូវដើរទៅយកសន្លឹកឆ្នោតមកបោះក្នុងហិបឆ្នោត ដែលបានដាក់នៅលើវេទការ។ ការអនុម័តបោះឆ្នោតជាចំហនៅលើវេទការនេះអាចធ្វើទៅបានលុះត្រាតែមានសមាជិករដ្ឋសភាចំនួនដប់១០រូបយ៉ាងតិចស្នើសុំ។[310]

៥.២.៣ ការអនុម័តបោះឆ្នោតដោយសម្ងាត់

(Adoption by Secret Election)

ការអនុម័តបោះឆ្នោតដោយសម្ងាត់ គឺជាការបោះឆ្នោតមួយប្រភេទដែលអ្នកតំណាងរាស្ត្រមិនសរសេរឈ្មោះរបស់ខ្លួននៅលើសន្លឹកឆ្នោតនោះទេ វិធីបោះឆ្នោតដោយសម្ងាត់នេះ ត្រូវបានគេយកមកប្រើនៅក្នុងការអនុម័តបោះឆ្នោតលើបញ្ហាមួយចំនួនដូចជា:

-ផ្តល់សេចក្តីទុកចិត្តបង្កើតរាជរដ្ឋាភិបាល

-អនុម័តក្នុងការបង្កើត និងជ្រើសតាំង

-អនុម័តច្បាប់ និងអនុម័តច្បាប់វិសោធនកម្មរដ្ឋធម្មនុញ្ញ

-អនុម័តញត្តិបន្ទោស

-អនុម័តកិច្ចការទាំងឡាយរបស់ប្រទេសជាតិជាច្រើនទៀត ។[311]

ការអនុម័តទាំងឡាយត្រូវបានអនុម័តតាមមតិភាគច្រើន ដែលមានកំណត់ក្នុងរដ្ឋធម្មនុញ្ញ ក្រៅពីនេះមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូលត្រូវចាត់ទុកថាជាបានការ បើចំនួនមតិយល់ព្រម និងចំនួនមតិមិនយល់ព្រមស្មើគ្នានោះ ការបោះឆ្នោតត្រូវធ្វើជាថ្មីម្តងទៀត បើលទ្ធផលនៃការបោះឆ្នោតលើកទី២នៅតែមានសម្លេងស្មើគ្នាត្រូវចាត់ទុកថា រដ្ឋសភាមិនយល់ព្រមនោះទេ។[312]

---

[309] ប្រការ៣៨ថ្មីនៃបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា។

[310] ប្រការ៣៩បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

[311] មាត្រា៩០ថ្មីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[312] ប្រការ៤២នៃបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា។

ក្រោយបានលទ្ធផលនៃការបញ្ចេញមតិរួចហើយ ប្រធានរដ្ឋសភាត្រូវប្រកាសថា រដ្ឋសភាបានអនុម័តយល់ព្រម ឬថារដ្ឋសភាបានអនុម័តមិនយល់ព្រមទេ។[313]

ការអនុម័តច្បាប់ស្តីពីការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ គឺអាចប្រព្រឹត្តទៅដោយវិធីបោះឆ្នោតជាសម្ងាត់បាន។[314]

ខ.សមាជិករដ្ឋសភា

(Members of Parliament)

សមាជិករដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងអាណត្តិទី១ នាឆ្នាំ១៩៩៣ ដល់ឆ្នាំ១៩៩៨មានចំនួនសមាជិកទាំងអស់១២០រូប។ អាណត្តិទី២ពីឆ្នាំ១៩៩៨ដល់ឆ្នាំ២០០៣មានសមាជិកចំនួន១២២រូប។ អាណត្តិទី៣ពីឆ្នាំ២០០៣ដល់ឆ្នាំ២០០៨មានសមាជិករដ្ឋសភាចំនួន១២៣រូប។ អាណត្តិទី៤ពីឆ្នាំ២០០៨ដល់ឆ្នាំ២០១៣មានសមាជិករដ្ឋសភាចំនួន១២៣រូប។ រីឯអាណត្តិទី៥ពីឆ្នាំ២០១៣ដល់ឆ្នាំ២០១៨មានសមាជិករដ្ឋសភាចំនួន១២៣រូប អាណត្តិទី៦ពីឆ្នាំ២០១៨ដល់ឆ្នាំ២០២៣មានសមាជិករដ្ឋសភាចំនួន១២៥រូប។

តំណាងរាស្ត្រ នៅក្នុងរដ្ឋសភាជាតំណាងរបស់ប្រជាជាតិខ្មែរទាំងមូល ពុំមែនគ្រាន់តែជាតំណាងប្រជាពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួនប៉ុណ្ណោះទេ។

អាណត្តិអាជ្ញាបញ្ជាទាំងឡាយត្រូវចាត់ទុកជាមោឃៈ។[315]

សមាជិករដ្ឋសភា គឺជាតំណាងរាស្ត្រ ដែលត្រូវបានប្រជាពលរដ្ឋខ្មែរបោះឆ្នោតជាសាកលដោយសេរី ដោយស្មើភាព ដោយចំពោះ និងដោយសម្ងាត់ ដែលបានមកពីមណ្ឌលផ្សេងៗគ្នានៅទូទាំងប្រទេសដើម្បីធ្វើជាតំណាងរបស់ខ្លួននៅក្នុងរដ្ឋសភា ដើម្បីធ្វើច្បាប់ អនុម័តច្បាប់ និងតាមដានការអនុវត្តច្បាប់របស់រាជរដ្ឋាភិបាលជាដើម។[316]

ការបោះឆ្នោតជ្រើសរើសយកតំណាង ត្រូវអនុវត្តតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។[317]តំណាងរាស្ត្រត្រូវបានជ្រើសតាំងដោយការបោះឆ្នោតជាទូទៅជាសកល ដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដោយស្មើភាព ដោយចំពោះ តាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់។[318]

---

[313] ប្រការ៨៣នៃបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

[314] ប្រការ៨០នៃបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

[315] មាត្រា៧៧នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[316] មាត្រា៧៦នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[317] មាត្រា២ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។

[318] មាត្រា៧៦នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

១-ការបោះឆ្នោតជាសាកល

(General Election)

ការបោះឆ្នោតជាសាកលគឺជាការបោះឆ្នោត ពីប្រជាពលរដ្ឋខ្មែរទាំងពីរភេទទូទាំងប្រទេស ដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅគឺមានសិទ្ធិទៅបោះឆ្នោតជ្រើសរើសតំណាងរាស្ត្របាន។

២-ការបោះឆ្នោតដោយសេរី

(Freedom Election)

ការបោះឆ្នោតដោយសេរីគឺជាការបោះឆ្នោតដោយប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានសិទ្ធិបោះឆ្នោតជ្រើសតាំងតំណាងរបស់ខ្លួនដោយសេរី ដែលមានន័យថាប្រជាពលរដ្ឋមានសេរីភាពពេញលេញក្នុងការបោះឆ្នោតឲ្យគណៈបក្សណាមួយក៏បាន ដោយគ្មានបុគ្គលណា ឬក្រុមណា ឬគណបក្សនយោបាយណាមួយ គឺអាចចាប់បង្ខំទាំងផ្លូវកាយ ទាំងផ្លូវចិត្ត ដើម្បីឲ្យគេបោះឆ្នោតឲ្យក្រុមខ្លួន ឬឲ្យគណបក្សរបស់ខ្លួនបានឡើយ។

៣-ការបោះឆ្នោតដោយស្មើភាព

(The Equality Election)

ការបោះឆ្នោតដោយស្មើភាពគឺជាការបោះឆ្នោតដោយប្រជាពលរដ្ឋខ្មែរ ទាំងពីរភេទ ដែលអាចទៅបោះឆ្នោតបានដូចគ្នា ហើយម្នាក់ៗបោះឆ្នោតបានតែ១សន្លឹកដូចគ្នា ហើយ១សន្លឹកមានតម្លៃស្មើគ្នាមាន១សម្លេងដូចគ្នា ដោយពុំគិតអំពីតួនាទី ឬឋានន្តរស័ក្តនៅក្នុងសង្គមឡើយ។

៤-ការបោះឆ្នោតដោយចំពោះ

(The Direct Election)

ការបោះឆ្នោតដោយចំពោះ គឺជាការបោះឆ្នោត ដោយប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលអាចប្រើសិទ្ធិខ្លួនឯងដោយផ្ទាល់ទៅបោះឆ្នោតដោយផ្ទាល់បាន។ ពោល គឺមិនអាចឲ្យបោះឆ្នោតជំនួសបានឡើយទោះបីស្ថិតក្នុងកាលទេសៈណាក៏ដោយ។

៥-ការបោះឆ្នោតដោយសម្ងាត់

(Secret Election)

ការបោះឆ្នោតដោយសម្ងាត់គឺជាការការបោះឆ្នោតដោយប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលអាចបោះឆ្នោតបានដោយសម្ងាត់ម្នាក់ឯង គឺមានន័យថា អ្នកបោះឆ្នោតនោះ អាចធ្វើការសម្រេចចិត្តជ្រើសរើសឆ្នោតដោយខ្លួនឯងផ្ទាល់ជាសម្ងាត់ គឺមិនអាចមានអ្នកណាម្នាក់ ឬតំណាងគណបក្សនយោបាយណាមួយអាចដឹង ឬឆែកឆេរសន្លឹកឆ្នោតដែលខ្លួនយើងបានបោះឆ្នោតរួចហើយនោះឡើយ។

គ.លក្ខខណ្ឌនៃការឈរឈ្មោះ និងមិនអាចឈរឈ្មោះ

(Conditions of Qualification and Disqualification)

១-លក្ខខណ្ឌនៃការឈរឈ្មោះ

(Conditions of Qualification Candidate)

តាមច្បាប់ស្តីពីការបោះឆ្នោត ជ្រើសរើសតំណាងរាស្ត្រចែងថា ប្រជាពលរដ្ឋខ្មែរដែលមានសិទ្ធិទៅបោះឆ្នោត និងមានបំណងឈរឈ្មោះជាបេក្ខជនដែលត្រូវបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម:

-មានសញ្ជាតិខ្មែរពីកំណើត គឺសំដៅជាជនជាតិខ្មែរ និងសញ្ជាតិខ្មែរ។

-មានអាយុម្តៃប្រាំឆ្នាំ(២៥)ឆ្នាំឡើងទៅគិតដល់ថ្ងៃបោះឆ្នោត។

-មានសិទ្ធិបោះឆ្នោត និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោត។[319]

-មានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

-មានការតែងតាំង ពីគណបក្សនយោបាយណាមួយ ដែលបានចុះបញ្ជីក្នុងការឈរឈ្មោះបោះឆ្នោតហើយ។[320]

២-លក្ខខណ្ឌមិនអាចឈរឈ្មោះ

(Conditions of Disqualification Candidate)

តាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្របានចែងថា:

-មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងកម្លាំងនគរបាលជាតិ ឬកងយោធពលខេមរភូមិន្ទក្នុងមុខតំណែង និងបុព្វជិតសាសនា ឬ

-ជន ដែលត្រូវបានតុលាការផ្តន្ទាទោស ដាក់ពន្ធនាគារគឺពីបទល្មើសព្រហ្មទណ្ឌមាន(បទឧក្រិដ្ឋ ឬបទមជ្ឈិម)ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ ឬ

-ជនដែលត្រូវបានផ្តន្ទាទោសដកសិទ្ធិបោះឆ្នោត ឬ

-ជនវិកលចរិត ឬជនដែលស្ថិតនៅក្រោមអាណាព្យាបាល ដែលមានលិខិតស្នាមបញ្ជាក់ពីក្រសួងមានសមត្ថកិច្ច ឬ

-ជនដែលត្រូវដកហូតជាបណ្តោះអាសន្ននូវសិទ្ធិបោះឆ្នោត ឬជនដែលត្រូវបានលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ដោយគណៈកម្មាធិការជាតិ និងគណៈកម្មការរៀបចំ ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឬ

---

[319] មាត្រា៧៦នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[320] មាត្រា៣៣ថ្មីនៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ។

-ជាសមាជិកគណៈកម្មាធិការជាតិ និងជាគណៈកម្មការរៀបចំ ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ឬ

- សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ឬ
- សមាជិកព្រឹទ្ធសភា
- សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ។[321]

ឃ.នីតិវិធីនៃការចូលកាន់តំណែងរបស់រដ្ឋសភា

(Procedure of Taking Office of National Assembly)

បន្ទាប់ពីប្រជាពលរដ្ឋខ្មែរបានបោះឆ្នោតគាំទ្របេក្ខជនជាប់ឆ្នោតទាំងអស់ នៅពេលបើកសម័យប្រជុំលើកទី១នៃនីតិកាលនីមួយៗ រដ្ឋសភាត្រូវចាប់ដំណើរការក្រោមអធិបតីភាពនៃប្រធានបណ្តោះអាសន្នមួយរូប ដែលជាបេក្ខជនជាប់ឆ្នោត មានអាយុច្រើនជាងគេ ហើយដែលឥតមានគេប្តឹងតវ៉ា ហើយជ្រើសរើសសមាជិក៥រូប ដែលជាបេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្រ ដែលមានអាយុតិចជាងគេ ហើយដែលឥតមានគេប្តឹងតវ៉ា ដើម្បីឲ្យធ្វើជាលេខាធិការ ដើម្បីជួយប្រធានក្នុងការងារ។

ការបើកសម័យប្រជុំដំបូងនៃនីតិកាលនីមួយៗ ក្នុងរយៈពេល៦០ថ្ងៃយ៉ាងយូរ ក្រោយពេលបោះឆ្នោតតាមការកោះប្រជុំរបស់ព្រះមហាក្សត្រ។[322]

ប្រធានរដ្ឋសភានៃនីតិកាលចាស់ ជាអ្នកលើកសំណើថ្វាយព្រះមហាក្សត្រដើម្បីទ្រង់ប្រទានការកោះប្រជុំសម័យប្រជុំដំបូងរបស់រដ្ឋសភានៃនីតិកាលថ្មី។

សម័យប្រជុំដំបូងនៃនីតិកាលនីមួយៗ របស់រដ្ឋសភាត្រូវចាប់ដំណើរការដូចជា:

១-ការចូលកាន់តំណែងក្នុងករណីធម្មតា

(Normal Conditions of Taking Office)

ជាទូទៅព្រះមហាក្សត្រទ្រង់ប្រកាសបើកសម័យប្រជុំដំបូង ឬទ្រង់អាចចាត់ព្រះរាជតំណាងក្រោមអធិបតីភាព និងក្រោមការដឹកនាំរបស់ព្រឹទ្ធសមាជិកនៃរដ្ឋសភា ជាប្រធានបណ្តោះអាសន្ន។ ប្រសិនបើមានកូរ៉ុមលើសពីពាក់កណ្តាលនៃចំនួនសមាជិករដ្ឋសភាទាំងមូលត្រូវរៀបចំ និងធ្វើតាមរបៀបវារៈដូចតទៅ:

-ប្រកាសឈ្មោះសមាជិករដ្ឋសភាពេញសិទ្ធិ

-ប្រកាសសម្រេចអំពីសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ

---

[321] មាត្រា៣៣ថ្មីនៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ។

[322] មាត្រា៨២ថ្មីនៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

-បោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នារវាងប្រធាន និងអនុប្រធានទាំងពីរនៃរដ្ឋសភា ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។

-បោះឆ្នោតជ្រើសរើសប្រធាន អនុប្រធាន និងលេខាធិការនៃគណៈកម្មការជំនាញនីមួយៗ របស់រដ្ឋសភា។ ហើយសមាជិករដ្ឋសភាទាំងអស់មិនអាចជជែក និងពិភាក្សាអំពីអ្វីឡើយនៅក្រោម អធិបតីភាពរបស់ព្រឹទ្ធសមាជិក។

តំណាងរាស្ត្រទាំងអស់ គឺត្រូវតែធ្វើសច្ចាប្រណិធានមុនពេលចូលកាន់មុខតំណែងក្រោម ការដឹកនាំរបស់ប្រធាន និងអនុប្រធានទាំងពីរនៃរដ្ឋសភា ដូចមាន ខ្លឹមសារចែងក្នុងឧបសម្ព័ន្ធ៥ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។[323]

២-ការចូលកាន់តំណែងក្នុងករណីពិសេស

(Special Conditions of Taking Office)

ករណីដែល ស្ថានភាពនយោបាយតម្រូវឲ្យអនុវត្តន៍តាមច្បាប់រដ្ឋធម្មនុញ្ញបន្ថែមដែលសំដៅ ជានានូវដំណើរការប្រព្រឹត្តទៅជាប្រក្រតីនៃស្ថាប័នជាតិ។

ជាទូទៅ ព្រះមហាក្សត្រទ្រង់ប្រកាសបើកសម័យប្រជុំដំបូង ឬទ្រង់អាចចាត់ព្រះរាជតំណាង

ក្រោមអធិបតីភាព និងក្រោមការដឹកនាំរបស់ព្រឹទ្ធសមាជិករបស់រដ្ឋសភា ដែលជាប្រធាន បណ្តោះអាសន្ន។ ប្រសិនបើ មានកូរ៉ុមលើសពីពាក់កណ្តាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល ត្រូវធ្វើតាមរបៀបវារៈដូចតទៅ:

-ប្រកាសឈ្មោះសមាជិករដ្ឋសភាពេញសិទ្ធិ

-ប្រកាសសម្រេចអំពីសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ

-បោះឆ្នោតជាកញ្ចប់ ដើម្បីជ្រើសតាំងប្រធាន អនុប្រធានទាំងពីរនៃរដ្ឋសភានិងប្រធាន អនុ ប្រធាន គណៈកម្មការជំនាញទាំងអស់របស់រដ្ឋសភា និងផ្តល់សេចក្តីទុកចិត្តចំពោះរាជរដ្ឋាភិបាល នៅដើមនីតិកាលនីមួយៗ។ ដោយវិធីលើកដៃ ដោយអនុម័តតាមមតិភាគច្រើនដាច់ខាតនៃចំនួន សមាជិករដ្ឋសភាទាំងមូល ។

សមាជិករដ្ឋសភា មិនអាចជជែក ឬពិភាក្សាអំពីអ្វីឡើយ នៅក្រោមអធិបតីភាពរបស់ព្រឹទ្ធ សមាជិក។ តំណាងរាស្ត្រទាំងអស់ត្រូវធ្វើសច្ចាប្រណិធានមុនពេលចូលកាន់មុខតំណែងក្រោមការ ដឹកនាំរបស់ប្រធាន និងអនុប្រធានទាំងពីរនៃរដ្ឋសភា ដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី៥នៃ រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។[324]

---

[323] មាត្រា៨២ថ្មីនៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[324] ប្រការ២ថ្មីបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

៣-សុពលភាពរបស់តំណាងរាស្ត្រ

(Validity of Representatives)

នៅពេលបើកសម័យប្រជុំដំបូងនៃនីតិកាលនីមួយៗខាងលើព្រឹទ្ធសមាជិក ត្រូវតែប្រកាសជូនអង្គសភាបានជ្រាបៈ

-ឈ្មោះបេក្ខជនជាប់ឆ្នោតជាស្ថាពរ ដែលគណៈកម្មាធិការជាតិរៀបចំការ បោះឆ្នោតបានបញ្ជូនមក។

-ឈ្មោះបេក្ខជនជាប់ឆ្នោត ដែលត្រូវបានគេប្តឹងតវ៉ា ហើយដែលក្រុមប្រឹក្សាធម្មនុញ្ញបានបដិសេធបណ្តឹងទាំងនោះ។

ឈ្មោះតំណាងរាស្ត្រពេញសិទ្ធិទាំងអស់ ដែលបានសម្រេចសុពលភាពរួចហើយ ត្រូវបិទផ្សាយក្នុងរដ្ឋសភា និងផ្សព្វផ្សាយជាសាធារណៈក្រោយពេលប្រជុំចប់ភ្លាម។[325]

អាសនៈរបស់តំណាងរាស្ត្រ ដែលនៅទំនេរ ដោយការសុំលាលែង ឬដោយបោះបង់ចោលការងារចំនួនបីខែ ដោយគ្មានការអនុញ្ញាត ឬដោយទទួលមរណភាព ដោយប្រាសចាកសមាជិកភាពនៃរដ្ឋសភា ឬដោយប្រាសចាកសមាជិកភាព ពីគណបក្សនយោបាយ ដែលបានជាប់ឆ្នោតត្រូវបំពេញជំនួសវិញដោយតំណាងរាស្ត្រថ្មី ទៅតាមលំដាប់លេខរៀងបន្ទាប់ ដែលជ្រើសរើសក្នុងបញ្ជីបេក្ខជនឈរឈ្មោះតំណាងគណបក្សមណ្ឌលជាមួយគ្នា។[326]

៤.អាណត្តិរដ្ឋសភា

(Parliament Mandate)

នីតិកាលរបស់រដ្ឋសភា មានអាណត្តិ៥ឆ្នាំ ហើយត្រូវផុតកំណត់ នៅពេលដែលរដ្ឋសភាថ្មីចូលកាន់តំណែង។ រដ្ឋសភាមិនអាចត្រូវបានរំលាយមុនផុតអាណត្តិបានឡើយ វៀរលែងតែក្នុងករណី ដែលរាជរដ្ឋាភិបាលត្រូវបានទម្លាក់ពីរដងក្នុងរយៈពេល១២ខែ(នៅសង្គមរាស្ត្រនិយម និងសាធារណៈរដ្ឋខ្មែរ១៨ខែ)។ ក្នុងករណីនេះ ព្រះមហាក្សត្រត្រូវរំលាយរដ្ឋសភា ក្រោយពីព្រះអង្គទ្រង់បានទទួលការស្នើពីនាយករដ្ឋមន្ត្រី និងបន្ទាប់ពីទ្រង់បានការយល់ព្រមពីប្រធានរដ្ឋសភា។

ការបោះឆ្នោតដើម្បីជ្រើសរើសសមាជិករដ្ឋសភាថ្មី នឹងប្រព្រឹត្តទៅក្នុងរយៈពេល៦០ថ្ងៃយ៉ាងយូរចាប់តាំងពីថ្ងៃរំលាយរដ្ឋសភាមក។[327]

ក្នុងរយៈពេលនេះរាជរដ្ឋាភិបាលមានភារកិច្ចដឹកនាំការងារប្រចាំថ្ងៃប៉ុណ្ណោះ។

---

[325] ប្រការ៣ថ្មីបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

[326] ប្រការ៨៣ថ្មីបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

[327] មាត្រា៧៨នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

ក្នុងពេលមានសង្គ្រាម ឬក្នុងកាល:ទេស:ពិសេសដទៃទៀតដែលមិនអាចធ្វើការបោះឆ្នោតទៅបាន។ រដ្ឋសភាអាចប្រកាសបន្តនីតិកាលរបស់ខ្លួន មួយដងបានមួយឆ្នាំ តាមសំណើរបស់ព្រះមហាក្សត្រ។[328]

ការប្រកាសបន្តនីតិកាលរបស់រដ្ឋសភាត្រូវសម្រេច ដោយមតិយល់ព្រមពីរភាគបី(២/៣)យ៉ាងតិចនៃចំនួនសមាជិករដ្ឋសភាទាំងមូល។[329]

ច.តួនាទីប្រធានរដ្ឋសភា

(Roles of President of National Assembly)

ប្រធានរដ្ឋសភាមានតួនាទីដូចជា:

-ប្រធានរដ្ឋសភាដឹកនាំអង្គប្រជុំរបស់រដ្ឋសភាទទួលអាញ្ញាត្តិច្បាប់ និងសេចក្តីសម្រេចចិត្តទាំងឡាយដែលរដ្ឋសភាបានអនុម័ត ធានាវ៉ាប់រងការអនុវត្តន៍បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា និងធ្វើការចាត់ចែងការងារ និងធ្វើទំនាក់ទំនងអន្តរជាតិទាំងឡាយរបស់រដ្ឋសភា។[330]

-ធានាការប្រព្រឹត្តទៅនៃរដ្ឋសភាឲ្យបានត្រឹមត្រូវស្របតាមរដ្ឋធម្មនុញ្ញ។

-ដឹកនាំការប្រជុំនៃរដ្ឋសភា។

-បើក និងលើកពេលប្រជុំនៃរដ្ឋសភា។

-រក្សាការពារសណ្តាប់ធ្នាប់ក្នុងរដ្ឋសភា។

-តំណាងរដ្ឋសភាក្នុងការធ្វើទំនាក់ទំនងជាមួយព្រះមហាក្សត្រ និងអាជ្ញាធរសោធារណៈ។

-ចាត់ចែងការពិភាក្សា ហើយចុះហត្ថលេខាលើកំណត់ហេតុនៃការប្រជុំរដ្ឋសភា។[331]

-កោះប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាដើម្បីប្រជុំពិភាក្សា និងធ្វើការអនុម័តទៅលើបញ្ហាផ្សេងៗ។ ដូចនេះ ប្រធានរដ្ឋសភាមានតួនាទីចុះហត្ថលេខាលើលិខិតអញ្ជើញកោះប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា។ ការប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ត្រូវមានកូរ៉ុម លើសពីពាក់កណ្តាលនៃចំនួនសមាជិកគណៈកម្មាធិការទាំងមូលគឺមានចំនួនយ៉ាងតិច៧រូប។

ការប្រជុំសភាពេញអង្គរបស់រដ្ឋសភា ជាទូទៅត្រូវប្រធានរដ្ឋសភា ជាអ្នកចុះហត្ថលេខាលើលិខិតអញ្ជើញសមាជិករដ្ឋសភាទាំងអស់ ដើម្បីមកចូលរួមប្រជុំទៅតាមកាលបរិច្ឆេទ និងទីកន្លែងប្រជុំច្បាស់លាស់។

---

[328] វាក្យខ័ណ្ឌ៥មាត្រា៧៨រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[329] មាត្រា៧៨រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[330] មាត្រា៨៧នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[331] ប្រការ៨បទបញ្ជាផ្ទៃក្នុងរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

-បើក និងការលើកពេលប្រជុំនៃរដ្ឋសភាមុនពេលចាប់ផ្តើមប្រជុំលេខាធិការរដ្ឋសភាត្រូវជម្រាបជូនអង្គសភាអំពីចំនួនកូរ៉ុម ប្រសិនបើកូរ៉ុមគ្រប់ចំនួនហើយ អង្គសភាអាចដំណើរការប្រជុំដែលប្រធានរដ្ឋសភាជាអ្នកប្រកាសបើកសម័យប្រជុំភ្លាម។

ប្រសិនបើ លេខាធិការរដ្ឋសភា ជម្រាបជូនអង្គសភាអំពីចំនួនកូរ៉ុម ហើយចំនួនកូរ៉ុមមិនគ្រប់នោះ ប្រធានរដ្ឋសភាត្រូវប្រកាសផ្អាកការប្រជុំបើកូរ៉ុមមិនគ្រប់ក្នុងរយៈពេល១៥នាទីបន្ទាប់ពីហួសពេលកំណត់នៃការចាប់ផ្តើមប្រជុំ។[332]

ការប្រជុំពិភាក្សាលើរបៀបវារៈចប់ ឬមិនចប់គឺអាស្រ័យពេលវេលាមុន នឹងបិទអង្គប្រជុំ ប្រធានរដ្ឋសភា ត្រូវប្រកាសជូនដំណឹងដល់សមាជិក និងសមាជិកានៃអង្គសភាទាំងមូលអំពីពេលវេលាប្រជុំថ្ងៃបន្តបន្ទាប់។

បើសិនអស់របៀបវារៈពិភាក្សា ប្រធានរដ្ឋសភាត្រូវប្រកាសលើកពេលប្រជុំ ដោយរងចាំទទួលលិខិតអញ្ជើញប្រជុំសាជាថ្មីទៀត។

-ប្រធានរដ្ឋសភាអាចសម្រេចបើសិនយល់ឃើញថាជាការមានប្រយោជន៍ ឬជាការចាំបាច់ ឬបើមានអ្នកតំណាងរាស្ត្រ១០នាក់យ៉ាងតិច ស្នើសុំដើម្បីឲ្យលើកពេលប្រជុំ នោះប្រធានរដ្ឋសភាអាចលើកពេលប្រជុំបាន។[333]

-ការពារកិត្តិយស និងសិទ្ធិរបស់រដ្ឋសភា ។

-ប្រធានរដ្ឋសភាជាអ្នកតែងតាំងបុគ្គលិកទាំងអស់នៃអគ្គលេខាធិការដ្ឋាន ការតែងតាំងត្រូវស្របទៅតាមច្បាប់ ស្តីពីលក្ខន្តិកៈមន្ត្រីរាជការរបស់ក្រុមនីតិប្បញ្ញត្តិ និងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។[334]

-ប្រធានរដ្ឋសភាជាអ្នកស្នើសុំតែងតាំងអគ្គលេខាធិការ និងអគ្គលេខាធិការរងក្រោយពីបានពិគ្រោះយោបល់ជាមួយអនុប្រធានទី១ និងអនុប្រធានទី២នៃរដ្ឋសភា។ អគ្គលេខាធិការ និងអគ្គលេខាធិការរងត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ។[335]

-ប្រធានរដ្ឋសភា ជាអ្នកចេញសេចក្តីសម្រេចនានាស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាន។

-ប្រធានរដ្ឋសភា ជាអ្នកសម្រេចតែងតាំងស៊ប់មន្ត្រីរាជការក្នុងក្របខ័ណ្ឌតាមសេចក្តីស្នើ

---

[332] ប្រការ៤៧ថ្មីបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

[333] ប្រការ៥៤បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

[334] ប្រការ១៧ថ្មីបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

[335] ប្រការ១៦បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

សុំពីអគ្គលេខាធិការរបស់រដ្ឋសភា។

-ចាត់ចែងការពិភាក្សា ហើយក៏ត្រូវចុះហត្ថលេខាលើកំណត់ហេតុនៃគ្រប់ការប្រជុំរបស់រដ្ឋសភា។

ប្រធានរដ្ឋសភាចុះហត្ថលេខាលើកំណត់ហេតុពិស្តារ នៅពេលចប់សម័យប្រជុំរដ្ឋសភាមួយលើកៗដែលមានរយៈពេល៣ខែយ៉ាងតិច។

-ប្រធានរដ្ឋសភា ជាអ្នកសម្រេចក្នុងការអនុញ្ញាតឲ្យផ្សព្វផ្សាយ ឬមិនអនុញ្ញាតឲ្យធ្វើការផ្សព្វផ្សាយលើកំណត់ហេតុនៃការប្រជុំទាំងអស់ និងឯកសារដទៃទៀតរបស់រដ្ឋសភា។កំណត់ហេតុ និងឯកសារផ្សេងៗត្រូវរក្សាទុកនៅក្នុងអគ្គលេខាធិការដ្ឋានរដ្ឋសភា។[336]

-ប្រធានរដ្ឋសភា ជាអ្នកសម្រេចកិច្ចការទាំងឡាយរបស់រដ្ឋសភាសំដៅធានាដល់ដំណើរការប្រព្រឹត្តទៅ ដោយផ្អែកលើច្បាប់គោលការណ៍សំខាន់ៗពីរ គឺច្បាប់រដ្ឋ ធម្មនុញ្ញ និងការប្រតិបត្តិតាមបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា។

-ប្រធានរដ្ឋសភា មានភារៈរក្សាការពារមិនឲ្យមានភយន្តរាយខាងក្នុងក្តីមកពីខាងក្រៅក្តីដែលកើតមានឡើងដល់រដ្ឋសភា។ ដើម្បីធ្វើឲ្យសម្រេចបានកិច្ចនេះ ប្រធានរដ្ឋសភាអាចប្រើកម្លាំងនគរបាល ឬសុំអន្តរាគមន៍ពីកម្លាំងកងទ័ពបាន។[337]

-ប្រធានរដ្ឋសភា មានសិទ្ធិបញ្ជាឲ្យបណ្តេញចេញភ្លាមៗបាន ក្នុងករណី ដែលជនណាម្នាក់ធ្វើឲ្យរំខានដល់ការពិភាក្សានៅពេលប្រជុំរដ្ឋសភា ដើម្បីរក្សាការពារសណ្តាប់ធ្នាប់ក្នុងរដ្ឋសភាឲ្យបានល្អប្រសើរឡើង។

-ប្រធានរដ្ឋសភា ជាអ្នកអនុញ្ញាតច្បាប់ជូន ឬមិនអនុញ្ញាតច្បាប់ជូនសមាជិករដ្ឋសភាគឺអាស្រ័យតាមកាលៈទេសៈ។

ជាធម្មតា ប្រធានរដ្ឋសភាអាចអនុញ្ញាតច្បាប់ជូនសមាជិកសមាជិការដ្ឋសភាម្នាក់ៗបានឈប់សម្រាកបានយ៉ាងយូរ១៥ថ្ងៃនៅក្នុងសម័យប្រជុំរដ្ឋសភានីមួយៗ។[338]

-ប្រធានរដ្ឋសភា ជាអ្នកគ្រប់គ្រងយន្តការនានា និងលើកស្ទួយការងាររបស់រដ្ឋសភា។

-ប្រធានរដ្ឋសភា តំណាងឲ្យរដ្ឋសភាក្នុងការធ្វើទំនាក់ទំនងលើបញ្ហាផ្សេងៗ ជាមួយនឹងព្រះមហាក្សត្រ និងអាជ្ញាធរសាធារណៈ។[339]

---

[336] ប្រការ១៨បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

[337] ប្រការ៦៣បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

[338] ប្រការ៦៨បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

[339] ប្រការ៨ថ្មីបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

ឆ.តួនាទីអនុប្រធានរដ្ឋសភា

(Roles of Vice-President of National Assembly)

អនុប្រធានរដ្ឋសភាទាំងពីរ ជួយធ្វើការប្រធានទៅតាមការបែងចែកភារកិច្ចពីប្រធាន។ កាលបើប្រធានអវត្តមាន ដោយមកធ្វើការពុំបាន អនុប្រធានធ្វើការជំនួសប្រធានក្នុងឋានៈជាប្រធានស្តីទីតាមរយៈលិខិតផ្ទេរសិទ្ធិ។[340]

ក្នុងករណី ដែលប្រធានរដ្ឋសភាមានធុរៈមិនអាចបំពេញមុខងារបានដោយហេតុមកពីមានជំងឺ ឬបំពេញមុខងារជាប្រមុខរដ្ឋស្តីទី ឬជាព្រះរាជានុសិទ្ធិ ឬបំពេញបេសកម្មនៅបរទេសមួយរយៈអនុប្រធានរដ្ឋសភាមួយរូបត្រូវទទួលភារកិច្ចចាត់ចែងការងារជំនួស។

ក្នុងករណីដែលប្រធាន ឬអនុប្រធានរដ្ឋសភាលាលែងពីមុខតំណែង ឬក៏ទទួលមរណភាព រដ្ឋសភាត្រូវបោះឆ្នោតជ្រើសតាំងប្រធាន ឬអនុប្រធានថ្មី។[341]

ជ.តួនាទីរបស់តំណាងរាស្ត្រ

(Roles of Representatives)

តំណាងរាស្ត្រ មានតួនាទីជាអ្នកផ្តួចផ្តើមធ្វើច្បាប់ អនុម័តច្បាប់ និងតាមដានការអនុវត្តន៍ច្បាប់របស់រាជរដ្ឋាភិបាល។

តំណាងរាស្ត្រ មានសិទ្ធិស្នើធ្វើវិសោធនកម្មច្បាប់ ក៏ប៉ុន្តែសំណើនេះ មិនអាចទទួលបានទេ បើសិនការធ្វើវិសោធនកម្មច្បាប់នោះ សំដៅដល់ការកាត់បន្ថយប្រាក់ចំណូលសាធារណៈ ឬបន្ថែមបន្ទុកលើប្រជាពលរដ្ឋ។[342]

អ្នកតំណាងរាស្ត្រគ្រប់រូប គឺអាចស្នើសុំធ្វើវិសោធនកម្មទៅលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់បាន ប៉ុន្តែពាក្យសុំធ្វើវិសោធនកម្មនេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរជូនទៅគណៈកម្មការជំនាញក៏បាន ឬជូនទៅរដ្ឋសភាក្នុងពេលប្រជុំពេញអង្គក៏បាន។[343]

តំណាងរាស្ត្រ គឺមានសិទ្ធិដាក់សំណួរដល់រាជរដ្ឋាភិបាលសំណួរទាំងអស់នេះ ត្រូវសរសេរជាលាយលក្ខណ៍អក្សរហើយប្រគល់ជូនរដ្ឋសភាតាមរយៈប្រធានរដ្ឋសភា។

ចម្លើយអាចធ្វើឡើងដោយរដ្ឋមន្ត្រីមួយរូប ឬច្រើនរូបអាស្រ័យដោយបញ្ហាដែលបានចោទឡើងពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់រដ្ឋមន្ត្រីមួយរូបឬច្រើនរូប។

---

[340] ប្រការ៩ថ្មីបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

[341] មាត្រា៨៧រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[342] មាត្រា៩១ថ្មីនៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[343] ប្រការ២៦នៃបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

បើបញ្ហាពាក់ព័ន្ធដល់នយោបាយទូទៅរបស់រាជរដ្ឋាភិបាល នាយករដ្ឋមន្ត្រីត្រូវឆ្លើយផ្ទាល់ខ្លួន ។

ចម្លើយរបស់រដ្ឋមន្ត្រី ឬចម្លើយរបស់នាយករដ្ឋមន្ត្រី អាចធ្វើដោយផ្ទាល់មាត់ ឬសរសេរជាលាយលក្ខណ៍អក្សរ។ ចម្លើយខាងលើនេះ ត្រូវធ្វើឡើងក្នុងរយៈពេលប្រាំពីរថ្ងៃបន្ទាប់ពីបានទទួលសំណួររហើយ ។

ចំពោះ ចម្លើយផ្ទាល់មាត់របស់រដ្ឋមន្ត្រី ឬនាយករដ្ឋមន្ត្រី ដែលប្រធានរដ្ឋសភាបានសម្រេចបើកឲ្យមាន ឬមិនឲ្យមានការជជែកដេញដោល។ បើគ្មានការបើកឲ្យជជែកដេញដោលទេនោះ ចម្លើយរបស់រដ្ឋមន្ត្រី ឬរបស់នាយករដ្ឋមន្ត្រីនឹងត្រូវបញ្ចប់សំណួរតែម្តង។

បើមានការបើកឲ្យជជែកដេញដោលម្ចាស់សំណួរឬវាគ្មិនឯទៀត និងរដ្ឋមន្ត្រីដែលពាក់ព័ន្ធ ឬនាយករដ្ឋមន្ត្រី អាចជជែកផ្លាស់ប្តូរយោបល់ទៅវិញទៅមក ក្នុងរយៈពេល ដែលមិនអាចលើសពីមួយពេលប្រជុំឡើយ។

រដ្ឋសភាកំណត់ទុកពេលមួយថ្ងៃក្នុងមួយសប្តាហ៍ សម្រាប់ធ្វើការឆ្លើយសំណួរ។

ទោះបីយ៉ាងណាក៏ដោយ ក៏សម័យប្រជុំសម្រាប់ឆ្លើយសំណួរខាងលើនេះមិនអាចបើកលទ្ធភាពឲ្យមានការបោះឆ្នោតប្រភេទណាមួយបានឡើយ។[344]

តំណាងរាស្ត្រ ដែលបានតាំងជាសំណួរ ចំពោះរដ្ឋមន្ត្រីណាមួយក៏អាចសុំដកលិខិតតាំងជាសំណួររបស់ខ្លួនចេញបាន។ តំណាងរាស្ត្រឯទៀត អាចទទួលពាក្យសុំតាំងសំណួរដែលដកចេញហើយនោះទៅជូនប្រធានរដ្ឋសភាសាជាថ្មីទៀតបាន កាលបើយល់ឃើញថា ចាំបាច់ បើមានការបើកឲ្យជជែកដេញដោល ម្ចាស់សំណួរ ឬវាគ្មិនឯទៀត និងរដ្ឋមន្ត្រីពាក់ព័ន្ធ ព្រមទាំងនាយករដ្ឋមន្ត្រី អាចជជែកប្តូរយោបល់ ក្នុងរយៈពេល ដែលមិនអាចលើសពីមួយពេលប្រជុំឡើយ។ រដ្ឋសភាកំណត់ទុកពេលមួយថ្ងៃក្នុងមួយសប្តាហ៍ ដើម្បីឲ្យអ្នកតំណាងរាស្ត្រសម្រាប់ចោទសួរ ដល់រាជរដ្ឋាភិបាល(ការប្រជុំនេះមិនទាមទារចំនួនកូរ៉ុមទេ)។

បើសំណួរ ចម្លើយរបស់នាយករដ្ឋមន្ត្រី នាយករដ្ឋមន្ត្រី ឬតំណាងក្នុងករណីដែលនាយករដ្ឋមន្ត្រីមានធុរៈត្រូវមកឆ្លើយសំណួរបាន។ តែបើសំណួរចម្លើយនៃសមាជិករាជរដ្ឋាភិបាលរូបណាសមាជិករូបនោះត្រូវមកឆ្លើយសំណួរនៅរដ្ឋសភា។

ទោះបីជាយ៉ាងណាក៏ដោយក៏សម័យប្រជុំ សម្រាប់ឆ្លើយសំណួរខាងលើនេះ មិនអាចបើកលទ្ធភាពឲ្យមានការបោះឆ្នោតប្រភេទណាមួយបានឡើយ[345]។

---

[344] មាត្រា៩៦នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[345] ប្រការ៣៣ថ្មីនៃបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

ជាពិសេសតំណាងរាស្ត្រត្រូវបំពេញបេសកកម្មទៅតាមបណ្តាខេត្តក្រុង ដើម្បីចុះជួយដល់ប្រជាពលរដ្ឋ និងទទួលសំណូមពរផ្សេងៗ ពីប្រជាពលរដ្ឋ។ តំណាងរាស្ត្រ ត្រូវចូលរួមសហប្រតិបត្តិការអន្តរជាតិ ដកបទពិសោធន៍ធ្វើទំនាក់ទំនងអន្តរជាតិអូសទាញអ្នកវិនិយោគធំៗ ដើម្បីមកធ្វើវិនិយោគនៅព្រះរាជាណាចក្រកម្ពុជា។

ឈ.គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា

(Permanent Committee of National Assembly)

១-សមាសភាព

(Compositions)

ជាទូទៅរដ្ឋសភា មានគណៈកម្មាធិការអចិន្ត្រៃយ៍មួយ ដែលមានសមាជិកទាំងអស់ចំនួន ១៣រូបសមាសភាពគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភារួមមាន:

-ប្រធានរដ្ឋសភា១រូបជាប្រធាន

-អនុប្រធានទី១រដ្ឋសភា១រូបជាសមាជិក

-អនុប្រធានទី២រដ្ឋសភា១រូបជាសមាជិក

-ប្រធានគណៈកម្មការជំនាញនានាទាំង១០ដែលទាំង១០រូបជាសមាជិក

គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាមានអាណត្តិស្មើនឹងនីតិកាលរបស់រដ្ឋសភា។[346]

២-តួនាទី

(Roles)

គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាមានតួនាទីសំខាន់ណាស់ ក្នុងការធានានូវាល់ដំណើរការប្រព្រឹត្តទៅរបស់រដ្ឋសភា។

តួនាទីនិងការកិច្ចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភារួមមាន:

-ចាត់ចែងការងាររបស់រដ្ឋសភានៅចន្លោះសម័យប្រជុំរដ្ឋសភា។

-កោះប្រជុំរដ្ឋសភាជាវិសាមញ្ញ ប្រសិនបើមានសំណូមពរពីព្រះមហាក្សត្រ ឬក៏មានសេចក្តីស្នើសុំពីនាយករដ្ឋមន្ត្រី ឬពីសមាជិករដ្ឋសភាចំនួនមួយភាគបី១ភាគ៣យ៉ាងតិច។[347]

-រាយការណ៍អំពីសកម្មភាពនានារបស់រដ្ឋសភានូវគ្រប់ចន្លោះសម័យប្រជុំរដ្ឋសភា នៅពេលបើកសម័យប្រជុំនីមួយៗ។

-ជាអ្នកកំណត់កាលបរិច្ឆេទ និងរបៀបវារៈនៃសម័យប្រជុំនីមួយៗរបស់រដ្ឋសភា។

---

[346] ប្រការ៧ថ្មី(ពីរ)បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

[347] មាត្រា៨៣នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

-គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ជាអ្នករៀបចំរបៀបវារៈ ក្នុងការកំណត់ពេលប្រជុំនីមួយៗ មុនផុតពេលប្រជុំនីមួយៗប្រធានត្រូវអានរបៀបវារៈសម្រាប់ពេលប្រជុំបន្តទៅទៀត។[348]

នៅក្នុងរបៀបវារៈនេះត្រូវមានសេចក្តីជាលំដាប់មុនក្រោយដូចតទៅនេះ៖

១-បញ្ហាទាំងឡាយដែលរដ្ឋសភាបានសម្រេចថាទុកជាការប្រញាប់។

២-បញ្ហាទាំងឡាយដែលរាជរដ្ឋាភិបាលដាក់ជូនមករដ្ឋសភា។[349]

-គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ត្រូវបញ្ជូនសេចក្តីស្នើសុំទាំងឡាយរបស់រាជរដ្ឋាភិបាលទៅគណៈកម្មការនីមួយៗ ទៅតាមមុខជំនាញនានាឲ្យធ្វើការត្រួតពិនិត្យ។ កាលបើបានពិនិត្យរួចហើយប្រធានគណៈកម្មការជំនាញ ត្រូវនាំយកយោបល់របស់គណៈកម្មការមកជម្រាបជូនរដ្ឋសភាឲ្យបានជ្រាប។[350]

-គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ជាអ្នកកំណត់នូវសេចក្តីស្នើថវិការបស់រដ្ឋសភាហើយត្រូវបញ្ជូនទៅក្រសួងមានសមត្ថកិច្ចដើម្បីបញ្ចូលក្នុងគម្រោងថវិកាជាតិ។[351]

-គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ជាអ្នកត្រួតពិនិត្យ និងសម្រេចលើរបាយការណ៍ក្នុងការទូទាត់ចំណាយថវិការបស់រដ្ឋសភានៅរាល់ដំណាច់ឆ្នាំ ហើយត្រូវបញ្ជូនទៅក្រសួងមានសមត្ថកិច្ច ដើម្បីរៀបចំបញ្ចូលក្នុងសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋ។[352]

-គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ជាអ្នកដាក់ទណ្ឌកម្ម និងវិន័យលើសមាជិករដ្ឋសភាដោយស្វ័យប្រវត្តិកាលបើបានដឹងច្បាស់ថា មូលហេតុដែលសមាជិករដ្ឋសភាខកខានមកប្រជុំនោះមិនអាចយកជាការបាន រៀវលែងតែករណី ដែលរដ្ឋសភាបានទទួលពាក្យតវ៉ា សមហេតុសមផលអំពីសាមីខ្លួនក្នុងពេលប្រជុំពេញអង្គ។[353]

-គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ត្រូវរៀបចំរបបប្រាក់បំណាច់របបធានាប៉ាប់រងសង្គមរបបបេសកកម្ម និងលក្ខខណ្ឌធ្វើការងាររបស់តំណាងរាស្ត្រ។[354]

---

[348] ប្រការ១៩នៃបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

[349] ប្រការ២០នៃបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

[350] ប្រការ២១នៃបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

[351] ប្រការ៣១ថ្មី(២)នៃបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

[352] វាក្យខ័ណ្ឌ២ប្រការ៣១ថ្មី(២)នៃបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

[353] ប្រការ៧២នៃបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

[354] ប្រការ៤ថ្មីនៃបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

-គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ជាអ្នកលើកសំណើ ជូនអង្គសភា ដើម្បីធ្វើការពិនិត្យ និងសម្រេច លើសេចក្តីស្នើសុំចោទប្រកាន់ ការចាប់ខ្លួន និងការឃុំខ្លួន សមាជិករដ្ឋសភាណាមួយ ដើម្បីអនុម័តសម្រេច។

-ដាក់ជូនអង្គសភាដើម្បីពិនិត្យ និងសម្រេចអំពីអភ័យឯកសិទ្ធិតំណាងរាស្ត្រ។

-ការពារផលប្រយោជន៍ និងអភ័យឯកសិទ្ធិតំណាងរាស្ត្រ។

-ជានាក្នុងការផ្តល់គ្រឿងឥស្សរិយយសជូនដល់សមាជិករដ្ឋសភា។

-គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ជាអ្នកបង្កើតគណៈកម្មការផ្សេងៗ ដើម្បីបម្រើការងារចាំបាច់ឲ្យរដ្ឋសភា។

-រៀបចំសមាសភាពលេខាធិការ៣រូប សម្រាប់សម័យប្រជុំបន្ទាប់ ក្នុងការដាក់ជូនអង្គប្រជុំ ដើម្បីឲ្យរដ្ឋសភាអនុម័តសម្រេច។

-ជានាការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា។

-ជានាការគ្រប់គ្រង និងការចំណាយថវិការដ្ឋសភា ឲ្យប្រព្រឹត្តទៅបានត្រឹមត្រូវស្របតាមការកំណត់ក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។

-គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ជាអ្នកលើកសំណើជូនអង្គសភា អំពីករណីការចោទប្រកាន់ការចាប់ខ្លួន និងការឃុំខ្លួនសមាជិករដ្ឋសភាណាមួយដោយអនុវត្តតាមកថាខ័ណ្ឌទី៣ និងទី៤នៃមាត្រា៨០នៃរដ្ឋធម្មនុញ្ញ។

-គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ជាអ្នកលើកសំណើ ជូនអង្គសភាពិនិត្យ និងសម្រេចលើការផ្អាកការឃុំខ្លួន ការចោទប្រកាន់សមាជិករដ្ឋសភាណាមួយ ដោយសម្លេងបីភាគ៤(៣/៤)នៃចំនួនរដ្ឋសភាទាំងមូល។

-គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ជាអ្នកលើកសំណើ ជូនអង្គសភាពិនិត្យ និងសម្រេចអំពីការលើកអភ័យឯកសិទ្ធិសភារបស់សមាជិករដ្ឋសភាណាមួយ។

-គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ជាអ្នកលើកសំណើ ជូនអង្គសភាពិនិត្យ និងសម្រេចការប្រគល់ជូនមកវិញនូវអភ័យឯកសិទ្ធិសភា ការបោះបង់ចោលការងារ វិសមិតភាព និងការប្រាសចាកសមាជិកភាពរដ្ឋសភាដោយសម្លេងពីរភាគបី(២/៣)នៃចំនួនរដ្ឋសភាទាំងមូល។[355]

ញ.គណៈកម្មការជំនាញនានារដ្ឋសភា

(Other Commissions of National Assembly)

គណៈកម្មការជំនាញនានារបស់រដ្ឋសភា ត្រូវបានបង្កើតឡើងក្នុងពេលតែមួយជាមួយនឹង

[355] ប្រការ៧៧ថ្មី(ពីរ)បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

ការបង្កើតអង្គការរដ្ឋសភាដែរ។[356]

១-ការជ្រើសរើសគណៈកម្មការជំនាញ

(The Selection of Expert Commission)

ក្នុងករណីធម្មតារដ្ឋសភាត្រូវធ្វើការបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នានូវសមាជិកគណៈកម្មការនានានៃរដ្ឋសភា។ គណៈកម្មការនីមួយៗ ត្រូវធ្វើការជ្រើសតាំងប្រធានមួយរូប អនុប្រធានមួយរូប និងលេខាធិការមួយរូបដោយវិធីបោះឆ្នោត។

ក្នុងករណីដែលស្ថានភាពនយោបាយ តម្រូវឲ្យអនុវត្តន៍តាមច្បាប់រដ្ឋធម្មនុញ្ញបន្ថែម ដើម្បីសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិការជ្រើសរើសប្រធាន និងអនុប្រធានគណៈនៃកម្មការជំនាញនានានៃរដ្ឋសភា ត្រូវធ្វើការអនុវត្តតាមបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាត្រង់ចំណុច ខ.២ នៃប្រការ២ថ្មី។[357]

បន្ទាប់មករដ្ឋសភាគឺក៏អាចដំណើរការបន្ត ដើម្បីធ្វើការជ្រើសតាំងដាច់ដោយឡែកពីគ្នានូវសមាជិកគណៈកម្មការនានារបស់រដ្ឋសភា ដោយសម្លេងភាគច្រើនដាច់ខាត(៥0%+១)នៃចំនួនសមាជិករដ្ឋសភាទាំងមូល។[358]

នៅក្នុងគណៈកម្មការជំនាញនីមួយៗរបស់រដ្ឋសភាជាទូទៅត្រូវមាន:

-ប្រធានគណៈកម្មការ ១រូប

-អនុប្រធានគណៈកម្មការ ១រូប

-លេខាធិការ ១រូប

-និងសមាជិកសរុបនៃគណៈកម្មការនីមួយៗមានចំនួនយ៉ាងតិច៧រូប

ជាទូទៅ សមាជិករដ្ឋសភាមួយរូបអាចបំពេញការងារ នៅក្នុងគណៈកម្មការជំនាញនានាពីរបាន។ ក្នុងករណី ប្រធានគណៈកម្មការអវត្តមានដោយមូលហេតុណាមួយ អនុប្រធានគណៈកម្មការត្រូវបំពេញការងារជំនួសប្រធានតាមរយៈលិខិតផ្ទេរសិទ្ធិ។

គណៈកម្មការនីមួយៗអាចស្នើសុំប្រធានរដ្ឋសភាជ្រើសតាំងអ្នកជំនាញ ឬអ្នកបច្ចេកទេសដែលមិនមែនជាសមាជិករដ្ឋសភាឲ្យមកជួយការងាររបស់គណៈកម្មការបាន ក៏ប៉ុន្តែអ្នកជំនាញ ឬអ្នកបច្ចេកទេសនោះមិនមានសិទ្ធិធ្វើការសម្រេចនៅក្នុងគណៈកម្មការនានាទាំងនោះទេ។[359]

---

[356] មាត្រា៨២ថ្មីនៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[357] ប្រការ៥ថ្មី(ពីរ)នៃបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

[358] ប្រការ១0ថ្មីបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

[359] ប្រការ១២បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

រដ្ឋសភាអាចតែងតាំង ឬបង្កើតគណៈកម្មការពិសេសណាមួយដើម្បីបំពេញបេសកកម្មឲ្យចូលរួមក្នុងការងារផ្សេងៗបាន ដែលមានសមាសភាពនៃចំនួនសមាជិកតិច ឬច្រើនអាស្រ័យទៅតាមតម្រូវការរបស់គណៈកម្មការ។[360]

ក្រុមសម្រាប់ប្រជុំគណៈកម្មការនានារបស់រដ្ឋសភា ត្រូវមានសមាជិកលើសពីពាក់កណ្តាលនៃចំនួនសមាជិកទាំងអស់។

២-គណៈកម្មការជំនាញឯកទេស

(Expert Commissions)

១-គណៈកម្មការសិទ្ធិមនុស្សទទួលពាក្យបណ្តឹងអង្កេត ទំនាក់ទំនងរដ្ឋសភា និងព្រឹទ្ធសភា។

២-គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម។

៣-គណៈកម្មការផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និង ធនធានទឹក។

៤-គណៈកម្មការមហាផ្ទៃ ការពារជាតិ អង្កេត បោសសម្អាត និងមុខងារ សាធារណៈ។

៥-គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន។

៦-គណៈកម្មការនីតិកម្ម និងយុត្តិធម៌។

៧-គណៈកម្មការអប់រំយុវជន និងកីឡា ធម្មការ កិច្ចការសាសនា វប្បធម៌ និងទេសចរណ៍។

៨-គណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី។

៩-គណៈកម្មការសាធារណការដឹកជញ្ជូន ទូរគមនាគមន៍ប្រៃសណីយ៍ ឧស្សាហកម្ម រ៉ែថាមពល ពាណិជ្ជកម្ម និងសំណង់។

១០-គណៈកម្មការអង្កេត បោសសំអាត និងប្រឆាំងអំពើពុករលួយ។[361]

៣-តួនាទីគណៈកម្មការនានារបស់រដ្ឋសភា

(Roles of Commissions of National Assembly)

គណៈកម្មការនីមួយៗជាទូទៅមានតួនាទីដូចជា:

-គណៈកម្មការនីមួយៗអាចស្នើសុំឲ្យប្រធានរដ្ឋសភា ចាត់តាំងអ្នកជំនាញដែលមិនមែនជាអ្នកតំណាងរាស្ត្រឲ្យចូលរួមធ្វើការបាន ប៉ុន្តែអ្នកជំនាញទាំងនោះ គ្មានសិទ្ធិសម្រេចនៅក្នុងគណៈកម្មការនានានោះបានទេ។[362]

---

[360] ប្រការ១១បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

[361] ប្រការ៦ថ្មី(ពីរ)បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

[362] ប្រការ១២បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

-គណៈកម្មការនានារបស់រដ្ឋសភា អាចកោះអញ្ជើញតំណាងរាជរដ្ឋាភិបាលមកបំភ្លឺពាក់ព័ន្ធនឹងសេចក្តីព្រាងច្បាប់របស់រាជរដ្ឋាភិបាល។

-គណៈកម្មការទាំងឡាយរបស់រដ្ឋសភាអាចអញ្ជើញរដ្ឋមន្ត្រីមកបំភ្លឺអំពីបញ្ហាអ្វីមួយ ដែលពាក់ព័ន្ធនឹងវិស័យទទួលខុសត្រូវរបស់ខ្លួនបាន។[363]

-គណៈកម្មការជំនាញនីមួយៗ ជាអ្នកទទួលសេចក្តីព្រាងច្បាប់ពីគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ហើយត្រូវធ្វើការពិភាក្សា និងពិនិត្យឲ្យបានត្រឹមត្រូវ។ កាលបើពិនិត្យរួចហើយ ប្រធាននៃគណៈកម្មការនោះត្រូវនាំយកយោបល់របស់គណៈកម្មការមកជម្រាបជូនរដ្ឋសភា។

-គណៈកម្មការនានា អាចអនុញ្ញាតឲ្យអ្នករៀបចំ និងអ្នកតាក់តែងសេចក្តីស្នើច្បាប់ ហើយចូលរាយការណ៍ជម្រាប ជូនគណៈកម្មការជំនាញដែលពិនិត្យសេចក្តីស្នើច្បាប់នោះ។

-គណៈកម្មការជំនាញ មានសិទ្ធិសូមឲ្យរដ្ឋសភាលើកចោល ពុំពិចារណាក៏បាននូវកិច្ចការដែលគណៈកម្មាធិការអចិន្ត្រៃយ៍បានប្រគល់ជូន។

-គណៈកម្មការជំនាញ មានសិទ្ធិសូមឲ្យរដ្ឋសភាបញ្ចេញមតិជាមុនសិនថាតើគួរទទួលយកមកពិចារណាឬទេ?

-គណៈកម្មការជំនាញមានសិទ្ធិសូមឲ្យរដ្ឋសភាទទួលពិចារណា ហើយនឹងចាត់ទុកជាការប្រញាប់ផងក៏បានដែរ។

-គណៈកម្មការនីមួយៗ ត្រូវជ្រើសតាំងប្រធានមួយរូប អនុប្រធានមួយរូប និងលេខាធិការមួយរូបដោយវិធីបោះឆ្នោត។[364]

៥.អំពីឋិសមិតភាពសភា

(Incompatibility)

អាណត្តិរបស់សមាជិករដ្ឋសភា មានវិសមិតភាពជាមួយនឹងការបំពេញមុខងារសាធារណៈជាសកម្ម ជាមួយមុខងារសមាជិកនៃស្ថាប័នដទៃៗទៀត ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ និងច្បាប់ជាធរមានរៀរលែងតែទៅបំពេញមុខងារជាសមាជិកនៃគណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល។ ក្នុងករណីនេះ សមាជិករដ្ឋសភារូបនោះ ត្រូវមានឋានៈជាសមាជិករដ្ឋសភាធម្មតា ហើយមិនអាចមានមុខតំណែងណាមួយ នៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ និងនៅក្នុងគណៈកម្មការជំនាញផ្សេងៗនៃរដ្ឋសភាឡើយ។[365]

---

[363] មាត្រា៩៧រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[364] ប្រការ១០ថ្មីបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

[365] មាត្រា៧៩រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

ជាទូទៅ បេក្ខជនដែលត្រូវបានជាប់ឆ្នោតជ្រើសរើស ជាសមាជិករដ្ឋសភា ហើយសមាជិករដ្ឋសភាទាំងនោះ មិនអាចបំពេញការងារនៅក្នុងក្របខ័ណ្ឌជាមន្ត្រីសាធារណៈសកម្មបានទេមានមន្ត្រីមួយចនួនដូចជាមន្ត្រីរាជការស៊ីវិល មន្ត្រីនគរបាលជាតិ កងកម្លាំងអាវុធហត្ថ កងយោធពលខេមរភូមិន្ទ និងសមាជិកនៃអង្គការស្ថាប័នដទៃទៀត ប៉ុន្តែបើជាមន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងកម្លាំងនគរបាលជាតិ កងយោធពលខេមរភូមិន្ទ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម រួមទាំងបុព្វជិតសាសនា ដែលមានបំណងឈរឈ្មោះបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រ គឺត្រូវតែដាក់ពាក្យសុំច្បាប់ឈប់ពិសេស និងលាចាកសិក្ខាបទរហូតដល់ថ្ងៃប្រកាសលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ជាស្ថាពរយ៉ាងតិចប្រាំពីរ (៧) ថ្ងៃមុនថ្ងៃបើកយុទ្ធនាការឃោសនាបោះឆ្នោត។

ប្រសិនបើសាមីខ្លួនជាប់ឆ្នោត សាមីខ្លួនត្រូវធ្វើពាក្យសុំព្យួរតាមហានុក្រមទៅសាមីក្រសួងសាមីអង្គភាព ដើម្បីទៅបម្រើការងារក្រៅពីក្របខ័ណ្ឌដើមក្នុងរយៈពេលអាណត្តិរបស់ខ្លួន។

រយៈពេលស្ថិតនៅក្រៅក្របខ័ណ្ឌដើម សាមីខ្លួនត្រូវមានសិទ្ធិឡើងឋានន្តរសក្តិ និងឡើងថ្នាក់ដោយស្វ័យប្រវត្តិ និងរក្សាអតីតភាពការងារសម្រាប់ទទួលប្រាក់សោធននិវត្តន៍។

នៅពេលចប់អាណត្តិជាសមាជិករដ្ឋសភា សាមីខ្លួនអាចសុំវិលត្រឡប់ទៅបម្រើការងារនៅក្នុងក្រសួង ឬអង្គភាពដើមវិញបាន ប៉ុន្តែមុខងារតួនាទី គឺអាស្រ័យដោយសាមីក្រសួង ឬសាមីអង្គភាពជាអ្នកសម្រេច។[366]

តំណាងរាស្ត្រ ក្នុងមុខតំណែងមានវិសមិតភាពជាមួយនឹងមុខងារជាមេធាវី ដូចមានចែងនៅក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។[367]

៥.អំពីអភ័យឯកសិទ្ធិសភា

(Paliament Immunity)

តំណាងរាស្ត្រមានអភ័យឯកសិទ្ធិសភា អភ័យឯកសិទ្ធិនេះចែកចេញជាពីរផ្នែកគឺ:

-ធានាដល់ការបញ្ចេញមតិ និងយោបល់ក្នុងការអនុម័តច្បាប់ទាំងឡាយរបស់តំណាងរាស្ត្រនៅក្នុងក្របខ័ណ្ឌនៃការបំពេញមុខងារ និងតួនាទីជាអ្នកតំណាងរាស្ត្រមានអភ័យឯកសិទ្ធិដាច់ខាតរបស់តំណាងរាស្ត្រ។

-ធានាមិនឲ្យមានការចោទប្រកាន់ ឬការចាប់ខ្លួន ឬការឃាត់ខ្លួន ឬការឃុំខ្លួនតំណាងរាស្ត្រ

[366] មាត្រា៣៥ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិករដ្ឋសភា។

[367] មាត្រា១៧ មាត្រា១៨ មាត្រា១៩ នៃច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ។

ណាមួយឡើយគឺជា**អភ័យឯកសិទ្ធិដោយប្រៀប**របស់តំណាងរាស្ត្រ។[368]

តំណាងរាស្ត្រ មិនអាចឆ្លៀតឱកាសប្រើអភ័យឯកសិទ្ធិសភានេះ ដោយរំលោភដែលនាំឲ្យប៉ះពាល់ទៅដល់ កិត្តិយសរបស់បុគ្គលដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ។[369]

ជាទូទៅសមាជិករដ្ឋសភារូបណាក៏ដោយ ក៏មិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួន ដោយហេតុពីការសម្តែងយោបល់ ឬបញ្ចេញមតិនៅក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ ។ ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនសមាជិករដ្ឋសភាណាមួយនឹងអាចធ្វើទៅបាន លុះត្រាតែ មានការយល់ព្រមពីរដ្ឋសភា ឬពីគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា វៀរលែងតែក្នុងករណី ដែលសមាជិករដ្ឋសភារូបនោះ បានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌជាក់ស្តែងតែប៉ុណ្ណោះ។

ក្នុងករណីនេះ ក្រសួងមានសមត្ថកិច្ច ត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា ឬជូនគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាជាបន្ទាន់ដើម្បីធ្វើការសម្រេច។

សេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ត្រូវដាក់ជូនសម័យប្រជុំរដ្ឋសភានាពេលខាងមុខ ដើម្បីធ្វើការអនុម័តសម្រេច ដោយមតិភាគច្រើនពីរភាគបី(២/៣)នៃចំនួនសមាជិករដ្ឋសភាទាំងមូល។

សមាជិករដ្ឋសភារូបណា ដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ នឹងអាចបើកឲ្យមានការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ការឃុំខ្លួនតាមផ្លូវច្បាប់ និងនីតិវិធីបានលុះត្រាតែ មានការលើកលែងអភ័យឯកសិទ្ធិសភារបស់សមាជិករដ្ឋសភារូបនោះជាមុនសិន។[370]

សេចក្តីស្នើសុំ ដើម្បីលើកអភ័យឯកសិទ្ធិសភា របស់សមាជិករដ្ឋសភារូបណាមួយ ត្រូវតែធ្វើឡើងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលមានភ្ជាប់មកជាមួយនូវសេចក្តីថ្លែងហេតុ ដើម្បីផ្ញើមកប្រធានរដ្ឋសភា។[371]

ការលើកអភ័យឯកសិទ្ធិសភា ត្រូវធ្វើនៅក្នុងសម័យចន្លោះ ប្រជុំរដ្ឋសភា ដែលគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាត្រូវធ្វើការពិនិត្យ និងពិចារណា ដោយផ្អែកទៅលើបទល្មើស និងកស្តុតាង

[368] មាត្រា៤ នៃច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ ។

[369] មាត្រា៥នៃច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ។

[370] មាត្រា៧នៃច្បាប់ស្តីពីលក្ខន្តិកៈសមាជិករដ្ឋសភា។

[371] មាត្រា៨នៃច្បាប់ស្តីពីលក្ខន្តិកៈសមាជិករដ្ឋសភា។

ផ្សេងៗ និងសេចក្តីថ្លែងហេតុ របស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ហើយត្រូវបានធ្វើការប្រជុំ និងអនុម័តសម្រេចឲ្យសមស្របទៅនឹងបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា សេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ត្រូវដាក់នៅក្នុងសម័យចន្លោះប្រជុំពេញអង្គរដ្ឋសភា ដើម្បីដកអភ័យឯកសិទ្ធិសភាសមាជិករដ្ឋសភារូបណាមួយ ដោយសម្លេងអនុម័ត តាមមតិភាគច្រើនពីរភាគបី(២/៣)នៃចំនួនសមាជិករដ្ឋសភាទាំងមូល។[372]

ការលើកអភ័យឯកសិទ្ធិសភា របស់សមាជិករដ្ឋសភាណាមួយ នៅក្នុងសម័យប្រជុំត្រូវតែអនុវត្តន៍ទៅតាមនីតិវិធីដូចតទៅ:

-រដ្ឋសភាអាចកោះប្រជុំជាសម្ងាត់ ដោយមានការស្នើសុំពីប្រធានរដ្ឋសភា ឬពីសមាជិករដ្ឋសភាដែលមានចំនួនមួយភាគដប់(១/១០)យ៉ាងតិច និងពីនាយករដ្ឋមន្ត្រី។

-កូរ៉ុមនៃការប្រជុំត្រូវមានចំនួនសមាជិករដ្ឋសភា លើសពីពីរភាគបី(២/៣)នៃចំនួនសមាជិករដ្ឋសភាទាំងមូល។

-ការអនុម័ត និងសម្រេច ដោយយកសម្លេងភាគច្រើនពីរភាគបី(២/៣)នៃចំនួនសមាជិករដ្ឋសភាទាំងមូល។[373]

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនសមាជិករដ្ឋសភាណាមួយ ដែលអាចធ្វើទៅបាន លុះត្រាតែមានការយល់ព្រមពីរដ្ឋសភា ឬពីគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា វៀរលែងតែក្នុងករណី ដែលសមាជិករដ្ឋសភារូបនោះ ត្រូវបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌជាក់ស្តែងតែប៉ុណ្ណោះ។

ក្នុងករណីនេះ ក្រសួងមានសមត្ថកិច្ច ត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា ឬជូនគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាជាបន្ទាន់ដើម្បីធ្វើការសម្រេច។ សេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ត្រូវដាក់ជូនក្នុងសម័យប្រជុំរដ្ឋសភានាពេលខាងមុខ ដើម្បីធ្វើការអនុម័តសម្រេច ដោយមតិភាគច្រើនពីរភាគបី(២/៣)នៃចំនួនសមាជិករដ្ឋសភាទាំងមូល។[374]

ក្នុងករណីទាំងអស់ខាងលើ រាល់ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន និងការឃុំខ្លួនសមាជិករដ្ឋសភាណាមួយត្រូវផ្អាក ប្រសិនបើរដ្ឋសភាទាំងមូលបានបញ្ចេញមតិ ឲ្យផ្អាកសិនដោយអនុម័តសម្រេច តាមមតិភាគច្រើនបីភាគបួន(៣/៤)នៃចំនួនសមាជិករដ្ឋសភាទាំងមូល។[375]

---

[372] មាត្រា១១នៃច្បាប់ស្តីពីលក្ខន្តិក:សមាជិករដ្ឋសភា។

[373] មាត្រា៩នៃច្បាប់ស្តីពីលក្ខន្តិក:សមាជិករដ្ឋសភា។

[374] មាត្រា៨០រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[375] មាត្រា១៣នៃច្បាប់ស្តីពីលក្ខន្តិក:សមាជិករដ្ឋសភា។

សមាជិកតំណាងរាស្ត្រ ដែលត្រូវបានលើកលែងអភ័យឯកសិទ្ធិសភាហើយនោះ ត្រូវស្ថិតក្នុងការចោទប្រកាន់របស់តុលាការ ក៏ប៉ុន្តែសមាជិករដ្ឋសភានោះនៅតែមានសិទ្ធិ និងបុព្វសិទ្ធិ ដូចសមាជិករដ្ឋសភាទូទៅផងដែរ។

សមាជិករដ្ឋសភាដែលស្ថិតនៅក្នុងការចាប់ខ្លួន ឬការឃាត់ខ្លួន ឬការឃុំខ្លួនជាបណ្តោះអាសន្ន សមាជិករដ្ឋសភានោះត្រូវបាត់បង់សិទ្ធិក្នុងការចូលរួមប្រជុំរបស់រដ្ឋសភា និងគណៈកម្មការផ្សេងៗ ប៉ុន្តែនៅមានសិទ្ធិទទួលប្រាក់បំណាច់ រៀរលែងតែប្រាក់បំណាច់នៃការប្រជុំ ប្រាក់បំណាច់បេសកកម្ម និងប្រាក់ប្រែងឥន្ធនៈតែប៉ុណ្ណោះ។

តំណាងរាស្ត្រ ដែលមានសាលក្រមចូលជាស្ថាពរ ឬសាលដីកាស្ថាពរបានសម្រេចថាជាទណ្ឌិតជាប់ពន្ធនាគារ តំណាងរាស្ត្ររូបនោះបានត្រូវបាត់បង់ទាំងស្រុងនូវសិទ្ធិ និងបុព្វសិទ្ធិជាសមាជិកភាពនៃសមាជិករដ្ឋសភា។[376]

តំណាងរាស្ត្រណាមួយជាទណ្ឌិត ហើយត្រូវបានព្រះមហាក្សត្រលើកលែងទោសតំណាងរាស្ត្ររូបណាមួយ តំណាងរាស្ត្រនោះនឹងទទួលបាននូវសុពលភាពអំពីអភ័យឯកសិទ្ធិ និងបុព្វសិទ្ធិឡើងវិញដោយស្វ័យប្រវត្តិ។[377]

តំណាងរាស្ត្ររូបណាមួយ ដែលមានសាលក្រមចូលជាស្ថាពរ ឬសាលដីកាជាស្ថាពរ បានសម្រេចថា ជាជនគ្មានទោសតំណាងរាស្ត្ររូបនោះនឹងត្រូវទទួលបានជាស្វ័យប្រវត្តិនូវអភ័យឯកសិទ្ធិ និងបុព្វសិទ្ធិពេញលេញឡើងវិញ។[378]

ក្នុងករណីទាំងអស់ខាងលើ រាល់ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ ខ្លួន ឬការឃុំខ្លួនត្រូវផ្អាកប្រសិនបើរដ្ឋសភាបានបញ្ចេញមតិឲ្យផ្អាក តាមការអនុម័តមតិភាគច្រើនបីភាគបួន (៣/៤)នៃសមាជិករដ្ឋសភាទាំងមូល។[379]

ក្នុងករណី សមាជិករដ្ឋសភាណាម្នាក់ត្រូវបានទទួលមរណភាព ឬសុំលាលែងពីសមាជិកភាពជាតំណាងរាស្ត្រ ឬប្រាសចាកសមាជិកភាពរដ្ឋសភា ដោយសាមូលហេតុផ្សេងៗ ដូចករណីដែលសមាជិករបស់គណបក្សនយោបាយមួយ បានសុំលាលែងចេញពីគណបក្សនោះ សាមីខ្លួនដែលបានសុំនោះ ត្រូវបានបាត់បង់សមាជិកភាពតំណាងរាស្ត្រ ដោយស្វ័យប្រវត្តិ ដែលកើតឡើងប្រាំមួយ(៦)ខែយ៉ាងតិចមុនពេលចប់នីតិកាល សាមីគណបក្សនយោបាយនោះ អាចស្នើសុំធ្វើ

[376] មាត្រា១៤នៃច្បាប់ស្តីពីលក្ខន្តិកៈសមាជិករដ្ឋសភា។

[377] មាត្រា១៥ នៃច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ ។

[378] មាត្រា១៦ នៃច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ ។

[379] មាត្រា៨០នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

ការជ្រើសតាំងសមាជិកថ្មីមកជំនួសបាន ដោយជ្រើសរើសក្នុងចំណោមបេក្ខជនដែលមានឈ្មោះតាមលេខរៀង នៅក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនៃមណ្ឌលរបស់សាមីខ្លួននោះមកជំនួសវិញដោយមិនចាំបាច់ធ្វើការបោះឆ្នោតឡើងវិញនោះទេ។[380]

ឧ.អំពីឋានៈ និងបុព្វសិទ្ធិសភា

(Position and Prerogative of Assembly)

ជាទូទៅសមាជិករដ្ឋសភា គឺមានឋានៈ និងបុព្វសិទ្ធិស្មើនឹងឧត្តមមន្ត្រីផុតលេខនៃព្រះរាជាណាចក្រកម្ពុជា។[381]

តំណាងរាស្ត្រមានថវិកាស្វយ័តសម្រាប់ដំណើរការរបស់ខ្លួន ហើយតំណាងរាស្ត្រត្រូវទទួលបាននូវប្រាក់បំណាច់។[382]

ការបំពេញភារកិច្ចក្នុងអាណត្តិសមាជិករដ្ឋសភាត្រូវទទួលបាននូវៈ

-សមាជិករដ្ឋសភាគ្រប់រូបត្រូវទទួលបាននូវការធានារ៉ាប់រងសង្គម

-ប្រាក់បំណាច់តាមការកំណត់របស់គណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា

-ក្នុងករណី ដែលសមាជិករដ្ឋសភាណាម្នាក់បានទទួលមរណភាព នៅក្នុងអាណត្តិ គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាត្រូវទទួលបន្ទុកជាអ្នករៀបចំកម្មវិធីធ្វើពិធីបុណ្យសព និងត្រូវផ្តល់ប្រាក់បំណាច់ ព្រមទាំងប្រាក់ឧបត្ថម្ភផ្សេងៗគ្រប់បែបយ៉ាងដល់ក្រុមគ្រួសារសពរយៈពេល១ឆ្នាំទៀត គឺគិតចាប់ពីថ្ងៃដែលទទួលមរណភាព។

-គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាត្រូវតែរៀបចំរបបប្រាក់បំណាច់ របបធានារ៉ាប់រងសង្គម របបឧបត្ថម្ភផ្សេងៗ របបប្រាក់សោធននិវត្តន៍ របបបេសកកម្ម ព្រមទាំងលក្ខខណ្ឌនៃការបំពេញការងារទាំងឡាយរបស់សមាជិកតំណាងរាស្ត្រ។[383]

-ប្រាក់សោធននិវត្តន៍របស់សមាជិករដ្ឋសភា ត្រូវបើកនៅក្នុងអគ្គលេខាធិការដ្ឋានរដ្ឋសភា ហើយប្រាក់សោធននិវត្តន៍ត្រូវបើកបានតែមួយកន្លែងគត់។

-គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា គឺជាអ្នកសម្រេចដើម្បីឲ្យសមាជិករដ្ឋសភាបានចូលនិវត្តន៍តាមការស្នើសុំរបស់សាមីខ្លួន។[384]

---

[380] មាត្រា១២០ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកតំណាងរាស្ត្រ។

[381] ប្រការ៤បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

[382] មាត្រា៨១រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[383] មាត្រា២០នៃច្បាប់ស្តីពីលក្ខន្តិកៈសមាជិកតំណាងរាស្ត្រ។

[384] មាត្រា២១នៃច្បាប់ស្តីពីលក្ខន្តិកៈសមាជិកតំណាងរាស្ត្រ។

-សមាជិករដ្ឋសភាទាំងឡាយ ដែលអាចទទួលបាននូវប្រាក់សោធននិវត្តន៍ សមាជិករដ្ឋសភានោះត្រូវមានលក្ខខណ្ឌមួយចំនួនដូចជា៖[385]

១-ជាអតីតសមាជិករដ្ឋសភា គិតចាប់តាំងពីឆ្នាំ១៩៩៣មក។

២-ជាអតីតសមាជិករដ្ឋសភាដែលមានអាយុចាប់ពី៦០ឆ្នាំឡើងទៅ។

៣-ជាអ្នកដែលមិនបានទទួលប្រាក់សោធននិវត្តន៍ពីស្ថាប័ណាមួយរបស់រដ្ឋ។

-ជាអតីតសមាជិករដ្ឋសភា ដែលមិនបានជាប់ឆ្នោតសាជាថ្មីឡើងវិញ តែក្រោយពីមានអាយុគ្រប់ចំនួន៦០ឆ្នាំគឺត្រូវទទួលបាននូវប្រាក់សោធននិវត្តន៍ ដោយអាចបើកប្រាក់ផ្តាច់បានត្រឹមរយៈពេលមួយឆ្នាំគត់។[386]

-សមាជិករដ្ឋសភា ត្រូវទទួលបាននូវជំនួយការផ្ទាល់ខ្លួនមួយចំនួន តាមការសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ក្នុងនាមជាមន្ត្រីបុគ្គលិកជាប់កិច្ចសន្យា ចំណែកប្រាក់កម្រៃជាបន្ទុកថវិការបស់រដ្ឋសភា។

-សមាជិករដ្ឋសភា ត្រូវទទួលបាននូវការជួយជ្រោមជ្រែង និងការដោះស្រាយបញ្ហានានា ព្រមទាំងការជួយសម្រួលគ្រប់បែបយ៉ាងពីអគ្គលេខាធិការដ្ឋានរដ្ឋសភា តាមបែបបទដូចមានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន។[387]

-សមាជិករដ្ឋសភា ត្រូវទទួលបាននូវឯកសណ្ឋានជាផ្លូវការ និងប្រពៃណី

-សមាជិករដ្ឋសភា ត្រូវទទួលបាន នូវប័ណ្ណសំគាល់សមាជិក សម្រាប់ពាក់ជាប់ខ្លួន

-សមាជិករដ្ឋសភាត្រូវទទួលបាននូវប័ណ្ណសំគាល់អភ័យឯកសិទ្ធិ

-សមាជិករដ្ឋសភា ត្រូវទទួលបាននូវគ្រឿងឥស្សរិយយស ពីរដងក្នុងមួយ អាណត្តិ។

-សមាជិករដ្ឋសភា ត្រូវទទួលបាននូវលិខិតឆ្លងដែនការទូតផ្ទាល់ខ្លួន សហព័ទ្ធ និងកូនដែលមានអាយុក្រោម១៨ឆ្នាំ។

-សមាជិករដ្ឋសភាត្រូវទទួលបាននូវរូបសញ្ញារដ្ឋសភាសម្រាប់ពាក់ជាប់ខ្លួន

-សមាជិករដ្ឋសភាត្រូវទទួលបាននូវរូបសញ្ញាបារមីរបស់រដ្ឋសភា។

-សមាជិករដ្ឋសភាត្រូវទទួលបាននូវផ្លាកសម្គាល់យានយន្តរដ្ឋសភា។

-សមាជិករដ្ឋសភា ត្រូវតែទទួលបាននូវការធានារ៉ាប់រងលើជំងឺដែលអាចព្យាបាលនៅតាមមន្ទីរពេទ្យរបស់រដ្ឋនៅទូទាំងប្រទេសនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាជាចេញបង់ថ្លៃសេវា

---

[385] មាត្រា២២នៃច្បាប់ស្តីពីលក្ខន្តិក:សមាជិកតំណាងរាស្ត្រ។

[386] មាត្រា២៤នៃច្បាប់ស្តីពីលក្ខន្តិក:សមាជិកតំណាងរាស្ត្រ។

[387] មាត្រា២៥នៃច្បាប់ស្តីពីលក្ខន្តិក:សមាជិកតំណាងរាស្ត្រ។

ផ្សេងៗរួមទាំងថ្លៃព្យាបាលផងដែរ ដោយថវិការបស់រដ្ឋសភា។[388]

-តំណាងរាស្ត្រ នៅក្នុងមុខតំណែងត្រូវទទួលបានងារជាឯកឧត្តម ឬលោកជំទាវ ឬអតីតតំណាងរាស្ត្រ ក្រោយពីពេលដែលបានបញ្ចប់អាណត្តិរបស់ខ្លួនហើយក៏ដោយក៏តំណាងរាស្ត្រនោះត្រូវបានរក្សាងារជាឯកឧត្តមអតីតតំណាងរាស្ត្រ ឬលោកជំទាវអតីតតំណាងរាស្ត្រដែរ។[389]

ឆ.ការគ្រប់គ្រងអគ្គលេខាធិការដ្ឋានរដ្ឋសភា

(Management of Secretary General of Assembly)

១-សញ្ញាណទូទៅ

(Notion)

អគ្គលេខាធិការដ្ឋានរដ្ឋសភា ជាសេនាធិការ បម្រើការងារសេវារដ្ឋបាលនានាឲ្យអង្គការរដ្ឋសភា នៅប្រទេសកម្ពុជាយើងពីមុនឆ្នាំ១៩៧៥ មន្ត្រីដែលបម្រើការងារ នៅអគ្គលេខាធិការដ្ឋានរដ្ឋសភាជាមន្ត្រីជាប់កិច្ចសន្យានៅពេលចប់នីតិកាលរបស់រដ្ឋសភា មន្ត្រីទាំងនោះក៏ត្រូវបញ្ចប់ការងាររបស់ខ្លួនដែរ ហើយអាចវិលត្រឡប់ទៅបំពេញការងារនៅកន្លែងដើមវិញបាន។ការអនុវត្តការងាររបៀបនេះ បណ្តាប្រទេសជាច្រើន នៅលើពិភពលោកគេនៅតែបន្ត និងកំពុងអនុវត្តន៍ជាហូរហែរហូតមកដល់បច្ចុប្បន្ន។

ដោយឡែក នៅព្រះរាជាណាចក្រកម្ពុជាយើង ចាប់តាំងពីឆ្នាំ១៩៩៣មក មន្ត្រីទាំងអស់ដែលបានបម្រើការនៅអគ្គលេខាធិការដ្ឋានរដ្ឋសភា មានមន្ត្រីអចិន្ត្រៃយ៍ មានមន្ត្រីជាប់កិច្ចសន្យា ឬបុគ្គលិកអណ្តែតជាដើម។

រហូតមកដល់ខែមករា ឆ្នាំ២០០៣ រដ្ឋសភាជាតិនៃព្រះរាជាណាចក្រកម្ពុជាដែលបានអនុម័តច្បាប់មួយស្តីពីលក្ខន្តិក:មន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ។

ដោយច្បាប់ទាំងនេះ ត្រូវបានយកមកអនុវត្តន៍នៅចំពោះតែមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ។[390]

ហេតុនេះ មន្ត្រីទាំងអស់របស់អគ្គលេខាធិការដ្ឋាន ត្រូវតែអនុវត្តន៍តាមច្បាប់ស្តីពីលក្ខន្តិក:មន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិនេះទាំងអស់គ្នា។

---

[388] មាត្រា២៦នៃច្បាប់ស្តីពីលក្ខន្តិក:សមាជិកតំណាងរាស្ត្រ។

[389] មាត្រា២៨នៃច្បាប់ស្តីពីលក្ខន្តិក:សមាជិកតំណាងរាស្ត្រ។

[390] មាត្រា១ច្បាប់ស្តីពីលក្ខន្តិក:មន្ត្រីរាជការនៃក្រុមនីតិប្បញ្ញាត្តិ។

២-អគ្គលេខាធិការដ្ឋានរដ្ឋសភា

(Secretary General of Assembly)

ជាទូទៅ រដ្ឋសភាត្រូវមានអគ្គលេខាធិការដ្ឋានមួយដែលទទួលបន្ទុកខាងការរៀបចំចាត់ចែងធ្វើកំណត់ហេតុផ្សេងៗរបស់រដ្ឋសភា និងរបស់គណៈកម្មការនានាផងដែរ។

អគ្គលេខាធិការដ្ឋាននេះ ទទួលរ៉ាប់រងផងដែរ នូវគ្រប់កិច្ចការរដ្ឋបាល និងសេវានានាជូនរដ្ឋសភា និងគណៈកម្មការទាំងអស់របស់រដ្ឋសភាព្រមទាំងធ្វើការទំនាក់ទំនងលើបញ្ហាការងារផ្សេងជាមួយបណ្តាអង្គការរដ្ឋនានាក្រៅអំពីរដ្ឋសភា។[391]

អគ្គលេខាធិការដ្ឋាន ត្រូវបានដឹកនាំដោយអគ្គលេខាធិការមួយរូប និងអមដោយអគ្គលេខាធិការរងច្រើនរូប។ អគ្គលេខាធិការ និងអគ្គលេខាធិការរង ត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យតាមសេចក្តីស្នើសុំពីប្រធានរដ្ឋសភា ក្រោយពីបានពិគ្រោះយោបល់ជាមួយអនុប្រធានទី១ និងអនុប្រធានទី២នៃរដ្ឋសភា ដែលអគ្គលេខាធិការរដ្ឋសភា មានឋានៈស្មើនឹងរដ្ឋលេខាធិការ ចំណែកអគ្គលេខាធិការរង មានឋានៈស្មើនឹងអនុរដ្ឋលេខាធិការ។

អគ្គលេខាធិការ និងអគ្គលេខាធិការរង ត្រូវធ្វើការជ្រើសតាំង នៅក្នុងចំណោមមន្ត្រីជាន់ខ្ពស់ដែលមានបទពិសោធន៍ ក្នុងកិច្ចការរដ្ឋបាលយ៉ាងតិចដប់ឆ្នាំ ហើយដែលមិនមែនជាសមាជិករដ្ឋសភា មិនមែនជាអ្នកដឹកនាំក្នុងគណបក្សនយោបាយណាមួយ។[392]

៣-ការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា

(Functioning Secretary General of Assembly)

ដើម្បីឲ្យអគ្គលេខាធិការដ្ឋានរដ្ឋសភា អាចបំពេញសកម្មភាពការងារនានា ប្រកបដោយប្រសិទ្ធភាពខ្ពស់ ហើយដែលជាសេនាធិការបម្រើការងារ និងសេវារដ្ឋបាលឲ្យរដ្ឋសភានោះ អគ្គលេខាធិការដ្ឋានរបស់រដ្ឋសភា ត្រូវមានរចនាសម្ព័ន្ធគ្រប់គ្រង និងបែងចែកភារកិច្ចនានា ឲ្យបានច្បាស់លាស់ ការរៀបចំចាត់ចែងការងារទាំងនេះ ត្រូវដឹកនាំដោយអគ្គលេខាធិការដ្ឋានរដ្ឋសភា និងមានការឯកភាពពីថ្នាក់ដឹកនាំរដ្ឋសភា ដែលប្រធានរដ្ឋសភា ចេញសេចក្តីសម្រេចស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាននេះទាំងមូល។

៤-តួនាទី និងភារកិច្ចអគ្គលេខាធិការ

(Roles and Duties of Secretary General)

អគ្គលេខាធិការរដ្ឋសភាមានតួនាទី និងភារកិច្ចដូចតទៅ:

---

[391] ប្រការ១៤ថ្មីបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

[392] ប្រការ១៦បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

-អគ្គលេខាធិការរដ្ឋសភា ជាអ្នកស្នើទៅប្រធានរដ្ឋសភា ដើម្បីឲ្យចេញសេចក្តីសម្រេចបង្កើតគណៈកម្មការនានារបស់រដ្ឋសភា យោងលើការចាំបាច់ដែលមានសមាសភាពតិច ឬច្រើនអាស្រ័យទៅតាមទំហំនៃការងារ។ គណៈកម្មការដែលបានបង្កើតឡើងនេះ នឹងរលាយបាត់ទៅវិញនៅពេលដែលគណៈកម្មការបានបំពេញការងារចប់ជាស្ថាពរ។

-អគ្គលេខាធិការរដ្ឋសភាជាអ្នករៀបចំគ្រប់គ្រងការងាររដ្ឋបាល និងសេវានានាជូនរដ្ឋសភា និងគណៈកម្មការជំនាញទាំងអស់នៃរដ្ឋសភា ដើម្បីឲ្យការងារអាចដំណើរការប្រព្រឹត្តទៅ ប្រកបដោយប្រសិទ្ធភាពខ្ពស់។

-អគ្គលេខាធិការរដ្ឋសភាជាអ្នករៀបចំធ្វើកំណត់ហេតុនានា នៅគ្រប់ការប្រជុំរបស់រដ្ឋសភា និងរបស់គណៈកម្មការនានានៃរដ្ឋសភា។[393]

-អគ្គលេខាធិការរដ្ឋសភា ជាអ្នករៀបចំ និងជាអ្នកលើកសំណើជូនប្រធានរដ្ឋសភា ដើម្បីធ្វើការជ្រើសរើសមន្ត្រីរាជការចូលបម្រើការងារនៅក្នុងអគ្គលេខាធិការដ្ឋាន។

-អគ្គលេខាធិការរដ្ឋសភា ជាអ្នកស្នើសុំតែងតាំងមន្ត្រីរាជការបម្រើការងារនៅក្នុងអគ្គលេខាធិការដ្ឋានរដ្ឋសភា ដែលត្រូវបានចេញសេចក្តីសម្រេចដោយប្រធានរដ្ឋសភា ស្របតាមច្បាប់ស្តីអំពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ។[394]

-អគ្គលេខាធិការរដ្ឋសភា ជាអ្នករៀបចំធ្វើគម្រោង សម្រង់បញ្ជីឈ្មោះមន្ត្រីបុគ្គលិកនៅតាមការិយាល័យនានាដែលមានស្នាដៃ និងគុណបំណាច់ខ្ពស់ ក្នុងការបំពេញការកិច្ចជូនរដ្ឋសភាទៅឲ្យគណៈកម្មការវាយតម្លៃ រួចហើយទើបស្នើសុំប្រធានរដ្ឋ សភាធ្វើការបំពាក់គ្រឿងឥស្សរិយយសជូនដល់មន្ត្រីរាជការដែលមានស្នាដៃល្អ។

-អគ្គលេខាធិការរដ្ឋសភាជាអ្នកគ្រប់គ្រងមន្ត្រីរាជការ បុគ្គលិកទាំងអស់នៃអគ្គលេខាធិការដ្ឋានរដ្ឋសភា។ អគ្គលេខាធិការរដ្ឋសភា ជាអ្នកគ្រប់គ្រង និងថែរក្សាទ្រព្យសម្បត្តិរបស់រដ្ឋសភា។

-អគ្គលេខាធិការរដ្ឋសភា ជាអ្នករៀបចំសណ្តាប់ធ្នាប់ សន្តិសុខ អនាម័យនៅក្នុងបរិវេណរដ្ឋសភាទាំងមូល។

-អគ្គលេខាធិការរដ្ឋសភាជាអ្នកគ្រប់គ្រង និងបញ្ជាផ្ទាល់ទៅលើចំណាយផ្សេងៗរបស់អគ្គលេខាធិការដ្ឋានរដ្ឋសភាដោយមានការសហការជាមួយអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា។

---

[393] ប្រការ១៤បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

[394] ប្រការ១៧បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

រចនាសម្ព័ន្ធរបស់រដ្ឋសភា

ប្រធានរដ្ឋសភា១រូប
អនុប្រធានទី១រដ្ឋសភា១រូប
អនុប្រធានទី២រដ្ឋសភា១រូប
សមាជិករដ្ឋសភាចាំងអស់១២២រូបមកពីរាជធានី និងខេត្ត
អគ្គលេខាធិការ១រូប និងអគ្គលេខាធិការរងច្រើនរូប

គណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភាមាន១៣រូប
ប្រធានរដ្ឋសភា១រូបជាប្រធានគណៈកម្មាធិការ
អនុប្រធានទី១រដ្ឋសភា១រូបជាសមាជិកគណៈកម្មាធិការ
អនុប្រធានទី២រដ្ឋសភា១រូបជាសមាជិកគណៈកម្មាធិការ
ប្រធានគណៈកម្មការនានាចាំង១០រូបជាសមាជិកគណៈកម្មការ

គណៈកម្មការនីមួយៗរបស់រដ្ឋសភា
សមាជិករដ្ឋសភា១រូបជាប្រធានគណៈកម្មការ
សមាជិករដ្ឋសភា១រូបជាអនុប្រធានគណៈកម្មការ
សមាជិករដ្ឋសភា១រូបជាលេខាធិការគណៈកម្មការ
សមាជិករដ្ឋសភាចំនួន៧រូបយ៉ាងតិចជាសមាជិកគណៈកម្មការ

អគ្គលេខាធិការដ្ឋានរដ្ឋសភា
អគ្គលេខាធិការរដ្ឋសភា១រូបមានឋានៈស្មើរដ្ឋលេខាធិការ
(មិនមែនជាសមាជិករដ្ឋសភា)
អគ្គលេខាធិការរងរដ្ឋសភាច្រើនរូបមានឋានៈស្មើអនុរដ្ឋលេខាធិការ
(មិនមែនជាសមាជិករដ្ឋសភា)
អាណត្តិទី៦នៃរដ្ឋសភាមានអគ្គលេខាធិការ១រូប និងអគ្គលេខាធិការរង៣រូប

ប្រព័ន្ធរបបនយោបាយ និងប្រព័ន្ធសេដ្ឋកិច្ចនៅកម្ពុជា

ប្រទេសកម្ពុជាយើងបានផ្លាស់ប្តូរប្រព័ន្ធរបបនយោបាយ និងប្រព័ន្ធសេដ្ឋកិច្ច ជាច្រើនលើក ច្រើនសាជាពិសេសចាប់តាំងពីឆ្នាំ១៩៤៧ មករហូតមកដល់បច្ចុប្បន្ន។

សូមមើលតារាងខាងក្រោម៖

របបសង្គម	រដ្ឋធម្មនុញ្ញ	សេដ្ឋកិច្ច
ព្រះរាជាណាចក្រកម្ពុជា (១៩៤៧-១៩៧០)	របបសភានិយម	ទីផ្សារសេរី
សាធារណរដ្ឋខ្មែរ (១៩៧០-១៩៧៥)	របបប្រធានាធិបតី	ទីផ្សារសេរី
កម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)	របបកុម្មុយនីស្ត	ផែនការ
សាធារណរដ្ឋប្រជាមានិតកម្ពុជា (១៩៧៩-១៩៨៩)	របបសង្គមនិយម	ផែនការ
រដ្ឋកម្ពុជា (១៩៨៩-១៩៩៣)	របបពហុបក្ស	ផែនការ
ព្រះរាជាណាចក្រកម្ពុជា (១៩៩៣-បច្ចុប្បន្ន)	របបសភានិយម	ទីផ្សារសេរី

"អំណាចអាស្រ័យនៅលើតម្លៃក្នុងភាពជាមនុស្ស ភាពជោគជ័យ និងភាពវិយឆ្លាតរបស់មនុស្សម្នាក់ៗ"

Power is one"s value , success and enterprise.

ផ្នែកទី៤

នីតិប្បញ្ញត្តិ ព្រឹទ្ធសភា

(Legislative of Senate)

ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ជាអង្គការនីតិប្បញ្ញត្តិដែលមានអំណាចនីតិប្បញ្ញត្តិ ហើយត្រូវបានបង្កើតឡើងតាមរយៈការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញនៅក្នុងឆ្នាំ១៩៩៩។

រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣នៃព្រះរាជាណាចក្រកម្ពុជាបានកំណត់ថា សមាជិកព្រឹទ្ធសភាមានចំនួនយ៉ាងច្រើនពាក់កណ្តាលនៃចំនួនសមាជិកតំណាងរាស្ត្រនៅក្នុងរដ្ឋសភា។

សមាជិកព្រឹទ្ធសភា ត្រូវបានធ្វើការជ្រើសរើសនៅក្នុងចំណោមប្រជាពលរដ្ឋខ្មែរទាំងពីរភេទ តាមរយៈការតែងតាំងផង តាមរយៈការជ្រើសតាំងផង និងការបោះឆ្នោតជាអសកលផង។

បន្ទាប់ពីមានកិច្ចព្រមព្រៀងទីក្រុងប៉ារីសនៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១មក។ ប្រទេសកម្ពុជាបានប្រកាន់យករបបរាជានិយមទី២ពេលនោះប្រទេសយើងមានសភាតែមួយថ្នាក់ប៉ុណ្ណោះ។

រហូតមកដល់ឆ្នាំ១៩៩៨ ក្រោយពីបានបោះឆ្នោតធ្វើការជ្រើសរើសតំណាងរាស្ត្រសម្រាប់នីតិកាលទី២នៃរដ្ឋសភារួចហើយនៅថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៩ ទើបបានបង្កើតឲ្យមានស្ថាប័នព្រឹទ្ធសភានេះឡើង។

នៅក្នុងអាណត្តិទី១នៃព្រឹទ្ធសភាសមាជិកព្រឹទ្ធសភាទាំងអស់ ត្រូវបានបង្កើតឡើងសុទ្ធតែតាមរយៈការតែងតាំងសម្រាប់អាណត្តិ៥ឆ្នាំ ហើយមានសមាជិកសរុបចំនួន៦០រូប ដោយបានធ្វើការតែងតាំងដោយព្រះមហាក្សត្រចំនួន២រូប តែងតាំងពីគណបក្សប្រជាជនកម្ពុជា ចំនួន៣១រូប តែងតាំងពីគណបក្ស ហ៊ុន ស៊ុនប៊ុច ចំនួន២១រូប និងតែងតាំងពីគណបក្ស សម រង្ស៊ី ចំនួន៧រូប ដែលបានបើកសម័យប្រជុំលើកទី១ នាថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៩។

ចាប់តាំងពីអាណត្តិទី២មក ទើបព្រឹទ្ធសភាមានការបោះឆ្នោតជាលក្ខណៈអសកល។

ក.ព្រឹទ្ធសភាជាអ្វី?

(What is Senate)

ព្រឹទ្ធសភាជាអង្គការនីតិប្បញ្ញត្តិ ដែលគេតែងឃើញមាននៅក្នុងអំណាចនីតិប្បញ្ញត្តិ ដែលមានចរិតលក្ខណៈជាទ្វីកសភានិយម ឬសភាពីរថ្នាក់។

នៅក្នុងគំនិតបែងចែកសភា(Le parlement)ជាពីរថ្នាក់បានកើតឡើងដំបូងនាសតវត្សន៍ទី១៨នៅក្នុងប្រទេសអង់គ្លេស។

ការបែងចែកសភានេះ បើតាមលោក ម៉ុងតេស្គីយើ (Montesquieu) គឺក្នុងគោលបំណង

ដើម្បីធ្វើឲ្យមានការស្រុះស្រួលគ្នា រវាងគោលការណ៍អភិជនាធិបតេយ្យ(Aristocratie) និងគោលការណ៍ប្រជាធិបតេយ្យ ក្នុងន័យនេះ គឺការពារកុំឲ្យមានការរំលោភបំពានសិទ្ធិអំណាចគ្នា ទៅវិញទៅមករវាងសមាជិកព្រឹទ្ធសភាដែលតំណាងឲ្យពួកអភិជន និងសមាជិករដ្ឋសភាដែលតំណាងឲ្យប្រជារាស្ត្រសាមញ្ញ។

ខ.ការរៀបចំ និងការប្រព្រឹត្តទៅរបស់ព្រឹទ្ធសភា

(Organization and Functioning of Senate)

១-ការបង្កើតស្ថាប័នព្រឹទ្ធសភា

(Establishment of Senate Institution)

នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៨ ប្រជាពលរដ្ឋខ្មែរទូទាំងព្រះរាជាណាចក្រកម្ពុជាបានទៅចូលរួមធ្វើការបោះឆ្នោតជ្រើសរើស សមាជិករដ្ឋសភាអាណត្តិទី២នៃរដ្ឋសភា ដែលមានគណៈបក្សនយោបាយទាំងអស់ចំនួន៣៩គណបក្ស បានប្រកួតប្រជែងធ្វើការបោះឆ្នោត ដើម្បីទទួលបានអាសនៈ សរុប១២២អាសនៈ(អាណត្តិទី២នៃរដ្ឋសភា)។ លទ្ធផលនៃការបោះឆ្នោត មានគណបក្សចំនួនបីដែលទទួលបានអាសនៈ គណបក្សប្រជាជនកម្ពុជាទទួលបានចំនួន៦៤អាសនៈ គណបក្សហ៊្វុនស៊ិនប៉ិចទទួលបាន៤៣អាសនៈ និងគណបក្ស សម រង្ស៊ីទទួលបាន១៥អាសនៈ។

ជាធម្មតា នៅក្នុងរបបប្រជាធិបតេយ្យ នៅលើពិភពលោកយើងបច្ចុប្បន្ន ចំនួនភាគច្រើន ៦៤អាសនៈ ដែលគណបក្សប្រជាជនកម្ពុជាទទួលបាន គឺគ្រប់គ្រាន់អាចបង្កើតស្ថាប័នរដ្ឋនានាទាំងឡាយ ដែលអាចរៀបចំ និងដំណើរការប្រព្រឹត្តទៅបានប្រកបដោយភាពរលូនជាពិសេសការរៀបចំបង្កើតរាជរដ្ឋាភិបាល។ ក្នុងករណីនេះ មិនអាចយកមកអនុវត្តន៍បានទេ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បានកំណត់ ដែលតម្រូវឲ្យមានការអនុម័តយល់ព្រមផ្តល់សេចក្តីទុកចិត្តរហូតដល់មតិភាគច្រើនពីរភាគបី(២/៣)។[395]

ការណ៍នេះ ធ្វើឲ្យប្រទេសកម្ពុជានៅសម័យនោះមានវិបត្តិនយោបាយ ដោយមានការចូលរួមអន្តរាគមន៍ពីព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា កិច្ចព្រមព្រៀងមួយត្រូវបានបង្កើតឡើងនៅថ្ងៃទី១២ ដល់១៣ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ដែលបានប្រកាសធ្វើវិសោធនកម្ម សើរើរដ្ឋធម្មនុញ្ញ មានលក្ខណៈជាទ្រង់ទ្រាយធំ។ ការសើរើ និងធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ត្រូវបានចាប់ដំណើរការហើយបានអនុម័តនៅថ្ងៃទី០៤ ខែមីនា ឆ្នាំ១៩៩៩ ដោយបានកែប្រែមាត្រាមួយចំនួន និងបានបង្កើតមាត្រាបន្ថែមចំនួន១៧មាត្រា ដើម្បីបង្កើតអង្គការសភាមួយថ្នាក់ទៀតគឺ ព្រឹទ្ធសភា។

---

[395] មាត្រា៩០ចាស់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ (ការអនុម័តរបស់រដ្ឋសភាក្នុងការផ្តល់សេចក្តីទុកបង្កើតរាជរដ្ឋាភិបាលត្រូវអនុម័តដោយសម្លេងពីរភាគបី ប៉ុន្តែនៅឆ្នាំ២០០៦ត្រូវបានកែមកភាគច្រើនដាច់ខាត)។

ស្ថាប័នព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជាត្រូវបានបង្កើតជាផ្លូវការនៅថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ដោយបោះឆ្នោតពីសមាជិករដ្ឋសភា ដែលបានអនុម័ត១០៦សម្លេង លើ១១១សម្លេង ៥សម្លេងមិនគាំទ្រ(៦សម្លេងអវត្តមាន)។

២-នីតិវិធីចូលកាន់តំណែងរបស់ព្រឹទ្ធសភា

(Procedure of Taking Office of Senate)

ប្រធានព្រឹទ្ធសភា នីតិកាលចាស់ ជាអ្នកលើកសំណើថ្វាយព្រះមហាក្សត្រ ដើម្បីទ្រង់ព្រះប្រទានការកោះប្រជុំសម័យប្រជុំដំបូងរបស់ព្រឹទ្ធសភានៃនីតិកាលថ្មី។

ការបើកសម័យប្រជុំព្រឹទ្ធសភា ជាលើកដំបូងនៃនីតិកាលនីមួយៗរបស់ព្រឹទ្ធសភា គឺ៦០ថ្ងៃ យ៉ាងយូរក្រោយពេលបោះឆ្នោតរួចហើយតាមការកោះប្រជុំរបស់ព្រះមហាក្សត្រ។

បន្ទាប់មកព្រះមហាក្សត្រ ឬព្រះរាជតំណាងទ្រង់ព្រះប្រទានផ្តល់កិត្តិយសចំពោះការបើកសម័យប្រជុំលើកដំបូងនៃនីតិកាលនីមួយៗ ព្រឹទ្ធសមាជិកព្រឹទ្ធសភា ដែលមានអាយុច្រើនជាងគេដែលបានជាប់ឆ្នោត ឬក៏តែងតាំង ដែលមានវត្តមានចំនួន១រូប ធ្វើជាប្រធានបណ្តោះអាសន្ន និងសមាជិកព្រឹទ្ធសភា ដែលជាប់ឆ្នោត ឬតែងតាំង ដែលមានវត្តមាន និងមានអាយុតិចជាងគេចំនួន ៥រូបធ្វើជាលេខាធិការ។ ប្រសិនបើ ព្រឹទ្ធសភាមានសមាជិកវត្តមានចំនួនលើសពីពាក់កណ្តាលនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ព្រឹទ្ធសភាអាចដំណើរការ បោះឆ្នោតជ្រើសរើស ដាច់ដោយឡែកពីគ្នានូវប្រធាន និងអនុប្រធានទាំងពីរនៃព្រឹទ្ធសភា ដោយមតិភាគច្រើនដាច់ខាត៥០បូក១ នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។[396]

សម័យប្រជុំដំបូងនៃនីតិកាលនីមួយៗរបស់ព្រឹទ្ធសភា គឺត្រូវចាប់ដំណើរការក្រោមអធិបតីភាពនៃប្រធានបណ្តោះអាសន្ន។

២.១.ប្រធានបណ្តោះអាសន្ន

(Temporary Chairman)

ប្រធានបណ្តោះអាសន្នត្រូវប្រកាស:

-ឈ្មោះសមាជិកព្រឹទ្ធសភាពេញសិទ្ធិ ។

-ឈ្មោះសមាជិកព្រឹទ្ធសភា២រូបដែលបានតែងតាំងដោយព្រះមហាក្សត្រ។

-ឈ្មោះសមាជិកព្រឹទ្ធសភា២រូប ដែលរដ្ឋសភាបានធ្វើការជ្រើសរើស ។

-ឈ្មោះសមាជិកព្រឹទ្ធសភា៥៧រូបដែលបានបោះឆ្នោតលក្ខណៈជាអសកល។

[396] មាត្រា១១១ថ្មី(ពីរ)រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

-បោះឆ្នោតជ្រើសតាំង ដាច់ដោយឡែកពីគ្នាចំពោះប្រធាន អនុប្រធានទី១ និងអនុប្រធានទី២របស់ព្រឹទ្ធសភា និងបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធាន និងលេខាធិការនៃគណៈកម្មការជំនាញនានានៃព្រឹទ្ធសភាដោយមតិភាគច្រើនដាច់ខាត៥០+១នៃសមាជិកព្រឹទ្ធសភាទាំងមូល។[397]

ក្រោយពីធ្វើការជ្រើសរើស ប្រធាន និងអនុប្រធានទាំងពីររបស់ព្រឹទ្ធសភា ហើយប្រធាន និងអនុប្រធាន ទាំងពីររបស់ព្រឹទ្ធសភា ត្រូវដឹកនាំសមាជិករបស់ខ្លួន ដើម្បីទៅធ្វើសច្ចាប្រណិធានដូចមានចែងក្នុងឧបសម្ព័ន្ធ៧ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាមុនចូលកាន់តំណែងថ្មី។[398]

២.២.សុពលភាពសមាជិកព្រឹទ្ធសភា

(Validity of Senators)

នៅពេលបើកសម័យប្រជុំដំបូងនៃនីតិកាលនីមួយៗខាងលើ ព្រឹទ្ធសមាជិកត្រូវតែប្រកាសជូនអង្គសភាឲ្យបានជ្រាបអំពី:

-ឈ្មោះបេក្ខជនដែលជាប់ឆ្នោតជាស្តាពរ ដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបានបញ្ជូនមក។

-ឈ្មោះបេក្ខជនជាប់ឆ្នោត ដែលមានគេប្តឹងតវ៉ា ហើយដែលក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបានបដិសេធបណ្តឹងទាំងនោះ។

ឈ្មោះសមាជិកព្រឹទ្ធសភាពេញសិទ្ធិទាំងអស់ ដែលបានប្រកាសអំពីសុពលភាពរួចហើយត្រូវតែបិទផ្សព្វផ្សាយនៅក្នុងព្រឹទ្ធសភា និងបិទផ្សព្វផ្សាយជាសាធារណៈ នៅក្រោយពេលដែលព្រឹទ្ធសភាបានប្រជុំចប់។[399]

គ.សមាជិកព្រឹទ្ធសភា

(Senators)

សមាជិកព្រឹទ្ធសភាទាំងអស់ មានចំនួនសមាជិកយ៉ាងច្រើន ស្មើនឹង៣ក់កណ្តាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល។[400]

១-ការជ្រើសរើសសមាជិកព្រឹទ្ធសភា

(Selection of Senators)

សមាជិកព្រឹទ្ធសភាក៏ជាតំណាងរាស្ត្រដែរ ប៉ុន្តែសមាជិកខ្លះត្រូវបានតែងតាំង និងខ្លះទៀត

---

[397] ប្រការ៥បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

[398] មាត្រា១០៦នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[399] ប្រការ៣បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

[400] មាត្រា២ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកព្រឹទ្ធសភា។

ត្រូវបានធ្វើការជ្រើសរើសដោយការបោះឆ្នោត ដែលមានលក្ខណៈជាអសកល ការបោះឆ្នោតជាអសកលនេះ អ្នកមានសិទ្ធិបោះឆ្នោតបាន គឺជាសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ ក្នុងមុខតំណែង និងអ្នកតំណាងរាស្ត្រក្នុងមុខតំណែងតែប៉ុណ្ណោះ។

ចំពោះការតែងតាំង និងការជ្រើសតាំងសមាជិកព្រឹទ្ធសភា ក្នុងនោះរួមមាន:

-សមាជិកព្រឹទ្ធសភាចំនួន០២រូប ត្រូវបានតែងតាំង ដោយព្រះមហាក្សត្រ។

-សមាជិកព្រឹទ្ធសភាចំនួន០២រូប ត្រូវបានរដ្ឋសភាជាអ្នកធ្វើការជ្រើសតាំង ដោយអនុម័តតាមមតិភាគច្រើនដោយប្រៀប។[401]

-សមាជិកខ្លះទៀតត្រូវបានជ្រើសរើសដោយការបោះឆ្នោតជាអសកល។ សមាជិកព្រឹទ្ធសភាអាចត្រូវបានតែងតាំង និងជ្រើសតាំងសាជាថ្មីបាន។[402]

ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ត្រូវធ្វើឡើងជារៀងរាល់៦ឆ្នាំម្តង ដែលត្រូវធ្វើឡើងនៅថ្ងៃអាទិត្យនាសប្តាហ៍ទី៨ មុនដំណាច់ឆ្នាំទី៦នៃនីតិកាលរបស់ព្រឹទ្ធសភា។[403]

ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ត្រូវធ្វើឡើងជាលក្ខណៈអសកលត្រូវអនុវត្តន៍ទៅតាមប្រព័ន្ធសមាមាត្រ និងផ្អែកតាមរូបមន្តមធ្យមភាគខ្ពស់បំផុត។ មណ្ឌលបោះឆ្នោត ត្រូវបានរៀបចំបែងចែកចេញជា៨ភូមិភាគដែលភូមិភាគទាំង៨ រួមមាន:

-ភូមិភាគទី១ គឺរាជធានីភ្នំពេញ ដែលមានអាសនៈចំនួន៦ កៅអី

-ភូមិភាគទី២ គឺខេត្តកំពង់ចាម ដែលមានអាសនៈចំនួន៨ កៅអី

-ភូមិភាគទី៣ គឺខេត្តកណ្តាល ដែលមានអាសនៈចំនួន៥ កៅអី

-ភូមិភាគទី៤ គឺខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប ខេត្តឧត្តរមានជ័យ និងខេត្តប៉ៃលិន ដែលមានអាសនៈចំនួន១០កៅអី។

-ភូមិភាគទី៥ គឺខេត្តតាកែវ ខេត្តកំពត និងខេត្តកែប ដែលមានអាសនៈចំនួន៧ កៅអី។

-ភូមិភាគទី៦ គឺខេត្តព្រៃវែង និងស្វាយរៀង ដែលមានអាសនៈចំនួន៧កៅអី។

-ភូមិភាគទី៧ គឺខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ខេត្តពោធិសាត់ ខេត្តកោះកុង និងខេត្តព្រះសីហនុ ដែលមានអាសនៈចំនួន៨ កៅអី ។

-ភូមិភាគទី៨ គឺខេត្តកំពង់ធំ ខេត្តព្រះវិហារ ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី និង

[401] មាត្រា១០០ថ្មីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[402] មាត្រា៩៩ថ្មីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[403] មាត្រា៧ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកព្រឹទ្ធសភា។

ខេត្តមណ្ឌលគិរី ដែលមានអាសនៈចំនួន៦កៅអី។[404]

អាសនៈសមាជិកព្រឹទ្ធសភាដែលទទួលបានពីការបោះឆ្នោតអសកល នៅតាមបណ្តាភូមិភាគទាំង៨មានចំនួនសរុប៥៧កៅអី។

២-ការបាត់បង់សមាជិកភាព

(Losing of Membership)

សមាជិកព្រឹទ្ធសភា ត្រូវបានបាត់បង់ឋានៈជាសមាជិកភាពរបស់ខ្លួនទៅតាមករណីណាមួយដូចខាងក្រោម:

-សាមីខ្លួនទទួលមរណភាព

-សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ច្បាស់លាស់ពីក្រសួង និងស្ថាប័នរដ្ឋដែលមានសមត្ថកិច្ច។

-សាមីខ្លួនសុំលាឈប់ពីសមាជិកព្រឹទ្ធសភា ដោយមានលាយលក្ខណ៍អក្សរ។

-សាមីខ្លួនត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋឬបទមជ្ឈិមណាមួយ។

-សាមីខ្លួនបាត់បង់សមាជិកភាព ពីគណបក្សនយោបាយរបស់ខ្លួន។[405]

នៅក្នុងនីតិកាលនីមួយៗរបស់ព្រឹទ្ធសភា អាសនៈរបស់សមាជិកព្រឹទ្ធសភាត្រូវប្រកាសថានៅមានទំនេរ អាសនៈរបស់សមាជិកព្រឹទ្ធសភា ដែលនៅទំនេរដោយសារមកពីការសុំលាលែង ឬដោយសារការបោះបង់ចោលការងាររបស់ខ្លួនចំនួនបី(៣)ខែ ដោយគ្មានការអនុញ្ញាត ឬដោយសារមកពីការទទួលមរណភាព ឬប្រាសចាកជាសមាជិកភាពរបស់ព្រឹទ្ធសភា ឬដោយការប្រាសចាកសមាជិកភាព ចេញពីគណបក្សនយោបាយរបស់ខ្លួនដែលបានជាប់ឆ្នោត។

អាសនៈនៃសមាជិកព្រឹទ្ធសភា ដែលនៅទំនេរនោះ ត្រូវមានរយៈពេលច្រើនជាង៦ខែមុនចប់នីតិកាលរបស់ខ្លួន អាសនៈទំនេរនោះត្រូវធ្វើការជ្រើសរើសបំពេញជំនួសវិញ ដោយសមាជិកព្រឹទ្ធសភាថ្មី តាមលំដាប់លេខរៀងជាបន្តបន្ទាប់ ដែលបានជ្រើសរើស ក្នុងបញ្ជីបេក្ខជនឈរឈ្មោះតំណាងគណបក្សនយោបាយមណ្ឌលជាមួយគ្នា ឬជ្រើសតាំងសមាជិកព្រឹទ្ធសភាថ្មីចេញពីប្រភពដើមដែលមានអាសនៈទំនេរ។[406]

ប្រសិនបើ អាសនៈដែលនៅទំនេររបស់សមាជិកព្រឹទ្ធសភាមានរយៈពេលតិចជាង៦ខែនោះ អាសនៈរបស់សមាជិកព្រឹទ្ធសភា ដែលនៅទំនេរ មិនចាំបាច់ ធ្វើការជ្រើសរើសសមាជិកព្រឹទ្ធសភា

[404] មាត្រា៩ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកព្រឹទ្ធសភា ។

[405] មាត្រា៣១ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកព្រឹទ្ធសភា។

[406] ប្រការ៧៨បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

ថ្មីមកជំនួសនោះទេ។

សមាជិកព្រឹទ្ធសភាដែលបានចូលថ្មីត្រូវចប់អាណត្តិដូចគ្នាទៅនឹងសមាជិកឯទៀតដែរ។

ឃ.លក្ខខណ្ឌនៃការឈរឈ្មោះ និងមិនអាចឈរឈ្មោះ

(Conditions of Qualification and Disqualification)

១-លក្ខខណ្ឌនៃការឈរឈ្មោះ

(Conditions of Qualification Candidate)

ដោយផ្អែកទៅលើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៧-០៦ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៧ និងព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ត្រូវបានយកមកអនុវត្តន៍ចំពោះបេក្ខជនសមាជិកព្រឹទ្ធសភាប៉ុន្តែបេក្ខជននោះ ត្រូវមានអាយុយ៉ាងតិច៤០ឆ្នាំគិតដល់ថ្ងៃបោះឆ្នោត ហើយដែលជាប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានសិទ្ធិ និងមានបំណងឈរឈ្មោះជាបេក្ខជនសមាជិកព្រឹទ្ធសភា។[407]

បេក្ខជនសមាជិកព្រឹទ្ធសភាត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោមនេះ៖

- មានសញ្ជាតិខ្មែរពីកំណើត
- មានអាយុ៤០ឆ្នាំឡើងទៅ គិតដល់ថ្ងៃបោះឆ្នោត
- មានសិទ្ធិបោះឆ្នោត និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោត
- មានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា
-មានការតែងតាំងពីគណបក្សនយោបាយណាមួយ ហើយដែលបានចុះ នៅក្នុងបញ្ជីឈរឈ្មោះបោះឆ្នោត។[408]

២-លក្ខខណ្ឌមិនអាចឈរឈ្មោះ

(Conditions of Disqualification Candidate)

លក្ខខណ្ឌដែលមិនមានសិទ្ធិ ឈរឈ្មោះជាបេក្ខជនបោះឆ្នោត ដើម្បីជ្រើសតាំងសមាជិកព្រឹទ្ធសភារួមមាន:

-មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងកម្លាំងនគរបាលជាតិ កងយោធពលខេមរភូមិន្ទនៅក្នុងមុខតំណែង និងបុព្វជិតសាសនា។

-ជនដែលត្រូវបានតុលាការផ្តន្ទាទោស ដាក់ពន្ធនាគារអំពីបទល្មើសឧក្រិដ្ឋ ឬបទមជ្ឈិម

[407] មាត្រា១៧ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកព្រឹទ្ធសភា។

[408] មាត្រា៣៣ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិករដ្ឋសភា។

ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ ឬ

-ជនដែលត្រូវបានផ្តន្ទាទោសដកសិទ្ធិបោះឆ្នោត

-ជនដែលវិកលចរិត ឬជនដែលស្ថិតនៅក្រោមអាព្យាបាល ដែលមានលិខិតបញ្ជាក់ អំពីក្រសួងមានសមត្ថកិច្ច ឬ

-ជនដែលត្រូវដកហូតជាបណ្តោះអាសន្ននូវសិទ្ធិបោះឆ្នោត ឬជនដែលត្រូវបានលុបឈ្មោះពីបញ្ជីបោះឆ្នោតដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

- សមាជិកនៃគណៈកម្មាធិការជាតិ និងគណៈកម្មការរៀបចំការបោះឆ្នោត ដើម្បីជ្រើសតាំងតំណាងរាស្ត្រ ឬ

- ជនបរទេសទាំងឡាយដែលរស់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា។

- សមាជិកនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ឬ

- សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ។[409]

៣-លក្ខខណ្ឌឈរឈ្មោះចំពោះអ្នកដែលច្បាប់ហាម

(Conditions of Legally Forbidden Candidate)

ការឈរឈ្មោះជាបេក្ខជនសមាជិកព្រឹទ្ធសភាដែលអ្នកទាំងនោះ ជាមន្ត្រីរាជការស៊ីវិល ជាមន្ត្រីតុលាការ កងកម្លាំងនគរបាលជាតិ កងយោធពលខេមរភូមិន្ទ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងបុព្វជិត សាសនា ដែលមានបំណងឈរឈ្មោះបោះឆ្នោតជ្រើសតាំងជាសមាជិកព្រឹទ្ធសភាត្រូវដាក់ពាក្យសុំច្បាប់ឈប់សម្រាកជាពិសេស ឬក៏លាចាកសិក្ខាបទមុនថ្ងៃបើកយុទ្ធនាការឃោសនាបោះឆ្នោតរហូតដល់ថ្ងៃប្រកាសលទ្ធផលនៃការបោះឆ្នោតជាស្តាពរយ៉ាងតិចប្រាំពីរ(៧)ថ្ងៃ។

ប្រសិនសាមីខ្លួន បានជាប់ឆ្នោតហើយ សាមីខ្លួនត្រូវធ្វើពាក្យសុំតាមឋានានុក្រមទៅសាមីក្រសួងឬសាមីអង្គភាព ដើម្បីទៅបម្រើការងារក្រៅក្របខ័ណ្ឌដើមក្នុងរយៈពេលអាណត្តិរបស់ខ្លួន។

ក្នុងរយៈពេល ដែលស្ថិតនៅក្រៅក្របខណ្ឌដើម សាមីខ្លួនត្រូវមានសិទ្ធិឡើង ឋានន្តរសក្តិ និងឡើងថ្នាក់ដោយស្វ័យប្រវត្តិ និងរក្សាអតីតភាពការងារសម្រាប់ទទួលសោធននិវត្តន៍។

នៅពេលចប់អាណត្តិជាតំណាងរាស្ត្រ សាមីខ្លួនអាចសុំត្រឡប់មកបម្រើការនៅក្រសួង ឬអង្គភាពដើមវិញ ប៉ុន្តែមុខងារអាស្រ័យ ដោយសាមីក្រសួង ឬ សាមីអង្គភាពជាអ្នកសម្រេច។[410]

[409] មាត្រា៣៤នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកព្រឹទ្ធសភា។

[410] មាត្រា៣៥ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកព្រឹទ្ធសភា។

ខ.តួនាទីរបស់ព្រឹទ្ធសភា

(Roles of Senate)

ព្រឹទ្ធសភាជាអង្គការមួយ ដែលមានអំណាចនីតិប្បញ្ញត្តិទី២ ហើយបំពេញការកិច្ចរបស់ខ្លួនដូចមានកំណត់នៅក្នុងច្បាប់រដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន។[411]

ព្រឹទ្ធសភាមានអំណាចនីតិប្បញ្ញត្តិដូចរដ្ឋសភាជាតិដែរ ជាអ្នកអនុវត្តន៍អំណាចនីតិប្បញ្ញត្តិ ជាអ្នកសម្របសម្រួលការងាររវាងរដ្ឋសភា និងការងាររាជរដ្ឋាភិបាល ព្រមទាំងមានតួនាទីផ្សេងៗមួយចំនួនទៀត។

១-ការអនុវត្តអំណាចរបស់ព្រឹទ្ធសភា

(Application to Power of Senate)

១.១.ការផ្តួចផ្តើមធ្វើច្បាប់

(Initiation of Law Making)

នៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ បានផ្តល់អំណាចទៅឲ្យអង្គការព្រឹទ្ធសភានូវអំណាចក្នុងការផ្តួចផ្តើមធ្វើច្បាប់ និងសេចក្តីស្នើច្បាប់។[412]

សេចក្តីស្នើច្បាប់ ដែលសមាជិកព្រឹទ្ធសភា ជាអ្នកធ្វើគឺត្រូវសរសេរជាលាយលក្ខណ៍អក្សរ ហើយត្រូវចែកជាមាត្រាដោយមានភ្ជាប់សេចក្តីថ្លែងហេតុមកជាមួយផង។

សេចក្តីស្នើច្បាប់ ជាទូទៅត្រូវបញ្ជូនទៅរដ្ឋសភា តាមរយៈគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាក្រោយពីបានដាក់ឲ្យគណៈកម្មការជំនាញរបស់ព្រឹទ្ធសភាបានផ្តល់យោបល់រួចហើយ។[413]

អ្នកតែងសេចក្តីស្នើច្បាប់ មានសិទ្ធិចូលរាយការណ៍ និងការពារចំពោះមុខ គណៈកម្មការដែលពិនិត្យសេចក្តីស្នើនោះ។

អ្នកតែងសេចក្តីស្នើច្បាប់ ជាអ្នកលើកបញ្ហានានា អាចដកសេចក្តីស្នើច្បាប់ ឬបញ្ហានានានោះចេញបានទោះបីជាព្រឹទ្ធសភាចាប់ផ្តើមពិភាក្សាហើយក៏ដោយ។

ចំពោះសេចក្តីស្នើច្បាប់ ឬបញ្ហានានា ដែលបានដកចេញមិនឲ្យពិភាក្សានោះក៏ដោយ ក៏សមាជិកផ្សេងៗទៀតអាចសុំឲ្យព្រឹទ្ធសភាពិភាក្សាវិញបាន។[414]

សមាជិកព្រឹទ្ធសភាគ្រប់រូបអាចស្នើសុំឲ្យធ្វើការកែសម្រួលលើសេចក្តីព្រាងច្បាប់ ឬសេចក្តី

---

[411] មាត្រា៩៩ថ្មីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[412] មាត្រា៩១ថ្មីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[413] ប្រការ២៤បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

[414] ប្រការ២៧បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

ស្នើច្បាប់ជាលាយលក្ខណ៍អក្សរ ដើម្បីជូនទៅគណៈកម្មការជំនាញក៏បាន ឬជូនទៅព្រឹទ្ធសភាក្នុងសម័យប្រជុំពេញអង្គក៏បាន។[415]

ព្រឹទ្ធសភា អាចសម្រេចយល់ព្រម ឬមិនយល់ព្រម យកពាក្យសុំនោះមក ពិភាក្សាបាន។

១.២.ការត្រួតពិនិត្យច្បាប់

(Law Examination)

សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ដែលរដ្ឋសភាបានអនុម័តយល់ព្រម លើកដំបូងរួចហើយព្រមទាំងបញ្ហានានាដែលរដ្ឋសភាបានដាក់ឲ្យពិនិត្យត្រូវបញ្ជូនមកគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា។ សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហានានានោះត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយចែកជូនសមាជិកព្រឹទ្ធសភានីមួយៗទាំងអស់ដោយភ្ជាប់សេចក្តីថ្លែងហេតុមកជាមួយផង។

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ត្រូវបញ្ជូនសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហានានាទៅឲ្យគណៈកម្មការជំនាញដើម្បីធ្វើការពិនិត្យ។

កាលបើគណៈកម្មការជំនាញបានពិនិត្យរួចហើយ ប្រធានគណៈកម្មការនោះ ត្រូវនាំយកយោបល់របស់គណៈកម្មការមកជម្រាបជូនព្រឹទ្ធសភាបានជ្រាប។[416]

-អង្គប្រជុំព្រឹទ្ធសភាអាចប្រើនីតិវិធី ដោយពិភាក្សាសង្ខេបបានដោយធ្វើការពិភាក្សាតែលើមាត្រាណា ឬជំពូកណា ដែលមានសំណើធ្វើការកែសម្រួល ជាលាយលក្ខណ៍អក្សរ ដូចមានចែងក្នុងប្រការទាំងឡាយខាងលើ។

ក្នុងករណី ដែលត្រូវប្រើនីតិវិធីណាមួយខាងលើគណៈកម្មាធិការអចិន្ត្រៃយ៍ត្រូវជូនព័ត៌មានដល់គ្រប់សមាជិកព្រឹទ្ធសភាទាំងអស់។[417]

-ព្រឹទ្ធសភាអនុម័តលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ទាំងមូលនោះបាន។

ជារួម ព្រឹទ្ធសភា ត្រូវពិនិត្យហើយឲ្យយោបល់ក្នុងរយៈពេលមួយខែយ៉ាងយូរ លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ដែលរដ្ឋសភាបានអនុម័តយល់ព្រម លើកដំបូងរួចហើយ ព្រមទាំងលើបញ្ហាទាំងឡាយទាំងពួង ដែលរដ្ឋសភាបានដាក់ឲ្យពិនិត្យ។ បើជាការប្រញាប់ រយៈពេលនោះត្រូវបន្ថយមកនៅត្រឹមតែប្រាំ(៧)ថ្ងៃ។

បើព្រឹទ្ធសភាបានឲ្យយោបល់យល់ព្រម ឬពុំបានឲ្យយោបល់សោះក្នុងរយៈពេលដែលបានកំណត់ទុកហើយនោះទេ ច្បាប់ដែលរដ្ឋសភា បានអនុម័តយល់ព្រមហើយនោះ នឹងត្រូវបានយក

[415] ប្រការ២៨បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

[416] ប្រការ២៣បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

[417] ប្រការ២៣បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

ទៅប្រកាសឲ្យប្រើ។

បើព្រឹទ្ធសភា សុំឲ្យកែសម្រួលសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះ រដ្ឋសភាត្រូវយកមកត្រួតពិនិត្យពិចារណាភ្លាមជាលើកទីពីរ។ រដ្ឋសភាត្រូវពិនិត្យ និងសម្រេចត្រង់ បទប្បញ្ញត្តិណា ឬចំណុចណាដែលព្រឹទ្ធសភាបានសុំឲ្យកែសម្រួល ដោយបដិសេធចោលទាំងមូល ឬទុកជាបានការខ្លះ។ ការបង្វិលទៅបង្វិលមក រវាងព្រឹទ្ធសភា និងរដ្ឋសភា ត្រូវធ្វើឡើងក្នុងរយៈពេលមួយខែប៉ុណ្ណោះ។ រយៈពេលនេះ ត្រូវបន្ថយមកត្រឹមតែដប់ថ្ងៃ បើត្រូវពិនិត្យសម្រេចអំពីថវិកាជាតិ និងហិរញ្ញវត្ថុ ហើយមកត្រឹមតែពីរថ្ងៃបើសិនជាការប្រញាប់។

បើរដ្ឋសភា ទុកឲ្យហួសរយៈពេលកំណត់ ឬពន្យារពេលដែលកំណត់ទុកសម្រាប់ពិនិត្យនោះរយៈពេលជាគោលការណ៍ សម្រាប់រដ្ឋសភាត្រួតពិនិត្យ និង ព្រឹទ្ធសភាត្រួតពិនិត្យត្រូវបន្ថែមរយៈពេលឲ្យស្មើគ្នាផងដែរ។

បើព្រឹទ្ធសភា បដិសេធសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះជាអសារបង់ នោះរដ្ឋសភានឹងមិនអាចយកសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះមកពិចារណាជាលើកទីពីរបានមុនរយៈពេលមួយខែទេ។ រយៈពេលនេះត្រូវបន្ថយមកត្រឹមដប់ប្រាំថ្ងៃ ប្រសិនបើពិនិត្យអំពីថវិកាជាតិ និងហិរញ្ញវត្ថុហើយមកត្រឹមតែបួនថ្ងៃបើជាការប្រញាប់។

ក្នុងការពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ជាលើកទី២នេះ រដ្ឋសភាគឺត្រូវអនុម័តដោយវិធីបោះឆ្នោតចំហ និងយកតាមមតិភាគច្រើនដាច់ខាត(៥០+១)។

សេចក្តីព្រាងច្បាប់ណា ឬសេចក្តីស្នើច្បាប់ណា ដែលបានសម្រេច ដូចខាង លើនេះហើយនោះ នឹងត្រូវបានយកទៅប្រកាសឲ្យប្រើ។[418]

១.៣.ការអនុម័តរបស់ព្រឹទ្ធសភា

(Adoption of Senate)

ការពិភាក្សាលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ត្រូវធ្វើដូចតទៅ:

-អង្គប្រជុំព្រឹទ្ធសភាត្រូវពិភាក្សា និងអនុម័តលើខ្លឹមសារទាំងមូល គឺបញ្ចេញមតិថាតើគួរពិចារណាឬទេ?

-អង្គប្រជុំព្រឹទ្ធសភា នឹងធ្វើការអនុម័តទៅលើមាត្រាមួយម្តងៗក៏បាន ឬលើជំពូកដោយអនុម័តមួយជំពូកម្តងៗក៏បាន។

ព្រឹទ្ធសភា អាចអនុម័តទៅលើបញ្ហាទាំងឡាយ គ្រប់បែបយ៉ាងរបស់ប្រទេសជាតិ ក្នុងករណី

[418] មាត្រា១១៣ថ្មីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

ច្បាប់ និងបញ្ហានានា ដែលរដ្ឋសភាបានធ្វើការអនុម័តរួចហើយ និងព្រឹទ្ធសភាបានត្រួតពិនិត្យ និងអនុម័តរួចហើយត្រូវបានព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខា និងចេញព្រះរាជក្រមប្រកាសឲ្យប្រើ។

ព្រឹទ្ធសភា អាចអនុម័តទៅលើបញ្ហាទាំងឡាយដូចជា៖

-ព្រឹទ្ធសភាអនុម័តថវិកាជាតិ ផែនការរដ្ឋ ឬការឲ្យរដ្ឋគេខ្ចីប្រាក់ពីប្រទេសយើង ឬការឲ្យរដ្ឋយើងខ្ចីប្រាក់ពីប្រទេសគេ ឬការសន្យានានាផ្នែកហិរញ្ញវត្ថុ និងការបង្កើតការកែប្រែ ឬការលុបចោលពន្ធដារជាដើម។

-ព្រឹទ្ធសភា ឲ្យសេចក្តីយល់ព្រមចំពោះគណនីរដ្ឋបាល។

-ព្រឹទ្ធសភា អនុម័តច្បាប់ស្តីពីការលើកលែងទោសជាទូទៅ។

-ព្រឹទ្ធសភាអនុម័តយល់ព្រម ឬលុបចោលសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ។

-ព្រឹទ្ធសភាអនុម័តច្បាប់ស្តីពីការប្រកាសសង្គ្រាម ។

ព្រឹទ្ធសភា បោះឆ្នោតអនុម័តបញ្ហានានាខាងលើនេះ អាចប្រព្រឹត្តទៅដោយមតិភាគច្រើនដាច់ខាត(៥០+១)នៃសមាជិកព្រឹទ្ធសភាទាំងមូល។

ព្រឹទ្ធសភាអាចអនុម័ត ដើម្បីឲ្យអង្គការមានសមត្ថកិច្ចធ្វើការចាប់ខ្លួនបានចំពោះសមាជិកព្រឹទ្ធសភា ដោយអនុម័តតាមមតិភាគច្រើន ពីរភាគបី(២/៣)នៃសមាជិកព្រឹទ្ធសភាទាំងមូល។

ព្រឹទ្ធសភា អាចអនុម័តទៅលើករណី ការឃុំខ្លួន ការចាប់ខ្លួន ការចោទប្រកាន់នៃសមាជិកព្រឹទ្ធសភារូបណាមួយត្រូវផ្អាកប្រសិនបើព្រឹទ្ធសភាបានបញ្ចេញមតិឲ្យផ្អាកតាមមតិភាគច្រើនបីភាគបួន(៣/៤)នៃសមាជិកព្រឹទ្ធសភាទាំងមូល។[419]

បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា ត្រូវអនុម័តយល់ព្រមដោយសម្លេងភាគ ច្រើនដាច់ខាត(៥០%+១)នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។[420]

២.តួនាទីជាអ្នកសម្របសម្រួល

(Roles as Coordinator)

តួនាទីជាអ្នកសម្របសម្រួលតាមរយៈទ្រឹស្តី គឺជាតួនាទីដ៏សំខាន់បំផុត ដែលបានអនុញ្ញាតឲ្យអង្គការព្រឹទ្ធសភាអាចអនុវត្តន៍អំណាច ដែលមានឥទ្ធិពលសំខាន់លើការងាររបស់ស្ថាប័នពីរ គឺអង្គការនីតិប្រតិបត្តិ(រាជរដ្ឋាភិបាល) និងអង្គការនីតិប្បញ្ញត្តិ(រដ្ឋសភា)។

នៅក្នុងច្បាប់ រដ្ឋធម្មនុញ្ញ ក៏បានកំណត់អំពីតួនាទីនេះដែរ ដោយព្រឹទ្ធសភាមានការកិច្ចធ្វើ

[419] មាត្រា១០៤ថ្មីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[420] មាត្រា១១៤ថ្មីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

ការសម្របសម្រួលការងាររវាងរដ្ឋសភា និងរាជរដ្ឋាភិបាល[421]។

ព្រឹទ្ធសភាមានភារកិច្ច ដែលអាចប្រើប្រាស់បាននូវគ្រប់មធ្យោបាយ និងអាចធ្វើអន្តរាគមន៍បានគ្រប់ពេលវេលា ដើម្បីដោះស្រាយវិបត្តិនយោបាយតូច ឬធំគ្រប់បែបយ៉ាង រវាងស្ថាប័នទាំងពីរ ប៉ុន្តែព្រឹទ្ធសភា ក៏មិនអាចចាប់បង្ខំ ដើម្បីឲ្យអង្គការស្ថាប័នទាំងពីរ ត្រូវតែអនុវត្តន៍ទៅតាមទស្សនៈរបស់ខ្លួនដោយគោរពតាមឆន្ទានុសិទ្ធិបានដែរ។

ជារួម តួនាទីសម្របសម្រួលរបស់ព្រឹទ្ធសភា អាចផ្តល់ជាយោបល់ទៅឲ្យរដ្ឋសភា និងរាជរដ្ឋាភិបាលអំពីបញ្ហាចម្រូងចម្រាសទាំងឡាយហើយក៏ជាអំណាចពិតប្រាកដមួយ ដែលព្រឹទ្ធសភាអាចធ្វើអន្តរាគមន៍ ដើម្បីស្វែងរកនូវដំណោះស្រាយ ឲ្យមានភាពស្រុះស្រួលគ្នារវាងរាជរដ្ឋាភិបាល និងរដ្ឋសភា។

ដូចជាករណីរដ្ឋសភា មិនយល់ស្របនឹងនយោបាយរបស់រាជរដ្ឋាភិបាលជាដើម។

៣-តួនាទីផ្សេងទៀតរបស់ព្រឹទ្ធសភា

(Other Roles of Senate)

ការសើរើ និងការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ច្បាប់មិនបានកំណត់ និងអនុញ្ញាតឲ្យអង្គការព្រឹទ្ធសភាអនុវត្តន៍ដូចរដ្ឋសភានោះទេ។ ប៉ុន្តែសមាជិកព្រឹទ្ធសភាចំនួនមួយភាគបី(១/៣)យ៉ាងតិចមានសិទ្ធិស្នើសុំព្រឹទ្ធសភាធ្វើការកោះប្រជុំព្រឹទ្ធសភាជាវិសាមញ្ញបាន។[422]

សមាជិកព្រឹទ្ធសភា ចំនួនមួយភាគដប់(១/១០)យ៉ាងតិច មានសិទ្ធិស្នើសុំឲ្យព្រឹទ្ធសភាធ្វើការប្រជុំជាសម្ងាត់បាន។ ព្រឹទ្ធសភាអាចបង្កើតគណៈកម្មការផ្សេងៗដែលចាំបាច់បាន។[423]

សមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន(១/៤)យ៉ាងតិចមានសិទ្ធិបញ្ជូនច្បាប់ ដែលរដ្ឋសភាបានអនុម័តទៅឲ្យក្រុមប្រឹក្សាធម្មនុញ្ញ ធ្វើការពិនិត្យធម្មនុញ្ញភាពនៃច្បាប់ មុនប្រកាសឲ្យប្រើ និងច្បាប់ដែលបានប្រកាសឲ្យប្រើរួចហើយ។[424]

ព្រឹទ្ធសភាមានសិទ្ធិធ្វើការតាមដានក្នុងការអនុវត្តច្បាប់ និងត្រួតពិនិត្យការងាររបស់រាជរដ្ឋាភិបាលបាន ប៉ុន្តែអង្គការព្រឹទ្ធសភាពុំអាចជើរតួនាទីជាអ្នកប្រឆាំងឬអ្នកគាំទ្ររាជរដ្ឋាភិបាលឡើយ ដែលជាទូទៅ អង្គការព្រឹទ្ធសភាមានបេសកកម្មបំពេញការងារទាំងឡាយ ឲ្យកាន់តែប្រសើរឡើង ក្នុងគោលដៅអាទិភាពដើម្បីធ្វើការអភិវឌ្ឍប្រទេសជាតិ។

---

[421] មាត្រា១១២ថ្មីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[422] មាត្រា១០៧ថ្មីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[423] មាត្រា១១៤ថ្មីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[424] មាត្រា១៤០មាត្រា១៤១ថ្មីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

ព្រឹទ្ធសភា អាចធ្វើការកែលម្អទៅលើបញ្ហាប្រទេសជាតិតាមរយៈដំណើរការសិក្សាស្រាវជ្រាវ វាយតម្លៃ និងកំណត់នូវចក្ខុវិស័យទៅមុខ ព្រមទាំងផ្តល់ជាអនុសាសន៍ល្អៗក្នុងការកសាងប្រទេសជាតិឲ្យក្លាយជានីតិរដ្ឋ។

ព្រឹទ្ធសភា អាចប្រជុំរួមគ្នាជាសមាជជាមួយរដ្ឋសភា ដើម្បីដោះស្រាយបញ្ហានានាសំខាន់ៗរបស់ប្រទេសជាតិ។

ច.ការប្រជុំព្រឹទ្ធសភា

(Meeting of Senate)

ការបើកសម័យប្រជុំរបស់ព្រឹទ្ធសភា ត្រូវបានធ្វើឡើង នៅរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជាក្នុងសាលប្រជុំរបស់ព្រឹទ្ធសភា។[425]

ព្រឹទ្ធសភា មិនអាចអនុវត្តន៍អំណាចរបស់ខ្លួន ជាសម្ងាត់បានទេ ជាទូទៅនៅគ្រប់សម័យប្រជុំនៃព្រឹទ្ធសភាត្រូវធ្វើឡើងជាសាធារណៈ។

ព្រឹទ្ធសភា អាចប្រជុំជាសម្ងាត់បាន តាមការស្នើសុំពីប្រធាន ឬពីសមាជិកចំនួនមួយភាគដប់យ៉ាងតិចនៃសមាជិកព្រឹទ្ធសភា ពីព្រះមហាក្សត្រ ឬពីនាយករដ្ឋមន្ត្រី។[426]

កាលបើព្រឹទ្ធសភា សម្រេចត្រូវប្រជុំជាសម្ងាត់ ប្រធានព្រឹទ្ធសភា និងលេខាធិការត្រូវត្រួតពិនិត្យមើលឲ្យបានច្បាស់ ជាមុនសិនថា ពិតជាគ្មានមនុស្សដទៃ ក្រៅពីសមាជិកព្រឹទ្ធសភាលេខាធិការ និងឥស្សរជនដែលព្រឹទ្ធសភាត្រូវការចាំបាច់នៅក្នុងសាលប្រជុំ។

ការកំណត់ថ្ងៃប្រជុំត្រូវធ្វើជាលិខិតផ្ញើទៅជូនសមាជិកព្រឹទ្ធសភា បើមានការកំណត់ដោយផ្ទាល់មាត់ក្នុងពេលប្រជុំការកំណត់ពេលប្រជុំនេះ នឹងត្រូវធ្វើជាលិខិតអញ្ជើញផ្ញើរជូនទៅសមាជិកព្រឹទ្ធសភាដែលមិនបានមកប្រជុំ។

តាមធម្មតា នៅពេលប្រជុំព្រឹទ្ធសភាម្តងៗត្រូវកំណត់ពេលវេលាយ៉ាងតិច២ថ្ងៃមុនវៀរលែងតែក្នុងករណីជាការប្រញាប់។[427]

លិខិតអញ្ជើញ ត្រូវមានភ្ជាប់ទៅជាមួយនូវរបៀបវារៈនៃកិច្ចប្រជុំ វៀរលែងតែក្នុងករណីជាការប្រញាប់។

ក្នុងពេលប្រជុំណាមួយប្រសិនបើប្រធាននិងអនុប្រធានរបស់ព្រឹទ្ធសភាមិននៅ ឬអវត្តមានដោយមានហេតុការណ៍អ្វីមួយ ជាពិសេសព្រឹទ្ធសភា អាចជ្រើសតាំង ប្រធានបណ្តោះអាសន្ន១រូប

---

[425] មាត្រា១០៩ថ្មីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[426] មាត្រា១១១ថ្មីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[427] ប្រការ៤៦បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

ឲ្យដឹកនាំការប្រជុំបន្តបាន។[428]

ប្រសិនបើមានបញ្ហាណាមួយត្រូវថ្លែងជម្រាបជូនព្រឹទ្ធសភា ប្រធានព្រឹទ្ធសភាត្រូវថ្លែងមុនចាប់ផ្តើមរបៀបវារៈ។

តាមធម្មតា ដំណើរការប្រជុំ ត្រូវធ្វើតាមរបៀបវារៈ វៀរលែងតែក្នុងពេលប្រជុំខ្លះ ដែលអង្គប្រជុំសម្រេចផ្សេងពីនេះ។ មុនការចាប់ផ្តើមនៃសម័យប្រជុំនីមួយៗព្រឹទ្ធសភាត្រូវអនុម័តរបៀបវារៈ និងសមាសភាពលេខាធិការសម័យប្រជុំ។[429]

របៀបវារៈមានជាលំដាប់មុនក្រោយដូចតទៅ:[430]

-បញ្ហាទាំងឡាយ ដែលព្រឹទ្ធសភាបានសម្រេចថាទុកជាការប្រញាប់

-បញ្ហាទាំងឡាយ ដែលរដ្ឋសភាជូនមកព្រឹទ្ធសភា

-បញ្ហាទាំងឡាយ ដែលរាជរដ្ឋាភិបាលជូនមកព្រឹទ្ធសភា

-បញ្ហាទាំងឡាយ ដែលគណៈកម្មការនានាជូនមកព្រឹទ្ធសភា

-បញ្ហាទាំងឡាយ ដែលសមាជិកព្រឹទ្ធសភាជូនមកព្រឹទ្ធសភា។

ការប្រជុំរបស់ព្រឹទ្ធសភា ជាទូទៅមានពីរយ៉ាង គឺការប្រជុំជាសាមញ្ញ និងជាវិសាមញ្ញ។

១-ការប្រជុំជាសាមញ្ញ

(Ordinary Meeting)

ព្រឹទ្ធសភាត្រូវប្រជុំជាសាមញ្ញពីរដងក្នុងមួយឆ្នាំ ក្នុងសម័យប្រជុំនីមួយៗត្រូវមានថេរៈវេលាយ៉ាងតិចបីខែ។មានន័យថា ព្រឹទ្ធសភាត្រូវប្រជុំជាប់ជាប្រចាំរយៈពេល៣ខែ ហើយរយៈពេល៣ខែបន្ទាប់ត្រូវឈប់សម្រាក បន្ទាប់មកចាប់ផ្តើមប្រជុំជាប់ជាប្រចាំរយៈពេល៣ខែ។[431]

២-ការប្រជុំជាវិសាមញ្ញ

(Extra Ordinary Meeting)

ការប្រជុំជាវិសាមញ្ញ គឺជាការប្រជុំមួយធ្វើឡើងនៅចន្លោះសម័យប្រជុំជាសាមញ្ញដែលការប្រជុំនេះ អាចធ្វើទៅបាន គឺក្នុងករណីមានការចាំបាច់ និងជាបន្ទាន់ណាមួយទាក់ទងទៅនឹងបញ្ហាសំខាន់ៗរបស់ប្រទេសជាតិ។

ព្រឹទ្ធសភា អាចកោះប្រជុំជាវិសាមញ្ញបានបើមានសំណូមពរពីព្រះមហាក្សត្រ ឬតាមសេចក្តី

---

[428] ប្រការ៤៨បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

[429] ប្រការ៥០បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

[430] ប្រការ២២បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

[431] មាត្រា១០៧ថ្មីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

ស្នើសុំពីនាយករដ្ឋមន្ត្រី ឬមានការស្នើសសុំពីសមាជិកព្រឹទ្ធសភា ដែលមានចំនួនមួយភាគបី(១/៣) នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។[432]

ក្នុងករណីនេះ រយៀបវារៈដាក់លាក់នៃសម័យប្រជុំវិសាមញ្ញនីមួយៗត្រូវផ្សព្វផ្សាយដល់ប្រជាពស្ត្រជាមួយនឹងថ្ងៃកំណត់ប្រជុំច្បាស់លាស់។[433]

៣-ការប្រជុំរាល់ថ្ងៃ

(Daily Meeting)

ការប្រជុំរាល់ថ្ងៃជាប្រចាំគឺធ្វើឡើងនៅពេលប្រទេសជាតិស្ថិតក្នុងភាពចាំបាច់ ឬក្នុងកាលៈទេសៈប្រទេសជាតិ ស្ថិតក្នុងភាពអាសន្ន ព្រឹទ្ធសភា ប្រជុំរាល់ថ្ងៃជាប់ជាប្រចាំ ព្រឹទ្ធសភាមានសិទ្ធិសម្រេចបញ្ចប់កាលៈទេសៈពិសេសខាងលើនេះ កាលបើសភាពការណ៍អនុញ្ញាត។

បើសិន ព្រឹទ្ធសភាមិនអាចប្រជុំបាន ដោយមូលហេតុចាំបាច់ជាអាទិ៍នៅពេលដែលកម្លាំងបរទេសបានចូលមកកាន់កាប់ទឹកដី ការប្រកាសភាពអាសន្នត្រូវបន្តទៅមុខជាស្វ័យប្រវត្តិ។នៅពេលដែលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ព្រឹទ្ធសភាមិនអាចត្រូវរំលាយបានឡើយ។[434]

ការប្រជុំព្រឹទ្ធសភាទាំងអស់ខាងលើ អាចដំណើរការទៅបានលុះត្រាតែមាន:

-កូរ៉ុមលើសពីពីរភាគបី(២/៣)នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល គឺសម្រាប់ការអនុម័តច្បាប់ទាំងឡាយណា ដែលច្បាប់តម្រូវឲ្យអនុម័ត ដោយមតិភាគច្រើនពីរភាគបី(២/៣)នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

-កូរ៉ុមលើសពីពាក់កណ្តាលនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល គឺសម្រាប់ការអនុម័តទាំងឡាយណា ដែលតម្រូវឲ្យអនុម័តយកមតិភាគច្រើនដោយប្រៀប ឬដោយមតិភាគច្រើនដាច់ខាត (៥០%+១)នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

ចំនួនសម្លេងដែលតម្រូវ សម្រាប់ឲ្យរដ្ឋសភាអនុម័តយល់ព្រម ហើយដែលបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញត្រូវបានយកមកអនុវត្តន៍សម្រាប់ព្រឹទ្ធសភាផងដែរ។[435]

សមាជិកព្រឹទ្ធសភា ដែលអវត្តមានត្រូវបានចុះក្នុងបញ្ជីអវត្តមាន ហើយបញ្ជីអវត្តមាននេះត្រូវបានប្រកាសដោយប្រធានព្រឹទ្ធសភាដោយបញ្ជាក់អំពីមូលហេតុផង។

ប្រធានព្រឹទ្ធសភាគឺត្រូវប្រកាសផ្អាកការប្រជុំ ប្រសិនបើចំនួនកូរ៉ុមមិនគ្រប់ចំនួនរយៈពេល

[432] មាត្រា១០៧ថ្មីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[៤៣៣] មាត្រា១០៧ថ្មី រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[៤៣៤] មាត្រា១០២ថ្មី រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[៤៣៥] មាត្រា១១១ថ្មី(ពីរ)រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

៣០នាទីបន្ទាប់ពីហួសពេលកំណត់នៃការចាប់ផ្តើមប្រជុំ។[436]

៤-នីតិវិធីនៃការអនុម័ត

(Procedure of Adoption)

ព្រឹទ្ធសភាអាចអនុម័តទាក់ទងបញ្ហាផ្សេងៗតាមនីតិវិធីបីយ៉ាងគឺ:[437]

- អនុម័តបោះឆ្នោត ដោយការលើកដៃ
- អនុម័តបោះឆ្នោត ដោយការបោះឆ្នោតជាចំហ
- អនុម័តបោះឆ្នោត ដោយការបោះឆ្នោតជាចំហនៅលើវេទិកា
- អនុម័តបោះឆ្នោត ដោយការបោះឆ្នោតជាសម្ងាត់

៤.១.ការអនុម័តដោយវិធីលើកដៃ

(Adoption by Raising Hand)

ការអនុម័ត ដោយវិធីលើកដៃគឺប្រធាន និងលេខាធិការទាំងឡាយជាអ្នករាប់ចំនួនសមាជិកព្រឹទ្ធសភាដែលត្រូវបានលើកដៃធ្វើការអនុម័ត។

បើប្រធាន និងលេខាធិការយល់ឃើញថា ការលើកដៃអនុម័តនេះ មិនបានច្បាស់លាស់ទេនោះ គេត្រូវធ្វើទៅតាមនីតិវិធីដដែលសារជាថ្មីម្តងទៀត កាលបើការលើកដៃអនុម័តបានរហូតទៅដល់ពីរដងហើយ ក៏ប៉ុន្តែនៅតែមិនទទួលបានលទ្ធផលច្បាស់លាស់ទេនោះ ព្រឹទ្ធសភាត្រូវអនុវត្តន៍ការអនុម័តបោះឆ្នោតជាចំហវិញ។[438]

៤.២.ការអនុម័តបោះឆ្នោតជាចំហ

(Adoption by Open Vote)

ការអនុម័តបោះឆ្នោតជាចំហ គឺជាការបោះឆ្នោតដែលមានគណៈកម្មការបោះឆ្នោតជាអ្នកកាន់ហិបឆ្នោតដើរប្រមូលយកសន្លឹកឆ្នោតពីសមាជិកព្រឹទ្ធសភាម្នាក់ៗ។

សមាជិកព្រឹទ្ធសភា ត្រូវតែសរសេរឈ្មោះរបស់ខ្លួនដាក់នៅលើសន្លឹកឆ្នោតនោះដែលសន្លឹកឆ្នោត មានសណ្ឋានបីពណ៌ ដែលមានពណ៌ខៀវ គឺមានន័យថាមិនយល់ព្រម ពណ៌សគឺមានន័យថាយល់ព្រម និងពណ៌សឆ្នូតខៀវគឺមានន័យថាអនុប្បវាទ។

ក្រោយពីបានបោះឆ្នោតរួចស្រេចហើយ លេខាធិការនៃព្រឹទ្ធសភាគឺជាអ្នករាប់សន្លឹកឆ្នោត

---

[436] ប្រការ៤៤បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

[437] ប្រការ៣៣បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

[438] ប្រការ៣៤បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

ហើយប្រធានព្រឹទ្ធសភាជាអ្នកប្រកាសជូនអង្គប្រជុំទាំងមូលបានជ្រាប។[439]

៤.៣. ការអនុម័តបោះឆ្នោតជាចំហនៅលើវេទិកា

(Adoption by Open Vote on Forum)

ការអនុម័តបោះឆ្នោតជាចំហនៅលើវេទិកា គឺជាការបោះឆ្នោតអនុម័តមួយប្រភេទ ដែលសមាជិកព្រឹទ្ធសភាម្នាក់ៗត្រូវដើរទៅយកសន្លឹកឆ្នោតមកបោះក្នុងហិបឆ្នោត ដែលបានដាក់នៅលើវេទិកា។ ការអនុម័តបោះឆ្នោតជាចំហនៅលើវេទិការនេះ អាចធ្វើទៅបាន លុះត្រាតែមានសមាជិកព្រឹទ្ធសភាចំនួន៦រូបយ៉ាងតិចបានស្នើសុំ។[440]

៤.៤.ការអនុម័តបោះឆ្នោតដោយសម្ងាត់

(Adoption by Secret Vote)

ការអនុម័តបោះឆ្នោតដោយសម្ងាត់ គឺជាការបោះឆ្នោតមួយប្រភេទដែលអ្នកតំណាងរាស្ត្រមិនសរសេរឈ្មោះរបស់ខ្លួននៅលើសន្លឹកឆ្នោតនោះទេ វិធីបោះឆ្នោតដោយសម្ងាត់នេះ ត្រូវបានគេយកមកប្រើក្នុងការអនុម័តបោះឆ្នោតលើបញ្ហាមួយចំនួនដូចជា:

-អនុម័តច្បាប់នានា និងអនុម័តច្បាប់វិសោធនកម្មរដ្ឋធម្មនុញ្ញ

-អនុម័តកិច្ចការទាំងឡាយរបស់ប្រទេសជាតិជាច្រើនទៀត

ការអនុម័តទាំងឡាយ ត្រូវបានអនុម័តតាមមតិភាគច្រើនដែលមានកំណត់ក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។ ក្រៅតែពីនេះ ការអនុម័តមតិភាគច្រើនជាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូលត្រូវចាត់ទុកថាជាបានការ។[441]

បើចំនួនមតិយល់ព្រម និងចំនួនមតិមិនយល់ព្រមមានចំនួនស្មើគ្នានោះការបោះឆ្នោតត្រូវធ្វើឡើងជាថ្មីម្តងទៀត បើលទ្ធផលនៃការបោះឆ្នោតលើកទី២នេះ នៅតែមានសម្លេងស្មើគ្នានោះ ព្រឹទ្ធសភាត្រូវចាត់ទុកថាការអនុម័តនេះមិនយល់ព្រម។[442]

ក្រោយពីទទួលបានលទ្ធផលនៃការបញ្ចេញមតិរួចហើយ ប្រធានព្រឹទ្ធសភាត្រូវប្រកាសថា ព្រឹទ្ធសភាបានអនុម័តយល់ព្រមហើយ ឬព្រឹទ្ធសភាបានអនុម័តមិនយល់ព្រមទេ។[443]

នៅក្នុងប្រទេសកម្ពុជាយើងសព្វថ្ងៃ អង្គការព្រឹទ្ធសភានៅប្រើប្រាស់នៃការអនុម័តសម្រេច

---

[439] ប្រការ៣៥បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

[440] ប្រការ៣៦បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

[441] ប្រការ៣៨បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

[442] ប្រការ៣៩បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

[443] ប្រការ៤០បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

លើករណីជាច្រើនដូចតទៅ:

៤.៥.ការប្រើចំនួនៃការអនុម័តដោយព្រឹទ្ធសភា

(Using kind of Numbers of Adopted by Senat)

ជាទូទៅព្រឹទ្ធសភា គឺជាអង្គការដែលមានសមត្ថកិច្ចក្នុងការអនុម័តសម្រេចលើបញ្ហានានារបស់ប្រទេសជាតិទាំងមូល តាមការកំណត់រដោយច្បាប់ ដែលព្រះរាជាណាចក្រកម្ពុជាយើងបានអនុវត្តន៍របបសភាពីរថ្នាក់ គឺមានន័យថា ប្រទេសយើងក្រោយអំពីរដ្ឋសភាបានអនុម័តសម្រេចរួចហើយត្រូវបញ្ជូនមកអង្គការព្រឹទ្ធសភាត្រួតពិនិត្យ និងអនុម័តបន្ត។

ហេតុនេះ នៅក្នុងព្រឹទ្ធសភាប្រទេសកម្ពុជាយើងបានប្រើប្រាស់នីតិវិធី និងប្រភេទចំនួននៃការអនុម័តដូចតទៅ:

-ការអនុម័តដោយសម្លេងភាគច្រើនបីភាគបួន(៣/៤)

-ការអនុម័តដោយសម្លេងភាគច្រើនពីរភាគបី(២/៣)

-ការអនុម័តដោយសម្លេងភាគច្រើនដាច់ខាត(៥០+១)

ការអនុម័តទាំងអស់ខាងលើនេះត្រូវបានអនុវត្តន៍នៅក្នុងព្រឹទ្ធសភាអាណត្តិទី៤សព្វថ្ងៃ។

៤.៥.១.ការអនុម័តដោយសម្លេងភាគច្រើនបីភាគបួន(៣/៤)

(Adopted by a Three of Four of Majority)

ការអនុម័តដោយសម្លេងបីភាគបួន ដែលអាចយកជាការបាន លុះត្រាតែការអនុម័តនោះបានចំនួនសម្លេងស្មើនឹងចំនួនសមាជិកព្រឹទ្ធសភាទាំងអស់គុណនឹង៣ ហើយចែកនឹង៤គឺសែសិបប្រាំពីរ(៤៧)សម្លេងឡើងទៅរហូតដល់៦២សម្លេងទើបអាចយកជាការបាន។

ឧទាហរណ៍ ចំនួនសមាជិកព្រឹទ្ធសភាសរុប ៦២ * ៣:៤ = ៤៧

សំគាល់ ការប្រើប្រាស់ក្នុងការអនុម័តដោយសម្លេងបីភាគបួន(**៣/៤**)**នេះ ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជាយើងសព្វថ្ងៃនៅប្រើចំពោះតែ*ករណីមួយគត់*** គឺការអនុម័តមិនឲ្យចាប់ខ្លួនសមាជិកព្រឹទ្ធសភាណាមួយ។[444]

៤.៥.២.ការអនុម័តដោយសម្លេងភាគច្រើនពីរភាគបី(២/៣)

(Adopted by a Two of Three of Majority)

ការអនុម័តដោយសម្លេងពីរភាគបី(២/៣)ដែលអាចយកជាការបានលុះត្រាតែការអនុម័ត

[444] វាក្យខ័ណ្ឌចុងក្រោយមាត្រា១០៤ថ្មីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

នោះបានចំនួនសម្លេងស្មើនឹងចំនួនសមាជិកព្រឹទ្ធសភាទាំងអស់គុណនឹង២ ហើយចែកនឹង៣គឺសែសិបពីរ(៤២)សម្លេងឡើងទៅរហូតដល់៦២សម្លេងទើបអាចយកជាការបាន។

ឧទាហរណ៍ ចំនួនសមាជិកព្រឹទ្ធសភាសរុប ៦២*២:៣ = ៤២

សំគាល់:ការប្រើប្រាស់ នៅក្នុងការអនុម័តដោយសម្លេងពីរភាគបី**(២/៣)នេះ ព្រឹទ្ធសភាព្រះរាជាណាចក្រកម្ពុជាយើងសព្វថ្ងៃ នៅប្រើសម្រាប់ការអនុម័តមានចំនួនតែ២ករណីនេះទេគឺ:**

ករណីទី១-ការអនុម័តដកអភ័យឯកសិទ្ធិសមាជិកព្រឹទ្ធសភាណាមួយ។[445]

ករណីទី២-ការអនុម័ត ការប្រកាសបន្តនីតិកាលរបស់ព្រឹទ្ធសភាត្រូវបានអនុម័ត ដោយសម្លេងភាគច្រើនពីរភាគបីនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។[446]

សំគាល់: ការប្រើប្រាស់នៅក្នុងការអនុម័ត ដោយសម្លេងភាគច្រើនពីរភាគបី(២/៣)នេះ **អង្គការព្រឹទ្ធសភាកម្ពុជាយើងសព្វថ្ងៃនៅប្រើសម្រាប់អនុម័តមានចំនួនតែ២ករណីទេ។**

៤.៥.៣.ការអនុម័តដោយសម្លេងភាគច្រើនដាច់ខាត(៥0%+១)

(Absolute Majority of Approval)

ការអនុម័តដោយសម្លេងភាគច្រើនដាច់ខាត(៥0%+១) គឺជាការអនុម័ត ដែលអាចយកជាការបាន លុះត្រាតែការអនុម័តនោះ បានចំនួនសម្លេងស្មើនឹងចំនួនសមាជិកព្រឹទ្ធសភាទាំងអស់ចែកនឹង២ហើយបូកនឹង១ គឺបានចំនួនសាមសិបពីរ(៣២)សម្លេងឡើងទៅ រហូតដល់៦២សម្លេងទើបអាចយកជាការបាន។

ឧទាហរណ៍ ចំនួនសមាជិកព្រឹទ្ធសភាសរុប ៦២:២+១ = ៣២

កំណត់សំគាល់: ក្រៅពីការអនុម័តដោយសម្លេងបីភាគបួន**(៣/៤)ដែលមាន១ករណី និង**ការអនុម័តដោយសម្លេងពីរភាគបី**(២/៣)ដែលមានតែ២ករណី លើកលែងករណីទាំងប៉ុន្មាននេះចេញ គឺគ្រប់ករណីទាំងអស់នៃការអនុម័តរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជាយើងសព្វថ្ងៃសុទ្ធតែត្រូវ**ប្រើប្រាស់ការអនុម័ត ដោយសម្លេងភាគច្រើនដាច់ខាត**(៥0%+១)ទាំងអស់មិនថាករណីនេះ ឬករណីណានោះទេ។**

ការអនុម័តទាំងឡាយរបស់ព្រឹទ្ធសភាត្រូវយកតាមមតិភាគច្រើន ដែលមានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញ។ ក្រៅពីនេះមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូលត្រូវទុកជាបាន

[445] មាត្រា១០៤ថ្មីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[446] មាត្រា១០២ថ្មីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

ការ រៀរលែងតែមានការកំណត់ក្នុងច្បាប់ដោយឡែក។[447]

ឆ.អាណត្តិព្រឹទ្ធសភា

(Mandate of Senate)

នីតិកាលរបស់ព្រឹទ្ធសភាមានអាណត្តិរយៈពេល៦ឆ្នាំ ហើយត្រូវផុតកំណត់ នៅពេលដែលសមាជិកព្រឹទ្ធសភាថ្មីចូលកាន់តំណែង។

ក្នុងករណី ប្រទេសជាតិមានសង្គ្រាម ឬក្នុងកាលៈទេសៈពិសេសដទៃទៀត ដែលមិនអាចធ្វើការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាទៅបាន ព្រឹទ្ធសភាអាចប្រកាសបន្តនីតិកាលរបស់ខ្លួនមួយដងបានមួយឆ្នាំតាមសំណើរបស់ព្រះមហាក្សត្រ។

ការប្រកាសបន្តនីតិកាលរបស់អង្គការព្រឹទ្ធសភា ត្រូវសម្រេចដោយមតិយល់ព្រម ពីរភាគបីយ៉ាងតិចនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

នៅក្នុងកាលៈទេសៈដូចបានរៀបរាប់ខាងលើនេះ ព្រឹទ្ធសភាត្រូវប្រជុំរាល់ថ្ងៃជាប់ជាប្រចាំ។ ព្រឹទ្ធសភាមានសិទ្ធិសម្រេចបញ្ចប់កាលៈទេសៈពិសេសខាងលើ កាលបើសភាពការណ៍អនុញ្ញាត។

ប្រសិនបើព្រឹទ្ធសភាមិនអាចធ្វើការប្រជុំបានទេ ដោយមូលហេតុចាំបាច់ជាអាទិ៍ នៅពេលដែលកម្លាំងបរទេសចូលមកកាន់កាប់ទឹកដី ការប្រកាសភាពអាសន្នត្រូវបន្តដោយស្វ័យប្រវត្តិ។[448]

ជាទូទៅការកំណត់ចំនួនអាសនៈនៃសមាជិកព្រឹទ្ធសភា ត្រូវធ្វើឡើង៦ខែយ៉ាងតិចមុនចប់នីតិកាលនីមួយៗព្រឹទ្ធសភាត្រូវអនុម័តកំណត់ចំនួនnSអាសនៈ និងការបែងចែកអាសនៈតាមភូមិភាគនីមួយៗ សម្រាប់នីតិកាលបន្ទាប់ហើយត្រូវផ្សព្វផ្សាយជាសាធារណៈ។

ក្នុងករណី ព្រឹទ្ធសភាខកខានពុំបានកំណត់សាជាថ្មីនូវអាសនៈក្នុងព្រឹទ្ធសភាចំនួនអាសនៈតាមភូមិភាគនោះ ព្រឹទ្ធសភាត្រូវយកតាមចំនួនអាសនៈក្នុងព្រឹទ្ធសភាដែលមានក្នុងនីតិកាលចាស់ឬនីតិកាលចុងក្រោយ។[449]

៩.តួនាទីប្រធានព្រឹទ្ធសភា

(Roles of Senate President)

ប្រធានព្រឹទ្ធសភាមានតួនាទីដូចជា:

-ប្រធានព្រឹទ្ធសភា ដឹកនាំអង្គប្រជុំរបស់រដ្ឋសភា ទទួលអាញ្ញត្តិច្បាប់ និងសេចក្តីសម្រេចចិត្តទាំងឡាយ ដែលព្រឹទ្ធសភាបានអនុម័តជានាវ៉ាប់រង ការអនុវត្តបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា

[447] ប្រការ៦៦បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

[448] មាត្រា១០២ថ្មីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[449] មាត្រា១០ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកព្រឹទ្ធសភា។

និងចាត់ចែងការធ្វើទំនាក់ទំនងអន្តរជាតិទាំងឡាយរបស់រដ្ឋសភា។[450]

-ធានាការប្រព្រឹត្តទៅនៃព្រឹទ្ធសភាឲ្យបានត្រឹមត្រូវស្របតាមរដ្ឋធម្មនុញ្ញ។

-ប្រធានព្រឹទ្ធសភា ជាប្រធាននៃគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា។[451]

-កោះប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីប្រជុំពិភាក្សា និងធ្វើការអនុម័តទៅលើបញ្ហាផ្សេងៗ។

-ប្រធានព្រឹទ្ធសភា មានតួនាទីចុះហត្ថលេខា លើលិខិតអញ្ជើញកោះប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ។ ការប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ត្រូវមានកូរ៉ុមលើស ពីពាក់កណ្តាលនៃចំនួនសមាជិកគណៈកម្មាធិការទាំងមូលដែលមានចំនួនយ៉ាងតិច៧រូប។

-ប្រធានព្រឹទ្ធសភា ជាអ្នកចុះហត្ថលេខា លើលិខិតអញ្ជើញសមាជិករដ្ឋសភាទាំងអស់ ដើម្បីចូលរួមការប្រជុំសភាពេញអង្គរបស់ព្រឹទ្ធសភាតាមកាលបរិច្ឆេទ និងទីកន្លែងប្រជុំច្បាស់លាស់។

-ប្រធានព្រឹទ្ធសភា ជាអ្នកបើក និងលើកពេលប្រជុំនៃព្រឹទ្ធសភា មុនពេលចាប់ផ្តើមប្រជុំលេខាធិការព្រឹទ្ធសភា ត្រូវជម្រាបជូនអង្គប្រជុំអំពីចំនួនកូរ៉ុម ប្រសិនបើកូរ៉ុមគ្រប់ចំនួនហើយ អង្គប្រជុំអាចដំណើការប្រជុំ ដោយប្រធានព្រឹទ្ធសភាជាអ្នកប្រកាសបើកសម័យប្រជុំភ្លាម។ ប្រសិនបើលេខាធិការព្រឹទ្ធសភាជម្រាបជូនអង្គប្រជុំអំពីចំនួនកូរ៉ុម ហើយកូរ៉ុមនៅមិនគ្រប់ចំនួននោះ ប្រធានព្រឹទ្ធសភាត្រូវប្រកាសផ្អាកការប្រជុំបើសិនចំនួនកូរ៉ុមមិនគ្រប់ក្នុងរយៈពេល៣០នាទី បន្ទាប់ពីហួសពេលកំណត់នៃការចាប់ផ្តើមប្រជុំ។[452]

-ប្រធានព្រឹទ្ធសភា អាចលើកពេលប្រជុំបាន បើប្រធានព្រឹទ្ធសភាយល់ឃើញថា ជាការមានប្រយោជន៍ ឬជាការចាំបាច់ ឬបើមានសមាជិកព្រឹទ្ធសភាចំនួន៦នាក់យ៉ាងតិចស្នើសុំ។[453]

-ការប្រជុំពិភាក្សាលើរបៀបវារៈចប់ ឬមិនចប់គឺអាស្រ័យលើពេលវេលាមុននឹងបិទអង្គប្រជុំ ប្រធានព្រឹទ្ធសភា ត្រូវប្រកាសជូនដំណឹងទៅដល់សមាជិក និងសមាជិកាអង្គប្រជុំទាំងមូល អំពីពេលវេលាប្រជុំនៅថ្ងៃបន្តបន្ទាប់។ បើសិនជាអស់របៀបវារៈពិភាក្សា ប្រធានព្រឹទ្ធសភាត្រូវប្រកាសលើកពេលប្រជុំដោយរងចាំទទួលលិខិតអញ្ជើញកោះប្រជុំសាជាថ្មីទៀត។

-ប្រធានព្រឹទ្ធសភាជាអ្នកការពារកិត្តិយស និងសិទ្ធិរបស់ព្រឹទ្ធសភា។

-ប្រធានព្រឹទ្ធសភា ជាអ្នកតែងតាំងបុគ្គលិកទាំងអស់នៃអគ្គលេខាធិការដ្ឋាន ដែលការតែង

---

[450] មាត្រា១១០ថ្មីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[451] ប្រការ៧បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

[452] ប្រការ៤៤បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

[453] ប្រការ៥១បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

តាំងត្រូវស្របទៅតាមច្បាប់ស្តីពីលក្ខន្តិក:មន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ និងស្របរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។[454]

-ប្រធានព្រឹទ្ធសភា ជាអ្នកស្នើសុំតែងតាំងអគ្គលេខាធិការ និងអគ្គលេខាធិការរង ក្រោយពីបានពិគ្រោះយោបល់ជាមួយអនុប្រធានទី១ និងអនុប្រធានទី២នៃព្រឹទ្ធសភា។ អគ្គលេខាធិការ និងអគ្គលេខាធិការរងត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ។[455]

-ប្រធានព្រឹទ្ធសភា ជាអ្នកចេញសេចក្តីសម្រេចនានា ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាន។

-ប្រធានព្រឹទ្ធសភា ជាអ្នកសម្រេចតែងតាំងសិប់ក្នុងក្របខ័ណ្ឌតាមសេចក្តីស្នើសុំពីអគ្គលេខាធិការរបស់ព្រឹទ្ធសភា។

-ប្រធានព្រឹទ្ធសភាចាត់ចែងការពិភាក្សា ហើយត្រូវចុះហត្ថលេខាលើកំណត់ហេតុក្នុងការប្រជុំនានារបស់ព្រឹទ្ធសភា។ ប្រធានព្រឹទ្ធសភាចុះហត្ថលេខា លើកំណត់ហេតុពិស្តារ នៅពេលចប់សម័យប្រជុំព្រឹទ្ធសភាមួយលើកៗដែលមានរយៈពេល៣ខែយ៉ាងតិច។

-ប្រធានព្រឹទ្ធសភា ជាអ្នកសម្រេចក្នុងការអនុញ្ញាតឲ្យផ្សព្វផ្សាយ ឬមិនអនុញ្ញាតឲ្យមានការផ្សព្វផ្សាយលើកំណត់ហេតុនៃការប្រជុំទាំងអស់ និងឯកសារដទៃទៀតរបស់ព្រឹទ្ធសភា កំណត់ហេតុ និងឯកសារផ្សេងៗ ត្រូវរក្សាទុកនៅក្នុងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។[456]

-ប្រធានព្រឹទ្ធសភា ជាអ្នកសម្រេចកិច្ចការទាំងឡាយរបស់ព្រឹទ្ធសភា សំដៅធានាដល់ការរៀបចំដំណើរការប្រព្រឹត្តទៅ ដោយផ្អែកលើច្បាប់គោលសំខាន់ៗពីរ គឺរដ្ឋធម្មនុញ្ញ និងការប្រតិបត្តិតាមបទបញ្ជាផ្ទៃក្នុងរបស់អង្គការព្រឹទ្ធសភា។

-ប្រធានព្រឹទ្ធសភា មានការៈរក្សាការពារមិនឲ្យមានកយន្តរាយខាងក្នុងក្តីមកពីខាងក្រៅក្តីដែលកើតមានឡើងដល់ព្រឹទ្ធសភា ដើម្បីធ្វើឲ្យសម្រេចកិច្ចការនេះប្រធានព្រឹទ្ធសភាអាចប្រើប្រាស់កម្លាំងនគរបាល ឬសុំអន្តរាគមន៍ពីកម្លាំងកងទ័ពបាន។[457]

-ប្រធានព្រឹទ្ធសភា មានសិទ្ធិបញ្ជាឲ្យបណ្តេញចេញភ្លាមៗបាន ក្នុងករណីដែលជនណាម្នាក់ ធ្វើឲ្យរំខានដល់ការពិភាក្សានៅពេលប្រជុំ ដើម្បីរក្សាការពារសណ្តាប់ធ្នាប់ក្នុងព្រឹទ្ធសភាឲ្យបានល្អ។ ជាគោលការណ៍ ប្រធានព្រឹទ្ធសភា អាចអនុញ្ញាតឲ្យសាធារណៈជនទូទៅឲ្យចូលទៅក្នុង

[454] ប្រការ១៨បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

[455] ប្រការ១៧បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

[456] ប្រការ២០បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

[457] ប្រការ៦០បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

សាលប្រជុំតាមចំនួនកន្លែងដែលមានកំណត់។[458]

-ប្រធានព្រឹទ្ធសភា ជាអ្នកអនុញ្ញាតច្បាប់ជូន ឬមិនអនុញ្ញាតច្បាប់ជូនសមាជិកព្រឹទ្ធសភា អាស្រ័យតាមកាលៈទេសៈ។

ជាធម្មតាប្រធានព្រឹទ្ធសភា ជាអ្នកអនុញ្ញាតច្បាប់ជូនសមាជិក។ សមាជិកាព្រឹទ្ធសភា ឈប់សម្រាកបានយ៉ាងយូរ១៥ថ្ងៃនៅក្នុងសម័យប្រជុំព្រឹទ្ធសភានីមួយៗ។[459]

-ប្រធានព្រឹទ្ធសភា ជាអ្នកគ្រប់គ្រងយន្តការនានា និងលើកស្ទួយការងាររបស់ព្រឹទ្ធសភា។

-ប្រធានព្រឹទ្ធសភា ត្រូវប្រកាសលទ្ធផលជូនអង្គប្រជុំក្រោយពីបោះឆ្នោតរួចស្រេចហើយ លេខាធិការត្រូវរាប់សន្លឹកឆ្នោតក្រោយពីបានរាប់សន្លឹកឆ្នោតរួចហើយ។

-ប្រធានព្រឹទ្ធសភា ត្រូវធ្វើទំនាក់ទំនងជាមួយប្រធានរដ្ឋសភា ដើម្បីរៀបចំ និងដំណើរការសមាជអង្គសភាទាំងមូល។

-ប្រធានព្រឹទ្ធសភា តំណាងឲ្យអង្គការព្រឹទ្ធសភាក្នុងការធ្វើទំនាក់ទំនងលើបញ្ហាផ្សេងៗជាមួយព្រះមហាក្សត្រ និងអាជ្ញាធរសាធារណៈ។[460]

-ប្រធានព្រឹទ្ធសភា ជាទូទៅបំពេញភារកិច្ចជាប្រមុខរដ្ឋ ជំនួសព្រះមហាក្សត្រក្នុងហានៈជាព្រះរាជានុសិទ្ធិ។[461]

-ប្រធានព្រឹទ្ធសភា ត្រូវបានបំពេញភារកិច្ចជាប្រមុខរដ្ឋស្តីទី ក្នុងហានៈជាព្រះរាជានុសិទ្ធិនៃព្រះរាជាណាចក្រកម្ពុជានៅពេលព្រះមហាក្សត្រចូលទិវង្គត។[462]

-ប្រធានព្រឹទ្ធសភា ជាអ្នកនាំសេចក្តីទៅថ្លែងជម្រាបព្រឹទ្ធសភា ហើយព្រឹទ្ធសភាសម្រេចថាយល់ព្រម ឬមិនយល់ព្រមទុកជាការប្រញាប់។ អ្នកស្នើសុំប្រកាសទុកជាការប្រញាប់ ត្រូវជូនហេតុផលជាលាយលក្ខណ៍អក្សរឲ្យបានច្បាស់លាស់។[463]

-ប្រធានព្រឹទ្ធសភា ជាប្រធានក្រុមប្រឹក្សារាជសម្បត្តិ ដែលមានតួនាទី ជាអ្នកធ្វើការជ្រើសរើសព្រះមហាក្សត្រថ្មី ក្នុងករណីព្រះមហាក្សត្រចូលនិវត្តន៍ ឬចូលទិវង្គត។[464]

---

[458] ប្រការ៦១បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

[459] ប្រការ៦៥បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

[460] ប្រការ៨បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

[461] មាត្រា១១ថ្មីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[462] មាត្រា១២ថ្មីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[463] ប្រការ៤៣បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

[464] មាត្រា១៣ថ្មីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

ឈ.តួនាទីអនុប្រធានព្រឹទ្ធសភា

(Roles of Senate Vice-President)

អនុប្រធានទាំងពីរអាចជួយធ្វើការប្រធានទៅតាមការបែងចែកភារកិច្ចពីប្រធានព្រឹទ្ធសភា។ ក្នុងករណី ដែលប្រធានព្រឹទ្ធសភាមានធុរៈ មិនអាចបំពេញមុខងារបានដោយហេតុមានជំងឺ ឬទៅបំពេញជាប្រមុខរដ្ឋស្តីទី ឬត្រូវបំពេញបេសកកម្មនៅបរទេស អនុប្រធានព្រឹទ្ធសភាមួយរូបត្រូវទទួលភារកិច្ចចាត់ចែងការងារជំនួសប្រធាន ក្នុងឋានៈជាប្រធានព្រឹទ្ធសភាស្តីទី តាមរយៈលិខិតផ្ទេរសិទ្ធ កាលបើប្រធានអវត្តមាន ឬមកធ្វើការងារពុំបាន អនុប្រធានធ្វើការជំនួសប្រធាន ក្នុងឋានៈជាប្រធានស្តីទីតាមរយៈលិខិតផ្ទេរសិទ្ធិ។[465]

ក្នុងករណី ដែលប្រធានព្រឹទ្ធសភាមានធុរៈ មិនអាចមកបំពេញមុខងារបាន ដោយហេតុមកពីមានជំងឺ ឬត្រូវបំពេញមុខងារជាប្រមុខរដ្ឋស្តីទី ឬជាព្រះរាជានុសិទ្ធិ ឬបំពេញបេសកកម្មនៅឯបរទេស អនុប្រធានព្រឹទ្ធសភាមួយរូប ត្រូវទទួលភារកិច្ចចាត់ចែងការងារជំនួស។

ក្នុងករណី ដែលប្រធាន ឬអនុប្រធានព្រឹទ្ធសភាលាលែងពីមុខតំណែង ឬទទួលមរណភាព ព្រឹទ្ធសភាត្រូវបោះឆ្នោតជ្រើសតាំងប្រធាន ឬអនុប្រធានជាថ្មីបាន។[466]

ញ.គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

(Senate Permanence Committee)

១-ការបង្កើតគណៈកម្មាធិការអចិន្ត្រៃយ៍

(Establishment of Permanence Committee)

ប្រធានព្រឹទ្ធសភា ជម្រាបជូនគណបក្សនយោបាយ ឬស្ថាប័នដែលពាក់ព័ន្ធ ដើម្បីដាក់បញ្ជីបេក្ខជនសមាជិកគណៈកម្មការនានារបស់ព្រឹទ្ធសភា។ សមាជិកព្រឹទ្ធសភាមួយរូប អាចឈរជាបេក្ខជនសមាជិកគណៈកម្មការ២បាន។[467]

ការបោះឆ្នោត ជ្រើសរើសសមាជិកគណៈកម្មការនានារបស់ព្រឹទ្ធសភា ត្រូវធ្វើដាច់ដោយឡែកពីគ្នា តាមវិធីបោះឆ្នោតជាសម្ងាត់ដោយអនុម័តតាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

ក្នុងករណីចាំបាច់ការបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មការនានា អាចធ្វើឡើងច្រើនគណៈកម្មការក្នុងពេលតែមួយបាន។ ប៉ុន្តែសន្លឹកឆ្នោត ត្រូវរៀបតាមបញ្ជីរាយនាម និងហិបឆ្នោត

---

[465] ប្រការ១២បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

[466] មាត្រា១១០ថ្មីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[467] ប្រការ៩ថ្មីបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

ត្រូវធ្វើឡើងដាច់ដោយឡែកពីគ្នា។

ការបោះឆ្នោត តាមបញ្ជីរាយនាមលើកទី១មិនបានសម្រេច ការបោះឆ្នោតលើកទី២តាមបញ្ជីរាយនាមបន្ត និងការបោះឆ្នោតលើកទី៣ គឺត្រូវធ្វើឡើងចំពោះតែបេក្ខជនដែលពុំទទួលបានសម្លេងគាំទ្រគ្រប់ចំនួនតែប៉ុណ្ណោះ។

ការបើបោះឆ្នោតលើកទី៣នេះនៅតែមិនបានសម្រេចទៀត នោះប្រធានព្រឹទ្ធសភាត្រូវតែជម្រាបជូនគណបក្សនយោបាយ និងស្ថាប័នដែលមានអាសនៈនៅក្នុងព្រឹទ្ធសភា ឲ្យធ្វើការផ្លាស់ប្តូរបេក្ខជន និងធ្វើការបោះឆ្នោតបន្តទៅទៀត។[468]

ក្រោមអធិបតីភាពនៃប្រធានព្រឹទ្ធសភា អាចចាប់ដំណើរការបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភា ដោយអនុម័តតាមមតិភាគច្រើនដាច់ខាត៥០បូក១នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។[469]

កូរ៉ុមសម្រាប់ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ត្រូវមានចំនួនលើសពីពាក់កណ្តាលនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល គ្រប់សេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍នានាត្រូវអនុម័តដោយសម្លេងភាគច្រើនដាច់ខាត៥០បូក១នៃចំនួនសមាជិកទាំងមូល។[470]

២-សមាសភាព

(Compositions)

ជាទូទៅ ព្រឹទ្ធសភាមានគណៈកម្មាធិការអចិន្ត្រៃយ៍មួយ ដែលមានសមាជិកចំនួន១៣រូប សមាសភាពគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភារួមមាន:[471]

-ប្រធានព្រឹទ្ធសភា	១រូប	ជាប្រធាន
-អនុប្រធានទី១ព្រឹទ្ធសភា	១រូប	ជាសមាជិក
-អនុប្រធានទី២ព្រឹទ្ធសភា	១រូប	ជាសមាជិក
-ប្រធានគណៈកម្មការជំនាញនានាទាំង១០	១០រូប	ជាសមាជិក

គណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភា និងគណៈកម្មការជំនាញនានាគឺមានអាណត្តិស្មើគ្នានឹងនីតិកាលរបស់ព្រឹទ្ធសភាដែរ។[472]

---

[468] ប្រការ១០បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

[469] ប្រការ៨បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

[470] ប្រការ៦បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

[471] ប្រការ១៣បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

[472] ប្រការ២១បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

៣-តួនាទី និងភារកិច្ច

(Roles and Duties)

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា មានតួនាទីភារកិច្ចសំខាន់ណាស់ក្នុងការធានានូវរាល់ដំណើរការប្រព្រឹត្តទៅរបស់ព្រឹទ្ធសភា។

តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភារួមមាន:

-គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ត្រូវទទួលការកិច្ច ចាត់ចែងការងាររបស់ព្រឹទ្ធសភានៅចន្លោះសម័យប្រជុំ។[473]

-កោះប្រជុំព្រឹទ្ធសភាជាវិសាមញ្ញប្រសិនបើមានសំណូមពរពីព្រះមហាក្សត្រ ឬមានសេចក្តីស្នើសុំពីនាយករដ្ឋមន្ត្រី ឬពីសមាជិកព្រឹទ្ធសភាចំនួនមួយភាគបីយ៉ាងតិច។[474]

-រាយការណ៍អំពីសកម្មភាពនានារបស់ព្រឹទ្ធសភា នូវរាល់គ្រប់ចន្លោះ សម័យប្រជុំព្រឹទ្ធសភានៅពេលបើកសម័យប្រជុំនីមួយៗ។

-កំណត់កាលបរិច្ឆេទ និងរបៀបវារៈនៃសម័យប្រជុំនីមួយៗរបស់ព្រឹទ្ធសភា។

-គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ជាអ្នករៀបចំរបៀបវារៈនៅក្នុងការកំណត់ពេលប្រជុំនីមួយៗ មុនផុតពេលប្រជុំនីមួយៗ ប្រធានត្រូវអានរបៀបវារៈសម្រាប់ពេលប្រជុំបន្តទៅទៀត។[475]

នៅក្នុងរបៀបវារៈនេះ ត្រូវមានសេចក្តីជាលំដាប់មុនក្រោយដូចតទៅនេះ៖

+បញ្ហាទាំងឡាយ ដែលព្រឹទ្ធសភា បានសម្រេចថាទុកជាការប្រញាប់

+បញ្ហាទាំងឡាយ ដែលរដ្ឋសភាជូនមកព្រឹទ្ធសភា

+បញ្ហាទាំងឡាយ ដែលរាជរដ្ឋាភិបាលជូនមកព្រឹទ្ធសភា

+បញ្ហាទាំងឡាយ ដែលគណៈកម្មការនានាជូនមកព្រឹទ្ធសភា

+បញ្ហាទាំងឡាយ ដែលសមាជិកព្រឹទ្ធសភាជូនមកព្រឹទ្ធសភា។

-គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ជាអ្នកពិនិត្យ និងសម្រេចរបាយការណ៍ទូទាត់ការចំណាយថវិការបស់ព្រឹទ្ធសភានៅរាល់ដំណាច់ឆ្នាំ ហើយត្រូវបញ្ជូនទៅក្រសួងមានសមត្ថកិច្ចដើម្បីរៀបចំបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋ។

-គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា គឺជាអ្នកកំណត់នូវសេចក្តីស្នើថវិការបស់ព្រឹទ្ធសភាដែលព្រឹទ្ធសភាត្រូវមានថវិកាស្វយ័តមួយ សម្រាប់ដំណើរការ ហើយត្រូវបញ្ជូនទៅក្រសួងមានសមត្ថ

[473] មាត្រា១០៨ថ្មីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[474] មាត្រា១០៧ថ្មីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[475] ប្រការ២១បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

កិច្ចដើម្បីបញ្ចូលក្នុងគម្រោងថវិកាជាតិ។[476]

-គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ជាអ្នកសម្រេច ដាក់ទណ្ឌកម្ម និងវិន័យលើសមាជិកព្រឹទ្ធសភាដោយស្វ័យប្រវត្តិកាលបើបានដឹងច្បាស់ថាមូលហេតុ ដែលសមាជិកព្រឹទ្ធសភាខកខានមិនបានមកប្រជុំនោះ ត្រូវទទួលវិន័យដូចមានចែងក្នុងប្រការ៧៧ ប្រការ៧៨ និងប្រការ៨០។[477]

-គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា មិនអាចដាក់វិន័យ ឬទណ្ឌកម្មបានទេ ប្រសិនបើព្រឹទ្ធសភាបានទទួលពាក្យតវ៉ាសមហេតុសមផលរបស់សាមីខ្លួនក្នុងខណៈពេលប្រជុំពេញអង្គ។

-គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ត្រូវរៀបចំរបបប្រាក់បំណាច់របបធា នាប៉ាប់រងសង្គមរបបបេសកកម្ម និងលក្ខខណ្ឌធ្វើការងារសមាជិកព្រឹទ្ធសភា។

-គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ជាអ្នកទទួលបន្ទុក រៀបចំពិធីបុណ្យសព និងផ្តល់ប្រាក់បំណាច់ ព្រមទាំងប្រាក់ឧបត្ថម្ភផ្សេងៗគ្រប់បែបយ៉ាង ដល់ក្រុម គ្រួសារសពរយៈពេលមួយឆ្នាំទៀតគិតពីថ្ងៃទទួលមរណភាព។[478]

-គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ជាអ្នកសម្រេច ដើម្បីឲ្យសមាជិកព្រឹទ្ធសភារូបណាមួយបានចូលនិវត្តន៍តាមការស្នើសុំពីសាមីខ្លួន។[479]

-គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ជាអ្នកលើកសំណើជូនអង្គប្រជុំ ដើម្បីធ្វើការពិនិត្យ និងសម្រេចលើសេចក្តីស្នើសុំ ការចោទប្រកាន់ ការចាប់ខ្លួន ការឃុំខ្លួនសមាជិកព្រឹទ្ធសភាណាមួយដើម្បីអនុម័តសម្រេច។[480]

-គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាជាអ្នកសម្រេចដាក់ប្រជុំ និងអនុម័តឲ្យស្របតាមរដ្ឋធម្មនុញ្ញ និងបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភាដើម្បីពិនិត្យ និងសម្រេចអំពីអភ័យឯកសិទ្ធិសភា។[481]

-ការពារផលប្រយោជន៍ និងអភ័យឯកសិទ្ធិសភា។

-ធានាក្នុងការផ្តល់គ្រឿងឥស្សរិយយស ជូនដល់សមាជិកព្រឹទ្ធសភា។

-គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាជាអ្នកបង្កើតគណៈកម្មការផ្សេងៗ ដើម្បីបម្រើការងារចាំបាច់ឲ្យអង្គការព្រឹទ្ធសភា។

---

[476] ប្រការ៣១បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

[477] ប្រការ៧២បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

[478] មាត្រា១៨ច្បាប់ស្តីពីលក្ខន្តិកៈសមាជិកព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

[479] មាត្រា១៩ច្បាប់ស្តីពីលក្ខន្តិកៈសមាជិកព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

[480] មាត្រា១១ច្បាប់ស្តីពីលក្ខន្តិកៈសមាជិកព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

[481] មាត្រា១០ច្បាប់ស្តីពីលក្ខន្តិកៈសមាជិកព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

-រៀបចំសមាសភាពលេខាធិការ២រូបសម្រាប់សម័យប្រជុំបន្តបន្ទាប់ ដើម្បីដាក់ជូនអង្គប្រជុំព្រឹទ្ធសភាអនុម័តសម្រេច។

-ធានាដល់ដំណើរការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

-ធានាដល់ការអនុវត្តវិន័យក្នុងព្រឹទ្ធសភា និងគោលការណ៍ក្រមសីលធម៌របស់សមាជិក។

-លើកជូនព្រឹទ្ធសភាដើម្បីធ្វើការពិនិត្យ និងសម្រេចទៅលើការផ្អាកការឃុំខ្លួន និងការចោទប្រកាន់ចំពោះសមាជិកព្រឹទ្ធសភាណាមួយ។

៨.គណៈកម្មការនានាព្រឹទ្ធសភា

(Commissions of Senate)

១-ការបង្កើតគណៈកម្មការ

(Establishment of Commission)

ធម្មតា ព្រឹទ្ធសភាត្រូវធ្វើការបោះឆ្នោតជ្រើសរើស ដាច់ដោយឡែកពីគ្នានូវសមាជិកគណៈកម្មការនានានៃព្រឹទ្ធសភាដោយមតិភាគច្រើនដាច់ខាត។[482]

ព្រឹទ្ធសភាអាចបង្កើតគណៈកម្មការផ្សេងៗទៀតដែលចាំបាច់ ដើម្បីរៀបចំ និងប្រព្រឹត្តទៅនៃអង្គការព្រឹទ្ធសភា តាមការកំណត់នៅក្នុងបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា ត្រូវអនុម័តយល់ព្រមដោយសម្លេងភាគច្រើនដាច់ខាត៥០បូក១នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។[483]

គណៈកម្មការជំនាញនីមួយៗរបស់ព្រឹទ្ធសភា គឺត្រូវកំណត់តួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួន ឲ្យស្របទៅនឹងរដ្ឋធម្មនុញ្ញ បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និងច្បាប់ជាធរមានរួចដាក់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ពិនិត្យ និងសម្រេច។[484]

គណៈកម្មការនីមួយៗត្រូវធ្វើការជ្រើសតាំង ប្រធាន១រូប អនុប្រធាន១រូប និងលេខាធិការ១រូប ដោយវិធីបោះឆ្នោតជាសម្ងាត់ គណៈកម្មការនីមួយៗមានសមាជិកយ៉ាងតិច៥រូប។[485]

នៅក្នុងគណៈកម្មការជំនាញនីមួយៗរបស់ព្រឹទ្ធសភាជារួមមាន:

- ប្រធានគណៈកម្មការ ១រូប
- អនុប្រធានគណៈកម្មការ ១រូប
- លេខាធិការ ១រូប

---

[482] មាត្រា១០៦ថ្មី(មួយ)រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[483] មាត្រា១១៤ថ្មី(មួយ)រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[484] ប្រការ១៧បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

[485] ប្រការ១៦បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

- សមាជិកសរុបនៃគណៈកម្មការនីមួយៗមានចំនួន៥រូប។

ការបោះឆ្នោត ជ្រើសរើសសមាជិកគណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា ត្រូវធ្វើដាច់ដោយឡែកពីគ្នាតាមវិធីបោះឆ្នោតជាសម្ងាត់តាមការអនុម័តសម្រេច ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។[486]

ក្នុងករណីចាំបាច់ព្រឹទ្ធសភា ក៏អាចអនុម័តដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ដើម្បីសម្រេចក្នុងការបង្កើតគណៈកម្មការពិសេសនានាបាន ដែលគណៈកម្មការមានសមាសភាពសមាជិកច្រើន ឬតិចទៅតាមតម្រូវការ។[487]

គណៈកម្មការនីមួយៗ អាចស្នើសុំប្រធានព្រឹទ្ធសភាឲ្យចាត់តាំងអ្នកជំនាញ ដែលមិនមែនជាសមាជិកព្រឹទ្ធសភា ដើម្បីឲ្យចូលរួមបំពេញការងារបាន។ ប៉ុន្តែអ្នកជំនាញនេះ គ្មានសិទ្ធិសម្រេចកិច្ចការរបស់គណៈកម្មការនានាទេ។[488]

ក្នុងករណី ប្រធានគណៈកម្មការអវត្តមាន ដោយមូលហេតុណាមួយ អនុប្រធាន ឬលេខាធិការគណៈកម្មការនោះ មានសិទ្ធិចូលរួមប្រជុំនៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ជំនួសបាន ប៉ុន្តែពុំមានសិទ្ធិសម្រេចការងារផ្សេងៗក្នុងនាមប្រធានបានឡើយ គណៈកម្មការត្រូវបំពេញការងារជំនួសប្រធានតាមរយៈលិខិតផ្ទេរសិទ្ធិ។[489]

ការបង្កើតគណៈកម្មការពិសេសនានា គឺស្ថិតក្នុងករណីដូចខាងក្រោម:

-ករណីបង្កើតគណៈកម្មការតាមការស្នើសុំរបស់ប្រធានព្រឹទ្ធសភា ដើម្បីបំពេញការងារចាំបាច់ណាមួយ។

-ករណីបង្កើតគណៈកម្មការ តាមការស្នើសុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ដើម្បីធ្វើការពិនិត្យ ឬសិក្សាទៅលើអត្ថបទច្បាប់ណាមួយ ឬការស្នើសុំធ្វើវិសោធនកម្មណាមួយ ដែលមានលក្ខណៈជាពិសេស។

-ករណីបង្កើតគណៈកម្មការណាមួយតាមសំណើរបស់ប្រធានគណៈកម្មការជំនាញ ដើម្បីដោះស្រាយបញ្ហាសំខាន់ចាំបាច់ ប៉ុន្តែការបង្កើតនេះ ត្រូវមានការឯកភាពពីព្រឹទ្ធសភាទាំងមូល ឬពីគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាជាមុនសិន។

-ករណីបង្កើតគណៈកម្មការ ដោយគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាបានប្រគល់អត្ថបទ

[486] ប្រការ១០បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

[487] ប្រការ១៩បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

[488] ប្រការ២៣បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

[489] ប្រការ១២ថ្មីបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

ច្បាប់ទៅគណៈកម្មការណាមួយ ដើម្បីធ្វើការពិនិត្យ និងសិក្សា ក៏ប៉ុន្តែគណៈកម្មការជំនាញនោះបានប្រកាសថា ខ្លួនពុំមានសមត្ថភាពក្នុងការពិនិត្យ ហើយក៏គ្មានគណៈកម្មការជំនាញណាផ្សេងទៀតអាចទទួលយកអត្ថបទច្បាប់នោះមកពិនិត្យបានដែរ។

ការបង្កើតគណៈកម្មការពិសេសនានា ជាទូទៅត្រូវគោរពទៅតាមគោលការណ៍សមាមាត្រ ដោយយកសម្លេងភាគច្រើនជាច់ខាត៥០បូក១ ហើយការរៀបចំសមាសភាពរបស់គណៈកម្មការពិសេសនេះ ត្រូវពិគ្រោះយោបល់នៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ហើយចាំបាច់ដាក់ឲ្យគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ឬព្រឹទ្ធសភាពេញអង្គជាអ្នកធ្វើការអនុម័ត និងសម្រេច។

២-គណៈកម្មការជំនាញនានា

(Expert Commissions)

នៅក្នុងអង្គការព្រឹទ្ធសភាសព្វថ្ងៃ បានបង្កើតគណៈកម្មការជំនាញនានា រហូតដល់ទៅ១០គណៈកម្មការដើម្បីបម្រើផលប្រយោជន៍ដល់អង្គការព្រឹទ្ធសភាទាំងមូលមានដូចខាងក្រោម:[490]

១-គណៈកម្មការការពារសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង និងងង្កេត។

២-គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម។

៣-គណៈកម្មការផែនការ វិនិយោគ កសិកម្ម ធនធានទឹក ឧតុនិយម អភិវឌ្ឍន៍ជនបទ និងបរិស្ថាន។

៤-គណៈកម្មការមហាផ្ទៃ ការពារជាតិ ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា អធិការកិច្ច និងមុខងារសាធារណៈ។

៥-គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន។

៦-គណៈកម្មការនីតិកម្ម និងយុត្តិធម៌។

៧-គណៈកម្មការអប់រំ យុវជន និងកីឡា ធម្មការ សាសនា វប្បធម៌ វិចិត្រសិល្បៈ និងទេសចរណ៍។

៨-គណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី។

៩-គណៈកម្មការសាធារណៈការដឹកជញ្ជូន អាកាសចរស៊ីវិល ប្រៃសណីយ៍ ទូរគមនាគមន៍ ឧស្សាហកម្ម រ៉ែ ឋាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

១០-គណៈកម្មការអង្កេតបោសសម្អាត និងប្រឆាំងអំពើពុករលួយ។

[490] ប្រការ១៥ថ្មីបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

៣-តួនាទីគណៈកម្មការ

(Roles of Commissions)

គណៈកម្មការនីមួយៗជាទូទៅមានតួនាទីដូចជា:

-គណៈកម្មការនីមួយៗ ត្រូវកំណត់តួនាទី សមត្ថកិច្ច និងភារកិច្ចរបស់ខ្លួនឲ្យសមស្របទៅនឹងរដ្ឋធម្មនុញ្ញ បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា និងច្បាប់ជាធរមានរបស់រដ្ឋរួចជាក់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាដើម្បីពិនិត្យ និងសម្រេច។[491]

-គណៈកម្មការនីមួយៗ អាចស្នើសុំប្រធានព្រឹទ្ធសភា ចាត់តាំងអ្នកជំនាញ ដែលមិនមែនជាសមាជិកព្រឹទ្ធសភាឲ្យចូលរួមធ្វើការបាន ក៏ប៉ុន្តែអ្នកជំនាញនោះគ្មានសិទ្ធិសម្រេចនៅក្នុងគណៈកម្មការនានានេះទេ។[492]

-គណៈកម្មការនានារបស់ព្រឹទ្ធសភាអាចកោះអញ្ជើញអ្នកតំណាង រាជរដ្ឋាភិបាលមកបំភ្លឺពាក់ព័ន្ធនឹងសេចក្តីព្រាងច្បាប់របស់រាជរដ្ឋាភិបាល។

-គណៈកម្មការនានារបស់ព្រឹទ្ធសភា អាចកោះអញ្ជើញរដ្ឋមន្ត្រីមកបំភ្លឺអំពីបញ្ហាអ្វីមួយបានដែលពាក់ព័ន្ធនឹងវិស័យទទួលខុសត្រូវរបស់ខ្លួន។[493]

-ការអញ្ជើញមកសាកសួរ គឺដើម្បីផ្តល់ព័ត៌មានផ្សេងៗ ពាក់ព័ន្ធទៅនឹងមុខងារ សមត្ថកិច្ចរបស់គណៈកម្មការជំនាញតែប៉ុណ្ណោះ គឺពុំមែនជាការសាកសួរ ឬសួរដេញដោល ដើម្បីប្រឆាំង ឬការគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាល ឬការដកតំណែងសមាជិកគណៈរដ្ឋមន្ត្រីណាម្នាក់ដូចអង្គការរដ្ឋសភានោះទេ។

-គណៈកម្មការតាមជំនាញនីមួយៗ ជាអ្នកទទួលសេចក្តីព្រាងច្បាប់អំពីគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ហើយត្រូវធ្វើការពិភាក្សា និងពិនិត្យឲ្យបានត្រឹមត្រូវ កាលបើពិនិត្យរួចហើយប្រធានគណៈកម្មការទាំងនោះត្រូវនាំយកយោបល់របស់គណៈកម្មការមកជម្រាបជូនព្រឹទ្ធសភា។[494]

-គណៈកម្មការនានា អាចអនុញ្ញាតឲ្យអ្នករៀបចំ និងតាក់តែងសេចក្តីស្នើច្បាប់ ចូលរាយការណ៍ជម្រាបជូនគណៈកម្មការជំនាញ ដែលពិនិត្យសេចក្តីស្នើច្បាប់នោះ។

-គណៈកម្មការជំនាញ មានសិទ្ធិសូមឲ្យព្រឹទ្ធសភា លើកចោលពុំពិចារណាបាននូវកិច្ចការទាំងឡាយដែលគណៈកម្មការបានលើកឡើង។

---

[491] ប្រការ១៧បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

[៤៩២] ប្រការ១២បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

[៤៩៣] មាត្រា៩៧រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[៤៩៤] ប្រការ២៣បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

-គណៈកម្មការជំនាញមានសិទ្ធិក្នុងការផ្តល់យោបល់ លើសេចក្តីស្នើច្បាប់ដែលគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាបានដាក់ឲ្យពិនិត្យ។[495]

-គណៈកម្មការជំនាញ មានសិទ្ធិសូមឲ្យព្រឹទ្ធសភាបញ្ចេញមតិជាមុនសិន ថាតើគួរទទួលយកមកពិចារណាឬទេ ?

-គណៈកម្មការជំនាញ មានសិទ្ធិសូមឲ្យព្រឹទ្ធសភា ទទួលពិចារណាហើយ នឹងទុកជាការប្រញាប់ផងក៏បានដែរ។

-គណៈកម្មការនីមួយៗត្រូវជ្រើសតាំងប្រធានមួយរូប អនុប្រធានមួយរូប និងលេខាធិការមួយរូបដោយវិធីបោះឆ្នោត។[496]

-ចាត់ចែងការងារគ្រប់គ្រង និងការងាររដ្ឋបាលទូទៅរបស់គណៈកម្មការ។

-លើកកម្មវិធីការងារ និងចាត់ចែងសកម្មភាពរបស់គណៈកម្មការ។

-កោះប្រជុំគណៈកម្មការ និងដឹកនាំកិច្ចប្រជុំទាំងនោះ។

-ចុះហត្ថលេខាលើកំណត់ហេតុប្រជុំរបស់គណៈកម្មការ។

-អញ្ជើញតំណាងក្រសួងពាក់ព័ន្ធ ឥស្សរជន អ្នកជំនាញការ ឬតំណាងសង្គមស៊ីវិលចូលរួមផ្តល់យោបល់លើបញ្ហាផ្សេងៗ។

-ធានាផ្តល់របាយការណ៍ការងារប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំប្រគល់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍។ ជាពិសេសនៅចន្លោះសម័យប្រជុំនីមួយៗ គណៈកម្មការតែងតែចុះទៅបំពេញមុខងារនៅតាមក្រសួង មន្ទីរ រាជធានី ខេត្តដើម្បីពិនិត្យមើលការអនុវត្តច្បាប់។

-ផ្តួចផ្តើមគំនិតរៀបចំសិក្ខាសាលា បេសកកម្មខាងក្នុង និងខាងក្រៅប្រទេសរបស់គណៈកម្មការ។ អនុប្រធាន និងលេខាធិការជួយដល់ប្រធានគណៈកម្មការ ក្នុងការសម្រេចភារកិច្ចខាងលើនេះ។ សមាជិកគណៈកម្មការផ្សេងៗទៀត បំពេញភារកិច្ចទៅតាមការបែងចែកជាក់ស្តែងក្នុងគណៈកម្មការ។[497]

៥.ឱសមិតភាពព្រឹទ្ធសភា

(Incompatibility of Senate)

អាណត្តិសមាជិកព្រឹទ្ធសភា មានវិសមិតភាពជាមួយនឹងការបំពេញមុខងារសាធារណៈជាសកម្មជាមួយមុខងារជាតំណាងរាស្ត្រ និងជាមួយមុខងារជាសមាជិកស្ថាប័នដ៏ទៃៗទៀត ដូចមាន

[495] ប្រការ២៤បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

[496] ប្រការ១០បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

[497] ប្រការ១៨បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

ចែងក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ និងច្បាប់ជាធរមាន។[498]

ជាទូទៅ បេក្ខជន ដែលត្រូវបានតែងតាំងជ្រើសតាំង និងជាប់ឆ្នោតជាសមាជិកព្រឹទ្ធសភា សមាជិកព្រឹទ្ធសភាទាំងនោះ មិនអាចទៅបំពេញការងារនៅក្នុងក្របខ័ណ្ឌជាមន្ត្រីសាធារណៈសកម្មបានទេ ដែលរួមមានដូចជា សមាជិករដ្ឋសភា មន្ត្រីរាជការស៊ីវិល មន្ត្រី នគរបាលជាតិ កងកម្លាំងអាវុធហត្ថ កងយោធពលខេមរភូមិន្ទ និងសមាជិកនៃអង្គការស្ថាប័នដទៃៗទៀត ក៏ប៉ុន្តែប្រសិនបើមន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងកម្លាំងនគរបាលជាតិ កងយោធពលខេមរភូមិន្ទ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងបុព្វជិតសាសនាដែលមានបំណងឈរឈ្មោះបោះឆ្នោតជ្រើសតាំងជាសមាជិកព្រឹទ្ធសភាត្រូវដាក់ពាក្យសុំច្បាប់ឈប់ជាពិសេស ត្រូវតែលាចាកសិក្ខាបទជាមុនសិនរហូតដល់ថ្ងៃប្រកាសលទ្ធផលនៃការបោះឆ្នោត ជាស្ថាពរយ៉ាងតិចប្រាំពីរ៧ថ្ងៃមុនពេលថ្ងៃបើកយុទ្ធនាការឃោសនាបោះឆ្នោត។

ប្រសិនបើសាមីខ្លួនជាប់ឆ្នោតសាមីខ្លួន ត្រូវធ្វើពាក្យសុំព្យួរតាមហានុក្រមទៅសាមីក្រសួងសាមីអង្គភាព ដើម្បីទៅបម្រើការងារ ក្រៅពីក្របខណ្ឌដើម ក្នុងរយៈពេលអាណត្តិរបស់ខ្លួន។ ក្នុងរយៈពេលស្ថិតនៅក្រៅក្របខណ្ឌដើមសាមីខ្លួនត្រូវមានសិទ្ធិឡើងឋានន្តរសក្តិ និងឡើងថ្នាក់ដោយស្វ័យប្រវត្តិ និងរក្សាអតីតភាពការងារសម្រាប់ទទួលប្រាក់សោធននិវត្តន៍។

នៅពេលចប់អាណត្តិ ជាសមាជិកព្រឹទ្ធសភាសាមីខ្លួនអាចសុំវិលត្រឡប់ ទៅបម្រើការនៅក្នុងក្រសួង ឬអង្គភាពដើមវិញ ក៏ប៉ុន្តែមុខងារ និងតួនាទីគឺអាស្រ័យដោយសាមីក្រសួង ឬសាមីអង្គភាពជាអ្នកសម្រេច។[499]

ឧ.អំពីអភ័យឯកសិទ្ធិព្រឹទ្ធសភា

(Immunity of Senate)

សមាជិកព្រឹទ្ធសភាមានអភ័យឯកសិទ្ធិសភាត្រូវបានចែកចេញជាពីរផ្នែកគឺ:

-ជានាដល់ការបញ្ចេញមតិ និងយោបល់ នៅក្នុងការអនុម័តច្បាប់ទាំងឡាយរបស់សមាជិកព្រឹទ្ធសភានៅក្នុងក្របខ័ណ្ឌនៃការបំពេញមុខងារ និងតួនាទីផ្សេងៗរបស់សមាជិកព្រឹទ្ធសភា គឺជាអភ័យឯកសិទ្ធិដាច់ខាតរបស់សមាជិកព្រឹទ្ធសភា។

-ជានាមិនឲ្យមានការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនរបស់សមាជិកព្រឹទ្ធសភារូបណាមួយ គឺជាអភ័យឯកសិទ្ធិដោយប្រៀបរបស់សមាជិកព្រឹទ្ធសភា។[500]

---

[498] មាត្រា១០៣ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[499] មាត្រា៣៥ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិករដ្ឋសភា និងច្បាប់ស្តីពីការជ្រើសរើសសមាជិកព្រឹទ្ធសភា។

[500] មាត្រា៤នៃច្បាប់ស្តីពីលក្ខន្តិកៈសមាជិកព្រឹទ្ធសភា។

សមាជិកព្រឹទ្ធសភា ដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ នឹងអាចបើក ឲ្យមានការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួន ស្របតាមផ្លូវច្បាប់ និងនីតិវិធីបាន លុះត្រាតែមានការលើកអភ័យឯកសិទ្ធិសភារបស់សមាជិកព្រឹទ្ធសភារូបនោះជាមុនសិន។

សេចក្តីស្នើសុំ ដើម្បីលើកអភ័យឯកសិទ្ធិសភារបស់សមាជិកព្រឹទ្ធសភារូប ណាមួយត្រូវធ្វើឡើង ដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ តាមរយៈរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដោយមានភ្ជាប់មកជាមួយនូវសេចក្តីថ្លែងហេតុដើម្បីផ្ញើជូនមកប្រធានព្រឹទ្ធសភា។[501]

ការលើកអភ័យឯកសិទ្ធិសភាសមាជិកព្រឹទ្ធសភា ត្រូវធ្វើឡើង នៅក្នុងសម័យចន្លោះប្រជុំព្រឹទ្ធសភា ដែលគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ត្រូវធ្វើការពិនិត្យ និងពិចារណា ដោយផ្អែកទៅលើបទល្មើស និងកស្តុតាងឬសេចក្តីថ្លែងហេតុរបស់អគ្គព្រះរាជអាជ្ញានៅអមសាលាឧទ្ធរណ៍។ ហើយត្រូវធ្វើការប្រជុំ និងអនុម័តសម្រេចឲ្យសមស្របទៅ នឹងបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា សេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ត្រូវដាក់ក្នុងសម័យចន្លោះប្រជុំពេញអង្គរបស់ព្រឹទ្ធសភា ដើម្បីដកអភ័យឯកសិទ្ធិសភាពីសមាជិកព្រឹទ្ធសភារូបណាមួយ ដោយមតិភាគច្រើន២ភាគ៣(២៣)នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។[502]

ការលើកអភ័យឯកសិទ្ធិសភារបស់សមាជិកព្រឹទ្ធសភា នៅក្នុងសម័យប្រជុំត្រូវអនុវត្តន៍ទៅតាមនីតិវិធីដូចតទៅ:

-ព្រឹទ្ធសភា អាចកោះប្រជុំជាសម្ងាត់ដោយមានការស្នើសុំពីប្រធានព្រឹទ្ធសភាឬពីសមាជិកព្រឹទ្ធសភា(ដែលមានចំនួនមួយភាគដប់យ៉ាងតិច) ឬពីព្រះមហាក្សត្រ ឬពីនាយករដ្ឋមន្ត្រី ឬពីប្រធានរដ្ឋសភា។

-កូរ៉ុមនៃការប្រជុំ គឺត្រូវមានចំនួនសមាជិកព្រឹទ្ធសភាលើសពីពីរភាគបី(២ភាគ៣)នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

-ការអនុម័ត ដោយយកសម្លេងភាគច្រើនពីរភាគបី(២ភាគ៣)នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។[503]

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនសមាជិកព្រឹទ្ធសភាណាមួយនឹងអាចធ្វើទៅបាន លុះត្រាតែមានការយល់ព្រមអំពីព្រឹទ្ធសភា ឬពីគណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភា វៀរលែងតែក្នុងករណីដែលសមាជិកព្រឹទ្ធសភារូបនោះបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ

[501] មាត្រា៨នៃច្បាប់ស្តីពីលក្ខន្តិក:សមាជិកព្រឹទ្ធសភា។

[502] មាត្រា១១នៃច្បាប់ស្តីពីលក្ខន្តិក:សមាជិកព្រឹទ្ធសភា។

[503] មាត្រា៩នៃច្បាប់ស្តីពីលក្ខន្តិក:សមាជិកព្រឹទ្ធសភា។

ជាក់ស្តែងតែប៉ុណ្ណោះ។

ក្នុងករណីនេះ ក្រសួងមានសមត្ថកិច្ចត្រូវធ្វើសេចក្តីរាយការណ៍ជូនព្រឹទ្ធសភា ឬជូនគណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភាជាបន្ទាន់ដើម្បីធ្វើការសម្រេច។

សេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា គឺត្រូវដាក់ចូលទៅសម័យប្រជុំព្រឹទ្ធសភានាពេលខាងមុខដើម្បីធ្វើការអនុម័តសម្រេច ដោយយកមតិភាគច្រើនពីរភាគបី(២/៣) នៃសមាជិកព្រឹទ្ធសភាទាំងមូល។[504]

ក្នុងករណីនេះ រាល់ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន និងការឃុំខ្លួននឹងត្រូវផ្អាក ប្រសិនបើព្រឹទ្ធសភាបានបញ្ចេញមតិឲ្យផ្អាក តាមការអនុម័ត ដោយមតិភាគច្រើនបីភាគបួន៣/៤ នៃសមាជិកព្រឹទ្ធសភាទាំងមូល។[505]

សមាជិកព្រឹទ្ធសភា ដែលត្រូវបានលើកលែងអភ័យឯកសិទ្ធិសភាហើយ ស្ថិតក្នុងការចោទប្រកាន់របស់តុលាការក៏ដោយ ក៏សមាជិកព្រឹទ្ធសភារូបនោះនៅតែមានសិទ្ធិ និងបុព្វសិទ្ធិដូចគ្នាទៅនឹងសមាជិកព្រឹទ្ធសភាទូទៅដែរ។

សមាជិកព្រឹទ្ធសភា ដែលស្ថិតនៅក្នុងការចាប់ខ្លួន ឬការឃាត់ខ្លួន ឬការឃុំខ្លួនជាបណ្តោះអាសន្ន សមាជិកព្រឹទ្ធសភារូបនោះ គឺត្រូវបាត់បង់សិទ្ធិក្នុងការចូលរួមប្រជុំពេញអង្គព្រឹទ្ធសភា និងគណៈកម្មការផ្សេងៗ ប៉ុន្តែសមាជិកព្រឹទ្ធសភារូបនោះ នៅមានសិទ្ធិទទួលបានប្រាក់បំណាច់ វៀរលែងតែប្រាក់បំណាច់នៃការប្រជុំ ប្រាក់បំណាច់បេសកកម្ម និងប្រាក់ប្រែងឥន្ធនៈជាដើម។

សមាជិកព្រឹទ្ធសភា ដែលមានសាលក្រមជាស្ថាពរ ឬសាលដីកាស្ថាពរ និងសម្រេចថា ជាទណ្ឌិត ជាប់ពន្ធនាគារហើយនោះ ត្រូវបាត់បង់ទាំងស្រុងនូវសិទ្ធិ និងបុព្វសិទ្ធិជាសមាជិកភាពនៃសមាជិកព្រឹទ្ធសភា។[506]

សមាជិកព្រឹទ្ធសភាណាមួយជាទណ្ឌិត ហើយត្រូវបាន ព្រះមហាក្សត្រ លើកលែងទោសសមាជិកព្រឹទ្ធសភារូបនោះ នឹងទទួលបានសុពលភាពអំពីអភ័យឯកសិទ្ធិសភា និងបុព្វសិទ្ធិផ្សេងទៀតជាធម្មតាឡើងវិញ។[507]

សមាជិកព្រឹទ្ធសភារូបណាមួយដែលមានសាលក្រមជាស្ថាពរ ឬសាលដីកាជាស្ថាពរដែលបានសម្រេចថា ជាជនគ្មានទោសសមាជិកព្រឹទ្ធសភារូបនោះនឹងត្រូវទទួលបានជាស្វ័យប្រវត្តិនូវ

[504] មាត្រា១០៨រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[505] មាត្រា១៣នៃច្បាប់ស្តីពីលក្ខន្តិកៈសមាជិកព្រឹទ្ធសភា។

[506] មាត្រា១៤នៃច្បាប់ស្តីពីលក្ខន្តិកៈសមាជិកព្រឹទ្ធសភា។

[507] មាត្រា១៥នៃច្បាប់ស្តីពីលក្ខន្តិកៈសមាជិកព្រឹទ្ធសភា។

អភ័យឯកសិទ្ធិសភា និងបុព្វសិទ្ធិពេញលេញឡើងវិញ។[508]

ឆ.អំពីឋានៈ និងបុព្វសិទ្ធិសមាជិកព្រឹទ្ធសភា

(Rank and Prerogative of Senators)

ជាទូទៅសមាជិកព្រឹទ្ធសភាមានឋានៈ និងបុព្វសិទ្ធិគឺស្មើនឹងឧត្តមមន្ត្រីផុតលេខនៃព្រះរាជាណាចក្រកម្ពុជា។

ព្រឹទ្ធសភា ត្រូវមានថវិកាស្វយ័តសម្រាប់ដំណើរការរបស់ខ្លួន។

ការបំពេញភារកិច្ចក្នុងអាណត្តិសមាជិកព្រឹទ្ធសភាត្រូវទទួលបាននូវៈ

-សមាជិកព្រឹទ្ធសភាត្រូវទទួលបាននូវប្រាក់បំណាច់។[509]

-សមាជិកព្រឹទ្ធសភាគ្រប់រូប ត្រូវទទួលបាននូវការធានារ៉ាប់រងសង្គម

-ប្រាក់បំណាច់តាមការកំណត់របស់គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

-ក្នុងករណី ដែលសមាជិកព្រឹទ្ធសភា បានទទួលមរណភាពនៅក្នុងអាណត្តិ គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ត្រូវទទួលបន្ទុករៀបចំពិធីបុណ្យសព និងត្រូវផ្តល់ប្រាក់បំណាច់ព្រមទាំងប្រាក់ឧបត្ថម្ភផ្សេងៗ គ្រប់បែបយ៉ាងដល់ក្រុមគ្រួសារសពរយៈពេល១ឆ្នាំទៀត គឺគិតចាប់គិតពីថ្ងៃដែលទទួលមរណភាព។

-គណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភា ត្រូវរៀបចំរបបប្រាក់បំណាច់របបធានារ៉ាប់រងសង្គម របបឧបត្ថម្ភផ្សេងៗ របបប្រាក់សោធននិវត្តន៍ របបបេសកកម្ម ព្រមទាំងលក្ខខណ្ឌនៅក្នុងការបំពេញការងារទាំងឡាយរបស់សមាជិកព្រឹទ្ធសភា។[510]

-ប្រាក់សោធននិវត្តន៍ របស់សមាជិកព្រឹទ្ធសភា ត្រូវបើកនៅអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ហើយប្រាក់សោធននិវត្តន៍ត្រូវបើកបានតែមួយកន្លែងគត់។

-គណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភា ជាអ្នកសម្រេច ដើម្បីឲ្យសមាជិកព្រឹទ្ធសភាបានចូលនិវត្តន៍តាមការស្នើសុំរបស់សាមីខ្លួន។[511]

សមាជិកព្រឹទ្ធសភាទាំងឡាយ ដែលអាចទទួលបាននូវប្រាក់សោធននិវត្តន៍ គឺត្រូវបំពេញលក្ខខណ្ឌមួយចំនួនដូចជា៖[512]

---

[508] មាត្រា១៦នៃច្បាប់ស្តីពីលក្ខន្តិកៈសមាជិកព្រឹទ្ធសភា។

[509] មាត្រា១០៥រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[510] មាត្រា១៨នៃច្បាប់ស្តីពីលក្ខន្តិកៈសមាជិកព្រឹទ្ធសភា។

[511] មាត្រា១៩នៃច្បាប់ស្តីពីលក្ខន្តិកៈសមាជិកព្រឹទ្ធសភា។

[512] មាត្រា២០នៃច្បាប់ស្តីពីលក្ខន្តិកៈសមាជិកព្រឹទ្ធសភា។

-ជាអតីតសមាជិកព្រឹទ្ធសភា ជាអតីតសមាជិករដ្ឋសភាគឺគិតចាប់ពីឆ្នាំ១៩៩៣មក ដែលបានមកបំពេញការងារជាសមាជិកព្រឹទ្ធសភា ឬជាអតីតសមាជិករបស់ក្រុមប្រឹក្សាធម្មនុញ្ញ គឺគិតចាប់តាំងពីឆ្នាំ១៩៩៨មក ហើយដែលបានមកបំពេញជាសមាជិកព្រឹទ្ធសភា។

-ជាអតីតសមាជិកព្រឹទ្ធសភាដែលមានអាយុចាប់ពី៦០ឆ្នាំឡើងទៅ។

-ជាអ្នកដែលមិនបានទទួលប្រាក់សោធននិវត្តន៍ពីស្ថាប័នរដ្ឋណាមួយទេ។

-ជាអតីតសមាជិកព្រឹទ្ធសភា ហើយដែលមិនត្រូវបានជាប់ឆ្នោតឡើងវិញក្រោយពីមានអាយុគ្រប់ចំនួន៦០ឆ្នាំ ត្រូវទទួលបាននូវប្រាក់សោធននិវត្តន៍បានដោយអាចបើកប្រាក់ផ្តាច់បានត្រឹមរយៈពេលមួយឆ្នាំគត់។

-សមាជិកព្រឹទ្ធសភា ត្រូវតែទទួលបានជំនួយការផ្ទាល់មួយចំនួន តាមការសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា។

-សមាជិកព្រឹទ្ធសភា ត្រូវតែទទួលបាននូវការជួយជ្រោមជ្រែង និងដោះស្រាយបញ្ហានានា ព្រមទាំងការជួយសម្រួលគ្រប់បែបយ៉ាងអំពីអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាតាមបែបបទ ដូចមានការកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន។[513]

-សមាជិកព្រឹទ្ធសភា ត្រូវទទួលបាននូវឯកសណ្ឋានជាផ្លូវការ និងប្រពៃណី

-សមាជិកព្រឹទ្ធសភា ត្រូវទទួលបាននូវប័ណ្ណសំគាល់សមាជិកសម្រាប់ពាក់ ជាប់ខ្លួន

-សមាជិកព្រឹទ្ធសភា ត្រូវទទួលបាននូវប័ណ្ណសំគាល់អភ័យឯកសិទ្ធិ

-សមាជិកព្រឹទ្ធសភាត្រូវទទួលបាននូវគ្រឿងឥស្សរិយយសពីរដងក្នុងអាណត្តិនីមួយៗ ហើយត្រូវទទួលបានគ្រប់អាណត្តិ។

-សមាជិកព្រឹទ្ធសភាត្រូវទទួលបាននូវលិខិតឆ្លងដែនផ្នែកការទូតផ្ទាល់ខ្លួន សហព័ទ្ធ និងកូនដែលមានអាយុក្រោម១៨ឆ្នាំ។

-សមាជិកព្រឹទ្ធសភា ត្រូវទទួលបាននូវរូបសញ្ញាសំគាល់ជាសមាជិកព្រឹទ្ធសភាសម្រាប់ពាក់ជាប់ខ្លួន និងសមាជិកព្រឹទ្ធសភាត្រូវទទួលបាននូវរូបសញ្ញាបារមីរបស់ព្រឹទ្ធសភា

-សមាជិកព្រឹទ្ធសភាត្រូវទទួលបាននូវផ្លាកសំគាល់យានយន្តព្រឹទ្ធសភា

-សមាជិកព្រឹទ្ធសភា ត្រូវទទួលបាននូវការធានារ៉ាប់រងជំងឺនៅក្នុងមន្ទីរពេទ្យរដ្ឋនានា នៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលចេញដោយថវិការបស់ព្រឹទ្ធសភា។[514]

---

[513] មាត្រា២៣នៃច្បាប់ស្តីពីលក្ខន្តិក:សមាជិកព្រឹទ្ធសភា។

[514] មាត្រា២៤នៃច្បាប់ស្តីពីលក្ខន្តិក:សមាជិកព្រឹទ្ធសភា។

ន.ការគ្រប់គ្រងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

(Management of Secretary General of Senate)

១-សញ្ញាណទូទៅ

(Notions)

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជាសេនាធិការបម្រើការងារ និងសេវារដ្ឋបាលនានាឲ្យអង្គការព្រឹទ្ធសភានៅព្រះរាជាណាចក្រកម្ពុជាយើង។

មន្ត្រីបុគ្គលិក ដែលបានបំពេញការងារ នៅអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាជា មន្ត្រីជាប់កិច្ចសន្យា នៅពេលចប់នីតិកាលរបស់ព្រឹទ្ធសភាមន្ត្រីទាំងនោះក៏ត្រូវបញ្ចប់ការងាររបស់ខ្លួនដែរ ហើយអាចវិលត្រឡប់ទៅបំពេញការងារនៅកន្លែងដើមវិញ។

នៅព្រះរាជាណាចក្រកម្ពុជា ចាប់តាំងពីឆ្នាំ១៩៩៩មក មន្ត្រីទាំងអស់ ដែលបានបម្រើការនៅអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាមានមន្ត្រីអចិន្ត្រៃយ៍ មានមន្ត្រីជាប់កិច្ចសន្យាឬបុគ្គលិកអណ្តែត។

រហូតមកដល់ខែមករា ឆ្នាំ២០០៣ រដ្ឋសភាជាតិនៃព្រះរាជាណាចក្រកម្ពុជា បានអនុម័តច្បាប់មួយ ស្តីពីលក្ខន្តិក:មន្ត្រីរាជការនៃក្រុមនីតិបញ្ញត្តិ ដោយច្បាប់នេះ ត្រូវបានយកមកអនុវត្តន៍ចំពោះមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។[515]

ហេតុនេះ មន្ត្រីទាំងអស់របស់អគ្គលេខាធិការដ្ឋាន ត្រូវតែអនុវត្តន៍តាមច្បាប់ស្តីពីលក្ខន្តិក:មន្ត្រីរាជការនៃក្រុមនីតិបញ្ញត្តិនេះទាំងអស់គ្នា។

អ្នករាជការក្រុមនីតិប្បញ្ញត្តិ ត្រូវគោរពគោលការណ៍អព្យាក្រិត្យ មិនប្រកាន់ចំពោះនិន្នាការគណបក្សនយោបាយនៅក្នុងការបំពេញការងាររបស់ខ្លួន។[516]

២-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

(Secretary General of Senate)

អង្គការព្រឹទ្ធសភា មានអគ្គលេខាធិការដ្ឋានមួយដែលទទួលបន្ទុករៀបចំចាត់ចែងកិច្ចការរដ្ឋបាលធ្វើកំណត់ហេតុផ្សេងៗរបស់ព្រឹទ្ធសភា និងរបស់គណៈកម្មការនានា។

អគ្គលេខាធិការដ្ឋាន ត្រូវទទួលរ៉ាប់រងផងដែរ នូវគ្រប់កិច្ចការរដ្ឋបាល និងសេវានានាជូនព្រឹទ្ធសភា និងគណៈកម្មការទាំងអស់របស់ព្រឹទ្ធសភាព្រមទាំងធ្វើការទំនាក់ទំនងលើ បញ្ហាការងារផ្សេងៗជាមួយបណ្តាអង្គការរដ្ឋនានា ក្រៅអំពីអង្គការព្រឹទ្ធសភា។[517]

---

[515] មាត្រា១ច្បាប់ស្តីពីលក្ខន្តិក:មន្ត្រីនៃក្រុមនីតិប្បញ្ញត្តិ។

[516] មាត្រា២ច្បាប់ស្តីពីលក្ខន្តិក:មន្ត្រីនៃក្រុមនីតិប្បញ្ញត្តិ។

[517] ប្រការ២៧បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

អគ្គលេខាធិការដ្ឋានត្រូវបានដឹកនាំដោយអគ្គលេខាធិការមួយរូប និងអមដោយអគ្គលេខាធិការរងមួយរូប។ អគ្គលេខាធិការ និងអគ្គលេខាធិការរង គឺត្រូវបានតែងតាំង ដោយព្រះរាជក្រឹត្យ តាមសេចក្តីស្នើសុំពីប្រធានព្រឹទ្ធសភា ក្រោយពីបានពិគ្រោះយោបល់ជាមួយអនុប្រធានទី១ និងទី២ព្រឹទ្ធសភា ដែលអគ្គលេខាធិការព្រឹទ្ធសភា គឺមានឋានៈស្មើនឹងរដ្ឋលេខាធិការ រីឯអគ្គលេខាធិការរងមានឋានៈស្មើនឹងអនុរដ្ឋលេខាធិការ។[518]

អគ្គលេខាធិការ និងអគ្គលេខាធិការរងត្រូវធ្វើការជ្រើសតាំងនៅក្នុងចំណោមមន្ត្រីជាន់ខ្ពស់ ដែលមានបទពិសោធន៍ក្នុងកិច្ចការរដ្ឋបាលយ៉ាងតិចដប់ឆ្នាំដែលមិនមែន ជាសមាជិកព្រឹទ្ធសភា មិនមែនជាអ្នកដឹកនាំក្នុងគណបក្សនយោបាយណាមួយ។[519]

៣-ការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

(Processing of Secretary General of Senate)

ដើម្បីឲ្យអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អាចបំពេញសកម្មភាពការងារនានា ប្រកបដោយប្រសិទ្ធភាពខ្ពស់ ដែលជាសេនាធិការបម្រើការងារ និងសេវារដ្ឋបាលឲ្យអង្គការព្រឹទ្ធសភានោះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ត្រូវមានរចនាសម្ព័ន្ធគ្រប់គ្រង និងបែងចែកភារកិច្ចនានាឲ្យបានច្បាស់លាស់ការរៀបចំចាត់ចែងការងារទាំងនេះត្រូវដឹកនាំដោយអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងមានការឯកភាពពីថ្នាក់ដឹកនាំព្រឹទ្ធសភា ដែលប្រធានព្រឹទ្ធសភា ជាអ្នកចេញសេចក្តីសម្រេចស្តីអំពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាននេះទាំងមូល។

អគ្គលេខាធិការដ្ឋាន ត្រូវកសាងរចនាសម្ព័ន្ធមួយ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងលក្ខន្តិកៈនៃមន្ត្រីបុគ្គលិក អគ្គលេខាធិការដ្ឋាន ដើម្បីដាក់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍អនុម័ត និងសម្រេចព្រមទាំងយកទៅអនុវត្តន៍។

៤-តួនាទី និងភារកិច្ចអគ្គលេខាធិការ

(Roles and duties of Secretary General)

អគ្គលេខាធិការព្រឹទ្ធសភាមានតួនាទី និងភារកិច្ចដូចតទៅ:

-អគ្គលេខាធិការព្រឹទ្ធសភា ជាអ្នកស្នើទៅប្រធានព្រឹទ្ធសភា ដើម្បីឲ្យចេញសេចក្តីសម្រេចបង្កើតគណៈកម្មការនានារបស់ព្រឹទ្ធសភា ដោយយោងលើការចាំបាច់ ដែលមានសមាសភាពតិចឬច្រើនអាស្រ័យទៅតាមទំហំការងារ។ គណៈកម្មការ ដែលបានបង្កើតនេះ នឹងរលាយបាត់ទៅវិញនៅពេលដែលគណៈកម្មការបានបំពេញការងារចប់ជាស្ថាពរ។

---

[518] ប្រការ២៩បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

[519] ប្រការ២៨បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

-អគ្គលេខាធិការព្រឹទ្ធសភា ជាអ្នករៀបចំ គ្រប់គ្រងការងាររដ្ឋបាល និងសេវាកម្មនានាជូនព្រឹទ្ធសភា និងគណៈកម្មការនានាទាំងអស់ដើម្បីឲ្យការងារដំណើរការ និងប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាពខ្ពស់។

-អគ្គលេខាធិការព្រឹទ្ធសភាជាអ្នករៀបចំធ្វើកំណត់ហេតុនានាគ្រប់ការប្រជុំ របស់ព្រឹទ្ធសភា និងរបស់គណៈកម្មការនានាព្រឹទ្ធសភា។

-អគ្គលេខាធិការព្រឹទ្ធសភា ជាអ្នកស្នើសុំតែងតាំងមន្ត្រីរាជការបម្រើការងារនៅក្នុងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដែលត្រូវបានចេញសេចក្តីសម្រេច ដោយប្រធានព្រឹទ្ធសភាស្របតាមច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិបញ្ញត្តិ។

-អគ្គលេខាធិការព្រឹទ្ធសភា ជាអ្នកធ្វើគម្រោងសម្រង់បញ្ជីឈ្មោះមន្ត្រីបុគ្គលិករបស់ខ្លួននៅតាមការិយាល័យនានា ដែលមានស្នាដៃ និងគុណបំណាច់ខ្ពស់ ក្នុងការបំពេញ ការកិច្ចជូនអង្គការព្រឹទ្ធសភា ដើម្បីឲ្យគណៈកម្មការវាយតម្លៃរួចហើយទើបស្នើសុំប្រធានព្រឹទ្ធសភាធ្វើការបំពាក់គ្រឿងឥស្សរិយយសជូនដល់មន្ត្រីរាជការដែលមានស្នាដៃល្អ.[520]

-អគ្គលេខាធិការព្រឹទ្ធសភា ជាអ្នកគ្រប់គ្រង និងថែរក្សាទ្រព្យសម្បត្តិរបស់ព្រឹទ្ធសភា។

-អគ្គលេខាធិការព្រឹទ្ធសភា ជាអ្នករៀបចំសណ្តាប់ធ្នាប់ សន្តិសុខ អនាម័យនៅក្នុងបរិវេណស្ថាប័នព្រឹទ្ធសភាទាំងមូល។

-អគ្គលេខាធិការព្រឹទ្ធសភា ជាអ្នកគ្រប់គ្រងបញ្ជាផ្ទាល់ ទៅលើគ្រប់ចំណាយផ្សេងៗ របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដោយមានការរួមសហការជាមួយនឹងអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុព្រឹទ្ធសភា។

-អគ្គលេខាធិការព្រឹទ្ធសភាជាអ្នករៀបចំផ្តល់កំណត់ហេតុ ឬសេវាផ្នែកនីតិវិធីតាមផ្លូវច្បាប់តាមជំនាញ និងតាមបច្ចេកទេសជូនសមាជិកព្រឹទ្ធសភា គណៈកម្មាធិការអចិន្ត្រៃយ៍ គណៈកម្មការនានារបស់ព្រឹទ្ធសភា។

-អគ្គលេខាធិការព្រឹទ្ធសភាជាអ្នករៀបចំ និងរក្សាកំណត់ហេតុរួមទាំងឯកសារផ្សេងៗរបស់ស្ថាប័នព្រឹទ្ធសភា ហើយជានាមិនឲ្យបែកខ្ចរខ្ចាយទៅខាងក្រៅ ដោយគ្មានការអនុញ្ញាតពីប្រធានព្រឹទ្ធសភាឡើយ។

[520] មាត្រា៣៩ច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ។

រចនាសម្ព័ន្ធព្រឹទ្ធសភា

ប្រធានព្រឹទ្ធសភា១រូប
អនុប្រធានទី១ព្រឹទ្ធសភា១រូប
អនុប្រធានទី២ព្រឹទ្ធសភា១រូប
សមាជិកព្រឹទ្ធសភាចំនួនអស់៥៨រូប
អគ្គលេខាធិការ១រូប និងអគ្គលេខាធិការរង១រូប

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាមាន១៣រូប
ប្រធានព្រឹទ្ធសភា១រូបជាប្រធានគណៈកម្មាធិការ
អនុប្រធានទី១ព្រឹទ្ធសភា១រូបជាសមាជិកគណៈកម្មាធិការ
អនុប្រធានទី២ព្រឹទ្ធសភា១រូបជាសមាជិកគណៈកម្មាធិការ
ប្រធានគណៈកម្មការនានាចំនួន១០រូបជាសមាជិកគណៈកម្មាធិការ

គណៈកម្មការជំនាញនីមួយៗរបស់ព្រឹទ្ធសភា
សមាជិកព្រឹទ្ធសភា១រូបជាប្រធានគណៈកម្មការ
សមាជិកព្រឹទ្ធសភា១រូបជាអនុប្រធានគណៈកម្មការ
សមាជិកព្រឹទ្ធសភា១រូបជាលេខាធិការគណៈកម្មការ
សមាជិកព្រឹទ្ធសភាចំនួន៥រូបយ៉ាងតិចជាសមាជិកគណៈកម្មការ

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គលេខាធិការព្រឹទ្ធសភា១រូប(មិនមែនជាសមាជិកព្រឹទ្ធសភា)
អគ្គលេខាធិការរងព្រឹទ្ធសភា១រូប(មិនមែនជាសមាជិកព្រឹទ្ធសភា)
អាណត្តិទី៤នៃព្រឹទ្ធសភាមានអគ្គលេខាធិការ១រូប និងអគ្គលេខាធិការរង១រូប

ផ្នែកទី៥

ក្រុមប្រឹក្សាធម្មនុញ្ញ

(Constitutional Council)

ក្រុមប្រឹក្សាធម្មនុញ្ញ ជាស្ថាប័នឯករាជ្យ និងអព្យាក្រិត្យ ក្នុងការបំពេញសមត្ថកិច្ចរបស់ខ្លួន ការបង្កើតស្ថាប័នមានគោលដៅ ដើម្បីកំណត់ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងការធានាការការពារ ការគោរពរដ្ឋធម្មនុញ្ញ ការបកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ ព្រមទាំងការពិនិត្យធម្មនុញ្ញភាពនៃច្បាប់ការដោះស្រាយវិវាទទាក់ទងនឹងការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសរើសសមាជិកព្រឹទ្ធសភា។

ក.ប្រវត្តិក្រុមប្រឹក្សាធម្មនុញ្ញ

(History of Constitutional Council)

នៅប្រទេសកម្ពុជាយើង ក្នុងសម័យសង្គមរាស្ត្រនិយមពុំទាន់មានបង្កើតប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាពទេដែលរដ្ឋធម្មនុញ្ញនៅថ្ងៃទី០៦ ខែឧសភា ឆ្នាំ១៩៤៧ បានលើកឡើងនៅក្នុងមាត្រា ១១៩ ស្តីអំពីសិទ្ធិបកស្រាយរដ្ឋធម្មនុញ្ញ ក៏ប៉ុន្តែមិនបាននិយាយអំពីការត្រួតពិនិត្យធម្មនុញ្ញភាពទេ សិទ្ធិបកស្រាយច្បាប់ចុងក្រោយគឺជាសិទ្ធិរបស់អង្គការនីតិប្បញ្ញត្តិរដ្ឋសភា។

រដ្ឋធម្មនុញ្ញ សម័យសាធារណរដ្ឋខ្មែរ នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧០ គឺបង្កើតឲ្យមានប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ និងបកស្រាយច្បាប់ ដែលមានឈ្មោះថាជា “តុលាការធម្មនុញ្ញ”។ ទោះបីជាមានឈ្មោះជាតុលាការធម្មនុញ្ញ ក៏ដោយ ក៏តុលាការធម្មនុញ្ញនេះ ស្ថិតនៅដោយឡែកពីអង្គការតុលាការផ្នែកយុត្តាធិការដែរ ការបង្កើតតុលាការធម្មនុញ្ញនេះ ពិតជាបានទទួលឥទ្ធិពលពីបស្ចឹមប្រទេសយ៉ាងពិតប្រាកដ។

មកដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បាននាំមកនូវរបបប្រល័យពូជ សាសន៍ ការកាប់សម្លាប់ប្រជាពលរដ្ឋ និងការបំផ្លិចបំផ្លាញរចនាសម្ព័ន្ធគ្រប់បែប យ៉ាងទាំងអស់ ព្រមទាំងជាន់ឈ្លីក្បួនច្បាប់ទាំងឡាយ គ្មានសេសសល់ រហូតដល់ ដំណាច់ឆ្នាំ១៩៧៨។

ក្រោយថ្ងៃរំដោះ **៧មករា** ឆ្នាំ១៩៧៩ **ទន្ទឹមនឹងការកសាងប្រទេសជាតិឡើងវិញ** លើគ្រប់វិស័យ ការស្តារប្រព័ន្ធច្បាប់ ពិតជាមានការលំបាកខ្លាំងណាស់។ **រដ្ឋធម្មនុញ្ញ សាធារណរដ្ឋប្រជាមានិតកម្ពុជា ឆ្នាំ១៩៨១ បានអនុញ្ញាតឲ្យមានការបកស្រាយច្បាប់ ដោយ**ក្រុមប្រឹក្សារដ្ឋ ដែលជាអង្គការអចិន្ត្រៃយ៍របស់រដ្ឋសភា។

ចាប់ពីឆ្នាំ១៩៨៩ដល់ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៣ រដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជាបានចែងអំពី

ការបកស្រាយច្បាប់ដោយគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាដែល។

រដ្ឋធម្មនុញ្ញថ្មី ដែលត្រូវបាននុម័ត នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ ដោយសភាធម្មនុញ្ញ ដែលកើតចេញពីការបោះឆ្នោតជាសកលទូទាំងប្រទេស ដែលបានរៀបចំឡើងដោយអង្គការសហប្រជាជាតិ នៅឆ្នាំ១៩៩៣ ត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។ ហើយរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣នេះ ក៏បានបង្កើតឲ្យមានស្ថាប័នកំពូលៗមួយចំនួនឡើង ដែលក្នុងនោះក៏បានបង្កើតឲ្យមានស្ថាប័ន“ក្រុមប្រឹក្សាធម្មនុញ្ញ”នេះដែរ។

ខ.ការរៀបចំក្រុមប្រឹក្សាធម្មនុញ្ញ

(Organizing Constitutional Council)

១-ការបង្កើតស្ថាប័ន

(Establishment of Institution)

ស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា គឺជាស្ថាប័នកំពូលមួយដែលជាស្ថាប័នឯករាជ្យ និងអព្យាក្រឹត្យមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ច្បាប់រៀបចំអង្គការមួយ នឹងកំណត់ពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។[521]

ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខជស/រកម/០៤៩៨/០៦ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ១៩៩៨។

ក្រុមប្រឹក្សាធម្មនុញ្ញ បានចាប់ផ្តើមដំណើរការក្នុងការបំពេញសកម្មភាពរបស់ខ្លួនជាផ្លូវការចាប់ពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៨ នៅក្នុងអាគារ “ស” ស្ថិតក្នុងបរិវេណនៃវិមានរដ្ឋចំការមន។ ដែលក្រុមប្រឹក្សាធម្មនុញ្ញ មានសមត្ថកិច្ច ជានាការការពារ ការគោរពរដ្ឋធម្មនុញ្ញ ការបកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ ព្រមទាំងមានសិទ្ធិពិនិត្យ និងសម្រេចលើករណីវិវាទកម្មដែលទាក់ទងទៅនឹងការបោះឆ្នោតជ្រើសតាំងសមាជិករដ្ឋសភា និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។[522]

ក្រុមប្រឹក្សាធម្មនុញ្ញ ថ្វាយមតិព្រះមហាក្សត្រ ចំពោះសេចក្តីស្នើទាំងឡាយ ដែលសុំធ្វើការសើរើ និងធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ។ ការសើរើ និងវិសោធនកម្មរដ្ឋធម្មនុញ្ញ ត្រូវបានហាមឃាត់ក្នុងកាលៈទេសៈ ដែលប្រទេសជាតិ ស្ថិតក្នុងភាពអាសន្ន ឬកាលបើប៉ះពាល់ដល់ប្រព័ន្ធប្រជាធិបតេយ្យសេរីពហុបក្សរបបរាជានិយម អាស្រ័យរដ្ឋធម្មនុញ្ញ ប្រការដែលព្រះមហាក្សត្រទ្រង់គ្រងរាជ

[521] មាត្រា១៤៤រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[522] មាត្រា១ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅក្រុមប្រឹក្សាធម្មនុញ្ញ។

សម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចនេះគឺមិនអាចសុំកែប្រែបានជាដាច់ខាត។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញគឺជាសេចក្តីសម្រេចស្ថាពរបិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តន៍ទៅលើអំណាចទាំងអស់ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ហើយត្រូវចុះផ្សាយក្នុងរាជកិច្ច។[523]

ការបង្កើតស្ថាប័ននេះឡើង គឺដើម្បីរួមចំណែកក្នុងការពង្រឹងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ការគោរពសិទ្ធិមនុស្ស ការកសាងនីតិរដ្ឋ និងការអនុវត្តន៍យុទ្ធសាស្ត្រគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

២-ការចូលកាន់តំណែង

(Taking Position)

មុនចូលកាន់តំណែង សមាជិកក្រុមប្រឹក្សាធម្មនុញ្ញត្រូវធ្វើសច្ចាប្រណិធានជាមុនសិន ដូចដែលមានចែងក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ដែលមិនបានធ្វើសច្ចាប្រណិធាន ដោយគ្មានមូលហេតុត្រឹមត្រូវក្នុងរយៈពេល៧ថ្ងៃក្រោយពីថ្ងៃ ដែលបានចេញព្រះរាជក្រឹត្យតែងតាំងចុងក្រោយ អាចនឹងត្រូវទទួលវិន័យ ដោយការដកចេញពីមុខតំណែងជាស្វ័យប្រវត្តិ ចំពោះសមាជិកក្រុមប្រឹក្សាធម្មនុញ្ញណាដែលត្រូវបានតុលាការកាត់ទោសដាក់ពន្ធនាគារពីបទមជ្ឈឹមឬបទឧក្រិដ្ឋ និងចំពោះសមាជិកក្រុមប្រឹក្សាធម្មនុញ្ញណា ដែលបានបំពេញការងារនៅក្នុងមុខតំណែងណាមួយ និងមុខរបរផ្សេងៗនៅក្នុងអាណត្តិរបស់ខ្លួន។

អ្នកដែលត្រូវបានតែងតាំងជាសមាជិកនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាទូទៅមុនចូលកាន់តំណែងត្រូវសុំលាឈប់ជាបណ្តោះអាសន្នពីមុខតំណែងនានា ឬមុខរបរផ្សេងៗទាំងអស់ដែលប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅសមាជិក ដែលស្ថិតនៅក្នុងមុខតំណែងនិងមុខរបរខាងលើឲ្យសុំលាឈប់ពីមុខតំណែង ឬមុខរបរនោះជាបន្ទាន់។ ប្រសិនបើសមាជិកក្រុមប្រឹក្សាធម្មនុញ្ញណាមួយ ដែលត្រូវសុំដកខ្លួនចេញពីបញ្ហា ដែលពាក់ព័ន្ធដល់ផលប្រយោជន៍ផ្ទាល់ខ្លួនមិនបានស្នើសុំដកខ្លួនចេញពីក្នុងរឿងនោះ។

ការសុំដកខ្លួន ឬការតម្រូវឲ្យដកខ្លួនត្រូវសម្រេច ដោយក្រុមប្រឹក្សាធម្មនុញ្ញ តាមមតិភាគច្រើនដាច់ខាត៥០បូក១នៃសមាជិកក្រុមប្រឹក្សាទាំងមូល។[524]

---

[523] មាត្រា២៣ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅក្រុមប្រឹក្សាធម្មនុញ្ញ។

[524] ប្រការ១បទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

ការកោះប្រជុំលើកទី១ របស់ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវតែធ្វើឡើងក្នុងរយៈពេល៧ថ្ងៃយ៉ាងយូរបន្ទាប់ពីចេញព្រះរាជក្រឹត្យតែងតាំងសមាជិករួចមក។[525]

ការកោះប្រជុំ និងការដឹកនាំអង្គប្រជុំលើកទី១របស់ក្រុមប្រឹក្សាធម្មនុញ្ញជាទូទៅត្រូវធ្វើឡើងតាមរយៈសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ដែលមានអាយុច្រើនជាងគេ ហើយបានធ្វើការសច្ចាប្រណិធានរួចមកហើយដែលមានវត្តមាន ដើម្បីធ្វើការជ្រើសតាំងប្រធានរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។[526]

គ.សមាសភាព និងអាណត្តិក្រុមប្រឹក្សាធម្មនុញ្ញ

(Compositions and Mandate of Constitutional Council)

សមាសភាពរបស់ក្រុមប្រឹក្សាធម្មនុញ្ញ រួមមាន សមាជិកទាំងអស់ចំនួន៩រូប ដែលត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ។ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មានអាណត្តិ៩ឆ្នាំសមាជិកទាំងនេះមានសមាសភាពមកពី:

- ព្រះមហាក្សត្រតែងតាំងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញចំនួន៣រូប
- ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជ្រើសតាំងសមាជិកចំនួន៣រូប
- រដ្ឋសភា ធ្វើការបោះឆ្នោតជ្រើសតាំង សមាជិកក្រុមប្រឹក្សាធម្មនុញ្ញចំនួន៣រូប ដោយមតិភាគច្រើនដាច់ខាត(៥០បូក១)នៃសមាជិករដ្ឋសភាទាំងមូល។[527]

ជាទូទៅសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ គឺត្រូវបានផ្លាស់ប្តូរចំនួនមួយភាគបីជារៀងរាល់រយៈពេលបីឆ្នាំម្តង មានន័យថា ត្រូវតែធ្វើការផ្លាស់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញចេញចំនួន៣រូប ហើយត្រូវធ្វើការតែងតាំង និងជ្រើសតាំងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញចំនួន៣រូបថ្មីចូលវិញដែរ។[528]

ដូចនេះ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញត្រូវបានតែងតាំងដោយព្រះមហាក្សត្រ១រូបត្រូវបានជ្រើសតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម១រូប និងត្រូវបានជ្រើសតាំងដោយរដ្ឋសភា១រូប។

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ដែលត្រូវបានតែងតាំង និងបោះឆ្នោតជ្រើសតាំង គឺសម្រាប់អាណត្តិរយៈពេល៩ឆ្នាំគឺមានចំនួន៣រូប។

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបានតែងតាំង និងជ្រើសតាំងសម្រាប់អាណត្តិរយៈពេល៦ឆ្នាំគឺមានចំនួន៣រូប និង៣រូបទៀត ត្រូវបានតែងតាំង និងជ្រើសតាំងសម្រាប់អាណត្តិរយៈពេល

---

[525] មាត្រា៣៩ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

[526] ប្រការ២បទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

[527] ការបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងករណីលើកទី១មិនបានសម្រេច ត្រូវបោះឆ្នោតជាលើកទី២តាមការអនុម័តដោយសម្លេងភាគច្រើនដោយប្រៀប។

[528] មាត្រា១៣៧រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

៣ឆ្នាំ។[529]

ការបោះឆ្នោតជ្រើសតាំង ដោយរដ្ឋសភាអាចធ្វើឡើងជាពីរលើកបានបើការបោះឆ្នោតលើកទី១មិនបានទទួលមតិភាគច្រើនដាច់ខាតទេនោះ ត្រូវបោះឆ្នោតជាលើកទី២ ដោយយកអ្នកដែលបានទទួលសម្លេងច្រើនជាងគេ ចំនួនយ៉ាងច្រើន៥រូប មកបោះឆ្នោតឡើងវិញ ការបោះឆ្នោតលើកទី២នេះ ត្រូវតែយកតាមមតិភាគច្រើនដោយប្រៀប។

នៅអាណត្តិទី១ការបោះឆ្នោតជ្រើសរើស ដោយរដ្ឋសភាចំពោះសមាជិកក្រុមប្រឹក្សាធម្មនុញ្ញដែលមានសមាជិកចំនួន៣រូបត្រូវបានតែងតាំង និងជ្រើសតាំង អ្នកដែលទទួលបានសម្លេងច្រើនជាងគេត្រូវបានតែងតាំងសម្រាប់អាណត្តិ៩ឆ្នាំ។ អ្នកដែលទទួលបានសម្លេងបន្ទាប់ ត្រូវបានតែងតាំងសម្រាប់អាណត្តិ៦ឆ្នាំ និងអ្នកដែលទទួលបានសម្លេងបន្តបន្ទាប់មកទៀត ត្រូវបានតែងតាំងសម្រាប់អាណត្តិរយៈពេល៣ឆ្នាំ។[530]

ក្នុងអាណត្តិបន្តបន្ទាប់ បើការបោះឆ្នោតលើកទី១ មិនបានទទួលមតិភាគ ច្រើនដាច់ខាតទេនោះត្រូវបោះឆ្នោតជាលើកទី២ ដោយយកអ្នកដែលទទួលសម្លេងច្រើនជាងគេចំនួន២នាក់មកបោះឆ្នោតឡើងវិញ។ ការបោះឆ្នោតលើកទី២នេះគឺត្រូវយកមតិភាគច្រើនដោយប្រៀប។

ក្នុងករណី ដែលបេក្ខជនទទួលបានសម្លេងស្មើគ្នា នោះត្រូវធ្វើការជ្រើសរើសយកអ្នកដែលមានអាយុច្រើនជាងគេ។

បេក្ខជនម្នាក់ៗដែលនឹងត្រូវជ្រើសតាំង ដោយរដ្ឋសភាត្រូវមានហត្ថលេខាគាំទ្រជាមុនសិនពីសមាជិករដ្ឋសភាមានចំនួនមួយភាគដប់(១/១០)នៃសមាជិករដ្ឋសភាទាំងមូល ហើយសមាជិករដ្ឋសភា១រូបៗមានសិទ្ធិគាំទ្របានតែបេក្ខជន១រូបតែប៉ុណ្ណោះ។[531]

ឃ.ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

(President of the Constitutional Council)

១-ការជ្រើសរើសប្រធាន

(Selection of the President)

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញត្រូវបានជ្រើសតាំងតាមរយៈការបោះឆ្នោតជ្រើសរើស ពីសមាជិកក្រុមប្រឹក្សាធម្មនុញ្ញទាំងអស់ ជារៀងរាល់៣ឆ្នាំម្តង តាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកក្រុមប្រឹក្សាទាំងមូល។

---

[529] មាត្រា៣៨ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

[530] មាត្រា៣ថ្មីច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

[531] មាត្រា៣ថ្មីច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបានជ្រើសតាំងឡើងដោយសមាជិកនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រធានមានសម្លេងឧត្តមានុភាពក្នុងករណីបែកសម្លេងជាពីរស្មើគ្នា។[532]

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញចាស់ អាចត្រូវបានជ្រើសតាំងសាជាថ្មីបាន។ ដែលប្រធានក្រុមប្រឹក្សាធម្មនុញ្ញត្រូវតែងតាំងដោយព្រះរាជក្រឹត្យ។

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញមានឋានៈ និងបុព្វសិទ្ធិស្មើនឹងប្រធានរដ្ឋសភា។[533]

២-តួនាទី និងភារកិច្ចប្រធាន

(The Roles and Duties of President)

ជាទូទៅប្រធានក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ច និងតួនាទីដូចខាងក្រោម:

-ប្រធានក្រុមប្រឹក្សាធម្មនុញ្ញជាអាណាប័កដើមខ្សែ។

-ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ជាអ្នករៀបចំគម្រោងរបៀបវារៈនៃអង្គប្រជុំ ក្នុងករណី ដែលប្រធានក្រុមប្រឹក្សា មានធុរៈចាំបាច់មិនអាចធ្វើទៅបាន សមាជិកក្រុមប្រឹក្សា ដែលមានអាយុច្រើនជាងគេ ដែលមានវត្តមានត្រូវរៀបចំរបៀបវារៈ។[534]

-ជានក្រុមប្រឹក្សាធម្មនុញ្ញ ជាអ្នកកោះអញ្ជើញប្រជុំនូវគ្រប់កិច្ចប្រជុំនានា របស់ក្រុមប្រឹក្សាធម្មនុញ្ញ។[535]

-ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ជាអធិបតីភាពនៅក្នុងការជ្រើសរើសសមាជិកក្រុម ដែលក្រុមនីមួយៗមានសមាជិកចំនួន៣រូប ដើម្បីស្រាវជ្រាវស៊ើបអង្កេតអំពីវិវាទកម្មទាក់ទងទៅនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ១រូបជាសមាជិកតែងតាំងដោយព្រះមហាក្សត្រ ១រូបជាសមាជិកជ្រើសតាំងដោយរដ្ឋសភា និង១រូបទៀត គឺជាសមាជិកតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដោយវិធីចាប់ឆ្នោត។[536]

-ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវប្រគល់សិទ្ធិទៅឲ្យក្រុមណាមួយទទួលខុសត្រូវ ដើម្បីធ្វើការស៊ើបអង្កេតជាបន្ទាន់ក្រោយពីបានទទួលពាក្យបណ្តឹង។[537]

-ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ជាអ្នកតែងតាំងសមាជិករាយការណ៍ ដែលទទួលបន្ទុកត្រួត

---

[532] មាត្រា១៣៧រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[533] មាត្រា៤ថ្មីច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

[534] ប្រការ១០បទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

[535] ប្រការ១២បទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

[536] មាត្រា៣០ថ្មីច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

[537] មាត្រា៣១ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

ពិនិត្យធម្មនុញ្ញភាពនៃអត្ថបទច្បាប់ ដែលបានដាក់ជូនក្រុមប្រឹក្សា។[538]

-ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ជាអ្នកគ្រប់គ្រង និងចាត់ចែងទៅលើអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ។[539]

-ប្រធានក្រុមប្រឹក្សាធម្មនុញ្ញជាអ្នកទទួលខុសត្រូវចំពោះការបំពេញសកម្មភាពការងារនានារបស់អគ្គលេខាធិការ និងអគ្គលេខាធិការរងផងដែរ។[540]

-ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ជាអ្នកលើកសំណើថ្វាយព្រះមហាក្សត្រ ក្នុងការតែងតាំងអគ្គលេខាធិការ និងអគ្គលេខាធិការរង។[541]

-ប្រធានក្រុមប្រឹក្សាធម្មនុញ្ញជាអ្នកជ្រើសរើសមន្ត្រីបុគ្គលិកឲ្យចូលបម្រើការងារ និងតែងតាំងមន្ត្រីបុគ្គលិកអគ្គលេខាធិការដ្ឋានតាមសំណើរបស់អគ្គលេខាធិការ។[542]

-ធានក្រុមប្រឹក្សាធម្មនុញ្ញ ជាអ្នកតែងតាំងគណនេយ្យករឲ្យទទួលបន្ទុកក្នុងការអនុវត្ត និងការចេញអាណត្តិឲ្យបើកប្រាក់បៀវត្សរ៍ ឬប្រាក់ឧបត្ថម្ភផ្សេងៗ។[543]

-ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ជាអ្នកប្រគល់ត្រា ឲ្យទៅសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីប្រើប្រាស់ត្រាក្នុងការប្រតិបត្តិការងារទាំងឡាយបាន ដោយសមាជិកក្រុមប្រឹក្សាធម្មនុញ្ញដែលបានបំពេញសកម្មភាពការងារ គឺគ្រាន់តែរាយការណ៍ទៅប្រធានក្រុមប្រឹក្សាធម្មនុញ្ញជូនព័ត៌មានជាការស្រេច។[544]

-ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ជាអ្នកលើកពេលប្រជុំបើប្រធានក្រុមប្រឹក្សាយល់ឃើញថាជាការមានប្រយោជន៍ ឬជាការចាំបាច់។

-ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ជាអ្នកអនុញ្ញាតឲ្យសមាជិកក្រុមប្រឹក្សាណាម្នាក់ដើម្បីឡើងរាយការណ៍ ទើបសមាជិកក្រុមប្រឹក្សាអាចនិយាយបានតាមលំដាប់មុនក្រោយ ដែលបានកត់ត្រាដោយគណៈលេខាធិការ ហើយសមាជិកម្នាក់ៗអាចនិយាយបាន១៥នាទីយ៉ាងច្រើន ក្នុងពេលអន្តរាគមន៍ម្តងៗ ហាមមិនឲ្យនិយាយកាត់ពាក្យអ្នកដទៃ ហាមមិនឲ្យនិយាយវាយប្រហារទៅលើបុគ្គល និង

---

[538] មាត្រា២២ថ្មីច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

[539] មាត្រា១អនុក្រឹត្យចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ១៩៩៨ស្តីពីក្រុមប្រឹក្សាធម្មនុញ្ញ។

[540] មាត្រា២អនុក្រឹត្យចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ១៩៩៨ស្តីពីក្រុមប្រឹក្សាធម្មនុញ្ញ។

[541] មាត្រា៣អនុក្រឹត្យចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ១៩៩៨ស្តីពីក្រុមប្រឹក្សាធម្មនុញ្ញ។

[542] មាត្រា៤អនុក្រឹត្យចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ១៩៩៨ស្តីពីក្រុមប្រឹក្សាធម្មនុញ្ញ។

[543] មាត្រា៥អនុក្រឹត្យចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ១៩៩៨ស្តីពីក្រុមប្រឹក្សាធម្មនុញ្ញ។

[544] ប្រការ៥បទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

ហាមមិនឲ្យសម្តែងអាការៈផ្សេងៗ ដែលនាំឲ្យខូចសណ្តាប់ធ្នាប់។

-ប្រធានក្រុមប្រឹក្សាជាអ្នកលើកពេលប្រជុំ ដោយការដើរចេញពីសាលប្រជុំ ប្រសិនបើមានការជ្រែលច្របល់ក្នុងពេលប្រជុំហើយប្រធានហាមមិនស្តាប់នោះ។[545]

-ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ជាអ្នកប្រកាសលទ្ធផលជូនអង្គប្រជុំស្តាប់ក្រោយពីអគ្គលេខាធិការបានរាយការណ៍អំពីលទ្ធផលនៃការប្រជុំអនុម័តនានារួចមក។[546]

-ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ជាអ្នកអនុញ្ញាតច្បាប់ឲ្យឈប់សម្រាកដល់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ជាទូទៅសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មិនអាចអវត្តមានដោយគ្មានការអនុញ្ញាតពីប្រធានបានឡើយ។

-ប្រធានក្រុមប្រឹក្សា មានសិទ្ធិអនុញ្ញាតឲ្យសមាជិកក្រុមប្រឹក្សាធម្មនុញ្ញបាន ឈប់សម្រាកយ៉ាងយូរ១៥ថ្ងៃ។ ការឈប់សម្រាកលើសរយៈពេលពី១៥ថ្ងៃត្រូវសុំឲ្យអង្គប្រជុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ និងសម្រេចយល់ព្រមជាមុនសិន ក្នុងករណី សមាជិកក្រុមប្រឹក្សាណាម្នាក់ មានជំងឺរយៈពេល៥ថ្ងៃជាប់ៗគ្នាត្រូវមានសំបុត្រពេទ្យជាសំអាង។[547]

-ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវក្រើនរំឭកទៅដល់សមាជិកក្រុមប្រឹក្សា ដែលបានធ្វើខុសដងដែលៗក្នុងរយៈពេល៣០ថ្ងៃ ឬសមាជិកក្រុមប្រឹក្សាធម្មនុញ្ញដែលបានធ្វើឲ្យខូចដល់សណ្តាប់ធ្នាប់ដោយបានប្រព្រឹត្តល្មើសទៅច្បាប់ដែលបានហាមឃាត់។[548]

-ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ជាអ្នកជូនដំណឹងទៅដល់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ដែលត្រូវដកចេញពីតំណែង ហើយសមាជិកនោះមានពេល១៤ថ្ងៃចាប់ពីថ្ងៃ ដែលបានទទួលលិខិតជូនដំណឹងដើម្បីធ្វើសារណាការពារខ្លួន។[549]

-ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ មានភារកិច្ចថែរក្សាការពារ មិនឲ្យមានភយន្តរាយខាងក្នុងក្តីខាងក្រៅក្តី ដែលកើតមានឡើងដល់ក្រុមប្រឹក្សាធម្មនុញ្ញ។ ដើម្បីសម្រេចបានកិច្ចការនេះ ប្រធានក្រុមប្រឹក្សាធម្មនុញ្ញអាចប្រើប្រាស់កម្លាំងនគរបាលឬអាចប្រើប្រាស់កម្លាំងកងទ័ពដើម្បីអន្តរាគមន៍បាន។[550]

---

[545] ប្រការ១៥បទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

[546] ប្រការ១៧បទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

[547] ប្រការ២១បទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

[548] ប្រការ២៣បទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

[549] ប្រការ២៧ស្ងួនបទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

[550] ប្រការ២៨បទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

-ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ជាអ្នកអនុញ្ញាតឲ្យធ្វើការផ្សព្វផ្សាយជាសាធារណៈ នូវរបាយការណ៍ និងឯកសារដទៃទៀតរបស់ក្រុមប្រឹក្សាធម្មនុញ្ញបាន។[551]

-ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ជាអ្នកចុះហត្ថខាលើបទបញ្ជាផ្ទៃក្នុង ដែលត្រូវបានអនុម័តដោយមតិយល់ព្រម ភាគច្រើន២ភាគ៣នៃសមាជិកក្រុមប្រឹក្សាធម្មនុញ្ញទាំងមូល ដែលមានចំនួន ៦សម្លេងយ៉ាងតិច ហើយត្រូវបានដាក់ឲ្យអនុវត្តន៍ចាប់ពីថ្ងៃចុះហត្ថលេខា។[552]

-ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ជាអ្នកបញ្ជូនគ្រប់សំណើទាំងអស់ ទៅឲ្យក្រុមណាមួយនៃក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីធ្វើការត្រួតពិនិត្យក្រោយពេលដែលបានចុះបញ្ជីរួចហើយ។[553]

ខ.លក្ខណៈសម្បត្តិសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ

(The Quality of Members Constitutional Council)

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មានចំនួន៩រូបដែលត្រូវបានតែងតាំង និងជ្រើសតាំងពីក្នុងចំណោមឥស្សរជនខ្មែរនានា ដែលមានជនជាតិជាជនជាតិខ្មែរ និងសញ្ជាតិជាសញ្ជាតិខ្មែរ ហើយមានអាយុយ៉ាងតិច៤៥ឆ្នាំ និងមានបទពិសោធន៍នៅក្នុងការងារយ៉ាងតិច១៥ឆ្នាំ។

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញត្រូវមានសញ្ញាប័ត្រចាប់ពីថ្នាក់ឧត្តមសិក្សាឡើងទៅខាងវិស័យច្បាប់ រដ្ឋបាល ការទូត និងខាងសេដ្ឋកិច្ច។[554]

ក្រុមប្រឹក្សាធម្មនុញ្ញ ជាស្ថាប័នឯករាជ្យ និងអព្យាក្រឹត្យក្នុងការបំពេញសមត្ថកិច្ចរបស់ខ្លួន សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មិនត្រូវប្រព្រឹត្តនូវអំពើ ដែលនាំឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរ ឯករាជ្យភាព អព្យាក្រឹត្យភាពនៃមុខតំណែងរបស់ខ្លួនឡើយ។[555]

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញក្នុងមុខតំណែងរបស់ខ្លួនមិនត្រូវ:

-កាន់កាប់នៅក្នុងគណបក្សណាមួយ នូវមុខតំណែងទទួលខុសត្រូវ ឬជាអ្នកដឹកនាំ ហើយជាទូទៅការបំពេញនូវសកម្មភាពទាំងឡាយត្រូវតែស្របទៅនឹងច្បាប់ ឬបទប្បញ្ញត្តិ ដែលមិនអាចធ្វើឲ្យផ្ទុយគ្នាជាមួយបទប្បញ្ញត្តិនៃប្រការខាងលើ។

-បណ្តោយឲ្យធ្វើនិទ្ទេសអំពីតួនាទីរបស់ខ្លួនជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញនៅក្នុងឯកសារ

---

[551] មាត្រា៦អនុក្រឹត្យចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ១៩៩៨ស្តីពីក្រុមប្រឹក្សាធម្មនុញ្ញ។

[552] មាត្រា៣២ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

[553] ប្រការ៣បទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

[554] មាត្រា១៣៨រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[555] ប្រការ៣បទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

ដែលអាចយកទៅបោះពុម្ពផ្សាយដែលទាក់ទងទៅនឹងគ្រប់សកម្មភាពសាធារណៈ ឬឯកជន។[556]

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវជូនដំណឹងឲ្យប្រធានដឹងអំពីការផ្លាស់ប្តូរ ដែលអាចកើតឡើងក្នុងសកម្មភាពវិជ្ជាជីវៈ ឬមុខរបរខ្លួននៅខាងក្រៅក្រុមប្រឹក្សាធម្មនុញ្ញ។

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ដែលមានបំណងសុំឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ ត្រូវសុំច្បាប់ឈប់សម្រាក ជាពិសេស៧ថ្ងៃមុនពេលធ្វើការបើកយុទ្ធនាការឃោសនាបោះឆ្នោត។ ការស្នើសុំដើម្បីធ្វើការឈប់សម្រាកនេះត្រូវបានអនុញ្ញាត។[557]

ក្នុងករណីចាំបាច់ ក្រុមប្រឹក្សាធម្មនុញ្ញ នឹងវាយតម្លៃសមាជិករបស់ខ្លួនណា ដែលខ្វះខាតមិនបានបំពេញកាតព្វកិច្ចទូទៅ ជាពិសេសកាតព្វកិច្ចដែលមានចែងនៅក្នុងច្បាប់នានា ឬនៅក្នុងបទបញ្ជាផ្ទៃក្នុងនេះ។ ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវសម្រេចដោយបោះឆ្នោតជាសម្ងាត់ យកតាមមតិភាគច្រើនដាច់ខាតនៃសមាជិកទាំងមូលដែលមាន៥សម្លេងយ៉ាងតិច។[558]

ច.សមត្ថកិច្ចក្រុមប្រឹក្សាធម្មនុញ្ញ

(Competence of the Constitutional Council)

ក្រុមប្រឹក្សាធម្មនុញ្ញ ជាស្ថាប័នឯករាជ្យ និងអព្យាក្រឹត ដែលមានសមត្ថកិច្ច ធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ ក្នុងក្របខ័ណ្ឌនៃការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់។ ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិពិនិត្យ និងសម្រេចអំពីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។[559]

តាមគោលការណ៍ក្រុមប្រឹក្សាធម្មនុញ្ញ មិនអាចយកបញ្ហាណាមួយមកពិនិត្យធម្មនុញ្ញភាពនៃច្បាប់ បកស្រាយរដ្ឋធម្មនុញ្ញ ឬច្បាប់ដោយខ្លួនឯងបានជាដាច់ខាត។

អ្នកដែលអាចយកបញ្ហាទាំងឡាយណាមួយ ដើម្បីឲ្យក្រុមប្រឹក្សាធម្មនុញ្ញ បានត្រួតពិនិត្យធម្មនុញ្ញនៃច្បាប់បាន គឺមានតែព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភាមួយភាគបួន និងសមាជិករដ្ឋសភាមួយភាគដប់ គឺអាចបញ្ជូនច្បាប់ ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយទៅឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុនច្បាប់នោះ ត្រូវប្រកាសឲ្យប្រើ។ ដែលមានច្បាប់រៀបចំអង្គការទាំងឡាយ បទបញ្ជាផ្ទៃក្នុងរដ្ឋសភា

[556] ប្រការ៤បទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

[557] ប្រការ៦បទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

[558] ប្រការ៦បទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

[559] មាត្រា១៣៦ថ្មីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

ឬបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ដែលច្បាប់ទាំងនោះ ត្រូវបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងប្រកាសឲ្យប្រើ។ ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវសម្រេចក្នុងរយៈពេលសាមសិប(៣០)ថ្ងៃយ៉ាងយូរ ថាតើច្បាប់រៀបចំអង្គការទាំងឡាយ បទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាខាងលើស្រប ឬមិនស្របទៅនឹងរដ្ឋធម្មនុញ្ញ។[560]

ក្រោយពីច្បាប់នានាដែលត្រូវបានប្រកាសឲ្យប្រើរួចហើយ ព្រះមហាក្សត្រប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន តំណាងរាស្ត្រចំនួនមួយភាគដប់ ឬតុលាការ អាចស្នើសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញត្រួតពិនិត្យអំពីធម្មនុញ្ញភាពនៃច្បាប់នោះ។

ប្រជារាស្ត្រខ្មែរទូទាំងប្រទេស ជាទូទៅមិនអាចលើកសំណើដើម្បីប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញដោយផ្ទាល់បានទេ។

ក៏ប៉ុន្តែប្រជារាស្ត្រខ្មែរ មានសិទ្ធិប្តឹងអំពីធម្មនុញ្ញភាពនៃច្បាប់បានគឺតាមរយៈតំណាងរាស្ត្រ ឬតាមរយៈប្រធានរដ្ឋសភា ឬតាមរយៈសមាជិកព្រឹទ្ធសភា ឬតាមរយៈប្រធានព្រឹទ្ធសភា ឬក៏តាមរយៈតុលាការដូចមានចែងក្នុងវាក្យខ័ណ្ឌខាងលើ។[561]

ប្រជារាស្ត្រអាចលើកសំណើប្តឹងទៅតុលាការអំពីបញ្ហាអធម្មនុញ្ញនៃច្បាប់ ឬសេចក្តីសម្រេចរបស់អង្គការស្ថាប័នរដ្ឋនានាបាន ដែលមានដូចជា ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងសេចក្តីសម្រេចរដ្ឋបាលផ្សេងៗ បានតាមរយៈ រឿងក្តីរបស់ខ្លួនទៅតុលាការបាន តុលាការថ្នាក់ក្រោមត្រូវបញ្ជូនពាក្យបណ្តឹងខាងលើនេះ ទៅតុលាការថ្នាក់ខ្ពស់ ជាបន្តបន្ទាប់រហូតដល់តុលាការកំពូល។ តុលាការកំពូលជាអ្នកបញ្ជូនបណ្តឹងនោះបន្តមកក្រុមប្រឹក្សាធម្មនុញ្ញប្រសិនបើជាតុលាការកំពូលយល់ឃើញថា សមហេតុសមផលបញ្ហាដែលកើតឡើងនោះ តុលាការត្រូវចាត់ទុកជាបញ្ហាបន្ទាន់បង្ខំ។

ដូចនេះតុលាការ ដែលទទួលបន្ទុកជំនុំជម្រះរឿងក្តី ត្រូវផ្អាកការជំនុំជម្រះជាបន្ទាន់ ដោយរង់ចាំចម្លើយ ឬសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញជាមុនសិន។

ករណីនេះ ក្រុមប្រឹក្សាធម្មនុញ្ញជាអ្នកជួយត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ជូនប្រជារាស្ត្រ។

១-ការពិនិត្យធម្មនុញ្ញភាពនៃច្បាប់

(The Exam of the Constitutionality of the Law)

ការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់គឺជាការត្រួតពិនិត្យទៅលើអត្ថបទច្បាប់ ថាតើវាស្រប

[560] មាត្រា១៤០រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[561] មាត្រា១៤១រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

ទៅនឹងរដ្ឋធម្មនុញ្ញ ឬមិនស្របទៅនឹងរដ្ឋធម្មនុញ្ញ ?។ បើច្បាប់នោះ បានពិនិត្យហើយឃើញថា វាស្របទៅនឹងរដ្ឋធម្មនុញ្ញគេថាច្បាប់នោះមានធម្មនុញ្ញភាពនៃច្បាប់ ប្រសិនបើច្បាប់នោះបានពិនិត្យហើយវាផ្ទុយទៅនឹងរដ្ឋធម្មនុញ្ញ គេថាច្បាប់នោះមានអធម្មនុញ្ញភាពនៃច្បាប់។

ជាទូទៅការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់មានពីរបែបគឺ:

ការត្រួតពិនិត្យជាអាទិកាល និងការត្រួតពិនិត្យជាបច្ចាកាល។

១.១.ការពិនិត្យធម្មនុញ្ញភាពនៃច្បាប់ជាអាទិកាល

(The Controle a Priori of the Constitutionality of the Laws)

ការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ជាអាទិកាល គឺជាការត្រួតពិនិត្យទៅលើអត្ថបទច្បាប់ទាំងឡាយណាមុនពេលដែលច្បាប់នោះ ត្រូវបានប្រកាសឲ្យប្រើ។ ការត្រួតពិនិត្យច្បាប់មុនប្រកាសឲ្យប្រើគេហៅថាជាការត្រួតពិនិត្យជាអាទិកាល។ ការត្រួតពិនិត្យជាអាទិកាលនេះ ត្រូវបានបែងចែកជាពីរទៀតគឺ: ការត្រួតពិនិត្យជាច់ខាត និងការត្រួតពិនិត្យមិនជាច់ខាត។

១.១.១.ការត្រួតពិនិត្យជាច់ខាត

(Absolute Control)

ការត្រួតពិនិត្យជាច់ខាត គឺជាការត្រួតពិនិត្យទៅលើអត្ថបទច្បាប់ទាំងឡាយណា ដែលចាំបាច់ត្រូវតែត្រួតពិនិត្យ ដោយមិនអាចខកខានបានឡើយ ដែលច្បាប់ទាំងនេះរួមមាន ច្បាប់រៀបចំអង្គការទាំងអស់(ច្បាប់អង្គិន) និងវិសោធនកម្មច្បាប់រៀបចំអង្គការ ក្រោយពីពេល ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានត្រួតពិនិត្យចប់សព្វគ្រប់ ហើយត្រូវដាក់ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញ ដោយប្រធានរដ្ឋសភា ដើម្បីពិនិត្យថា តើច្បាប់នោះស្រប ឬមិនស្របទៅនឹងរដ្ឋធម្មនុញ្ញ ? មុននឹងត្រូវបានប្រកាសឲ្យប្រើ។

បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា និងវិសោធនកម្មនៃបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា ក្រោយពីរដ្ឋសភាបានអនុម័តរួចហើយ ត្រូវតែដាក់ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញដោយប្រធានរដ្ឋសភា ដើម្បីត្រួតពិនិត្យទៅលើបទបញ្ជាផ្ទៃក្នុងរដ្ឋសភានោះ ថាតើស្រប ឬមិនស្របទៅនឹងរដ្ឋធម្មនុញ្ញដែរឬទេ ? មុននឹងត្រូវបានប្រកាសឲ្យប្រើ។

បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា និងវិសោធនកម្មបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា ក្រោយពីព្រឹទ្ធសភាបានអនុម័តហើយ ត្រូវដាក់ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញដោយប្រធានព្រឹទ្ធសភា ដើម្បីធ្វើការត្រួតពិនិត្យទៅលើបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានោះ ថាតើស្រប ឬមិនស្របទៅនឹងរដ្ឋធម្មនុញ្ញមុននឹងត្រូវបានប្រកាសឲ្យប្រើ។[562]

[562] មាត្រា១៦ថ្មីច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

សមាសភាពដែលមានសិទ្ធិលើកសំណើ

(Compositions have Rights to Request)

សមាសភាពដែលអាចដាក់សំណើ ដើម្បីឲ្យក្រុមប្រឹក្សាធម្មនុញ្ញត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់រួមមាន:

- ព្រះមហាក្សត្រ
- ប្រធានព្រឹទ្ធសភា
- ប្រធានរដ្ឋសភា
- នាយករដ្ឋមន្ត្រី
- សមាជិករដ្ឋសភាចំនួន១ភាគ១០
- សមាជិកព្រឹទ្ធភាចំនួន១ភាគ៤

សមាសភាពខាងលើនេះអាចបញ្ជូនច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានត្រួតពិនិត្យរួចហើយទៅឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពមុននឹងប្រកាសឲ្យប្រើបាន។[563]

១.១.២.ការត្រួតពិនិត្យមិនជាច់ខាត

(Not Absolute Control)

ការត្រួតពិនិត្យមិនជាច់ខាត គឺជាការត្រួតពិនិត្យទៅលើអត្ថបទច្បាប់ទាំងឡាយណា ដែលអាចត្រួតពិនិត្យធម្មនុញ្ញភាព និងមិនចាំបាច់ត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់។

បានសេចក្តីថា ច្បាប់ដែលរដ្ឋសភាបានអនុម័តរួច និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ គឺអាចឲ្យក្រុមប្រឹក្សាធម្មនុញ្ញត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ និងមិនចាំបាច់ឲ្យក្រុមប្រឹក្សាធម្មនុញ្ញ ត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ក៏បានដែរ។ ប្រសិនបើច្បាប់ទាំងនោះ គឺជាច្បាប់ធម្មតា មិនមែនជាច្បាប់រៀបចំអង្គការទេ។ ដែលច្បាប់ធម្មតា មានដូចជា ច្បាប់រដ្ឋប្បវេណី ច្បាប់ការងារ ច្បាប់បរិស្ថាន ច្បាប់ចរាចរ និងច្បាប់ផ្សេងៗដែលច្បាប់ទាំងនេះ ជាទូទៅមិនចាំបាច់ឲ្យក្រុមប្រឹក្សាធម្មនុញ្ញត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ទេ។ ករណីប្រសិនបើមានការសង្ស័យថា ច្បាប់ទាំងនោះមានអធម្មនុញ្ញភាពនៃច្បាប់។ ដូចនេះ ច្បាប់ទាំងនោះ អាចឲ្យក្រុមប្រឹក្សាធម្មនុញ្ញត្រួតពិនិត្យអំពីធម្មនុញ្ញភាពនៃច្បាប់បាន។

ដូចនេះអ្នកដែលមានសមត្ថកិច្ច ឬអ្នកសង្ស័យទាំងនេះ អាចស្នើសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់បាន។

---

[563] មាត្រា១៧ថ្មីច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

សមាសភាពដែលមានសិទ្ធិលើកសំណើ[564]

(Compositions have Rights to Request)

- ព្រះមហាក្សត្រ
- ប្រធានព្រឹទ្ធសភា
- ប្រធានរដ្ឋសភា
- នាយករដ្ឋមន្ត្រី
- សមាជិករដ្ឋសភាចំនួន១ភាគ១០
- សមាជិកព្រឹទ្ធភាចំនួន១ភាគ៤។

១.២.ការពិនិត្យធម្មនុញ្ញភាពនៃច្បាប់ជាបច្ឆាកាល

(The Controle a Posteriori of the Constitutionality of the Laws)

ការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ជាបច្ឆាកាល គឺជាការត្រួតពិនិត្យទៅលើអត្ថបទច្បាប់ទាំងឡាយណា ដែលច្បាប់ទាំងនោះត្រូវបានប្រកាសឲ្យប្រើរួចហើយ។ ការត្រួតពិនិត្យច្បាប់ដែលបានប្រកាសឲ្យប្រើរួចហើយហៅថាជាការត្រួតពិនិត្យជាបច្ចាកាល។

ច្បាប់ដែលអាចធ្វើការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ គឺជាច្បាប់ដែលត្រូវបានប្រកាសឲ្យប្រើរួចហើយទាំងអស់ ដែលរួមមាន ទាំងច្បាប់រៀបចំអង្គការទាំងអស់(ច្បាប់អង្គិន) បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា និងបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា ទាំងច្បាប់ធម្មតាទាំងអស់ ដែលច្បាប់ទាំងនេះនៅជាធរមាន ដែលកំពុងតែអនុវត្តន៍ក្នុងពេលបច្ចុប្បន្ន និងបន្តអនុវត្តន៍ទៅថ្ងៃអនាគតទៀត។

សមាសភាពដែលមានសិទ្ធិលើកសំណើ

(Compositions have Rights to Request)

- ព្រះមហាក្សត្រ
- ប្រធានព្រឹទ្ធសភា
- ប្រធានរដ្ឋសភា
- នាយករដ្ឋមន្ត្រី
- សមាជិករដ្ឋសភាចំនួន១ភាគ១០
- សមាជិកព្រឹទ្ធភាចំនួន១ភាគ៤
- តុលាការ

[564] មាត្រា១៧ថ្មីច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

សមាសភាពខាងលើ អាចបញ្ជូនគ្រប់ច្បាប់ទាំងអស់ទៅឲ្យក្រុមប្រឹក្សាធម្មនុញ្ញ ត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់បាន។[565]

ប្រជារាស្ត្រ មានសិទ្ធិប្តឹងអំពីអធម្មនុញ្ញភាពនៃច្បាប់ ទៅក្រុមប្រឹក្សាធម្មនុញ្ញបានតាមរយៈប្រធានរដ្ឋសភា ឬតំណាងរាស្ត្រចំនួនមួយភាគដប់ តាមរយៈប្រធានព្រឹទ្ធសភា ឬសមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន។[566]

បុគ្គលដែលពាក់ព័ន្ធក្នុងរឿងក្តីណាមួយ ហើយរឿងក្តីនោះឡើងដល់តុលាការបុគ្គលនោះអាចលើកអំពីអធម្មនុញ្ញភាពនៃច្បាប់នូវបទប្បញ្ញត្តិណាមួយនៃច្បាប់ ឬសេចក្តីសម្រេចរបស់ស្ថាប័នរដ្ឋនានាមានដូចជា ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងសេចក្តីសម្រេច ជូនតុលាការបាន។ បើតុលាការយល់ឃើញថា ការលើកឡើងនេះមានមូលដ្ឋានគ្រប់គ្រាន់ត្រឹមត្រូវនោះ តុលាការត្រូវលើកករណីនេះ បញ្ជូនពាក្យបណ្តឹងទៅតុលាការកំពូល ក្នុងរយៈពេល១០ថ្ងៃយ៉ាងយូរ តុលាការកំពូលអាចប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល១៥ថ្ងៃយ៉ាងយូរ។ ប្រសិនបើ តុលាការកំពូលយល់ឃើញថា បណ្តឹងតវ៉ានោះសមហេតុផល លើកលែងតែតុលាការកំពូលយល់ឃើញថា ពាក្យប្តឹងតវ៉ានេះមិនអាចទទួលបាន។[567]

ប្រសិនបើក្រុមប្រឹក្សាធម្មនុញ្ញកំណត់ថា បទបញ្ញត្តិណាមួយនៃច្បាប់នេះមិនស្របទៅនឹងរដ្ឋធម្មនុញ្ញៈ

-បើបទប្បញ្ញត្តិនោះ មិនអាចបំបែកចេញអំពីអត្ថបទច្បាប់ ដែលនៅសល់បានទេ អត្ថបទច្បាប់ទាំងមូលមិនអាចយកទៅប្រកាសឲ្យប្រើ ឬយកទៅអនុវត្តន៍បានឡើយ។

-បើបទប្បញ្ញត្តិនោះអាចបំបែកចេញពីអត្ថបទដែលនៅសល់បាននោះ មានតែបទប្បញ្ញត្តិច្បាប់ដែលផ្ទុយនឹងរដ្ឋធម្មនុញ្ញប៉ុណ្ណោះទេ ដែលមិនអាចយកទៅប្រកាសឲ្យប្រើ ឬមិនអាចយកទៅអនុវត្តន៍បាន។[568]

ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិអញ្ជើញជនណាម្នាក់ ឬច្រើននាក់ ដើម្បីឲ្យមកបំភ្លឺ ឬផ្តល់ឯកសារទាំងឡាយដែលពាក់ព័ន្ធបាន។ បុគ្គលគ្រប់រូបនៃស្ថាប័នរដ្ឋ ឬឯកជនទាំងឡាយត្រូវតែគោរព និងប្រតិបត្តិតាមការអញ្ជើញ និងការស្នើសុំរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

---

[565] មាត្រា១៨ថ្មីច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

[566] មាត្រា១៨ថ្មីច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

[567] មាត្រា១៩ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

[568] មាត្រា២០ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវតែសម្រេចសេចក្តីជាលាយលក្ខណ៍អក្សរ លើគ្រប់ករណីទាំងអស់ដែលត្រូវបានដាក់ជូនក្នុងរយៈពេល៣០ថ្ងៃ។ ប្រសិនបើជាការប្រញាប់រយៈពេលនេះត្រូវបន្តយមកត្រឹម៨ថ្ងៃ។ ក្រុមប្រឹក្សាធម្មនុញ្ញ អាចពិនិត្យពិចារណាលើធម្មនុញ្ញភាព ដោយផ្អែកលើសេចក្តីរាយការណ៍របស់សមាជិកក្រុមប្រឹក្សា ដែលប្រធានក្រុមប្រឹក្សាធម្មនុញ្ញបានប្រគល់ការកិច្ចឲ្យត្រួតពិនិត្យ និងរាយការណ៍។

ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវតែសម្រេចសេចក្តីដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកទាំងមូល។ ក្នុងករណី ដែលសម្លេងបានបែកជាពីរស្មើគ្នា សម្លេងរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញជាសម្លេងមានឧត្តមានុភាព សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវតែបញ្ជាក់អំពីមូលហេតុ និងហេតុផលឲ្យបានច្បាស់លាស់។[569]

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ គឺជាសេចក្តីសម្រេចបិទផ្លូវតែវ៉ាហើយមានអានុភាពអនុវត្តន៍ទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ។[570]

សេចក្តីសម្រេច របស់ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវតែផ្ញើថ្វាយ ព្រះមហាក្សត្រ ផ្ញើជូនប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី និងប្រធានតុលាការកំពូល នឹងត្រូវចុះផ្សាយក្នុងរាជកិច្ច។ ប្រធានរដ្ឋសភាត្រូវជូនដំណឹងពីសេចក្តីសម្រេចនេះទៅដល់សមាជិករដ្ឋសភាទាំងអស់។

ប្រធានតុលាការកំពូលត្រូវជូនដំណឹងដល់តុលាការសាមី។[571]

២-ការបកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់

(Interpretation of Constitution and Laws)

ក្រុមប្រឹក្សាធម្មនុញ្ញ មានសមត្ថកិច្ចធានាការការពារ ការគោរពរដ្ឋធម្មនុញ្ញ ការបកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ រដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានត្រួតពិនិត្យចប់សព្វគ្រប់ហើយ។[572]

ក្រុមប្រឹក្សាធម្មនុញ្ញ មានសិទ្ធិបកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់នានាតាមសំណើព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន ឬសមាជិកតំណាងរាស្ត្រមួយភាគដប់។

ប្រជារាស្ត្រ មានសិទ្ធិស្នើសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញ ធ្វើការបកស្រាយ រដ្ឋធម្មនុញ្ញ ច្បាប់ និង

---

[569] មាត្រា២២ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

[570] មាត្រា២៣ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

[571] មាត្រា២៤ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

[572] មាត្រា១៣៦រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

សេចក្តីសម្រេចនានារបស់អង្គការស្ថាប័នរដ្ឋតាមរយៈប្រធានរដ្ឋសភាតំណាងរាស្ត្រចំនួនមួយភាគដប់ ឬប្រធានព្រឹទ្ធសភា និងសមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន។[573]

ក្រោយពីបានទទួលសំណើពីព្រះមហាក្សត្រ ពីប្រធានរដ្ឋសភា ពីនាយករដ្ឋមន្ត្រី ពីប្រធានព្រឹទ្ធសភា ពីសមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន(១/៤) ពីសមាជិករដ្ឋសភាចំនួនមួយភាគដប់ ពីតុលាការ ពីប្រជារាស្ត្រតាមរយៈប្រធានរដ្ឋសភា ឬសមាជិករដ្ឋសភាចំនួនមួយភាគដប់ ឬពីប្រធានព្រឹទ្ធសភា ឬពីសមាជិកព្រឹទ្ធសភាមួយភាគបួន ឬពីតុលាការកំពូល ប្រធានក្រុមប្រឹក្សាធម្មនុញ្ញត្រូវចាត់ការឲ្យចុះបញ្ជីនៅអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ។[574]

រយៈពេលដោះស្រាយត្រូវចាប់រាប់តាំងពីថ្ងៃចុះបញ្ជីនេះ ហើយពេលវេលាដោះស្រាយត្រូវធ្វើតាមការកំណត់នៅក្នុងច្បាប់ជាធរមាន។[575]

ក្រោយពេលចុះបញ្ជីរួច ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបញ្ជូនសំណើទាំងនោះឲ្យទៅក្រុមនៃក្រុមប្រឹក្សាធម្មនុញ្ញដើម្បីធ្វើការត្រួតពិនិត្យ។ របាយការណ៍របស់ក្រុមនៃក្រុមប្រឹក្សាធម្មនុញ្ញត្រូវដាក់ជូនអង្គប្រជុំបឋមដើម្បីធ្វើការពិភាក្សា។[576]

ក្រុមនីមួយៗនៃក្រុមប្រឹក្សាធម្មនុញ្ញ មានសមាសភាពសមាជិក៣រូប ដែល១រូបជាសមាជិកដែលបានតែងតាំងដោយព្រះមហាក្សត្រ ១រូបជាសមាជិកតែងតាំង ដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និង១រូបទៀតជាសមាជិកដែលត្រូវបានជ្រើសតាំងដោយរដ្ឋសភា។ សមាជិកទាំងបីក្រុមត្រូវជ្រើសរើសដោយវិធីចាប់ឆ្នោត ដែលស្ថិតក្រោមអធិបតីភាពរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ។ សមាជិករាយការណ៍ត្រូវតែងតាំងដោយប្រធានក្រុមប្រឹក្សាធម្មនុញ្ញ។[577]

ក្នុងការប្រតិបត្តិការងារ សមាជិករាយការណ៍ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រុមប្រឹក្សាធម្មនុញ្ញដោយគ្រាន់តែជូនព័ត៌មានទៅប្រធានក្រុមប្រឹក្សាធម្មនុញ្ញ។[578]

ទោះក្នុងករណីណាក៏ដោយ សមាជិករាយការណ៍ ត្រូវតែរាយការណ៍ជូនអង្គប្រជុំជាបឋមរបាយការណ៍នេះ ត្រូវដាក់ជូនអង្គប្រជុំពេញអង្គដើម្បីពិភាក្សា និងសម្រេចជាស្ថាពរ។[579]

---

[573] មាត្រា១៨ថ្មីច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

[574] ប្រការ១ថ្មីបទបញ្ជាផ្ទៃក្នុងស្តីពីនីតិ វិធីដែលត្រូវអនុវត្តន៍ទៅមុខក្រុមប្រឹក្សាធម្មនុញ្ញ។

[575] ប្រការ២បទបញ្ជាផ្ទៃក្នុងស្តីពីនីតិ វិធីដែលត្រូវអនុវត្តន៍ទៅមុខក្រុមប្រឹក្សាធម្មនុញ្ញ។

[576] ប្រការ៣បទបញ្ជាផ្ទៃក្នុងស្តីពីនីតិ វិធីដែលត្រូវអនុវត្តន៍ទៅមុខក្រុមប្រឹក្សាធម្មនុញ្ញ។

[577] ប្រការ៤បទបញ្ជាផ្ទៃក្នុងស្តីពីនីតិ វិធីដែលត្រូវអនុវត្តន៍ទៅមុខក្រុមប្រឹក្សាធម្មនុញ្ញ។

[578] ប្រការ៥បទបញ្ជាផ្ទៃក្នុងស្តីពីនីតិ វិធីដែលត្រូវអនុវត្តន៍ទៅមុខក្រុមប្រឹក្សាធម្មនុញ្ញ។

[579] ប្រការ៦ថ្មីបទបញ្ជាផ្ទៃក្នុងស្តីពីនីតិ វិធីដែលត្រូវអនុវត្តន៍ទៅមុខក្រុមប្រឹក្សាធម្មនុញ្ញ។

ចំពោះគ្រប់សំណើស្នើសុំឲ្យត្រួតពិនិត្យទាំងអស់ខាងលើក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវតែសម្រេចក្នុងពេលវេលាមួយ ដែលមានកំណត់ក្នុងច្បាប់ និងអនុម័តតាមមតិភាគច្រើនដាច់ខាតនៃសមាជិកក្រុមប្រឹក្សាធម្មនុញ្ញទាំងមូល(ដែលមានចំនួន៥សម្លេងយ៉ាងតិច)។[580]

ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវតែសម្រេចសេចក្តីជាលាយលក្ខណ៍អក្សរលើគ្រប់ករណី ដែលត្រូវបានដាក់ជូនក្នុងរយៈពេល៣០ថ្ងៃ ប្រសិនបើជាការប្រញាប់ក្នុងរយៈពេលនេះ ត្រូវបន្តយមកត្រឹម៨ថ្ងៃ។ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវធ្វើការត្រួតពិនិត្យ និងធ្វើការបកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ដោយផ្អែកលើសេចក្តីរាយការណ៍របស់សមាជិក ដែលប្រធានក្រុមប្រឹក្សាធម្មនុញ្ញបានប្រគល់ភារកិច្ចឲ្យពិនិត្យ និងរាយការណ៍។

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចសេចក្តីតាមមតិភាគច្រើនដាច់ខាត៥០បូក១ នៃសមាជិកក្រុមប្រឹក្សាទាំងមូល ក្នុងករណី ដែលសម្លេងបានបែកជាពីរស្មើគ្នា សម្លេងរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញជាសម្លេងមានឧត្តមានុភាព។[581]

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវផ្ញើថ្វាយព្រះមហាក្សត្រ ត្រូវផ្ញើជូនប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី និងប្រធានតុលាការកំពូលនឹងត្រូវចុះផ្សាយក្នុងរាជកិច្ច។ ប្រធានព្រឹទ្ធសភាត្រូវជូនដំណឹងអំពីសេចក្តីសម្រេចនេះ ដល់សមាជិកព្រឹទ្ធសភាទាំងអស់។ ប្រធានរដ្ឋសភាត្រូវតែជូនដំណឹងអំពីសេចក្តីសម្រេចនេះដល់សមាជិករដ្ឋសភាទាំងអស់។ នាយករដ្ឋមន្ត្រីត្រូវជូនដំណឹងពីសេចក្តីសម្រេចនេះដល់សមាជិករាជរដ្ឋាភិបាលទាំងអស់។ ប្រធានតុលាការកំពូលត្រូវជូនដំណឹងអំពីសេចក្តីសម្រេចនេះដល់តុលាការសាមី។[582]

៣-ការដោះស្រាយវិវាទនៃការបោះឆ្នោត

(Solving litigations of Election)

ក្រុមប្រឹក្សាធម្មនុញ្ញ មានសមត្ថកិច្ចសម្រេចចំពោះបណ្តឹងដែលទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងជ្រើសតាំងសមាជិកព្រឹទ្ធសភា។[583]

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវតែធ្វើការពិនិត្យ និងសម្រេចលើបណ្តឹងរបស់គណបក្សនយោបាយទាំងឡាយដែលក្រសួងមហាផ្ទៃបានបដិសេធមិនព្រមចុះបញ្ជីគណបក្សនយោបាយ។

ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវពិនិត្យ និងសម្រេចបណ្តឹងតវ៉ា និងបណ្តឹងជំទាស់នឹងបញ្ជីដំបូង

---

[580] ប្រការ៧បទបញ្ជាផ្ទៃក្នុងស្តីពីនីតិ វិធីដែលត្រូវអនុវត្តន៍ទៅមុខក្រុមប្រឹក្សាធម្មនុញ្ញ។

[581] មាត្រា២២ថ្មីច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

[582] មាត្រា២៤ថ្មីច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

[583] មាត្រា២៥ថ្មីច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

នៃការចុះឈ្មោះបោះឆ្នោត និងបណ្តឹងក្នុងពេលឃោសនាបោះឆ្នោត។

ចំពោះលទ្ធផលនៃការបោះឆ្នោតរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវត្រួតពិនិត្យ និងសម្រេចលើបណ្តឹងតវ៉ារបស់បុគ្គល ឬគណបក្សនយោបាយដែលមិនសុខចិត្តនឹងលទ្ធផលនៃការបោះឆ្នោត ឬបណ្តឹងដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលសម្រេចបដិសេធការតវ៉ាអំពីលទ្ធផលនៃការបោះឆ្នោត។

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវត្រួតពិនិត្យ និងសម្រេច:

-លើបណ្តឹងតវ៉ារបស់គណបក្សនយោបាយ ឬរបស់បេក្ខជនប្តឹងមិនសុខចិត្ត និងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលសម្រេចបដិសេធ លើការតវ៉ាពីបេក្ខភាព ឬសម្រេចបដិសេធលើការតវ៉ាអំពីបញ្ជីរាយនាមបេក្ខជន។ ការប្តឹងនេះ ត្រូវធ្វើឡើងក្នុងរយៈពេល៧ថ្ងៃយ៉ាងយូរ ក្រោយពេលបានទទួលលិខិតជូនដំណឹង ពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

-លើបណ្តឹងតវ៉ារបស់បុគ្គលប្តឹងមិនសុខចិត្ត និងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលបានសម្រេចបដិសេធការតវ៉ាសុំចុះឈ្មោះបោះឆ្នោតការប្តឹងនេះ ត្រូវធ្វើឡើងក្នុងរយៈពេល៥ថ្ងៃយ៉ាងយូរ ក្រោយពីបានទទួលលិខិតជូនដំណឹងអំពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

-លើបណ្តឹងតវ៉ារបស់បុគ្គល ឬអ្នកតំណាងដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលសម្រេចបដិសេធពីការបាត់ឈ្មោះ ឬអំពីការជំទាស់និងការចុះឈ្មោះ ឬអំពីការរក្សាទុកឈ្មោះក្នុងបញ្ជីបោះឆ្នោតនូវបុគ្គលណាម្នាក់ ដែលគេយល់ឃើញថា មានលក្ខណៈមិនត្រឹមត្រូវ តាមលក្ខខណ្ឌនៃច្បាប់បោះឆ្នោត។ ការប្តឹងនេះ ត្រូវតែធ្វើឡើងក្នុងរយៈពេល៥ថ្ងៃយ៉ាងយូរ ក្រោយពីបានទទួលលិខិតជូនដំណឹងអំពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវសម្រេចករណីខាងលើ ក្នុងរយៈពេល១០ថ្ងៃ យ៉ាងយូរបន្ទាប់ពីបានទទួលពាក្យបណ្តឹង។

-លើបណ្តឹងតវ៉ារបស់គណបក្សនយោបាយណាមួយ ដែលមកអំពីការមិនព្រមចុះបញ្ជីគណបក្សនយោបាយ។ បណ្តឹងនេះ ត្រូវធ្វើឡើងក្នុងរយៈពេល៥ថ្ងៃយ៉ាងយូរ ក្រោយពេលបានទទួលលិខិតជូនដំណឹងរបស់ក្រសួងមហាផ្ទៃ។ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចករណីខាងលើនេះ ក្នុងរយៈពេល៣០ថ្ងៃយ៉ាងយូរ បន្ទាប់ពីពេលបានទទួលពាក្យបណ្តឹងសាមីគណបក្សនយោបាយ។[584]

[584] មាត្រា២៦ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ និងសម្រេច:

-លើបណ្តឹងតវ៉ាដោយផ្អាល់អំពីលទ្ធផលនៃការបោះឆ្នោតជ្រើសតាំង ដែលបុគ្គលឬគណៈបក្សនយោបាយ ដែលបានឈរឈ្មោះបោះឆ្នោតមិនសុខចិត្តនឹងលទ្ធផលនៃការបោះឆ្នោតបណ្តឹងនេះ គឺត្រូវធ្វើឡើងក្នុងរយៈពេល៧២ម៉ោងយ៉ាងយូរ បន្ទាប់ពីការប្រកាសលទ្ធផលបោះឆ្នោតជាបណ្តោះអាសន្នរួចមក ឬបន្ទាប់ពីការទទួលការជូនដំណឹងនៃសេចក្តីសម្រេចបដិសេធរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ ក្នុងសមត្ថកិច្ចនេះ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវមានតួនាទីដូចជាតុលាការធម្មតាដែរ ដោយប្រើនីតិវិធីឲ្យភាគីផ្តល់កស្តុតាង ដោយស្តាប់ចម្លើយសាក្សី ដោយធ្វើការស្រាវជ្រាវ ស៊ើបអង្កេត និងសួរដេញដោលចំពោះមុខ ក្នុងសវនាការជាសាធារណៈមុនពេលធ្វើការសម្រេចសេចក្តី។

-លើបណ្តឹងតវ៉ារបស់បុគ្គល ឬគណៈបក្សនយោបាយ ដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលសម្រេចបដិសេធការតវ៉ាអំពីលទ្ធផលនៃការបោះឆ្នោតការប្តឹងតវ៉ានេះ ត្រូវធ្វើឡើងក្នុងរយៈពេល៧២ម៉ោងយ៉ាងយូរក្រោយពីពេលបានទទួលលិខិតជូនដំណឹងអំពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចករណីខាងលើក្នុងរយៈពេល២០ថ្ងៃយ៉ាងយូរ បន្ទាប់ពីពេលបានទទួលពាក្យបណ្តឹង។[585]

បុគ្គលណាម្នាក់ ឬគណៈបក្សនយោបាយណាមួយ ដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬមិនសុខចិត្តនឹងលទ្ធផលនៃការបោះឆ្នោតនោះ ត្រូវធ្វើពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរ ជូនទៅឲ្យក្រុមប្រឹក្សាធម្មនុញ្ញ។ ដែលពាក្យបណ្តឹងនេះត្រូវធ្វើឡើងទៅតាមនីតិវិធីដូចតទៅ:

-ឈ្មោះបុគ្គលឬឈ្មោះគណបក្សនយោបាយដែលជាអ្នកប្តឹងតវ៉ា

-ឋានៈតាមផ្លូវច្បាប់របស់អ្នកប្តឹងតវ៉ា(ជាអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតឬជាបេក្ខជន ឬជាតំណាងគណបក្សនយោបាយ)។

-ឈ្មោះមណ្ឌលបោះឆ្នោតដែលមានការប្តឹងតវ៉ា

-ឈ្មោះបុគ្គល ឬគណបក្សនយោបាយ ដែលត្រូវបានគេប្រកាសថា ជាប់ឆ្នោតហើយដែលគេប្តឹងតវ៉ា។

-គ្រប់ឯកសារ ឬកស្តុតាងសម្រាប់គាំទ្រការសុំបដិសេធ

ក្រុមប្រឹក្សាធម្មនុញ្ញ ផ្អែកតាមឆន្ទានុសិទ្ធិរបស់ខ្លួន អាចទុកពេល៥ថ្ងៃឲ្យបុគ្គល ឬគណៈ

[585] មាត្រា២៧ថ្មីច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

បក្សនយោបាយ ដែលជាអ្នកប្តឹងដើម្បីផ្តល់ភស្តុតាង។

ក្រុមប្រឹក្សាធម្មនុញ្ញ អាចសម្រេចបដិសេធមិនឲ្យធ្វើការស៊ើបអង្កេតលើបណ្តឹងណាមួយបើបណ្តឹងនោះ មិនបានបំពេញលក្ខខណ្ឌកំណត់ក្នុងមាត្រានេះ។ គ្រប់ករណីទាំងអស់ ដែលប្តឹងតវ៉ាទៅក្រុមប្រឹក្សាធម្មនុញ្ញមិនតម្រូវឲ្យមានការបង់ប្រាក់ទេ។[586]

ពាក្យប្តឹងតវ៉ា គឺគ្មានអានុភាពផ្អាកការអនុវត្តទេ។ ប៉ុន្តែក្នុងរយៈពេលរង់ចាំសេចក្តីសម្រេចជាស្ថាពរ ក្រុមប្រឹក្សាធម្មនុញ្ញបើយល់ឃើញថា ចាំបាច់អាចចេញបញ្ជាជាបឋមមួយ ដើម្បីឲ្យព្យួរជាបណ្តោះអាសន្ន នូវលទ្ធផលការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រណាម្នាក់ ឬសមាជិកព្រឹទ្ធសភាណាម្នាក់ ឬក៏គណបក្សនយោបាយណាមួយ ដែលគេបានប្តឹងតវ៉ា បញ្ហានោះនឹងត្រូវបញ្ចប់អានុភាព នៅពេលដែលក្រុមប្រឹក្សាធម្មនុញ្ញចេញសេចក្តីសម្រេចជាស្ថាពរ។[587]

ដើម្បីស្រាវជ្រាវ ស៊ើបអង្កេតអំពីវិវាទកម្មទាក់ទងទៅនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងជ្រើសរើសសមាជិកព្រឹទ្ធសភា ក៏ដូចជាការស្រាវជ្រាវត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ ឬបកស្រាយច្បាប់ ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវចែកចេញជា៣ក្រុម។

ក្រុមនីមួយៗមានសមាជិកចំនួន៣រូប ដែល១រូបជាសមាជិក ដែលបានតែងតាំងដោយព្រះមហាក្សត្រ ១រូបជាសមាជិកជ្រើសតាំងដោយរដ្ឋសភា និង១រូបទៀតជាសមាជិកដែលត្រូវបានតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សមាជិកក្នុងក្រុមទាំង៣នេះត្រូវជ្រើសរើសដោយវិធីចាប់ឆ្នោតក្រោមអធិបតីភាពរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ។[588]

ក្រោយពីបានទទួលពាក្យបណ្តឹងមកប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវតែប្រគល់សិទ្ធិទៅឲ្យក្រុមណាមួយទទួលខុសត្រូវ ដើម្បីធ្វើការស៊ើបអង្កេត។ ក្រុមនោះត្រូវជូន ដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់ដល់អ្នកប្តឹងតវ៉ា និងដល់ជន ឬគណបក្សនយោបាយ ដែលគេបានប្តឹងតវ៉ាថា អ្នកទាំងនោះមានពេលយ៉ាងយូរ១០ថ្ងៃដើម្បីពិនិត្យលើសេចក្តីប្តឹងតវ៉ា និងភស្តុតាងដែលភាគីបានផ្ញើជូនមកក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីរៀបចំជាលិខិតឆ្លើយតបក្នុងទម្រង់ ជាលាយលក្ខណ៍អក្សរ។[589]

ក្រោយពីបានទទួល លិខិតឆ្លើយតបខាងលើនេះ ឬក៏ក្រោយផុតកំណត់រយៈពេល១០ថ្ងៃ និងក្រោយធ្វើការស៊ើបអង្កេតចប់សព្វគ្រប់រួចហើយ ក្រុមដែលទទួលបន្ទុក គឺត្រូវដាក់លទ្ធផលនៃការស៊ើបអង្កេតព្រមទាំងយោបល់របស់ក្រុមនេះជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពេញអង្គ។ ក្រុមប្រឹក្សា

[586] មាត្រា២៨ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

[587] មាត្រា២៩ថ្មីច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

[588] មាត្រា៣០ថ្មីច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

[589] មាត្រា៣១ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

ធម្មនុញ្ញអាចឲ្យធ្វើការស៊ើបអង្កេតបន្ថែមទៀតបាន ហើយអាចស្តាប់អ្នកប្តឹងតវ៉ានិងអ្នកដែលត្រូវគេប្តឹងតវ៉ាដោយផ្ទាល់បាន។[590]

ពេលធ្វើការស៊ើបអង្កេត ក្រុមប្រឹក្សាធម្មនុញ្ញ ឬក្រុមនៃក្រុមប្រឹក្សាធម្មនុញ្ញ គឺអាចធ្វើការសាកសួរលើគ្រប់បញ្ហាទាំងអស់ ព្រមទាំងឯកសារ និងរបាយការណ៍ផ្សេងៗ និងការកោះអញ្ជើញជនទាំងឡាយដែលពាក់ព័ន្ធក្នុងការបោះឆ្នោត។

ក្រុមប្រឹក្សាធម្មនុញ្ញ ឬក្រុមនៃក្រុមប្រឹក្សាធម្មនុញ្ញអាចចាត់តាំងបុគ្គលិករបស់ខ្លួន ឬបុគ្គលផ្សេងៗទៀតឲ្យជួយក្នុងការស៊ើបអង្កេត ជាពិសេសនៅពេលទទួលចម្លើយរបស់សាក្សី ដែលបានធ្វើសច្ចាប្រណិធានរួចហើយ។

កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃចម្លើយរបស់សាក្សី ត្រូវតម្កល់ទុកសម្រាប់ភាគីទាំងអស់។ បើសិនអ្នកស៊ើបអង្កេត ឬសមាជិកក្នុងក្រុមណាម្នាក់ បានដឹងថា សាក្សីមានការភ័យខ្លាចអាចគេធ្វើបាប ឈ្មោះសាក្សីត្រូវរក្សាទុកជាសម្ងាត់មិនឲ្យនរណាដឹងទាំងអស់ ក្រៅអំពីក្រុមប្រឹក្សាធម្មនុញ្ញគឺអាចឲ្យដឹងតែអំពីខ្លឹមសារនៃចម្លើយតែប៉ុណ្ណោះ។[591]

ក្រុមប្រឹក្សាធម្មនុញ្ញសម្រេចសេចក្តី ក្នុងករណីដែលមានការតវ៉ាអំពីនិយ័តភាពនៃការបោះឆ្នោត អំពីភាពដែលអាចជ្រើសតាំងបាននៃបេក្ខជន សម្រាប់ធ្វើការ បោះឆ្នោត និងភាពអាចជ្រើសតាំងបាននៃបេក្ខជនដែលប្រកាសថាជាប់ឆ្នោត។

ក្រុមប្រឹក្សាធម្មនុញ្ញអាចយល់ស្រប ឬមិនយល់ស្របតាមសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក៏អាចប្រកាសមោឃភាពនៃការបោះឆ្នោត ដែលគេបានប្តឹងតវ៉ា ឬប្រកាសថាបេក្ខជនជាប់ឆ្នោតដោយត្រឹមត្រូវ។

ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវសម្រេចសេចក្តីតាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកទាំងមូល។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញត្រូវបញ្ជាក់អំពីហេតុផល។[592]

៤-សមត្ថកិច្ចផ្សេងៗ

(Other Competences)

-ក្រុមប្រឹក្សាធម្មនុញ្ញ មានសមត្ថកិច្ចសម្រេចលើមោឃៈភាពនៃការអនុម័តទាំងឡាយរបស់រដ្ឋសភា ដែលផ្ទុយនឹងគោលការណ៍នៃការរក្សា ការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជាដែលនាំឲ្យប៉ះពាល់ដល់ឯកភាពនយោបាយ ឬការគ្រប់គ្រងរដ្ឋបាលរបស់

[590] មាត្រា៣២ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

[591] ប្រការ៣៣បទបញ្ជាផ្ទៃក្នុងស្តីពីនីតិ វិធីដែលត្រូវអនុវត្តន៍ទៅមុខក្រុមប្រឹក្សាធម្មនុញ្ញ។

[592] ប្រការ៣៤ថ្មីបទបញ្ជាផ្ទៃក្នុងស្តីពីនីតិ វិធីដែលត្រូវអនុវត្តន៍ទៅមុខក្រុមប្រឹក្សាធម្មនុញ្ញ។

ប្រទេសជាតិ។[593]

-ក្រុមប្រឹក្សាធម្មនុញ្ញ មានសមត្ថកិច្ចថ្វាយមតិយោបល់ដល់ព្រះមហាក្សត្រ នៅពេលដែលព្រះមហាក្សត្រ ទ្រង់បានពិគ្រោះមតិយោបល់ជាមួយនឹងក្រុមប្រឹក្សាធម្មនុញ្ញ នៅក្នុងករណីចំពោះសេចក្តីស្នើទាំងឡាយដែលសុំធ្វើវិសោធនកម្មលើរដ្ឋធម្មនុញ្ញ។[594]

ក្រុមប្រឹក្សាធម្មនុញ្ញ មានសមត្ថកិច្ចក្នុងការធ្វើទំនាក់ទំនងអន្តរជាតិជាមួយ បណ្តាប្រទេសជាច្រើននៅលើពិភពលោក ដើម្បីពង្រីកសហប្រតិបត្តិការអន្តរជាតិ ឲ្យកាន់តែល្អប្រសើរឡើង ក្នុងគោលដៅអនុវត្តន៍សកម្មភាពការងារ ក្នុងក្របខ័ណ្ឌការការពាររដ្ឋធម្មនុញ្ញ ការបកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ ដែលរដ្ឋសភាបានអនុម័តរួចហើយ ព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ និងសម្រេចអំពីករណីវិវាទកម្ម ទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដែលក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានក្លាយទៅជាសមាជិកនៃសមាគមតុលាការធម្មនុញ្ញនៃប្រទេសប្រើភាសាបារាំងចាប់តាំងពីឆ្នាំ១៩៩៨មក។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញជាសេចក្តីសម្រេចបិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តន៍លើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ។

បទប្បញ្ញត្តិណាមួយនៃច្បាប់ដែលក្រុមប្រឹក្សាធម្មនុញ្ញបានសម្រេចថា មិនស្របទៅនឹងរដ្ឋធម្មនុញ្ញគឺមិនអាចយកទៅប្រកាសឲ្យប្រើ ឬយកទៅអនុវត្តន៍បានឡើយ។ សេចក្តីសម្រេចនេះត្រូវធ្វើថ្វាយព្រះមហាក្សត្រ បញ្ជូនទៅឲ្យរដ្ឋសភា និងរាជរដ្ឋាភិបាលហើយត្រូវចុះក្នុងរាជកិច្ច។[595]

ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិបញ្ជូនបណ្តឹង ដែលមិនចូលទៅក្នុងសមត្ថកិច្ចរបស់ខ្លួនទៅឲ្យអង្គការមានសមត្ថកិច្ចផ្សេងៗទៀតបាន។[596]

៩.អំពីការប្រជុំ

(The Meeting)

ក្រុមនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលបានទទួលការចាត់តាំងហើយ ត្រូវតែធ្វើការពិភាក្សាអំពីការវិភាគ និងទស្សនៈផ្សេងៗ ដែលសមាជិករាយការណ៍បានលើកជូនក្រោយពីក្រុមបានពិភាក្សាចប់សព្វគ្រប់ហើយទោះបីការពិភាក្សានោះ ពុំបានចុះសម្រុងនឹងគ្នាក៏ដោយ ក៏សមាជិករាយការណ៍ត្រូវដាក់របាយការណ៍របស់ខ្លួន ជូនសម័យប្រជុំបឋមនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលត្រូវបានកំណត់

[593] មាត្រា៩២រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[594] មាត្រា១៤៣ថ្មីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[595] មាត្រា៣៤ថ្មីច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

[596] មាត្រា៣៥ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

កាលបរិឆ្ឆេទដោយប្រធានក្រុមប្រឹក្សារួចហើយ។

ការប្រជុំរបស់ក្រុមប្រឹក្សាធម្មនុញ្ញជាទូទៅមានពីរគឺ:

ការប្រជុំជាបឋម និងការប្រជុំពេញអង្គ

១-ការប្រជុំជាបឋម

(Primary Session)

ការប្រជុំជាបឋម គឺជាការប្រជុំរៀបចំសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញដែលសមាជិកម្នាក់ៗអាចបញ្ចេញយោបល់របស់ខ្លួនបាន ប៉ុន្តែពុំមានការសម្រេចឡើយ។

ក្នុងការប្រជុំរៀបចំ គឺដើម្បីធ្វើការត្រួតពិនិត្យពិភាក្សាទៅលើការងារអ្វីមួយ ឬរបាយការណ៍ណាមួយ ក្នុងការចុះក្នុងសៀវភៅជំនុំជម្រះ ហើយនឹងរៀបចំដាក់បន្តទៅក្នុងកិច្ចប្រជុំពេញអង្គ។

២-ការប្រជុំពេញអង្គ

(Plenary Session)

ការប្រជុំពេញអង្គ គឺជាការប្រជុំ ដើម្បីធ្វើការត្រួតពិនិត្យ និងពិភាក្សាសម្រេចលើបញ្ហាទាំងឡាយដែលបានប្រជុំជាបឋមរួចមកហើយ ដើម្បីអនុម័តចេញសេចក្តីសម្រេចជាស្ថាពរ។

ការប្រជុំនោះ ត្រូវអនុម័តសម្រេច ដោយមតិភាគច្រើនដាច់ខាត(៥០បូក១)នៃសមាជិកទាំងមូល។ ការប្រជុំពេញអង្គនេះ ក៏អាចកែប្រែទៅជាសវនការជំនុំជម្រះជាសាធារណៈបានដែរ។

គ្រប់ការប្រជុំជាបឋមនិងការប្រជុំពេញអង្គត្រូវធ្វើឡើងតាមនីតិវិធីដូចតទៅ:

ការប្រជុំរបស់ក្រុមប្រឹក្សាធម្មនុញ្ញត្រូវធ្វើការកោះអញ្ជើញដោយប្រធានក្រុមប្រឹក្សា ឬដោយសមាជិករបស់ក្រុមប្រឹក្សាដែលមានអាយុច្រើនជាងគេ ក្នុងករណី ប្រធានក្រុមប្រឹក្សាមានធុរៈមិនអាចធ្វើការងារនេះបាន។

កិច្ចប្រជុំរបស់ក្រុមប្រឹក្សាធម្មនុញ្ញ នឹងអាចដំណើរការទៅបាន លុះត្រាតែមានសមាជិកនៃក្រុមប្រឹក្សាធម្មនុញ្ញលើសពីពាក់កណ្តាលចូលរួមប្រជុំ។

អាសនានុក្រមរបស់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវរៀបចំតាមលំដាប់អតីតភាព ប៉ុន្តែក្នុងករណីមានអតីតភាពស្មើគ្នា អាសនានុក្រមត្រូវរៀបចំតាមលំដាប់អាយុ។[597]

ការកោះប្រជុំ ត្រូវធ្វើជាលិខិតអញ្ជើញ ដោយភ្ជាប់ជាមួយគម្រោងរបៀបវារៈ ហើយផ្ញើជូនសមាជិកយ៉ាងតិច២ថ្ងៃមុនថ្ងៃកំណត់ប្រជុំ លើកលែងតែស្ថិតក្នុងការប្រញាប់។មុននឹងប្រជុំគណៈលេខាធិការ ដែលមានអគ្គលេខាធិការ ឬអគ្គលេខាធិការរងរួមនឹងលេខាធិការ២នាក់ទៀត ត្រូវ

[597] ប្រការ១២ថ្មីបទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

ត្រួតពិនិត្យឲ្យច្បាស់ថា គឺគ្មានមនុស្សដទៃនៅក្នុងសាលប្រជុំ ប្រសិនបើក្រុមប្រឹក្សាធម្មនុញ្ញ បានសម្រេចថា ត្រូវប្រជុំជាសម្ងាត់។[598]

មុននឹងចាប់ផ្តើមសម័យប្រជុំក្រុមប្រឹក្សាធម្មនុញ្ញត្រូវអនុម័តនូវរបៀបវារៈ និងសមាសភាពលេខាធិការ ដែលត្រូវចូលរួមជាមួយអគ្គលេខាធិការ ឬអគ្គលេខាធិការរង។

ការប្រជុំត្រូវធ្វើតាមរបៀបវារៈលើកលែងតែក្រុមប្រឹក្សាធម្មនុញ្ញសម្រេច ផ្សេងអំពីនេះ ក្នុងពេលប្រជុំនីមួយៗមានអគ្គលេខាធិការដោយមានលេខាធិការ ជាអ្នកជួយត្រូវស្រង់ឈ្មោះសមាជិកក្រុមប្រឹក្សាធម្មនុញ្ញដែលអវត្តមាន និងធ្វើកំណត់ហេតុនៃអង្គប្រជុំ។[599]

បើប្រធានយល់ឃើញថា ជាការមានប្រយោជន៍ ឬជាការចាំបាច់ប្រធានអាចលើកពេលនៃការប្រជុំបាន។

សមាជិកទាំងឡាយ ត្រូវទទួលការអនុញ្ញាត ពីប្រធានជាមុនសិន ទើបអាចនិយាយបានតាមលំដាប់លំដោយមុនក្រោយដែលកត់ត្រា ដោយគណៈលេខា សមាជិកម្នាក់ៗអាចនិយាយបានត្រឹមតែ១៥នាទីយ៉ាងច្រើនក្នុងពេលធ្វើអន្តរាគមន៍ម្តងៗ។

ហាមមិនឲ្យនិយាយកាត់ពាក្យអ្នកដទៃ មិនឲ្យនិយាយវាយប្រហារទៅលើបុគ្គល និងមិនឲ្យសម្តែងអាការៈផ្សេងៗដែលនាំឲ្យខូចសណ្តាប់ធ្នាប់នៅពេលប្រជុំ។

បើមានការជ្រួលច្របល់ក្នុងពេលប្រជុំហើយប្រធានហាមមិនស្តាប់នោះ ប្រធានអាចលើកពេលប្រជុំដោយដើរចេញពីសាលប្រជុំ។[600]

៣-អំពីការបញ្ចេញមតិ

(Expression)

នៅក្នុងបញ្ហាទាំងឡាយដែលត្រូវសម្រេចដោយក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបានអនុម័តដោយវិធីពីរយ៉ាងគឺដោយការលើកដៃ និងដោយការបោះឆ្នោតសម្ងាត់។[601]

ក្នុងការអនុម័តទាំងពីរយ៉ាងនេះ គណៈលេខាធិការដែលមានលេខាធិការ ជាអ្នកជួយរាប់ចំនួនសមាជិកក្រុមប្រឹក្សាដែលបានលើកដៃ ឬរាប់សន្លឹកឆ្នោតដែលសមាជិកក្រុមប្រឹក្សាធម្មនុញ្ញបានបោះឆ្នោត។

អគ្គលេខាធិការ ត្រូវតែរាយការណ៍ជូនប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីធ្វើការប្រកាសអំពី

---

[598] ប្រការ១៣ថ្មីបទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

[599] ប្រការ១៤បទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

[600] ប្រការ១៥បទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

[601] ប្រការ១៦បទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

លទ្ធផលជូនអង្គប្រជុំស្តាប់[602]។

ការអនុម័តទាំងឡាយរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវតែយកតាមមតិភាគច្រើនដាច់ខាតនៃសមាជិកទាំងមូល(ដែលមានចំនួន៥សំលេងយ៉ាងតិច)។ លើកលែងតែ ការសម្រេចដកសមាជិកក្រុមប្រឹក្សាធម្មនុញ្ញណាម្នាក់ ដែលត្រូវអនុម័តដោយមតិភាគច្រើនពីរភាគបីនៃចំនួនសមាជិកក្រុមប្រឹក្សាទាំងមូល(ដែលមានចំនួន៦សម្លេងយ៉ាងតិច)។[603]

ករណីការអនុម័តដោយមតិភាគច្រើនដាច់ខាតនៃសមាជិកទាំងមូល បើចំនួនមតិយល់ព្រម និងចំនួនមតិ មិនយល់ព្រម គឺមានចំនួនស្មើគ្នានោះ។ សម្លេងរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញត្រូវមានឧត្តមានុភាព។[604]

ការបោះឆ្នោតជាសម្ងាត់ដោយសន្លឹកឆ្នោតមាន៣ពណ៌:[605]

-ពណ៌ "ខៀវ" សំគាល់ថា ជាការមិនយល់ព្រម

-ពណ៌ "ស" សំគាល់ថា ជាការយល់ព្រម

-ពណ៌ "ស ឆ្នូត ខៀវ" សំគាល់ថា ជាអនុប្បវាទ។

៤-អំពីការខានមកប្រជុំ

(The Absence of Meeting)

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញមិនអាចអវត្តមាន ដោយគ្មានការអនុញ្ញាត អំពីប្រធានក្រុមប្រឹក្សាបានឡើយ។ ប្រធានក្រុមប្រឹក្សាមានសិទ្ធិអាចអនុញ្ញាតឲ្យសមាជិកឈប់សម្រាកយ៉ាងយូរបំផុត១៥ថ្ងៃ។ ការឈប់សម្រាកលើសរយៈពេលពី១៥ថ្ងៃទៅត្រូវសុំឲ្យអង្គប្រជុំក្រុមប្រឹក្សាធម្មនុញ្ញអនុម័តយល់ព្រមជាមុនសិន។

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញដែលមានជំងឺរយៈពេល៥ថ្ងៃជាប់ៗគ្នាត្រូវមានសំបុត្រពេទ្យជាសំអាង។[606]

៥-អំពីការដាក់ទិន្ន័យ

(Regulations)

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញដែលមិនគោរពតាមបទប្បញ្ញត្តិនៃច្បាប់ស្តីអំពីការរៀបចំ និង

---

[602] ប្រការ១៧បទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

[603] ប្រការ១៨ថ្មីបទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

[604] ប្រការ១៩បទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

[605] ប្រការ២០បទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

[606] ប្រការ២១បទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវផ្តន្ទាទោសខាងបទវិន័យដោយពុំទាន់បានគិតដល់ទោសព្រហ្មទណ្ឌដាយថាហេតុ។

សមាជិកដែលមិនគោរពបទបញ្ជាផ្ទៃក្នុងត្រូវផ្តន្ទាទោសខាងបទវិន័យ ដែលទណ្ឌកម្មខាងវិន័យចំពោះក្រុមប្រឹក្សាធម្មនុញ្ញរួមមាន:

-ក្រើនរំឭកដោយប្រធានក្រុមប្រឹក្សាធម្មនុញ្ញ។

-ក្រើនរំឭកដោយចុះកំណត់ហេតុនៅលើកទី២ដោយប្រធានក្រុមប្រឹក្សា។

-ស្តីបន្ទោសដោយមានធ្វើជាលាយលក្ខណ៍អក្សរ។[607]

សមាជិកណាដែលត្រូវបានក្រើនរំឭក៣ដងហើយ នៅតែប្រព្រឹត្តខុសទៀត ត្រូវក្រើនរំឭកដោយមានចុះក្នុងកំណត់ហេតុ។ ក្រោយអំពីការដាក់វិន័យនេះហើយ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវកាត់ប្រាក់បំណាច់ប្រចាំខែរបស់សមាជិកនោះចំនួន១ភាគ៤។[608]

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវដាក់ទណ្ឌកម្មវិន័យស្តីបន្ទោសចំពោះសមាជិកណា:

-នាំឲ្យជ្រួលច្របល់ក្នុងសាលប្រជុំ ឬក្រៅសាលប្រជុំ ឬនាំអាទិ៍ឲ្យសមាជិកជាច្រើននាក់មិនចូលរួមធ្វើការក្នុងក្រុមប្រឹក្សាធម្មនុញ្ញ។

-ប្រមាថមើលងាយបង្កជម្លោះ ឬគម្រាមកំហែងសមាជិកដទៃទៀត ឬញុះញង់សមាជិកឯទៀតឲ្យប្រើអំពើហឹង្សា។

-មើលងាយក្រុមប្រឹក្សាធម្មនុញ្ញ ឬប្រធានក្រុមប្រឹក្សាធម្មនុញ្ញ។

-ប្រមាថមើលងាយព្រះមហាក្សត្រ

ការដាក់វិន័យដល់សមាជិក ចំពោះរូបភាពជាការស្តីបន្ទោសរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវកាត់ប្រាក់បំណាច់ប្រចាំខែរបស់សមាជិករូបនោះចំនួន៥0%រយៈពេលពីរខែ។

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ដែលត្រូវទទួលវិន័យ ចំពោះការស្តីបន្ទោសតាមបទបញ្ជាផ្ទៃក្នុងនេះ ក្រោយពីបានទទួលសំណុំរឿងផ្ទាល់ខ្លួន សមាជិកដែលទទួលការស្តីបន្ទោស ត្រូវធ្វើការឆ្លើយដោះសាក្នុងរយៈពេល៥ថ្ងៃ ប្រសិនបើផុតកំណត់រយៈពេលនេះ ទោះបីសាមីខ្លួនធ្វើការឆ្លើយដោះសា ឬមិនដោះសាក្តី ក្រុមប្រឹក្សាធម្មនុញ្ញត្រូវតែសម្រេចដាក់វិន័យ ដោយមតិភាគច្រើនដាច់ខាតនៃសមាជិកទាំងមូលដែលមានចំនួន៥សម្លេងយ៉ាងតិច បើសិនចំនួនមតិយល់ព្រម និងមិនយល់ព្រមស្មើគ្នា សម្លេងរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញត្រូវមានឧត្តមានុភាព។[609]

---

[607] ប្រការ២២បទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

[608] ប្រការ២៤បទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

[609] ប្រការ២៦ថ្មីបទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

ការដកសមាជិកណាមួយពីក្រុមប្រឹក្សាធម្មនុញ្ញត្រូវអនុវត្តន៍:

ការសម្រេចដកសមាជិកក្រុមប្រឹក្សាធម្មនុញ្ញណាមួយ ចេញពីតំណែង គឺតម្រូវឲ្យមានការយល់ព្រមពីសមាជិកចំនួនពីរភាគបីនៃសមាជិកក្រុមប្រឹក្សាធម្មនុញ្ញទាំងមូល។

ការសម្រេចដក សមាជិកក្រុមប្រឹក្សាធម្មនុញ្ញណា ដែលត្រូវបានតុលាការកាត់ទោសដាក់ពន្ធនាគារពីបទមជ្ឈិម ឬឧក្រិដ្ឋត្រូវដកចេញពីមុខតំណែងជាស្វ័យប្រវត្តិ។

ការសុំលាឈប់ពីតំណែងរបស់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ អាចប្រព្រឹត្តទៅបានលុះត្រាតែសមាជិកនោះ បានជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រុមប្រឹក្សាធម្មនុញ្ញ និងក្រោយពីស្ថាប័នមានសមត្ថកិច្ច ត្រូវបានតែងតាំង ឬជ្រើសតាំងជំនួស។ ក្នុងករណីនេះ ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវតែជូនដំណឹងភ្លាមទៅឲ្យស្ថាប័នដែលមានសមត្ថកិច្ចតែងតាំង ឬជ្រើសតាំងដើម្បីឲ្យស្ថាប័នទាំងនោះតែងតាំង ឬជ្រើសតាំងសមាជិកថ្មីមកជំនួសភ្លាម។[610]

ឈ.ទិសមិតភាពនៃក្រុមប្រឹក្សាធម្មនុញ្ញ

(Incompatibility of Constitutional Council)

មុខងាររបស់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញមានវិសមិតភាពនឹងមុខងារ សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា សមាជិករាជរដ្ឋាភិបាល ចៅក្រមក្នុងមុខតំណែង ឬការកាន់តំណែងណាមួយនៅក្នុងមុខងារសាធារណៈ ប្រធាន និងអនុប្រធានគណបក្សនយោបាយ និងប្រធានអនុប្រធានសហជីព។[611]

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ គឺមិនត្រូវបំពេញមុខតំណែង និងមុខរបរផ្សេងទៀត នៅក្នុងអាណត្តិរបស់ខ្លួនឡើយ។[612]

អ្នកដែលបានតែងតាំងជាសមាជិកនៃក្រុមប្រឹក្សាធម្មនុញ្ញ មុនចូលកាន់តំណែងត្រូវសុំលាឈប់ជាបណ្តោះអាសន្ននូវតំណែង ឬមុខរបរផ្សេងៗទាំងអស់ ដែលបានចែងក្នុងវាក្យខ័ណ្ឌខាងលើ។ ប្រធានក្រុមប្រឹក្សាធម្មនុញ្ញត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅសមាជិកដែលស្ថិតនៅក្នុងមុខតំណែង និងមុខរបរខាងលើឲ្យសុំលាឈប់ពីមុខតំណែង ឬមុខរបរនោះជាបន្ទាន់។[613]

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មិនត្រូវធ្វើនិទ្ទេសអំពីតួនាទីរបស់ខ្លួនជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងឯកសារនានាដែលអាចយកទៅបោះពុម្ពផ្សាយ និងទាក់ទងទៅនឹងគ្រប់សកម្មភាព

---

[610] ប្រការ២៧បទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

[611] មាត្រា១៣៩ថ្មីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[612] មាត្រា៥ថ្មីច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

[613] មាត្រា៥ថ្មីច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

ជាសាធារណៈ ឬជាឯកជន។[614]

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវឲ្យប្រធានដឹងអំពីការផ្លាស់ប្តូរដែលអាចកើតឡើងនៅក្នុងសកម្មភាពវិជ្ជាជីវៈ ឬមុខរបរខ្លួនខាងក្រៅក្រុមប្រឹក្សាធម្មនុញ្ញ។[615]

ជាទូទៅវិសមិតភាពរបស់ក្រុមប្រឹក្សាធម្មនុញ្ញ មានលក្ខណៈទូទៅ និងមានការកំណត់នៅក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ រួមទាំងលិខិតបទដ្ឋានគតិយុត្តិនានាដែលបានហាមឃាត់មិនឲ្យក្រុមប្រឹក្សាធម្មនុញ្ញបំពេញសកម្មភាពការងារជាសាធារណៈ ឬក៏សកម្មភាពការងារឯកជនផ្សេងៗនៅក្នុងអាណត្តិរបស់ខ្លួនឡើយ។

ញ.អត័យឯកសិទ្ធិ

(Immunity)

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញមិនអាចទទួលខុសត្រូវបទល្មើសព្រហ្មទណ្ឌ ឬបទរដ្ឋប្បវេណីណាមួយ ចំពោះការសម្រេចដែលបានធ្វើឡើង នៅក្នុងកាលៈទេសៈជាសមាជិករបស់ក្រុមប្រឹក្សាបំពេញភារកិច្ចជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញឡើយ។[616]

ក្រុមប្រឹក្សាធម្មនុញ្ញ អាចដកចេញពីតំណែងសមាជិកណា ដែលបានរំលោភលើមុខងារសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មានវិសមិតភាពជាមួយនឹងមុខងារជាសមាជិករាជរដ្ឋាភិបាល សមាជិករដ្ឋសភា សមាជិកព្រឹទ្ធសភា ប្រធាន និងអនុ ប្រធានគណបក្សនយោបាយ ប្រធាន និងអនុប្រធានសហជីព និងចៅក្រមក្នុងមុខតំណែង។

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញគឺមិនត្រូវបំពេញមុខតំណែង និងមុខរបរផ្សេងទៀតនៅក្នុងអាណត្តិរបស់ខ្លួនឡើយ។ មុននឹងចូលកាន់តំណែងជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ចាំបាច់ត្រូវធ្វើសច្ចាប្រណិធាន។

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញត្រូវរក្សាការសម្ងាត់ក្នុងការពិភាក្សា និងការបោះឆ្នោត ហើយមិនត្រូវបញ្ចេញយោបល់របស់ខ្លួននៅក្រៅអង្គប្រជុំទេ ឬក៏មិនបានមកប្រជុំលើសពី៣ដងផ្តួនៗគ្នាដោយឥតជូនដំណឹងជាមុន ឬក៏មិនអាចបំពេញមុខងារជារៀងរហូតបាន ដោយបាត់បង់សមត្ថភាពខាងបញ្ញា ឬរូបរាងកាយជាអចិន្ត្រៃយ៍។

ការសម្រេចដក សមាជិកក្រុមប្រឹក្សាធម្មនុញ្ញណាមួយពីតំណែង គឺតម្រូវឲ្យមានការយល់ព្រមពីសមាជិកចំនួនពីរភាគបីនៃសមាជិកក្រុមប្រឹក្សាធម្មនុញ្ញទាំងមូល។

---

[614] ប្រការ៤បទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

[615] ប្រការ៥បទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

[616] មាត្រា១១ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញណា ដែលត្រូវបានតុលាការកាត់ទោសដាក់ពន្ធនាគារអំពីបទមជ្ឈឹម ឬបទឧក្រិដ្ឋ សមាជិកនោះត្រូវដកចេញពីមុខតំណែងជាស្វ័យប្រវត្តិ។[617]

៨.ឋានៈ និងបុព្វសិទ្ធិ

(Rank and Prerogatives)

-ប្រធានក្រុមប្រឹក្សាធម្មនុញ្ញមានឋានៈ និងបុព្វសិទ្ធិស្មើប្រធានរដ្ឋសភា

-សមាជិកក្រុមប្រឹក្សាធម្មនុញ្ញមានឋានៈ និងបុព្វសិទ្ធិស្មើអនុប្រធានរដ្ឋសភា

៩.អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

(Secretary General Constitutional Council)

១-សញ្ញាណទូទៅ

(Notion)

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ជាសេនាធិការបម្រើការងារសេវារដ្ឋបាលនានាឲ្យក្រុមប្រឹក្សាធម្មនុញ្ញនៅព្រះរាជាណាចក្រកម្ពុជាយើង។

មន្ត្រីបុគ្គលិក ដែលបានបម្រើការងារនៅអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញគឺជាមន្ត្រីជាប់កិច្ចសន្យា នៅពេលចប់នីតិកាលរបស់ក្រុមប្រឹក្សាធម្មនុញ្ញ មន្ត្រីទាំងនោះ ត្រូវបញ្ចប់ការងាររបស់ខ្លួនហើយអាចវិលត្រឡប់ទៅបំពេញការងារនៅកន្លែងដើមវិញ។

រហូតមកដល់ខែមករា ឆ្នាំ២០០៣ រដ្ឋសភាជាតិនៃព្រះរាជាណាចក្រកម្ពុជា បានអនុម័តច្បាប់មួយស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិបញ្ញត្តិដោយច្បាប់នេះ ត្រូវបានអនុវត្តន៍ចំពោះមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ។[618]

ហេតុនេះ មន្ត្រីទាំងអស់របស់អគ្គលេខាធិការដ្ឋាន ត្រូវតែអនុវត្តន៍តាមច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិបញ្ញត្តិនេះទាំងអស់គ្នាដែលក្នុងនោះមានមន្ត្រីអចិន្ត្រៃយ៍ និងមានមន្ត្រីជាប់កិច្ចសន្យា ឬបុគ្គលិកអណ្តែត។

អ្នករាជការនៃក្រុមនីតិបញ្ញត្តិ ត្រូវគោរពគោលការណ៍អព្យាក្រិត្យ និងមិនប្រកាន់និន្នាការគណបក្សនយោបាយនៅក្នុងការបំពេញការងាររបស់ខ្លួន។[619]

២-អគ្គលេខាធិការដ្ឋាន

(Secretariat General)

---

[617] មាត្រា១០ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

[618] មាត្រា១ច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ។

[619] មាត្រា២ច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ។

ក្រុមប្រឹក្សាធម្មនុញ្ញមានអគ្គលេខាធិការដ្ឋានមួយ ដែលទទួលបន្ទុករៀបចំចាត់ចែងកិច្ចការរដ្ឋបាលធ្វើកំណត់ហេតុផ្សេងៗរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញត្រូវទទួលរ៉ាប់រងនូវគ្រប់កិច្ចការរដ្ឋបាល និងសេវាកម្មនានាជូនក្រុមប្រឹក្សាធម្មនុញ្ញ និងក្រុមនៃក្រុមប្រឹក្សាទាំងអស់ ព្រមទាំងធ្វើការទំនាក់ទំនងលើបញ្ហាការងារផ្សេងៗ ជាមួយបណ្តាអង្គការរដ្ឋនានាក្រៅអំពីក្រុមប្រឹក្សាធម្មនុញ្ញ។[620]

អគ្គលេខាធិការដ្ឋានត្រូវបានដឹកនាំដោយអគ្គលេខាធិការមួយរូប និងអមដោយអគ្គលេខាធិការរងមួយរូប។ អគ្គលេខាធិការ និងអគ្គលេខាធិការរង ត្រូវបានតែងតាំង ដោយព្រះរាជក្រឹត្យតាមសេចក្តីស្នើពីប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ដែលអគ្គលេខាធិការក្រុមប្រឹក្សាធម្មនុញ្ញគឺមានឋានៈស្មើនឹងរដ្ឋលេខាធិការ ចំណែកឯអគ្គលេខាធិការរងក្រុមប្រឹក្សាធម្មនុញ្ញ គឺមានឋានៈស្មើនឹងអនុរដ្ឋលេខាធិការ។[621]

អគ្គលេខាធិការ និងអគ្គលេខាធិការរង ត្រូវបានជ្រើសតាំងនៅក្នុងចំណោមមន្ត្រីជាន់ខ្ពស់ដែលមានបទពិសោធន៍ ក្នុងការងារកិច្ចការរដ្ឋបាលយ៉ាងតិចដប់ឆ្នាំ ហើយមិនមែនជាសមាជិកនៃក្រុមប្រឹក្សាធម្មនុញ្ញ និងមិនមែនជាអ្នកដឹកនាំគណបក្សនយោបាយណាមួយ។[622]

៣-ការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាន

(Functioning of Secretariat General)

ដើម្បីឲ្យអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធ្មនុញ្ញ អាចបំពេញសកម្មភាពការងារនានាបានប្រកបដោយប្រសិទ្ធភាពខ្ពស់ដែលជាសេនាធិការបម្រើការងារ និងផ្តល់សេវារដ្ឋបាលឲ្យក្រុមប្រឹក្សាធម្មនុញ្ញនោះ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវមានរចនាសម្ព័ន្ធគ្រប់គ្រង និងបំណែងចែកភារកិច្ចនានាឲ្យបានច្បាស់លាស់ ការរៀបចំនិងចាត់ចែងការងារទាំងនេះត្រូវដឹកនាំដោយអគ្គលេខាធិការ និងអគ្គលេខាធិការរងក្រុមប្រឹក្សាធម្មនុញ្ញ និងមានការឯកភាពយល់ព្រមអំពីប្រធានក្រុមប្រឹក្សាធម្មនុញ្ញ។

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិអំណាច ក្នុងការប្រគល់ឲ្យអគ្គលេខាធិការដ្ឋានទទួលបន្ទុករៀបចំចាត់ចែងការងារធ្វើកំណត់ហេតុ និងទទួលរ៉ាប់រង នូវគ្រប់កិច្ចការរដ្ឋបាលទាំងអស់នៃក្រុមប្រឹក្សាធម្មនុញ្ញ។[623]

---

[620] ប្រការ១៥បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

[621] មាត្រា៣អនុក្រឹត្យស្តីពីការបង្កើតអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ។

[622] មាត្រា២អនុក្រឹត្យស្តីពីការបង្កើតអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ។

[623] មាត្រា១អនុក្រឹត្យស្តីពីការបង្កើតអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ។

អគ្គលេខាធិការដ្ឋាន ត្រូវមានរចនាសម្ព័ន្ធមួយ ដែលមានអគ្គនាយកដ្ឋាន ឬថ្នាក់ប្រហាក់ប្រហែលនឹងនាយកដ្ឋាន ឬថ្នាក់ប្រហាក់ប្រហែលមួយចំនួនសម្រាប់ជួយការងារនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ។[624]

សព្វថ្ងៃអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបានបង្កើតឲ្យមាននាយកដ្ឋានចំនួនប្រាំមួយ៦ដែលរួមមាន:

-នាយកដ្ឋានរដ្ឋបាល

-នាយកដ្ឋានហិរញ្ញកិច្ច និងបុគ្គលិក

-នាយកដ្ឋានច្បាប់ និងវិវាទកម្ម

-នាយកដ្ឋានព័ត៌មានវិទ្យា និងបកប្រែភាសា

-នាយកដ្ឋានស្រាវជ្រាវតម្កល់ឯកសារ និងបណ្ណាល័យ

-នាយកដ្ឋានសវនកម្មផ្ទៃក្នុង

មន្ត្រីបុគ្គលិកនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបានជ្រើសរើស និងតែងតាំងដោយប្រធានក្រុមប្រឹក្សាធម្មនុញ្ញតាមសំណើរបស់អគ្គលេខាធិការ។

មន្ត្រីបុគ្គលិកនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញអាចធ្វើការជ្រើសរើសថ្មី ឬផ្ទេរចេញពីស្ថាប័នផ្សេងៗទៀតក៏បាន។

មន្ត្រីបុគ្គលិករាជការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ទទួលបាននូវប្រាក់បៀវត្សរ៍ និងប្រាក់ឧបត្ថម្ភផ្សេងៗទៀតស្មើនឹងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា និងព្រឹទ្ធសភា។[625]

៤-តួនាទី និងភារកិច្ចអគ្គលេខាធិការ

(Roles and Duties Secretary General)

អគ្គលេខាធិការក្រុមប្រឹក្សាធម្មនុញ្ញមានតួនាទី និងភារកិច្ចដូចតទៅ:

-អគ្គលេខាធិការ និងអគ្គលេខាធិការរង ត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវអំពីប្រធានក្រុមប្រឹក្សាធម្មនុញ្ញ។

-អគ្គលេខាធិការក្រុមប្រឹក្សាធម្មនុញ្ញ ជាអ្នកដឹកនាំគ្រប់គ្រង និងចាត់ចែង ការងាររដ្ឋបាលរបស់ក្រុមប្រឹក្សាធម្មនុញ្ញក្រោមការណែនាំអំពីប្រធានក្រុមប្រឹក្សាធម្មនុញ្ញ។

-អគ្គលេខាធិការក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលសិទ្ធិអំពីប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីចុះហត្ថលេខាលើលិខិតបទដ្ឋាន ឬសេចក្តីសម្រេចរដ្ឋបាលផ្សេងៗ របស់អគ្គលេខាធិការដ្ឋានក្រុម

[624] មាត្រា៤ថ្មីអនុក្រឹត្យស្តីពីការបង្កើតអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ។

[625] មាត្រា៤ថ្មីអនុក្រឹត្យស្តីពីការបង្កើតអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ។

ប្រឹក្សាធម្មនុញ្ញទាំងមូល។[626]

-អគ្គលេខាធិការក្រុមប្រឹក្សាធម្មនុញ្ញ ជាអ្នកលើកសំណើ ទៅប្រធានក្រុមប្រឹក្សា ដើម្បីធ្វើការជ្រើសរើសនិងតែងតាំងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានទាំងមូល។[627]

-អគ្គលេខាធិការក្រុមប្រឹក្សាធម្មនុញ្ញ ជាអ្នករៀបចំធ្វើកំណត់ហេតុនានា គ្រប់ការប្រជុំ និងស្រង់ឈ្មោះសមាជិករបស់ក្រុមប្រឹក្សាធម្មនុញ្ញដែលអវត្តមាន។[628]

-អគ្គលេខាធិការក្រុមប្រឹក្សាធម្មនុញ្ញ ជាអ្នករៀបចំគម្រោងសម្រង់បញ្ជីឈ្មោះមន្ត្រីបុគ្គលិកនៅតាមការិយាល័យនានាដែលមានស្នាដៃ និងគុណបំណាច់ខ្ពស់នៅក្នុងការបំពេញការកិច្ចជូនក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីឲ្យគណៈកម្មការវាយតម្លៃ រួចហើយទើបស្នើសុំទៅប្រធានក្រុមប្រឹក្សាធម្មនុញ្ញធ្វើការបំពាក់គ្រឿងឥស្សរិយយសជូនដល់មន្ត្រីរាជការដែលមានស្នាដៃល្អ។[629]

-អគ្គលេខាធិការក្រុមប្រឹក្សាធម្មនុញ្ញ ជាអ្នកគ្រប់គ្រងមន្ត្រីរាជការ បុគ្គលិកទាំងអស់នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ។

-អគ្គលេខាធិការក្រុមប្រឹក្សាធម្មនុញ្ញ គឺជាអ្នកគ្រប់គ្រងថែរក្សាទ្រព្យសម្បត្តិទាំងអស់របស់ក្រុមប្រឹក្សាធម្មនុញ្ញ។

-អគ្គលេខាធិការក្រុមប្រឹក្សាធម្មនុញ្ញគឺជាអ្នករៀបចំសណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខអនាម័យនៅក្នុងបរិវេណស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញទាំងមូល។

-អគ្គលេខាធិការក្រុមប្រឹក្សាធម្មនុញ្ញ ជាអ្នកគ្រប់គ្រងបញ្ជាផ្ទាល់ទៅលើការចំណាយផ្សេងៗរបស់អគ្គលេខាធិការដ្ឋាន ដោយមានការរួមសហការជាមួយ នឹងនាយកដ្ឋានរដ្ឋបាល និងនាយកដ្ឋានហិរញ្ញកិច្ច និងបុគ្គលិកនៃក្រុមប្រឹក្សាធម្មនុញ្ញ។

-អគ្គលេខាធិការ ក្រុមប្រឹក្សាធម្មនុញ្ញ ជាអ្នករៀបចំ និងរក្សាកំណត់ហេតុ រួមទាំងឯកសារផ្សេងៗរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ហើយធានាមិនឲ្យបែកខ្ញែរខ្ចាយទៅក្រៅ ដោយគ្មានការអនុញ្ញាតពីប្រធានក្រុមប្រឹក្សាធម្មនុញ្ញឡើយ។[630]

---

[626] មាត្រា២អនុក្រឹត្យស្តីពីការបង្កើតអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ។

[627] មាត្រា៤ថ្មីអនុក្រឹត្យស្តីពីការបង្កើតអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ

[628] ប្រការ១៤បទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

[629] មាត្រា៣៦ច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ។

[630] មាត្រា៦អនុក្រឹត្យស្តីពីការបង្កើតអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ។

ផ្នែកទី៦

សមាជជាតិ

(National Congress)

នៅក្នុងជំពូកទី១៤នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បានកំណត់ឲ្យមានសមាជជាតិ។ ទោះបីជាសមាជជាតិនោះ តាមផ្លូវបច្ចេកទេសមិនមែនជាផ្នែកមួយនៃអង្គការនីតិប្បញ្ញត្តិក៏ដោយ ក៏គេចាត់ទុកថាជា “គណៈកម្មាធិការផ្តល់យោបល់របស់ប្រជាពលរដ្ឋ” ដូចរដ្ឋសភាជាតិដែរ។

គោលបំណងនៃការធ្វើសមាជជាតិគឺដើម្បីធ្វើឲ្យពលរដ្ឋបានជ្រាប ដោយផ្តាល់អំពីកិច្ចការទាំងឡាយដែលជាប្រយោជន៍ជាតិ និងផ្តល់វេទិការជូនប្រជាពលរដ្ឋម្នាក់ៗដើម្បីមានឱកាសលើកនូវបញ្ហាផ្សេងៗ ដែលប្រជាពលរដ្ឋទាំងនោះកំពុងជួបការលំបាក និងដើម្បីលើកជាសំណូមពរជូនចំពោះរាជរដ្ឋាភិបាលដើម្បីធ្វើការដោះស្រាយ។

ប្រជារាស្ត្រខ្មែរទាំងពីរភេទមានសិទ្ធិទៅចូលរួមក្នុងសមាជជាតិ។[631]

សមាជជាតិ ត្រូវបើកធ្វើឡើងជារៀងរាល់ឆ្នាំ១ដងក្នុង១ឆ្នាំនៅដើមខែធ្នូតាមរយៈការកោះអញ្ជើញរបស់នាយករដ្ឋមន្ត្រី ហើយត្រូវស្ថិតនៅក្រោមព្រះរាជអធិបតីភាពរបស់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។[632]

សមាជជាតិគឺមិនអាចធ្វើច្បាប់ទេ ប៉ុន្តែអាចអនុម័តសេចក្តីស្នើយោបល់សម្រាប់ឲ្យរាជរដ្ឋាភិបាល ឬរដ្ឋសភា ឬក៏ព្រឹទ្ធសភាធ្វើការពិចារណា។[633]

ទោះបីជារដ្ឋធម្មនុញ្ញនៅឆ្នាំ១៩៩៣ បានបង្កើតឲ្យមានស្ថាប័នសមាជជាតិនេះក៏ដោយ ក៏ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសមាជជាតិ នៅមិនទាន់បានរៀបចំបង្កើត និងអនុម័តនៅឡើយដែរ។

ហេតុនេះទើបមកដល់ពេលបច្ចុប្បន្នរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាពុំទាន់បានរៀបចំធ្វើសមាជជាតិម្តងណាឡើយ។

---

[631] មាត្រា១៤៧ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[632] មាត្រា១៤៨ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[633] មាត្រា១៤៩ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

ឧបសម្ព័ន្ធទី១

ទង់ជាតិ



ឧបសម្ព័ន្ធទី២

ភ្លេងជាតិនគរាជ

១.	សូមពួកទេព្តា	រក្សា មហាក្សត្រយើង
	ឲ្យ បានរុងរឿង	ជោគជ័យមង្គល សិរីសួស្តី
	យើងខ្ញុំព្រះអង្គ	សូមជ្រក ក្រោមម្លប់ព្រះបារមី
	នៃព្រះន-របតី	វង្សក្សត្រាដែលសាងប្រាសាទថ្ម
	គ្រប់គ្រងដែនខ្មែរ	បុរាណប្តើងថ្កាន ។
២.	ប្រាសាទសីលា	កំបាំងកណ្តាលព្រៃ
	គួរអោយស្រមៃ	នឹកដល់យសសក្តិ មហានគរ
	ជាតិខ្មែរដូចថ្ម	គង់វង់នៅល្អ រឹងប៉ឹងជំហរ
	យើងសង្ឃឹមពរ	ភ័ព្វព្រេងសំណាងរបស់កម្ពុជា
	មហារដ្ឋកើតមាន	យូរអង្វែងហើយ ។
៣.	គ្រប់វត្តអារាម	ឮតែសូរសព្ទធម៌
	សូត្រដោយអំណរ	រំឭកគុណពុទ្ធសាសនា

ចូរយើងជាអ្នក ជឿជាក់ស្មោះស្ម័គ្រ តាមបែបដូនតា
គង់តែទេវតា នឹងជួយជ្រោមជ្រែង ផ្តត់ផ្តង់ប្រយោជន៍ឲ្យ
ដល់ប្រទេសខ្មែរ ជាមហានគរ ។

ឧបសម្ព័ន្ធទី៣

សញ្ញាជាតិ

ឧបសម្ព័ន្ធទី៤

សច្ចាប្រណិធាន

នៃ

ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

ខ្ញុំតាំងសច្ចាថា និងប្រព្រឹត្តតាមរដ្ឋធម្មនុញ្ញ

និងច្បាប់ទាំងឡាយនៃព្រះរាជាណាចក្រកម្ពុជា

ហើយនឹងតាំងចិត្តធ្វើផលប្រយោជន៍ដល់រដ្ឋ និងប្រជារាស្ត្រ ។

ឧបសម្ព័ន្ធទី៥

សច្ចាប្រណិធាន

ទូលព្រះបង្គំ
យើងខ្ញុំ
ប្រធាន អនុប្រធាន និងសមាជិកឧត្តមសភានៃព្រះរាជាណាចក្រកម្ពុជា

សូមធ្វើសច្ចាប្រណិធាន
នៅចំពោះប្រភ័ក្ត្រព្រះមហាក្សត្រ ព្រះភ័ក្ត្រនៃសម្តេចព្រះសង្ឃរាជ
និងទេវតារក្សាស្វែតច្ឆត្រដូចតទៅ ៖

ក្នុងពេលប្រតិបត្តិការតាមមុខតំណែងខ្លួន និងក្នុងការបំពេញបេសកម្មដែលប្រជារាស្ត្រខ្មែរបានប្រគល់ជូនចំពោះទូលព្រះបង្គំយើងខ្ញុំគ្រប់ៗរូបទូលព្រះបង្គំយើងខ្ញុំសុំប្តេជ្ញាគោរពរដ្ឋធម្មនុញ្ញ បម្រើជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគតនូវផលប្រយោជន៍របស់ប្រជារាស្ត្រប្រជាជាតិ និងមាតុភូមិកម្ពុជា។ ទូលព្រះបង្គំយើងខ្ញុំសូមសច្ចាថាមិនកេងប្រវ័ញ្ចនូវផលប្រយោជន៍របស់ប្រជារាស្ត្រសម្រាប់ផ្ទាល់ខ្លួន ឬសម្រាប់គ្រួសារ ឬសម្រាប់បក្សពួក ឬសម្រាប់ភាគីរៀងៗខ្លួនឡើយ។

ទូលព្រះបង្គំយើងខ្ញុំសូមប្តេជ្ញាប្តូរផ្តាច់ហ៊ានបូជាជីវិតដើម្បីការពារជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគតនូវ៖

- ឯករាជ្យភាពទាំងស្រុងនៃមាតុភូមិកម្ពុជា
- អធិបតេយ្យភាពជាតិពេញបរិបូរណ៌
- បូរណភាពទឹកដីដ៏ត្រឹមត្រូវតាមច្បាប់នៅក្នុងព្រំដែនដីគោក និងព្រំដែនសមុទ្រដែលកម្ពុជាធ្លាប់មានក្នុងជំនាន់ឆ្នាំ១៩៦៣ដល់ឆ្នាំ១៩៦៩។
- ឯកភាពជាតិហើយមិនអនុញ្ញាតឲ្យមានការបែងចែក ឬការធ្វើអបគមន៍ណាមួយឡើយ។
- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញារក្សាទុកជានិច្ចទាំងក្នុងបច្ចុប្បន្នទាំងក្នុងអនាគតនូវអព្យាក្រឹត្យភាព និងភាពមិនចូលបក្សសម្ព័ន្ធសម្រាប់កម្ពុជា ហើយមិនអនុញ្ញាតជាដាច់ខាត ឲ្យជនណាក៏ដោយ ដែលចង់ជ្រៀតជ្រែកចូលក្នុងផ្ទៃក្នុងនៃកម្ពុជា ឬមកបង្គាប់បញ្ជាចំពោះគោលនយោបាយជាតិ និងអន្តរជាតិរបស់កម្ពុជាឡើយ។ ទូលព្រះបង្គំយើងខ្ញុំ មិនបម្រើដាច់ខាតនូវផលប្រយោជន៍បរទេស ហើយធ្វើឲ្យខូតខាតដល់ផលប្រយោជន៍ប្រជារាស្ត្រប្រជាជាតិ និងមាតុភូមិកម្ពុជាឡើយ។

-ក្នុងការដោះស្រាយបញ្ហាទាំងឡាយលើផ្នែករាបជាតិ និងអន្តរជាតិ ទូលព្រះបង្គំយើងខ្ញុំបំបាត់ចោលទាំងស្រុងនូវអំពើហឹង្សាគ្រប់បែបយ៉ាង។ ប៉ុន្តែព្រះរាជាណាចក្រកម្ពុជាសូមរក្សាទុកនូវសិទ្ធិកាន់អាវុធតស៊ូប្រឆាំង និងការរំលោភឈ្លានពានមកពីក្រៅដើម្បីការពារជាតិមាតុភូមិខ្លួន។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាគោរពជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវលទ្ធិប្រជាធិបតេយ្យសេរីនិយមដែលមានរបបសភា និងពហុបក្ស ព្រមទាំងមានការគោរពយ៉ាម៉ឺងម៉ាត់ចំពោះសិទ្ធិមនុស្ស ដូចមានចែងក្នុងសេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាតស៊ូប្រឆាំងអំពើពុករលួយគ្រប់បែបយ៉ាង ប្រឆាំងអយុត្តិធម៌សង្គមហើយតស៊ូដើម្បីផ្សះផ្សាជាតិ ដើម្បីឯកភាពជាតិដើម្បីសន្តិភាពសង្គម និងសន្តិភាពជាតិ ដើម្បីភាពសម្បូរសប្បាយនៃប្រជារាស្ត្រកម្ពុជា និងដើម្បីភាពរុងរឿងថ្កើនថ្កានៃមាតុភូមិកម្ពុជាជាទីគោរពសក្ការៈ និងជាទីស្នេហានៃទូលព្រះបង្គំយើងខ្ញុំគ្រប់រូប។

ឧបសម្ព័ន្ធទី៦

សច្ចាប្រណិធាន

ទូលព្រះបង្គំ
យើងខ្ញុំ
ឆាយករដ្ឋមន្ត្រី និងសមាជិករាជរដ្ឋាភិបាល

សូមធ្វើសច្ចាប្រណិធាន
នៅចំពោះប្រភ័ក្ត្រនៃសម្តេចព្រះសង្ឃរាជ
និងទេវតារក្សាស្វេតច្ឆត្រ
ដូចតទៅ ៖

ក្នុងពេលប្រតិបត្តិការតាមមុខតំណែងខ្លួន និងក្នុងការបំពេញបេសកម្មដែលប្រជារាស្ត្រខ្មែរបានប្រគល់ជូនចំពោះទូលព្រះបង្គំយើងខ្ញុំគ្រប់ៗរូបទូលព្រះបង្គំយើងខ្ញុំសុំប្តេជ្ញាគោរពរដ្ឋធម្មនុញ្ញ បម្រើជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគតនូវផលប្រយោជន៍របស់ប្រជារាស្ត្រប្រជាជាតិ និងមាតុភូមិកម្ពុជា។ ទូលព្រះបង្គំយើងខ្ញុំសូមសច្ចាថាមិនកេងប្រវ័ញ្ចនូវផលប្រយោជន៍របស់ប្រជារាស្ត្រសម្រាប់ផ្ទាល់ខ្លួន ឬសម្រាប់គ្រួសារ ឬសម្រាប់បក្សពួក ឬសម្រាប់ភាគីរៀងៗខ្លួនឡើយ។

ទូលព្រះបង្គំយើងខ្ញុំសូមប្តេជ្ញាប្តូរផ្តាច់ហ៊ានបូជាជីវិតដើម្បីការពារជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគតនូវ៖

- ឯករាជ្យភាពទាំងស្រុងនៃមាតុភូមិកម្ពុជា
- អធិបតេយ្យភាពជាតិពេញបរិបូរណ៌
- បូរណភាពទឹកដីដ៏ត្រឹមត្រូវតាមច្បាប់នៅក្នុងព្រំដែនដីគោក និងព្រំដែនសមុទ្រដែលកម្ពុជាធ្លាប់មានក្នុងដំនាន់ឆ្នាំ១៩៦៣ដល់ឆ្នាំ១៩៦៩។
- ឯកភាពជាតិហើយមិនអនុញ្ញាតឲ្យមានការបែងចែក ឬការធ្វើអបគមន៍ណាមួយឡើយ។
- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញារក្សាទុកជានិច្ចទាំងក្នុងបច្ចុប្បន្នទាំងក្នុងអនាគតនូវអព្យាក្រឹត្យភាព និងភាពមិនចូលបក្សសម្ព័ន្ធសម្រាប់កម្ពុជា ហើយមិនអនុញ្ញាតជាដាច់ខាត ឲ្យជនណាក៏ដោយ ដែលចង់ជ្រៀតជ្រែកចូលក្នុងផ្ទៃក្នុងនៃកម្ពុជា ឬមកបង្គាប់បញ្ជាចំពោះគោលនយោបាយជាតិ និងអន្តរជាតិរបស់កម្ពុជាឡើយ។ ទូលព្រះបង្គំយើងខ្ញុំ មិនបម្រើដាច់ខាតនូវផលប្រយោជន៍បរទេស ហើយធ្វើឲ្យខូតខាតដល់ផលប្រយោជន៍ប្រជារាស្ត្រប្រជាជាតិ និងមាតុភូមិកម្ពុជាឡើយ។

-ក្នុងការដោះស្រាយបញ្ហាទាំងឡាយលើផ្នែករាបជាតិ និងអន្តរជាតិ ទូលព្រះបង្គំយើងខ្ញុំបំបាត់ចោលទាំងស្រុងនូវអំពើហឹង្សាគ្រប់បែបយ៉ាង។ ប៉ុន្តែព្រះរាជាណាចក្រកម្ពុជាសូមរក្សាទុកនូវសិទ្ធិកាន់អាវុធតស៊ូប្រឆាំង និងការរំលោភឈ្លានពានមកពីក្រៅដើម្បីការពារជាតិមាតុភូមិខ្លួន។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាគោរពជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវលទ្ធិប្រជាធិបតេយ្យសេរីនិយមដែលមានរបបសភា និងពហុបក្ស ព្រមទាំងមានការគោរពយ៉ាម៉ឺងម៉ាត់ចំពោះសិទ្ធិមនុស្ស ដូចមានចែងក្នុងសេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាតស៊ូប្រឆាំងអំពើពុករលួយគ្រប់បែបយ៉ាង ប្រឆាំងអយុត្តិធម៌សង្គមហើយតស៊ូដើម្បីផ្សះផ្សាជាតិ ដើម្បីឯកភាពជាតិដើម្បីសន្តិភាពសង្គម និងសន្តិភាពជាតិដើម្បីភាពសម្បូរសប្បាយនៃប្រជារាស្ត្រកម្ពុជា និងដើម្បីភាពរុងរឿងថ្កើនថ្កានៃមាតុភូមិកម្ពុជាជាទីគោរពសក្ការៈ និងជាទីស្នេហានៃទូលព្រះបង្គំយើងខ្ញុំគ្រប់រូប។

ឧបសម្ព័ន្ធទី៧

សច្ចាប្រណិធាន
ទូលព្រះបង្គំ
យើងខ្ញុំ
ប្រធាន អនុប្រធាន និងសមាជិកព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា

សូមធ្វើសច្ចាប្រណិធាន
នៅចំពោះប្រកប័ក្ត្រនៃសម្តេចព្រះសង្ឃរាជ
និងទេវតារក្សាស្វេតច្ឆត្រ
ដូចតទៅ:

ក្នុងពេលប្រតិបត្តិការតាមមុខតំណែងខ្លួន និងក្នុងការបំពេញបេសកម្មដែលប្រជារាស្ត្រខ្មែរបានប្រគល់ជូនចំពោះទូលព្រះបង្គំយើងខ្ញុំគ្រប់ៗរូបទូលព្រះបង្គំយើងខ្ញុំសុំប្តេជ្ញាគោរពរដ្ឋធម្មនុញ្ញ បម្រើជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគតនូវផលប្រយោជន៍របស់ប្រជារាស្ត្រប្រជាជាតិ និងមាតុភូមិកម្ពុជា។ ទូលព្រះបង្គំយើងខ្ញុំសូមសច្ចាថាមិនកេងប្រវ័ញ្ចនូវផលប្រយោជន៍របស់ប្រជារាស្ត្រសម្រាប់ផ្ទាល់ខ្លួន ឬសម្រាប់គ្រួសារ ឬសម្រាប់បក្សពួក ឬសម្រាប់ភាគីរៀងៗខ្លួនឡើយ។

ទូលព្រះបង្គំយើងខ្ញុំសូមប្តេជ្ញាប្តូរផ្តាច់ហ៊ានបូជាជីវិតដើម្បីការពារជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគតនូវ៖

- ឯករាជ្យភាពទាំងស្រុងនៃមាតុភូមិកម្ពុជា
- អធិបតេយ្យភាពជាតិពេញបរិបូរណ៌
- បូរណភាពទឹកដីដ៏ត្រឹមត្រូវតាមច្បាប់នៅក្នុងព្រំដែនដីគោក និងព្រំដែនសមុទ្រដែលកម្ពុជាធ្លាប់មានក្នុងជំនាន់ឆ្នាំ១៩៦៣ដល់ឆ្នាំ១៩៦៩។
- ឯកភាពជាតិហើយមិនអនុញ្ញាតឲ្យមានការបែងចែក ឬការធ្វើអបគមន៍ណាមួយឡើយ។
- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញារក្សាទុកជានិច្ចទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគតនូវអព្យាក្រឹត្យភាព និងភាពមិនចូលបក្សសម្ព័ន្ធសម្រាប់កម្ពុជា ហើយមិនអនុញ្ញាតជាដាច់ខាត ឲ្យជនណាក៏ដោយ ដែលចង់ជ្រៀតជ្រែកចូលក្នុងផ្ទៃក្នុងនៃកម្ពុជា ឬមកបង្គាប់បញ្ជាចំពោះគោលនយោបាយជាតិ និងអន្តរជាតិរបស់កម្ពុជាឡើយ។ ទូលព្រះបង្គំយើងខ្ញុំ មិនបម្រើដាច់ខាតនូវផលប្រយោជន៍បរទេស ហើយធ្វើឲ្យខូតខាតដល់ផលប្រយោជន៍ប្រជារាស្ត្រប្រជាជាតិ និងមាតុភូមិកម្ពុជាឡើយ។
-ក្នុងការដោះស្រាយបញ្ហាទាំងឡាយលើផ្ទៃរាបជាតិ និងអន្តរជាតិ ទូលព្រះបង្គំយើងខ្ញុំ

បំបាត់ចោលទាំងស្រុងនូវអំពើហឹង្សាគ្រប់បែបយ៉ាង។ ប៉ុន្តែព្រះរាជាណាចក្រកម្ពុជាសូមរក្សាទុកនូវសិទ្ធិកាន់អាវុធតស៊ូប្រឆាំង និងការរំលោភឈ្លានពានមកពីក្រៅដើម្បីការពារជាតិមាតុភូមិខ្លួន។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាគោរពជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវលទ្ធិប្រជាធិបតេយ្យសេរីនិយមដែលមានរបបសភា និងពហុបក្ស ព្រមទាំងមានការគោរពយ៉ាម៉ឺងម៉ាត់ចំពោះសិទ្ធិមនុស្ស ដូចមានចែងក្នុងសេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាតស៊ូប្រឆាំងអំពើពុករលួយគ្រប់បែបយ៉ាង ប្រឆាំងអយុត្តិធម៌សង្គមហើយតស៊ូដើម្បីផ្សះផ្សាជាតិ ដើម្បីឯកភាពជាតិដើម្បីសន្តិភាពសង្គម និងសន្តិភាពជាតិ ដើម្បីភាពសម្បូរសប្បាយនៃប្រជារាស្ត្រកម្ពុជា និងដើម្បីភាពរុងរឿងប្តើនថ្កានៃមាតុភូមិកម្ពុជាជាទីគោរពសក្ការៈ និងជាទីស្នេហានៃទូលព្រះបង្គំយើងខ្ញុំគ្រប់រូប។

គណៈកម្មការរៀបរៀងរដ្ឋធម្មនុញ្ញ

បានអនុម័តដោយសភាធម្មនុញ្ញនាសម័យប្រជុំពេញអង្គលើកទី១

ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៣

១.ឯកឧត្តមសម្តេចប្រធានសភាធម្មនុញ្ញ ឬឯកឧត្តមអនុប្រធាន
សភាធម្មនុញ្ញ "ករណីសម្តេចប្រធានអវត្តមាន" ជាប្រធាន *

២- ឯកឧត្តម ចែម សួន	ជាអនុប្រធាន
៣- ឯកឧត្តមបណ្ឌិត តាវ សេងហួរ	ជាអ្នករាយការណ៍
៤- ឯកឧត្តម កាន់ ម៉ន	ជាសមាជិក
៥- ឯកឧត្តម គាត ឈន់	ជាសមាជិក
៦- ឯកឧត្តម ឈួរ លាងហួត	ជាសមាជិក
៧- ឯកឧត្តម ថោ ប៉េងលាត	ជាសមាជិក
៨- ឯកឧត្តម សម រង្ស៊ី	ជាសមាជិក
៩-អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរីរ័ត្ន	ជាសមាជិក
១០- ឯកឧត្តម សឺន ស៊ូប៊ែរ្ត៏	ជាសមាជិក
១១- ឯកឧត្តម សោម ចាន់បុត្រ	ជាសមាជិក
១២- ឯកឧត្តម អ៊ុន នឹង	ជាសមាជិក
១៣- ឯកឧត្តម ឡួយ ស៊ឹមឈាង	ជាសមាជិក
១៤- ឯកឧត្តម ជាម យៀប	ជាសមាជិកបំរុង
១៥- ឯកឧត្តម ប៉ុល ហំម	ជាសមាជិកបំរុង
១៦- ឯកឧត្តម ពូរ សុធីរៈ	ជាសមាជិកបំរុង
១៧- ឯកឧត្តម សរ សំអាត	ជាសមាជិកបំរុង
១៨- ឯកឧត្តម អ៊ឹង គៀត	ជាសមាជិកបំរុង
១៩- ឯកឧត្តម អ៊ុក រ៉ាប៊ុន	ជាសមាជិកបំរុង
២០- ឯកឧត្តម អ៊ុង សំផន	ជាសមាជិកបំរុង
២១- ឯកឧត្តម ឯក សំអុល	ជាសមាជិកបំរុង
២២- ឯកឧត្តម សាយ បូរី	ជាអ្នកជំនាញការ
២៣- ចាន់ សុក	ជាអ្នកជំនាញការ
២៤- ឯកឧត្តម ឈន អៀម	ជាអ្នកជំនាញការ

២៥- ឯកឧត្តម ហេង រង្សីប៊ុនធាត ជាអ្នកជំនាញការ
២៦- ឯកឧត្តម ខៀវ រ៉ាដា ជាអ្នកជំនាញការ

<u>កំណត់សំគាល់:</u> យោងជំពូក៧ ប្រការ១៨ ស្តីពីគណៈកម្មការ និងប្រធានគណៈកម្មការសភាធម្មនុញ្ញ

"នយោបាយ គឺជាសិល្បៈនៃកិច្ចការដែលអាចសម្រេចបាន"

(Politics is the art of the possible.)

ច្បាប់ធម្មនុញ្ញបន្ថែម

សំដៅ

ធានានូវដំណើរការដាប្រក្រតីនៃស្ថាប័នជាតិ

មាត្រា១

ច្បាប់ធម្មនុញ្ញនេះមានគោលដៅធានាក្នុងគ្រប់កាល:ទេស:នូវដំណើរការល្អប្រសើនៃស្ថាប័នជាតិ ដោយគោរពទៅតាមគោលការណ៍ជាមូលដ្ឋាននៃលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្សសមស្របតាមតម្រូវការនៃភាពចាំបាច់។

មាត្រា២

នៅដើមនីតិកាលថ្មីនីមួយៗរដ្ឋសភាក្រោមអធិបតីភាពព្រឹទ្ធសមាជិករដ្ឋសភាមុននឹងផ្តើមការងារបស់ខ្លួន និងក្រោយពេលសម្រេចអំពីសុពលភាពនៃអាណត្តិរបស់សមាជិកម្នាក់ៗ អាចចាប់ផ្តើមអនុម័តអត្ថបទ ដែលមានចារិកជារដ្ឋធម្មនុញ្ញ ឬច្បាប់ដើមអនុវត្តន៍បាននូវគោលដៅ មានចែងក្នុងមាត្រា១។

អត្ថបទទាំងនេះ ក្រោយពីបានត្រូវទទួលការបោះឆ្នោតអនុម័តដោយរដ្ឋសភារួចហើយ ត្រូវតែបានទទួល ជាបន្ទាន់នូវចំណាត់ការ ដោយរួសរាន់ពីសំណាក់ព្រឹទ្ធសមាជិករដ្ឋសភា តាមនីតិវិធីកំណត់សម្រាប់អត្ថបទទាំងនោះ រហូតដល់ពេលដែលត្រូវបានប្រកាសឲ្យចូលជាធរមាន។

មាត្រា៣

ក្នុងករណីដែលឃើញថា នីតិវិធីនៃមាត្រា៨២ និង១១៩ថ្មីនៃរដ្ឋធម្មនុញ្ញ មិនអាចសម្រេចបាន រដ្ឋសភា តាមសំណើរបស់គណបក្ស ដែលមានអាសន:ច្រើនជាងគេ នៅក្នុងរដ្ឋសភា អាចដំណើរការការបោះឆ្នោតជាកញ្ចប់ ដើម្បីជ្រើសតាំងប្រធាន អនុប្រធានរដ្ឋសភា ក៏ដូចជាប្រធាន និងអនុប្រធានគណៈកម្មការក្នុងពេលជាមួយគ្នា និងការផ្តល់សេចក្តីទុកចិត្តចំពោះរាជរដ្ឋាភិបាល។

មាត្រា៤

ការរៀបចំបញ្ជីរាយនាមបេក្ខជន ដើម្បីបោះឆ្នោតជ្រើសតាំង និងផ្តល់សេចក្តីទុកចិត្តត្រូវអនុវត្តន៍ដូចតទៅ ៖

-បញ្ជីរាយនាមបេក្ខជន ប្រធាន និងអនុប្រធាននៃរដ្ឋសភាក៏ដូចជាប្រធាន និងអនុប្រធានគណៈកម្មការជំនាញទាំងអស់នៃរដ្ឋសភា ត្រូវរៀបចំ និងស្នើដោយគណបក្សនយោបាយ ដែលព្រមព្រៀងគ្នា ដើម្បីបង្កើតរាជរដ្ឋាភិបាលចម្រុះហើយត្រូវផ្ញើជូនព្រឹទ្ធសមាជិករដ្ឋសភា។

-តាមសេចក្តីស្នើ ពីគណបក្សនយោបាយ ដែលមានចំនួនអាសន:ច្រើន ជាងគេនៅក្នុងរដ្ឋសភា តាមរយៈព្រឹទ្ធសមាជិករដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូប ក្នុងចំណោម

តំណាងរាស្ត្រនៃគណបក្សនយោបាយដែលឈ្នះឆ្នោតឲ្យបង្កើតរាជរដ្ឋាភិបាល។

រដ្ឋមន្ត្រីជន ដែលត្រូវបានចាត់តាំងនេះត្រូវរៀបចំផ្លូវផ្តួងតំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាល រួចផ្ញើបញ្ជីរាយនាមសមាជិកទាំអស់នៃរាជរដ្ឋាភិបាលជូនព្រឹទ្ធសមាជិករដ្ឋសភា។

-ព្រឹទ្ធសមាជិករដ្ឋសភាត្រូវរៀបចំបញ្ជីរាយនាមជាកញ្ចប់មួយនូវបេក្ខជន ប្រធាន និងអនុប្រធាននៃរដ្ឋសភា ក៏ដូចជាប្រធាន និងអនុប្រធានគណៈកម្មការជំនាញទាំងអស់នៃរដ្ឋសភា ព្រមទាំងបេក្ខជន នាយករដ្ឋមន្ត្រី និងសមាជិកទាំងអស់នៃរាជរដ្ឋាភិបាល ដើម្បីដាក់ជូនរដ្ឋសភាបោះឆ្នោត។

មាត្រា៥

នៅក្នុងដំណើរការនៃការបោះឆ្នោតជាកញ្ចប់មិនអាចដកដៃកពិភាក្សាអ្វីឡើយហើយក៏មិនអាចមានការពន្យល់អំពីការបោះឆ្នោតក្រោយការប្រកាសលទ្ធផលនៃការបោះឆ្នោតជាកញ្ចប់នេះដែរ។

សមាជិករដ្ឋសភា ត្រូវធ្វើការបោះឆ្នោតដោយកញ្ចប់ថា ព្រម ឬមិនព្រមចំពោះបញ្ជីរាយនាមជាកញ្ចប់មួយ ដែលព្រឹទ្ធសមាជិករដ្ឋសភាបានដាក់ជូន។ ការបោះឆ្នោតនេះ ត្រូវធ្វើឡើងដោយវិធីលើកដៃ។

មាត្រា៦ ថ្មី

ការបោះឆ្នោត ជាកញ្ចប់ខាងលើនេះ ត្រូវយកមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល។

ក្នុងករណីការបោះឆ្នោតជុំទី១មិនបានសម្រេចនីតិវិធីដដែលនេះនឹងត្រូវអនុវត្តន៍ចំពោះការបោះឆ្នោតជុំក្រោយៗទៀត។

មាត្រា៧

ច្បាប់ធម្មនុញ្ញបន្ថែមនេះត្រូវបានប្រកាសជាការប្រញាប់និងយកមកអនុវត្តន៍ចាប់តាំងពីដើមនីតិកាលបច្ចុប្បន្ននេះទៅ។

រាជធានីភ្នំពេញ.ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤
ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គ
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ជករ
ញឹក ប៊ុនឆៃ

ពរល.០៤.០៧.១១៧
បានឃើញសេចក្តីក្រាបបង្គំទូលថ្វាយ
សូមទ្បាយព្រះហស្តលេខាព្រះមហាក្សត្រ
ព្រឹទ្ធសមាជិក និងជាប្រធានអង្គប្រជុំរដ្ឋសភា
ហត្ថលេខាជា សុទ្ធ

ឯកសារយោង

-រដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧
-រដ្ឋធម្មនុញ្ញឆ្នាំ១៩៧២
-រដ្ឋធម្មនុញ្ញឆ្នាំ១៩៧៦
-រដ្ឋធម្មនុញ្ញឆ្នាំ១៩៨១
-រដ្ឋធម្មនុញ្ញឆ្នាំ១៩៨៩
-រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣
-ក្រមព្រហ្មទណ្ឌសង្គមចាស់ឆ្នាំ១៩៤៧
-ច្បាប់ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី
-ច្បាប់ស្តីពីសមត្ថកិច្ច និងនីតិវិធីនៃការធ្វើច្បាប់ និងបទបញ្ញា
-ច្បាប់បោះឆ្នោតជ្រើសរើសសមាជិករដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា
-ច្បាប់ស្តីពីការរៀបចំរដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា
-ច្បាប់ស្តីពីការរៀបចំរដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា
-ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សារាជសម្បត្តិ
-ច្បាប់រៀបចំ និងការប្រព្រឹត្តិទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
-ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
-ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃអាវុធហត្ថ
-ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ
-ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិករដ្ឋសភា
-ច្បាប់ស្តីពីលក្ខន្តិក:តំណាងរាស្ត្រ
-ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកតំណាងរាស្ត្រ
-ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកព្រឹទ្ធសភា
-ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
-ច្បាប់ស្តីពីលក្ខន្តិក:មន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ

-សន្ធិសញ្ញាមិត្តភាពខ្មែរបារាំងស្តីពី"ការការពារ និងពាណិជ្ជកម្ម"១១សីហា១៨៦៣
-បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សារដ្ឋនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា
-បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សារដ្ឋនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា
-បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា
-បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
-បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា
-បទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
-បទបញ្ជាផ្ទៃក្នុងស្តីពីនីតិវិធី ដែលត្រូវអនុវត្តទៅមុខក្រុមប្រឹក្សាធម្មនុញ្ញ
-ព្រះរាជក្រមលេខ ០២/នស/៩៥ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៥
-អនុក្រឹត្យចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ១៩៩៨ស្តីពីក្រុមប្រឹក្សាធម្មនុញ្ញ
-អនុក្រឹត្យស្តីពីការបង្កើតអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ
-Durkheim,Emile {1895} "the Rules of sociological Method" 8th edition.
-Paul Foulquié, Vocabulaire des sciences sociales, PUF, 1ère édition, 1978.
-Dictionnaire Le Robert d'aujourd'hui, ADAGP, Paris, 1997.
-Lexique des sciences sociales, dalloz, 6è édition, 1994.
-Dictionnaire Le Petit Robert, nouvelle édition, 1993.
-Dictionnaire Le Petit Larousse, GRAND FORMAT, 1992.
-Durkheim theory in Sociologist.
-ខៀវ ថវិកា ស្ថាប័នអន្តរជាតិបោះពុម្ពឆ្នាំ១៩៩៧
-មេរៀនប្រវត្តិស្ថាប័នខ្មែររបស់សាស្ត្រាចារ្យ គឹម ណារិន
-មេរៀនប្រវត្តិស្ថាប័នខ្មែររបស់សាស្ត្រាចារ្យ ពៅ សារឿន
-មេរៀនប្រវត្តិស្ថាប័នខ្មែររបស់សាស្ត្រាចារ្យ គង់ ភីរុណ
-African history by Alistair Boddy-Evans,Definition "**Political institutions**"
-ត្រឹងងា ប្រវត្តិសាស្ត្រខ្មែរបោះពុម្ពឡើងវិញ ដោយក្រសួងអប់រំឆ្នាំ២០០៣
-Chandler David. A History of Cambodia, 2005.

-ពុយ គា រដ្ឋាភិបាលកម្ពុជាពីឆ្នាំ១៩៤៥ ដល់ឆ្នាំ២០១០បោះពុម្ពលើកទី២ឆ្នាំ២០១០

-ស្ងួរ អឿ ប្រវត្តិសាស្ត្រព្រះរាជាណាចក្រកម្ពុជាបោះពុម្ពឆ្នាំ១៩៩៥

-តាមឯកសារប្រវត្តិវិទ្យា បោះពុម្ពផ្សាយដោយក្រសួងអប់រំឆ្នាំ១៩៩៤

-តាមឯកសាររបស់ លោកជីវ តាក្វាន់ នៅសតវត្សទី១៣

-តាមឯកសារប្រវត្តិវិទ្យា បោះពុម្ពផ្សាយដោយក្រសួងអប់រំឆ្នាំ១៩៩៤

-សេចក្តីសម្រេចរបស់ក្រុមប្រឹក្សារាជសម្បត្តិលេខ ករស/សសរ/១០០៤/០០១ ចុះថ្ងៃទី១៤ តុលា ២០០៤

-សុន្ទរកថាថ្លែងដោយ ឯកឧត្តម ងួន ញ៉ិល នៅថ្ងៃទី២៣-២៤ ខែឧសភា ឆ្នាំ២០០០ នៅវិមានរដ្ឋាភិបាលវត្តភ្នំ។

-ទស្សនាវដ្តី ស្វែងរកការពិត លេខ១៦ ចេញផ្សាយខែមេសា ឆ្នាំ២០០១